

ISBN: 978-9924-631-18-7

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
ទស្សនាវដ្ដីស្រាវជ្រាវ RESEARCH JOURNAL VOLUME 9
ASIA EURO UNIVERSITY

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

ASIA EURO UNIVERSITY

សៀវភៅ

# ទស្សនាវដ្ដីស្រាវជ្រាវ

# RESEARCH JOURNAL

www.aeu.edu.kh

VOLUME 9
September 2024

# អារម្ភកថា

ការកសាងសមត្ថភាព និង អភិវឌ្ឍធនធានមនុស្ស គឺជាទិសដៅមួយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការប្ដេជ្ញាចិត្តខ្ពស់ សំដៅសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា និងការអភិវឌ្ឍប្រកបដោយសមធម៌ ដោយផ្អែកលើមូលដ្ឋាននៃចរិតលក្ខណៈប្រជាជន។ ប្រជាជាតិកម្ពុជា ធ្លាប់មានប្រពៃណីជាជនជាតិមួយដែលស្វែងរកចំណេះដឹងពុំមានការនឿយហត់។ ចក្ខុវិស័យ និង ផែនការយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍវិស័យឧត្តមសិក្សានាឆ្នាំ២០២០ ព្រមទាំងទស្សនាវដ្ដីស្រាវជ្រាវ ដែលអ្នកអានកំពុងកាន់ក្នុងដៃនេះ គឺជាចំណែកមួយដែលធ្វើឱ្យការពិតបានកើតជារូបរាងជាក់ស្ដែងឡើង តាមរយៈការប្រមូលផ្ដុំនូវចំណេះដឹង ភាពឈ្លាសវៃដែលប្រកបដោយគតិបណ្ឌិត និងសីលធម៌វិជ្ជាជីវៈរបស់បញ្ញវន្តខ្មែរ សំដៅលើកស្ទួយការស្រាវជ្រាវនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការឈានចូលទៅក្នុងសហគមន៍អ្នកស្រាវជ្រាវក្នុងតំបន់ និង សកលលោក។

ទស្សនាវដ្ដីស្រាវជ្រាវនេះ មានបេសកកម្មជំរុញ និងបង្កើតឡើងនូវស្នាដៃស្រាវជ្រាវថ្មីៗ ក៏ដូចជាទេពកោសល្យនៃអ្នកស្រាវជ្រាវខ្មែរនានា ដែលបានខិតខំពុះពារគ្រប់ការលំបាកនិងឧបសគ្គ តាមរយៈការប្រើប្រាស់នូវប្រាជ្ញាស្មារតីរបស់ខ្លួន ដើម្បីស្វែងរកចំណេះដឹងថ្មីៗ រួមចំណែកដោះស្រាយបញ្ហានានាក្នុងក្របខ័ណ្ឌវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃសង្គមខ្មែរ ក្នុងសម័យសកលភាវូបនីយកម្មនាពេលបច្ចុប្បន្ននេះ។

ទស្សនាវដ្ដីស្រាវជ្រាវនេះផងដែរ ត្រូវបានបោះពុម្ពផ្សាយរយៈពេល៤ខែម្ដង តាមរយៈការប្រមូលផ្ដុំនូវស្នាដៃនានាដូចជា សេដ្ឋកិច្ច ពាណិជ្ជកម្ម ច្បាប់ នយោបាយ អក្សរសាស្ត្រ មនុស្សសាស្ត្រ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រអប់រំ វិទ្យាសាស្ត្រទូទៅ ដែលសុទ្ធសឹង ជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ហើយអត្ថបទទាំងនេះ អាចជាជំនួយស្មារតីអ្នកសិក្សាស្រាវជ្រាវទាំងឡាយ សម្រាប់វិភាគជាលក្ខណៈវិទ្យាសាស្ត្រថ្មីៗផ្សេងទៀត។ ទស្សនាវដ្ដីស្រាវជ្រាវ បានបោះពុម្ពស្នាដៃស្រាវជ្រាវរបស់បេក្ខជនបណ្ឌិតនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និងស្នាដៃថ្មីៗរបស់អ្នកស្រាវជ្រាវដទៃទៀត ដែលទើបស្រាវជ្រាវរកឃើញ ដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់និស្សិត និងអ្នកស្រាវជ្រាវ

ទូទៅស្វែងយល់ និងជួយជំរុញដល់អ្នកស្រាវជ្រាវទាំងឡាយឱ្យកាន់តែមានសុឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។ ទស្សនាវដ្តីស្រាវជ្រាវនេះ ក៏ជាចំណែកមួយសម្រាប់ឱ្យអ្នកស្រាវជ្រាវគ្រប់រូប មានឱកាសបង្ហាញនូវស្នាដៃស្រាវជ្រាវរបស់ខ្លួនផងដែរ។

ជាមួយគ្នានេះដែរ ទស្សនាវដ្តីស្រាវជ្រាវ សង្ឃឹមថា អត្ថបទទាំងឡាយដែលបានចុះផ្សាយក្នុងទស្សនាវដ្តីនេះ នឹងក្លាយជាឯកសារមួយដែលមានសារៈសំខាន់ និងជាខ្នាតមួយសម្រាប់កម្រិតនូវរាល់កិច្ចការស្រាវជ្រាវទាំងឡាយ ឱ្យកាន់តែមានភាពសុក្រឹតស្របតាមស្តង់ដារវិទ្យាសាស្ត្រ។

# មាតិកា

ទំព័រ

១- ផលវិបាកនៃស្ថានទម្ងន់ទោសក្នុងបទល្មើសឧក្រិដ្ឋនៅព្រះរាជាណាចក្រកម្ពុជា
បណ្ឌិត *អ៊ូ ស្រីម៉ាច* .............................................................................. ១

២- លក្ខណៈវិនិច្ឆ័យលើមុខងារផ្លូវច្បាប់នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត
បណ្ឌិត *សោ សុតា*............................................................................ ២៣

៣- បុព្វហេតុបង្កើតឱ្យមានជម្លោះ នៅប្រជុំកោះស្ប្រាតលីនៃតំបន់សមុទ្រចិនខាងត្បូង
បណ្ឌិត *តាំង សុខជី* .......................................................................... ៤៨

៤- ការចំណាយលើការថែទាំសុខភាពនៅកម្ពុជា
បណ្ឌិត *រស់ ឈុនអៀង*..........................................................................៧១

៥- ទស្សនាទាននៃការផ្តល់ឥណទានមីក្រូហិរញ្ញវត្ថុទៅលើជីវភាពប្រជាជន
បណ្ឌិត *ឌឹត សំណាង*.............................................................................៩៧

៦- ការពង្រឹងបទដ្ឋានគតិយុទ្ធស្ថាប័នរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
បណ្ឌិត *សាម រ៉ាត*........................................................................... ១១៦

៧- ការទទួលសេវាថែទាំជំងឺអេដស៍ពីស្ថាប័នសុខភាពសាធារណៈនៅកម្ពុជា (ករណីសិក្សាការម៉ាក់ងាយ នៃអ្នកផ្ទុកមេរោគអេដស៍)
បណ្ឌិត*ស៊ឹម សុផៃ* ........................................................................... ១៣៦

៨- ភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា
បណ្ឌិត *យ៉េន សិត្យា* ......................................................................... ១៧២

៩- សិទ្ធទទួលបានការអប់រំរបស់ខ្មែរក្រោមនៅកម្ពុជាក្រោម
បណ្ឌិត *ស៊ឺន ជុំជួន* .......................................................................... ១៩៩

១០-ប្រសិទ្ធនៃការគ្រប់គ្រងប្រតិបត្តិការរបស់កងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩
បេក្ខជនបណ្ឌិត *ឡាក់ គួន*.....................................................................២៣៥

១១-ការពង្រឹងគុណភាពអប់រំមធ្យមសិក្សាបឋមភូមិ (ករណីសិក្សានៅខេត្តកំពង់ឆ្នាំង)
បេក្ខជនបណ្ឌិត *លី សុខា*.......................................................................២៥៣

១២-ការទប់ស្កាត់បទល្មើសគ្រឿងញៀននៅកម្ពុជា
បេក្ខជនបណ្ឌិត *សោម សុជាតិ*..................................................................២៧១

# ផលវិបាកនៃស្ថានទម្ងន់ទោសក្នុងបទល្មើសឧក្រិដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា

*បណ្ឌិត **អ៊ូ ស្រីម៉ាច***

## មូលន័យសង្ខេប

ក្រោយពីបានស្វែងយល់លើស្ថានភាពទូទៅ នៃទោសព្រហ្មទណ្ឌរួចយើងសង្ឃឹមថាអ្នកអាន ក៏ដូចជាអ្នកស្វែងយល់អំពីទោសព្រហ្មទណ្ឌនឹងបានយល់ច្បាស់នូវអត្ថន័យនៃទោសព្រហ្មទណ្ឌ (ផ្នែកទី១)។ ក្រៅពីនេះទៀតអ្នកនឹងបានយល់អំពី ចរិកលក្ខណៈនៃទោសព្រហ្មទណ្ឌ (ផ្នែកទី២)។ មិនតែប៉ុណ្ណោះ អ្នករៀបរៀងនឹងព្យាយាមបកស្រាយអំពីមុខងារនៃទោសព្រហ្មទណ្ឌ ឬពេលខ្លះក៏អាចប្រើពាក្យថាជាគោលបំណង នៃទោសព្រហ្មទណ្ឌក៏បានដែរ (ផ្នែកទី៣)។ បន្ទាប់ពីយល់អំពីផ្នែកទី១,២,៣ រួចយើងនឹង អាចវិភាគបានអំពីផលវិបាកនៃទោសព្រហ្មទណ្ឌ (ផ្នែកទី៤) ជាក់ជាមិនខានឡើយ។ ដូច្នេះដើម្បីយល់បានច្បាស់អំពីស្ថានភាពទូទៅនៃទោសព្រហ្មទណ្ឌ សូមមើលសេចក្តីពន្យល់លម្អិតដូចតទៅៈ

## ១ សេចក្តីផ្តើម

### ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នីតិព្រហ្មទណ្ឌជាសាខាមួយនៃនីតិដែលសិក្សាពីការកំណត់បទល្មើស ការស្វែងរកជនល្មើស ការស្វែងរកពិរុទ្ធភាព ឬភាពស្លូតត្រង់របស់ជនល្មើស ការចោទប្រកាន់ ការជំនុំជម្រះ ការប្រកាសទោស និងការអនុវត្តទោសជាដើម។ និយាយក្នុងន័យចង្អៀត នីតិព្រហ្មទណ្ឌជាសារវន្តនៃវិធានគតិយុត្តដែលកំណត់ពីទណ្ឌកម្ម។ តែបើនិយាយក្នុងន័យទូលាយនីតិព្រហ្មទណ្ឌបានដល់បណ្តុំនៃបទដ្ឋានគតិយុត្តដែលចែងពីការបង្ក្រាបបទល្មើស ដោយរដ្ឋអំណាច។ សិទ្ធិផ្តាច់មុខរបស់រដ្ឋក្នុងការផ្តន្ទាទោស តំណាងឲ្យអំណាចអធិបតេយ្យ។

យោងតាមស្មារតីនេះ គេសន្និដ្ឋានថានីតិព្រហ្មទណ្ឌ ឬនិយាយឲ្យចំច្បាប់ព្រហ្មទណ្ឌជាសាខាមួយនៃនីតិដែលរឹតបន្តឹងសិទ្ធិសេរីភាពពលរដ្ឋ ឬសេរីភាពបុគ្គល រហូតពេលខ្លះឈានទៅដល់ការដកហូតសិទ្ធិសេរីភាពមួយចំនួន (ទោសដាក់ពន្ធនាគារ) ទៀតផង ព្រោះ

នីតិព្រហ្មទណ្ឌស្តែងឡើងជាព្រំដែននៃសិទ្ធិ។ នីតិព្រហ្មទណ្ឌមានចរិតបង្ក្រាប ហើយការដាក់ទោសនេះបង្ហាញពីប្រតិកម្មរបស់សង្គមចំពោះអំពើឈ្លានពានមិន សមហេតុផល និងគ្មានវិចារណញ្ញាណ។ ដូចនេះ នីតិព្រហ្មទណ្ឌបង្កើតបទល្មើស និងដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយាទាំងឡាយណាដែលបង្កចលាចលដល់ការរស់នៅជាសង្គម និងប៉ះពាល់ដល់តំលៃសង្គមដែលត្រូវបានការពារ។ តាមន័យនេះសង្គមបង្កើតបទល្មើសឡើង ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខ ផ្តន្ទាទោសជនល្មើស និង ធ្វើការហាមឃាត់ជនដទៃដែលបំរុងនឹងបង្ករការអុកឡុកសង្គមឲ្យបញ្ឈប់ការសម្រេចចិត្តប្រព្រឹត្តបទល្មើសរបស់ខ្លួនជាបន្ទាន់ដោយខ្លាចអោរនឹងទណ្ឌកម្មដែលរដ្ឋបង្កើតឡើង (វិធីគំរាម និងធ្វើឲ្យខ្លាចអោរ)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅលើមុខវិជ្ជាផ្នែក នីតិព្រហ្មទណ្ឌវិទ្យា ដែលជាមុខវិជ្ជាមួយមានសារៈសំខាន់និងចាំបាច់បំផុតដែលមានការទាក់ទងនិងសង្គមមនុស្សជាតិកំពង់រស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជារស់នៅលើពិភពលោកយើងនេះដែលមិននិយាយថាពូជសាសន៍អ្វីនោះទេយើងម្នាក់ៗគ្រប់រូបតែងតែស្វែងយល់ និងត្រូវតែចេះដឹងគ្រប់ៗគ្នា ពីព្រោះថារាល់សកម្មភាពនិងជីវភាពរស់នៅក្នុងសង្គមមនុស្សយើងម្នាក់ៗ តែងតែធ្វើការទំនាក់ទំនងរវាងគ្នានិងគ្នាគ្រប់ពេលវេលាមិនថាយប់ ឬថ្ងៃនោះទេ ការទំនាក់ទំនងជាប្រចាំនេះគឺតែងតែមានការប៉ះទង្គិចទៅលើអារម្មណ៍តាមពាក្យសំដីប្រការល្អ និង ប្រការអាក្រក់បានញុំាងអោយមនុស្សយើងម្នាក់ៗ សប្បាយចិត្ត ឬមិនសប្បាយចិត្តជាពុំខានឡើយ។ បើប្រការល្អនោះមានសេចក្តីសុខជាមួយគ្នាតែ បើប្រការអាក្រក់វិញនោះ គឺវានឹងក្លាយទៅជាទំនាស់រំលោភបំពានទៅវិញទៅមកគ្មានឈប់ឈរ នឹងបង្កើតបានជាបទល្មើសផ្សេងៗ ដែលជាហេតុនាំអោយមានការប៉ះពាល់ដល់សិទ្ធិសេរីភាព តាមផ្លូវកាយវាចារចិត្តទ្រព្យសម្បត្តិ សារធារណៈទ្រព្យសម្បត្តិអ្នកដ៏ទៃ ជាពិសេសគឺប៉ះពាល់ដល់អាយុជីវិតរបស់មនុស្សជាតិត្រូវបានការពារដោយច្បាប់ជាតិនិងច្បាប់អន្តរជាតិ ពីព្រោះថាមនុស្សគ្រប់រូបត្រូវបានសង្គមចាត់ទុកជាធនធានមានតម្លៃនិងជាធាតុចម្បងបំផុតរបស់វប្បធម៌នៃជាតិនីមួយៗ។ ហើយខាងក្រោមនេះយើងនឹងធ្វើការសិក្សាស្រាវជ្រាវថា៖

១. អ្វីទៅជាស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ?
២. តើផលវិបាកនៃស្ថានទម្ងន់ទោសមានអ្វីខ្លះ?
៣. តើមានដំណោះស្រាយអ្វី ដើម្បីកាត់បន្ថយស្ថានភាពនៃអំពើទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងស្ថានទម្ងន់ទោស?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់នៃការស្រាវជ្រាវនេះចង់បង្ហាញអោយឃើញនូវះ

១. រកអោយឃើញសារជាតុនៃខ្លឹមសារស្ថានទម្ងន់ទោស
២. រចនាសម្ព័ន្ធ នៃជាតុផ្សំទាំង៣ដែលនាំអោយមានបទល្មើសកើតឡើង
៣. ទម្រង់នៃស្ថានការ ហេតុអ្វីបានជាមានទម្រង់បែបនេះ ដោយវាមានបទល្មើស
៤. គោលការណ៍ ដាក់ទោសលើជនល្មើសអោយមានភាពរាងចាលនឹងអំពើល្មើសរបស់ខ្លួន ។

## ១.៤ វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការសិក្សាក្នុងនិក្ខេបបទ ស្ថានទម្ងន់ទោសនៅព្រះរាជាណាចក្រកម្ពុជាយើង។

យើងបានជ្រើសរើសយក សាលាដំបូង និងក្រុមមេធាវី A-Z និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

ក្នុងការស្វែងរកការពិត នៅក្នុងដំណើរការស្ថានទម្ងន់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះ យើងត្រូវធ្វើការសង្កេត ស្រាវជ្រាវម៉ត់ចត់ ព្រមជាមួយគ្នានេះ ការសិក្សាស្រាវជ្រាវនេះ និងធ្វើការវិភាគ ស្វែងយល់នូវទស្សនៈ តាមឯកសារដែលមានច្បាស់លាស់ និងធ្វើការប្រៀបធៀបទៅនិងសកម្មភាពជាក់ស្តែង។

- វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យ ដែលត្រូវការចាំបាច់ឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សា និងត្រូវប្រមូលបានដោយប្រើប្រាស់វិធីប្រមូលទិន្នន័យដែលមានស្រាប់ និងវិធីសាស្ត្រប្រមូលទិន្នន័យបឋម តាមរយៈសាលាដំបូងរាជធានី-ខេត្ត និងក្រុមមេធាវី A-Z ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

- ទិន្នន័យដែលមានស្រាប់

ទិន្នន័យបែបនេះនិងត្រូវបានសិក្សាស្រាវជ្រាវ និងប្រមូលពីៈ

- បណ្ណាល័យពាក់ព័ន្ធទាំងអស់ក្នុងប្រទេស
- សាលាដំបូងរាជធានី-ខេត្ត
- ក្រុមមេធាវី A-Z
- ពន្ធនាគារ
- តាមប្រព័ន្ធអ៊ិនធឺណេត
- ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត..ល..។

- ទិន្នន័យបឋម

ទិន្នន័យនេះ ត្រូវបានប្រមូលពីសាលាដំបូងរាជធានីភ្នំពេញ ក្រុមមេធាវី A-Z ក៏ដូចជាទិន្នន័យដែលទទួលបានពីស្ថាប័នពាក់ព័ន្ធមួយចំនួន។

- វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យ ដែលប្រមូលបានតាមរយៈធ្វើការវិភាគ ស្វែងយល់នូវទស្សនៈ តាមឯកសារដែលមានច្បាស់លាស់ និងធ្វើការប្រៀបធៀបទៅនិងសកម្មភាពជាក់ស្តែង។ ការវិភាគទិន្នន័យ គឺផ្តោតទៅលើស្ថានទម្ងន់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបង្ករលក្ខណៈអសកម្មកើតឡើងក្នុងសង្គម ត្រូវបានច្បាប់ហាមឃាត។

# ២ រំលឹកទ្រឹស្តី

## ២.១ អត្ថន័យនៃទោសព្រហ្មទណ្ឌ

- **អត្ថន័យតាមបែបទស្សនៈវិជ្ជា ឬសង្គមវិជ្ជា**

ទោសព្រហ្មទណ្ឌ គឺជាប្រតិកម្មរបស់សង្គមឬក៏ជាការឆ្លើយតបរបស់សង្គមទៅនឹងអ្នកប្រព្រឹត្តបទល្មើសបានន័យថាប្រឆាំងជាមួយនឹងចារីនៃបទល្មើស។

បទល្មើស គឺ ជាអំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឲ្យមានគ្រោះថ្នាក់ដល់សង្គមអំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជរមាន និងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

ជាធម្មតាយើងដឹងហើយថា គ្រប់សង្គមទាំងអស់តែងតែមានធ្វើការកំណត់នូវច្បាប់ដើម្បីធ្វើការគ្រប់គ្រងសង្គម ហើយក៏ដើម្បីធានានូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈរបស់

សង្គម កំណត់នូវវិធានការកំណត់នូវសកម្មភាពមួយចំនួនដែលច្បាប់ហាមឃាត់ ហើយការប្រព្រឹត្តផ្ទុយទៅនឹងអំពើហាមឃាត់របស់សង្គមពេលនោះសង្គម នឹងមានវិធានការយ៉ាងតឹងរឹងតបត្រឡប់ទៅវិញដែលក្នុងក្រមនេះការហាមឃាត់ដោយច្បាប់ព្រហ្មទណ្ឌ គឺជាបទល្មើសព្រហ្មទណ្ឌ ហើយការប្រព្រឹត្តផ្ទុយទៅនឹងការហាមឃាត់ដែលជាបទល្មើសព្រហ្មទណ្ឌគឺត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌ ឬ ទោសព្រហ្មទណ្ឌ ។ នេះគឺជាការពិចារណាទៅតាមបែបទស្សនៈវិជ្ជាឬសង្គមវិជ្ជា ។ តែបើយោងតាមអត្ថន័យម្យ៉ាង ទៀតគឺ

- **អត្ថន័យតាមបែបគតិយុត្ត ឬតាមបែបនីតិសាស្ត្រ**

ទោសព្រហ្មទណ្ឌ គឺជាទោសដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ហើយដែលត្រូវប្រកាសដោយតុលាការ ព្រហ្មទណ្ឌ។

យោងលើន័យតាមបែបច្បាប់នេះ គឺយើងពឹងផ្អែកជាពិសេសទៅលើក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រ កម្ពុជាយើង ត្រង់មាត្រា ១ មាត្រា ៣ ត្រង់កថាខណ្ឌទី ២ និងមាត្រា ៦[១]។

ចំណាំ៖ គតិយុត្តគឺតាមគន្លងច្បាប់ ឬ ដែលទាក់ទងនឹងច្បាប់ដែលត្រឹមត្រូវតាមច្បាប់ ។ ចំណែកឯពាក្យ នីតិសាស្ត្រគឺគម្ពីរប្រាប់វិទ្យាច្បាប់ (យោងតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជួនណាត)។ ម្យ៉ាងទៀត នីតិសាស្ត្រគឺជា វិទ្យាសាស្ត្រដែលសិក្សាអំពីនីតិដែលនីតិគឺច្បាប់ ជាលិខិតបទដ្ឋានរបស់រដ្ឋ ៖ បណ្តុំនៃលិខិតបទដ្ឋានរបស់សង្គម។ ច្បាប់និងបទបញ្ញាទាំងអស់ដែលអង្គការមានសមត្ថកិច្ចបានកំណត់ឡើងដើម្បីគ្រប់គ្រងជីវភាពក្នុងសង្គម ។

## ២.២ ចរិកលក្ខណៈនៃទោសព្រហ្មទណ្ឌ

ស្តែងចេញមកអំពីលក្ខណៈដ៏សំខាន់ និងមានភាពច្បាស់លាស់នៃទោសព្រហ្មទណ្ឌដូចមាននៅក្នុងអត្ថន័យតាមបែបគតិយុត្ត ឬ តាមន័យច្បាប់ខាងលើគឺធ្វើឲ្យទោសព្រហ្មទណ្ឌមានលក្ខណៈខុសពីទោសផ្សេងៗទៀត។ ដូច្នេះយើងអាចទាញចេញនូវចរិកលក្ខណៈនៃទោសព្រហ្មទណ្ឌចំនួន ២ (ពីរ) គឺ៖

---

[១] មាត្រា១,៣,៦ ក្រមព្រហ្មទណ្ឌ

**២.២.១ ត្រូវកំណត់ដោយច្បាប់ព្រហ្មទណ្ឌ**

ចំណុចមួយនេះ យើងអាចឃើញនៅក្នុងក្រមព្រហ្មទណ្ឌរបស់យើងត្រង់មាត្រា ១ បានកំណត់ថា ច្បាប់ព្រហ្មទណ្ឌ គឺមានគោលដៅកំណត់បទល្មើសចង្អុលបង្ហាញអំពីបុគ្គលដែលត្រូវទទួលរងទោស ឬអាចត្រូវប្រកាសថា ទទួលខុសត្រូវព្រហ្មទណ្ឌ ហើយមានគោលដៅកំណត់អំពីទោសព្រមទាំងបែបបទនៃការអនុវត្តទោសនោះ។ ចរិកលក្ខណៈទី ១ ដែលថាទោសព្រហ្មទណ្ឌត្រូវកំណត់ដោយច្បាប់ព្រហ្មទណ្ឌនេះ គឺឆ្លើយតបជាមួយនឹងគោលការណ៍ ទូទៅមួយឈ្មោះថា គោលការណ៍នីត្យានុកូលភាពនៃទោសព្រហ្មទណ្ឌដែលយើងឃើញកំណត់នៅក្នុងមាត្រា ៣ កថាខណ្ឌទី២ នៃក្រមនេះ។

មានទស្សនៈ២(ពីរ)គេហៅថាការកំណត់បទល្មើសនេះ ឬការធ្វើចំណាត់ថ្នាក់នូវបទល្មើសថាជាបទឧក្រិដ្ឋ បទមជ្ឈិមបទលហុនោះ មានទស្សនៈខ្លះគេបានផ្អែកទៅលើចរិកគ្រោះថ្នាក់នៃអំពើដែលបានកើតឡើងសម្រាប់សង្គម។ បើសិនជា ចរិកគ្រោះថ្នាក់នោះកើតឡើងដោយសារ មានការអន្តរាយធ្ងន់ធ្ងរគេចាត់ទុកថានោះជាប្រភេទបទល្មើសឧក្រិដ្ឋ។បើកម្រិតគ្រោះថ្នាក់នេះល្មមគួរសមគេចាត់ទុកថាជាប្រភេទបទល្មើសមជ្ឈិម។ បើចរិកគ្រោះថ្នាក់នោះស្រាលគេចាត់ទុកថាជាប្រភេទបទល្មើសលហុ។ ផ្អែកលើទស្សនៈដូចគ្នាដែរប៉ុន្តែយើងកំណត់ជាទោសវិញគេថាប្រសិនជាចរិកគ្រោះថ្នាក់នៃអំពើកើនខ្ពស់ កម្រិតទោសត្រូវធ្ងន់ធ្ងរឡើងៗ ពីព្រោះដើម្បីអោយមានតុល្យភាពរវាងអំពើជាមួយ នឹងការខូចខាតដល់សង្គម។ ដូច្នេះ បើយើងផ្អែកទៅលើមូលដ្ឋាននេះ យើងបានកំណត់ថា ៖

**ទីមួយ៖** ទោសទាំងឡាយណាដែលដាក់ពន្ធនាគារអស់មួយជីវិត។ ហើយសូមជម្រាបជូនថានៅក្នុងច្បាប់នេះ ទោសដាក់ពន្ធនាគារអស់មួយជីវិតនោះគឺមានតិចតួចណាស់ ប៉ុន្តែគឺ សុទ្ធតែជាប្រភេទបទល្មើសដែលមានគ្រោះថ្នាក់ធ្ងន់ធ្ងរមែនទែន។ ករណីបទល្មើសមនុស្សឃាត ឬមួយក៏ឃាតកម្មគិតទុកជាមុនបានន័យថា ធ្វើការសម្លាប់មនុស្សដោយមានការគ្រោងទុក ឬមួយមានការពួនស្ទាក់។ វានេះគឺជាប្រភេទបទឧក្រិដ្ឋមួយ ដែលបង្កអោយមានការស្លាប់ដល់អាយុជីវិតមនុស្សដែលជាប្រភេទនៃគ្រោះថ្នាក់ធ្ងន់ធ្ងរខ្លាំងណាស់ ហេតុនេះក្នុងក្រមនេះដែលសុទ្ធតែជាបទល្មើសពាក់ព័ន្ធនឹងការប្រល័យពូជសាសន៍ ការប្រឆាំងនឹង

មនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម។ដូចនេះ បើសិនជា នៅក្នុងច្បាប់ចែងថាទោសនោះគឺជាទោសដាក់ពន្ធនាគារ អស់មួយជីវិតនោះហើយគឺជាប្រភេទបទឧក្រិដ្ឋ។

**ទីពីរ៖** បទឧក្រិដ្ឋនេះគឺទោសដាក់ពន្ធនាគារមានរយះពេលលើសពី៥ឆ្នាំ និង ក្រោមឬស្មើនឹង៣០ឆ្នាំ។ នៅទីនេះបើនិយាយអោយចំមែនទែនច្បាប់យើងបានសំដៅទៅរកអតិបរមានៃទោសដាក់ពន្ធនគារដែលកំណត់ដោយច្បាប់ ប្រសិនបើបទល្មើសណាមួយកណត់អំពីអតិបរមានៃទោសដាក់គុកលើសពី៥ឆ្នាំ ហ្នឹងហើយគឺជាបទឧក្រិដ្ឋ។ ហើយសុំកុំអោយច្រឡំពីព្រោះមានពេលខ្លះច្បាប់ចែងថា អំពើណាមួយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៦ឆ្នាំ។ អញ្ចឹងសួរថាតើនេះគឺជាបទឧក្រិដ្ឋ ឬក៏ជាបទមជ្ឈិម? បើគិតពីគោលការណ៍ដែលមានចែងនៅក្នុងមាត្រា៤៦[២] នេះហើយគឺជាបទឧក្រិដ្ឋ។ដោយសាតែកម្រិតអតិបរមាននៃទោសនោះ មាន៦ឆ្នាំគឺ លើសពី៥ឆ្នាំ។ ដូច្នេះសម្រាប់បទឧក្រិដ្ឋគឺទណ្ឌកម្មត្រូវលើសពី៥ឆ្នាំរហូតទៅដល់ក្រោមឬស្មើនឹង៣០ឆ្នាំ។ ចំណែកឯសម្រាប់បទមជ្ឈិម គឺជាប្រភេទបទល្មើសដែលមានទណ្ឌកម្មរបស់វាលើសពី៦ថ្ងៃទៅដល់ក្រោម ឬស្មើនឹង៥ឆ្នាំ។ ដូច្នេះបើអតិបរមាដែលចែងនៅក្នុងច្បាប់លើស ពី៦ថ្ងៃ ឧបមាដូចជា ច្បាប់ថាជនណាដែល ប៉ោយដៃហៅអ្នកដ៏ទៃនៅទីសាធារណៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ១ថ្ងៃដល់៧ថ្ងៃ ដូច្នេះមានន័យ ថាជាទោសមជ្ឈិមវិញហើយ។មិនមែនជាបទលហុដូចនៅក្នុងមាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌថ្មីយើងឡើយ។ អញ្ចឹងគេត្រូវពិនិត្យទៅលើកម្រិតអតិបរមានៃច្បាប់។ ចំណែកឯបទលហុ គឺទោសនោះស្មើ ហើយនឹងក្រោម ៦ថ្ងៃ បានសេចក្តីថាគឺជាប្រភេទបទលម្មើសដែលកម្រិតគ្រោះថ្នាក់នៃការខូចខាតនោះវាតិចតួចមែនទែន។ ហើយជាទូទៅនៅក្នុបទលហុនេះចៅក្រមមិនមានទីធ្ងន់ធ្ងរ។ រីឯបញ្ហាទី២ គឺទោសទាំងឡាយណាដែលគេ កំណត់ក្នុងច្បាប់ថាអោយពិន័យជាប្រាក់សុទ្ធសាធគឺមិនមានទណ្ឌកម្មផ្នែកខាងគុកទេ។ ចំណុចនេះហើយ គឺច្បាប់ចែងថានៅក្នុងសកម្មភាពអ្វីមួយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ដល់៥០លានរៀល ក៏ដោយក៏នៅតែជាបទលហុដដែលពីព្រោះអត់មានគិតអំពីកម្រិតអតិបរមានៃទោសពិន័យទេ។ ទាំងអស់ខាងលើនេះគឺជាគោលគំនិតនៅក្នុងការបែងចែងរវាងមាត្រា៤៦ មាត្រា៤៧ និង មាត្រា៤៨[៣]។

---

[២] មាត្រា៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ

[៣] មាត្រា៤៦,៤៧,៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌ

## ២.៣ ទោសបន្ថែម

អ្វីដែលជាទោសបន្ថែម នៅក្នុងច្បាប់នេះ គឺ ខុសពីអនុទោសដែលបានចែង នៅក្នុងក្រមព្រហ្មទណ្ឌ ចាស់ឆ្នាំ១៩៥៦នោះ ។ នៅក្នុងក្រមព្រហ្មទណ្ឌចាស់បានចែងអំពីអនុទោស ឬបរិវាទោស បានន័យថាជាទោសដែលតុលាការទោះបីជាសម្រេច ឬមួយមិនសម្រេចក៏ដោយ ក៏ទោសនោះត្រូវមានលក្ខណៈស្វ័យប្រវត្តិតែម្តងមានន័យថាប្រសិនបើបទប្បញ្ញត្តិព្រហ្មទណ្ឌ នៅត្រង់មាត្រាណាមួយនិយាយពី បទល្មើសនិងមាននិយាយពី អនុទោស ទោះបីជាតុលាការមិនប្រកាសក៏ដោយ ក៏អនុទោសនោះ ត្រូវប្រើតែម្តង ត្រូវតែអនុវត្តជាដាច់ខាត ព្រោះមានលក្ខណៈស្វ័យប្រវត្តិ។ ប៉ុន្តែនៅក្នុងច្បាប់នេះគឺ យើងបានជ្រើសរើសយកគោលការណ៍មួយថា បើសិនជាមានការកំណត់បែបនេះ វានឹងទៅជាមានលក្ខណៈមួយដ៏រឹងកំព្រឹសនៅពេលដែលគេយកទៅអនុវត្ត នោះគឺមិនស្របជាមួយនឹងស្ថានភាពជាក់ស្តែងទេ មិនស្របជាមួយនឹងស្ថានភាពនៃបទល្មើសទេ មិនស្របជាមួយនឹងស្ថានភាពរបស់សង្គមទេ។ ដូច្នេះហើយបានយើងទុកសិទ្ធិអោយដល់ចៅក្រមព្រោះពាក្យថាទោសបន្ថែមនៅទីនេះ គឺត្រូវស្របជាមួយនឹងគោលការណ៍ ដែលមានចែងនៅក្នុងមាត្រា៥៤ ជាមុនសិនដូច្នេះចៅក្រមត្រូវពិនិត្យមើលលើមាត្រាមួយនេះ។

មាត្រា៥៤ ចែងថាទោសបន្ថែមអាចប្រកាសទៅបានលុះត្រាតែទោសនេះ ត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ នេះជាគោលការណ៍នីត្យានុកូលភាព គឺមានន័យថាទោសបន្ថែមដែលចង្អុលនៅក្នុងមាត្រា៥៣ ចំនួនទាំងអស់១៩ចំណុចនេះមិនមែនចេះតែយកទៅអនុវត្តនោះទេ ទាល់តែមានបទប្បញ្ញត្តិស្តីពីបទល្មើសណាមួយនោះ ច្បាប់កំណត់ថាអោយប្រើទោសបន្ថែមជាមុនសិនទើបចៅក្រមអាចយកទៅប្រើប្រាស់បានទី១។ ទី២៖ ទោសបន្ថែមនេះទោះបីជាបានចែងច្បាស់លាស់អញ្ចឹងហើយក៏ដោយគាត់អាច ប្រកាសក៏បាន មិនប្រកាសក៏បាននេះជាលក្ខខណ្ឌទី២។ ទី៣៖ បើច្បាប់បានចែងជាក់លាក់ថា ត្រូវតែប្រកាសទោសបន្ថែមនោះទើបចៅក្រមត្រូវតែប្រកាសទោសបន្ថែមជាកាតព្វកិច្ច។ ប៉ុន្តែបទប្បញ្ញត្តិជាកាតព្វកិច្ចនោះ គឺមានតិចទេ បើនៅក្នុងច្បាប់ពិសេសទើបបានសម្បូរ។ ប៉ុន្តែនៅក្នុងច្បាប់ព្រហ្មទណ្ឌទូទៅគេច្រើនតែយកគោលការណ៍មួយថាជ្រើសរើសប្រកាស ឬមិនប្រកាស។

## ២.៤ វិធានស្រូបទោស

វិធាននេះអាចយកទៅអនុវត្តបានសម្រាប់បទល្មើសត្រួតគ្នា ទាំងក្នុងនីតិវិធីនៃការចោទប្រកាន់តែមួយ ទាំងក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ដោយឡែកពីគ្នា។ វិធាននេះមានចែងកំណត់នៅក្នុងមាត្រា ១៣៧ និងមាត្រា ១៣៨[៤] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ក-លក្ខខណ្ឌនៃការអនុវត្តវិធាន

វិធានស្រូបទោសតាមបទប្បញ្ញត្តិ មាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌថ្មី ត្រូវយកទៅអនុវត្ត នៅក្នុងនីតិវិធី នៃការចោទប្រកាន់តែមួយចំពោះបទល្មើសត្រួតគ្នាទាំងអស់។ ការចោទប្រកាន់តែមួយនេះ សំដៅដល់ស្ថានភាពនៃនីតិវិធី ដែលក្នុងនោះបទល្មើសត្រួតគ្នាទាំងអស់ត្រូវបានចោទប្រកាន់នៅក្នុងលិខិតចោទប្រកាន់ តែមួយដូចជាការចោទបទល្មើសត្រួតគ្នានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរតែមួយ នៅក្នុងកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាមតែមួយ ឬ ក៏នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់តែមួយ។ ទន្ទឹមនឹងនេះដែរ ត្រូវបានចាត់ទុកថាជាការចោទប្រកាន់តែមួយផងដែរក្នុងករណី ដូចខាងក្រោម៖

- នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ចៅក្រមស៊ើបសួរបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បន្ថែមពីអយ្យការសម្រាប់អង្គហេតុនៃបទល្មើសថ្មីផ្សេង ដែលចៅក្រមស៊ើបសួរបានរកឃើញថាមានការពាក់ព័ន្ធទៅនឹងជនត្រូវចោទ ហើយចៅក្រមស៊ើបសួរ បានសម្រេចបិទការស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ សម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។ ដូចគ្នាដែរ នៅក្នុងករណីដែល សភាស៊ើបសួរពន្លាត ការស៊ើបសួររបស់ខ្លួនទៅដល់បទល្មើសពាក់ព័ន្ធផ្សេងទៀត ស្របតាមបទប្បញ្ញត្តិមាត្រា ២៦៣[៥] នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ហើយបានបិទបញ្ចប់ការស៊ើបសួររបស់ខ្លួន តាមសាលដីកាបញ្ជូនទៅជំនុំជម្រះ សម្រាប់អង្គហេតុ បង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។
- នៅក្នុងករណី ដែលមានការចោទប្រកាន់តែមួយសម្រាប់បទល្មើសត្រួតគ្នាដូចបានរៀបរាប់ខាងលើតុលា ការត្រូវអនុវត្តវិធាននៃការស្រូបទោសដោយស្វ័យប្រវត្តិស្រប

---

៤ មាត្រា១៣៧,១៣៨ នៃក្រមព្រហ្មទណ្ឌ

៥ មាត្រា២៦៣ នៃក្រមព្រហ្មទណ្ឌ

តាមបទប្បញ្ញត្តិមាត្រា ១៣៧[៦] នៃក្រមព្រហ្មទណ្ឌកម្ពុជា បើទោះបីជាពុំមានបណ្តឹងសុំពីអយ្យការ ឬភាគីពាក់ពន្ធ័ក៏ដោយ។

**ខ- ខ្លឹមសារនៃការអនុវត្តវិធាន**

មាត្រា ១៣៧ ចែងថា "កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ហើយជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើនទោសនីមួយៗអាចត្រូវបានប្រកាសឡើង។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមា ស្របច្បាប់ដែលខ្ពស់ជាងគេ។ ទោសនីមួយៗដែលប្រកាស ត្រូវចាត់ទុកថាជាទោសរួមចំពោះបទល្មើសដែលត្រួតគ្នា នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ។" យោងតាមបញ្ញត្តិនៃ មាត្រានេះ យើងឃើញថានៅក្នុងសម្មតិកម្មខ្លះ តុលាការត្រូវប្រកាសទោសនីមួយៗ សម្រាប់បទល្មើសត្រួតគ្នាហើយ នៅក្នុងសម្មតិកម្មខ្លះទៀត តុលាការ គឺមិនអាចប្រកាសទោសនីមួយៗ សម្រាប់បទល្មើសត្រួតគ្នាឡើយ ក៏ប៉ុន្តែតុលាការត្រូវប្រកាសទោសតែមួយរួមគ្នាសម្រាប់បទល្មើសត្រួតគ្នាទាំងអស់។

សម្មតិកម្ម ៖ ករណីដែលតុលាការត្រូវប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា

វិធាននេះ ត្រូវយកទៅអនុវត្ត នៅក្នុងករណីដែលទោសត្រូវប្រកាសសម្រាប់បទល្មើសត្រួតគ្នា មាន ប្រភេទ ខុសគ្នា ដូចជា ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ គឺជាទោសដែលមានប្រភេទខុសគ្នា។

<u>ឧទាហរណ៍៖</u> ឈ្មោះ"ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នារួមមាន៖

- "បទរំលោភសេពសន្ថវៈ"៖ មាត្រា ២៣៩[៧] នៃក្រមព្រហ្មទណ្ឌចែងផ្តន្ទទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។
- "បទបរិហារកេរ្តិ៍"៖ មាត្រា ៣០៥[៨] នៃក្រមព្រហ្មទណ្ឌចែងផ្តន្ទទោសពិន័យជាប្រាក់ពី ១ សែនរៀល ទៅ ១០លាន រៀល។

[៦] មាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ

[៧] មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ

[៨] មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ

ឧទាហរណ៍ខាងលើ គឺជាសម្មតិកម្មដែលតុលាការត្រូវប្រកាសទោសនីមួយៗសម្រាប់បទល្មើសត្រួតគ្នា គឺមានអត្ថន័យថាតុលាការត្រូវប្រកាសទោសដាក់ពន្ធនាគារសម្រាប់បទរំលោភសេពសន្ថវៈ និង ទោសពិន័យជាប្រាក់សម្រាប់បទបរិហារកេរ្តិ៍។

យោងតាមមាត្រា ១៣៧[៩] នៃក្រមព្រហ្មទណ្ឌ តុលាការត្រូវប្រកាសទោសតែមួយ ចំពោះប្រភេទ នៃទោស ដាក់ពន្ធនាគារ និងប្រកាសទោសតែមួយ ចំពោះប្រភេទនៃទោសពិន័យជាប្រាក់ នៅក្នុងព្រំដែន អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ មានន័យថាតុលាការអាចប្រកាសទោសដាក់ពន្ធនាគារ អតិបរមាច្រើនបំផុតត្រឹមតែ ១០ឆ្នាំ និង ពិន័យជាប្រាក់អតិបរមាច្រើនបំផុតត្រឹមតែ ១០ លានរៀល សម្រាប់បទល្មើសទាំង ៣ (បី) ខាងលើ។

ទោសដាក់ពន្ធនាគារ ១០ឆ្នាំ និងទោសពិន័យជាប្រាក់ ១០លានរៀល ដែលតុលាការប្រកាសនោះ ត្រូវចាត់ទុកថាជាទោសរួមចំពោះបទល្មើសដែលត្រួតគ្នា នៅក្នុងព្រំដែនអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ មានន័យថានៅក្នុងឧទាហរណ៍ខាងលើ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ១០ឆ្នាំ, បទកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៥ឆ្នាំ និង ពិន័យជាប្រាក់ពី ១០ លានរៀល និង បទឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី ៦ លានរៀល។

**វិធានស្រូបទោសយោងតាមបញ្ញត្តិមាត្រា ១៣៨នៃក្រមព្រហ្មទណ្ឌ**

**លក្ខខណ្ឌនៃការអនុវត្តវិធានៈ** បើយោងតាមបញ្ញត្តិមាត្រា ១៣៨[១០] នៃក្រមព្រហ្មទណ្ឌថ្មី វិធានស្រូបទោស ក៏អាចយកទៅអនុវត្តបានផងដែរ នៅក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នាចំពោះបទល្មើសត្រួតគ្នា។

យោងតាមបញ្ញត្តិនៃមាត្រានេះ និង យោងតាមបញ្ញត្តិមាត្រា ៥០១[១១] នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរឆ្នាំ២០០៧ តុលាការដែលអាចសម្រេចអំពីការស្រូបទោសបញ្ចូលគ្នាបាន គឺតុលាការដែលត្រូវសម្រេចចុងក្រោយគេ ឬតុលាការដែលបានសម្រេចចុងក្រោយគេ។ ប្រសិនបើសំណុំរឿងកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួននៅឡើយ តុលាការអាចសម្រេចដោយឯកឯង

---

[៩] មាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ

[១០] មាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ

[១១] មាត្រា៥០១ នៃក្រមព្រហ្មទណ្ឌ

បានអំពីការស្រូបទោសបញ្ចូលគ្នា។ ក្រៅពីនេះទៀត តុលាការអាចសម្រេចបានលុះត្រាតែបានទទួលបណ្តឹងសុំពីអយ្យការ ឬពីភាគីពាក់ពន្ធ័ (មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៧)។ នៅក្នុងករណីចុងក្រោយនេះតុលាការត្រូវសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្តាប់អយ្យការភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ។ ក្នុងគ្រប់ករណីទាំងអស់ ការស្រូបទោសបញ្ចូលគ្នាត្រូវធ្វើតាមសាលក្រម ឬសាលដីការបស់តុលាការ។

**ចំណាំ៖** មេធាវី គឺជាជនដែលជាសមាជិកនៃគណៈមេធាវី ផ្តល់យោបល់ និង តាក់តែងលិខិតស្នាម ផ្សេងៗក្នុងវិស័យគតិយុត្ត តំណាងឱ្យកូនក្តី ឬ ការពារឲ្យកូនក្តីនៅគ្រប់សាលាជម្រះក្តី និង គ្រប់ដំណាក់កាលនៃនីតិវិធី (ពាក្យចាស់ ហៅថា ស្នាក្តី)។

**ខ្លឹមសារនៃការអនុវត្តវិធាន៖** ក្នុងករណីដែលតុលាការសម្រេចអនុវត្តវិធានស្រូបទោស តុលាការអាចសម្រេចឲ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នាបានស្របតាមរបៀប នៃការស្រូបទោសដែលមានចែងនៅក្នុងមាត្រា ១៣៧[១២] នៃក្រមព្រហ្មទណ្ឌ។ ក៏ប៉ុន្តែនៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះបទល្មើសត្រួតគ្នាណាមួយហើយ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនៅឡើយទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ នៅក្នុងការអនុវត្តវិធានស្រូបទោសនេះ ត្រូវបានកំណត់ដាក់ពន្ធនាគារ មិនឱ្យលើសពី ៣០ (សាមសិប) ឆ្នាំ។ វិធាននេះត្រូវអនុវត្តដូចគ្នាដែរចំពោះទណ្ឌិត ប្រសិនបើទណ្ឌិតនេះមិនត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ។ ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានោះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ។

## វិធានត្រួតទោស

វិធានត្រួតទោសនេះ មានចែងកំណត់នៅក្នុងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ។ ជាទូទៅ វិធានត្រួតទោស ត្រូវយកមកអនុវត្តនៅក្នុងករណីនៃការចោទប្រកាន់ដាច់ពីគ្នាចំពោះបទល្មើសត្រួតគ្នា។ មាត្រា ១៣៨ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌថ្មី បានចែងថា "នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជន ជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើស

---

[១២] មាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ

ច្រើន ទោសដែលត្រូវប្រកាសត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ ដែលខ្ពស់ជាងគេ ។" នៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារ អស់មួយជីវិត ចំពោះបទល្មើសណាមួយហើយ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ។ ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែល ត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្ត ទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ។

<u>**ឧទាហរណ៍៖**</u> ឈ្មោះ"ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នារួមមាន៖

- "បទរំលោភសេពសន្ថវៈ" ៖ មានចែងផ្តន្ទទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ តាមមាត្រា ២៣៩[13] នៃក្រមព្រហ្មទណ្ឌ។
- "បទកំហែងយក" ៖ មានចែងផ្តន្ទទោស ទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤ លានរៀល ទៅ ១០ លានរៀល តាមមាត្រា ៣៦៤[១៤] នៃក្រមព្រហ្មទណ្ឌ។
- "បទឆបោក" ៖ មានចែងផ្តន្ទទោស ទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៦ លានរៀល តាមមាត្រា ៣៧៨[១៥] នៃក្រមព្រហ្មទណ្ឌ។

នៅក្នុងឧទាហរណ៍នេះ ឈ្មោះ"ក" ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងចំនួន ៣ ដាច់ពីគ្នា ហើយ តុលាការបានសម្រេចផ្តន្ទាទោសតាមសាលក្រម ឬសាលដីកាស្ថាពរចំនួន ៣ ដាច់ពីគ្នាដោយសម្រេចផ្តន្ទាទោស ៖

- ចំពោះ បទរំលោភសេពសន្ថវៈ៖ ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ
- ចំពោះ បទកំហែងយក៖ ដាក់ពន្ធនាគារកំណត់ចំនួន ៣ ឆ្នាំ និង ពិន័យជាប្រាក់ពី ៨ លានរៀល។

---

[១៣] មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ

[១៤] មាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ

[១៥] មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ

- ចំពោះ បទឆបោក៖ ដាក់ពន្ធនាគារកំណត់ចំនួន ២ ឆ្នាំ និង ពិន័យជាប្រាក់ពី ៤ លានរៀល។

យោងតាមមាត្រា ១៣៨[១៦] នៃក្រមព្រហ្មទណ្ឌ ទោសដែលតុលាការប្រកាសផ្តន្ទាទោសត្រូវអនុវត្តគ្រួតគ្នានៅ ក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេមានន័យថាទណ្ឌិតត្រូវទទួលរងនូវការអនុវត្តទោសដាក់ពន្ធនាគារជាអតិបរមាត្រឹម ១០ ឆ្នាំ និង ពិន័យជាប្រាក់អតិបរមាត្រឹម ១០ លានរៀល សម្រាប់បទល្មើសទាំង ៣ ខាងលើ។

យោងតាមមាត្រា ១៣៨[១៧] នៃក្រមព្រហ្មទណ្ឌ ទណ្ឌិតត្រូវទទួលរងនូវការអនុវត្តទោសដាក់ពន្ធនាគារជាអតិបរមាត្រឹម ៣០ ឆ្នាំ និង ពិន័យជាប្រាក់អតិបរមាត្រឹម ១០ លានរៀល សម្រាប់បទល្មើសទាំង ៣ ខាងលើ។ (យោងទៅតាមស្មារតីនៃមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៥០១[១៨] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទោសដែលតុលាការបានប្រកាសផ្តន្ទាទោសត្រូវអនុវត្តគ្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ)។ ប៉ុន្តែនៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះបទល្មើសគ្រួតគ្នាណាមួយ ហើយប្រសិនបើទណ្ឌិតមិនត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ សម្រាប់អនុវត្តវិធាននៃការស្រូបទោស។

### គ- វិធានបូកទោស

វិធានបូកទោសនេះ យើងឃើញមានចែងកំណត់នៅក្នុងមាត្រា ១៤០[១៩] នៃក្រមព្រហ្មទណ្ឌ។ វិធានបូកទោសនេះ ត្រូវយកមកអនុវត្តចំពោះបទល្មើសគ្រួតគ្នា ទោះនៅក្នុងនីតិវិធីនៃការចោទប្រកាន់ តែមួយក្តី ទោះនៅក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នាក្តី។ មាត្រា ១៤០ នៃក្រមព្រហ្មទណ្ឌបាន ចែងកំណត់អំពីវិធាននៃការបូកទោស នេះយ៉ាងច្បាស់ណាស់ថា "ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុ

[១៦] មាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ

[១៧] មាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ

[១៨] មាត្រា៥០១ នៃក្រមព្រហ្មទណ្ឌ

[១៩] មាត្រា១៤០ នៃក្រមព្រហ្មទណ្ឌ

ច្រើននោះត្រូវបូកបញ្ចូលគ្នាហើយត្រូវបូកផងដែរជាមួយទោស ពិន័យដែលប្រកាសឡើង ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។"

ការបូកបញ្ចូលគ្នានៃទោសនេះ ក៏ត្រូវបានយកទៅអនុវត្តផងដែរចំពោះទោសដាក់ពន្ធនាគារ។ បើយោងទៅ តាមបទប្បញ្ញត្តិនៃមាត្រា ១៤១[២០] នៃក្រមព្រហ្មទណ្ឌទោសដែលតុលាការសម្រេចផ្ដន្ទាពីបទរត់ចេញពីពន្ធនាគារ ត្រូវបូកបញ្ចូលគ្នាជាមួយគ្នានិង ទោសដែលប្រកាសឡើង ចំពោះបទល្មើស ដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ឬគ្រួតគ្នាតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រា ១៣៧[២១] និង មាត្រា ១៣៨ នៃ ក្រមព្រហ្មទណ្ឌខ្មែរថ្មីឡើយ។

គួរកត់សម្គាល់ផងដែរថាៈ ការបូកបញ្ចូលគ្នានៃទោសក៏ត្រូវបានយកទៅអនុវត្តផងដែរនៅក្នុងករណីក្រៅពីស្ថានភាពនៃបទល្មើសត្រួតគ្នាជាអាទិ៍ នៅក្នុងករណីដែលមានការដកហូតការព្យួរទោស (ទោះបីជាព្យួរទោសធម្មតាក្តី ព្យួរទោសសាកល្បងក្តី) ដោយសារមានការផ្តន្ទាទោសថ្មីតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រា ១០៩ មាត្រា ១១៤ និង មាត្រា ១២២[២២] នៃក្រមព្រហ្មទណ្ឌ។ នៅក្នុងករណីទាំងអស់នេះទោសទី១ ត្រូវអនុវត្តដោយបូកបញ្ចូលគ្នា ជាមួយទោសទី២ ដោយគ្មានការស្រូបចូលគ្នា ឬ ត្រួតគ្នាតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១៣៧ និង មាត្រា ១៣៨[២៣] នៃក្រមព្រហ្មទណ្ឌខ្មែរថ្មីឡើយ។

## ២.៥ មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស

សូមជម្រាបជូន អំពីអត្ថន័យដែលពាក់ព័ន្ធនឹងមូលហេតុទូទៅ ដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស ដើម្បីជាទស្សនៈក្នុងការអនុវត្តច្បាប់នេះឲ្យបានត្រឹមត្រូវផង។ នៅក្នុងនេះពាក់ពន្ឋ័ទៅនឹងរឿងអាជ្ញាយុកាលនៃទោសនេះ គឺជាមូលហេតុមួយមានន័យថា នៅពេលដែលតុលាការបានសម្រេចសេចក្ដីហើយ សេចក្ដីសម្រេចនោះចូលជាស្ថាពរកំណត់ថា ជនណាមួយមានពិរុទ្ធនៅក្នុងបទណាមួយ គាត់កំណត់អំពីទោសដែលត្រូវអនុវត្តទៅលើជននោះរួច

---

[២០] មាត្រា១៤១ នៃក្រមព្រហ្មទណ្ឌ

[២១] មាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ

[២២] មាត្រា១០៩,១១៤,១២២ នៃក្រមព្រហ្មទណ្ឌ

[២៣] មាត្រា១៣៧,១៣៨ នៃក្រមព្រហ្មទណ្ឌ

ហើយ ឥឡូវឧទាហរណ៍ដូចជា ការអនុវត្តទោសបន្ថែម ឬមួយក៏នូវទោសបន្ថែមជំនួសឱ្យមូលទោស ឬមួយក៏អនុវត្តមូលទោស បើដូច្នេះនៅពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ សេចក្តីសម្រេចនេះ ត្រូវតែមានអានុភាពទៅតាមផ្លូវច្បាប់ គឺត្រូវតែអនុវត្តយកទៅអនុវត្តជាដាច់ខាត។ ប៉ុន្តែនៅក្នុងច្បាប់នេះក៏មានចែងអំពីមូលហេតុមួយចំនួន ដែលនាំឱ្យមានផលប៉ះពាល់ដល់ការអនុវត្តទោសផងដែរ គឺបានន័យថាទោសនោះ មិនអាចអនុវត្តបានដោយសារមានមូលហេតុ ឬ មួយក៏ត្រូវបានដកការអនុវត្តរយៈពេលណាមួយ ហើយទុកនូវរយៈពេលណាមួយដើម្បីឱ្យទោស នោះត្រូវបានអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការ

មូលហេតុសំខាន់ទី១ គឺពាក់ពន្ធ័ជាមួយនឹង "អាជ្ញាយុកាល"។ ហើយសូមជម្រាបជូនថា អាជ្ញាយុកាលនៃបទល្មើស ឬ មួយក៏អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា មិនដូចគ្នាជាមួយនឹងអាជ្ញាយុកាលនៃទោសនោះទេ។

## ២.៦ ស្ថានទម្ងន់ទោស

ជាទូទៅស្ថានទម្ងន់ គឺអ្នកដែលរៀបចំតាក់តែងច្បាប់បានចង្អុលបង្ហាញយ៉ាងជាក់លាក់ណាស់អំពីស្ថានទម្ងន់ទោសថាជា សញ្ញាណដាច់ខាត ពីព្រោះថាបើអត់មានច្បាប់ចែងនោះទេ គឺ ចៅក្រមមិនអាចជ្រើសរើសយកស្ថានទម្ងន់ផ្សេងទៀតមកបំពេញបន្ថែមឡើយ។ បើទោះបីជាស្របជាមួយនឹងទស្សនៈរបស់សង្គមក៏ដោយឱ្យតែច្បាប់មិនទាន់បានចែងទេ ចៅក្រមមិនអាចយកស្ថានទម្ងន់ផ្សេងទៀតក្រៅពីច្បាប់ចែងមកប្រើនោះឡើយ។ នេះត្រូវចងចាំថា បើសិនជាច្បាប់ចែងនូវកាលៈទេសៈ ដែលនាំឱ្យមានស្ថានទម្ងន់ទោសដូចជាចំណុច ១,២,៣,៤,៥។ ចៅក្រមមិនអាចបង្កើតនូវចំណុចទី៦ដោយខ្លួនឯងបានទេ ទោះបីជាសង្គមទទួលស្គាល់ថាគួរបង្កើតឱ្យមានចំណុចទី៦នោះក៏ដោយ ឱ្យតែអត់មានច្បាប់គឺហាមមិនឱ្យចៅក្រមប្រើដាច់ខាតតែម្តង។ អញ្ចឹងហើយបានជាថាសញ្ញាណនៃស្ថានទម្ងន់គឺ ជាសញ្ញាណដាច់ខាត នោះហើយវាជាកាលៈទេសៈដែលច្បាប់តម្រូវឱ្យកម្រិតនៃទណ្ឌកម្មកើនឡើង និង មិនអោយចៅក្រមណាមួយមានសិទ្ធិពន្លាតសញ្ញាណផ្សេងទៀត ដែលច្បាប់មិនបានចែងថាជាស្ថានទម្ងន់ទោសនោះទេ។ មុននឹងទៅពន្យល់លម្អិតអំពីស្ថានសម្រាលទោស គឺទាមទារឱ្យយើងយល់ពីស្ថានទម្ងន់ទោសជាមុនសិន។ ចំណុចពិសេស នៅក្នុងការកំណត់អំពីស្ថានទម្ងន់ទោសនេះចៅក្រម

ផ្អែកទៅលើបញ្ហា ២(ពីរ) គឺ ចរិកគ្រោះថ្នាក់នៃ អំពើរបស់ជនល្មើស (កថាភាគទី១) ឯ (កថាភាគទី២) គឺការមិនរាងចាល៖

### ក.ចរិកគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស

បានន័យថាត្រូវពិនិត្យមើលថាតើអំពើនោះជាប្រភេទអំពើបែបណាខ្លះ? ព្រោះថា ស្ថានទម្ងន់ទោសខ្លះ គឺច្បាប់បានកំណត់យ៉ាងជាក់លាក់នៅក្នុងច្បាប់ពាក់ពន្ធ័ជាមួយនឹងបទល្មើសនីមួយៗហ្នឹង ដោយសារតែទម្រង់នៃអំពើនោះជាប្រភេទអំពើមួយដែលគេគិតថាវាមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សង្គម ។

### ខ. ការមិនរាងចាល

ទាក់ទងទៅនឹងបញ្ហាមួយទៀត គឺ ទាក់ទងទៅនឹងការប្រព្រឹត្តដោយមិនរាងចាលនេះ គេហៅថាចូលទៅក្នុងករណីមិនរាងចាល។ ហើយត្រូវចងចាំជាប់ជានិច្ចថា ការមិនរាងចាលនេះអនុវត្តបានតែចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមប៉ុណ្ណោះ ចំណែកបទលហុវិញ គឺគ្មានករណីមិនរាងចាលនេះទេ ពីព្រោះថាបទលហុនេះ បុគ្គលម្នាក់ៗងាយ នឹងប្រព្រឹត្តវាណាស់ដូចជាករណីបទល្មើសចរាចរណ៍ជាដើម ដូច្នេះទើបក្រមមិនចែងចំពោះបទលហុឡើយ។

## ៣.លទ្ធផលនៃការស្រាវជ្រាវ

យោងតាមការសិក្សារមួយរយៈកន្លងមក យើងទទួលបានជាលទ្ធផលដែលបង្ហាញអំពីស្ថានទម្ងង់ទោសនៅក្នុងបទល្មើសមជ្ឈិម និងឧក្រិដ្ឋ។ ដែលនៅក្នុងច្បាប់យើង គេផ្អែកទៅគោលការណ៍មួយ គេថាបើសិនជាកម្រិតនៃទោសដល់កម្រិតណាមួយនោះជាបទឧក្រិដ្ឋ បទល្មើសដែលទោសត្រូវកម្រិតប៉ុណ្ណាជាបទមជ្ឈិមដោយផ្អែកទៅលើអ្វីខ្លះ? ជាទូទៅគឺមានទស្សនៈ២ គេហៅថាការកំណត់បទល្មើសនេះ ឬការធ្វើចំណាត់ថ្នាក់នូវបទល្មើសថាជាបទឧក្រិដ្ឋបទមជ្ឈិមនោះ មានទស្សនៈខ្លះគេបានផ្អែកទៅលើចរិកគ្រោះថ្នាក់ នៃអំពើដែលបានកើតឡើងសម្រាប់សង្គម។ បើសិនជាចរិកគ្រោះថ្នាក់នោះកើតឡើងដោយសារមានការអន្តរាយធ្ងន់ធ្ងរគេចាត់ទុកថានោះជាប្រភេទបទល្មើសឧក្រិដ្ឋ ហើយបើកម្រិតគ្រោះថ្នាក់នេះល្មមគួរសមគេចាត់ទុកថាជាប្រភេទបទល្មើសមជ្ឈិមផ្អែកលើទស្សនៈដូចគ្នាដែរ។ ប៉ុន្តែយើងកំណត់ជាទោសវិញគេថាប្រសិនជាចរិកគ្រោះថ្នាក់នៃអំពើកើនខ្ពស់ កម្រិតទោសត្រូវធ្ងន់ធ្ងរ

ឡើងៗ ពីព្រោះដើម្បីអោយមានតុល្យភាពរវាងអំពើជាមួយ នឹងការខូចខាតដស់សង្គម។ ដូច្នេះបើយើងផ្អែកទៅលើមូលដ្ឋាននេះយើងបានកំណត់ថា ៖

### ៣.១ បញ្ហាប្រឈម

បទល្មើសជាច្រើននៅតែបន្តកើតមាន ទោះបីជាប្រពន្ធអប់រំ និងការផ្សព្វផ្សាយអំពីផលវិបាក និងការទទួលខុសត្រូវចំពោះមុខច្បាប់មានភាពរីកចម្រើនក៏ដោយ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួននៅតែមិនមានការគោរព ហើយធ្វើការគេចវេសពីការទទួលខុសត្រូវ (ឧ៖ បទល្មើសចរាចរណ៍ ការមិនពាក់មួកសុវត្ថិភាព, មិនគោរពប៉ូលិសចរាចរណ៍ជាដើម)។ហើយបទល្មើសមួយចំនួនទៀតដូចជា បទល្មើសលួច ហឹង្សា រំលោភ និងឃាតកម្មបានបង្កអោយសង្គម។

#### ក.ផលប៉ះពាល់ដោយផ្ទាល់

- មានវិបត្តិផ្លូវចិត្ត
- មានវិបត្តិផ្លូវកាយ
- ផ្នែកសិទ្ធិបុគ្គល

#### ខ.ផលប៉ះពាល់ដោយប្រយោល

- ធ្វើអោយសង្គមខ្វេចខ្វាំ
- ធ្វើអោយបាត់បង់ពលកម្មយុវជន
- ប៉ះពាល់ដល់ការអភិវឌ្ឍន៍សង្គម
- ប៉ះពាល់ដល់សង្គមព្រោះគាត់ជាធនធានដ៏កំរ

### ៣.២ ដំណោះស្រាយ

រដ្ឋាភិបាលបាននិងកំពុងព្យាយាមយ៉ាងខ្លាំងក្នុងការរៀបចំទប់ស្កាត់ និងបង្រ្កាបនូវបទល្មើសផ្សេងៗកុំឱ្យបន្តកើតឡើង ដូចនេះមានកត្តាមួយចំនួនដែលយើងត្រូវយកចិត្តទុកដាក់៖

- បំបាត់នៅអាវុធជាតិផ្ទុះអោយបាន១០០%
- បំបាត់ក្មេងទំនើង
- បណ្តុះបណ្តាលការអប់រំតាមសាលារៀន

- ផ្តល់ពត៌មានដល់យុវជន និងប្រជាពលរដ្ឋបានយល់ដឹងពីបទល្មើសនានាដែលមានក្នុងសង្គមបច្ចុប្បន្ន
- ធ្វើការអប់រំកែប្រែ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកទោសផ្នែកព្រហ្មទណ្ឌឧក្រិដ្ឋ.....ល.....។

## ៣.៣ តំរូវការជាក់ស្តែង

ស្របពេលគ្នានេះដែរ រដ្ឋាភិបាលពិតជាត្រូវធនធានមនុស្ស ក៏ដូចជាសំភារៈជាច្រើនក្នុងការសម្រួលដល់សកម្មភាពរបស់ខ្លួនក្នុងការដោះស្រាយ និងទប់ស្កាត់បទល្មើសដែលកត្តាសំខាន់ៗ និងចាំបាច់ក្នុងពេលនេះមាន៖

១. បណ្តុះបណ្តាលមន្ត្រីជំនាញផ្នែកព្រហ្មទណ្ឌ
២. បង្កើនថវិកាដល់មន្ត្រីពន្ធនាគារ ដើម្បីឃុំគ្រងអ្នកទោស
៣. រឹតបន្តឹងការសុខសុវត្ថិភាពសាធារណៈបន្ថែមមួយកំរិតទៀត
៤. បញ្ជូនកម្មវិធីសិក្សាដល់យុវជនគ្រប់រូបលើបញ្ហាដែលត្រូវប្រឈមពេលដែលអ្នកបានប្រព្រឹត្តបទល្មើសណាមួយ....ល.....។

# ៤.សន្និដ្ឋាន និងអនុសាសន៍

ជាសរុបមកវិញទោសដែលក្រមព្រហ្មទណ្ឌបានចែងទៅតាមចរិកលក្ខណៈនៃទោសនីមួយៗ ក៏ដូចគ្នានេះដែរគ្រប់បទល្មើសឧក្រិដ្ឋ ច្បាប់សុទ្ធតែចែងទុកដែលស្តែងបញ្ជាក់អោយឃើញអំពីការដាក់ពិន័យណាមួយដើម្បីធ្វើយ៉ាងណាអោយជនដែលបានប្រព្រឹត្តបទល្មើសនោះទទួលបានការដាក់ពិន័យអោយសមស្របទៅនឹងទង្វើដែលខ្លួនបានប្រព្រឹត្តខុស ហើយមានភាពរៀងចាលចំពោះទង្វើដែលខ្លួនបានប្រព្រឹត្តផ្ទុយ ឬខុសពីច្បាប់ដែលបានចែងទុកជាធរមាន។ ក៏ដូចគ្នានេះដែរ ក្រមព្រហ្មទណ្ឌក៏បានកំណត់យ៉ាងច្បាស់លាស់អំពីទោសនីមួយៗដែលអាចត្រូវបានដាក់បន្ថែមទោស ឬស្ថានទម្ងន់ទោសទៅតាមសកម្មភាពដែលបានប្រព្រឹត្តនោះដែលវាបង្កអោយមានហានាភ័យមួយចំនួនកើតឡើង ហើយការដាក់ទណ្ឌកម្មបន្ថែមនេះក៏ដើម្បីទប់ស្កាត់ និងដាក់ទោសដល់បុគ្គលដែលបានប្រព្រឹត្តខុសទទួលបាននូវទោសដែលសមស្របនឹងអ្វីដែលខ្លួនបានប្រព្រឹត្ត និងមានភាពរៀងចាលចំពោះកំហុសរបស់ខ្លួន។

ជាចុងបញ្ចប់ក្នុងនាមយើងខ្ញុំក៏សង្ឃឹមថាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចនឹងឈានមួយកំរិតទៀតក្នុងការដាក់ទណ្ឌកម្មបន្ថែមដល់ជនល្មើសដែលបានប្រព្រឹត្តដោយសារតែនៅមានបុគ្គលមួយចំនួនដែលក្រោយពីទទួលទណ្ឌកម្មព្រហ្មទណ្ឌហើយ តែនៅមិនទាន់មានភាពរៀងចាលចំពោះទង្វើរបស់ខ្លួននៅឡើយ។

# គន្ថនិទ្ទេស


១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។
២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
៣. បទប្បញ្ញត្តិ ស្តីពីតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា សម័យអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។
៤. ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ អនុម័តនៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ និងប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ ។
៥. សៀវភៅឯកសារតុលាការ និងយុត្តិធម៌ ( Recueil Judiciare et de Jurispudence ) ខែកក្កដា ឆ្នាំ២០០០ ផ្សាយដោយអង្គភាពសម្របសម្រួលការងារនីតិកម្មអមទីស្តីការគណៈរដ្ឋមន្ត្រីជាភាសាខ្មែរ និង ជាភាសាបារាំង
៦. កម្រងឯកសារ ស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី សម័យប្រជុំពេញអង្គ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ រៀបចំដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។
៧. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទៅ០៧ ខែមិថុនា ឆ្នាំ២០០៧ ដោយមានការឯកភាពទាំងស្រុងពីព្រឹទ្ធសភា កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ ហើយតម្រូវឲ្យអនុវត្តភ្លាមៗស្របតាមខ្លឹមសារនៃមាត្រា៦១២ នៃក្រមនេះ ។
៨. សៀវភៅឯកសារតុលាការ និងយុត្តិសាស្រ្ត លេខ ១/កក្កដា ២០០០/No. 1 Juillet, 2000 ។
៩. សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ( Projet de code penal ) ឆ្នាំ២០០០ ។
១០. សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ ( Projet de nouveau code penal corrumente et compare ) ឆ្នាំ២០០៥។

១១. អត្ថាធិប្បាយច្បាប់ភាគ១ ក្នុងរឿងព្រហ្មទណ្ឌ សម្រាប់ប្រជារាស្ត្រសាមញ្ញ រៀបរៀងដោយលោក **ហ៊ីង ធីរឫទ្ធិ** ឆ្នាំ២០០៧ ។
១២. និក្ខេបបទថ្នាក់បណ្ឌិត ស្តីពីកិច្ចដំណើរការមេធាវីក្នុងនីតិវិធីព្រហ្មទណ្ឌ-រដ្ឋប្បវេណី ចន្លោះឆ្នាំ១៩៩២-២០០៦ របស់លោកបណ្ឌិតមេធាវី **ម៉ួង សុគន្ធ** ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ។
១៣. ច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ឆ្នាំ ២០០២
១៤. ច្បាប់ស្តីពី រយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ឆ្នាំ ១៩៩៩
១៥. សៀវភៅ មូលដ្ឋានគ្រឹះនៃភាពជាអ្នកច្បាប់ របស់សាស្ត្រាចារ្យផ្នែកនីតិឯកជន ឆ្នាំ ២០១៣
១៦. របាយការណ៍ និងឯកសារស្រង់ពីប្រព័ន្ធ Internet។

# លក្ខណៈវិនិច្ឆ័យលើមុខងារផ្លូវច្បាប់នៃលេខាធិការដ្ឋាន រដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត

បណ្ឌិត ***សោ សុគា***

## មូលន័យសង្ខេប

ប្រវត្តិនៃការកកើតប្រព័ន្ធច្បាប់រដ្ឋបាលតុលាការនៅកម្ពុជា ដោយចាប់តាំងពីមុនសម័យអាណានិគមបារាំង (Pre-French Colonial Period) គឺជារបបរាជានិយមដែលព្រះមហាក្សត្រក្តោបអំណាចទាំងអស់ដោយផ្ទាល់តែមួយអង្គឯង ជាពិសេសអំណាចនយោបាយ រដ្ឋបាល និងអំណាចតុលាការផងដែរ។

មកដល់សម័យអាណានិគមបារាំង (French Colonial Period) យើងដឹងហើយថាបារាំងបានធ្វើសន្ធិសញ្ញាមួយនៅឆ្នាំ១៨៦៣ ដាក់ប្រទេសកម្ពុជាឱ្យស្ថិតក្រោមអាណាព្យាបាល (Protectorate) របស់ប្រទេសបារាំង។ ២០ឆ្នាំក្រោយសន្ធិសញ្ញាឆ្នាំ១៨៦៣ គឺនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ សន្ធិសញ្ញាមួយទៀតដែលបារាំងបានបង្ខំឱ្យព្រះបាទនរោត្តមចុះហត្ថលេខាទាំងក្តៅក្រហាយនោះ បានធ្វើឱ្យប្រទេសខ្មែរក្លាយទៅជាប្រទេសមួយស្ថិតនៅក្រោមអាណានិគមបារាំង ថ្វីបើគេសសេរជាផ្លូវការថា (Protectoria) ក៏ដោយពីព្រោះ បារាំងបានដកអំណាចពិតប្រាកដទាំងអស់ចេញពីព្រះមហាក្សត្រខ្មែរ ដោយបានផ្ទេរទៅឱ្យលោក Resident Superieur បារាំងវិញ។ សេនាបតីសភាត្រូវប្រជុំក្រោមអធិបតីភាពរបស់លោក Resident Superieur កិច្ចប្រជុំលែងស្ថិតនៅក្រោមព្រះរាជាធិបតីរបស់ព្រះមហាក្សត្រខ្មែរដូចកាលដើមទៀតឡើយ។

ពីសម័យឯករាជ្យមកដល់ឆ្នាំ១៩៧៥ បារាំងបានកាន់កាប់ប្រទេសខ្មែរជាង ៩០ឆ្នាំ ទើបសុខចិត្តប្រគល់ឱ្យខ្មែរនូវឯករាជ្យភាពជាតិវិញនៅឆ្នាំ១៩៥៣ ដោយសារស្នាព្រះហស្តព្រះបាទនរោត្តមសីហនុ ព្រះមហាក្សត្រខ្មែរ និងដោយសារការរួបរួមសាមគ្គីរបស់ប្រជាពលរដ្ឋខ្មែរប្រកបដោយសេចក្តីប្តេជ្ញាចិត្តយ៉ាងមុតមាំ។ ហើយបារាំងក៏បានដកអាណានិគមចេញមែន ដោយបានបន្សល់នូវការគ្រប់គ្រងរបៀបបារាំងលិខិតស្នាមផ្លូវការច្រើនសសេរជាភាសាបារាំង

របៀបធ្វើការនិងច្បាប់ទាំងឡាយក៏នៅតែទៅតាមបារាំងទាំងអស់ ពីព្រោះជំនាញការ (Experts) ច្រើនតែពួកបារាំង។

នៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជារបបមួយដែលប្រជាពលរដ្ឋទូទៅ ហៅថា របបខ្មែរក្រហម ដោយខ្មែរក្រហមបានដឹកនាំតាមរបៀបផ្តាច់ការឃោរឃៅកាប់សម្លាប់ឥតត្រាប្រណីហួសវិស័យ ដែលប្រជាពលរដ្ឋខ្មែរនឹកស្មានមិនដល់ ចំពោះឯកសារច្បាប់ផ្សេងៗ និងប្រព័ន្ធគ្រប់គ្រងត្រូវលុបបំបាត់ចោលទាំងស្រុង។

រហូតមកដល់ឆ្នាំ១៩៩៣ ដោយមានការជួយជ្រោមជ្រែងពីសហគមន៍អន្តរជាតិដែលប្រជាពលរដ្ឋខ្មែរ ហៅអ៊ុនតាក់ (UNTAC = United Nations Transactional Authorithy of Cambodia)។ ហើយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានចែងអំណាចបីដាច់ពីគ្នា អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ នៅពេលនោះការងារផ្នែករដ្ឋបាលតុលាការពុំទាន់មានភាពល្អប្រសើរនៅឡើយទេ ដោយសារកង្វះធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធនានាត្រូវបានបំផ្លាញរួមទាំងអាគារតុលាការផងដែរ។

ចំពោះលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត ត្រូវបានបង្កើតឡើង ដោយច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងតាមអនុក្រឹត្យលេខ២១ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ រួមទាំងយុត្តិសាស្ត្រសាលាក្តីខ្មែរក្រហមផងដែរ។

ប្រព័ន្ធច្បាប់ដែលនាំឱ្យកើតមាននូវលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត នៅព្រះរាជាណាចក្រកម្ពុជាកើតចេញមកពីប្រភពចម្រុះបែប common law និង civil law ហើយជាពិសេសយកគំរូតាមសាលាក្តីខ្មែរក្រហម ហើយប្រព័ន្ធច្បាប់ដែលនាំឱ្យបង្កើតនូវលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត នៅព្រះរាជាណាចក្រកម្ពុជា មានប្រវត្តិដូចខាងក្រោម៖

ក.ប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាឡឺម៉ង់ដ៏ (systeme romano-germanique) មានប្រទេសបារាំង ប្រទេសអឺរ៉ុបមួយចំនួន ប្រទេសអាមេរិកឡាទីន និងប្រទេសកម្ពុជាជាដើម។ ប្រព័ន្ធច្បាប់នេះគេហៅម្យ៉ាងទៀតថាប្រព័ន្ធដីគោក (systeme continental) ពីព្រោះគេ

ប្រៀបធៀបទៅនឹងប្រព័ន្ធអង់គ្លេសដែលជាប្រទេសលើដីកោះ។ ប្រទេសអ៊ឺរ៉ុប ក្រៅពីអង់គ្លេស នៅលើដីគោក។ គេចែងច្បាប់ជាច្រើនប្រភេទចងក្រងជាក្រុម (Codes) ហើយនិយមប្រើពាក្យច្បាប់មាននិយមន័យដូចគ្នា តាមក្បួនរបស់ពួករ៉ូម៉ាំង និងអាឡឺម៉ង់ដ៏។

ខ.ប្រព័ន្ធច្បាប់ខូម៉នឡូ (systeme common law) មានប្រទេសអង់គ្លេសអៀកឡង់ដ៏ សហរដ្ឋអាមេរិក និងពួកដែលយកព្រះមហាក្សត្រីយានីអង់គ្លេសជាប្រមុខរដ្ឋរបស់ខ្លួន។ល។ ប្រព័ន្ធនេះខុសពីប្រព័ន្ធខាងលើត្រង់មូលដ្ឋានរបស់គេច្រើនចេញពីចៅក្រម តាមប្រពៃណីច្រើនជាងពុំមានប្រភេទច្បាប់ដូចខាងចំណុច (ក) ខាងលើ ហើយពាក្យច្បាប់ក៏ពុំមានន័យដូចគ្នាដែរ ថ្វីបើសព្វថ្ងៃនេះមានការវិវត្តន៍មករកប្រព័ន្ធខាងលើវិញដែរហើយ។

សព្វថ្ងៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត ត្រូវបានបង្កើតឡើងដោយ **ច្បាប់ស្តីពីការរៀប ចំអង្គការតុលាការ** ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និង **អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលតុលាការ** ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលលេខាធិការដ្ឋាននេះមាន ទីតាំងស្ថិតនៅក្នុងតុលាការរាជធានី-ខេត្ត តែម្តងដែលមាន ប្រធានលេខាធិការដ្ឋាន និងអនុប្រធានលេខាធិការដ្ឋាន ព្រមទាំងមានការិយាល័យចំនួនបួនទៀត ចំណុះឱ្យដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន តុលាការ និងព្រះរាជអាជ្ញា។

**ពាក្យគន្លឹះ៖** *យុត្តិធម៌ សាលាក្តីខ្មែរក្រហម យុត្តាធិការ* ។

# ១. សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងការយល់ឃើញនៃទស្សនទានសេរីភាព និងគំនិតជាច្រើនបានផ្តោតលើមាគ៌ាខិតទៅរកនីតិរដ្ឋ និងសង្គមពលរដ្ឋ។ ដោយចេញពីស្ថានភាពទាំងនេះស្ថិតនៅចំពោះមុខរដ្ឋនិងសង្គមបែបទំនើបភារកិច្ចនៃការស្ថាបនា បែបគុណភាពដែលចាំបាច់ធ្វើការវិវឌ្ឍទៅតាមទម្រង់នៃសង្គម ដែលត្រូវបានទទួលស្គាល់នៅលើមូលដ្ឋានច្បាប់។

មូលដ្ឋាននៃការជ្រើសរើសកម្មវត្ថុ និងជំនាញនៃការស្រាវជ្រាវនាបច្ចុប្បន្ននេះបានទាក់ទងដោយផ្ទាល់ជាមួយនឹងប្រធានបទស្រាវជ្រាវ អំពីការជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលតុលាការនៅសាលាដំបូងរាជធានី-ខេត្ត ហើយមានទិសដៅមកលើការបង្កើននីតិរដ្ឋ

នៅព្រះរាជាណាចក្រកម្ពុជា។ គោលបំណងតែមួយ ដែលបានដាក់ចំពោះមុខសង្គមនៅដើមសតវត្សទី២១នេះ ក៏ដូចជានៅចំពោះមុខសង្គមបច្ចុប្បន្ន នៅក្នុងលក្ខខណ្ឌ នៃការកំណត់ភារកិច្ចដំបូងរបស់មន្ត្រីអនុវត្តច្បាប់ សម្រាប់សម្រេចបាននូវតម្លៃយុត្តិធម៌ពិតប្រាកដរបស់ពួកគេ។ ដោយចេញពីទស្សនទានភាពត្រឹមត្រូវតាមច្បាប់នូវបាតុភូត ដែលបានពិនិត្យមើលត្រូវបង្ហាញដោយសកម្មនូវការប្រើប្រាស់បទពិសោធន៍នៃការធ្វើផែនការ តាមបែបលក្ខណៈវិទ្យាសាស្ត្រដែលប្រព្រឹត្តទៅនៅលើមូលដ្ឋានចំណេះដឹងប្រកបដោយវិចារណញ្ញាណពិតគឺ មិនមែនប្រព្រឹត្តទៅនៅលើមូលដ្ឋាននៃទស្សនទុទិដ្ឋិនិយមទេ។

ដោយមានគោលដៅបែបនេះ រាជរដ្ឋាភិបាលបានរៀបចំឱ្យមានក្របខណ្ឌទទួលខុសត្រូវរបស់មន្ត្រីនៅក្នុងលក្ខខណ្ឌនៃការបំពេញភារកិច្ចប្រកបដោយសណ្ដាប់ធ្នាប់ យុត្តិធម៌ និងធានាបាននូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋទាំងការការពារផលប្រយោជន៍ទ្រព្យសម្បត្តិ អាយុជីវិត និងសេចក្ដីថ្លៃថ្នូរជាដើម។ល។

ដោយសារប្រធានបទនៃការសិក្សាស្រាវជ្រាវនេះមានលក្ខណៈជាតម្រូវការបន្ទាន់ ដើម្បីឱ្យគេអាចធ្វើវិសុទ្ធកម្មជំនាញក្នុងការបំពេញភារកិច្ចនិងធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាល តុលាការបានតែក្នុងលក្ខខណ្ឌដែលគេចេះប្រើប្រាស់នូវវិធីសាស្ត្របច្ចេកទេសវិទ្យាសាស្ត្រ គ្រប់គ្រង និងបច្ចេកទេសការងាររដ្ឋបាលឱ្យបានទូលំទូលាយបំផុត ស្របតាមនិយាមនៃការទទួលស្គាល់ជាលក្ខណៈជាតិនិងអន្តរជាតិ។ លក្ខណៈស្មុគស្មាញក្នុងការសិក្សាស្រាវជ្រាវ អាចឱ្យគេធ្វើការវិភាគចំណោទបញ្ហាដែលបានលើកឡើងពាក់ព័ន្ធការប្រើវិទ្យាសាស្ត្រនានារួមគ្នាដូច ជាវិទ្យាសាស្ត្រស្ដីពីធម្មជាតិការងារសាធារណៈនិងបច្ចេកទេស។ ទំនាក់ទំនងជិតស្និទ្ធរវាងវិទ្យាសាស្ត្រទាំងអស់នេះសព្វថ្ងៃនេះអាចធ្វើឱ្យវិទ្យាសាស្ត្រ និងបច្ចេកទេសនានាប្រើប្រាស់បានសម្រាប់គ្រប់ទិសដៅទាំងអស់។

ចុងក្រោយករណីនេះជួយបង្ហាញពីភាពចាំបាច់ដែលត្រូវការ ធ្វើការសិក្សាស្រាវជ្រាវ លើប្រធានបទមួយស្ដីពី **«យុត្តាធិការនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្តនៅព្រះរាជាណាចក្រកម្ពុជា»**។

ហេតុដូច្នេះជាចាំបាច់យើងត្រូវចេះប្រើប្រាស់ប្រភេទវិទ្យាសាស្ត្រដែលបានលើកឡើងឱ្យបានត្រឹមត្រូវនិងស្របតាមកាលៈទេសៈជាក់ស្ដែង ដើម្បីធ្វើជាវិធីសាស្ត្រអនុវត្តសកម្មភាពនានា។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការដោះស្រាយបញ្ហាប្រកបដោយជោគជ័យ នៅក្នុងដំណើរការលេខាធិការដ្ឋានរដ្ឋបាល និងយន្តការអនុវត្ត ច្បាប់នៃសាលាដំបូងរាជធានី-ខេត្ត ប្រព្រឹត្តទៅបានលុះត្រាតែមានការរៀបចំប្រព័ន្ធគ្រប់គ្រងតាមបែបរដ្ឋបាលតម្លាភាពដែលបញ្ហានេះមានទំនាក់ទំនងមិនផ្ដាច់បានជាមួយនឹងបញ្ហាដូចខាងក្រោមៈ

១. លក្ខណៈវិនិច្ឆ័យលើមុខងារផ្លូវច្បាប់នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត ប្រព្រឹត្តទៅយ៉ាងដូចម្ដេច ?

២. បញ្ហាប្រឈម និងតម្រូវការជាក់ស្ដែង ដែលត្រូវការដោះស្រាយមានអ្វីខ្លះ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ មានគោលបំណងបង្ហាញអំពីការបង្កើត និងដំណើការវិវត្តន៍នៃស្ថាប័នសាលាដំបូងរាជធានី-ខេត្ត ជំរុញប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគ្រប់គ្រងដឹកនាំក្នុងស្ថាប័នជំរុញឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការបែងចែកមុខងារភារកិច្ចរបស់មន្ត្រីសាលាដំបូងទៅតាមសមត្ថភាព និងជំនាញឯកទេស ជំរុញឱ្យមានក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ចំពោះកាតព្វកិច្ចរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់ជាងនេះជំរុញឱ្យកាន់តែខ្លាំង ចំពោះការយកចិត្តទុកដាក់ដល់បញ្ហាជីវិត សុខភាព និងសេចក្ដីថ្លៃថ្នូររបស់មន្ត្រីព្រម ទាំងបង្ហាញឱ្យឃើញពីដំណើរការអនុវត្តផ្នែករដ្ឋបាលដែលមានការខ្វះខាត ឬលំបាក ឬក៏ដំណើរការទៅដោយរលូនជានាឱ្យបាននូវនិរន្តភាពប្រសិទ្ធភាព និងសុខដុមនីយកម្មនៃអង្គភាពសាលាជម្រះក្ដី។ ឱ្យបានដឹងផងដែរ អំពីសញ្ញាណទូទៅ និងចេនាសម្ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត ឱ្យស្របតាម ស្មារតី នៃអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង។ និងអំពីការតែងតាំងរបស់ប្រធានលេខាធិការដ្ឋាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានការិយាល័យនីមួយៗ។ ព្រមទាំងអំពីការផ្ទេរការងាររដ្ឋបាល បុគ្គលិកហិរញ្ញវត្ថុពីនាយក

ក្រឡាបញ្ជី/ក្រឡាបញ្ជី ដែលខ្លួនធ្លាប់ទទួលបន្ទុកពីមុនមក ស្ថិតនៅក្រោមប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង វិញ...។ល។

## ១.៤ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ក.ការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវគឺស្ថិតក្នុងក្របខ័ណ្ឌនៃវិទ្យាសាស្ត្រនីតិធម្មនុញ្ញ ដែលកំណត់ពីសិទ្ធិអំណាចក្នុងការ វិនិច្ឆ័យ និងក្របខ័ណ្ឌនៃវិទ្យាសាស្ត្រនីតិរដ្ឋបាលដែលកម្រិតអំពីមុខងារតួនាទីរបស់មន្ត្រីរាជការគ្រប់ លំដាប់ថ្នាក់ ការទទួលខុសត្រូវតាមឋានានុក្រមដែលមានលក្ខណៈភាពជាចំណុះរបស់បុគ្គល។ ក្នុងការសិក្សាបានប្រើប្រាស់ទិន្នន័យជាលាយលក្ខណ៍ដូចជាឯកសារស្នាដៃនិពន្ធកម្រិតជាតិស្នាដៃបរទេសច្បាប់បញ្ញត្តិជាតិ និងលិខិតបទដ្ឋានក្រោមច្បាប់នានា។ លើសពីនេះមានទស្សនាវដ្ដីវិទ្យាសាស្ត្រ កាសែតកោះសន្តិភាព រស្មីកម្ពុជា និងកម្ពុជាថ្មី។ល។

ព្រមទាំងបានសាកសួរមន្ត្រីរដ្ឋបាល ចៅក្រម និងក្នុងលក្ខខណ្ឌនៃការស្រាវជ្រាវច្រើនប្រើប្រាស់ឯកសារ ដែលមានប្រភពពីបណ្ណាដ្ឋានជាតិ ប្រធានតុលាការដែលបានចូលនិវត្តន៍។ បណ្ណាល័យទីស្ដីការគណៈរដ្ឋមន្ត្រី បណ្ណាល័យអង្គការជាតិ និងអន្តរជាតិ បណ្ណាល័យសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ជាពិសេសវិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការសន្តិភាព និងវិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។

### ខ.ការវិភាគទិន្នន័យ

វិធីសាស្ត្រស្រាវជ្រាវដែលគ្រោងប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ គឺបែបគុណវិស័យដែលបានកំណត់ទិសដៅ សម្រាប់ចុះស្រាវជ្រាវប្រមូលឯកសារដែលមានស្រាប់មកវិភាគវាយតម្លៃ ដូចជាលិខិតបទដ្ឋានគតិយុត្ត នានា ដែលមានការពាក់ព័ន្ធក្របខណ្ឌច្បាប់ និងការអនុវត្តកម្លងមក។

### គ.វិសាលភាពនិងដែនកំណត់

ការសិក្សាស្រាវជ្រាវ មានវិសាលភាពលើលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកំពង់ចាមតែប៉ុណ្ណោះ និងមានដែនកំណត់នៅចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។

## ២. រំលឹកទ្រឹស្តី

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវបានបង្កើតឡើងដោយដោយប្រព័ន្ធច្បាប់ចម្រុះមានប្រភពមកពីច្បាប់ common law និង civil law ហើយជាពិសេសយកគំរូតាមសាលាក្តីខ្មែរក្រហម ។

ប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាឡឺម៉ង់ដ៍ (systeme romano-germanique) មានប្រទេសបារាំង ប្រទេសអ៊ឺរ៉ុបមួយចំនួន ប្រទេសអាមេរិកឡាទីន និងប្រទេសកម្ពុជាជាដើម។ប្រព័ន្ធច្បាប់នេះគេហៅម្យ៉ាងទៀតថាប្រព័ន្ធ ដីគោក (systeme continental) ពីព្រោះគេប្រៀបធៀបទៅនឹងប្រព័ន្ធអង់គ្លេសដែលជាប្រទេសលើដីកោះ។ ប្រទេសអ៊ឺរ៉ុបក្រៅពីអង់គ្លេសនៅលើដីគោក។ គេចែងច្បាប់ជាច្រើនប្រភេទចងក្រងជាក្រុម (Codes) ហើយនិយមប្រើពាក្យច្បាប់មាននិយមន័យដូចគ្នា តាមក្បួនរបស់ពួករ៉ូម៉ាំង និងអាឡឺម៉ង់ដ៍។

ប្រព័ន្ធច្បាប់ខូម៉នឡ (systeme common law) មានប្រទេសអង់គ្លេសអៀកឡង់ដ៍ សហរដ្ឋអាមេរិក និងពួកដែលយកព្រះមហាក្សត្រីយានីអង់គ្លេសជាប្រមុខរដ្ឋរបស់ខ្លួន។ល។ ប្រព័ន្ធនេះខុសពីប្រព័ន្ធខាងលើត្រង់មូលដ្ឋានរបស់គេច្រើនចេញពីចៅក្រមតាមប្រពៃណីច្រើនជាងពុំមានប្រភេទច្បាប់ដូចខាងចំណុច (ក) ខាងលើ ហើយពាក្យច្បាប់ក៏ពុំមានន័យដូចគ្នាដែរ ថ្វីបើសព្វថ្ងៃនេះមានការវិវត្តន៍មករកប្រព័ន្ធខាងលើវិញដែរហើយ។

ចំពោះច្បាប់ដែលបង្កើតលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង នៅព្រះរាជាណាចក្រកម្ពុជាមាន ***ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ*** ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ (មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤)។ និងតាម ***អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលតុលាការ*** ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ មានចំនួន១៣ មាត្រា។ ដែលលេខាធិការដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងតុលាការខេត្តក្រុងតែម្តង ដែលមានប្រធានលេខាធិការដ្ឋាន និងអនុប្រធាន លេខាធិការដ្ឋាន ព្រមទាំងមានការិយាល័យចំនួនបួនទៀតចំណុះឱ្យដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានតុលាការ និងព្រះរាជអាជ្ញា។

# ៣. លក្ខណៈវិនិច្ឆ័យលើមុខងារផ្លូវច្បាប់នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង រាជធានី-ខេត្ត

## ៣.១. បញ្ហាប្រឈម

ចំពោះបញ្ហាប្រឈមនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត បានចុះធ្វើការសិក្សាស្រាវជ្រាវទៅលើខេត្ត-ក្រុងចំនួន ០៤មានដូចខាងក្រោម៖

**១.សាលាដំបូងរាជធានីភ្នំពេញ**

ចៅក្រមស៊ើបសួរភាគច្រើនពុំបានកំណត់ថេរវេលាក្នុងដីកាបង្គាប់ឱ្យនាំខ្លួន តាមមាត្រា ១៩០ នៃក្រម នីតិវិធីព្រហ្មទណ្ឌពុំបានចែងអំពីរយៈពេលផុតកំណត់ក្នុងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនទេ ជាហេតុធ្វើឱ្យអ្នកអនុវត្តដីកាពិបាកក្នុងការគំណត់ថាតើដីកាបង្គាប់ឱ្យនាំខ្លួននេះមានសុពលភាពអនុវត្តដល់ថ្ងៃណា ជាគោលការណ៍ច្បាប់ត្រូវអស់សុពលភាពនៅពេលមានកិច្ចនីតិវិធីថ្មីមួយទៀត។ ឧទាហរណ៍ ដូចជាចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ឬដីកាដំណោះស្រាយ នោះដីកាបង្គាប់ឱ្យនាំត្រូវអស់សុពលភាព។ ផ្ទុយមកវិញនៅពេលហួសកិច្ចនីតិវិធីបង្គាប់ឱ្យនាំខ្លួនមន្ត្រីនគរបាលយុត្តិធម៌នៅតែអនុវត្តនៅដីកា ដោយបាននាំខ្លួនមកកាន់ចៅក្រមស៊ើបសួរដដែល ដោយសំណុំរឿងខ្លះចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយរួចហើយ។ ក្នុងករណីនេះវានាំឱ្យប៉ះពាល់ដល់សិទ្ធ និងភាពថ្លៃថ្នូររបស់បុគ្គលព្រមទាំងប៉ះពាល់ទៅដល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

បញ្ហាដែលចៅក្រមស៊ើបសួរពុំបានជូនដំណឹង ទៅតំណាងអយ្យការក្នុងនីតិវិធីបង្ហាញខ្លួនលើកដំបូង និងការពិភាក្សាដេញដោល ករណីដែលមិនបានជូនដំណឹងដូចនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធរបស់តំណាងអយ្យការ ដែលត្រូវធ្វើសេចក្តីសន្និដ្ឋានលើការស្នើសុំឃុំខ្លួន ឬមិនឃុំខ្លួន ក្នុងកំណត់ហេតុដេញដោលចំពោះមុខ ហើយតំណាងអយ្យការពុំបានស្តាប់សេចក្តីថ្លែងការណ៍ និងសំណូមពររបស់ជនជាប់ចោទទាក់ទងនឹងស្ថានភាពផ្សេងៗ។ ឧទាហរណ៍ជនជាប់ចោទជាជនដែលមានជម្ងឺប្រចាំកាយមានកូនច្រើនក្នុងបន្ទុក ហើយដែលបទល្មើសប្រព្រឹត្តមានព្យសនកម្មតិចតួចដល់សង្គម។ ដូចនេះប្រសិនបើចៅក្រមស៊ើបសួរបានជូនដំណឹងទៅដល់តំណាងអយ្យការ តំណាងអយ្យការអាចសន្និដ្ឋានសុំកុំឱ្យឃុំខ្លួនបានមូលហេតុដោយផ្អែកលើស្ថានភាពគ្រួសារ និងការប៉ះពាល់សង្គមមានលក្ខណៈតិចតួច។

បញ្ហាក្នុងការប្រគល់វត្ថុតាងបើកផ្ទះឱ្យម្ចាស់ដើមវិញ តាមគោលការណ៍ច្បាប់តំណាងអយ្យការដែលជាម្ចាស់បណ្ដឹងអាជ្ញាជាអ្នកចុះទៅឃាត់អ្នកប្រព្រឹត្តបទល្មើស និងធ្វើការបិទផ្ទះនោះជាបណ្ដោះអាសន្ន តែក្នុងករណីដែលសំណុំរឿងបញ្ជូនទៅដល់ដំណាក់កាលចៅក្រមស៊ើបសួរ ប្រសិនបើគាត់ស៊ើបសួរក្នុងករណីរកពុំឃើញមានពិរុទ្ធនោះចៅក្រមស៊ើបសួរជាអ្នកមានសមត្ថកិច្ចលើរឿងនេះ។

នីតិវិធីស៊ើបសួរជំនួស អាចអនុវត្តវិធានការនិរន្តរាយឃុំខ្លួនជនត្រូវចោទបានដែរឬទេ ករណីនេះ មានមតិខុសគ្នាដោយមួយចំនួនចង់ឱ្យចៅក្រមដែលចេញវិធានការនិរន្តរាយជាអ្នកឃុំខ្លួន និងមតិខ្លះទៀតចង់ឱ្យចៅក្រមដែលទទួលនូវដីកាស៊ើបសួរជំនួសនោះជាអ្នកឃុំខ្លួនបណ្ដោះអាសន្ន។

ការបញ្ជូនដីកាពីខេត្តនានា នៅតាមខេត្តខ្លះពុំមានអាជ្ញាសាលា ការផ្ញើរតាមប្រៃសណីយ៍មានការយឺតយ៉ាវ។ RI ក្នុងបទល្មើសលហុ ដោយសារតំណាងអយ្យការខ្លះគាត់បានបើកការស៊ើបសួរទៅលើបទល្មើសលហុ តែខ្លះទៀតពុំអនុវត្តដូចនេះទេ។ កំណើនបទល្មើសនានាដែលបានកើតមានឡើងក្នុងសង្គមដូចជាបទល្មើសលួច ឆក់ ប្លន់ និងគ្រឿងញៀន។ អាគារសាលាដំបូងរាជធានីភ្នំពេញ មានទំហំតូចចង្អៀតបើប្រៀបធៀបទៅនឹងចំនួនចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរាជការដែលបម្រើការងារនិងចំនួនប្រជាជនដែលមកទទួលសេវាយុត្តិធម៌។ ចៅក្រមព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីរដ្ឋបាលមានចំនួនតិចមិនទាន់ឆ្លើយតបទៅនឹងទំហំការងារសំណុំរឿងគ្រប់ប្រភេទកើនឡើងខ្លាំង។ ឃ្លាំងវត្ថុតាងមានទំហំតូចចង្អៀតមិនឆ្លើយតបទៅនឹងកំណើនវត្ថុតាង ចាប់យកដែលបង្កការលំបាកស្មុកស្មាញច្រើនដល់ការគ្រប់គ្រងថែរក្សា និងការពារដែលជាហេតុធ្វើឱ្យវត្ថុតាងចាប់យកមួយចំនួនខូចគុណភាព។ ឧបករណ៍បច្ចេកទេស និងសម្ភារៈការិយាល័យមានការខ្វះខាតដែល ថវិការរដ្ឋផ្ដល់ឱ្យមិនគ្រប់គ្រាន់។ ការអនុវត្តនីតិវិធីទារប្រាក់ពិន័យពីទណ្ឌិត (ទណ្ឌិតជាជនក្រីក្រ)។

### ២.សាលាដំបូងខេត្តកំពង់ចាម

ខេត្តកំពង់ចាម មានស្រុកចំនួន០៩ និងក្រុងចំនួន ០១ គឺមានស្រុកខ្លះដាច់ស្រយាល និងមានចម្ងាយផ្លូវឆ្ងាយពិបាក ហេតុដូចនេះការបញ្ជូន និងទទួលពត៌មានអាច

មានការយឺតយ៉ាវ ក៏ដូចជាការបង្វិលដើមដីកាចូលក្នុងសំណុំរឿងពុំទាន់ពេលវេលាប្រហែល ៦០ភាគរយ ដោយសព្វថ្ងៃពុំមានអាជ្ញាសាលា ឬក៏អ្នករត់សំបុត្រទេ ហើយចំពោះការចេញដីកានានា គឺមានដូចជាផ្ញើនៅនឹងប៉ុស្តិ៍យាមនៅមុខតុលាការផ្ទាល់តែម្តង ឬក៏រង់ចាំផ្ញើតាមប្រជាពលរដ្ឋ ដែលមានអាសយដ្ឋានត្រូវនឹងសំបុត្រដែលផ្ញើទៅ ចំពោះដីកាចាប់ ឬដីកានាំគឺផ្ញើទៅស្នងការដ្ឋាន នគរបាលខេត្តកំពង់ចាមផ្ទាល់តែម្តង តាមរយៈប៉ូលីសបញ្ជូនជនល្មើសក្នុងសំណុំរឿងជាក់ស្តែង ហើយពេលខ្លះទៀត បុគ្គលិករដ្ឋបាលជាអ្នកយកទៅផ្ទាល់ ហើយនិងខ្លះទៀតផ្ញើទៅតាមប្រៃសណីយ៍ ដែលក្រឡាបញ្ជីជាអ្នកចេញ សោហ៊ុយផ្ទាល់ខ្លួនក្នុងការផ្ញើ។ ហេតុនេះការប្រឈមដែលសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម កំពុងជួបប្រទះនាពេលបច្ចុប្បន្នមានដូចជាៈ

ការបញ្ជូនដីកា និងការបង្វិលដើមដីកាមានការយឺតយ៉ាវ។ កង្វះធនធានមនុស្ស។ កង្វះថវិកាប្រចាំឆ្នាំសម្រាប់ធ្វើសកម្មភាពផ្សេងៗដូចជាៈ មធ្យោបាយធ្វើដំណើរ សោហ៊ុយក្នុងការចុះស៊ើបអង្កេតសម្ភារៈបរិក្ខារ បច្ចេកទេសមានម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនស្តែននិងម៉ាស៊ីនថតចម្លង សង្ហារឹម មានតុកៅអីជាដើម។ ឃ្លាំងសម្រាប់ដាក់វត្ថុតាងមានចំនួន០២ មានការខ្វះខាត។

មន្ត្រីនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ជាមន្ត្រីថ្មីៗដែលទើបតែប្រលងតាមរយៈការប្រកាស ជ្រើសរើសរបស់ក្រសួងយុត្តិធម៌ឆ្នាំ២០១៦ ពុំទាន់មានបទពិសោធន៍ ចំណែកប្រធានលេខាធិការដ្ឋានរដ្ឋបាលមានតែមួយនាក់ ពុំមានអនុប្រធាន ឬប្រធានការិយាល័យ ជាហេតុនាំឱ្យកកស្ទះនូវសំណុះរឿងនិងសំណុំឯកសារផ្សេងៗមិនបានលឿនរហ័ស។

### ៣. សាលាដំបូងខេត្តបន្ទាយមានជ័យ

ការធ្វើកោសល្យវិច្ច័យផ្សេងៗ ពិសេសទាក់ទិននឹងបទល្មើសគ្រឿងញៀន ត្រូវការពេលវេលាយូរនាំឱ្យប៉ះពាល់ដល់ការឃុំខ្លួនជនត្រូវចោទ និងប៉ះពាល់ដល់ការសម្រេចសេចក្តី។ បញ្ហាស្រាវជ្រាវអត្តសញ្ញាណ (ក្នុងរឿងព្រហ្មទណ្ឌ) ពុំសូវបានលទ្ធផលល្អដូចការចង់បានធ្វើឱ្យពិបាកក្នុងការសម្រេចសេចក្តី។

ការអនុវត្តដីកាឱ្យដំណឹងពីសាលក្រមកំបាំងមុខនៅមានការលំបាកច្រើន ដោយមន្ត្រីនគរបាលយុត្តិធម៌ ពុំបានបញ្ជូនដីកានេះមកតុលាការវិញឱ្យបានគ្រប់ចំនួន ដែលធ្វើឱ្យតុលាការពិបាកក្នុងការបញ្ជាក់ពីសាលក្រម ចូលស្ថាពរចំពោះដើមបណ្តឹង និងកំបាំងមុខជនជាប់ចោទ។ វត្ថុតាងនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរមាន ភាពខុសគ្នាមិនច្បាស់លាស់ ពិបាកក្នុងការសម្រេចសេចក្តី ក្នុងសាលក្រម។

ការបញ្ជូនដីកា និងឯកសារផ្សេងៗការបញ្ជូនដីកាគ្រប់ប្រភេទមានដីកាត្រឡប់មកវិញតិចតួចនិងពេលខ្លះត្រឡប់មកវិញហួសរយៈពេលកំណត់។ សំណុំរឿងព្រហ្មទណ្ឌចាស់ៗពិបាកកោះហៅដីកាផ្សេងៗក្នុងសំណុំរឿងដល់ភាគីដែលពាក់ព័ន្ធព្រោះ លំនៅដ្ឋាន ខ្លះឆ្ងាយដាច់ស្រយាល។ ពិបាកក្នុងការបញ្ជូនដីកាកោះហៅដើមចោទ និងចុងចម្លើយក្នុងសំណុំរឿងរដ្ឋប្បវេណីពីព្រោះភាគច្រើនភាគីគឺជាជនចំណាកស្រុក ឬចាកចេញពីមូលដ្ឋាន (បាត់ខ្លួនតែម្តង)។ មន្ត្រីសាលាដំបូងខេត្តទទួលបន្ទុកការបញ្ជូនដីកាឯកសារផ្សេងៗ របស់សាលាដំបូងនានា សាលាឧទ្ធរណ៍ តុលាការកំពូលដែលបញ្ជូនឱ្យសាមីភាគី គឺពុំមានសោហ៊ុយក្នុងកិច្ចដំណើរការនេះទេ។

ការងារអនុវត្តសាលក្រម ឬសាលដីកា មានផលលំបាកដោយភាគីអ្នកចាញ់ក្តីតែងតែបង្កការរាំងស្ទះ ដោយបង្កើតជាក្រុម និងជាហ្វូងតវ៉ាពេលសមតក្កកិច្ចចុះអនុវត្តសេចក្តីសម្រេចផ្សេងៗ និងមានការអន្តរាគមន៍ពី មន្ត្រីនានានិងមជ្ឈដ្ឋានខាងក្រៅ។

កាងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ កង្វះខាតកំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនថតចម្លង ម៉ាស៊ីនត្រជាក់ ប្រព័ន្ធចុះបញ្ជីសំណុំរឿងក្តីគ្រប់ប្រភេទ។ ខ្វះខាតមធ្យោបាយធ្វើដំណើរនិងបំពេញការងាររដ្ឋបាល និងចំណាត់ ការសំណុំរឿងព្រមទាំងគ្មានដីសម្រាប់ ដាក់វត្ថុតាងដោយសព្វថ្ងៃសាលាដំបូងខេត្តបានជួលដីសម្រាប់ដាក់ទុក វត្ថុតាងមួយចំនួនដូចជារថយន្តនិងម៉ូតូ និងមិនមានដំបូលដែលជាហេតុធ្វើឱ្យ វត្ថុតាងទាំងនោះបាត់បង់គុណ ភាពស្ទើរតែទាំងស្រុង។ ខ្វះអាគាររដ្ឋបាល សម្រាប់មន្ត្រីធ្វើការងារនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងព្រមទាំងខ្វះអាគារស្នាក់នៅសម្រាប់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ដែលមានសុវត្ថិភាពល្អប្រសើ និងបន្ទប់មានសភាពតូចចង្អៀតមិនសមស្របទៅនឹងទំហំការងារនិងមន្ត្រីដែលបម្រើការងារ។ ចំនួនចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី មិនទាន់មានគ្រប់គ្រាន់ឆ្លើយតបទៅ

នឹងតម្រូវការការងារនៅឡើយ និងខ្វះមន្ត្រីសម្រាប់បំពេញការងារនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ព្រមទាំងខ្វះដំណើរការងារអាផ្សាសាលា ដើម្បីសម្រួលក្នុងការងារបញ្ជូន។ ខ្វះថវិការប្រចាំឆ្នាំសម្រាប់ផ្គត់ផ្គង់ដំណើរកិច្ចការរដ្ឋបាល និងកិច្ចការសំណុំរឿង។ ដីកាកោះរបស់សាលាឧទ្ធរណ៍តុលាការកំពូលដែលឱ្យក្រឡាបញ្ជីសាលាដំបូងបញ្ជូនឱ្យសាម៉ីខ្លួនពុំមានសោហ៊ុយ និងពុំទាន់មានលក្ខន្តិកៈក្រឡាបញ្ជី។

**៤. សាលាដំបូងខេត្តស្វាយរៀង**

សាលាដំបូងខេត្តស្វាយរៀងមានការខ្វះខាតក្រឡាបញ្ជី ដោយនៅសាលាដំបូងមានតែចំនួន ០៤រូប ដែលធ្វើការងារជំនាញនៅតាមចៅក្រម ហើយចៅក្រមមានចំនួន ០៨រូប ចំណែកឯក្រឡាបញ្ជីអយ្យការមាន ចំនួន ០២រូប នាំឱ្យចំណាត់ការរឿងក្តីមានការយឺតយ៉ាវ។

ការងារចុះបញ្ជីសំណុំរឿងក្តីតាមបច្ចេកទេសរបស់តុលាការគំរូមិនអាចដំណើរការបានតាមសំណូមពរ ដោយមូលហេតុពុំមានមន្ត្រីចុះបញ្ជីគ្រប់គ្រាន់។ បញ្ហាបណ្តឹងទាក់ទងនិងអត្រានុកូលដ្ឋានកំណើត ពុំត្រូវបានទទួលធ្វើការដោះស្រាយដោយរង់ចាំការណែនាំពីក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ។

ការរៀបចំលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង យឺតយ៉ាវដោយខ្វះធនធានមនុស្ស និងសម្ភារៈបរិក្ខារទាំងស្រុង ពិសេសការគ្រប់គ្រងរដ្ឋបាលហាក់មិនទាន់ឯកភាពគ្នាលើការងារអយ្យការ និងតុលាការ (មិនស្ថិតក្នុងស្ថានភាពច្រកចេញចូលតែមួយ) គឺការគ្រប់គ្រងមានលក្ខណៈដាច់ដោយដុំ។ អនុវត្តដីកាផ្សេងៗក្នុងរឿងព្រហ្មទណ្ឌដោយអង្គភាពនគរបាលយុត្តិធម៌មានការយឺតយ៉ាវ។

## ៣.២. ដំណោះស្រាយ

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត ចំនួន ០៤ ខាងលើធ្វើការដោះស្រាយខាងក្រោម៖

**១. សាលាដំបូងរាជធានីភ្នំពេញ**

ចំពោះការកំណត់ថេរវេលាដីកាបង្គាប់ឱ្យនាំខ្លួន នៅសាលាដំបូងរាជធានីភ្នំពេញបានឯកភាពគ្នា ដោយកំណត់នូវការកំណត់ថេរវេលាកុំឱ្យប៉ះពាល់ដល់ដំណើរការដល់នីតិវិធីស៊ើបសួរដូចជានៅរាជធានីភ្នំពេញកំណត់រយៈពេល៣០ថ្ងៃ និងតាមបណ្តាខេត្តកំណត់រយៈពេល ៦០

ថ្ងៃ។ ដូចនេះនៅពេលមានកិច្ចនីតិវិធីថ្មីដូចជាដីកាបង្គាប់ឱ្យចាប់ខ្លួន ឬក៏ដីកាដំណោះស្រាយនោះនីតិវិធីនៃដីកាបង្គាប់ឱ្យនាំខ្លួននឹងលែងមានអានុភាពអនុវត្តបន្តទៀត។

ចំពោះបញ្ហាចៅក្រមស៊ើបសួរពុំបានជូនដំណឹង ទៅតំណាងអយ្យការចំពោះនីតិវិធីបង្ហាញខ្លួនលើកដំបូង និងនីតិវិធីបង្ហាញខ្លួនភ្លាមក្រោយពីបានពិនិត្យលើចំណុចនេះប្រធានសាលាដំបូងរាជធានីភ្នំពេញបានធ្វើការប្រជុំផ្ទៃក្នុងដែលមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា-រង ក្រឡាបញ្ជី និងមន្ត្រីទាំងអស់នៅសាលាដំបូងរាជធានីភ្នំពេញ ដោយបានកំណត់ត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញាទៅតាមច្បាប់កំណត់ ដើម្បីកុំឱ្យប៉ះពាល់ដល់សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា និងប៉ះពាល់សិទ្ធរបស់ជនជាប់ចោទ។

ចំពោះបញ្ហាប្រគល់វត្ថុតាង (ផ្ទះ) ឱ្យទៅម្ចាស់ដើមវិញ ក្នុងករណីដែលវត្ថុតាងនោះមិនទាន់ប្រគល់ទៅឱ្យម្ចាស់ផ្ទះវិញ ហើយសំណុំរឿងបានបញ្ជូនទៅដល់ដំណាក់កាលចៅក្រមនោះចៅក្រមជាអ្នកមានសមត្ថ-កិច្ចលើរឿងនេះ។

ចំពោះការចេញដីកាស៊ើបសួរជំនួស តើអាចអនុវត្តវិធានការនិរន្តរាយឃុំខ្លួនបានដែរឬទេ ក្នុងករណីនេះចៅក្រមនាទីកន្លែងដែលទទួលបាននូវដីកាស៊ើបសួរជំនួសអាចធ្វើការឃុំខ្លួនបាន។ ហើយចំពោះករណីព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាបទល្មើសលហុនោះ ដោយសារកត្តាបញ្ហាខ្លះសំណុំរឿងពុំទាន់ភាពគ្រប់លក្ខណៈដោយសំណុំរឿងមិនទាន់បានស៊ើបអង្កេតពេញលេញ ដូចនេះត្រូវតែធ្វើការចោទប្រកាន់ (RI) ដើម្បីឱ្យចៅក្រមស៊ើបសួរបន្ថែមទៀត។

និងមានដំណោះស្រាយបន្ថែមទៀតដូចជាបានទទួលនូវកិច្ចសហការល្អប្រសើរពីមន្ត្រីនគរបាលយុត្តិធម៌និងអាជ្ញាធរធ្វើឱ្យសាលាដំបូងរាជធានីភ្នំពេញ សម្រេចបានជោគជ័យក្នុងបេសកកម្មស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីទាំងអស់នៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញសុទ្ធតែជាអ្នកមានវិជ្ជាជីវៈ និងបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ។ សមត្ថភាពយល់ដឹងរបស់ចៅក្រមព្រះរាជអាជ្ញា និងក្រឡាបញ្ជី ត្រូវបានលើកកំពស់បន្ថែមតាមរយៈសិក្ខាសាលានានា។ ចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីទាំងអស់នៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមាន ភាពសាមគ្គីភាពល្អសហការគ្នាធ្វើការងារដោយរលូននិងមានការចូល

រួមយ៉ាងសកម្មពីមន្ត្រីជាប់កិច្ចសន្យា។ មានអាគារល្អសម្រាប់ធ្វើការងារសក្តិសមជាស្ថាប័នតុលាការ និងមានទីតាំងនៅកណ្តាលរាជធានីភ្នំពេញ។ មានជំនឿទុកចិត្តក្នុងការដោះស្រាយរឿងក្តីដូចជារឿងឧក្រិដ្ឋធំៗ ត្រូវបានផ្ទេរសមត្ថកិច្ចពីខេត្តនានាមកសាលាដំបូងរាជធានីភ្នំពេញ ក្នុងនោះមានបទល្មើសព្រៃឈើ បទល្មើសគ្រឿងញៀន និងអំពើពុករលួយជាដើម។

### ២. សាលាដំបូងខេត្តកំពង់ចាម

ចំពោះបញ្ហានូវការបញ្ជូនដីកានៅសាលាដំបូងខេត្តកំពង់ចាមដោយមានការប្រជុំផ្ទៃក្នុងនៅលេខាធិការដ្ឋាន រដ្ឋបាលសាលាដំបូង ប្រធានលេខាធិការដ្ឋានបានចាត់ឱ្យមន្ត្រីលេខាធិការដ្ឋានចំនួន០៣រូប ដោយបែង ចែកភារកិច្ចក្នុងមន្ត្រី០១នាក់ គ្រប់គ្រងលើ០៣ក្រុង ឬស្រុក ធ្វើការបញ្ជូនដីកាចេញនិងដីកាចូលផ្សេងៗ ដូចនេះធ្វើឱ្យមានភាពលឿនរហ័សជាងមុនក្នុងការបញ្ជូនដីកាចេញឬដីកាចូល។

បច្ចុប្បន្នសាលាដំបូងខេត្តកំពង់ចាម កំពុងធ្វើអាគារថ្មីមួយទៀត លើអាគារចាស់ដែលមានស្រាប់ដែល មានចំនួន០៤អាគារ។ ព្រមទាំងធ្វើការជួសជុលដាក់អាគារវត្ថុតាងចាស់ ព្រមទាំងធ្វើអាគារដាក់វត្ថុតាងថ្មីមួយ ទៀតដើម្បីបំពេញឱ្យតម្រូវការវត្ថុតាងក្នុងបទល្មើសកើនឡើង។ចំពោះសោហ៊ុយក្នុងធ្វើដំណើរឬក៏ចុះបេសកកម្មផ្សេងៗ មានការឱ្យជាថ្លៃបេសកកម្មទៅតាមចម្ងាយផ្លូវ ឬក៏រយះពេលទៅបំបេញបេកកម្មនោះ ដែលវាជួយសម្រាលបន្ទុកមួយផ្នែកទៀតដល់មន្ត្រីនៅសាលាដំបូងខេត្តកំពង់ចាមទាំងអស់។ចំណែកសម្ភារៈប្រើប្រាស់ដែលបម្រើឱ្យសេវារបស់ប្រជាពលរដ្ឋដូចជាម៉ាស៊ីនព្រីនម៉ាស៊ីនកំព្យូទ័រ... មន្ត្រីនៅសាលាដំបូងភាគច្រើនប្រហែល ៧០% គឺពួកគាត់ធ្វើការទិញខ្លួនឯកយកមកប្រើប្រាស់ ចំណែកខ្លះទៀតជាការចែកឱ្យរបស់ក្រសួងយុត្តិធម៌ អំណោយអង្គការផ្សេងៗ ព្រមទាំងមួយចំនួនតូចទៀតបានមកពីអំពីវត្ថុតាងនៃបទល្មើសផ្សេងៗ ដែលត្រូវរឹប អូសចូលជារបស់រដ្ឋ។

ព្រមទាំងបានទទួលនូវកិច្ចសហការល្អប្រសើរពីមន្ត្រីនគរបាលយុត្តិធម៌ និងអាជ្ញាធរធ្វើឱ្យសាលាដំបូងខេត្តកំពង់ចាម សម្រេចបានជោគជ័យក្នុងបេសកកម្មស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីទាំងអស់នៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម សុទ្ធតែជាអ្នកមានវិជ្ជាជីវៈនិងបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ។ សមត្ថភាពយល់ដឹងរបស់ចៅក្រមព្រះរាជអាជ្ញានិងក្រឡា បញ្ជីត្រូវបានលើកកំពស់

បន្ថែមតាមរយៈសិក្ខាសាលានានា។ ចៅក្រមព្រះរាជអាជ្ញាក្រឡាបញ្ជី និងមន្ត្រីទាំងអស់ នៅសាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្តកំពង់ចាមមានភាពសាមគ្គីភាពល្អសហការគ្នាធ្វើការងារដោយរលូន និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីជាប់កិច្ចសន្យា។

**៣. សាលាដំបូងខេត្តបន្ទាយមានជ័យ**

ក្នុងករណីសំណាកកោសល្យវិច្ច័យមានការយឺតយ៉ាវ ដំណោះស្រាយនៃនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្រធានលេខាធិការដ្ឋានធ្វើការដាស់តឿនតាមរយៈឡើងទៅសាកសួរដោយផ្ទាល់ ឬក៏តាមរយៈទូរស័ព្ទទៅមន្ទីរអាជ្ញាធរសវនកម្មគ្រឿងញៀនឱ្យបញ្ជូនសំណាកឱ្យលឿន សម្រាប់យកមកវិនិច្ឆ័យលើជន ល្មើសក្នុងករណីគ្រឿងញៀន។

ចំណែកបញ្ហាស្រាវជ្រាវអត្តសញ្ញាណជនល្មើសក្នុងបទល្មើសព្រហ្មទណ្ឌ ដោយបច្ចុប្បន្ន នៅពេលជុំនុំជម្រះក្នុងករណីមានបក្សពួកច្រើនហើយបក្សពួកខ្លះទៀតពុំទាន់ស្គាល់សាវតាជាតិ ចៅក្រមស៊ើបសួរបានអនុវត្ត នូវនីតិវិធីបញ្ជូនជនដែលមានសវតាជាតិទៅជម្រះជាមុនចំណែកជនល្មើសដែលពុំទាន់មានសវតាជាតិគ្រប់គ្រាន់ ចៅក្រមស៊ើបសួរនៅធ្វើការអនុវត្តនីតិវិធីស៊ើបសួរបន្តទៀត។

ចំណែកការឱ្យដំណឹងពីសាលក្រមកំបាំងមុខទៅភាគីណាមួយវិញ ពិបាកក្នុងការបញ្ជាក់សាលក្រមស្ថាពរ ករណីនេះចៅក្រមកំពុងអនុវត្តតាមនីតិវិធីដូចជាជូនដំណឹងតាមទូរស័ព្ទ ឬតាមសារពត៌មានផ្សេងៗ ឬក៏តាមនីតិវិធីផ្សេងៗទៀតដែលអាចឱ្យភាគីបានដឹងអំពីសាលក្រមកំបាំងមុខនេះ។

ចំពោះការងារអនុវត្តសាលក្រមប្រជាពលរដ្ឋតែងមានការប្រមូលផ្តុំតវ៉ា ដោយសារករណីនេះប្រជាពលរដ្ឋគាត់ពុំសូវបានយល់ដឹងអំពីច្បាប់ដូចនេះមន្ត្រីដែលជាអ្នកអនុវត្តច្បាប់ត្រូវធ្វើការពន្យល់ទៅកាន់ពួកគាត់ឱ្យ បានយល់ឱ្យមានការព្រមព្រៀងគ្នាជាមុនសិន។

ព្រមទាំងមានដំណោះស្រាយបន្ថែមទៀតដូចជាចៅក្រមព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងក្រឡាបញ្ជីបុគ្គលិករដ្ឋបាល បុគ្គលិកជាប់កិច្ចសន្យា អ្នកជំនួយការអនុវត្ត ការងារដោយស្មារតីទទួលខុសត្រូវខ្ពស់អភិវឌ្ឍន៍ សមត្ថភាពកាន់តែមានភាពប្រសើរឡើង និងមានសាមគ្គីភាពឯកភាពផ្ទៃក្នុងរឹងមាំ។

ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងបច្ចេកទេសកុំព្យូទ័រ ក្នុងកិច្ចការរដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ និងកិច្ចការសំណុំរឿងធ្វើឱ្យការងារមានភាពងាយស្រួលជាងមុន។

មន្ត្រីសាលាដំបូង និងអយ្យការអមសាលាដំបូងមានទំនាក់ទំនង និងផ្តល់កិច្ចសហការគ្នាល្អជាមួយសាលាខេត្ត នគរបាលយុត្តិធម៌ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ព្រមទាំងមន្ត្រីរាជការមន្ទីរអង្គភាពជុំវិញខេត្ត។ ប្រជាពលរដ្ឋកាន់តែមានជំនឿទុកចិត្តលើប្រព័ន្ធតុលាការ។

ការអនុវត្តការងារបច្ចេកទេសសំណុំរឿងមានភាពងាយស្រួល និងរលូនដោយថ្នាក់ដឹកនាំសាលាដំបូង និងអយ្យការអមសាលាដំបូង បានធ្វើកិច្ចប្រជុំបណ្តុះបណ្តាលអំពីវិស័យច្បាប់ និងនីតិវិធីការងារបច្ចេកទេសនិង ក្រមសីលធម៌វិជ្ជាជីវៈ ដល់មន្ត្រីថ្នាក់ក្រោមជាប់ជាប្រចាំ។

ចេះពិគ្រោះយោបលគ្នាក្នុងនីតិវិធីចាត់ការរឿងក្តី ដើម្បីឱ្យមានភាពត្រឹមត្រូវ និងបានសុក្រឹតភាព។ មានភាពរីកចម្រើនក្នុងការងារ ពិសេសការងាររដ្ឋបាលរៀបចំឱ្យមានសណ្តាប់-ធ្នាប់ល្អ។ មានកិច្ចសហប្រតិបត្តិការផ្ទៃ ក្នុងនិងមានទំនាក់ទំនងល្អជាមួយស្ថាប័នដែលជាប់ពាក់ព័ន្ធ សំដៅផ្តល់នូវយុត្តិធម៌ជូនភាគីនៃរឿងក្តី។ មានដំណើរការរលូនសម្រាប់ការអនុវត្តនីតិវិធីច្បាប់ និងចំណាត់ការសំណុំរឿង។

### ៤. សាលាដំបូងខេត្តស្វាយរៀង

ចំពោះបញ្ហាខ្វះខាតមន្ត្រីធ្វើការប្រធានលេខាធិការដ្ឋានរដ្ឋបាល បានធ្វើការស្នើសុំមន្ត្រីបន្ថែមទៀតទៅកាន់ក្រសួងយុត្តិធម៌។ ព្រមទាំងបន្តការរៀបចំដំណើរការលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឱ្យបានល្អប្រសើរជាងមុនតាមលក្ខណៈជាក់ស្តែងបន្ថែមទៀត។ ជំរុញឱ្យចំណាត់ការលើរឿងក្តីទាំងសំណុំរឿងព្រហ្មទណ្ឌសំណុំ រឿងរដ្ឋប្បវេណី សំណុំរឿងនៅអយ្យការ រឿងក្តីអនុវត្តដោយបង្ខំ និងការអនុវត្តទណ្ឌកម្មព្រហ្មទណ្ឌ តាមអំណាចនៃសេចក្តីសម្រេចស្ថាពរទាំងអស់ឱ្យបានត្រឹមត្រូវតាមច្បាប់ និងឱ្យទាន់ពេលវេលា។ ជំរុញឱ្យចំណាត់ការរឿងក្តីដោយផ្តល់នូវអាទិភាពចាត់ការឱ្យបានឆាប់ទាន់ពេលវេលាលើសំណុំរឿងព្រហ្មទណ្ឌ ដែលទាក់ទិនកុមារ និងស្ត្រី។ ជំរុញឱ្យចៅក្រមអសនៈ និងចៅក្រមអយ្យការ ក្រឡាបញ្ជី មន្ត្រីរដ្ឋបាលសាលាដំបូង និងអយ្យការទាំងអស់ឱ្យលើកកម្ពស់សមត្ថភាពយល់ដឹងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ វិន័យការងារឱ្យបានត្រឹមត្រូវ និងស្វែងយល់ឱ្យបានស៊ីជម្រៅបន្ថែមទៀតនូវរាល់អត្ថបទច្បាប់ ទាក់ទិនវិស័យយុត្តិធម៌ ដើម្បីធានាដល់ការអនុវត្តឱ្យបានត្រឹមត្រូវ។ ចុះពិនិត្យបញ្ជី

ចុះបណ្ដឹង បញ្ជីឃាត់ខ្លួននៅអង្គភាពនគរបាលយុត្តិធម៌ និងចុះត្រួតពិនិត្យប្រចាំខែដល់ពន្ធនាគារដោយចៅក្រមអយ្យការ។

### ៣.៣. តម្រូវការជាក់ស្តែង

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកំពង់ចាម និងលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ មានតម្រូវការជាក់ស្ដែងប្រហាក់ប្រហែលគ្នា ដូចជាថវិកាពុំទាន់ធានាបាននូវតម្រូវការជាក់ស្ដែង និងចាំបាច់មួយចំនួនដូចជាសោហ៊ុយស៊ើបសួរស៊ើប អង្កេត ប្រេងឥន្ធនៈ សម្ភារៈពត៌មានវិទ្យា សម្ភារៈការិយាល័យ សង្ហារឹម អគ្គិសនី។ ដំណើរការការងារមានការកើនឡើង ចំណាយក៏កាន់តែច្រើនដែរ។

ចំណែកឯលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្វាយរៀងមានតម្រូវការជាក់ស្ដែង ដូចជា សុំផ្តល់រូបមន្ត និងសៀវភៅរូបមន្តប្រើប្រាស់សម្រាប់អនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី ក៏ដូចជារូបមន្តប្រើប្រាស់សម្រាប់អនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងកិច្ចការតុលាការ និងអយ្យការ។ សុំជួយអន្តរាគមន៍ជូនក្រសួងហិរញ្ញវត្ថុដើម្បី បន្ថែមថវិកាសម្រាប់សាលាដំបូងរាជធានី-ខេត្ត ឱ្យបានសមស្របតាមតម្រូវការ និងតាមភាពចាំបាច់។ ខ្វះខាតវត្ថុតាងឃ្លាំង, ឃ្លាំងរក្សាទុកសំណុំរឿង និងសម្ភារះបរិក្ខារ។ ពង្រីកឃ្លាំង និងស្វែងរកដំណោះស្រាយលក់ឡាយឡុង វត្ថុចាប់យកឱ្យឆាប់។ កង្វះខាតក្រឡបញ្ជី និងមន្ត្រីរដ្ឋបាលជាមន្ត្រីជាប់កិច្ចសន្យា។ សាលសវនាការជា សាលប្រជុំឃ្លាំងដាក់វត្ថុតាង និងបរិក្ខារ កង្វះមធ្យោបាយសម្រាប់ធ្វើការស៊ើបអង្កេត។ ជ្រើសរើសក្រឡាបញ្ជីស្នើសុំក្រសួងជ្រើសយកមន្ត្រីដែលមានស្រុកកំណើត និងទីលំនៅក្នុងតំបន់ ស្នើសុំក្រសួងគិតគូរអំពីការសាងសង់អាគារ។ សូមជួយអន្តរាគមន៍បន្ថែមក្របខ័ណ្ឌបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារលិខិតស្នាមរដ្ឋបាល ដីកា សាលក្រមជាដើម។

### ៣.៤ យុទ្ធសាស្ត្ររួម

និយាយជារួមមក ការអនុវត្តរដ្ឋបាលនៅក្នុងប្រព័ន្ធតុលាការកម្ពុជានៅមានកំរិតនៅឡើយ ពុំទាន់ឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយទេ ដោយសារតែព្រះរាជាណាចក្រកម្ពុជា ត្រូវបានញាំញីដោយភ្លើងសង្គ្រាមចាប់តាំងពីសង្គ្រាមលោកលើកទី២ ហើយ

ត្រូវបិទបញ្ចប់ទំព័រខ្មៅងងឹត នៅថ្ងៃក្រោយរំដោះ ០៧ មករា ឆ្នាំ១៩៧៩ ដែលប្រព័ន្ធរដ្ឋបាលតុលាការនៅកម្ពុជាត្រូវបំផ្លាញទាំងស្រុង។ ហើយសព្វថ្ងៃការអនុវត្តរដ្ឋបាលនៅតុលាការកម្ពុជាឃើញថាមានភាពប្រសើរឡើងជាលំដាប់ ដោយបានផ្តោតលើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ អនុក្រឹតស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងព្រមទាំង សេចក្តីត្រូវការសម្រាប់អនុក្រឹត្យ និងសេចក្តីណែនាំផ្សេងទៀត ដើម្បីរដ្ឋបាលតុលាការ។ បញ្ហាផ្សេងៗដែលកើត មានឡើងនៅគ្រប់សាលាដំបូងរាជធានីខេត្ត-ក្រុងរួមមានដំណោះស្រាយព្រមទាំងសេចក្តីត្រូវការសម្រាប់ពង្រីកបន្ថែមទៀត និងបង្កើនការប្រើប្រាស់និងមធ្យោបាយងាយស្រួលក្នុងការ ទទួលបាននូវមូលដ្ឋានទិន្នន័យនៃរឿងក្តី។ បញ្ហាសំខាន់យ៉ាងខ្លាំងទាំងនេះ នឹងត្រូវពិភាក្សាឱ្យស៊ីជម្រៅថែមទៀតជាមួយក្រសួងយុត្តិធម៌ដើម្បីវិភាគថាតើបញ្ហាទាំងនេះអាចនឹងត្រូវអភិវឌ្ឍន៍បន្ថែមដោយរបៀបណា។

ដោយហេតុថាប្រព័ន្ធតុលាការឯករាជ្យ ជាប្រព័ន្ធតុលាការមួយដែលការពារលទ្ធិប្រជាធិបតេយ្យ និង ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋគឺនៅពេលណាដែលមានការអនុវត្តច្បាប់ និងការប្រតិបត្តិរាល់វិធានការគតិយុត្តទាំងអស់ ហើយត្រូវបានគ្រប់គ្រងដោយចៅក្រមឯករាជ្យប៉ុណ្ណោះ។ តម្លាភាពរបស់រាជរដ្ឋាភិបាលក្នុងការជ្រើសតាំងមិនអាចសម្រេចបានឡើយនៅពេលណាដែលសកម្មភាពរបស់ខ្លួនមិនបានត្រូវពិនិត្យមើលភាពស្របច្បាប់ ដោយស្ថាប័នមួយដែលមិនបានស្ថិតនៅក្រោមឥទ្ធិពលរបស់សាខានីតិប្រតិបត្តិរបស់ខ្លួនឯងទេនោះ។ ដូច្នេះគេត្រូវអនុវត្តគោលការណ៍នៃការបែងចែកអំណាច ដោយភាពតឹងរឹងដាច់ខាតទៅលើទំនាក់ទំនងរវាង អំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។

ដូច្នេះតាមរយៈនេះគប្បីចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីលេខាធិការដ្ឋានរដ្ឋបាល ត្រូវទទួលនូវការបង្ហាត់បង្ហាញបន្ថែមទៀត តាមរយៈការចូលរួមទៅរៀនវគ្គខ្លីៗអំពីនីតិវិធីក្នុងការអនុវត្តនៅក្នុងស្ថាប័នតុលាការ ឬតាមរយៈសិក្ខាសាលាដែលរៀបចំដោយក្រសួងយុត្តិធម៌ រៀបចំដោយអង្គការដែលជាដៃគូរបស់រាជរដ្ឋាភិបាល និងមិនមែនដៃគូរផ្សេងទៀត។

ចំពោះកង្វះខាតថវិការ ឬតម្រូវការដាក់ស្តែង គប្បីសាលាដំបូងនីមួយៗ ធ្វើការគ្រប់គ្រងលើការទទួលប្រាក់ចំណូលពន្ធឱ្យបានត្រឹមត្រូវ តាមការកំណត់របស់ច្បាប់ ឬបទដ្ឋានគតិយុត្តិ

ផ្សេងទៀត ព្រមទាំងស្នើសុំប្រាក់ពន្ធដែលទទួលបាននោះ មកបម្រើការងារឱ្យស្ថាប័នសាលាដំបូងនីមួយៗវិញ។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ៤.១. សន្និដ្ឋាន

ដោយបច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌បានបង្កើតឱ្យមាន *ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ* ចុះថ្ងៃ ទី១៦ ខែកក្កដា ឆ្នាំ២០១៤ និង ***អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលសាលា ដំបូង*** ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥។ ក្រសួងយុត្តិធម៌ក៏បានរៀបចំបទដ្ឋានគតិយុត្តិក្រោមច្បាប់មួយចំនួន ដើម្បីគាំទ្រដល់ដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការជាពិសេសអនុក្រឹត្យពាក់ព័ន្ធ និងការរៀបចំ អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី។

ការដោះស្រាយបញ្ហាប្រកបដោយជោគជ័យស្របតាមដំណើរការរដ្ឋបាលតុលាការ និងនីតិវិធីដែលមានចែងនៅក្នុងច្បាប់អាចប្រព្រឹត្តទៅបានដោយជោគជ័យតែក្នុងលក្ខខណ្ឌចាំបាច់ដែលថាគេត្រូវពិចារណាព្រឹត្តិការណ៍នានានៃការងារគ្រប់គ្រងឱ្យបានពេញលេញគ្រប់ជ្រុងជ្រោយ គឺមិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការធ្វើឱ្យប្រសើរឡើងនូវអត្តសញ្ញាណកម្មនានា និងការកសាងផែនការ។

ដោយហេតុថាប្រព័ន្ធតុលាការឯករាជ្យ គឺជាប្រព័ន្ធតុលាការមួយ ដែលការពារលទ្ធិ-ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ គឺនៅពេលណាដែលមានការអនុវត្តន៍ច្បាប់ និងការប្រតិបត្តិរាល់វិធានការគតិយុត្តទាំងអស់ ហើយត្រូវបានគ្រប់គ្រងដោយចៅក្រមឯករាជ្យប៉ុណ្ណោះ។ តម្លាភាពរបស់រាជរដ្ឋាភិបាលក្នុងការជ្រើសតាំងមិនអាចសម្រេចបានឡើយ នៅពេលណាដែលសកម្មភាពរបស់ខ្លួន មិនត្រូវបានពិនិត្យមើល ភាពស្របច្បាប់ ដោយស្ថាប័នមួយដែលមិនបានស្ថិតនៅក្រោមឥទ្ធិពលរបស់សាខានីតិប្រតិបត្តិខ្លួនឯងទេនោះ។ ដូច្នេះគេត្រូវអនុវត្តគោលការណ៍នៃការបែងចែកអំណាចដោយភាពតឹងរឹងដាច់ខាត ទៅលើទំនាក់ទំនងរវាង អំណាចតុលាការ និងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។

យើងត្រូវចងចាំទុកជានិច្ចថា នៅពេលដែលពិនិត្យមើលគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធតុលាការឯករាជ្យ និងមិនលំអៀងមួយ និងផលជាក់លាក់មួយចំនួនរបស់គោលការណ៍

នេះនៅក្នុងប្រទេសកម្ពុជា។ យើងក៏ត្រូវតែពិចារណាទៅលើកត្តាពីរទៀត ដែលធ្វើឱ្យខ្សោយដល់ឯករាជ្យភាពរបស់ចៅក្រម នៅពេលដែលយើងនិយាយអំពីឯករាជ្យភាពរបស់តុលាការនៅប្រទេសកម្ពុជាគឺ៖

ដោយសារប្រាក់បៀវត្សរ៍ចៅក្រមមិនគ្រប់គ្រាន់ ប្រព័ន្ធតុលាការបច្ចុប្បន្ន ត្រូវទទួលរងគ្រោះដោយសារអំពើពុករលួយ ដែលត្រូវបានដកស្រង់នៅក្នុងរបាយការណ៍ស្តីពីសិទ្ធិមនុស្សជាច្រើនរាប់បញ្ចូលទាំងរបាយការណ៍ នៃអ្នកតំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផង។

លើសពីនេះ ចៅក្រមភាគច្រើននៃចៅក្រមទាំងអស់នេះ មិនបានទទួលការបណ្តុះ-បណ្តាលផ្នែកច្បាប់ត្រឹមត្រូវហើយជួបប្រទះកង្វះខាតការបណ្តុះបណ្តាលនិងជំនាញ ពីព្រោះពួកគេត្រូវបានជ្រើសរើស និងតែងតាំងយ៉ាងឆាប់រហ័សភ្លាមៗបន្ទាប់ពីរបបផ្តាច់ការប្រល័យពូជសាសន៍បានសម្លាប់សមាជិកនៃអាជីពអ្នកច្បាប់ស្ទើរតែទាំងអស់។

ប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា គឺជាប្រព័ន្ធមួយដែលនៅមានលក្ខណៈទន់ខ្សោយ និងមានលក្ខណៈខ្វះចន្លោះច្រើននៃទំនាក់ទំនងពីស្ថាប័នមួយទៅស្ថាប័នមួយទៀត។ ហើយនីតិវិធីនៃការអនុវត្តកន្លងមក គឺជួបប្រទះនូវឧបសគ្គជាពិសេសគឺក្នុងពេលអនុវត្តសាលក្រម ដែលខ្លះបានឈានដល់អំពើហិង្សា គឺការអនុវត្តពុំសូវមានប្រសិទ្ធភាព។ ទាំងនេះគឺបង្ហាញឱ្យឃើញពីដំណើរការនៃប្រព័ន្ធតុលាការបច្ចុប្បន្ន គឺមានសភាពយឺតយ៉ាវដោយទទួលរងនូវឥទ្ធិពលយ៉ាងខ្លាំងពីការអនុវត្តច្បាប់ ដូចជាការទទួលព័ត៌មានខុស និងការរំលោភលើនីតិវិធីជាដើម។

គ្រប់បញ្ហាលំបាកស្មុគស្មាញសុទ្ធតែបានរាជរដ្ឋាភិបាល ក្រសួងយុត្តិធម៌ តុលាការកំពូល ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអាជ្ញាធរខេត្ត ជួយដោះស្រាយភ្លាមៗ ធ្វើឱ្យមានការកែទម្រង់នៅសាលាដំបូងបានទទួលលទ្ធផលល្អ និងសម្រេចទាន់ចិត្ត។

### ៤-២ អនុសាសន៍

ដោយហេតុថាការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ជាការងារចាំបាច់ដែលត្រូវធានានិរន្តភាព ប្រសិទ្ធភាព ក្រសួងយុត្តិធម៌បាន

រៀបចំសំណើរតែងតាំងឱ្យមានប្រធាន លេខាធិការដ្ឋាន ០១រូប នៅគ្រប់រាជធានីខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែកន្លងមកលេខាធិការដ្ឋាន រដ្ឋបាលសាលាដំបូង នៅពុំទាន់អាចរៀបចំ និងដំណើរការបានល្អនៅឡើយ ដែលធ្វើឱ្យមានការរាំងស្ទះដល់ប្រសិទ្ធភាពនៃការរៀបចំប្រព័ន្ធរដ្ឋបាលរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងស្របតាម *ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ* និង*អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលតុលាការ*។

ដើម្បីឱ្យប្រព័ន្ធយុត្តិធម៌មានដំណើរការទៅបានល្អប្រសើរ ប្រកបដោយជោគជ័យក្នុងកិច្ចអភិវឌ្ឍប្រទេសជាតិ និងក្នុងគោលបំណងឱ្យប្រព័ន្ធតុលាការកម្ពុជាក្លាយជាស្ថាប័នមួយឯករាជ្យពិត ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ នោះគួរតែមានការយកចិត្តទុកដាក់លើលក្ខខណ្ឌដូចតទៅ៖ ជម្រុញប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ ដែលចែងថាចៅក្រមតុលាការត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រម ដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ សុចរិតមានបទពិសោធន៍ក្នុងការងារជំនាញ។ ជម្រុញការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រព័ន្ធតុលាការតាមជំនាញ និងវិជ្ជាជីវៈបច្ចេកទេសច្បាស់លាស់។ ជម្រុញប្រសិទ្ធភាពអនុវត្តគោលការណ៍សិទ្ធបុគ្គល (ក្នុងកម្រិត នីតិរដ្ឋ) ជនទាំងនេះមានសិទ្ធិទទួលនូវដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងត្រូវមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួនហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ចៅក្រមត្រូវមានកាតព្វកិច្ចធានានូវឯករាជ្យភាព និងអនាគតឱ្យបានរឹងមាំ។ ផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរជាពិសេស ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋបានចូលរួមស្តាប់ក្នុងពេលបើកសវនការ។ ធ្វើឱ្យប្រសើរនូវគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ។ បង្កើតតុលាការពាណិជ្ជកម្មដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និងពាណិជ្ជកម្ម ព្រមទាំងបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ បង្កើតតុលាការរដ្ឋបាលដើម្បីដោះស្រាយវិវាទ រដ្ឋបាលនិងរដ្ឋបាលសាធារណៈ។ បង្កើតតុលាការការងារ ដើម្បីដោះស្រាយវិវាទការងារ។ ផ្តល់ប្រាក់បៀវត្សរ៍ឱ្យចៅក្រមគ្រប់គ្រាន់ចៀសវាងអំពើពុករលួយ។

អាស្រ័យហេតុនេះ ដើម្បីជានាឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និរន្តរភាព និងសុខដុមនីយកម្មនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គប្បីអនុវត្តដូចតទៅៈ រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋ បាលសាលាដំបូង ត្រូវរៀបចំឱ្យបានសមស្របតាមស្មារតីស្ដីពីការរៀបចំអង្គការតុលាការ និងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលតុលាការ ឱ្យបានឆាប់រហ័ស។ គ្រប់នាយកក្រឡា បញ្ជី និងក្រឡាបញ្ជី ត្រូវផ្ទេរការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ដែលខ្លួនធ្លាប់ទទួលបន្ទុកពីមុនមកឱ្យ ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងដើម្បីអនុវត្តបានស្របតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និង អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលតុលាការ។ មន្ត្រីរដ្ឋបាលនិងបុគ្គលិកអណ្ដែតទាំងអស់ ដែលបម្រើការងារនៅសាលាដំបូង ត្រូវដាក់ឱ្យស្ថិតនៅក្រោមការសម្របសម្រួល និងគ្រប់គ្រងរបស់អង្គភាពរដ្ឋបាលសាលាជម្រះក្ដី។ ប្រធានលេខាធិការដ្ឋានរដ្ឋបាលត្រូវបង្កើនកិច្ចសហការ និងសម្របសម្រួលដើម្បីរៀបចំឱ្យលេខាធិការដ្ឋានរដ្ឋបាល មានកិច្ចដំណើរការល្អ ហើយក្នុងករណីចាំបាច់ត្រូវរាយការណ៍ទៅប្រធានតុលាការ ឬក៏ព្រះរាជអាជ្ញា។

# គន្ថនិទ្ទេស

## ក.ឯកសារច្បាប់ជាតិ និងអន្តរជាតិ

១- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២- ច្បាប់ លិខិតបទដ្ឋានរបស់ព្រះរាជាណាចក្រកម្ពុជា

៣- ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦

៤- ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩

៥- ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧

៦- ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

៧- ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៦

៨- ក្រសួងយុត្តិធម៌/ប្រជុំអត្ថបទច្បាប់លេខ២ *ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនិងអយ្យការ*

៩- ច្បាប់ស្តីពី*ការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី*មាត្រា១៨ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩៣

១០- ច្បាប់ស្តីពី*ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ*

១១- ក្រសួងយុត្តិធម៌ *ក្បួននីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧*

១២- អនុក្រឹត្យស្តីពី*ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌*លេខ២៤០ អ.ន.ក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤

១៣- អនុក្រឹត្យស្តីពី*ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឆ្នាំ២០១៥*

១៤- រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ១៩/អនក្រ.បក ស្តីពី*ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌* ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០

១៥- អនុក្រឹត្យស្តីពី*ការបង្កើតនាយកដ្ឋានរបស់ក្រសួងយុត្តិធម៌*លេខ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០

## ខ.ឯកសារអ្នកនិពន្ធ

១៦- កំណត់ហេតុរបស់ ជីវ តាខ្វាន់ *អំពីប្រពៃណីនៃអ្នកស្រុកចេនឡា* (អត្ថបទកែប្រែពីឯកសារដើមជាភាសាចិនឆ្នាំ១៩៧៣)

១៧- *តុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ* សេចក្តីដកស្រង់សាលក្រមព្រហ្មទណ្ឌលេខ១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៨០

១៨- *របាយការណ៍របស់តុលាការរាជធានីភ្នំពេញឆ្នាំ២០១១*

១៩- *របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់សាលាដំបូងរាជធានីភ្នំពេញឆ្នាំ២០១៦*

២០- របាយការណ៍ស្តីពី*សភាពការទូទាំងប្រទេស និងទិសដៅកំណែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ប្រព័ន្ធយុត្តិធម៌* ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២

២១- *ប្រវត្តិស្ថាប័នអយ្យការ២០០៧*

២២- ឯកសារក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ឆ្នាំ២០០២

២៣- *សៀវភៅស្ថាប័នយុត្តាធិការ*របស់សាកលវិទ្យាល័យបៀលប្រាយ

២៤- របាយការណ៍សន្និបាតសរុបប្រចាំឆ្នាំរបស់សាលាដំបូងខេត្តកំពង់ចាមឆ្នាំ២០១៦

២៥- ផែនការណ៍យុទ្ធសាស្រ្តថវិការរបស់សាលាដំបូងខេត្តកំពង់ចាមឆ្នាំ២០១៦-២០១៨

២៦- *ដីកាសម្រេចលេខ២៣៣៦រប/១៥*ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ចាម

២៧- *របាយការណ៍របស់សាលាដំបូងខេត្តកំពង់ចាមលេខ១៧៣៦រប/១៦* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦

២៨- តារាងកម្មវិធីសវនាការរបស់សាលាដំបូងខេត្តកំពង់ចាមឆ្នាំ២០១៥

២៩- តារាងកម្មវិធីបែងចែកវេនឈប់សម្រាកឆ្នាំ២០១៦

៣០- របាយការណ៍បូកសរុបលទ្ធផលការងាររបស់សាលាដំបូងខេត្តស្វាយរៀងឆ្នាំ២០១៦

៣១- *របាយការណ៍បូកសរុបលទ្ធផលការងារលេខ២៣០១* ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ

៣២- កេរដំណែលរបស់សលាក្តីខ្មែរក្រហម និងបច្ចេកទេសការងារក្នុងវិស័យច្បាប់ឆ្នាំ ២០១២ របស់លោក មេធាវី **នី ចាន់ឌី**

# បុព្វហេតុបង្កើតឱ្យមានជម្លោះ
# នៅប្រជុំកោះស្ព្រាតលីនៃតំបន់សមុទ្រចិនខាងត្បូង

*បណ្ឌិត* ***តាំង សុខទី***

## មូលន័យសង្ខេប


តំបន់ឈូងសមុទ្រចិនខាងត្បូង រួមមានប្រជុំកោះធំៗពីរ គឺប្រជុំកោះប៉ារ៉ាសែល (Paracel Islands) និងប្រជុំកោះស្ព្រាតលី (Spratly Islands)។ តំបន់ប្រជុំកោះស្ព្រាតលីជាតំបន់សំបូរទៅដោយត្រី កំណាប់ប្រេង និងឧស្ម័នដ៏មហាសាល។ ប្រជុំកោះស្ព្រាតលី គឺជាតំបន់ដែលមានជម្លោះពីក្នុងចំណោមប្រទេសរួមមាន ប្រទេសចិន កោះតៃវ៉ាន់ វៀតណាម ហ្វីលីពីន ម៉ាឡេស៊ី និងប្រ៊ុយណេ សារតែប្រទេសពាក់ព័ន្ធនឹងជម្លោះ បាន**ប្រកាន់យកមូលដ្ឋានរៀងៗខ្លួន។ ប្រទេសចិន និងវៀតណាម បានផ្អែកតាមកត្តាប្រវត្តិសាស្ត្រ** ចំណែកឯប្រទេសហ្វីលីពីន ម៉ាឡេស៊ី និងប្រ៊ុយណេ បានផ្អែកតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ (UNCLOS)។

ដោយសារតែជម្លោះពាក់ព័ន្ធនឹងសមាជិកអាស៊ាន ដូច្នេះ អាស៊ាន ដើរតួនាទីដ៏មានសារៈសំខាន់ក្នុងការសម្របសម្រួលជម្លោះ ដោយផ្អែកតាមសេចក្តីប្រកាសនៃក្រមប្រតិបត្តិគ្រប់ភាគីជម្លោះនៅតំបន់សមុទ្រចិនខាងត្បូងឆ្នាំ២០០២ (2002 Declaration of Conduct in the South China Sea-DoC) និងក្របខណ្ឌនៃក្រមប្រតិបត្តិ (The Framework of Code of Conduct-CoC) ដែលអាស៊ាន-ចិន ទើបតែបានអនុម័តឡើងកាលពីថ្ងៃ៦ ខែសីហា ឆ្នាំ២០១៧។

ថ្វីត្បិតតែគ្រប់ភាគីជម្លោះ បានព្រមព្រៀងគ្នា ប្តេជ្ញាអនុវត្តតាម DoC និងCoC ក៏ដោយក៏ប្រទេសនីមួយៗនៅតែមានជំហរដោះស្រាយជម្លោះខុសៗគ្នាដែរ។ ប្រទេសខ្លះ បានប្រកាន់យកជំហរដំណោះស្រាយទ្វេភាគី និងប្រទេសខ្លះទៀត បានប្រកាន់យកជំហរដំណោះស្រាយពហុភាគី ដោយមានការចូលរួមពីប្រទេសទី៣ និងចង់ប្រែក្លាយបញ្ហាទៅជាជម្លោះអន្តរជាតូបនីយកម្ម។

# ១. សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

តំបន់ប្រជុំកោះស្ព្រាតលីដែលមានជម្លោះ មានទីតាំងនៅក្នុងឈូងសមុទ្រចិនខាងត្បូង រួមមាន កូនកោះតូចៗជាង១០០ ឬកោះថ្មប៉ប្រះទឹក តែពុំមានប្រជាជនដើមកំណើតរស់នៅទីនោះឡើយកោះ។ កូអរ៍ឌីណេភូមិសាស្ត្រនៃប្រជុំកោះស្ព្រាតលីមានទី២តាំងនៅត្រង់ចំណុច 8 38 N, 111 55 E។ ផ្ទៃដីកោះធំៗ មានទំហំសរុបតូចជាង៥ គ.មដែលនៅរាយប៉ាយលើផ្ទៃសមុទ្រទំហំជាង៤២៥ ០០០គ.ម២។

ចំពោះជម្លោះនៅតំបន់ប្រជុំកោះស្ព្រាតលី[1] គឺពាក់ព័ន្ធនឹងការដណ្តើមតំបន់គ្រប់គ្រងដែនទឹក (Territorial Claim) ការកំណត់ព្រំដែនទឹក (Demarcation of Territorial Sea) និងជម្លោះកំណត់តំបន់ សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zones-EEZ) រវាងប្រទេសចិន និងសមាជិកអាស៊ាន៤ប្រទេសផ្សេងទៀត រួមមាន ប្រទេសវៀតណាម ហ្វីលីពីន ម៉ាឡេស៊ី និងប្រ៊ុយណេ។

ជម្លោះនេះបានកើតឡើងដោយសារតែប្រទេសចិន បានកាន់កាប់ និងគ្រប់គ្រងប្រជុំកោះដោយផ្អែកតាមកត្តាប្រវត្តិសាស្ត្រ និងប្រើប្រាស់ផែនទីបន្ទាត់ដែលមានស្នាមដិត៩ចំណុច (The Nine-Dash Line) ដែលបានក្តោបយកតំបន់សមុទ្រចិនភាគខាងត្បូងស្ទើរតែ ៩០% ដែលបណ្តាលឱ្យមានការតវ៉ាពីប្រទេសវៀតណាម (ផ្អែកតាមកត្តាប្រវត្តិសាស្ត្រ) ហ្វីលីពីន ម៉ាឡេស៊ី និងប្រ៊ុយណេ ផ្អែកតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២[2] (UNCLOS)។

ដោយសារតែជម្លោះខាងលើពាក់ព័ន្ធនឹងសន្តិភាព ស្ថិរភាពនៅក្នុងតំបន់ និងនៅក្នុងឆាកអន្តរជាតិ អាស៊ាន ត្រូវបានគេមើលឃើញថា មានតួនាទីដោយជៀសមិនបាន ក្នុងការចូលរួមសម្របសម្រួលជម្លោះដោយផ្អែកទៅតាម DoC CoC និងអនុសញ្ញា UNCLOS។ ទោះបីជា

---

[1] http://www.lawteacher.net>scs.

[2] អនុសញ្ញា UNCLOS ត្រូវបានចុះហត្ថលេខានៅក្រុងម៉ុងតេហ្គោបេប្រទេសចាមេកា នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ និងបានអនុម័ត នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៨២ មាន១៧ជំពូក ៣២០មាត្រា និង៩ឧបសម្ព័ន្ធ។

យ៉ាងណាក៏ដោយ ក៏ជម្លោះនេះនៅតែពុំឃើញពន្លឺនៅឡើយនោះទេ ក្នុងខណៈពេលដែលប្រទេសជម្លោះនីមួយៗ មិនទាន់បានឯកភាពទៅលើយន្តការដំណោះស្រាយជម្លោះនៅឡើយ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែជម្លោះនៅប្រជុំកោះស្ព្រាតលីក្នុងតំបន់សមុទ្រចិនខាងត្បូង ជាបញ្ហារសើបសំរាប់សន្តិសុខ និងស្ថិរភាពតំបន់យើងបានលើកយកចំណោទបញ្ហាបីចំណុចមកធ្វើការសិក្សាស្រាវជ្រាវ ដូចខាងក្រោម៖

១. តើអ្វីជាបុព្វហេតុនៃជម្លោះនៅតំបន់ប្រជុំកោះស្ព្រាតលី?

២. តើដំណោះស្រាយជម្លោះតាមការសម្របសម្រួលពីអាស៊ានអាចជោគជ័យដែរឬទេ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទ "**បុព្វហេតុបង្កើតឱ្យមានជម្លោះនៅប្រជុំកោះស្ព្រាតលីនៃសមុទ្រចិនខាងត្បូង**" គឺមានគោលបំណងសំខាន់ៗបីចំណុចដូចខាងក្រោម៖

១. កំណត់ពីបុព្វហេតុបង្កើតឱ្យមានជម្លោះនៅតំបន់ប្រជុំកោះស្ព្រាតលី។

២. កំណត់ពីចំណុចអវិជ្ជមានតាមការសម្របសម្រួលជម្លោះពីអាស៊ាននិង

៣. កំណត់ពីយុទ្ធសាស្ត្រដែលអាចឈានទៅរកដំណោះស្រាយជម្លោះនៅថ្ងៃអនាគត។

## ១.៤ វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងវិធីស្រាវជ្រាវ ជាដំបូង យើងបានចងក្រងឯកសារដែលប្រមូលបានពីកិច្ចសម្ភាសន៍ តាមរយៈការអានសៀវភៅ សារព័ត៌មាន (ជាតិ និងអន្តរជាតិ) វេបសាយ វិទ្យុ និងទូរទស្សន៍ និងបានធ្វើការសិក្សាស្វែងយល់ទៅលើឯកសារប្រវត្តិសាស្ត្រ ច្បាប់ពាក់ព័ន្ធនឹងដំណោះស្រាយជម្លោះក្នុងតំបន់ប្រជុំកោះស្ព្រែតលីនៃឈូងសមុទ្រចិនខាងត្បូង រួមមាន ឯកសារស្តីពី៖ សេចក្តីថ្លែងការណ៍រួមរវាងរដ្ឋមន្ត្រីការបរទេសចិន-អាស៊ាន សន្និសិទសារព័ត៌មានរបស់ប្រមុខរដ្ឋាភិបាល ប្រមុខការទូតកម្ពុជា សេចក្តីប្រកាសនៃក្រមប្រតិបត្តិគ្រប់ភាគីជម្លោះនៅតំបន់សមុទ្រចិនខាងត្បូង (DoC) របាយការណ៍កិច្ចប្រជុំកំពូលអាស៊ាន និងវេទិកានៃកិច្ចប្រជុំអាស៊ាន-ចិន រួមនឹងឯកសារដែលទទួលបានពីអគ្គនាយកដ្ឋានអាស៊ាននៃក្រសួងការបរទេស

និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីយកមករៀបចំចងក្រង និងធ្វើការរក្សាទុកនៅក្នុងកម្មវិធី Microsoft Word ឆ្នាំ២០១០។

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយមានហេតុផលត្រឹមត្រូវ និងមានលក្ខណៈវិទ្យាសាស្ត្រ យើងបានធ្វើការសិក្សាទៅលើអនុមាណរួម និងអនុមាណញែក តាមវិធីសាស្ត្រដូចខាងក្រោមៈ

**ក-ការវិភាគបែបគុណវិស័យ**

ការកំណត់គោលការណ៍ដែលត្រូវយកមកប្រើប្រាស់ដើម្បីធ្វើការវិភាគ និងវាយតម្លៃឯកសារដោយផ្អែកលើមូលដ្ឋានធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter) ធម្មនុញ្ញអាស៊ាន (Asean Charter) រដ្ឋធម្មនុញ្ញកម្ពុជា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ឆ្នាំ១៩៨២ (UNCLOS) សេចក្តីប្រកាសនៃក្រមប្រតិបត្តិគ្រប់ភាគីជម្លោះនៅតំបន់សមុទ្រចិនខាងត្បូងឆ្នាំ២០០២ (DoC) ក្របខ័ណ្ឌនៃក្រមប្រតិបត្តិ (CoC) និងលទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ាន-ចិន និងសេចក្តីថ្លែងការណ៍រួមរវាងរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិនពាក់ព័ន្ធនឹងជម្លោះនៅក្នុងតំបន់សមុទ្រចិនខាងត្បូង។

**ខ-ការវិភាគបែបពិពណ៌នា**

ការកំណត់គោលការណ៍ដែលត្រូវយកមកប្រើប្រាស់ដើម្បីធ្វើការវិភាគបែបពិពណ៌នា គឺបានធ្វើឡើងតាមរយៈការកត់ត្រាទុកនូវរាល់យោបល់ពីសាស្ត្រាចារ្យដឹកនាំទាំងពីររូប និងវាគ្មិនឯកទេសក្នុងសិក្ខាសាលា ការប្រមូលចងក្រងរាល់សេចក្តីថ្លែងការណ៍ ការតាមដានអង្កេតទៅលើស្ថានភាពដែលបានវិវឌ្ឍ និងប្រែប្រួលទៅតាមសកម្មភាពជាក់ស្តែង រួមនឹងកិច្ចពិភាក្សាក្នុងការដោះស្រាយជម្លោះក្នុងចំណោមភាគីពាក់ព័ន្ធនានា តាមដំណាក់កាលនៃកិច្ចប្រជុំកំពូលអាស៊ាននីមួយៗ និងប្រមូលព័ត៌មានទាក់ទងនឹងដំណោះស្រាយជម្លោះដែលទទួលបានពីកាសិក្សាស្រាវជ្រាវ ការអាន ការស្តាប់ ក៏ដូចជាការពិគ្រោះយោបល់ជាមួយអ្នកជំនាញ ដើម្បីយកមកធ្វើការប្រៀបធៀបវិភាគ ឱ្យបានស៊ីជម្រៅទៅលើស្ថានភាពទាំងឡាយដែលបានកើតមានឡើង។

## ២. បុព្វហេតុបង្កើតឱ្យមានជម្លោះនៅប្រជុំកោះស្រ្កាតលី

បន្ទាប់ពីបានសិក្សាពីប្រវត្តិខាងលើ បានបង្ហាញឱ្យឃើញថា បុព្វហេតុដែលបង្កើតឱ្យមានជម្លោះនៅប្រជុំកោះស្រ្កាតលីនៃតំបន់សមុទ្រចិនខាងត្បូង បានកើតឡើងតាមកត្តាដូចខាងក្រោមៈ

១. សាធារណរដ្ឋប្រជាមានិតចិន បានប្រើផែនទីប្រវត្តិសាស្រ្តស្នាមឱត ៩ចំណុច (The Nine Dotted Line) ដែលបានបង្កើតឡើងដោយសាធារណរដ្ឋចិន (កោះតៃវ៉ាន់) ក្នុងឆ្នាំ១៩៤៧ ដែលក្តោបយកតំបន់កោះស្ទើតែ ៩០% នៃផ្ទៃទឹកទាំងមូលនៅក្នុងតំបន់សមុទ្រចិនខាងត្បូងដាក់នៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

២. ភាពមិនច្បាស់លាស់ពីការបោះបង់សិទ្ធិកាន់កាប់របស់ប្រទេសជប៉ុនបន្ទាប់ពីខ្លួនបានចាញ់សង្គ្រាមលោកលើកទី២ក្នុងឆ្នាំ១៩៤៥ មកឱ្យសាធារណរដ្ឋប្រជាមានិតចិន (កោះតៃវ៉ាន់) ក្នុងឆ្នាំ១៩៤៩ ជាអ្នកកាន់កាប់ជំនួសសាធារណរដ្ឋចិន ដែលបណ្តាលឱ្យប្រទេសដែលមានជម្លោះផ្សេងទៀតប្រើប្រាស់សន្ធិសញ្ញា San Francisco Treaty ដែលតំរូវយកតាម Res Nullius។

៣. បន្ទាប់ពីទទួលជ័យជំនះសង្គ្រាមលើវៀតណាមខាងត្បូងក្នុងឆ្នាំ ១៩៧៥ វៀតណាមខាងជើង បានដកការទទួលស្គាល់នូវអ្វីដែលលោកអតីតនាយករដ្ឋមន្រ្តីវៀតណាមខាងជើង ហ្វាម វ៉ាន់ ឌុង (Pham Van Dong) ធ្លាប់សន្យាជាមួយប្រទេសចិន ឱ្យជួយផ្តួលរំលំវៀតណាមខាងត្បូងដោះដូរទៅនឹងការទទួលស្គាល់ទំហំសមុទ្រដែនដីចម្ងាយ ១២ម៉ៃយ៍ សមុទ្រ[៣]ដែលវៀតណាមខាងត្បូងមិនទទួលស្គាល់[៤]។

---

[៣] នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៥៨ ប្រទេសចិន បានប្រកាសការពង្រីកទំហំសមុទ្រដែនដីប្រវែង១២ម៉ៃយ៍សមុទ្រ... ប៉ុន្តែសហរដ្ឋអាមេរិក បានទទួលស្គាល់ទំហំសមុទ្រដែនដីទំហំ៣ម៉ៃយ៍សមុទ្រ។

[៤] កំណត់ទូតផ្លូវការរបស់លោក ហ្វាម វ៉ាន់ឌុង ផ្ញើលោកអតីនាយករដ្ឋមន្រ្តីចិន ហ្ស៊ូ អេងឡាយ (Zhu Enlai) ក្នុងឆ្នាំ១៩៥៨។

៤. ប្រទេសពាក់ព័ន្ធនឹងជម្លោះនៅក្នុងប្រជុំកោះស្រ្ពាតលី មិនគោរពអនុ-សញ្ញាស្តីពីនីតិសមុទ្រអង្គការសហប្រជាជាតិឆ្នាំ១៩៨២ (UNCLOS 1982) ប៉ុន្តែបន្តរក្សាអនុវត្តតាមកត្តាប្រវត្តិសាស្រ្តក្នុងការពង្រីកទឹកដី ការទាមទារកាន់កាប់ និងគ្រប់គ្រងកោះ (ក្នុងនោះរួមមានៈ ប្រទេសចិន វៀតណាម និងកោះតៃវ៉ាន់) និងការអនុវត្តន៍ DoC មិនបានពេញលេញ។

## ៣. ការទាមទាររបស់ភាគីជម្លោះ

### ៣.១ ប្រទេសប្រ៊ុយណេ

ប្រទេសប្រ៊ុយណេ បានទាមទារផ្នែកខ្លះនៃតំបន់នៅកៀកបំផុតសមុទ្រចិនខាងត្បូងថា ជាតំបន់ខ្ពង់រាបបាតសមុទ្រ (Continental Shelf) និងតំបន់សេដ្ឋកិច្ចពិសេស (EEZ)។ នៅក្នុងឆ្នាំ១៩៨៤ ប្រទេសប្រ៊ុយណេ បានប្រកាសតំបន់សេដ្ឋកិច្ចផ្តាច់មុខនៅព័ទ្ធជុំវិញកូនកោះតូចៗដែលខ្លួនបានអះអាងក្នុងតំបន់កោះ Louisa Reef។ ប្រទេសប្រ៊ុយណេ មិនបានដាក់វត្តមានយោធានៅក្នុងតំបន់នោះទេ។ ប្រ៊ុយណេ បានទាមទារយកតំបន់កោះថ្មប្រ៉ប្រ៉ះទឹកផ្អែកតាមអនុសញ្ញា UNCLOS ដោយបានបញ្ជាក់ថា ផ្នែកមួយនៃជួរប្រជុំកោះស្រ្ពាតលីភាគខាងត្បូង តាមពិត គឺជាតំបន់ខ្ពង់រាបបាតសមុទ្រ ដូច្នេះ វាស្ថិតនៅក្នុងអធិបតេយ្យភាពរបស់ខ្លួន ដែលជាហេតុធ្វើឱ្យប្រទេសប្រ៊ុយណេទាមទារយកតំបន់ខ្ពង់រាបបាតសមុទ្រ ដែលលាតសន្ធឹងហួសពីចម្ងាយ២០០ម៉ៃយ៍ពីឆ្នេររបស់ខ្លួនទៅអង្គការសហប្រជាជាតិ ប៉ុន្តែមានប្រតិកម្មពីប្រទេសចិន។

### ៣.២ ប្រទេសម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីបានទាមទារយកកោះតូចៗមួយចំនួន នៅក្នុងប្រជុំកោះស្រ្ពាតលីដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ដែលមានចម្ងាយ២០០ម៉ៃយ៍។ ចាប់តាំងពីឆ្នាំ១៩៨៣ ប្រទេសម៉ាឡេស៊ី បានកាន់កាប់កោះ៣ រួមមានៈ កោះ Swallow Reef (Layang Layang/Terumbu Layang/ Paulau Layang) Ardasier Reef (Terumbu Ubi) និងកោះ Mariveles Rees (Terumu Mant-anani)។ បច្ចុប្បន្ន កោះទាំង៣នេះបានប្រែក្លាយជាតំបន់ទទួលភ្ញៀវទេសចរណ៍មកកំសាន្ត។

ការទាមទារកោះរបស់ម៉ាឡេស៊ី គឺបានផ្អែកតាមគោលការណ៏តំបន់ខ្ពង់រាបបាតសមុទ្រ និងបានកំណត់ទីតាំងភូអ័រដើនណោក្នុងរង្វង់កំណត់នៅតំបន់ EEZ ក្នុងឆ្នាំ១៩៧៩។ កិច្ចព្រមព្រៀងនេះបានតម្រូវថា កោះទាំងឡាយ គឺរក្សា res nullius[៥] ដោយសារតែជប៉ុនបានប្រកាសបោះបង់កោះដែលខ្លួនកាន់កាប់តាមសន្ធិសញ្ញា San Francisco Treaty[៦]។

### ៣.៣ ប្រទេសហ្វីលីពីន

ការអះអាងរបស់ហ្វីលីពីនពីមូលដ្ឋានអធិបតេយ្យភាពរបស់ខ្លួន ទៅលើប្រជុំកោះស្ព្រាតលី គឺយោងតាម res nullius និងតាមទីតាំងភូមិសាស្ត្រដែលបានផ្អែកតាមអនុសញ្ញា UNCLOS ឆ្នាំ១៩៨២ ពីព្រោះថា ខ្លួនគ្មានអធិបតេយ្យភាពស្របច្បាប់ទៅលើកោះទាំងឡាយនោះទេ។ នៅទសវត្សរ៍ឆ្នាំ១៩៣០ ទើបប្រទេសហ្វីលីពីន ទទួលបានកោះមួយចំនួនមកគ្រប់គ្រងបន្ទាប់ពីប្រទេសបារាំង និងបន្ទាប់ពីប្រទេសជប៉ុន បានចាញ់សង្គ្រាមលោកលើកទី២ ក្នុងឆ្នាំ១៩៤៥ ធ្វើឱ្យកោះទាំងឡាយ បានប្រែក្លាយជា Res nullius ធ្វើឱ្យប្រទេសហ្វីលីពីនដាក់បញ្ចូលជាឧបសម្ព័ន្ធរបស់ខ្លួន ។ បច្ចុប្បន្ន នៅតំបន់ប្រជុំកោះស្ព្រាតលី ប្រទេសហ្វីលីពីនបានកាន់ចំនួន៩កោះ[៧]។

### ៣.៤ ប្រទេសវៀតណាម

ប្រទេសវៀតណាម បានទាមទារថា ខ្លួនបានកាន់កាប់ប្រជុំកោះស្ព្រាតលី និងប្រជុំកោះប៉ារ៉ាសែលយ៉ាងហោចណាស់ គឺចាប់តាំងពីសតវត្សទី១៧ នៅពេលដែលតំបន់ប្រជុំកោះទាំងនេះ មិនទាន់បានស្ថិតជាអធិបតេយ្យភាពរបស់រដ្ឋណាមួយនៅឡើយ។ ផ្អែកតាមសៀវភៅប្រវត្តិសាស្ត្រ Phi bien tap luc និពន្ធដោយអ្នកប្រាជ្ញឈ្មោះ ឡេ វ៉ូយ ឌុង (Le Quy Dong) គឺថា ប្រជុំកោះ Hoang Sa (Paracel Islands) និងប្រជុំកោះ Truong Sa (Spratly Islands) ត្រូវបានកំណត់ថាជាកម្មសិទ្ធិស្ថិតក្នុងស្រុក Quang Ngai District របស់ប្រទេសវៀតណាម។ ដោយបានបដិសេធទៅនឹងការព្រមប្រគល់តំបន់សមុទ្រចិនខាងត្បូងមកឱ្យប្រទេសចិនដោយលោកនាយករដ្ឋមន្ត្រីវៀតណាមខាងត្បូង ហ្វាម វ៉ាន់ដុង នៅថ្ងៃទី២៦

---

[៥] របស់ដែលគ្មានម្ចាស់កាន់កាប់ ឬគ្រប់គ្រង (nobody's thing)។

[៦] សន្ធិសញ្ញាដែលពាក់ព័ន្ធ នឹងការទាមទារសិទ្ធិកាន់កាប់យកកោះដោយគ្មានអ្នកទទួលសិទ្ធិ។

[៧] Spratly Islands Dispute-Wikipedia. https://en.m.wikipedia.org.wiki>Spratl...

ខែតុលា ឆ្នាំ១៩៥៥ វៀតណាមខាងជើង បានលើកឡើងថា វៀតណាមខាងត្បូង ត្រូវបានជំនួសដោយរដ្ឋវៀតណាមខាងជើង (ផ្នែកមួយសហភាពបារាំង) ហើយបានផ្តល់មរតកមកខ្លួន និងតាមហេតុផល៣ចំណុចៈ

**ទី១**-សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) គឺមិនបានគ្រប់គ្រងប្រជុំកោះប៉ារ៉ាសែល និងប្រជុំកោះស្រ្តាតលី នៅពេលដែលលោកនាយករដ្ឋមន្រ្តី ឌុង សរសេរលិខិតនោះទេ។

**ទី២**- រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៦ និងឆ្នាំ១៩៥៧ របស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានចែងថា ការផ្ទេរទឹកដី ត្រូវតែសំរេចដោយច្បាប់សភាដែលជាស្ថាប័នដ៏មានអំណាចបំផុតនៅក្នុងប្រទេស។ ដូច្នេះ នាយករដ្ឋមន្រ្តី គ្មានសិទ្ធិបោះបង់កោះនោះទេ។

**ទី៣**- លិខិតរបស់លោកនាយករដ្ឋមន្រ្តី ហ្វាម វ៉ានឌុង គឺជាសេចក្តីប្រកាសដោយឯកតោភាគីដែលបានសរសេរតែឯកឯង ក្នុងការឆ្លើយតបទៅនឹងសេចក្តីប្រកាសទទួលស្គាល់សមុទ្រដែនដីមានទំហំ១២ម៉ៃយ៍សមុទ្រ។ នាពេលបច្ចុប្បន្ន នៅប្រជុំកោះស្រ្តាតលី ប្រទេសវៀតណាម បានកាន់កាប់ចំនួន២១ កោះ រួមមាន[៨]។

## ៣.៥ សាធារណរដ្ឋប្រជាមានិតចិន

សាធារណរដ្ឋប្រជាមានិតចិន ទាមទារតំបន់ប្រជុំកោះស្រ្តាតលីទាំងមូលជាផ្នែកមួយរបស់ខ្លួនដោយផ្អែកតាមផែនទីស្នាមអិត៩ចំណុច (The Nine Dotted Line) និងតាមកត្តាប្រវត្តិសាស្រ្ត។ សាធារណរដ្ឋប្រជាមានិតចិន បានអះអាងថា ខ្លួនបានរកឃើញកោះនៅក្នុងសម័យរាជវង្សហាន (Han Dynasty) ក្នុងសតវត្សទី២ មុនគ្រិះសករាជ (២ BC)។ កោះទាំងនោះ ត្រូវបានដាក់បញ្ចូលក្នុងផែនទី និងបានចងក្រងទុកក្នុងអំឡុងពេលរជ្ជកាលរាជវង្សហានភាគខាងកើត (Eastern Han dynasty) និងក្នុងរជ្ជកាល រាជវង្សវូ៉ភាគខាងកើត (Eastern Wu) ដែលត្រូវបានគេដឹងថាជារជ្ជកាលមួយក្នុងចំណោមរជ្ជកាលទាំងបីនៃអាណាចក្របីជំនាន់របស់សាមកុក (One of Three Kingdoms)។

បន្ទាប់ពីសង្រ្គាមលោកលើកទី២ បានបញ្ចប់ ក្នុងឆ្នាំ១៩៤៦ សាធារណរដ្ឋចិន (កោះតៃវ៉ាន់) បានដាក់ទ័ពនៅលើកោះ អ៊ីទូ អាបា (Itu Aba) បោះទងជាតិ និងបានដាំ

---

[៨] Spratly Islands Dispute-Wikipedia. https://en.m.wikipedia.org.wiki>Spratl...

បង្គោលតាមបណ្ដោយកោះវ៉ូឌី (Woody Island) នៅក្នុងប្រជុំកោះប៉ារ៉ាសែល។ នៅក្នុងឆ្នាំ ១៩៤៧ សាធារណរដ្ឋចិន បានគូសផែនទីស្នាមឱត៩ចំណុចដែលបានក្ដោបទៅលើតំបន់សមុទ្រចិនខាងត្បូងក្ដោបយកប្រជុំកោះស្ព្រាតលី និងកោះប៉ារ៉ាសែលទាំងមូល។ បន្ទាប់ពីបានផ្ដួលរបបសាធារណរដ្ឋចិន ក្នុងឆ្នាំ១៩៤៩ សាធារណរដ្ឋប្រជាមានិតចិន (ចិនដីគោក) បានប្រើប្រាស់ផែនទីឆ្នាំ១៩៤៧ បន្ត និងគ្រប់គ្រងតំបន់សមុទ្រចិនខាងត្បូងស្ទើរតែទាំងមូល។ បច្ចុប្បន្ន នៅប្រជុំកោះស្ព្រាតលី ប្រទេសចិន បានកាន់កាប់កោះថ្មប្រ៉ប្រ៉ះទឹកចំនួន៧[៩]។

# ៤. ដំណើរការដោះស្រាយជម្លោះដោយសន្តិវិធី

## ៤.១ តាមរយៈអាស៊ាន

ជម្លោះនៅតំបន់ប្រជុំកោះស្ព្រាតលីនៃសមុទ្រចិនខាងត្បូង ជាជម្លោះដែលមានលក្ខណៈទ្វេភាគី[១០]តែចាំបាច់ត្រូវមានការចូលរួមសម្របសម្រួល រកដំណោះស្រាយពីអាស៊ាន ពីព្រោះជម្លោះមួយនេះ បានកើតឡើងរវាងប្រទេសចិន នឹងសមាជិកអាស៊ាន៤ប្រទេស។ ភាពចាំបាច់ដែលត្រូវមានវត្តមានសម្របសម្រួលពីអាស៊ាន គឺថាទាំងប្រទេសចិន និងអាស៊ាន គឺមិនចង់ឱ្យមានភាពល្អក់កករទាំងខាងទំនាក់ទំនងការទូត និងសេដ្ឋកិច្ចដែលនាំឱ្យខាតប្រយោជន៍របស់ប្រទេសទាំងពីរ។

ដើម្បីជាដំណោះស្រាយជម្លោះខាងលើ អាស៊ាន បានបង្កើតឱ្យមានយន្តការស្វែងរកដំណោះស្រាយជម្លោះដោយសន្តិវិធីមាន៤ដំណាក់កាលធំៗ ដូចខាងក្រោម៖

១-សេចក្ដីប្រកាសអាស៊ានស្ដីពីសមុទ្រចិនខាងត្បូងឆ្នាំ១៩៩២ (១៩៩២ Asean Declaration on the South China Sea)។ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩២ អាស៊ានបានចេញសេចក្ដីថ្លែងការណ៍មួយពាក់ព័ន្ធនឹងតំបន់សមុទ្រចិនខាងត្បូង ដោយបានសង្កត់ធ្ងន់ថា ជម្លោះតំបន់សមុទ្រចិនខាងត្បូង ត្រូវតែយកមកដោះស្រាយដោយសន្តិវិធីដោយគ្មានការងាកទៅរកអំពើហឹង្សាណាមួយឡើយ។

---

[៩] Spratly Islands Dispute-Wikipedia. https://en.m.wikipedia.org.wiki>Spratl...

[១០] asean.org/static_post=declaration-on-the-conduct-of-parties-in-the-south: "...negotiations by sovereign states directly concerned...", Declaration 4 April, 2002.

២-កិច្ចព្រមព្រៀងឆ្នាំ១៩៩៥ ( 1995 Asean Agreement )។ ផ្អែកតាមកិច្ចព្រមព្រៀងអាស៊ានឆ្នាំ១៩៩៥ អាស៊ាន បានបង្កើតកិច្ចព្រមព្រៀងមួយរវាងប្រទេសចិន និងសមាជិកអាស៊ានដោយតម្រូវឱ្យប្រទេសមួយត្រូវជូនដំណឹងដល់ប្រទេសដ៏ទៃ ប្រសិនបើមានការផ្លាស់កងទ័ពនៅក្នុងដែនដីជម្លោះ និងបានតម្រូវមិនឱ្យមានការកសាងសំណង់បន្ថែម។ ប៉ុន្តែកិច្ចព្រមព្រៀងនេះ ត្រូវបានរំលោភបំពានភ្លាមៗដោយប្រទេសចិន និងម៉ាឡេស៊ី ដោយពួកគេបានធ្វើការចូលចតនាវារបស់កងទ័ពចិនចំនួន៧គ្រឿងមកក្នុងតំបន់ជម្លោះ ដើម្បីជួសជុលទីជម្រកនេសាទត្រីនៅក្នុងតំបន់កោះថ្មប៉ប្រះទឹកប៉ាងណានីបាន ( Pangnaniban/Commodore )។

ជាការឆ្លើយតប ប្រទេសហ្វីលីពីន បានដាក់ពាក្យជំទាស់ផ្លូវការ និងបានទាមទារលុបចោលរចនាសម្ព័ន្ធសំណង់ផ្សេងៗ បង្កើនកងនាវាយាមល្បាតក្នុងតំបន់កោះ Kalayaan និងបានអញ្ជើញអ្នកនយោបាយអាមេរិកមកចូលរួមអង្កេតការមូលដ្ឋានរបស់ប្រទេសចិនដោយប្រើយន្តហោះ។

៣-សេចក្តីប្រកាសស្តីពី ក្រមប្រតិបត្តិគ្រប់ភាគីជម្លោះក្នុងតំបន់សមុទ្រចិនខាងត្បូងឆ្នាំ២០០២(DoC)។ នៅថ្ងៃទី៤ ខែវិច្ឆកា ឆ្នាំ២០០២ ក្នុងទីក្រុងភ្នំពេញ DoC មួយត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសទាំង១០ប្រទេសរបស់សមាជិកអាស៊ាននិងប្រទេសចិនលើយន្តការដោះស្រាយជម្លោះនៅក្នុងតំបន់សមុទ្រចិនខាងត្បូង។

នៅក្នុងកិច្ចព្រមព្រៀងនេះ គ្រប់ភាគីជម្លោះ បានប្តេជ្ញាចិត្ត អនុវត្តយ៉ាងម្មត់ចត់នូវសេចក្តីប្រកាសនេះ ដោយបានប្តេជ្ញាចិត្តថា "ធ្វើការដោះស្រាយជម្លោះដែនដី និងជម្លោះយុត្តាធិការដោយមធ្យោបាយសន្តិវិធី និងដោយគ្មានងាកទៅរកការគម្រាមកំហែង ឬប្រើប្រាស់កម្លាំង តាមរយៈការពិគ្រោះយោបល់ និងការចរចាដោយមិត្តភាពដោយរដ្ឋអធិបតេយ្យភាពពាក់ព័ន្ធនឹងជម្លោះផ្ទាល់ "គ្រប់ភាគីជម្លោះ ត្រូវតែមានភាពអត់ធ្មត់រាល់សកម្មភាពទាំងឡាយណាដែលបង្កឱ្យមានភាពស្មុកស្មាញ ឬបង្កើនឱ្យមានភាពតានតឹងដែលប៉ះពាល់ដល់ស្ថិរភាព និងសន្តិភាព រួមមានការជៀសវាងពីការតាំងទីលំនៅ ឬមិនទាន់តាំងទីលំនៅនៅលើកោះដែលមានជម្លោះ កោះថ្មប៉ប្រះទឹក ថ្មខ្ពស់ក្រោមផ្ទៃទឹក កូនកោះ និងសណ្ឋានកោះដ៏ទៃៗទៀត។

ដើម្បីអនុវត្តកិច្ចព្រមព្រៀងប្រកបទៅដោយប្រសិទ្ធភាព ប្រទេសពាក់ព័ន្ធនឹងជម្លោះផ្ទាល់ បានអនុវត្តវិធានការណ៍កសាងទំនុកចិត្ត (Confident Building Measures-CBM) ដូចជាការបង្កើតកិច្ចសន្ទនា និងផ្លាស់ប្តូរមតិសមស្របរវាងមន្ត្រីការពារ និងយោធា ការធ្វើលំហាត់យោធារួមគ្នា និងមានការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងបញ្ហាជម្លោះឱ្យគ្នាទៅវិញទៅមក។

គ្រប់ភាគីជម្លោះ ត្រូវតែបង្កើនសកម្មភាពកិច្ចសហប្រតិបត្តិការ ដូចជាការការពារបរិស្ថានដែនសមុទ្រ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រដែលសមុទ្រ សុវត្ថិភាពនាវាចរណ៍ និងទំនាក់ទំនងតំបន់សមុទ្រ រួមមាន កិច្ចសហប្រតិបត្តិការសង្គ្រោះ និងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន មានដូចជា អំពើរត់ពន្ធគ្រឿងញៀន ចោរ សមុទ្រ អំពើប្លន់ប្រដាប់អាវុធនៅឯសមុទ្រ និងការលក់អាវុធខុសច្បាប់ជាដើម។ សេចក្តីប្រកាសនៃក្រមប្រតិបត្តិ (DoC) ត្រូវបានគេចាត់ទុកថា នឹងបន្ថយភាពតានតឹង ទោះបីជា វាមិនបានចងទៅដោយផ្លូវច្បាប់ក៏ដោយ និងកសាងក្រមប្រតិបត្តិក្នុងតំបន់សមុទ្រចិនខាងត្បូង[១១] (Code of Conduct-CoC) ដែលជាការជុំរុញឱ្យអាស៊ាន-ចិន មានដំណោះស្រាយដោយសន្តិវិធី និងទប់ស្កាត់សភាពការណ៍ពីការតានតឹងទាក់ទងនឹងជម្លោះនៅតំបន់សមុទ្រចិនខាងត្បូង។ CoC ជាកិច្ចព្រមព្រៀងដែលបានផ្តួចផ្តើមឡើងដោយប្រទេសឥណ្ឌូនេស៊ីកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

នៅក្នុងខែកក្កដា ឆ្នាំ២០១២ ប្រទេសចិន បានប្រកាសថា ខ្លួន នឹងបើកិច្ចពិភាក្សាទៅលើការកសាង CoC ប៉ុន្តែបានអំពាវនាវដល់គ្រប់ភាគីជម្លោះអនុវត្តភាព DoC និងអនុសញ្ញា UNCLOS ឆ្នាំ១៩៨២។ សេចក្តីប្រកាសរបស់ប្រទេសចិន ត្រូវបានមតិនានាធ្វើការរិះគន់ពីរដ្ឋដែលមានជម្លោះនឹងខ្លួន ពីព្រោះវាជាទង្វើខុសច្បាប់របស់ចិនដែលពាក់ព័ន្ធនឹងការកាន់កាប់កោះ Scarborough Shoal របស់ហ្វីលីពីនក្នុងគ្រាដែលប្រទេសចិនបានបង្កើតឱ្យមានការគ្រប់គ្រងថ្មី (De Facto Control) ក៏មានប្រតិកម្មពីសហរដ្ឋអាមេរិក[១២]ផងដែរ។

---

[១១] *https://thediplomat.com/tag/south-china-sea-coc* (ឧបសម្ព័ន្ធរូបភាពទី២៤)។

[១២] នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ ស ហ រ បានអនុម័តសេចក្តីសំរេចចិត្តដោយឯកច្ឆ័ន្ទលើដំណោះស្រាយមួយដោយបានប្រកាសថាសកម្មភាពឆ្នាំ២០១២ របស់ចិនដែលបានធ្វើការអះអាងគ្រប់គ្រងដែនទឹកដែលមានជម្លោះដោយឯកតោភាគីនៅក្នុងតំបន់ប្រជុំកោះស្ព្រាតលី គឺមានលក្ខណៈផ្ទុយពី (DoC) និងបានធ្វើឲ្យរាំងស្ទះដល់ដំណើរនៃការដោះស្រាយដោយសន្តិវិធី។

ទន្ទឹមនឹងគ្នានេះដែរ ទោះបីជាមានឧបសគ្គក្នុងការកសាងក្រមប្រតិបត្តិសមុទ្រចិនខាងត្បូងនាពេលកន្លងមកក៏ដោយ ប៉ុន្តែផ្ទុយមកវិញ នៅទីបំផុត អាស៊ាន ទទួលបានការព្រមព្រៀងដើម្បីឈានទៅអនុម័តបាននូវ CoC នៅថ្ងៃខាងមុខដែលជាលទ្ធផលបង្កើតឡើងដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន នាក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិនលើកទី៥០ និងកិច្ចប្រជុំពាក់ព័ន្ធក្នុងចន្លោះថ្ងៃទី០៤-០៦ ខែសីហា ឆ្នាំ២០១៧ ក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីននាពេលកន្លងមក។

ការអនុម័តក្របខណ្ឌនៃក្រមប្រតិបត្តិដោយអាស៊ាន-ចិន គឺជាជំហានប្រវត្តិសាស្ត្រថ្មីមួយទៀត ដើម្បីឈានទៅរកដំណោះស្រាយមួយប្រកបទៅដោយប្រសិទ្ធភាពដែលដំណោះស្រាយនេះ គ្រប់ភាគីជម្លោះ បានផ្តោតទៅលើបញ្ហា៤ចំណុចសំខាន់ៗរួមមាន៖

ទី១ ការមិនតាំងទីលំនៅលើសណ្ឋានកោះដែលគ្មានមនុស្សរស់នៅ

ទី២ ការមិនរំលោភបំពានលើអ្វីដែលគ្រប់ភាគីជម្លោះបានព្រមព្រៀងគ្នា

ទី៣ ការគោរពកិច្ចព្រមព្រៀងដែលចងភ្ជាប់ដោយផ្លូវច្បាប់ ឧទាហរណ៍ ការអនុវត្តក្របខ័ណ្ឌនៃក្រមប្រតិបត្តិ និង

ទី៤ គោរពពីតួនាទីសម្របសម្រួលជម្លោះដោយអាស៊ានដែលផ្អែកតាមសេចក្តីប្រកាសនៃក្រមប្រតិបត្តិ។ ផ្អែកតាមការសិក្សាស្រាវជ្រាវស្តីពីដំណើរនៃប្រវត្តិព្រឹត្តិការណ៍សំខាន់ៗក្នុងដំណើរទៅកាន់ការកសាង និងអនុម័តក្រមប្រតិបត្តិដោយអាស៊ាន-ចិន នៅតំបន់សមុទ្រចិនខាងត្បូង (The Road to an Asean-China Code of Conduct in the SCS) គិតត្រឹមថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៧ មានចំនួន២៧លើក[១៣]។

**៤-៤.១-តាមរយៈការចេញសេចក្តីថ្លែងការណ៍រួម**

ក្រៅពីដំណោះស្រាយជម្លោះតាមរយៈយន្តការសម្របសម្រួលពីអាស៊ាន ដើម្បីកាត់បន្ថយភាពតានតឹងដែលអាចឈានទៅរកសង្គ្រាម ប្រទេសពាក់ព័ន្ធនឹងជម្លោះផ្ទាល់ បានធ្វើការផ្លាស់ប្តូរដំណើរទស្សនកិច្ចដើម្បី កសាងទំនុកចិត្តគ្នា ក៏ដូចជាការបង្កើនកិច្ចសហប្រតិបត្តិការឱ្យបានកាន់តែរឹងមាំនិងស្និតស្នាលថែមទៀត។ តាមការអញ្ជើញរបស់ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ស៊ី ជិងពីង (Xi Jingping) ឯកឧត្តមប្រធានាធិបតីនៃ

[១៣] Virtual Electronic Resource Access។

សាធារណរដ្ឋហ្វីលីពីន រ៉ូឌ្រីហ្គោរ ឌុយតែតេ បានមកបំពេញទស្សនកិច្ចជាផ្លូវនៅប្រទេសចិន ចាប់ពីថ្ងៃទី១៨-២១ ខែតុលា ឆ្នាំ២០១៦។ នាក្នុងឱកាសនៃដំណើរទស្សនកិច្ចនោះ ប្រទេសទាំងពីរបានចេញសេចក្តីថ្លែងការណ៍រួមមួយដែលមាន៤៧ប្រការ[១៤]។

ក្នុងចំណោមសេចក្តីថ្លែងការណ៍រួមមាន៤ប្រការ (ប្រការទី១៨ ៤០ ៤១ និង៤២)។ ក្នុងចំណោមប្រការទាំង៤៧ គឺភាគីទាំងពីរ បានលើកយកមកដោះស្រាយជម្លោះដោយសន្តិវិធី។ ឧទាហរណ៍: នៅក្នុងប្រការទី៤០ បានចែងថា:...ភាគីជម្លោះ បានបញ្ជាក់អះអាងពីសារៈសំខាន់នៃការរក្សា និងលើកកំពស់សន្តិភាព និងស្ថិរភាពសេរីភាពនាវាចរណ៍ទាំងក្នុង និងនៅលើតំបន់សមុទ្រចិនខាងត្បូងដោះស្រាយជម្លោះទឹកដី និងជម្លោះដែនយុត្តាធិការដោយគ្មានការងាកទៅរកការគម្រាមកំហែង ឬប្រើប្រាស់កម្លាំង រាល់ដំណោះស្រាយ គឺត្រូវធ្វោះឡើងតាមរយៈការចរចា និងការពិគ្រោះយោបល់ដោយរដ្ឋពាក់ព័ន្ធនឹងជម្លោះផ្ទាល់... និងអនុលោមទៅតាមធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter) និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ (UNCLOS ១៩៨២)។

ផ្អែកតាមសេចក្តីថ្លែងការណ៍រួមរវាងប្រទេសចិន និងវៀតណាម កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ ពាក់ព័ន្ធនឹងដំណោះស្រាយជម្លោះនៅក្នុងតំបន់សមុទ្រចិនខាងត្បូង ភាគីទាំងពីរ បានឈានដល់ការព្រមព្រៀងមួយស្តីកិច្ចសហប្រតិបត្តិការនៅតំបន់សមុទ្រ ដោយភាគីទាំងពីរ បានប្តេជ្ញាចិត្តថា ប្រទេសទាំងពីរ អនុវត្តដ៏ពេញលេញ និងដោយមានប្រសិទ្ធភាពទៅលើសេចក្តីប្រកាសនៃក្រមប្រតិបត្តិ (DoC) និងពុះពារបញ្ចប់ការកសាងក្របខ័ណ្ឌនៃក្រមប្រតិបត្តិ (CoC) ផ្អែកលើមូលដ្ឋានកុសង់ស៊ីសធ្វើឡើងតាមរយៈការពិគ្រោះយោបល់ (On the basis of consensus made through consultations)[១៥]។

ផ្អែកតាមសេចក្តីថ្លែងការណ៍រួមរវាងប្រទេសហ្វីលីពីន និងវៀតណាម នាឱកាសដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតី រូឌ្រីហ្គូ ដុយតែតេ នៅក្នុងប្រទេសវៀតណាម ចាប់ពីថ្ងៃទី២៨-២៩ ខែកញ្ញា ឆ្នាំ២០១៦ លោក រូឌ្រីហ្គូ ដុយតែតេ និងលោកប្រធានាធិបតីវៀតណាម ត្រាំង ដាយវ៉ាង (Tran Dai Quang) បានធ្វើការគូសបញ្ជាក់ឡើងវិញស្តីពីការ

[១៤] Beta.philstar.com៖ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦។

[១៥] Xinhua៖ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧។

រកដំណោះស្រាយជម្លោះនៅក្នុងតំបន់សមុទ្រចិនខាងត្បូង។ នៅក្នុងជំនួបនោះ ភាគីទាំងពីរ បានលើកឡើងស្តីពីចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមដូចជា៖

- ការប្តេជ្ញាចិត្តរក្សា និងបង្កើតសន្តិភាព សន្តិសុខ ស្ថិរភាព សុវត្ថិភាព និង សេរីភាពនាវាចរណ៍...។
- ការអំពាវនាវស្វែងរកដំណោះស្រាយជម្លោះដោយសន្តិភាព ស្របតាមផ្លូវច្បាប់ និងដំណើរការការទូតពេញលេញ ការអត់ធ្មត់នៅក្នុងការប្រតិបត្តិរាល់ សកម្មភាពទាំងឡាយ ដោយគ្មានការគម្រាមកំហែងនិងការប្រើកម្លាំង...។
- ការប្តេជ្ញាថា គ្រប់ដំណោះស្រាយ ត្រូវធ្វើឡើងផ្អែកតាមគោលការណ៍ច្បាប់ អន្តរជាតិរួមមានអនុសញ្ញា UNCLOS ឆ្នាំ១៩៨២ ជាដើម។
- ការគាំទ្រការអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាព ចំពោះសេចក្តី ប្រកាស និងព្យាយាមពន្លឿនកសាងក្របខ័ណ្ឌនៃក្រមប្រតិបត្តិ បញ្ចប់មុន កាលកំណត់។

នៅក្នុងដំណើរទស្សនកិច្ចខាងលើនេះ ភាគីជម្លោះទាំងពីរ បានរក្សាជំហរគោរព សាលក្រមរបស់តុលាការមជ្ឈត្តិកម្មអចិន្ត្រៃយ៍ពាក់ព័ន្ធនឹងការកាត់សេចក្តីនៅក្នុងអធិករណ៍ ក្នុងតំបន់សមុទ្រចិនខាងត្បូង ប៉ុន្តែសេចក្តីសំរេចនេះ ត្រូវបានភាគីចិនបដិសេធយ៉ាងដាច់ អហង្ការពុំព្រមទទួលយកដោយបានលើកឡើងថា ខ្លួន នឹងមិនគោរពតាមសេចក្តីសម្រេច នេះឡើយព្រមទាំងបានព្រមានដល់ប្រទេសជាប់ពាក់ព័ន្ធនឹងជម្លោះកំពុងតែជំរុញឱ្យបញ្ហានេះ ចូលក្នុងភ្នក់ភ្លើងសង្គ្រាមហើយ។

# ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.២ សេចក្តីសន្និដ្ឋាន

ជម្លោះនៅប្រជុំកោះស្ព្រាតលីនៃតំបន់សមុទ្រចិនខាងត្បូង គឺជាជម្លោះមានលក្ខណៈ ស្មុគស្មាញដោយសារតែប្រទេសដែលមានជម្លោះផ្ទាល់ (Claimant States) នីមួយៗ មាន ជំហរបកស្រាយស្មារតីសេចក្តីប្រកាសនៃក្រមប្រតិបត្តិ (DoC) តាមផ្លូវច្បាប់ (Legal Interpretation) តាមការយល់ឃើញរៀងៗខ្លួន។ ជាក់ស្តែង បើផ្អែកតាម DoC នៅក្នុង សេចក្តីប្រកាសទី៤ បានចែងថា «**ប្តេជ្ញាដោះស្រាយជម្លោះ**...**ដោយសន្តិវិធីដោយគ្មានការគំរាម**

**កំហែង តាមរយៈការពិគ្រោះយោបល់ និងការចរចាដោយរដ្ឋអធិបតេយ្យភាពពាក់ព័ន្ធនឹងជម្លោះផ្ទាល់ដោយអនុលោមតាមគោលការណ៍ និងច្បាប់អន្តរជាតិដែលទទួលស្គាល់ជាសកលរួមមានអនុសញ្ញា UNCLOS ឆ្នាំ១៩៨២ ស្តីពីនីតិសមុទ្រក៏ដោយ** ក៏ប៉ុន្តែ បើតាមការបកស្រាយពីប្រទេសដែលមានជម្លោះនីមួយៗនាពេលកន្លងមក យើងឃើញថា នៅតែមានភាពខ្វែងគំនិតគ្នានៅឡើយ។

សំរាប់ប្រទេសចិន ចំពោះ (DoC) ដែលបានចែងថា៖ «...**ដោះស្រាយជម្លោះ...ដោយសន្តិវិធី ដោយគ្មានការគំរាមកំហែងតាមរយៈការពិគ្រោះយោបល់ និងការចរចាដោយរដ្ឋអធិបតេយ្យភាពពាក់ព័ន្ធនឹងជម្លោះផ្ទាល់**...» គឺមានន័យថា បានតម្រូវឱ្យភាគីជម្លោះដោះស្រាយតែក្នុងរង្វង់ប្រទេសពាក់ព័ន្ធនឹងជម្លោះតែប៉ុណ្ណោះ គឺពុំងាកទៅរកភាគីទី៣នោះទេ។ ប៉ុន្តែផ្ទុយមកវិញ សំរាប់ប្រទេសហ្វីលីពីន បានបកស្រាយនៅត្រង់ចំណុច «...**ប្តេជ្ញាដោះស្រាយជម្លោះ...ដោយសន្តិវិធី...ដោយអនុលោមតាមគោលការណ៍ និងច្បាប់អន្តរជាតិដែលទទួលស្គាល់ជាសកលរួមមានអនុសញ្ញាUNCLOS ឆ្នាំ១៩៨២ ស្តីពីនីតិសមុទ្រក៏ដោយ**» គឺថាប្រទេសហ្វីលីពីន មានសិទ្ធិគ្រប់គ្រាន់ក្នុងការផ្តួចផ្តើមបណ្តឹងទៅកាន់សាលាក្តី PCA ដែលប្រទេសចិនចាត់ទុកថា ខុសពីអ្វីដូចមានចែងនៅក្នុង DoC។ ដូច្នេះ យើងយល់ថា ការមានមតិយល់ឃើញខុសៗគ្នាផ្អែកតាម**ការបកស្រាយខាងផ្លូវច្បាប់** វាជាឧបសគ្គដ៏ចម្បងមួយមកលើដំណោះស្រាយជម្លោះ ក្នុងដំណើរទៅរកភាពវិជ្ជមាននៅថ្ងៃខាងមុខ។ នេះនៅពុំទាន់បានរាប់បញ្ចូលភាពបត់បែនផ្នែកនយោបាយ បញ្ហាជាតិនិយម និងការឃាយីពីប្រទេសទី៣មកក្នុងជម្លោះនេះផង។

ពាក់ព័ន្ធនឹងបញ្ហាខាងលើ ថ្វីត្បិតតែអាស៊ាន មានតួនាទីត្រឹមតែជាអ្នកសម្របសម្រួលជម្លោះ និងបានប្រកាន់ខ្ជាប់នូវគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃក៏ដោយ ក៏ប៉ុន្តែ អាស៊ាន បានបង្កើតឱ្យមានភាពមន្ទិលសង្ស័យតាមរយៈការភ្ជាប់ធម្មនុញ្ញភាពរបស់ខ្លួនមកក្នុងស្មារតីសេចក្តីប្រកាសនៃក្រមប្រតិបត្តិដែលធ្វើឱ្យដំណោះស្រាយជម្លោះកាន់តែមានភាពស្មុកស្មាញ។ សិទ្ធិស្វ័យសំរេចរបស់ប្រទេសដែលពុំជាប់ពាក់ព័ន្ធនឹងជម្លោះក្នុងការប្រើសិទ្ធិវ៉េតូ ថ្វីត្បិតតែធ្វើឡើងក្នុងគោលបំណងរក្សានូវការឯកភាពអាស៊ាន ស្ថិរភាពសន្តិសុខក្នុងតំបន់អាស៊ាន ប៉ុន្តែ វាជាចំណុចខ្សោយមួយរបស់អាស៊ាន ក៏ដូចជាប្រទេសដែលពាក់ព័ន្ធ

នឹងជម្លោះពីព្រោះថា ការប្រើសិទ្ធិវ៉េតូ បានបង្កើតឱ្យមានភាពរាំងស្ទះ និងធ្វើឱ្យដំណោះស្រាយជម្លោះ រឹតតែមិនអាចរកច្រកចេញបានសមតាមការខិតខំប្រឹងប្រែងរបស់អាស៊ាន-ចិនដែលបានធ្វើកន្លងមកនោះទេ។ ដូច្នេះ ចំពោះការចូលរួមសម្របសម្រួលជម្លោះពីអាស៊ានដែលបានភ្ជាប់ធម្មនុញ្ញភាពរបស់ខ្លួន កើតឡើងចេញពីកត្តាពីរចំណុចៈ

**ទី១** សំរាប់ប្រទេសជម្លោះដែលមានមាឌតូច និងកម្លាំងខ្សោយជាង ដូចជាប្រទេសវៀតណាម និងហ្វីលីពីនជាដើម ដើម្បីទទួលបានតុល្យភាពកម្លាំង បានយល់ថា មានតែអាស៊ាន និងស្ថាប័នយុត្តិធម៌អន្តរជាតិប៉ុណ្ណោះដែលមានអំណាចគ្របសង្កត់ទៅលើប្រទេសចិន ប៉ុន្តែទង្វើនេះ វាខុសទៅនឹងស្មារតីសេចក្តីប្រកាសនៃក្រមប្រតិបត្តិដែលបានតម្រូវឱ្យពួកគេដោះស្រាយជម្លោះដោយផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ និង

**ទី២** សំរាប់ប្រទេសចិនវិញ ដើម្បីប្រឆាំងទៅនឹងទង្វើខាងលើ បានបញ្ចុះបញ្ចូលសមាជិកអាស៊ានណាមួយដែលពុំបានពាក់ព័ន្ធនឹងជម្លោះប្រើសិទ្ធិវ៉េតូទៅលើបំណងណាមួយដែលអាចអូសទាញអាស៊ានទាំងមូលមកតតាំងនឹងខ្លួន ដែលអាចបង្កឱ្យមានផលវិបាកទាំងផ្នែកច្បាប់ និងតុល្យភាពកម្លាំងមកក្នុងដំណោះស្រាយជម្លោះនេះបាន។

ក្រៅពីកត្តាទាំងពីរខាងលើ ដើម្បីធ្វើឱ្យដំណោះស្រាយជម្លោះមករកភាពកាន់តែប្រសើរ អាស៊ាន-ចិន នៅមានការប្រឈមថ្មីមួយទៀត គឺបន្តការធ្វើឱ្យមានប្រសិទ្ធិភាពមកក្នុងដំណោះស្រាយជម្លោះតាមរយៈការកសាងឱ្យបានក្រមប្រតិបត្តិ (CoC) មួយដែលមានទម្ងន់ជាង (DoC)។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រហូតមកដល់នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៧ អាស៊ាន-ចិន អនុម័តបានក្របខ័ណ្ឌនៃក្រមប្រតិបត្តិមួយ (The Framework of CoC) តែនៅមិនទាន់ឈានដល់ចំណុចកុងសង់ស៊ីសរួមមួយនៅឡើយទេ ថាតើ The framework of CoC មានប្រសិទ្ធិភាព និងដែនកំណត់ដែលអាចដោះស្រាយជម្លោះត្រឹមកំរិតណានោះទេ ពីព្រោះប្រទេសដែលមានជម្លោះនឹងប្រទេសចិននៅមានការខ្វែងគំនិតគំនិតគ្នានៅឡើយ។

ផ្អែកតាមការដកស្រង់សំដីរបស់លោកបណ្ឌិតសាស្ត្រាចារ្យ មីង ចាងលី (Dr. Mingjiang Li) នៃសាលាសិក្សាអន្តរជាតិ S. Rajaratnam (RSIS) បានឱ្យដឹងថា លោកអតីតរដ្ឋមន្ត្រីការបរទេសចិន យ៉ាង ហ្ស៊ិចចី (Yang Jiechi) បានសង្កត់ធ្ងន់ថា "CoC គឺបានផ្អែកទាំងស្រុងទៅតាម DoC ..." គឺមិនបានចងទៅដោយផ្លូវច្បាប់នោះទេ។ រីឯលោករដ្ឋមន្ត្រី

ការបរទេសចិន វ៉ាង យី (Wang Yi) ក៏បានមានប្រសាសន៍ដែរថា ក្របខ័ណ្ឌនៃក្រមប្រិតបត្តិ (CoC) មិនមែនជាឧបករណ៍ផ្លូវច្បាប់ដែលត្រូវយកមកដោះស្រាយជម្លោះដែនដី ឬក៏បញ្ហាកំណត់ព្រំដែនទឹកនោះឡើយ។ ចំពោះការលើកឡើងបែបនេះ គឺបានផ្ទុយនឹងប្រទេសជម្លោះដ៏ទៃដែលបានលើកឡើងថា CoC ជាឧបករណ៍បានចងទៅដោយផ្លូវច្បាប់។

ដូច្នេះ បើតាមអ្វីដូចបានបកស្រាយខាងលើ ចំពោះដំណោះស្រាយជម្លោះនៅតំបន់ប្រជុំកោះស្ព្រាតលីនៃតំបន់សមុទ្រចិនខាងត្បូង គឺជាដំណោះស្រាយមួយដែលមានលក្ខណៈស្មុកស្មាញ នឹងមិនងាយស្រួលក្នុងការដោះស្រាយនោះឡើយ ពីព្រោះថា ទាំងសេចក្ដីប្រកាសនៃក្រមប្រតិបត្តិ (DoC) ទាំងក្របខណ្ឌនៃក្រមប្រតិបត្តិ (CoC)គ្រាន់តែជាគោលការណ៍កំណត់ដែលតម្រូវឱ្យគ្រប់ភាគីជម្លោះថា តើត្រូវដោះស្រាយតាមវិធីណាមួយនោះឡើយ ប៉ុន្តែផ្ទុយមកវិញ គឺមិនទាន់បានកំណត់រូបមន្តដោះស្រាយជាក់លាក់ណាមួយថាតើត្រូវស្រាយបានយ៉ាងរបៀបណា។ បើនិយាយពីតួនាទីរបស់អាស៊ាន នាពេលកន្លងមកថា តើអាស៊ានបានបំពេញតួនាទីក្នុងនាមជាអ្នកសម្របសម្រួលដល់ត្រឹមកំរិតណា? តាមការជាក់ស្ដែង រាល់ការបើកកិច្ចប្រជុំកំពូលអាស៊ានម្ដងៗ ជាពិសេសពាក់ព័ន្ធនឹងជម្លោះនៅតំបន់សមុទ្រចិនខាងត្បូង អាស៊ាន តែងតែបរាជ័យក្នុងការបញ្ចូលរបៀបវារៈរបស់អាស៊ាន និងថែមទាំងបានបង្កើតឱ្យមានភាពតានតឹង បើមិនរវាងសមាជិកខ្លួនដែលមានជម្លោះជាមួយនឹងប្រទេសចិន ក៏ជាមួយនឹងសមាជិកអាស៊ានដែលពុំពាក់ព័ន្ធនឹងជម្លោះដែក្នុងការប្រើសិទ្ធិវ៉េតូដែរ។ ឧទាហរណ៍ ដូចជាករណីជម្លោះនៅតំបន់ប្រជុំកោះប៉ប្រ៉ះទឹកស្កាបូរ៉ូស (Scarbourough Shoal Standoff) និងការមិនបានចេញសេចក្ដីថ្លែងការណ៍រួមក្នុងឆ្នាំ ២០១២ ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះដែលធ្វើឱ្យទំនាក់ទំនងកម្ពុជា-ហ្វីលីពីនធ្លាក់ចុះយ៉ាងខ្លាំង និងការដែលប្រទេសកម្ពុជា មិនបានគាំទ្រឱ្យអាស៊ាន ដាក់បញ្ចូលសេចក្ដីសម្រេចរបស់សាលាក្ដី PCA ដែលបានផ្ដួចផ្ដើមដោយប្រទេសហ្វីលីពីនមកក្នុងរបៀបវិរៈនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤៩ឆ្នាំ នៅទីក្រុងវៀងច័ន្ទក្នុងប្រទេសឡាវក្នុងឆ្នាំ២០១៦ដែលមានមតិមិនតិចទេ បានរិះគន់ និងវាយប្រហារមកលើកម្ពុជា។

ចំពោះការខ្វែងគំនិតគ្នាទៅលើការបកស្រាយខាងផ្លូវច្បាប់របស់ប្រទេស ដែលពាក់ព័ន្ធនឹងជម្លោះនៅក្នុងសេចក្ដីប្រកាសនៃក្រមប្រតិបត្តិវិញ ជាបញ្ហាប្រឈមថ្មីមួយទៀតចំពោះ

អាស៊ាននៅថ្ងៃខាងមុខថា តើអាស៊ានត្រូវរកវិធីថ្មីក្នុងការកែប្រែ ឬសម្រួល រឺប្រការនៅក្នុងសេចក្តីប្រកាស និងថា តើអាស៊ាន គួរតែទុកឱ្យជម្លោះនេះត្រូវតែយកមកដោះស្រាយតែក្នុងរង្វង់ប្រទេសដែលមានជម្លោះឬយ៉ាងណា? ក្នុងខណៈពេលដែលមាត្រានៃធម្មនុញ្ញអាស៊ានមួយចំនួន បានបង្កើតពីភាពរាំងស្ទះនៅក្នុងដំណើរការ ក៏ដូចជាយន្តការដោះស្រាយជម្លោះម្តងៗ។ ចំពោះការប្រកាន់យកដំណោះស្រាយជម្លោះផ្អែកតាមកត្តាប្រវត្តិសាស្ត្រ កត្តាជាតិនិយម ក៏ដូចជាការដាក់បញ្ចូលអធិបតេយ្យភាពទីប្រជុំកោះប៉ារ៉ាសែល និងប្រជុំកោះស្ព្រាតលីនៃតំបន់សមុទ្រចិនខាងត្បូងមកក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសដែលមានជម្លោះនីមួយៗ គឺជាបញ្ហារសើប និងគ្រោះថ្នាក់បំផុតសំរាប់ថ្នាក់ដឹកនាំរបស់គេ។

សរុបសេចក្តីមក យើងឃើញថា ចំពោះដំណោះស្រាយជម្លោះនៅក្នុងតំបន់សមុទ្រចិនខាងត្បូង ជាពិសេសនៅតំបន់ជម្លោះនៃទីប្រជុំកោះស្ព្រាតលី នឹងមិនអាចដោះស្រាយចេញបានក្នុងពេលឆាប់ៗនោះទេ យ៉ាងហោចណាស់ ក៏ត្រូវការរយៈពេលបីទសវត្សរ៍ទៀតដែរ មុននឹងរកដំណោះស្រាយបាន។ ការលើកយកមកធ្វើការវិភាគបែបនេះ គឺរដោយសារតែ វាជាជម្លោះពាក់ព័ន្ធនឹងដែនអធិបតេត្យភាព វាជាអាយុជីវិតរបស់សេដ្ឋកិច្ច និងជាទីតាំងភូមិសាស្ត្រដែលបំរើឱ្យជាតិនីមួយៗនីមួយៗ ជាពិសេស ការដណ្តើមយកធ្វើជាទីតាំងនយោបាយភូមិសាស្ត្រ ពីប្រទេសមហាអំណាចក្នុងសតវត្សរ៍ទី២១ មានដូចជា ប្រទេសចិន និងសហរដ្ឋអាមេរិកជាដើម ក្នុងការដណ្តើមយកកិត្យានុភាព និងការក្តោបយកអំណាចទាំងស្រុងមកកាន់ក្នុងដៃ។

## ៥.២ អនុសាសន៍

ផ្អែកតាមការសន្និដ្ឋានខាងលើ ដើម្បីបញ្ចៀសភាពតានតឹង និងការឈានទៅរកដំណោះស្រាយជម្លោះនៅក្នុងតំបន់សមុទ្រចិនខាងត្បូងក្នុងរយៈពេលវែង គ្រប់ប្រទេសដែលពាក់ព័ន្ធនឹងជម្លោះ ត្រូវតែអនុវត្តនូវអ្វីដែលពួកគេបានព្រមព្រៀងគ្នា រីឯអាស៊ានដែលមានតួនាទីធ្វើជាអ្នកសម្របសម្រួលជម្លោះ ត្រូវតែជៀសវាងយកធម្មនុញ្ញរបស់ខ្លួនមកជាប់ព័ន្ធនៅមកក្នុងដំណោះស្រាយជម្លោះ ដូចខាងក្រោម៖

១-គោរពសេចក្តីប្រកាសនៃក្រមប្រតិបត្តិគ្រប់ភាគីជម្លោះ នៅតំបន់សមុទ្រចិនខាងត្បូង (DoC) តាមរយៈការរួមគ្នាបន្តអនុវត្តដោះស្រាយដោយផ្អែកតាមក្របខណ្ឌនៃក្រមប្រតិបត្តិ

(CoC) ទោះជាតាមរយៈកិច្ចប្រជុំកំពូលអាស៊ានក្តី ឬតាមកិច្ចប្រជុំវេទិកាតំបន់ក្តី។ រាល់ដំណោះស្រាយជម្លោះ គួរតែធ្វើការចរចាដោយផ្ទាល់ (Direct Negotiation) ព្រោះការធ្វើបែបនេះ នឹងទទួលបានការយោគយល់គ្នា ការទទួលបានទំនុកចិត្ត និងការកាត់បន្ថយបាននូវភាពស្មុកស្មាញក្នុងករណីដែលភាគីជម្លោះ លើកយកមកបកស្រាយតាមផ្លូវច្បាប់ចេញពី DoC និង CoC ។

២-បង្រួមការខ្វែងគំនិតគ្នា ធ្វើការដោះស្រាយជម្លោះតែក្នុងរង្វង់ប្រទេសដែលពាក់ព័ន្ធនឹងជម្លោះផ្ទាល់ដោយគ្មានភាគីទីបីចូលរួមមកក្នុងដំណោះស្រាយជម្លោះ កាត់បន្ថយការបង្កើនតុល្យភាពកម្លាំងយោធា និងបង្កើនសមត្ថភាពយោធា និងត្រូវរក្សាតំបន់ជម្លោះឱ្យនៅស្ថានភាពដើម (Status Quo)។

៣-ជៀសវាងលើកយកសេចក្តីសំរេចរបស់តុលាការមជ្ឈត្តកម្មអចិន្ត្រៃយ៍ (PCA) មកពិភាក្សាក្នុងកិច្ចប្រជុំអាស៊ានដែលអាចធ្វើជាឧបករណ៍តាមផ្លូវច្បាប់ ក្នុងការដាក់សម្ពាធមកលើប្រទេសចិនពីព្រោះទង្វើរបែបនេះ តែងតែមិនបានទទួលសម្លេងកុងសង់ស៊ីស និងកាន់តែធ្វើឱ្យជម្លោះកាន់ទៅរកភាពតានតឹងដែលអាចផ្លាស់ពីជម្លោះទ្វេភាគី ទៅជាជម្លោះពហុភាគី ឬអាចប្រែក្លាយទៅជាជម្លោះអន្តរជាតូបនីយកម្មបាន។

៤-ដកយកបទពិសោធន៍ក្នុងករណីដោះស្រាយជម្លោះអធិបតេយ្យភាពដែនទឹក និងបង្កើតកិច្ចសហប្រតិការរួមគ្នារវាងភាគីនីមួយៗ ដូចជាក្នុងករណី ជម្លោះរវាងប្រទេសម៉ាឡេស៊ី និងថៃ នៅក្នុងជម្លោះឈូងសមុទ្រថៃ (The Gulf of Thailand) ដែលពួកគេបាន"**ទុកជម្លោះនៅមួយអន្លើ ដោយធ្វើការអភិវឌ្ឍរួមគ្នាជាលក្ខណៈទ្វេភាគី**" ដែលបង្កើតឱ្យមានតំបន់អភិវឌ្ឍរួមគ្នាយកតាមរូបមន្តបែងចែកធនធានធម្មជាតិ នៅក្នុងតំបន់អភិវឌ្ឍរួមតាមរូបមន្ត៥០/៥០។ ប្រទេសពាក់ព័ន្ធនឹងជម្លោះ ត្រូវជៀសវាងបង្កើតឱ្យមានបញ្ហាជាតិនិយមជ្រុលតាមរយៈការដាក់បញ្ចូលតំបន់ជម្លោះមកក្នុងច្បាប់ធម្មនុញ្ញរបស់ខ្លួន ដោយពុំបានផ្អែកតាមកត្តាប្រវត្តិសាស្ត្រ និងស្របតាមច្បាប់អន្តរជាតិ ដូចជា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ ១៩៨២ (UNCLOS) ជាដើម។ ការអនុវត្តបានចំពោះករណីនេះ មានន័យថា ប្រទេសនោះបានចូលរួមបង្ករភាពងាយស្រួលមកក្នុងដំណោះស្រាយជម្លោះ។

៥-គ្រប់ភាគីជម្លោះ ត្រូវមានឆន្ទះ និងទទួលយកការសម្របសម្រួលជម្លោះ ក៏ដូចជាយោបល់ល្អៗពីអាស៊ានក្នុងគោលដៅរក្សាបាននូវស្ថិរភាព ដើម្បីឈានទៅរកទីបញ្ចប់ជម្លោះទោះក្នុងរយៈវែងក្តី ប៉ុន្តែការទទួលយកបានពីភាគីជម្លោះ បានរួមចំណែកកសាងសុខសន្តិភាពនៅក្នុងតំបន់ និងអន្តរជាតិ ការបន្តទទួលបានការអភិវឌ្ឍសេដ្ឋកិច្ចជាតិកាន់តែខ្លាំង រីឯអាស៊ានវិញ នឹងរក្សាបានជាប៉ូលមហាអំណាចមួយនៅក្នុងលោកនាសតវត្សរ៍ទី២១ ថែមទៀតផង។

៦-អាស៊ាន គួរតែលុបចោលនូវប្រការមួយចំនួនចេញពីសេចក្តីប្រកាសនៃក្រមប្រតិបត្តិ (DoC) ជាពិសេស នៅត្រង់សេចក្តីប្រកាសទី៤ ហើយគ្រប់ភាគីជម្លោះ ត្រូវបង្កើតកិច្ចព្រមព្រៀងទ្វេភាគី ជៀសវាងពីការបកស្រាយតាមផ្លូវច្បាប់ដែលកើតចេញពីចំណុចមិនច្បាស់លាស់ដូចមានចែងនៅក្នុង DoC ឧទាហរណ៍ ករណីផ្តួចផ្តើមបណ្តឹងហ្វីលីពីនទៅកាន់តុលាការមជ្ឈត្តកម្មអចិន្ត្រៃយ៍ (PCA) ប្រឆាំងនឹងប្រទេសចិនដែលបានជំទាស់ពីទង្វើរនេះយ៉ាងដាច់អហង្កការ។

៧-អាស៊ាន គួរពុំគំរូវឱ្យមានការអនុម័តកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងជម្លោះដោយផ្អែកតាមសម្លេងកុងសង់ស៊ីសនោះទេ និងត្រូវកំណត់ព្រំដែនរបស់ខ្លួនត្រឹមឋានៈជាអ្នកសម្របសម្រួលជម្លោះ និងជាអ្នកផ្តល់យោបល់ ហើយត្រូវទុកជម្លោះឱ្យពួកគេជាអ្នកដោះស្រាយដោយផ្ទាល់ខ្លួន។ បើអាចធ្វើដូច្នេះបាន អាស៊ាន មិនត្រឹមតែរក្សាបាននូវទំនាក់ទំនងល្អ និងការឯកភាពផ្ទៃក្នុង ក្នុងចំណោមសមាជិកខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានពីភាពកក់ក្តៅ និងពង្រឹងបានទំនាក់ទំនងកាន់តែប្រសើរ។

# គន្ថនិទ្ទេស

## ឯកសារភាសាខ្មែរ


១- នីតិសមុទ្រ៖ *អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រឆ្នាំ ២០១០*

២- សមុទ្រចិនខាងត្បូង៖ *ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ ឆ្នាំ ២០១៣*

៣- នយោបាយការបរទេស៖ *ម្សិលមិញ ថ្ងៃនេះ និងថ្ងៃស្អែក ឆ្នាំ ២០១៥*

៤- វចនានុក្រមច្បាប់អគ្លេស-ខ្មែរ ឆ្នាំ ១៩៩៧

៥- នីតិអន្តរជាតិសាធារណៈ ឆ្នាំ ២០១១

៦- វចនានុក្រម អង់គ្លេស-ខ្មែរ៖ *ពាក្យច្បាប់ ឆ្នាំ ២០១៣*

៧- ពិភពលោកសតវត្សទី២០៖ *អាស៊ី និងមជ្ឈិមបូព៌ា ឆ្នាំ ២០១១*

៨- បញ្ហាសន្តិសុខតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ ២០១១

៩- មើលឱ្យធ្លុះគ្រប់ផ្នែកអំពី៖ *មហាអំណាចចិន ឆ្នាំ ២០១៥*

១០-មហាយក្សចិន៖ *ភូមិសាស្ត្រនយោបាយនៃប្រទេសចិន*

១១-ចិន នៅក្នុងនយោបាយសកលលោក ឆ្នាំ ២០១៣

១២-ទំនាក់ទំនងអន្តរជាតិ ឆ្នាំ ២០០៣

១៣-សហគមន៍អាស៊ាន

១៤-សង្គ្រាមត្រជាក់៖ *ការដួលរលំប្រព័ន្ធសង្គមនិយម និងឥទ្ធិពលរបស់សង្គ្រាមត្រជាក់ក្នុងតំបន់*

១៥-ចម្បាំងត្រជាក់រវាងអាមេរិក និងចិន ឆ្នាំ ២០១៤

១៦-ជួន ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិតឆ្នាំ១៩៦៧

១៧-សំណួរ-ចម្លើយ៖ *អាស៊ាន*

១៨-អាស៊ាន៖ *ឱកាស និងការប្រឈមមុខ*


## ឯកសារបរទេស


១៩-China Perspectives 2001

២០-Charter Of The United Nations And Statute of The International Court Of Justice

២១-Confidence Building Measures in the South China Sea: By Scott Snyder, Brad Glosserman, and Ralph A. Cossa 2001

២២- Asean Declaration on the South China Sea, signed in Manila, Philippines, July, 1992

២៣- Joint Statement RP-PRC Consultations on the SCS and on Other Areas of Cooperation 9-10 August 1995.

២៤-China's Draft Code of Conduct in The South China Sea.

២៥-Asean Draft Regional Code of Conduct in the South China Sea.

២៦-Full Text: Joint Statement of the Philippines and China, October 21, 2016.

២៧-2002 Declaration on the Conduct of Parties in the South China Sea.

២៨-The Sprately Islands Dispute: Multilateral Negotiations Within Asean and With China.

## ឯកសារស្រង់ពីសារព័ត៌មានខ្មែរ

២៩- រស្មីកម្ពុជា

៣០- ហ្វ្រេសញ៉ូវ (Fresh News)

៣១- ភ្នំពេញប៉ុស្ត៍ (Phnom Penh Post)

៣២- កម្ពុជាដេលី (Cambodia Daily)

## ឯកសារស្រង់ពីសារព័ត៌មានបរទេស

៣៣- Xinhua News

៣៤- Reuters

៣៥- Sputnik International

៣៦- China Daily

៣៧- Philippines Star

៣៨- Associated Press

៣៩- Bangkok Post

៤០- The New York Times


## ឯកសារស្រង់ពីវិទ្យុ

៤១- វិទ្យុបារាំងអន្តរជាតិ

៤២- វិទ្យុអាស៊ីសេរី

៤៣- វិទ្យុសំឡេងសហរដ្ឋអាមេរិក


## ឯកសារស្រង់ពីវេបសាយ

៤៤- Google Vietnam

៤៥- Google BBC

៤៦- Google Philippines

៤៧- Google China

៤៨- Wikipedia. Org

៤៩- The Free encyclopedia

៥០- World Press. Com

៥១- Website Diplomat


## ឯកសារទទួលបានពីសិក្ខាសាលា

៥២- The Belt and Road Initiative and Its Implementations for Cambodia, Symposium Proceedings. 21-22 December 2015, Inter-Continental Hotel Phnom Penh, Cambodia.

៥៣- Symposium on "Promoting Cooperation: Cambodia and the Region under the Belt and Road Initiative.

# ការចំណាយលើការថែទាំសុខភាពនៅកម្ពុជា ២០០៩-២០១៥

*បណ្ឌិត **រស់ ឈុនអៀខ***

ការវិភាគអំការចំណាយលើការថែទាំសុខភាពនោកម្ពុជា មានគោលដៅបង្កើតភ័ស្តុតាង ដើម្បីផ្តល់ជាព័ត៌មាន ដើម្បីរួមចំណែកក្នុងការតាមដាននិងវាយតម្លៃកំណែទម្រង់ប្រព័ន្ធសុខាភិបាលក្នុងការវាស់វែងវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែង លើការគាំពារសុខភាពសង្គម ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកល។ ការសិក្សានេះប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមថ្នាក់ជាតិនៅកម្ពុជាឆ្នាំ ២០០៩-២០១៦ ដើម្បីវិភាគ ដោយប្រើវិធីសាស្ត្រដែលទទួលស្គាល់មានលក្ខណៈស្តង់ដារអន្តរជាតិមួយ ដែលត្រូវបានចងក្រងឡើងដោយអង្គការសុខភាពពិភពលោក ដើម្បីគណនាការចំណាយមហន្តរាយលើការថែទាំសុខភាព និងការធ្លាក់ក្នុងភាពក្រីក្រ។

លទ្ធផលវិភាគបានបង្ហាញថា ប្រជាពលរដ្ឋភាគច្រើនបានស្វែងរកការថែទាំពេលមានជំងឺក្នុងចន្លោះពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥។ ការថយចុះនៃចំណាយមហន្តរាយលើសុខភាពបានធ្លាក់ចុះ ទន្ទឹមនេះ ការធ្លាក់ចូលក្នុងភាពក្រីក្រដោយសារចំណាយលើសុខភាពក៏បានថយចុះផងដែរ។ អ្នករស់នៅជនបទមានការស្វែងរកសេវាថែទាំសុខភាពញឹកញ៉ាប់ជាងអ្នករស់នៅទីប្រជុំជនឬទីក្រុង ទន្ទឹមនោះអត្រាស្វែងរកសេវាថែទាំសុខភាពអ្នករស់នៅទីក្រុងមានការថយចុះ។

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពសំរាប់មនុស្សម្នាក់បានកើនឡើងពី ៤១ ដុល្លាក្នុងឆ្នាំ២០០០៩ មក៤៤ដុល្លាក្នុងឆ្នាំ២០១៥ ហើយសំរាប់គ្រួសារកើនពី ១៨៦ដុល្លា មក១៩៧ ក្នុងឆ្នាំ២០១៥។ សរុបចំណាយលើការថែទាំសុខភាពបានកើនពី ៥៣៤លានដុល្លានៅឆ្នាំ២០០០៩ មក៦៥៣លានដុល្លាក្នុងឆ្នាំ២០១៥។ ក្រុមគ្រួសារស្ថិតក្នុងលំដាប់សេដ្ឋកិច្ចខ្ពស់ជាងគេ មានការចំណាយច្រើនជាង ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចទាបជាងគេ។ ការចំណាយរបស់ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចទាបជាងគេ ហាក់មិនមានការប្រែប្រួលទេ

ប៉ុន្តែការចំណាយ សំរាប់អ្នករស់នៅតំបន់ជនបទកើតឡើងច្រើនជាងអ្នកនៅទីក្រុង។ ការចំណាយពៅហោប៉ៅលើការថៃទាំសុខភាពត្រូវបានស្រូបយកភាគច្រើនដោយអ្នកផ្តល់សេវានៃគ្លីនិកឯកជន។

សមត្ថភាពចំណាយមានការកើនឡើងគួរអោយកត់សំគាល់រវាងឆ្នាំ២០០៩ និង ២០១៥ គឺកើនពី ១.៨៧៣ដុល្លា មក ៣.០០៤ដុល្លា ស្របគ្នាឬមានសង្គត់ភាពទៅនឹងការកើនឡើងនៃចំណាយសរុបរបស់គ្រួសារ។ ការចំណាយពីហោប៉ៅលើការថៃទាំសុខភាពដែលជាសមាសភាគនៃចំណាយសរុបរបស់គ្រួសារបានថយចុះពី៦,៧% មក៤,៦% ទន្ទឹមនោះការចំណាយពីហោប៉ៅជាសមាសភាគនៃសមត្ថភាពចំណាយក៏បានថយចុះពី ១២,៧% មក ៧,៧%ផងដែរ ពីឆ្នាំ២០០៩ មកឆ្នាំ២០១៥។ និន្នាការនៃការធ្លាក់ចូលទៅក្នុភាពក្រីក្រដោយសារការចំណាយពីហោប៉ៅលើការថៃទាមសុខភាពបានថយចុះចាប់តាំងពីឆ្នាំ២០០៩ មក គឺថយពី ៥,៧% មក ១,៤% ក្នុងឆ្នាំ២០១៥ ក៏ដូចគ្នានឹងចំណាយមហន្តរាយផងដែរ មានការថយចុះពី ៨,៨% មក៣,៧%។

ជាទូទៅ ការចំណាយពីហោប៉ៅលើការថៃទាំសុខភាពមានកំរិតខ្ពស់ ខណៈពេលដែលប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាលក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគាំពារសុខភាពសង្គមនិងវឌ្ឍនភាពរបស់ខ្លួនឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល វាមានសារៈសំខាន់ក្នុងការឃ្លាំមើលឬតាមដានការប្រើប្រាស់សេវាសុខភាព និងបន្ទុកហិរញ្ញវត្ថុ ជាមួយគ្នានេះក៏អាចវាយតម្លៃការអនុវត្តប្រព័ន្ធគាំពារសុខភាពសង្គម និងការគ្របដណ្តប់សុខភាពជាសកលផងដែរ។

ហេតុនេះ ការត្រួតពិនិត្យតាមមដានការចំណាយពីហោប៉ៅលើការថៃទាំសុខភាពគឺការវាស់វែងប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តគម្រោងគាំពារសុខភាពសង្គម។ លទ្ធផលនៃការត្រួតពិនិត្យតាមដានក៏គាំទ្រដល់ការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅរកសូចនាករសំខាន់ៗរបស់ការគ្របដណ្តប់សុខភាពជាសកល នៃគោលដៅអភិវឌ្ឍន៏ប្រកបដោយនិរន្តរភាព។ ការត្រួតពិនិត្យបែបនេះគួរអោចត្រូវបានធ្វើឡើងអោយបានទៀងទាត់។

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាកំពុងតែទទួលបានការកែទម្រង់ជាច្រើន ដើម្បីលើកកម្ពស់ការការពារសង្គមឱ្យកាន់តែប្រសើរឡើងសម្រាប់សុខភាព កាត់បន្ថយឧបសគ្គក្នុងការប្រើប្រាស់ និងលើកកម្ពស់គុណភាពសេវាសុខភាព។ ការឃ្លាំមើលវឌ្ឍនភាពនៃកំណែទម្រង់ដែលកំពុងបន្តទាមទារអោយមានទិន្នន័យស្តីពីការការពារហិរញ្ញវត្ថុ និងការវិភាគយ៉ាងហ្មត់ចត់ ដែលអាចគាំទ្រដល់គោលនយោបាយដែលផ្អែកលើភស្តុតាង។ ការចំណាយថវិកាពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋនៅពេលប្រើប្រាស់សេវាសុខភាពគឺជាឧបសគ្គឬរបាំងហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាសុខភាពកម្ពុជា។ ការទូទាត់ថវិកាពីហោប៉ៅ រួមមានថ្លៃពិគ្រោះជំងឺ ការទិញថ្នាំពេទ្យ សំរាកពេទ្យ និងពិគ្រោះជំងឺក្រៅនៅមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន។ សេវាសុខភាពក្នុងវិស័យឯកជនហាក់មិនទាន់ត្រូវបានគ្រប់គ្រងចបាស់លាស់ទេ ដែលធ្វើឱ្យតម្លៃ និងគុណភាពសេវាគឺជាបញ្ហាប្រឈមមួយខ្លាំង។ ការចំណាយថវិកាពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋ អាចបង្ហាញពីឧបសគ្គចម្បងមួយចំពោះការថែទាំសុខភាព និងជាបុព្វហេតុនៃការជំពាក់បំណុល និងភាពក្រីក្រ។ ថវិកាពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋមិនសម្រួលដល់ការចែករំលែកហានិភ័យឬសាមគ្គីភាពរបស់ប្រជាពលរដ្ឋ ដែលជាមុខងារស្នូលនៃគោលនយោបាយហិរញ្ញប្បទាន និងជាធាតុសំខាន់ក្នុងការឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល។ លើសពីនេះទៅទៀតថវិកាពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋ មិនមែនជាមធ្យោបាយស្មើភាព ឬប្រសិទ្ធភាពក្នុងការផ្តល់ហិរញ្ញប្បទានដល់ការថែទាំសុខភាពនោះទេ។ ការពឹងផ្អែកលើថវិកាពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋ បង្កើនលទ្ធភាពអោយមានការចំណាយមហន្តរាយ និងពន្យាពេលឬបោះបង់ចោលសេវាថែទាំ ដោយពួកគេមិនអាចមានលទ្ធភាពបង់ថ្លៃសេវា។ ថវិកាពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋ មានចំនួន ៧២៩ លានដុល្លារអាមេរិក (៦០,៤%) នៃការចំណាយលើការថែទាំសុខភាពសរុបរបស់កម្ពុជា ដែលមានប្រមាណជាង១ពាន់លានដុល្លារ[១]។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការចំណាយថវិកាពីហោប៉ៅ

[១] របាយការណ៍គណនេយ្យសុខាភិបាលជាតិ ក្រសួងសុខាភិបាល ២០១៦

ផ្ទាល់របស់ប្រជាពលរដ្ឋលើការថែទាំសុខភាពគឺជាបញ្ហាប្រឈមមួយ ហើយកំពុងពង្រីក និងពង្រឹងប្រព័ន្ធគាំពារសុខភាពសង្គម រួមមានប្រព័ន្ធធានារ៉ាប់រងសុខភាព និងជំនួយសង្គម។

ឯកសារនេះបង្ហាញពីការរកឃើញនៃការសិក្សាពីការចំណាយប្រាក់ហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋ លើការថែទាំសុខភាព ដោយធ្វើការវិភាគលើនិន្នាការចំណាយថវិកាពីហោប៉ៅ និងតាមដានការការពារផ្នែកហិរញ្ញវត្ថុដោយប្រើសូចនាករផ្សេងៗគ្នា ដោយរួមបញ្ចូលទាំងវិធីសាស្ត្រចងក្រងដោយអង្គការសុខភាពពិភពលោក ក្នុងសម្រាប់វាស់វែងចំណាយមហន្តរាយលើការថែទាំសុខភាព ភាពក្រីក្រដោយសារចំណាយលើការថែទាំសុខភាព និងបំណុលដោយសារការចំណាយរបស់គ្រួសារលើការថែទាំសុខភាព។ សូចនាករទាំងនេះអាចប្រើដើម្បីវាស់វែងវឌ្ឍនភាពនៃការការពារហិរញ្ញវត្ថុ និងភាពខុសគ្នានៃហានិភ័យហិរញ្ញវត្ថុសមាសភាគសំខាន់ៗនៃសមធម៌ក្នុងការគ្របដណ្តប់សុខភាពជាសកល។

## គោលបំណង

គោលបំណងរួមនៃការសិក្សានេះ គឺផលិតភស្តុតាងដើម្បីផ្តល់ជាពត៌មានដល់ការសម្រេចចិត្តរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ និងរួមចំណែកដល់ការត្រួតពិនិត្យតាមដាន និងវាយតំលៃកំណែទម្រង់ប្រព័ន្ធសុខាភិបាលនៅកម្ពុជា។

## គោលដៅ

- ប៉ាន់ស្មានចំណាយពីហោប៉ៅលើការថែទាំសុខភាពនៅកម្ពុជាឆ្នាំ ២០០៩-២០១៥
- ប៉ាន់ស្មានចំណាយមហន្តរាយ និងការធ្លាក់ចុះទៅរកភាពក្រីក្រដោយសារចំណាយលើការថែទាំសុខភាព
- គាំទ្រដល់ការវាស់វែង និងការតាមដានការគ្របដណ្តប់សុខភាពជាសកល

# ២. ប្រភពទិន្នន័យ និងវិធីសាស្ត្រ

## ២.១. ប្រភពទិន្នន័យ

ប្រភពទន្នន័យសំខាន់សម្រាប់ការសិក្សានេះគឺ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (Cambodia Socio Economic Survey-CSES) ដែលជាការអង្កេតថ្នាក់ជាតិធ្វើឡើងជារៀងរាល់ឆ្នាំដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ការអង្កេតនេះប្រមូលទិន្នន័យស្តីពីលក្ខណៈប្រជាសាស្ត្រ លំនៅដ្ឋាន កសិកម្ម អប់រំ កំលាំងពលកម្ម សុខភាពនិងអាហារបំប៉ន

និងចំណូល និងការប្រើប្រាស់របស់គ្រួសារ។ ការចំណាយពីហោប៉ៅលើការថែទាំសុខភាព ប្រើប្រាស់ទិន្នន័យក្នុងម៉ូឌុលចំណាយមិនមែនម្ហូបអាហារនៅក្នុងទិន្នន័យអង្កេត យ៉ាងណានោះ ការណ៍នេះទំនងជាផ្តល់នូវលម្អៀងតិចតួចនៃការប៉ាន់ស្មានសមាមាត្រនៃការចំណាយទូទៅ របស់គ្រួសារទៅលើការថែទាំសុខភាព[២]។ សមាមាត្រនៃការចំណាយលើសុខភាពនិងការឆ្លើយ តបទៅនឹងសំណួរអង្កេតជាក់លាក់ស្តីពីការចំណាយលើការថែទាំសុខភាពកំណត់ដោយ លក្ខណៈបុគ្គល ដូចជាអាយុ ទីលំនៅ ភេទនិងអ្នកផ្តល់សេវា ត្រូវបានយកចេញពីម៉ូឌុល "សុខភាព"។

ទម្ងន់នៃសំណាកគំរូរបស់អង្កេតត្រូវបានអនុវត្ត ដើម្បីបង្កើតទិន្នន័យតំណាងទូទាំង ប្រទេសក៏ដូចជាសម្រាប់ក្រុមនៃប្រជាជននីមួយៗ (មើលទៅលើស្ថានភាពសេដ្ឋកិច្ចសង្គម អ្នករស់នៅទីក្រុងធៀបនឹងជនបទ អាយុនិងភេទ)។ ទម្ងន់ឯកត្តជនត្រូវបានប្រើសម្រាប់ការ វិភាគតាមបុគ្គលនីមួយៗ (ឧ. ជំងឺ ការប្រើប្រាស់សេវាថែទាំសុខភាព និងការចំណាយតាម ប្រភេទអ្នកផ្តល់សេវា ភេទ អាយុនិងជំងឺ) និងទម្ងន់ជាលក្ខណៈគ្រួសារត្រូវបានប្រើសម្រាប់ ការវិភាគតាមគ្រួសារ (ឧ. ការចំណាយពីហោប៉ៅ ចំណាយមហន្តរាយ និងការធ្លាក់ខ្លួនក្រ ដោយសារចំណាយលើការថែទាំសុខភាព)។

## ២.២. វិធីសាស្រ្តវិភាគ

ការសិក្សានេះប្រើប្រាស់វិធីសាស្រ្តស្តង់ដារនិងទទួលស្គាល់ជាអន្តរជាតិ ដែលចងក្រង ឡើងដោយអង្គការសុខភាពពិភពលោក ដែលបរិយាយអំពីការបែងចែកចំណាយ មហន្តរាយ ចំណាយ និងការធ្លាក់ក្នុងភាពក្រីក្រដោយសារចំណាយលើការថែទាំងសុខភាព ដោយ ប្រើប្រាស់កម្មវិធី ស្តាតា១៤(STATA Version 14)៖

- ការប៉ានស្មានករណីជំងឺ និងប្រើប្រាស់សេវាថែទាំសុខភាព ទិន្នន័យបានមកពីម៉ូឌុល ចំណាយលើការថែទាំសុខភាពរបស់ CSES ។ អត្រាកើតជំងឺត្រូវបានគណនាដោយ ផ្អែកលើចំនួនបុគ្គលដែលបានរាយការណ៍ថាមានជំងឺ របួស ឬបញ្ហាសុខភាពក្នុង រយៈពេល៣០ថ្ងៃមុន។ ទម្ងន់នៃអង្កេតត្រូវបានអនុវត្តដើម្បីអោយទិន្នន័យអាចជា

---

[២] Rannan-Eliya, R. (2010) Estimating OOP spending for national health accounts. Geneva: World Health Organization

តំណាងប្រជាជនទូទាំងប្រទេស និងការប៉ាន់ស្មានតួលេខជាតិផ្អែកលើចំនួនមធ្យមនៃការឈឺឬមានជម្ងឺសំរាប់មនុស្សម្នាក់ ដោយយកចំនួនអ្នកឈឺបានរាយការណ៍ចែកអោយចំនួនប្រជាជនសរុប។

- ភាគរយនៃការថែទាំ ឬការព្យាបាល ដែលស្វែងរកសម្រាប់គ្រប់ដំណាក់កាលនៃជំងឺត្រូវបានគណនាដោយផ្អែកលើចំនួនអ្នកដែលបានស្វែងរកការថែទាំ ឬព្យាបាលជំងឺដែលបានរាយការណ៍ក្នុងរយៈពេល 30 ថ្ងៃមុន ចែកអោយចំនួនអ្នករាយការណ៍ថាឈឺ។
- ការប្រើប្រាស់សេវាតាមប្រភេទអ្នកផ្តល់សេវាផ្សេងៗគ្នា ត្រូវបានគេគណនាជាសមាមាត្រប្រើប្រាស់តាមប្រភេទសេវាដោយយកចំនួនអ្នកស្វែងរកសេវាតាមប្រភេទអ្នកផ្តល់សេវា ចែកអោយចំនួនអ្នកស្វែងរកសេវាសរុប។
- ការចំណាយពីហោប៉ៅលើការថែទាំសុខភាព ត្រូវបានធ្វើឡើងដោយបុគ្គលនៅពេលពួកគេទទួលឬប្រើប្រាស់សេវាសុខភាព។ វាត្រូវបានសន្មត់ថាការចំណាយដែលបានរាយការណ៍នៅក្នុងការអង្កេត គឺជាការចំណាយពីហោប៉ៅលើការថៃទាមសុខភាពដោយមិនមានសំណងពីអ្នកផ្តល់សេវាជានារ៉ាប់រងសុខភាពឬប្រភពផ្សេងទៀតទេ។ ការចំណាយពីហោប៉ៅលើការថែទាំសុខភាពត្រូវបានគណនាដូចខាងក្រោម៖

✓ ការចំណាយពីហោប៉ៅសំរាប់មនុស្សម្នាក់=

$$\frac{\text{សរុបចំណាយថវិកាពីហោប៉ៅ សំរាប់អ្នកមានជំងឺ}_i}{\text{សរុបចំនួនអ្នកឈឺ}}$$

✓ ការចំណាយពីហោប៉ៅលើការពិគ្រោះជំងឺ១ដង=

$$\frac{\text{ចំណាយពីហោប៉ៅលើសេវាពិគ្រោះជំងឺ}}{\text{សរុបករណីពិគ្រោះជំងឺ}}$$

✓ ការចំណាយពីហោប៉ៅលើការសំរាកពេទ្យ១ដង=

$$\frac{\text{ចំណាយពីហោប៉ៅលើសេវាសំរាបពេទ្យ}}{\text{សរុបចំនួនអ្នកសំរាកពេទ្យ}}$$

- សមត្ថភាពចំណាយរបស់គ្រួសារត្រូវបានកំនត់ថាជាចំណាយលើសពីចំណាយលើតម្រូវការចំបាច់ចិញ្ចឹមជីវិត កាលណាចំណាយលើចំណីអាហារតិចជាងចំណាយលើតម្រូវការចំបាច់ចិញ្ចឹមជីវិតនោះ ចំណាយផ្សេងៗក្រៅពីចំណីអាហារត្រូវបានចាត់ថាជាចំណាយមិនចាំបាច់។ សមត្ថភាពចំណាយ=ចំណាយសរុប-ចំណាយចិញ្ចឹមជីវិត។ បន្ទុកចំណាយលើសុខភាព ត្រូវបានកំនត់ថាជាចំណាយពីហោប៉ៅ ក៏ដូចជាភាគរយនៃសមត្ថភាពចំណាយរបស់គ្រួសារ។ បន្ទុកចំណាយលើសុខភាព(OOP)=ចំណាយពីហោប៉ៅ/សមត្ថភាពចំណាយ។
- ចំណាយមហន្តរាយលើការថែទាំសុខភាពត្រូវបានកំណត់នៅពេលចំណាយពីហោប៉ៅស្មើរឬលើស៤០%នៃសមត្ថភាបចំណាយរបស់គ្រួសារ[៣]។ អថេរដាំមីលើចំណាយមហន្តរាយលើការថែទាំសុខភាពត្រូវបានរៀបចំ ដោយលេខ១ បញ្ជាក់ថាគ្រួសារមានមហន្តរាយចំណាយ និងលេខពីបញ្ជាក់ថាគ្រួសារមិនមានមហន្តរាយចំណាយ។ ចំណាយមហន្តរាយលើការថែទាំសុខភាព=១ ប្រសិនចំណាយពីហោប៉ៅ/សមត្ថភាពចំណាយលើសឬស្មើ ០,៤ ឬ ៤០% ហើយចំណាយមហន្តរាយលើការថែទាំសុខភាព=0 ប្រសិនចំណាយពីហោប៉ៅ/សមត្ថភាពចំណាយតិចជាង០,៤ឬ ៤០%។
- គ្រួសារដែលមិនមានជីវភាពក្រីក្រ ធ្លាក់ក្នុងភាពក្រីក្រដោយការបង់ថ្លៃសេវាសុខភាព។ ដើម្បីវាយតម្លៃពីវិសាលភាពនៃភាពក្រីក្រ អថេរដាំមីលើភាពក្រីក្រដែលទទួលរងឥទ្ធិពលពីចំណាយលើការថែទាំសុខភាពត្រូវបានកំនត់ថា បើស្មើ១ កាលណាចំណាយរបស់មនុស្សម្នាក់ស្មើឬលើសពីបន្ទាត់នៃភាពក្រីក្រ[៤]មុនចំណាយលើការថែទាំសុខភាព ហើយបើស្មើ០ កាលណាវាទាបជាងបន្ទាត់នៃភាពក្រីក្របន្ទាប់ពីចំណាយពីហោប៉ៅ។

---

[៣] Xu K, Klavus J, Kawabata K, Evans DB, Hanvoravongchai P, Ortiz de Iturbide JP, et al. Household healt system contributions and capacity to pay: definitional, empirical and technical challenges. In: Murray CJL, Evans DB, eds. Health systems performance assessment: debates, methods and empiricism. Geneva: World Health Organization; ២០០៣.

[៤] Source: National poverty line ២០០៩–២០១៤, Ministry of Planning, and ២០១៦ values were estimated taking into account inflation

- សូចនាករអភិវឌ្ឍប្រកបដោយចេរភាព ៣.៨.២ បានកំណត់ថា ការចំណាយពីហោប៉ៅរបស់គ្រួសារគឺជាសមាសភាគចំណាយមួយដែលស្មើឬលើសពី១០% (កំរិតទាប) និង២០%(កំរិតខ្ពស់)នៃចំណាយគ្រួសារសរុប[៥]។

# ៣.លទ្ធផល

លទ្ធផលវិភាគបានបង្ហាញថា ប្រជាពលរដ្ឋជាង ៩០% បានស្វែងរកការថែទាំពេលមានជំងឺក្នុងចន្លោះពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៥។ ការថយចុះនៃចំណាយមហន្តរាយលើសុខភាពបានធ្លាក់ចុះពី ៨,៨% ក្នុងឆ្នាំ ២០០៩ ដល់ ៥,១% ក្នុងឆ្នាំ ២០១៥ ទន្ទឹមនេះ ការធ្លាក់ចុះក្នុងភាពក្រីក្រដោយសារចំណាយលើសុខភាពបានថយចុះ ពី៥,៧% ទៅ ១,៤% ក្នុងរយៈពេលដូចគ្នា។

## ៣.១.ការប្រើប្រាស់សេវាសុខភាព

សមាសភាគអ្នកដែលបានរាយការណ៍ថាមានជំងឺក្នុងរយៈពេល៣០ថ្ងៃមុន ប្រែប្រួលក្នុងចន្លោះពី១៤% និង១៩% ហើយអត្រាជំងឺរ៉ាំរ៉ៃមានពី២,៧% ដល់ ៣,៧% ជាមួយគ្នានេះការស្វែងរកសេវាថែទាំក្នុងចំណោមអ្នកមានជំងឺមានពី ៨៧% ដល់ ៩៦% ពីឆ្នាំ២០០៩ មក២០១៥ ។ ហើយអ្នករស់នៅជនបទមានការស្វែងរកសេវាថែទាំសុខភាពញឹកញ៉ាប់ជាងអ្នករស់នៅទីប្រជុំជនឬទីក្រុង ក្នុងនោះអត្រាស្វែងរកសេវាថែទាំសុខភាពរបស់អ្នកនៅទីក្រុងមានការថយចុះពី១១,៣% មក៤,៦% ក្នុងឆ្នាំ២០១៥ (តារាង១)។

[៥] World Health Organization and World Bank (២០១៧). Tracking universal health coverage: ២០១៧ global monitoring report (http://pubdocs.worldbank.org/en/១៩៣៣៧១៥១៣១៦៩៧៩៨៣៤៧/២០១៧-global-monitoring-report.pdf accessed ២៨ March ២០១៨).

**តារាង ១: អត្រាអ្នកស្វែងរកសេវាសុខភាពតាមភូមិសាស្ត្ររស់នៅ ២០០៩- ២០១៥**

| | ២០០៩ (%) | ២០១០ (%) | ២០១៣ (%) | ២០១៤ (%) | ២០១៥ (%) |
|---|---|---|---|---|---|
| ទូទាំងប្រទេស | 14.4 | 16.6 | 16.5 | 13.1 | 13.0 |
| ភ្នំពេញ | 11.3 | 13.6 | 10.2 | 7.2 | 4.6 |
| ទីប្រជុំជនផ្សេងៗ | 13.8 | 14.0 | 16.0 | 12.0 | 12.1 |
| ជនបទ | 14.9 | 17.3 | 17.5 | 14.2 | 14.6 |

សមាសភាគអ្នកមានជំងឺ និងឥរិយាបទស្វែងរកសេវាតាមថ្នាក់សេដ្ឋកិច្ចគ្រួសារ (quintile) លទ្ធផលបង្ហាញថា ចំនួនដងអ្នកដែលមានជំងឺ និងស្វែងរកសេវាថែទាំសុខភាពគិតជាមធ្យម តិចជាង២ដងក្នុង១ខែ ហើយមិនការប្រែប្រួលខុសគ្នាគួរអោយគត់សំគាល់ តែក្រុមប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចទាបជាងគេ ហាក់មានការស្វែងរកសេវាថែទាំសុខភាពតិចជាងក្រុមប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចខ្ពស់។

ជំរើសនៃការស្វែងរកសេវាថែទាំសុខភាពលើកដំបូង លទ្ធផលបង្ហាញថាមូលដ្ឋានសេវាឯកជនគឺជាជំរើសមុនគេសំរាប់អ្នកស្វែងរកសេវាថែទាំសុខភាព និងជំរើសចុងក្រោយនៅគ្រប់ការអង្កេតចាប់តាំងពីឆ្នាំ២០០៩មក ក្នុងនោះកន្លែងលក់ថ្នាំ[៦] ច្រើនជាងគេ និងគ្លីនិកឯកជនពេលអ្នកជំងឺស្វែងរកសេវា១ ឬ២ ដងក្នុង១ខែ។ ប្រជាពលរដ្ឋស្វែងរកសេវាថែទាំសុខភាពញឹកញាប់នៅកន្លែងផ្តល់សេវាមិនមែនវេជ្ជសាស្ត្រ [៧] ជាងនៅមូលដ្ឋានសុខាភិបាលសាធារណៈ ជារឿយៗអ្នកផ្តល់សេវាមិនមែនវេជ្ជសាស្ត្រត្រូវបានមើលឃើញថាមានការថយចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០១៥ (រូបភាព១)។

---

[៦] The term drugstore includes: private pharmacies and shops selling drugs from the non-medical sector ( specific details in Annex ៣ ).

[៧] Non-medical providers include Khmer magicians, shops/markets selling drugs, traditional medicines, religious leaders and traditional birth attendants.

### រូបភាព ១: ជំរើសនៃការស្វែងរកសេវាលើកដំបូង ២០០៩ ២០១៥




ប្រជាពលរដ្ឋស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចទាបជាងគេ ហាក់មានការស្វែងរកសេវាភាគច្រើននៅតាមផ្ទះពេទ្យ កន្លែងលក់ថ្នាំ និងមណ្ឌលសុខភាព ដោយឡែកប្រជាពលរដ្ឋស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ច ខ្ពស់ជាងគេមានការស្វែងរកសេវាថៃទាំសុខភាពនៅគ្លីនិក និងឱសថស្ថានឯកជន (រូបភាព២)។ ប្រជាពលរដ្ឋស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចទាបជាងគេដែលរស់នៅតំបន់ជនបទ មានការស្វែងរកសេវាថៃទាំសុខភាពនៅកន្លែងផ្តល់សេវាមិនមែនវេជ្ជសាស្ត្រច្រើនជាង ប្រជាពលរដ្ឋស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចខ្ពស់ជាងគេរស់នៅតំបន់ទីប្រជុំជន។

រូបភាព ២: អត្រាស្វែងរកសេវាថែទាំសុខភាពតាមប្រភេទមូលដ្ឋានសុខាភិបាល និងលំដាប់ថ្នាក់សេដ្ឋកិច្ច ២០១៥




## ៣.២.ការចំណាយពីហោប៉ៅលើការថែទាំសុខភាព

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពសំរាប់មនុស្សម្នាក់បានកើនឡើងពី ៤១ ដុល្លាក្នុងឆ្នាំ២០០៩ មក៤៤ដុល្លាក្នុងឆ្នាំ២០១៥ ហើយសំរាប់គ្រួសារកើនពី ១៨៦ដុល្លា មក១៩៧ដុល្លា ក្នុងឆ្នាំ២០១៥។ សរុបចំណាយលើការថែទាំសុខភាពបានកើនពី ៥៣៤ លានដុល្លានៅឆ្នាំ២០០៩ មក ៦៥៣លានដុល្លា ក្នុងឆ្នាំ២០១៥(រូបភាព៣)។ គួរកត់សំគាល់ផងដែរថា ការចំណាយពីហោប៉ៅរួមទាំងការចំណាយលើសេវាថែទាំសុខភាពក្រៅប្រទេសផងដែរ ដែលមាន៤%ក្នុងឆ្នាំ២០១៤ និង២២% ក្នុងឆ្នាំ២០១៥។ មានហេតុជាច្រើនដែលបណ្តាលអោយមានការកើនឡើងនេះ: ការកើនឡើងនៃសេដ្ឋកិច្ច លទ្ធភាពចំណាយរបស់គ្រួសារលើការថែទាំសុខភាព ការផ្លាស់ប្តូរនិន្នាការប្រជាសាស្ត្រជាមួយចំណាយកើនឡើងសម្រាប់មនុស្សចាស់ ការកើនឡើងនៃថ្លៃសេវាសុខភាព និងការកើនឡើងនៃការប្រើប្រាស់សេវាសុខភាព ពិសេសសំរាកពេទ្យ។

## រូបភាព ៣: ការចំណាយថវិកាពីហោប៉ៅផ្ទាល់មធ្យមលើការថែទាំសុខភាព របស់មនុស្សម្នាក់ និងក្រុមគ្រួសារមួយ




ក្នុងចន្លោះឆ្នាំ ២០០៩-២០១៥ ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចខ្ពស់ជាងគេ មានការចំណាយច្រើនជាង ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចទាបជាងគេ ជាក់ស្តែងក្នុងឆ្នាំ២០០៩ ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចខ្ពស់ជាងគេ ចំណាយច្រើនជាងក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចទាបជាងគេ ១២ដង និង១៦ដងក្នុងឆ្នាំ២០១៥ ដោយមានកំណើនពី ៥០២ដុល្លាក្នុងឆ្នាំ ២០០៩ មក ៦៥៣ដុល្លាក្នុងឆ្នាំ ២០១៥។ មូលហេតុនៃគំលាតនេះ អាចបណ្តាលមកពីក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចខ្ពស់ជាងគេស្វែងរកសេវាថែទាំនៅក្រៅប្រទេស និងអ្នកផ្តល់សេវាវិស័យឯកជន។ ការចំណាយក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចទាបជាងគេ ហាក់មិនមានការប្រែប្រួលទេ គឺស្ថិតក្នុងរង្វង់៤១ដុល្លា ក្នុងរយៈ៥ឆ្នាំនេះ ប៉ុន្តែការចំណាយ សំរាប់អ្នករស់នៅតំបន់ជនបទមាន២១២ដុល្លា ច្រើនជាងនៅទីប្រជុំជនដែលមានតែ១៤៣ដុល្លា (រូបភាព៤ និងតារាង២)។

រូបភាព ៤: ការចំណាយថវិកាពីហោប៉ៅលើការថែទាំសុខភាព តាមគ្រួសារ លំដាប់ថ្នាក់សេដ្ឋកិច្ច និងភូមិសាស្ត្រ




តារាង ២: ការចំណាយពៅហោប៉ៅតាមលំដាប់ថ្នាក់សេដ្ឋកិច្ច និងភូមិសាស្ត្រ

| លំដាប់ | ២០០៩ | ២០១០ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|
| Q1 | 41 | 40 | 51 | 38 | 35 |
| Q2 | 72 | 81 | 85 | 75 | 76 |
| Q3 | 120 | 106 | 117 | 110 | 88 |
| Q4 | 193 | 191 | 214 | 204 | 136 |
| Q5 | 502 | 605 | 581 | 592 | 653 |
| Urban | 176 | 194 | 176 | 148 | 143 |
| Rural | 188 | 207 | 218 | 219 | 212 |
| Average | 186 | 204 | 210 | 204 | 197 |

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពតាមប្រភេទអ្នកផ្តល់សេវា ក្នុងឆ្នាំ២០១៥ លទ្ធផលបានបង្ហាញថាការចំណាយពៅហោប៉ៅលើការថែទាំសុខភាព ត្រូវបានស្រូបយកភាគច្រើនដោយអ្នកផ្តល់សេវានៃគ្លីនិកឯកជន២៩% ក្រៅប្រទេស ២២% បន្ទាប់មន្ទីរពេទ្យជាតិ ១៨%និងមន្ទីរពេទ្យខេត្ត ៨% មន្ទីរពេទ្យឯកជន៨% កន្លែងលក់ឱសថ ៨% មណ្ឌលសុខភាព៤%។

តារាង ៣: ការបែងចែកចំណាយពីហោប៉ៅតាមប្រភេទអ្នកផ្តល់សេវា

| Health facility | 2009 | 2010 | 2013 | 2014 | 2015 | 2016 |
|---|---|---|---|---|---|---|
| Health center | 4% | 3% | 4% | 5% | 4% | 2% |
| National hospital | 12% | 19% | 5% | 10% | 18% | 15% |
| Provincial hospital | 7% | 9% | 5% | 8% | 8% | 4% |
| District hospital | 8% | 3% | 3% | 4% | 1% | 1% |
| Other public | 2% | 1% | 0% | 1% | 0% | 0% |
| Private hospital | 8% | 4% | 14% | 16% | 8% | 10% |
| Private clinic | 34% | 35% | 43% | 39% | 29% | 45% |
| Drugstore | 9% | 10% | 13% | 9% | 8% | 13.1% |
| Other private | 5% | 9% | 5% | 2% | 1% | 1% |
| Overseas | | | | 4% | 22% | 7% |
| Other | 11% | 7% | 8% | 3% | 2% | 1% |

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពសំរាប់ការពោគ្រោះជំងឺក្រៅ និងសំរាកពេទ្យទិន្នន័យនេះមានត្រឹមអង្កេតឆ្នាំ២០១៣ លទ្ធផលបង្ហាញថាតំលៃនៃការពិនិត្យជំងឺក្រៅ និងសំរាកពេទ្យកើនឡើងរៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៣មក។ ជាក់ស្តែង គិតជាមធ្យមចំណាយលើការពិនិត្យជំងឺក្រៅ១ដងកើនពី១០ដុល្លា មក ១៦ដុល្លា ហើយចំណាយសំរាកពេទ្យក្នុង១ករណីកើនពី១៥១ដុល្លា មក១៧៧ដុល្លា ក្នុងចន្លោះឆ្នាំ២០១៣ និង២០១៥។

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពតាមប្រភេទជំងឺ ទិន្នន័យនេះមានតែនៅក្នុងអង្កេតឆ្នាំ២០១៥ ដោយសន្មត់ថាអ្នកដែលឈឺមានតែប្រភេទជំងឺតែមួយមុខប៉ុណ្ណោះខែមុន។ ថ្វីត្បិតតែមានចំលើយតិចតួចទៅនឹងសំណួរនេះ ហើយលទ្ធផលនៃការវិភាគមិនអាចជាតំណាងអោយទូទាំងប្រទេសបាន តែលទ្ធផលបង្ហាញថាការចំណាយកើតឡើងច្រើនទៅលើការស្វែងរកការថែទាំ និងព្យាបាលជំងឺបេះដូង មហារីកថ្លើម ជំងឺស្រួចស្រាវនានា។

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពតាមភេទលទ្ធផលបានបង្ហាញថា ការចំណាយខ្ពស់កើតឡើងសំរាប់ស្ត្រី ស្ត្រីបានចំណាយប្រាក់លើការថែទាមសុខភាពច្រើនជាងបុរសប្រមាណ១,៣ដង ជាក់ស្តែង ៤២ដុល្លា ហើយបុរស៣៩ដុល្លាក្នុងឆ្នាំ២០០៩ ហើយក្នុងឆ្នាំ២០១៥ ស្ត្រីចំណាយ ៥០ដុល្លា បុរសចំណាយតែ៣៧ដុល្លាប៉ុណ្ណោះ។

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពតាមអាយុចាប់តាំងពីឆ្នាំ២០០៩ ចំណាយពីហោប៉ៅលើការថែទាំសុខភាពគិតជាមធ្យមបានកើនឡើងគួរអោយកត់សំគាល់ ជាមួយគ្នានេះ

ការចំណាយសំរាប់មនុស្សម្នាក់ដែលមានអាយុក្រោម៥ឆ្នាំ និងអាយុចន្លោះពី១៥ទៅ៥៩ឆ្នាំ ហាក់មិនការប្រែប្រួល ហើយសំរាប់អាយុពី៥ ដល់១៤ឆ្នាំមានការថយចុះ ប៉ុន្តែមានការកើនឡើងខ្លាំងសំរាប់អាយុចាប់ពី៦០ឆ្នាំឡើងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥។ ការកើនឡើងនៃការចំណាយនេះ អាចបណ្តាលមកពីការប្រើប្រាស់សេវាញឹកញាប់[៨] និងការកើនឡើងនៃតម្លៃសេវាសុខភាព។

## ៣.៣. សមត្ថភាពចំណាយលើការថែទាំសុខភាព

សមត្ថភាពចំណាយត្រូវបានកំណត់ថា ចំណូលដែលសល់បន្ទាប់ពីចំណាយលើការចិញ្ចឹមជីវិត (ចំណាយលើអាហារ)។ លទ្ធផលបង្ហាញថា មានការកើនឡើងគួរអោយកត់សម្គាល់រវាងឆ្នាំ២០០៩ និង២០១៥ គឺកើនពី ១.៨៧៣ដុល្លា មក ៣.០០៤ដុល្លា ស្របគ្នាឬមានសង្គត់ភាពទៅនឹងការកើនឡើងនៃចំណាយសរុបរបស់គ្រួសារ។ ការចំណាយពីហោប៉ៅលើការថែទាំសុខភាព ដែលជាសមាសភាគនៃចំណាយសរុបរបស់គ្រួសារបានថយចុះពី ៦,៧% មក៤,៦% ទន្ទឹមនោះការចំណាយពីហោប៉ៅជាសមាសភាគនៃសមត្ថភាពចំណាយក៏បានថយចុះពី ១២,៧% មក ៧,៧%ផងដែរ ពីឆ្នាំ ២០០៩ មកឆ្នាំ២០១៥។ លទ្ធផលក៏បានបង្ហាញផងដែរថា ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចទាបបំផុត មានការចំណាយលើការចិញ្ចឹមជីវិត ឬម្ហូបអាហាររហូតទៅដល់៥០% នៃចំណាយសរុប មានន័យថាសមត្ថភាពចំណាយរបស់គេមានកំរិតទាបជាងក្រុមស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចខ្ពស់បំផុត ដែលចំណាយចិញ្ចឹមជីវិតមានត្រឹមតែ ២៥%នៃចំណាយសរុបប៉ុណ្ណោះ។

**តារាង ៤៖ ការចំណាយពីហោប៉ៅ ដែលជាសមាសភាគនៃសមត្ថភាពចំណាយ តាមលំដាប់ថ្នាក់សេដ្ឋកិច្ច**

| Indicator | 2009 | 2010 | 2013 | 2014 | 2015 |
|---|---|---|---|---|---|
| Q1 | 10.8% | 8.7% | 7.2% | 5.6% | 6.2% |
| Q2 | 12.3% | 11.6% | 8.0% | 6.8% | 8.5% |
| Q3 | 13.7% | 11.4% | 8.0% | 7.2% | 7.4% |
| Q4 | 13.9% | 13.2% | 9.8% | 8.7% | 7.7% |
| Q5 | 12.7% | 13.4% | 10.4% | 9.0% | 8.6% |
| Average | 12.7% | 11.7% | 8.7% | 7.5% | 7.7% |

[៨] Across all years, the average number of visits was higher for this group.

## ៣.៤. សូចនាករទាស់ដែនការការពារផ្នែកហិរញ្ញវត្ថុ ក្នុងគោលដៅអភិវឌ្ឍប្រកបដោយចិរភាព ៣.៨.២

លទ្ធផលបង្ហាញថា និន្នាការនៃការធ្លាក់ចូលទៅក្នុភាពក្រីក្រដោយសារការចំណាយពីហោប៉ៅលើការថែទាមសុខភាពបានថយចុះចាប់តាំងពីឆ្នាំ២០០៩មក គឺថយពី ៥,៧% មក ១,៤% ក្នុងឆ្នាំ២០១៥ ក៏ដូចគ្នានឹងចំណាយមហន្តរាយផងដែរ មានការថយចុះពី ៨,៨% មក៣,៧% ក្នុងរយៈពេលដូចគ្នា តាមរូមន្ត ចំណាយលើការថែទាំសុខភាពលើសពី៤០% បន្ទាប់ដកចំណាយចិញ្ចឹមជីវិត ហើយក៏ត្រូវបានមើលឃើញថាវាថយចុះស្របគ្នា បើទោះប្រើរូបមន្តដែលបានកំនត់ក្នុគោលដៅអភិវឌ្ឍប្រកបដោយចេរភាព (តារាងទី៥)។

**តារាង ៥៖ ចំណាយមហន្តរាយ និងការធ្លាក់ក្នុងភាពភាពក្រីក្រ**

| សូចនាករ | ២០០៩ | ២០១០ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|
| ចំណាយលើការថែទាំសុខភាពលើសពី ៤០% បន្ទាប់ដកចំណាយចិញ្ចឹមជីវិត (ចំណាយមហន្តរាយ) | 8.8 | 7.8 | 5.8 | 4.8 | 5.1 |
| ចំណាយលើការថែទាំសុខភាពលើសពី ២៥% នៃចំណាយសរុប (ចំណាយមហន្តរាយ) | 6.5 | 6.4 | 5.3 | 4.7 | 4.8 |
| ចំណាយលើការថែទាំសុខភាពលើសពី ១០% នៃចំណាយសរុប (ចំណាយមហន្តរាយ) | 20.4 | 19.1 | 16.3 | 14.4 | 13.8 |
| ការធ្លាក់ចូលក្នុងភាពក្រីក្រដោយចំណាយលើសុខភាព | 5.7 | 5.3 | 2.5 | 2.1 | 1.4 |

ចំណាយមហន្តរាយលើការថែទាំសុខភាព តាមលំដាប់ថ្នាក់សេដ្ឋកិច្ចនិន្នាការនៃចំណាយមហន្តរាយលើការថែទាំសុខភាពមានការថយចុះ ហើយចំណាយនេះកើតឡើងខ្លាំងសម្រាប់ក្រុមស្ថិតក្នុលំដាប់សេដ្ឋកិច្ចខ្ពស់ ទោះយ៉ាងណាចំណាយនេះក៏ត្រូវបានវាស់វែងបន្ទាប់ពីមានការចំណាយលើការថែទាំសុខភាពរួចផងដែរ។ ការណ៍នេះវាឆ្លើយតបទៅនឹងសមាសភាគ ឬករណីនៃក្រុមគ្រួសារដែលធ្លាក់ក្នុងភាពក្រីក្រដោយការចំណាយពីហោប៉ៅ

ដែលមានខ្ពស់សំរាប់ក្រុមស្ថិតក្នុលំដាប់សេដ្ឋកិច្ចទាបបំផុត។ ចំណាយមហន្តរាយហាក់មានទំនោនៅខ្ពស់រវាង៤% និង៦% ក្នុងចន្លោះឆ្នាំ២០០៩ និង២០១៥។

ចំណាយមហន្តរាយលើការថែទាំសុខភាពនៅកម្ពុជាប្រៀបធៀបជាមួយបណ្តាប្រទេសមួយចំនួននៅអាស៊ី-សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ុងហ្គោលី ហ្វីលីពីន និងវៀតណាម។ លទ្ធផលបង្ហាញថា ការចំណាយមហន្តរាយលើសុខភាពនៅកម្ពុជាខ្ពស់ជាងគេ។ ហើយនិន្នាការចំណាយមហន្តរាយលើសុខភាពនេះ កើតឡើងសំរាប់ក្រុមស្ថិតក្នុងលំដាប់សេដ្ឋកិច្ចមធ្យម និងការចំណាយខ្ពស់បំផុតគឺកើតឡើងសម្រាប់ក្រុមស្ថិតក្នុលំដាប់ថ្នាក់សេដ្ឋកិច្ចកម្រិតខ្ពស់បំផុត។ ការណ៍នេះគឺស្រដៀងគ្នាទៅនឹងបណ្តាប្រទេសផ្សេងទៀត (ប្រទេសម៉ុងហ្គោលី និងហ្វីលីពីន)។ នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ការចំណាយមហន្តរាយខ្ពស់បំផុតមានសំរាប់ក្រុមស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចកម្រិតមធ្យម និងទាបបំផុត ហើយនៅវៀតណាមកើតខ្ពស់សំរាប់ក្រុមស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចកម្រិតមធ្យម ហើយថយចុះជាលំដាប់សំរាប់ក្រុមស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចកម្រិតខ្ពស់បំផុត។

**រូបភាព ៥៖ ចំណាយមហន្តរាយលើការថែទាំសុខភាពក្នុងប្រទេសមួយចំនួន**




*Sources*: Draft cross-country comparative draft report on Access to care and the financial burden of health payments for selected countries in the Western Pacific (២០១៧), WHO Regional Office for the Western Pacific. Data obtained from individual country reports.

## ៣.៥. ប្រភពនៃហិរញ្ញប្បទានសំរាប់ចំណាយលើសុខភាព

ការចំណាយលើការថែទាំសុខភាព ភាគច្រើននៃគ្រួសារពឹងផ្អែកលើចំណូល និងការសន្សំ ទោះយ៉ាងណា ក៏មានប្រមាណជាក្រុមគ្រួសារ៣% ខ្ចីបុលដើម្បីបង់ថ្លៃសេវាថែទាំសុខភាពដែរ ទន្ទឹមនោះក៏ការលក់ទ្រព្យសម្បត្តិ និងផលិតផលនានាដើម្បីចំណាយលើការថែទាំសុខភាព ត្រូវបានមើលឃើញថាថយចុះ ដែលឆ្នាំមុនមានរហូតដល់៧% ហើយឆ្នាំនេះមានត្រឹមតែ១%ប៉ុណ្ណោះ។

**តារាង ៦៖ ប្រភពហិរញ្ញប្បទានសំរាប់ចំណាយលើសុខភាព**

| ប្រភព | ២០១០ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|
| ចំណូល (%) | 69 | 72 | 69 | 55 |
| សន្សំ (%) | 20 | 22 | 23 | 38 |
| ខ្ចីបុល (%) | 3 | 3 | 3 | 4 |
| លក់ទ្រព្យសម្បត្តិ (%) | 2 | 2 | 2 | 0 |
| លក់ផលិតផល (%) | 5 | 2 | 1 | 1 |
| ផ្សេងៗ (%) | 1 | 1 | 2 | 2 |

## ៤.ពិភាក្សា

ការចំណាយពីហោប៉ៅលើការថែទាំសុខភាពមានកំរិតខ្ពស់ ដែលមានរហូតដល់ទៅ ៦០% នៃចំណាយសរុបលើសុខភាពប្រមាណជា ៤៤ដុល្លាអាមេរិកសំរាប់មនុស្សម្នាក់ក្នុងឆ្នាំ ២០១៥។ ខណៈពេលដែលប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាលក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគាំពារសុខភាពសង្គម និងវឌ្ឍនភាពរបស់ខ្លួនឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល វាមានសារៈសំខាន់ក្នុងការឃ្លាំមើលឬតាមដានការប្រើប្រាស់សេវាសុខភាព និងបន្ទុកហិរញ្ញវត្ថុនៃការទូទាត់ថ្លៃសេវាសុខភាពដោយផ្តោតលើសមធម៌ និងវាយតម្លៃការអនុវត្តប្រព័ន្ធគាំពារសុខភាពសង្គម និងឥទ្ធពលនៃការផ្លាស់ប្តូរគោលនយោបាយសុខាភិបាល។ រួមជាមួយនឹងការរបាយការណ៍គណនីសុខាភិបាល និងរបាយការណ៍ហិរញ្ញប្បទានរបស់ក្រសួងសុខាភិបាល របកគំហើញគួរតែបញ្ចូលទៅក្នុងគោលនយោបាយជាតិ និងដំណើរការនៃការរៀបចំផែនការ។

ឥរិយាបថស្វែងរកសេវាសុខភាពនៅពេលដែលមានជំងឺមានកំរិតខ្ពស់នៅគ្រប់មជ្ឈដ្ឋាន (គ្រប់ក្រុមលំដាប់ថ្នាក់សេដ្ឋកិច្ច) ទាំងអស់ ហើយប្រជាជនដែលរស់នៅតាមតំបន់ជនបទតែងតែស្វែងរកសេវាថែទាំសុខភាពញឹកញាប់ជាងអ្នករស់នៅតាមទីក្រុង។ បន្ទុកនៃជម្ងឺរ៉ាំរ៉ៃបានកើនឡើងពី២,៩%ដល់ ៣,៧% ពីឆ្នាំ 2009 ដល់ឆ្នាំ 201៥ ។ សេវាជំងឺមិនឆ្លងនៅតាមបណ្តាមូលដ្ឋានសុខាភិបាល ពិសេសនៅមណ្ឌលសុខភាពនៅមានកម្រិតនៅឡើយ ហើយបច្ចុប្បន្នសេវាទាំងនេះត្រូវបានគេយកទៅព្យាបាលនៅមន្ទីរពេទ្យ។ ចំណាង់ចំណូលចិត្តសម្រាប់អ្នកដែលធ្លាក់ខ្លួនឈឺគឺការទទួលបានការថែទាំពីវិស័យឯកជនសម្រាប់ការចូលមើលលើកដំបូងនិងចុងក្រោយ ជាពិសេសនៅគ្លីនិកឯកជននិងឱសថស្ថានឬឱសថស្ថាន។ ឥរិយាបថស្វែងរកសេវាសុខភាពរបស់ក្រុមលំដាប់ថ្នាក់សេដ្ឋកិច្ចទាប គឺទៅប្រើប្រាស់សេវានៅមណ្ឌលសុខភាព ចំណែកឯក្រុមលំដាប់ថ្នាក់សេដ្ឋកិច្ចខ្ពស់ស្វែងរកការថែទាំនៅឯមន្ទីរពេទ្យឯកជន។

មានការសិក្សាមួយ បានរកឃើញលទ្ធផល ស្រដៀងគ្នានិងការសិក្សានេះថា ហេតុផលដែលប្រជាជនកម្ពុជាមានចំណាប់អារម្មណ៍ទៅលើអ្នកផ្តល់សេវាឯកជនជាងសេវាសាធារណៈដោយសារសេវាសាថារណៈនៅឆ្ងាយនិងមានការរង់ចាំយូរ។ លើសពីនេះទៀត គឺការខ្វះឬអត់មានសេវានៅពេលយប់ និងនៅចុងសប្តាហ៍នៅមណ្ឌលសុខភាព ដែលជាឧបសគ្គមួយចំពោះការចូលដំណើរការផ្ទុយទៅនឹងការថែទាំ២៤ម៉ោងនៅកន្លែងឯកជន។ ជាងនេះទៅទៀតនោះការយល់ដឹងពីអ្វីដែលបង្កើតការថែទាំប្រកបដោយប្រសិទ្ធភាពអាចជះឥទ្ធិពលដល់ជម្រើសជាមួយនោះក៏មានភាពលម្អៀងនៃអន្តរាគមន៍ដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តស្វែងរកសេវាថែទាំផងដែរ[៩] ។

មានអ្នកផ្តល់សេវាសុខាភិបាលត្រឹមតែ ៥៤% ប៉ុណ្ណោះដែលមានការបណ្តុះបណ្តាលជាផ្លូវការដែលជាមូលហេតុនៃការព្រួយបារម្ភចំពោះឥរិយាបថស្វែងរកសុខភាពនៅកម្ពុជា ដែលជួយដល់អ្នកផ្តល់ឯកជន [១០] ។ យ៉ាងណាក៏ដោយរាជរដ្ឋាភិបាល និងក្រុមប្រឹក្សាវេជ្ជសាស្ត្របានខិតខំចុះបញ្ជីអ្នកជំនាញផ្នែកសុខាភិបាលទាំងអស់រួមទាំងអ្នកដែលនៅក្នុងវិស័យឯកជន។ អ្នកផ្តល់សេវាសុខភាពសាធារណៈមានការគោរព និងមានជំនាញវេជ្ជសាស្ត្រច្បាស់លាស់

---

៩ . HNPGP Knowledge Brief (២០១៤). Cambodia's rural health markets and quality of care

១០ . Study on *Cambodia's rural health markets and quality of care, world bank ២០១៦*

ហើយការប្រើប្រាស់អ្នកផ្តល់សេវាសាធារណៈ មានការកើនឡើងជាមួយនឹងការអនុវត្តគំរោងគាំពារសុខភាពសង្គម ពិសេសមូលនិធិសមធម៌ និងប័ណ្ណសុខភាព។ ការណ៍នេះស្រប ជាមួយនឹងការរកឃើញ ដែលថាអ្នកប្រើប្រាស់សេវាសាធារណៈជាទូទៅ ត្រូវបានប្រើប្រាស់ដោយក្រុមស្ថិតក្នុលំដាប់ថ្នាក់សេដ្ឋកិច្ចមានកម្រិតទាប ដែលត្រូវបានបង្កើនលទ្ធភាពដោយគម្រោងជំនួយសង្គម។ ទន្ទឹមនេះកំណើនសេដ្ឋកិច្ចឆាប់រហ័សនិងការពង្រីកប្រព័ន្ធគាំពារសង្គមអាចរួមចំណែកដល់ការបង្កើនការប្រើប្រាស់សេវាសុខាភិបាលនៅគ្រប់មជ្ឈដ្ឋាន ឬគ្រប់លំដាប់ថ្នាក់សេដ្ឋកិច្ច។

ការចំណាយពិហោប៉ៅលើការថែទាំសុខភាពដោយសារការកើនឡើងនៃថ្លៃសេវា និងថ្នាំពេទ្យទាំងនៅមូលដ្ឋានសុខាភិបាលសាធារណៈទាំងឯកជន ការកើនឡើងនៃការប្រើប្រាស់សេវាថែទាំសុខភាព និងការរីកចំរើសេដ្ឋកិច្ចបានផ្តល់លទ្ធភាពចំណាយលើការថែទាំសុខភាព។ ការចំណាយពីហោប៉ៅភាគច្រើនកើតឡើងខ្ពស់សំរាប់ក្រុមស្ថិតនៅក្នុងលំដាប់សេដ្ឋកិច្ចខ្ពស់។ គម្លាតនៃការចំណាយរបស់ប្រពលរដ្ឋរស់នៅជនបទ និងទីក្រុងខុសគ្នា ដែលអាចមកពីអ្នករស់នៅជនបទអាចកើតមានជំងឺ ឬសុខភាពមិនល្អច្រើនជាង ហើយលទ្ធភាពប្រើប្រាស់សេវាបង្ការមានតិចជាង អ្នករស់នៅទីក្រុង។

អ្នកផ្តល់សេវាឯកជនក្នុមានការបង្កើនថ្លៃសេវាថែទាំសុខភាពកម្ពុជា តែអ្នកផ្តល់សេវាថែទាំសុខភាពឯកជននៅតែជាជម្រើសដំបូងសម្រាប់ប្រជាជនភាគច្រើន។ ដែលធ្វើអោយចំណាយពៅហោប៉ៅកើតឡើងច្រើននៅវិស័យឯកជនចាប់តាំងពីឆ្នាំ២០១០មក អ្នកផ្តល់សេវាឯកជនបានរួមចំណែកក្នុងការបង្កើនចំណាយពៅហោប៉ៅលើសុខភាព ដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃវិស័យឯកជន ជាប្រភពនៃការផ្តល់សេវាថែទាំសុខភាព ហើយត្រូវបានមើលឃើញថាជាបញ្ហាក្នុងប្រព័ន្ធសុខាភិបាល ដែលមានការកំហិត ឬអនុវត្តបទដ្ឋានគតិយុទ្ធគ្រប់គ្រងអ្នកផ្តល់សេវា។

ការស្វែងរកសេវានៅបរទេសមិនមែនជាជម្រើសចម្បង សម្រាប់ប្រជាជនកម្ពុជាឡើយ។ ទោះជាយ៉ាងណា វាក៏មានចំនួនច្រើនផងដែរ ដែលមានចំណាយរហូតទៅដល់ ២២% នៅឆ្នាំ២០១៥។ ប្រជាជនកម្ពុជាកំពុងតែជ្រើសរើសទៅក្រៅប្រទេសដើម្បីស្វែងរកការថែទាំ ដែលអាចមានផលប៉ះពាល់ដោយអចេតនាខ្លះទៅលើប្រព័ន្ធសុខាភិបាលក្នុងស្រុក។ បញ្ហា

ប្រឈមអាចកើតមានឡើងក្នុងរយៈពេលយូរប្រសិនបើនិន្នាការនេះបន្តកើនឡើង។ ប្រព័ន្ធថែទាំសុខភាពពីរជាន់អាចត្រូវបានបង្កើតឡើង ដែលក្នុងនោះអ្នកជំងឺដែលមានប្រាក់ចំណូលអាចជ្រើសរើសទៅក្រៅប្រទេសក្នុងការថែទាំ ដែលអាចកាត់បន្ថយការលើកទឹកចិត្តក្នុងការវិនិយោគនៅក្នុងប្រព័ន្ធសាធារណៈ និងដើម្បីជំរុញការវិនិយោគក្នុងសរុក។ ទោះជាយ៉ាងណា វាអាចជំរុញដល់អ្នកផ្តល់សេវាក្នុងស្រុកអោយមានសម្ពាធដោយប្រយោលកាន់តែច្រើន ក្នុងការធ្វើអោយប្រសើរឡើងនូវគុណភាពសេវា។ ការយល់ដឹងពីផលប៉ះពាល់នៃការថែទាំនៅក្រៅប្រទេសលើវិស័យសាធារណៈនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។

ប្រជាជនដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ ជាមធ្យមភាគមានការចំណាយខ្ពស់ (២០% នៃការចំណាយពីហោប៉ៅសរុបលើការថែទាំសុខភាព ខណៈដែលមានតែ៨,២%នៃចំនួនប្រជាជន [១១] ។ ការចែករំលែកនេះទំនងជានឹងកើនឡើងតាមពេលវេលាខណៈអាយុប្រជាជន (ចំណែកមនុស្សចាស់ត្រូវបានគេព្យាករថានឹងកើនឡើងត្រឹម២០% នៅត្រឹមឆ្នាំ២០៥០) ហើយអត្រាកើតជម្ងឺមិនឆ្លងអាចកើនឡើងស្របពេលគ្នា ហើយការមានសមាជិកចាស់ជរាក្នុងគ្រួសារបង្កើនការចំណាយមហន្តរាយ។ ដូច្នេះប្រព័ន្ធសុខាភិបាលត្រូវមានការយកចិត្តទុកដាក់ដើម្បីដោះស្រាយតម្រូវការរបស់ពួកគេ និងជៀសវាងបង្កការលំបាកផ្នែកហិរញ្ញវត្ថុចំពោះក្រុមប្រជាជននេះនៅពេលទទួលបានការថែទាំ[១២] ។

ជាទូទៅការចំណាយមហន្តរាយលើការថែទាំសុខភាព បានកើនឡើងពីក្រុមស្ថិតក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចកម្រិតទាបបំផុតទៅក្រុមកម្រិតខ្ពស់។ នេះក៏បង្ហាញផងដែរនូវការពិតដែលថាគ្រួសារនៅក្រុមកំរិតខ្ពស់កំពុងស្វែងរកសេវាថែទាំថ្លៃ ដូចជានៅគ្លីនិកឯកជន និងមន្ទីរពេទ្យឯកជន។ ដោយឡែកគ្រួសារ ដែលស្ថិតក្នុងលំដាប់សេដ្ឋកិច្ចកម្រិត២ និង៣ មានការចំណាយមហន្តរាយលើសុខភាពខ្ពស់ជាងអ្នកស្ថិតនៅក្នុងក្រុមលំដាប់សេដ្ឋកិច្ចកម្រិតទាបបំផុត។ ហេតុផលមួយដែលអាចទៅរួចគឺថាអ្នកដែលស្ថិតក្នុងគ្រួសារទាំងនេះគឺ "គ្រួសារដែលជិតក្រីក្រ" វិស័យមិនផ្លូវការ ឬក្រុមងាយរងគ្រោះដទៃទៀតហើយមិនមានសំណាញ់

[១១] . ស្ថិតិប្រជាជន ក្រសួងផែនការឆ្នាំ២០១៤

[១២] .Zimmer Z, Fadane K. (២០១៣). Ageing and migration in Cambodia. A CRUMP Series Report. Phnom Penh: Ministry of Planning, Government of Cambodia.

ការពារគ្រប់គ្រាន់ ដើម្បីការពារពួកគេពីការលំបាកផ្នែកហិរញ្ញវត្ថុនៅពេលត្រូវការប្រើប្រាស់សេវាថែទាំសុខភាព។

នៅពេលពិនិត្យមើលលក្ខណៈនៃគ្រួសារដែលរងគ្រោះដោយមហន្តរាយចំណាយលើការថែទាំសុខភាព មាន៩១% ដែលមានទីតាំងរស់នៅតំបន់ជនបទ។ លើសពីនេះទៀត គ្រួសារទាំងនោះដែលមានសមាជិកពិការ មានវ័យចំណាស់ ឬមានជំងឺរ៉ាំរ៉ៃមានអត្រាចំណាយមហន្តរាយខ្ពស់ ដែលបង្ហាញពីតម្រូវការនៃការការពារផ្នែកហិរញ្ញវត្ថុសម្រាប់ក្រុមប្រជាជនទាំងនេះ។

ភាពក្រីក្រដោយសារការបង់ថ្លៃសុខភាព បានថយចុះសម្រាប់គ្រប់ក្រុមគ្រួសារទាំងអស់នៅត្រឹមឆ្នាំ ២០១៥ ប៉ុន្តែនៅតែគួអោយចាប់អារម្មន៍សម្រាប់ក្រុមដែលមានចំណូលទាបបំផុត។ នៅឆ្នាំ២០១៥ គ្រួសារតិចជាង១%នៅក្នុងក្រុមដែលស្ថិតក្នុងលំដាប់សេដ្ឋកិច្ចកម្រិត៤ និង៥ ធ្លាក់ក្នុងភាពក្រីក្រដែលឆ្លុះបញ្ជាំងពីលទ្ធភាពចំណាយរបស់ពួកគេ។ ទោះជាយ៉ាងណាប្រសិនបើពួកគេមិនធ្លាក់ក្នុងភាពក្រីក្រ ភាគច្រើនក្រុមអ្នកមានទ្រព្យសម្បត្តិ ដែលទទួលរងនូវការចំណាយមហន្តរាយ។ ដោយឡែកក្រុមដែលស្ថិតនៅកម្រិត១ ២ និង៣ នៅតែប្រឈមមុខនឹងកម្រិតនៃភាពក្រីក្រ ដែលមានន័យថាការចំណាយសុខភាពបានរុញពួកគេទៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ ដែលអាចបំផ្លាញដល់ប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ។ ជាច្រើនឆ្នាំមកហើយចំនួនគ្រួសារដែលក្រីក្រដោយសារតែការចំណាយពីហោប៉ៅលើការថែទាំសុខភាព មានចំនួនខ្ពស់ចំពោះអ្នកដែលស្ថិតក្នុងលំដាប់ទីពីរនិងទីបី ធៀបទៅក្រុមទីមួយ។ មូលហេតុដែលអាចកើតឡើងបានគឺថាពួកគេជាគ្រួសារ «ជិតក្រីក្រ» ហើយមិនត្រូវបានការពារដោយគម្រោងគាំពារសង្គមឡើយ។

ការកាត់បន្ថយចំណាយមហន្តរាយលើការចំណាយសុខភាព និងភាពក្រីក្រដោយសារការចំណាយសុខភាព អាចត្រូវបានចូលរួមដោយកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ដែលបានបង្កើនចំណាយយសរុបរបស់គ្រួសារនិងសមត្ថភាពចំណាយរបស់គ្រួសារលើសេវាសុខភាព។ ប្រការនេះអាចឆ្លុះបញ្ជាំងពីវឌ្ឍនភាពនៃការគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា អមដោយការកើនឡើងនៃសមត្ថភាពចំណាយនៅក្នុងគ្រួសារ។ ទោះជាយ៉ាង

ណា វិសមភាពនៃការការពារផ្នែកហិរញ្ញវត្ថុនៅទូទាំងក្រុមនៅតែជាបញ្ហា ជាពិសេស គ្រួសារក្រីក្រ និងជនបទ ដោយសារអត្រាចំណាយពីហោប៉ៅ និងធ្លាកក្នុងភាពក្រីក្រខ្ពស់។

ប្រភពហិរញ្ញប្បទាន របកគំហើញបាន បង្ហាញថាគ្រួសារក្រីក្រ និងជិតក្រមានទំនោរខ្ចីប្រាក់ (បុល) ពីអ្នកអោយខ្ចីក្រៅផ្លូវការ ដែលមានអត្រាការប្រាក់ខ្ពស់ដោយសារកម្រិតប្រាក់ចំណូលទាបនិងចំនួនប្រាក់កម្ចីច្រើន[១៣]។ ប្រាក់កម្ចីដែលគ្មានប្រាក់ចំណូលសម្រាប់ចំណាយលើថ្លៃម្ហូបអាហារនិងវេជ្ជសាស្ត្របានបង្កើនភាពងាយរងគ្រោះរបស់អ្នកក្រីក្រ និងអ្នកជិតក្រ បានក្លាយទៅជាអ្នកជាប់អន្ទាក់នៅក្នុងវដ្តនៃភាពក្រីក្រ។ គ្រួសារនៅជនបទជារឿយៗជំពាក់បំណុលច្រើនជាងគ្រួសារនៅតាមទីក្រុង ទោះបីជាការខ្ចីប្រាក់មានច្រើនជាងនៅតំបន់ទីក្រុងក៏ដោយ។

## ៥.សន្និដ្ឋាន

ប្រទេសកម្ពុជាកំពុងបោះជំហានឆ្ពោះទៅរកការអភិវឌ្ឍយន្តការទូទាត់ចំណាយសម្រាប់សេវាសុខភាព ព័ត៌មានអំពីសមត្ថភាពចំណាយ និងការកំណត់សូចនាករអំពីសមត្ថភាពចំណាយដោយផ្អែកលើបរិបទប្រទេសកម្ពុជា រួមទាំងសមត្ថភាពចំណាយតាមក្រុមលំដាប់ថ្នាក់សេដ្ឋកិច្ច អាចមានប្រយោជន៍ក្នុងការយល់ដឹង និងកំនត់ពីរបៀបនិងកំរិតនៃការចូលរួមវិភាគទានក្នុងគំរោងបុរេបង់ថ្លៃឬគាំពារសុខភាពសង្គម។ ជម្រើសសក្តានុពលសម្រាប់ការប្រមូលប្រាក់នៃការទូទាត់ជាមុនសម្រាប់សុខភាព។ បុរេបង់ថ្លៃ និងការចែករំលែកហានិភ័យគឺជាមូលដ្ឋានគ្រឹះក្នុងការកសាងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ ដើម្បីការពារមហន្តរាយ និងការធ្លាក់ក្នុងភាពក្រីក្រដោយសារចមណាយលើការថែទាមសុខភាព និងសម្រេចបានការគ្របដណ្តប់សុខភាពជាសកល[១៤]។

---

[១៣] Asian Development Bank (2014). Cambodia: country poverty analysis 2014 (https://www.adb.org/sites/default/files/institutional-document/151706/cambodia-country-poverty-analysis-2014.pdf, accessed 28 March 2018).

[១៤]. World Health Organization (2010). Health systems financing: The path to universal coverage (http://www.who.int/whr/2010/10_summary_en.pdf, accessed 28 March 2018).

របកគំហើញនៃការវិភាគនេះបង្ហាញពីតម្រូវការ របស់ប្រជាពលរដ្ឋ ហើយបង្ហាញថាគោលនយោបាយគាំពារសង្គមត្រូវកាចាំបាច់ដើម្បីការពារក្រុមងាយរងគ្រោះ រួមទាំងគ្រួសារក្រីក្រ ចាស់ជរា ជនពិការ អ្នកនៅជនបទ ស្ត្រី និងអ្នកមានជំងឺមិនឆ្លងជាដើម។

## ៦. ដែនកំណត់

ដែនកំណត់សំខាន់ៗជាច្រើនចាំបាច់ត្រូវពិចារណានៅពេលគូរលទ្ធផលពីលទ្ធផលដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ។ ទីមួយអថេរប្រើសេវាសុខភាពរួមបញ្ចូលទាំងការប្រើប្រាស់សម្រាប់របួស ឬជំងឺមិនមែនសម្រាប់ហេតុផលផ្សេងទៀតដើម្បីស្វែងរកការថែទាំសុខភាពឡើយ។

អង្កេតសេដ្ឋកិច្ចសង្គមប្រមូលព័ត៌មានអំពីការចំណាយ និងការប្រើប្រាស់ប្រចាំឆ្នាំ។ ការស្ទាបស្ទង់មតិគំរូធំៗ ត្រូវបានធ្វើឡើងរៀងរាល់ ៥ ឆ្នាំម្តងគឺឆ្នាំ២០០៤ ឆ្នាំ២០០៩ និងឆ្នាំ២០១៤ ដែលគ្របដណ្តប់ជាង ១០.០០០គ្រួសារ ប្រមាណជា៧០.០០០នាក់។ ដោយប្រៀបធៀបក្នុងឆ្នាំ២០១០ ឆ្នាំ២០១៣ និងឆ្នាំ២០១៥ ទំហំសំណាកគំរូសម្រាប់គ្រួសារមានប្រហែល ៣.៥០០នាក់ និង១៦.០០០នាក់ប៉ណ្ណោះ។ ការលំអិតពត៌មានឬបែងចែកតាមឆ្នាំដែលមានគំរូសំណាកតូចជាង ប្រហែលជាមិនតំណាងឱ្យចំនួនប្រជាជនទាំងមូលទេ។

ទាក់ទងនឹងដែនកំណត់នៃការស្ទង់មតិ ព័ត៌មានត្រូវប្រមូលបានតែលើប្រភេទជំងឺតែមួយ។ ការសន្មត់គឺថាបុគ្គលម្នាក់ៗមានជំងឺមួយក្នុងមួយខែ អាចមិនមែនជាការពិតសម្រាប់បុគ្គលទាំងអស់នោះទេ។ ទាក់ទងទៅនឹងអ្នកផ្តល់សេវា ព័ត៌មានត្រូវបានប្រមូលបានតែនៅលើអ្នកផ្តល់សេវាដំបូង និងចុងក្រោយ ដែលអាចចាត់ទុកថាជាការសន្មត់ដោយសមស្របឬយុត្តិធម៌ ព្រោះបុគ្គលភាគច្រើនស្វែងរកការថែទាំតិចជាងពីរដងក្នុងមួយខែ។ ទោះជាយ៉ាងណាការប៉ាន់ស្មានអំពីចំណាយតាមប្រភេទអ្នកផ្តល់សេវា ត្រូវបានគេសន្មតថាបុគ្គលម្នាក់ៗចំណាយប្រាក់ស្មើគ្នានៅតាមកន្លែងផ្តល់សេវានីមួយៗ ប្រសិនបើពួកគេបានទៅមើលច្រើនជាងមួយដងដែលមិនមែនជាករណីនោះទេ។

ទាក់ទងទៅនឹងដែនកំណត់នៃវិធីសាស្ត្រ ដែលត្រូវបានប្រើដើម្បីផលិតរបាយការណ៍នេះនិយមន័យសមត្ថភាពចំណាយ អាចសំដៅទៅលើចំណែកនៃថវិកាគ្រួសារដែលសល់

បន្ទាប់ពីចំណាយលើការចិញ្ចឹមជីវិត[១៥]។ ប៉ុន្តែ សមត្ថភាពចំណាយអាចត្រូវបានកំណត់ធំពេក ដោយសារតែគ្រួសារមានតម្រូវការមូលដ្ឋានផ្សេងទៀត ក្រៅពីការចំណាយលើម្ហូបអាហារ។ ចំណាយលើការចិញ្ចឹមជីវិតផ្សេងទៀតដូចជាលំនៅដ្ឋាន ការដឹកជញ្ជូននិងសំលៀកបំពាក់ បើសិនជាមានសារៈសំខាន់នៅក្នុងបរិបទកម្ពុជា គួរតែអាចត្រូវបានគេបញ្ចូល ដើម្បីជៀសវាងការប៉ាន់ស្មានលើសលើសមត្ថភាពចំណាយរបស់គ្រួសារ។

បន្តពីរបាយការណ៍នេះ មានឱកាសវិភាគបន្ថែមលើលទ្ធផលមួយចំនួនទៀតពីអង្កេតនេះ។ វាអាចមានប្រយោជន៍ក្នុងការធ្វើការវិភាគតាមក្រុមលំដាប់ថ្នាក់សេដ្ឋកិច្ចអំពីចំណាយរបស់មនុស្សម្នាក់ៗដោយមិនរាប់បញ្ចូលការចំណាយពីហោប៉ៅលើការថែទាំសុខភាព ពីព្រោះវាអាចចំណាត់គ្រួសារនោះក្នុងលំដាប់ថ្នាក់សេដ្ឋកិច្ចខ្ពស់ ដោយសារមានការចំណាយលើការថែទាំសុខភាពខ្ពស់ ហើយអាចនឹងនាំឱ្យមានការភ័ន្តច្រឡំ។ លើសពីនេះទៀត វានឹងមានប្រយោជន៍ផងដែរ សំរាប់ការវិភាគបន្ថែមលើគ្រួសារដែលចំណាយខ្ពស់ និងថាតើការចំណាយខ្ពស់ទាំងនេះត្រូវបានចងភ្ជាប់ទៅនឹងជំងឺជាក់លាក់ណាមួយ ឬដោយសារតែកត្តាដទៃទៀត។

[១៥] . Xu, Ke & World Health Organization. Dept. of Health System Financing, Expenditure and Resource Allocation. (២០០៥). Distribution of health payments and catastrophic expenditures Methodology / by Ke Xu. Geneva : World Health Organization (http://www.who.int/iris/handle/១០៦៦៥/៦៩០៣០).

# គន្ថនិទ្ទេស


១. របាយការណ៍គណនេយ្យសុខាភិបាលជាតិ ក្រសួងសុខាភិបាល ២០១៦

២. Rannan-Eliya, R. (២០១០) Estimating OOP spending for national health accounts. Geneva: World Health Organization

៣. Ke, Xu (២០០៥). Distribution of health payments and catastrophic expenditures. Geneva: World Health Organization.

៤. Xu K, Klavus J, Kawabata K, Evans DB, Hanvoravongchai P, Ortiz de Iturbide JP, et al. Household healt system contributions and capacity to pay: definitional, empirical and technical challenges. In: Murray CJL, Evans DB, eds. Health systems performance assessment: debates, methods and empiricism. Geneva: World Health Organization; ២០០៣.

៥. National poverty line ២០០៩–២០១៤, Ministry of Planning, and ២០១៦ values were estimated taking into account inflation

៦. World Health Organization and World Bank (២០១៧). Tracking universal health coverage: ២០១៧ global monitoring report (http://pubdocs.worldbank.org/en/១៩៣៣៧១៥១៣១៦៩៧៩៨៣៤៧/២០១៧-global-monitoring-report.pdf accessed ២៨ March ២០១៨).

៧. World Health Organization (២០១០). Health systems financing: The path to universal coverage (http://www.who.int/whr/២០១០/១០_summary_en.pdf).

៨. Xu, Ke & World Health Organization. Dept. of Health System Financing, Expenditure and Resource Allocation. (២០០៥). Distribution of health payments and catastrophic expenditures Methodology / by Ke Xu. Geneva: World Health Organization (http://www.who.int/iris/handle/១០៦៦៥/៦៩០៣០).

# ទស្សនទាននៃការផ្តល់ឥណទានមីក្រូហិរញ្ញវត្ថុទៅលើជីវភាពប្រជាជន

*បណ្ឌិត* ***ឌឹត សំណាង***

## មូលន័យសង្ខេប

វិស័យមីក្រូហិរញ្ញវត្ថុ គឺជាចលករមួយនៅក្នុងចំណោមចលករសំខាន់ៗដ៏ទៃទៀតនៃវិស័យសេដ្ឋកិច្ច ក្នុងការជួយជំរុញឱ្យមានការអភិវឌ្ឍ កំណើនសេដ្ឋកិច្ច ការបង្កើតការងារ ការកាត់បន្ថយភាពក្រីក្រ ជាដើម។

ប្រជាជនកម្ពុជាក្រីក្រជាច្រើនមានការខ្វះខាតទទួលបាននូវសេវាកម្មហិរញ្ញវត្ថុផ្លូវការពីធនាគារ ដោយសារធនាគារទាំងនោះដាក់លក្ខខ័ណ្ឌតឹងតែង ដូចជា តម្រូវការប្លង់រឹង របាយការណ៍ប្រាក់ចំណូលចំណាយច្បាស់លាស់ មានការធានាវ៉ាប់រង មានមេធាវី ជាដើម។

មូលហេតុនេះហើយ បានជាប្រជាជនទាំងនោះ មាននិន្នាការទៅប្រើប្រាស់ឥណទានពីមីក្រូហិរញ្ញវត្ថុវិញ ដោយសារ មីក្រូហិរញ្ញវត្ថុមានលក្ខខ័ណ្ឌធូរស្រាលជាងធនាគារ ដូចជា ប្រជាជនអាចខ្ចីបានទោះបីជាពួកគាត់មានប្លង់រឹង ឬប្លង់ទន់ មានចំណូលចំណាយតាមរដូវកាល ក៏ដោយ។

គោលបំណងសំខាន់បំផុតនៃការស្រាវជ្រាវនេះគឺចង់ដឹងថា តើឥណទានមីក្រូហិរញ្ញវត្ថុមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះ ទៅលើជីវភាពប្រជាជន។

វិធីសាស្ត្រនៅក្នុងការស្រាវជ្រាវនេះ គឺសិក្សាទៅលើលទ្ធផលនៃនិក្ខេបបទ និងរបាយការណ៍ដែលបានសិក្សារួចហើយដោយអ្នកជំនាញ និងអ្នកសិក្សាស្រាវជ្រាវ កន្លងទៅ។

ជាលទ្ធផល ការស្រាវជ្រាវទាំងនោះបានបង្ហាញថា ឥណទានមីក្រូហិរញ្ញវត្ថុមានឥទ្ធិពលវិជ្ជមានទៅលើជីវភាពប្រជាជន ដូចជា ចំនួនប្រាក់ចំណូល ចំនួនប្រាក់ចំណាយ ស្ថានភាពផ្ទះ ទ្រព្យសម្បត្តិក្នុងផ្ទះ ចំនួនទឹកប្រាក់សន្សំ ចំណីអាហារ សុខភាព និងកូនចូលរៀន មានភាពល្អប្រសើរឡើងជាងមុន។

**ពាក្យគន្លឹះ៖** ៖ *ការអភិវឌ្ឍ កំណើនសេដ្ឋកិច្ច ការបង្កើតការងារ ការកាត់បន្ថយភាពក្រីក្រ ឥទ្ធិពល ចលករ។*

## ១-១ លំនាំបញ្ហានៃការស្រាវជ្រាវ (Problem Statement)

វិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមបង្កើតឡើងក្នុងអំឡុងដើមទសវត្សទី៩០ បន្ទាប់ពីប្រទេសរបស់យើងងើបរួចចេញផុតពីភ្នក់ភ្លើងសង្គ្រាមស៊ីវិលអស់រយៈពេលជាងម្ភៃឆ្នាំ។ ឥណទានខ្នាតតូចៗទាំងនៅទីក្រុងនិងជនបទត្រូវបានបង្កើតឡើងដោយអង្គការក្រៅរដ្ឋាភិបាល ដើម្បីបំពេញចន្លោះខ្វះខាតនៃវិស័យហិរញ្ញវត្ថុ។ វិស័យ មីក្រូហិរញ្ញវត្ថុនៅពេលនោះបង្កើតឡើងក្រោមកម្មវិធីអភិវឌ្ឍន៍នានា របស់អង្គការក្រៅ រដ្ឋាភិបាលអន្តរជាតិដូចជា GRET (1991), World Relief (1992), World Vi-sion (1993), Concern Worldwide (1993) មានលក្ខណៈជាឥណទានខ្នាតតូច ដើម្បីជួយជំរុញឱ្យប្រជាពលរដ្ឋក្រីក្រមានឱកាសចាប់យកនូវការងារធ្វើ ជំនួញខ្នាតតូចផ្សេងៗ[១]។

ក្នុងរយៈពេលពីរទសវត្សន៍ចុងក្រោយនេះវិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាមានការកើនឡើង យ៉ាងឆាប់រហ័ស ដែលអនុញ្ញាត្តិឲ្យប្រជាជនជាច្រើន ជាពិសេសស្ត្រីមានឱកាសទទួលបាននូវសេវាកម្មហិរញ្ញវត្ថុដូចជា សេវាកម្មឥណទាន ដើម្បីយកទៅប្រកបមុខរបររកស៊ី ឬប្រើប្រាស់ផ្សេងៗ ក្នុងគោលបំណងបង្កើននូវប្រាក់ចំណូលក្នុងក្រុមគ្រួសាររបស់ពួកគាត់។

## ១-២ ចំណោទបញ្ហានៃការស្រាវជ្រាវ (Research Questions)

ចំណុចសំខាន់នៃចំណោទបញ្ហា ក្នុងការសិក្សាស្រាវជ្រាវ នេះគឺ៖

- តើការផ្តល់ឥណទានរបស់មីក្រូហិរញ្ញវត្ថុ មានឥទ្ធិពលដូចម្តេចខ្លះ ចំពោះជីវភាពប្រជាជន?

## ១-៣ គោលបំណងនៃការស្រាវជ្រាវ (Objectives)

គោលបំណងសំខាន់ នៃការសិក្សានេះ គឺ៖

- សិក្សាពីឥទ្ធិពលនៃការផ្តល់ឥណទានរបស់មីក្រូហិរញ្ញវត្ថុទៅលើជីវភាពរស់នៅរបស់ប្រជាជន ដូចជា៖បម្រែបម្រួលប្រាក់ចំណូល បម្រែបម្រួលប្រាក់ចំណាយ បម្រែបម្រួលស្ថានភាពផ្ទះ បម្រែបម្រួលទ្រព្យសម្បត្តិក្នុងផ្ទះ

---

[១] កង ចាន់ដារ៉ារ័ត្ន និងលិវ ដាណេ (២០១១), ឥទ្ធិពលនៃសេវាកម្មមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា, ទំព័រទី៩

បម្រែបម្រួលចំនួនទឹកប្រាក់សន្សំ បម្រែបម្រួលចំណីអាហារ បម្រែបម្រួលសុខភាព និងបម្រែបម្រួលកូនចូលរៀនជាដើម។

### ១-៤ វិធីសាស្ត្រនៃការស្រាវជ្រាវ (Research Method)

វិធីសាស្ត្រនៃការស្រាវជ្រាវនេះ គឺជាការសិក្សាទៅលើលទ្ធផលនៃនិក្ខេបបទ និងរបាយការណ៍ដែលមានស្រាប់រួចហើយ។

វិសាលភាពនៃការសិក្សាគឺការសិក្សាទៅលើលទ្ធផលនៃនិក្ខេបបទ និងរបាយការណ៍សរុបចំនួន១២ ដែលក្នុងនោះ និក្ខេបបទនិងរបាយការណ៍ក្នុងស្រុក ចំនួន៦ និងនិក្ខេបបទនិងរបាយការណ៍ក្រៅប្រទេស ចំនួន៦ ផ្សេងទៀត។

### ២-១ និយមន័យស្តីអំពីមីក្រូហិរញ្ញវត្ថុ (Definitions of Microfinance)

មានការផ្តល់នូវនិយមន័យអំពីមីក្រូហិរញ្ញវត្ថុ ពីស្ថាប័នធំៗ និងបុគ្គល មួយចំនួនដែលត្រូវគេបានចងក្រង និងសិក្សា រួចមកហើយ ដូចខាងក្រោម៖

១) លោកមហាម៉ាត់ យូនូស (Muhammad Yunus) បានផ្តល់និយមន័យដល់វិស័យមីក្រូហិរញ្ញវត្ថុ ដូច្នេះថា "គឺជាឥណទានខ្នាតតូច ដែលជាមធ្យោបាយសំរាប់ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ" (Microcredit as a Means of Fighting Poverty)[២] ។

២) ធនាគារពិភពលោក (World Bank) បានផ្តល់និយមន័យដល់វិស័យមីក្រូហិរញ្ញវត្ថុ ថា "វិស័យមីក្រូ ហិរញ្ញវត្ថុ គឺជាមធ្យោបាយសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច ដល់ស្ត្រីនិងបុរសទាំងឡាយ ដែលមានប្រាក់ចំណូលទាប។ វាសំដៅដល់ការផ្តល់សេវាកម្មហិរញ្ញវត្ថុផ្សេងៗដល់អតិថិជន ដែលមានប្រាក់ចំណូលទាបៗ ក្នុងនោះរួមទាំងអ្នក ដែលរកស៊ីតូចតាចដោយខ្លួនឯងផងដែរ"[៣]។ វិស័យមីក្រូហិរញ្ញវត្ថុ មិនត្រឹមតែជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដ៏សាមញ្ញមួយនោះទេ វាគឺជាឧបករណ៍សំរាប់អភិវឌ្ឍន៍ជាតិមួយ។

[២] គេហទំព័រ https://newint.org/books/reference/world-development/case-studies/poverty-microcredit-grameen-bank/

[៣] គេហទំព័រ https://www.ifc.org/wps/wcm/connect/industry_ext_content/ifc_external_corporate_site/industries/financial+markets/msme+finance/microfinance/microfinance

៣) ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) បានផ្តល់និយមន័យដល់វិស័យមីក្រូហិរញ្ញវត្ថុ ថា "វិស័យមីក្រូហិរញ្ញវត្ថុ គឺជាការផ្តល់សេវាកម្មច្រើនប្រភេទ ដូចជាការផ្តល់ប្រាក់កម្ចី ការទទួលប្រាក់សន្សំ សេវាកម្មទូទាត់ផ្សេងៗ ប្រាក់បញ្ញើរ និងធានារ៉ាប់រងដល់គ្រួសារដែលមានប្រាក់ចំណូលទាបៗ និងអាជីវកម្មខ្នាតតូចៗរបស់ពួកគេ"[៤]។ ប្រភពសំខាន់ៗបីយ៉ាង ដែលផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុមានដូចជា៖

៤) មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) បានផ្តល់និយមន័យដល់វិស័យមីក្រូហិរញ្ញវត្ថុ ថា "មីក្រូហិរញ្ញវត្ថុគឺជាការផ្តល់នូវសេវាកម្មផ្នែកហិរញ្ញវត្ថុច្រើនប្រភេទដល់ប្រជាជនក្រីក្រ គ្រួសារដែលមានប្រាក់ចំណូលទាប និងដល់សហគ្រាសខ្នាតតូចៗ ដែលខ្វះលទ្ធភាពទទួលបានសេវាកម្មផ្លូវការពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុធំៗ"[៥]។

## ២-២ និយមន័យស្តីអំពីអថេរសំខាន់ៗ (Definitions of Main Variables)

### ២.២.១ ឥទ្ធិពល (Impact)

ឥទ្ធិពល គឺជាកំលាំង អានុភាព ឬអំណាចដែលធ្វើឲ្យមានសេចក្តីសម្រេច សេចក្តីចម្រើន ឬសក្តិសិទ្ធ[៦]។

ឥទ្ធិពល គឺជាការវាស់វែងនៃផលប៉ះពាល់រូបី (ជាក់ស្តែងឬមើលឃើញនឹងភ្នែក) និងអរូបី (មិនជាក់ស្តែងឬមើលមិនឃើញនឹងភ្នែក) នៃសកម្មភាពរបស់មនុស្ស សត្វ ឬវត្ថុអ្វីមួយ ទៅលើមនុស្ស សត្វ ឬវត្ថុអ្វីមួយផ្សេងទៀត[៧]។

### ២.២.២ ជីវភាពរស់នៅ (Living Standard)

ជីវភាពរស់នៅគឺជាការបង្ហាញនូវកម្រិតនៃទ្រព្យសម្បត្តិ ផាសុខភាព សម្ភារៈចាំបាច់ផ្សេងៗដែលអាចរកបានសម្រាប់ផ្នែកសេដ្ឋកិច្ចក្នុងគ្រួសារមួយ សង្គមមួយឬតំបន់ភូមិសាស្ត្រមួយជាក់លាក់។ ជីវភាពរស់នៅរួមបញ្ចូលនូវកត្តាសំខាន់ៗ ដូចជា ប្រាក់ចំណូល ផលិតផលក្នុងស្រុកសរុបកំណើនសេដ្ឋកិច្ចជាតិ ស្ថិរភាពសេដ្ឋកិច្ចនិងនយោបាយ សេរីភាពនយោបាយ

---

[៤] គេហទំព័រ https://www.adb.org/sectors/finance/microfinance

[៥] គេហទំព័រ https://www.imf.org/external/pubs/ft/wp/2002/wp02159.pdf

[៦] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជជួន ណាត គ.ស. ១៩៦៧

[៧] គេហទំព័រ www.businessdictionary.com/definition/impact.html

និងសាសនា គុណភាពបរិស្ថាន អាកាសធាតុនិងសុវត្ថិភាព។ ជីវភាពរស់នៅមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងគុណភាពនៃជីវិត[៨]។ គុណភាពនៃជីវិតបង្ហាញពីភាពល្អប្រសើរឡើងនៃធាតុផ្សំសំខាន់ៗ មួយចំនួន ដូចជា ៖ ១) ប្រាក់ចំណូលកើនឡើងខ្ពស់ជាងមុន ២) ការសិក្សាអប់រំល្អប្រសើរជាងមុន ៣) ស្តង់ដារសុខភាព និងអាហាររូបត្ថម្ភល្អប្រសើរជាងមុន ៤) ភាពក្រីក្រមានចំនួនតិចជាងមុន ៥) បរិស្ថានរស់នៅស្អាតជាងមុន ៦) ភាពស្មើគ្នានៃឱកាសមានច្រើនជាងមុន ៧) សេរីភាពបុគ្គលប្រសើរជាងមុន ៨) វប្បធម៌ជីវិតសម្បូរសប្បាយច្រើនជាងមុន។

### ២.២.៣ ឥណទាន (Loan or Credit)

ឥណទានគឺជាសាច់ប្រាក់ ទ្រព្យសម្បត្តិ ឬវត្ថុធាតុដើមផ្សេងៗដែលត្រូវផ្តល់ជូនទៅភាគីម្ខាងទៀត ក្នុងគោលបំណងថានឹងមានការសងត្រឡប់សាច់សាច់ប្រាក់ ទ្រព្យសម្បត្តិ ឬវត្ថុធាតុដើមនោះមកវិញ បូកនឹងការប្រាក់ ឬប្រាក់កម្រៃផ្សេងៗទៀត នៅពេលអនាគត។ ឥណទានអាចបើកសរុបតែមួយដងទាំងអស់ ឬទៅតាមតំណាក់កាល នីមួយៗទៅតាមកិច្ចព្រមព្រៀងរវាងស្ថាប័ន និងអតិថន[៩]។

ចំណែកទំហំឥណទានបង្ហាញ អំពីកម្រិត ឬចំនួនទឹកប្រាក់ដែលស្ថាប័នផ្តល់ជា កម្ចីដល់អតិថិជនរបស់ខ្លួន។

### ២.២.៤ ការប្រាក់ (Interest Rate)

ជាទូទៅ ការប្រាក់គណនាជាអត្រា។ ដូច្នេះ ការប្រាក់គឺជាចំនួនទឹកប្រាក់ដែលគេកំណត់ ទៅលើប្រាក់ដើម ដែលគិតជាភាគរយ ក្នុងរយៈពេលណាមួយជាក់លាក់ (ថ្ងៃ ខែ ឬឆ្នាំ)។ ទ្រព្យសកម្មដែលអាចខ្ចីបានរាប់បញ្ចូលជាសាច់ប្រាក់ ទំនិញប្រើប្រាស់ និងទ្រព្យសម្បត្តិផ្សេងៗ ដូចជារថយន្ត ឬអគារជាដើម[១០]។

---

[៨] គេហទំព័រ https://www.investopedia.com/terms/s/standard-of-living.asp

[៩] គេហទំព័រ https://www.investopedia.com/terms/l/loan.asp

[១០] គេហទំព័រ https://www.investopedia.com/terms/i/interestrate.asp

### ២.២.៥ រយៈពេលកម្ចី (Loan Term)

រយៈពេលកម្ចី គឺជាចំនួនទឹកប្រាក់កម្ចីដែលត្រូវសងត្រឡប់ទៅស្ថាប័នជាទៀងទាត់ក្នុងរយៈពេលកំណត់ណាមួយជាក់លាក់។ ជាទូទៅ រយៈពេលកម្ចី អាចមានរយៈពេលចន្លោះពីមួយឆ្នាំទៅដប់ឆ្នាំ។ ប៉ុន្តែអាចមានរយៈពេលដល់ ១៥ឆ្នាំ ២០ឆ្នាំ ឬ ៣០ឆ្នាំ ទៅតាមទំហំកម្ចីនិងការចរចាររវាងស្ថាប័ន និងអតិថិជន។ ជាមូលដ្ឋាន រយៈពេលកម្ចី អាចផ្តល់ឱ្យបុគ្គលណាម្នាក់ ប៉ុន្តែស្ថាប័នក៏អាចផ្តល់វាដល់អាជីវកម្មខ្នាតតូច និងមធ្យម សម្រាប់ប្រើប្រាស់បានផងដែរ។ លទ្ធភាពក្នុងការទូទាត់សងវិញក្នុងរយៈពេលវែងគឺជាការទាក់ទាញសម្រាប់សហគ្រាសថ្មីឬការពង្រីកទំហំប្រតិបត្តិការ ពីព្រោះអតិថិជនអាចបង្កើនប្រាក់ចំណេញរបស់ពួកគេក្នុងរយៈពេលមួយ។ រយៈពេលកម្ចី គឺជាមធ្យោបាយដ៏ល្អក្នុងការបង្កើនដើមទុនយ៉ាងឆាប់រហ័សដើម្បីបង្កើនសមត្ថភាពអាជីវកម្ម។ ឧទាហរណ៍ ក្រុមហ៊ុនថ្មីមួយចំនួនអាចប្រើរយៈពេលកម្ចីដើម្បីទិញរថយន្តសម្រាប់ក្រុមហ៊ុន ឬជួលកន្លែងបន្ថែមទៀតសម្រាប់ពង្រីកប្រតិបត្តិការរបស់ពួកគេ[១១]។

### ២.២.៦ ប្រាក់ចំណូល (Income)

ប្រាក់ចំណូលគឺជាប្រាក់ដែលបុគ្គលម្នាក់ ឬគ្រួសារមួយ ឬអាជីវកម្មមួយទទួលបានពីក្នុងការបំពេញការងារក្នុងផលិតកម្ម ឬការផ្តល់សេវាកម្ម តាមរយៈការវិនិយោគមូលធនកំលាំងកាយ ឬកំលាំងបញ្ញា។ មនុស្សដែលមានអាយុចាប់ពី ៦៥ឆ្នាំចុះក្រោម ទទួលបានប្រាក់ចំណូលភាគច្រើនពីប្រាក់ខែឬប្រាក់កម្រៃដែលរកបានពីការងារ ឬអាជីវកម្មផ្សេងៗ[១២]។ ប្រាក់ចំណូលក្នុងគ្រួសារ គឺជាការវាស់វែងនៃប្រាក់ចំណូលរួមគ្នារបស់សមាជិកទាំងអស់ដែលរួមរស់នៅជាមួយគ្នាក្នុងគ្រួសារមួយជាក់លាក់។ វារួមបញ្ចូលទាំងអស់នូវរាល់ទម្រង់នៃប្រាក់ចំណូល ឧទាហរណ៍ ប្រាក់ខែនិងប្រាក់ឈ្នួល ប្រាក់ចូលនិវត្តន៍ ប្រាក់ចំណេញពីអាជីវកម្មជាដើម[១៣]។

---

[១១] គេហទំព័រ https://en.wikipedia.org/wiki/Term_loan

[១២] គេហទំព័រ https://www.investopedia.com/terms/i/income.asp

[១៣] គេហទំព័រ https://en.wikipedia.org/wiki/Household_income

### ២.២.៧ ប្រាក់ចំណាយ (Expense)

ប្រាក់ចំណាយត្រូវបានគេកំណត់ថាជាលំហូរនៃសាច់ប្រាក់ ឬទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ ឬគ្រួសារមួយ ឬក្រុមហ៊ុនមួយ សម្រាប់ទិញទំនិញ ឬសេវាកម្មមួយ[១៤]។ ចំណាយនៅក្នុងគ្រួសារតំណាងឱ្យការបំបែកចំណាយនៃការរស់នៅសម្រាប់មនុស្សម្នាក់ៗ នៅក្នុងគ្រួសារមួយ។ វារួមបញ្ចូលនូវចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់ការស្នាក់នៅ ចំណាយលើម្ហូបអាហារ ចំណាយលើឧបករណ៍ប្រើប្រាស់នៅក្នុងផ្ទះ ចំណាយទៅលើការទិញ ឬប្រើប្រាស់យានជំនិះ ការចំណាយទៅលើទឹក-ភ្លើង ការចំណាយទៅលើការថែរក្សាសុខភាព ការចំណាយទៅលើការសិក្សាអប់រំ ការចំណាយទៅលើការចូលរួមក្នុងកម្មវិធីសង្គម និងការកំសាន្តផ្សេងៗ។ ជាទូទៅ ចំណាយសរុបនៅក្នុង គ្រួសារមួយមានការប្រែប្រួលជារៀងរាល់ខែ។ ដូច្នេះដើម្បីងាយស្រួលនៅក្នុងការគណនា គេនិយមប្រើប្រាស់ប្រាក់ចំណាយមធ្យមប្រចាំខែ នៅក្នុងគ្រួសារនីមួយៗ[១៥]។

### ២.២.៨ ស្ថានភាពផ្ទះ (House Condition)

ការកំណត់ស្ថានភាពផ្ទះសំបែងនៅកម្ពុជាថាល្អប្រសើរ ឬមិនទាន់ល្អប្រសើរ អាស្រ័យទៅលើធាតុផ្សំសំខាន់ៗ ចំនួន ៥ រួមមាន ទី១) ទំហំផ្ទះ (តូច មធ្យម ធំ) ទី២) សរសរ (ឈើអន់ៗ ឈើធម្មតា ឈើល្អៗ/បេតុង) ទី៣) ចំនួនជាន់ (ជាន់ផ្ទាល់ដី មួយជាន់លើសពីមួយជាន់) ទី៤) តំបូល (ស្លឹក សង្កសី ក្បឿង/ថ្ម) ទី៥) ជញ្ជាំង (ស្លឹក សង្កសី/ឈើ ថ្ម)[១៦]។

### ២.២.៩ ទ្រព្យសម្បត្តិក្នុងផ្ទះ (House Condition)

សម្រាប់មនុស្សភាគច្រើនអចលនទ្រព្យគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតរបស់ពួកគេ។ ទ្រព្យសកម្មគឺជាសម្ភារៈ ឬវត្ថុនានា ដែលមានតម្លៃជារូបិយវត្ថុ មានន័យថាអ្នកអាចលក់វាហើយប្តូរវាទៅជាសាច់ប្រាក់។ ក្រៅពីផ្ទះទ្រព្យសម្បត្តិផ្សេងទៀត ដូចជា រថយន្តទូក និងសម្ភារៈនៅក្នុងគ្រួសារ ដូចជាគ្រឿងសង្ហារិម គ្រឿងអេឡិចត្រូនិច សម្លៀកបំពាក់ និងគ្រឿងអលង្ការ។

---

[១៤] គេហទំព័រ https://debitoor.com/dictionary/expense

[១៥] គេហទំព័រ https://www.investopedia.com/terms/h/householdexpenses.asp

[១៦] គេហទំព័រ http://nada-nis.gov.kh/index.php/catalog/9/datafile/F13/?offset=200&limit=100

អ្នកជំនាញហិរញ្ញវត្ថុបានអះអាងថា អចលនទ្រព្យ និងទ្រព្យសម្បត្តិ ផ្សេងៗទៀតដែលអាចលក់ដើម្បីទទួលបានជាសាច់ប្រាក់ ត្រូវបានគេស្គាល់ថាជាទ្រព្យសកម្មថេរ។ សាច់ប្រាក់ក៏ជាទ្រព្យសកម្មផងដែរ ដូចជា គណនីសៃក្រ និងគណនីសន្សំ និងការវិនិយោគផ្សេងៗ ដូចជាភាគហ៊ុននិងមូលបត្របំណុលជាដើម។ ទ្រព្យសម្បត្តិទាំងនេះត្រូវបានគេស្គាល់ថាជាទ្រព្យសកម្មសាច់ប្រាក់ពីព្រោះពួកគេអាចប្តូរទៅជាសាច់ប្រាក់បានយ៉ាងឆាប់រហ័ស[១៧]។

**២.២.១០ ប្រាក់សន្សំ (Saving)**

ការសន្សំប្រាក់ គឺជាចំណែកមួយផ្នែកនៃប្រាក់ចំណូលដែលមិនត្រូវបានចំណាយ ឬយកទៅប្រើប្រាស់។ វិធីសាស្ត្រនៃការសន្សំ គឺការដាក់សាច់ប្រាក់ដាច់ដោយឡែកពីប្រាក់សម្រាប់ចំណាយ ឧទាហរណ៍ គណនីសន្សំប្រាក់ គណនីសោធននិវត្ត មូលនិធិវិនិយោគ ឬជាសាច់ប្រាក់សុទ្ធ។ ការកាត់បន្ថយការចំណាយមិនចាំបាច់មួយចំនួន ក៏ជាការសន្សំផងដែរ។ ទាក់ទងនឹងហិរញ្ញវត្ថុផ្ទាល់ខ្លួន ជាទូទៅ ការដាក់ប្រាក់សន្សំ បង្ហាញអំពីហានិភ័យកំរិតទាបដែលផ្ទុយពីការដាក់ប្រាក់សម្រាប់វិនិយោគគឺមានហានិភ័យគឺខ្ពស់ជាងច្រើន[១៨]។

**២.២.១១ ចំណីអាហារ (Food)**

អាហារចាំបាច់ប្រចាំថ្ងៃសំរាប់ប្រជាជនកម្ពុជាគឺបាយ ដែលផលិតចេញមកពី ស្រូវ និងអង្ករ។ សំរាប់ម្ហូបវិញគឺត្រី សាច់មាន់ សាច់ជ្រូក និងសាច់គោ។ អាហារគឺជាសារជាតុដែលគេប្រើដើម្បីផ្តល់ការគាំទ្រផ្នែកអាហារូបត្ថម្ភដល់សារពាង្គកាយមនុស្ស។ ជាធម្មតាអាហារមានប្រភពពីរុក្ខជាតិ ឬសត្វ ឬបន្លែ ឬផ្លែឈើ ហើយមានសារជាតុចិញ្ចឹមសំខាន់ៗ ដូចជាកាបូអ៊ីដ្រាត ខ្លាញ់ ប្រូតេអ៊ីន វីតាមីន ឬជាតិរ៉ែ។ សារជាតុនេះត្រូវបានជ្រាបចូលក្នុងសារពាង្គ-កាយមនុស្ស ហើយស្រូបយកដោយកោសិការបស់សារពាង្គកាយ ដើម្បីផ្តល់ថាមពលរក្សាជីវិត ឬជំរុញការលូតលាស់[១៩]។

---

[១៧] គេហទំព័រ https://budgeting.thenest.com/household-assets-21479.html

[១៨] គេហទំព័រ https://en.wikipedia.org/wiki/Saving

[១៩] គេហទំព័រ https://en.wikipedia.org/wiki/Food

### ២.២.១២ សុខភាព (Health)

សុខភាពគឺជាសមត្ថភាពរបស់ប្រព័ន្ធជីវសាស្ត្រក្នុងការទទួលយក ការប្តូរ ការបែងចែក ការចែកចាយ និងការប្រើប្រាស់ថាមពលប្រកបដោយចីរភាព។ អង្គការសុខភាពពិភពលោក (WHO) បានផ្តល់និយមន័យសុខភាពរបស់មនុស្សក្នុងន័យទូលំទូលាយនៅក្នុងធម្មនុញ្ញរបស់ខ្លួនក្នុងឆ្នាំ ១៩៤៨ របស់ខ្លួនថា «ស្ថានភាពសុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសង្គមពេញលេញ ហើយមិនមែនគ្រាន់តែអវត្តមានពីជំងឺ ឬភាពគ្មានជំងឺនោះទេ»[២០]។

### ២.២.១៣ កូនចូលរៀន (School Child)

កូនចូលរៀន គឺជាសំគាល់ដល់កុមារដែលដល់អាយុត្រូវចូលរៀនហើយបានចូលរៀន។ ការបន្តការសិក្សារបស់កុមារមិនត្រូវរារាំងឲ្យឈប់ដើម្បីមកជួយធ្វើកិច្ចការងារផ្ទះ ឬជួយប្រកបអាជីវកម្មណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ការលូលាស់រាង្គកាយ និងសតិបញ្ញាស្មារតីនោះទេ។ ការតម្រូវឲ្យកុមាររៀននៅប្រទេសកម្ពុជា យ៉ាងហោចណាស់ក៏រៀនដល់ថ្នាក់ទី៩ ឬអនុវិទ្យាល័យដែរ[២១]។

## ២-៣ ការស្រាវជ្រាវអំពីឥទ្ធិពលនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅលើជីវភាពប្រជាជនកន្លងមក (Last Studies of the Impact of Microfinance Loan on the people Living Standard)

មានការសិក្សាបន្តបន្ទាប់ ស្តីអំពីឥទ្ធិពលនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅលើជីវភាពប្រជាជនកម្ពុជានិងបរទេសកន្លងមក ដែលមានដូចខាងក្រោម៖

១) ការស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យ ឡេង ប៊ុនហ័រ និងក្រុមការងាររបស់លោកបានសិក្សាអំពីឥទ្ធិពលនៃការផ្តល់ឥណទានខ្នាតតូច ទៅលើសេដ្ឋកិច្ចគ្រួសារនៅក្នុងឆ្នាំ២០១១ ហើយបានចុះផ្សាយដោយព្រឹត្តិប័ត្របរិស្ថាន និងការអភិវឌ្ឍជនបទអន្តរជាតិ បានរកឃើញថា៖

---

[២០] គេហទំព័រ https://en.wikipedia.org/wiki/Health

[21] គេហទំព័រ https://www.merriam-webster.com/dictionary/schoolchild

ក. ឥណទានខ្នាតតូចពិតជាបានជួយឲ្យប្រសើរឡើងនូវសេដ្ឋកិច្ចគ្រួសារ ដូចជា បង្កើនប្រាក់ចំណូល ទ្រព្យសម្បត្តិក្នុងគ្រួសារ ឱកាសបង្កើតការងារ និងមុខរបរ ផ្តល់សិទ្ធអំណាចដល់ស្ត្រី ជួយទំនុកបំរុងការសិក្សាអប់រំកូនៗ និងសុខមាលភាពគ្រួសារ ដែលប្រើប្រាស់ឥណទានខ្នាតតូច។

ខ. ទោះបីជាដូច្នេះក៏ដោយ របាយការណ៍ក៏បានបង្ហាញឱ្យឃើញថា ឥណទានខ្នាតតូច ក៏មានឥទ្ធិពលអវិជ្ជមានខ្លះៗដល់គ្រួសារ ដូចជាមានភាពតឹងតែងអារម្មណ៍ក្នុងការរកប្រាក់ចំណូលសងត្រឡប់ទៅវិញផងដែរ។

ជារួមការសិក្សានេះ បានសរុបសេចក្តីថា មីក្រូហិរញ្ញវត្ថុគឺជាឧបករណ៍ដ៏មានប្រសិទ្ធិភាព សម្រាប់ការលប់បំបាត់ភាពក្រីក្រនៅកម្ពុជា[២២]។

២) ការស្រាវជ្រាវរបស់លោកកង ចាន់ដារ៉ារត្ន និងលោកស្រី លីវ ដាណែត បានសិក្សាអំពីឥទ្ធិពលនៃការផ្តល់សេវាកម្មហិរញ្ញវត្ថុខ្នាតតូចនៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ២០១១ បានរកឃើញថាៈ

ក. ឥទ្ធិពលនៃការផ្តល់សេវាកម្មហិរញ្ញវត្ថុខ្នាតតូចទៅដល់ប្រជាជនមានភាពវិជ្ជមាន ដូចជា ប្រាក់ចំណូលមានការប្រែប្រួលកើនឡើង មានប្រភពប្រាក់ចំនូលមានលើសពីមួយ មានទ្រព្យសម្បត្តិក្នុងគ្រួសារកើនឡើងមានប្រាក់សម្រាប់បង់ប្រាក់ដើមនិងការប្រាក់ត្រឡប់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ មានការចូលរួមក្នុងសង្គមកើនឡើង និងមានការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។

ខ. ប៉ុន្តែការសិក្សានេះ ក៏បានរកឃើញផងដែរអំពីហានិភ័យមួយចំនួនកើតឡើង ដែលត្រូវយកចិត្តទុកដាក់សម្រាប់ប្រជាជនទាំងនោះផងដែរ ដូចជា កម្ចីជាន់ច្រើនស្ថាប័ន និងបំណុលវ័ណ្ឌករ ជាដើម[២៣]។

---

[២២] BUNHOR LENG et al. Impacts of Micro-credit on Household Economics, International Journal of Environmental and Rural Development, 2011, page 113

[២៣] Dr. Kang Chandararot and Ms. Dannet Liv, Impact of Micro Finance Services in Cambodia, Cambodia Institute of Development Study ( CIDS ), 2011, pages 34-35

៣) និក្ខេបបទថ្នាក់បណ្ឌិតរបស់លោកស្រី អូលហ្គា តូរេស ហ្គាស្យា (Olga Torres Garcia) ស្តីអំពីការវាស់វែងពីភាពក្រីក្រនិងភាពងាយរងគ្រោះនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ករណីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេ អឹម ខេ ក្នុងឆ្នាំ២០០៩ បានរកឃើញថា៖

ក. អតិថិជនអេអឹមខេ ភាគច្រើនគឺជាអតិថិជនមានជីវភាពក្រីក្រ (ដោយហេតុថា អតិថិជនអេអឹមខេភាគច្រើនជាអតិថិជនជាក្រុមរស់នៅតំបន់ជនបទជាកសិករ ហើយខ្ចីកម្ចីក្នុងទំហំតូចត្រឹម ១,២០០,០០០ រៀលចុះក្រោម)។

ខ. អេអឹមខេ បានផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រនៅជនបទ ឱ្យមានឱកាសចាប់យកនូវមុខរបរតូចៗជាច្រើន សម្រាប់បង្កើនចំណូល គ្រួសារ និងធ្វើឲ្យក្រុមគ្រួសារជាច្រើនអាចគេចចេញផុតពីវិបត្តិក្រីក្រខ្លាំងក្នុងករណីមានសមាជិកក្នុងគ្រួសារមានជំងឺ (អេអឹមខេ មានកម្ចីសង្គ្រោះ បន្ទាន់ និងលុបបំណុលចោលប្រសិនបើអតិថិជនស្លាប់)[២៤]។

៤) ការស្រាវជ្រាវរបស់លោកស្រី ហ្វ្លរិន មីឡាន់ (Florence Milan) ស្តីអំពីបម្រែបម្រួលសូចនាករភាពក្រីក្រ ករណីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេ អឹម ខេ ក្នុងឆ្នាំ ២០០៩ បានរកឃើញថា៖

ក. ទាំងអតិថិជនអេអឹមខេ និងអ្នកមិនមែនអតិថិជន មានការកើនឡើងនូវចំណាយរបស់ពួកគាត់ទៅលើសំលៀកបំពាក់និងស្បែកជើង ចំណីអាហារ និងទ្រព្យសម្បត្តិក្នុងផ្ទះ (ម៉ូតូ ទូរទស្សន៍ ទូរស័ព្ទ ជាដើម)។

ខ. ជាការបន្ថែម អតិថិជនអេអឹមខេ មាននិន្នាការដាក់ប្រាក់សន្សំនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេអឹមខេ ជាងអ្នកមិនមែនជាអតិថិជន[២៥]។

៥) របាយការណ៍ស្រាវជ្រាវរបស់កញ្ញាការ៉ូលីន ហ្គីលបើត (Caroline Guilbert) និង ឌឹត សំណាង ស្តីអំពីការវាស់វែងសង្គម ករណីសិក្សាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេ អឹម ខេ ក្នុងឆ្នាំ២០១០ បានរកឃើញថា៖

---

[២៤] Olga Torres García, Measuring Poverty and Vulnerability in Microfinance, 2009, pages 289-290

[២៥] Florence milan, Temporal Changes in Poverty Indicators, AMK, 2009, Pages 4-5

ក. អតិថិជនអេ អឹម ខេ ចំនួន៤០% គឺជាអតិថិជនរស់នៅក្រោមបន្ទាត់ក្រីក្រថ្នាក់ជាតិ (ដោយហេតុថាអតិថិជនអេអឹមខេភាគច្រើន គឺជាកសិករ រស់នៅក្នុងតំបន់ដាច់ស្រយ៉ាល)។ ជាការបន្ថែម អតិថិជនអេអឹមខេមានកម្រិតជីវភាពល្អប្រសើរជាងអ្នកមិនមែនជាអតិថិជនទៅលើចំណីអាហារគ្រប់គ្រាន់ និងគុណភាពម្ហូបអាហារ[២៦]។

៦) របាយការណ៍ស្រាវជ្រាវរបស់អង្គការឥណ្ឌូឆាយណា (Indochina Research) ស្តីអំពីឥទ្ធិពលមីក្រូហិរញ្ញវត្ថុទៅលើជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍក្នុងឥណ្ឌូចិន ក្នុងឆ្នាំ២០១៣ បានរកឃើញថា៖

ក. ប្រជាជនកម្ពុជាមួយចំនួនបានខ្ចីប្រាក់ទៅកែលំអផ្ទះ ឬធ្វើផ្ទះមួយចំនួនទៀតបានយកទៅទិញតុកៗ បើកសំអាងការ លក់ចាប់ហួយ ឬពង្រីកអាជីវកម្មផ្សេងៗ។

ខ. ចំណែកប្រជាជនខ្លះទៀតបានដាក់ប្រាក់សន្សំមួយចំនួនជារៀងរាល់ខែក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងគោលបំណងសំខាន់ៗរបស់ពួកគេ ក្នុងពេលអនាគត ដូចជា ពង្រីកអាជីវកម្ម ឬសម្រាប់កូនៗរៀនសូត្រជាដើម[២៧]។

៧) និក្ខេបបទថ្នាក់អនុបណ្ឌិតរបស់លោក មហាម៉ាត់ អេ ខាន់ និងមហាមេត អេ រ៉ាហាម៉ាន់ (Mohammad A. Khan and Mohammed A. Rahaman) ស្តីអំពីឥទ្ធិពលនៃមីក្រូហិរញ្ញវត្ថុទៅលើកំរិតជីវភាពរស់នៅ ការផ្តល់សិទ្ធិនិងការលុបបំបាត់ភាពក្រីក្រ (ករណីសិក្សា ស្រុកជីតាហ្គុង ប្រទេសបង់ក្លាដែស) ក្នុងឆ្នាំ២០០៧ បានរកឃើញថា៖

ក. អតិថិជនដែលរស់នៅក្នុងតំបន់សិក្សា ចំនួន ៨៤% គឺជាស្ត្រី ហើយការសិក្សារបស់ពួកគាត់ត្រឹមតែបឋមសិក្សាប៉ុណ្ណោះ។

---

[២៦] Caroline GUILBERT and Dith Samnang, Report on Measuring the social impact, The case of AMK, 2010, pages 9-10

[២៧] Indochina Research, The Impact of Microfinance on People lives and Development Across Indochina, 2013, pages 10-12

ខ. អតិថិជនជាស្ត្រីទាំងនោះភាគច្រើនបំផុតចាប់ផ្តើមបង្កើតមុខរបរតូចតាច របស់ខ្លួនដោយសារកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងតំបន់ បន្ទាប់មកធ្វើឱ្យជីវភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើង។

គ. នៅពេលជីវភាពរស់នៅរបស់ពួកគាត់ប្រសើរឡើង ស្ត្រីទាំងនោះមានសិទ្ធិក្នុងការធ្វើការសំរេចចិត្តនានា ដូចជាមុខរបរ ការងារ គ្រួសារ និង សង្គម កើនឡើង។ ម្យ៉ាងទៀត អតិថិជនក្រីក្រទទួលកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានងាយស្រួលជាងទៅខ្ចីប្រាក់ពីធនាគារ ដោយសារធនាគាររឹតបន្តឹងក្នុង លក្ខខ័ណ្ឌមួយចំនួន ដូចជា ទ្រព្យធានា ប្រាក់ចំណូលទៀងទាត់ខ្ពស់ បញ្ជីចំណូលចំណាយ និងលក្ខខ័ណ្ឌធានារ៉ាប់រងកម្ចី ជាដើម[២៨]។

៨) និក្ខេបបទថ្នាក់បណ្ឌិតរបស់លោក សាហ៊ីឌុល អ៊ីស្លាម (Md. Sahidul Islam) ស្តីអំពីឥទ្ធិពលនៃកម្មវិធីឥណទានខ្នាតតូចរបស់ធនាគារហ្គ្រាមីន ទៅលើជីវភាព រស់នៅរបស់ស្ត្រីក្នុងជនបទ (ករណីសិក្សា ស្រុកបូក្រា ប្រទេសបង់ក្លាដែស) ក្នុងឆ្នាំ ២០១៤ បានរកឃើញថា៖

ក. ឥទ្ធិពលនៃកម្មវិធីឥណទានខ្នាតតូចរបស់ធនាគារហ្គ្រាមីនមានភាពវិជ្ជមាន ទៅលើជីវភាពប្រជាជនក្រីក្រនៅក្នុងតំបន់ជនបទ។ គេសង្កេតឃើញថា ប្រជាជនបានបញ្ជូនកូនចៅទៅសាលារៀនមានចំនួន ច្រើនជាងមុន។

ខ. ផ្ទះសម្បែងរបស់អតិថិជន មានការកែលំអឲ្យស្អាតល្អជាងមុន។ អតិ-ថិជនមានប្រាក់ទិញដីកសិកម្មកើនឡើងជាងមុន។

គ. ការប្រើប្រាស់ទឹកស្អាត ភ្លើងបំភ្លឺផ្ទះសំបែង មានភាពល្អប្រសើរជាងមុន ហើយអ្នកទៅទទួលសេវាថែទាំសុខភាពមានការកើនឡើង ជាងមុន[២៩]។

---

[២៨] Mohammad Arifujjaman Khan and Mohammed Anisur Rahaman, Impact of Microfinance on Living Standards, Empowerment and Poverty Alleviation of Poor People: A Case Study on Microfinance in the Chittagong District of
Bangladesh, Masters Thesis, Fall 2007, pages 74-76

[២៩] Md. Shahidul Islam, IMPACT OF GRAMEEN BANK'S MICROCREDIT PROGRAM ON THE LIV-ING STANDARD OF RURAL WOMEN: A STUDY IN BOGRA DISTRICT, 2014, page 107

៩) របាយការណ៍ព្រឹត្តិប័ត្រវិទ្យាសាស្ត្រពិភពលោក (World Applied Sciences Journal) ស្តីអំពីវិធីសាស្ត្រមីក្រូហិរញ្ញវត្ថុរបស់ធនាគារហ្គ្រាមីន បារ៉ាក់ និងអាសា (Grameen Bank, BRAC and ASA) ក្នុងប្រទេស បង់ក្លាដែស ក្នុងឆ្នាំ២០១២ បានរកឃើញថា៖

ក. ធនាគារទាំងបីខាងលើបានបំពេញតួនាទី យ៉ាងមានប្រសិទ្ធិភាព ក្នុងការជម្រុញឱ្យមានការអភិវឌ្ឍប្រកបដោយចេរភាពផ្នែកមីក្រូហិរញ្ញវត្ថុ ក្នុងតំបន់ក្រីក្រ នៃប្រទេសបង់ក្លាដែស។

ខ. ធនាគារទាំងនោះបានប្រើប្រាស់វិធីសាស្ត្រទាំង "ធានាគ្នាក្នុងក្រុម" និង "ការដាក់ទ្រព្យធានា" ដើម្បីឱ្យដំណើរការកម្ចី និងការសងត្រឡប់មានភាពរលូន។

គ. ទោះបីជាដូច្នេះក៏ដោយ ធនាគារទាំងនោះត្រូវតែមាន គំនិតថ្មីៗ ក្នុងការបង្កើតផលិតផល និងសេវាកម្មថ្មីៗទៀត ផ្នែកហិរញ្ញវត្ថុដើម្បីឲ្យមានការជោគជ័យបន្ត[៣០]។

១០) និក្ខេបបទថ្នាក់អនុបណ្ឌិតរបស់លោកវិធិ កូតាវ៉ាឡា (Vudhi Kotahwala) ស្តីអំពីមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសឥណ្ឌា និងការផ្តល់សិទ្ធិដល់ស្ត្រី ក្នុងឆ្នាំ២០១២ បានរកឃើញថា៖

ក. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់កម្ចី ដល់ស្ត្រីក្រីក្រទាំងនៅក្នុង តំបន់ជនបទ និងទីក្រុងប្រកបមុខរបរតូចតាចដើម្បីបង្កើនប្រាក់ ចំណូលនៅក្នុងគ្រួសារ។

ខ. ផលប្រយោជន៍ឥណទានខ្នាតតូច មានច្រើនប្រភេទដ៏ទៃទៀត ដូចជាស្ត្រីមានទំនាក់ទំនងជាមួយក្រុមស្ត្រីផ្សេងៗទៀតក្នុងមុខរបរ។ ពួកគេរៀនសូត្រអំពីសិទ្ធិរបស់ពួកគេ និងការបញ្ចេញគំនិតយោបល់ផ្សេងៗក្នុងសហគមន៍របស់ពួកគេ។

---

30 World Applied Sciences Journal, The Synthesis of Grameen Bank, BRAC and ASA Microfinance Approaches in Bangladesh, 2012, page 1061

គ. ការផ្តល់ឥណទានខ្នាតតូចក៏មានភាពអវិជ្ជមានខ្លះៗផងដែរដោយសារប្រជាជនក្រីក្រជាច្រើនបានពឹងផ្អែកតែទៅលើដំណាំកសិកម្មតាមរដូវកាល។ ករណីដែលមានគ្រោះធម្មជាតិកើតឡើង ដូចជា គ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួត នាំឱ្យប្រជាជនគ្មានផលិតផលកសិកម្មលក់ ដូច្នេះ ពួកគាត់ក៏ពិបាករកប្រាក់ចំណូលបង់សងត្រឡប់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញដែរ[៣១]។

១១) និក្ខេបបទថ្នាក់បណ្ឌិតរបស់លោកស្រី ព្រីយ៉ានកា បាហ្គាល់ (Priyanka Bargal) ស្តីអំពីប្រសិទ្ធផលនៃមីក្រូហិរញ្ញវត្ថុក្នុងការអភិវឌ្ឍទីក្រុងក្រីក្រ (ករណីសិក្សាទីក្រុងឥណ្ឌូរី ប្រទេសឥណ្ឌា) ក្នុងឆ្នាំ២០១៤ បានរកឃើញថា៖

ក. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចូលរួមចំណែកក្នុងការអភិវឌ្ឍដល់ប្រជាជនក្រីក្រ ដោយផ្តល់ប្រាក់កម្ចី ប្រជាជនបានបង្កើតក្រុមជួយ ខ្លួនឯងក្នុងការបង្កើតមុខរបររកស៊ីនិងបង្កើតការងារ បង្កើនប្រាក់ ចំណូលក្នុងគ្រួសារ និងបង្កើនការទិញទ្រព្យសម្បត្តិចាំបាច់ប្រើប្រាស់ ក្នុងគ្រួសារ។

ជារួម វិស័យមីក្រូហិរញ្ញវត្ថុ គឺជាវិស័យដែលឈានមុខគេ ក្នុងការបំរើសេវាកម្មហិរញ្ញវត្ថុ ទៅដល់ប្រជាជនក្រីក្របំផុត ហើយជួយលើកស្ទួយប្រជាជនទាំងនោះឱ្យរួចចាកផុតពីភាពក្រីក្រ[៣២]។

១២) និក្ខេបបទថ្នាក់បណ្ឌិតរបស់លោក ចយ មុន្នី ម៉ៃណា គីរូ (Joy Mueni Maina Kiiru) ស្តីអំពីឥទ្ធិពលនៃមីក្រូហិរញ្ញវត្ថុទៅលើប្រាក់ចំណូលគ្រួសារ និងគ្រួសារក្រីក្រងាយរងគ្រោះនៅតំបន់ជនបទ (ករណីសិក្សាស្រុកម៉ាគូនី ប្រទេសកេនយ៉ា) ក្នុងឆ្នាំ២០០៧ បានរកឃើញថា៖

ក. មីក្រូហិរញ្ញវត្ថុគឺជាឧបករណ៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ។

ខ. មីក្រូហិរញ្ញវត្ថុបានជួយជំរុញសហគ្រិនមិនផ្លូវការជាច្រើនឱ្យបង្កើនប្រាក់ចំណូល ពង្រីកឱកាសបង្កើតការងារ និងមុខរបរ និងបង្កើនទិន្នផលកសិកម្ម។

---

[៣១] Vidhi Kotahwala, B.A., MICROFINANCE IN INDIA AND HOW IT EMPOWERS WOMEN, 2012, page 81-82

[៣២] Priyankar Bargal, Effectiveness of Microfinance in Development of Slum Areas of Indore, 2014, page 173

គ. ដើម្បីកាត់បន្ថយភាពក្រីក្រឲ្យមានប្រសិទ្ធភាព រដ្ឋាភិបាលត្រូវមានគោលនយោបាយទីផ្សារច្បាស់លាស់ ដើម្បីអន្តរាគមន៍នៅពេលផលិតផលរបស់កសិករមានការកើនឡើង ដូចជាបង្កើតបណ្តាញទីផ្សារទាំងនៅក្នុងស្រុក និងក្រៅស្រុកជាដើម[៣៣]។

ជារួម តាមរយៈការសិក្សាមួយចំនួនដូចមានការបង្ហាញខាងលើវិស័យមីក្រូហិរញ្ញវត្ថុមានឥទ្ធិពលវិជ្ជមាន គួរឲ្យកត់សំគាល់ទៅលើជីវភាពប្រជាជនក្រីក្រជាច្រើនគ្រួសារនៅតាមតំបន់ជនបទ ដូចជាជួយជម្រុញឲ្យប្រជាជនក្រីក្រីទាំងនោះ មានមុខរបរនិងទីផ្សារប្រសើរជាងមុន មានប្រាក់ចំណូលច្រើនជាងមុន មានលទ្ធភាពទិញចំណីអាហារផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់ជាងមុន ចំណីអាហារមានគុណភាពល្អប្រសើរជាងមុន។ ប្រជាជនក៏មានលទ្ធភាពទិញសម្ភារៈចាំបាច់មួយចំនួនសម្រាប់ប្រើប្រាស់ក្នុងគ្រួសារផងដែរ ដូចជា ម៉ូតូ ទូរទស្សន៍ ខោអាវ ទូ គ្រែ ចានឆ្នាំង។ ប្រជាជនខ្លះមានលទ្ធភាពធ្វើផ្ទះថ្មី ឬជួសជុលផ្ទះដែលរស់នៅបច្ចុប្បន្នជាដើម។

ជាការបន្ថែម ដោយសារជីវភាពមានភាពល្អប្រសើរជាងមុន ប្រជាជនទាំងនោះបានបញ្ជូនកូនចៅទៅសាលារៀនជាប់លាប់ច្រើនជាងមុន។ ការថែរក្សាសុខភាព អនាម័យប្រសើរជាងមុន។

ជាចុងក្រោយ នៅពេលមានប្រាក់ចំណូល និងមានជីវភាពល្អប្រសើរជាងមុន ស្ត្រីនៅក្នុងក្រុមគ្រួសារជាច្រើន មានសិទ្ធិចូលរួមក្នុងការសំរេចចិត្តក្នុងគ្រួសារ និងសហគមន៍របស់ពួកគាត់កាន់តែច្រើនជាងមុន។ ដូច្នេះ ស្ត្រីជាច្រើនមានសិទ្ធិអំណាចចូលរួមអភិវឌ្ឍន៍ក្នុងក្រុមគ្រួសារផង និងសង្គមជាតិផង។

---

[៣៣] Joy Mueni Maina Kiiru, THE IMPACT OF MICROFINANCE ON RURAL POOR HOUSEHOLDS' INCOME AND VULNERABILITY TO POVERTY: CASE STUDY OF MAKUENI DISTRICT, KENYA, 2007, page 126-127

## ២-៤ ក្របខ័ណ្ឌទស្សនាទាន ( Conceptual Framework )



# ឯកសារយោង

## ឯកសារភាសាខ្មែរ


១. សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៥១១ គ.ស. ១៩៦៧

២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, ២០០៤, ២០០៦ និង ២០០៨ សោម សុមុនី, ការសរសេរអត្ថបទបែបវិទ្យាសាស្រ្ត, ឆ្នាំ ២០១៦

៣. សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៥១១ គ.ស. ១៩៦៧

៤. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, ២០០៤, ២០០៦ និង ២០០៨

៥. សោម សុមុនី, ការសរសេរអត្ថបទបែបវិទ្យាសាស្រ្ត, ឆ្នាំ ២០១៦

៦. សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប, សេចក្តីណែនាំការធ្វើនិក្ខេបបទ, ឆ្នាំ២០១៧

៧. ធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, ឆ្នាំ១៩៩៩

៨. ធនាគារជាតិនៃកម្ពុជា កម្រងបទបញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, បច្ចុប្បន្នកម្ម ឆ្នាំ២០១១

៩. ធនាគារជាតិនៃកម្ពុជា, របាយការណ៍ប្រចាំឆ្នាំ២០១៦

១០. ក្រេឌីត, របាយការណ៍ប្រចាំឆ្នាំ២០១៦

១១. អម្រឹត, របាយការណ៍ប្រចាំឆ្នាំ២០១៦


## ឯកសារភាសាបរទេស


១. AMK Research Department, AMK Depth of Outreach, 2010

២. Britta Augsburg, PhD Thesis, Microfinance – Greate Good or Lesser Evil? Maastricht University, 2009

៣. Daniel C.Hardy et al., Microfinance Institutions and Public Policy, IMF, 2002

៤. Evans Brako Ntiamoah et al., Loan Default Rate and its Impact on Profitability in Financial Institutions, School of Management & Economics, University of Electronic Science and Technology of China, 2014

៥. Finance for the Poor: Microfinance Development Strategy, ADB, 2000

៦. Kang Chandararot and Dannet Liv, Impace of Micro Finance Services in Cambodia, Cambodia Institution of Development Study (CIDS), Phnom Penh, 2011

៧. Mohammad Arifujjaman Khan and Mohammad Anisur Rahaman, Master Thesis, Fall, Impact of Microfinance on Living Standards, Empowerment and Poverty Alleviation of Poor People: A Case Study on Microfinance in the Chittagong District of Bangladesh, 2007.

# ការពង្រឹងបទដ្ឋានគតិយុត្តស្ថាប័នរដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា

*បណ្ឌិត* ***សាម វ៉ាត***

## មូលន័យសង្ខេប

បន្ទុកនៃការកសាងច្បាប់ឬគោលនយោបាយនានារបស់រដ្ឋ នៅក្នុងការជម្រុញនូវកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រគឺជាកិច្ចការមួយដ៏សំខាន់របស់សភា។ សភាឬក៏អង្គនីតិប្បញ្ញត្តិគឺជាអំណាចមួយក្នុង ចំណោមអំណាចសំខាន់ៗទាំងបីរបស់រដ្ឋ ដែលរួមមានអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាច តុលាការ។ អភិបាលកិច្ចល្អនិងការកាត់បន្ថយភាពក្រីក្រចាំបាច់ត្រូវតែមានការចូលរួមចំណែកពីផ្នែកនីតិប្បញ្ញត្តិ ដោយសារតែផ្នែកនេះមានមុខងារនីតិកម្ម ត្រួតពិនិត្យនិងតាមដានការអនុវត្តន៍ការងាររបស់រដ្ឋាភិបាល ព្រមទាំងធ្វើជាអ្នកតំណាងឱ្យពលរដ្ឋទូទៅ។ ការផាត់ចោលសភាចេញពីឆាកនយោបាយ ឬពីកិច្ចការរដ្ឋ ឬក៏ការដែលធ្វើឱ្យសភាមិនអាចបំពេញមុខងារទាំងអស់នេះបានល្អ ឬមួយក៏បំពេញមុខងារមិនអស់ពីសក្តានុពលរបស់ខ្លួនគឺ មិនត្រឹមតែនាំឱ្យមានការខាតបង់ដល់ប្រយោជន៍ជាតិប៉ុណ្ណោះទេ តែវាថែមទាំងនាំមកនូវផលវិបាកធ្ងន់ធ្ងរដល់នយោបាយរបស់ជាតិរាំងស្ទះការអភិវឌ្ឍន៍ មិនអាចដោះស្រាយបាននូវតម្រូវការរបស់ពលរដ្ឋ ព្រមទាំងមិនអាចកាត់បន្ថយនូវភាពក្រីក្របានទៀតផង។

ដោយមើលឃើញពីសារសំខាន់នៃតួនាទីរបស់អង្គការនីតិប្បញ្ញត្តិបែបនេះហើយ ទើបការសិក្សារបស់យើងនៅពេលនេះ គឺចង់ស្វែងរកនូវគន្លឹះដែលអាចជួយជម្រុញឱ្យរដ្ឋសភាបំពេញការងារកាន់តែមានប្រសិទ្ធិភាពខ្លាំងជាងមុន តាមរយៈការកែលម្អលើច្បាប់ និងបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធដល់ការបំពេញការងាររបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀត ដោយសារតែមិនសូវមានអ្នកសិក្សាចាប់អារម្មណ៍លើការ សិក្សាពីរដ្ឋសភាកម្ពុជា និងដោយមើលឃើញពីសារសំខាន់របស់សភាដូចដែលបានរៀបរាប់ខាងលើការជ្រើសរើសយកប្រធានបទស្តីពី "**ការពង្រឹងបទដ្ឋានគតិយុត្តស្ថាប័នរដ្ឋសភានៃព្រះរាជាណា-**

**ចក្រកម្ពុជា**" ដែលជាការវិភាគលើប្រសិទ្ធិភាពបំពេញមុខងារ និងការអភិវឌ្ឍន៍ច្បាប់ និងបទដ្ឋានគតិយុត្តិ ដែលអាចជះឥទ្ធិពលលើប្រសិទ្ធិភាពបំពេញមុខងាររបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា (២០០៧-២០១៧) និងពិនិត្យមើលពីតួនាទីរបស់ច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងការបង្កើតរដ្ឋសភា និងការបំពេញមុខងាររបស់រដ្ឋសភា។ យើងសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះ គឺមានលក្ខណៈសមស្រមតាមសភាពជាក់ស្តែងនៃការវិវឌ្ឍរបស់ប្រទេសជាតិហើយវាក៏មានតម្លៃ និងសារប្រយោជន៍ដល់សង្គម និងដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗទៀតផង។

# ១.សេចក្តីផ្តើម

## ១.១ ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំណោទបញ្ហាមួយដែលយើងចង់ដឹងគឺថា តើច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលគ្រប់គ្រងលើការបង្កើតស្ថាប័នរដ្ឋសភា និងដំណើរការបំពេញមុខងាររបស់សភាជួយលើកស្ទួយដល់ប្រសិទ្ធិភាពបំពេញមុខងារ របស់សភាក្នុងកម្រឹតណា។ បញ្ហាសំខាន់នៃការស្រាវជ្រាវនេះ គឺចងដឹងពីចំណុចវិជ្ជមានហើយ និងចំណុចអវិជ្ជមានរបស់ច្បាប់ដែលជះឥទ្ធិពលទៅលើឥរិយាបទហើយ និងការប្រព្រឹត្តរបស់សមាជិកសភាហើយ និងមន្ត្រីរាជការនៃអគ្គលេខាធិការ-ដ្ឋានរដ្ឋសភា។ ដូច្នេះយើងនឹងពិនិត្យមើលចំណុចនានារបស់ច្បាប់ជាពិសេសគឺ ចំណុចណាដែលអាចជាឧបសគ្គផ្នែកច្បាប់ ដែលរារាំងដល់ការបំពេញតួនាទីរបស់សមាជិកសមាជិការដ្ឋសភា ឬរារាំងដល់ការបំពេញមុខងាររបស់មន្ត្រីរាជការរដ្ឋសភាហើយក៏ចង់បង្ហាញឱ្យឃើញថា តើបញ្ហាហើយ និងឧបសគ្គដែលរារាំងដល់ការខិតខំបំពេញមុខងាររបស់រដ្ឋសភាទាំងនោះ គេអាចធ្វើការដោះស្រាយ ឬធ្វើកំណែទម្រង់យ៉ាងដូចម្តេច ដើម្បីឱ្យរដ្ឋសភាមានដំណើរការកាន់តែល្អ។ ដោយសារតែទិន្នផលនៃការបំពេញការងាររបស់រដ្ឋសភា មានការជាប់ទាក់ទងទៅនឹងសមត្ថភាពបំពេញការងាររបស់សមាជិកសភា លក្ខខណ្ឌបំពេញការងាររបស់សមាជិករដ្ឋសភា ព្រមទាំងរចនាសម្ព័ន្ធនិងសេវាកម្មជំនួយការគាំទ្រផ្សេងៗទៀតពីមន្ត្រីរដ្ឋបាលរបស់សភាផង នោះយើងនឹងផ្ទៀងផ្ទាត់មើលថាតើច្បាប់និងបទដ្ឋានគតិយុត្តិ ដែលកំពុងតែស្ថិតនៅជាធរមានព្រមទាំងវិធានការនានា និងកំណែទម្រង់រដ្ឋសភានាពេលកន្លងមកនេះ មានលក្ខណៈសមស្របទៅនឹងសភាពជាក់ស្តែងរបស់សង្គម ឬមានលក្ខណៈ

វិទ្យាសាស្ត្រសម្រាប់គាំទ្រដល់ការបញ្ចេញសមត្ថភាពបំពេញការងារ ឬលើកស្ទួយលក្ខខណ្ឌបំពេញការងាររបស់សមាជិករដ្ឋសភាដែរឬទេ។ ដូចនេះសំណួរសំខាន់ៗ ដែលត្រូវលើកយកមកសិក្សារួមមាន៖

១. តើនិយ័តកម្មបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹង**ការជ្រើសរើសមនុស្ស** ដើម្បីបំពេញមុខងារក្នុង ស្ថាប័នរដ្ឋសភាមានលក្ខណៈយ៉ាងដូចម្តេច?
២. តើនិយ័តកម្មបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹង**ការរៀបចំរចនាសម្ព័ន្ធ** ដើម្បីបំពេញមុខងារក្នុងស្ថាប័នរដ្ឋសភាមានលក្ខណៈយ៉ាងដូចម្តេច?
៣. តើនិយ័តកម្មបទដ្ឋានគតិយុត្តនានាទាក់ទងនឹង**សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ**របស់បុគ្គល និងអង្គភាពនានា ក្នុងការបំពេញមុខងារមានលក្ខណៈយ៉ាងដូចម្តេច?

## ១.២ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺចង់ចូលរួមចំណែកកែលម្អប្រសិទ្ធិភាពបំពេញមុខងាររដ្ឋសភាកម្ពុជា ដោយធ្វើការស្វែងយល់ពីទស្សនាទាននិងទ្រឹស្តីនានាដែលទាក់ទងនឹងមុខងារសភា រចនាសម្ព័ន្ធ របស់រដ្ឋសភានិងដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈទ្រឹស្តី និងព័ត៌មាននានាដែលរកបានក្នុងការសិក្សានេះ យើងអាចចូលរួមចំណែកក្នុងការពិភាក្សា និងចូលរួម យោបល់ក្នុងការកែលម្អទៅលើវិស័យច្បាប់ ជាពិសេសច្បាប់ដែលមានឥទ្ធិពលទៅលើការបំពេញមុខងាររបស់រដ្ឋសភាកម្ពុជាឲ្យកាន់តែល្អនិងមានប្រសិទ្ធិភាព។ ដើម្បីធ្វើឱ្យការសិក្សាលើប្រធានបទនេះកាន់តែមានលក្ខណៈទូលំទូលាយ និងច្បាស់លាស់យើងនឹងធ្វើការពិនិត្យលើចំណុចសំខាន់ៗមួយចំនួនរបស់សភាដូចជា៖

១. ឥទ្ធិពលរបស់រដ្ឋធម្មនុញ្ញនិងច្បាប់មួយចំនួនទៅលើដំណើរការបង្កើតស្ថាប័នរដ្ឋសភា
២. ឥទ្ធិពលរបស់រដ្ឋធម្មនុញ្ញ និងច្បាប់មួយចំនួនទៅលើដំណើរការបំពេញមុខងាររបស់រដ្ឋសភា
៣. តើរដ្ឋសភាកម្ពុជាបានធ្វើអ្វីខ្លះក្នុងការកែលំអច្បាប់និងបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន។

ផ្អែកតាមលទ្ធផលនៃការរកឃើញនៅក្នុងចំណុចខាងលើ យើងក៏**មានបំណងរៀបចំនូវអនុសាសន៍មួយចំនួនដែលទាក់ទងនឹងការពង្រឹងដំណើរការការងារកំណែទម្រង់ និងបង្កើនសមត្ថភាពរបស់រដ្ឋសភាដែលរួមមានសមត្ថភាពបំពេញការងាររបស់សមាជិករដ្ឋសភា និងសមត្ថភាពផ្តល់សេវាកម្មរបស់មន្ត្រីអគ្គលេខាធិការដ្ឋានជូន ដល់រដ្ឋសភា និងអ្នកតំណាងរាស្ត្រ។** ការពង្រឹងចំណុចទាំងអស់នេះ អាចធ្វើឱ្យអ្នកតំណាងរាស្ត្រមានសមត្ថភាព និងមានមូលដ្ឋានគ្រប់គ្រាន់រឹងមាំក្នុងការបំពេញមុខងារសំខាន់ៗទាំងបីរបស់ខ្លួន គឺមុខងារនីតិកម្ម ដែលជាមុខងារ ពិនិត្យ និងអនុម័តច្បាប់ មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល និងមុខងារធ្វើជាតំណាងរបស់ប្រជាពលរដ្ឋ។

## ២. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះស្ថិតក្នុងក្របខណ្ឌមុខវិជ្ជានីតិរដ្ឋបាលសាធារណៈ។ វិធីសាស្ត្រដែលត្រូវប្រើក្នុងការស្រាវជ្រាវនេះគឺ **ការវិភាគលើប្រសិទ្ធិភាពនៃនិយ័តកម្មបទដ្ឋានគតិយុត្តិ** (The Regulatory Impact Analysis)។ ជាទូទៅ ការវិភាគលើប្រសិទ្ធិភាពនៃនិយ័តកម្មបទដ្ឋានគតិយុត្តិ គឺជាដំណើរការមួយដែលមានការប្រមូល និងការវិភាគនូវនិន្នន័យនានាក្នុងគោលបំណងបង្កើននូវប្រសិទ្ធិភាពនៃវិធានគតិយុត្តិ ដោយធ្វើការវិភាគពីឥទ្ធិពលរបស់ច្បាប់ទៅលើសង្គម សេដ្ឋកិច្ច និងផលប៉ះពាល់ផ្សេងៗទៀត ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ដោយការបង្ហាញហេតុផលផ្សេងៗទៅតាមចរិតលក្ខណៈរបស់បទដ្ឋានគតិយុត្តិនីមួយៗ។

### ក.ចំណុចដែលត្រូវវិភាគ

ដើម្បីវាយតម្លៃពីកត្តាជម្រុញរបស់បទដ្ឋានគតិយុត្តិនានា ទៅលើសមត្ថភាពបំពេញមុខងាររបស់រដ្ឋសភា យើងធ្វើការវិភាគសំខាន់ៗលើទិដ្ឋភាពចំនួនបីគឺ៖

ក-លក្ខខណ្ឌនៃការជ្រើសរើសមនុស្ស ដើម្បីបំពេញមុខងារដែលកំណត់ក្នុងបទដ្ឋានគតិយុត្តិនានា។

ខ-លក្ខខណ្ឌនៃការរៀបចំរចនាសម្ព័ន្ធការងារ ដែលកំណត់ក្នុងបទដ្ឋានគតិយុត្តិនានា។

គ-លក្ខខណ្ឌនៃការបំពេញមុខងារដែលកំណត់ក្នុងបទដ្ឋានគតិយុត្តិនានា។

ជាទូទៅសមត្ថភាពផ្ទាល់របស់បុគ្គលម្នាក់ ដែលត្រូវជ្រើសរើសឱ្យបំពេញមុខងារអ្វីមួយគឺមានសារសំខាន់ណាស់ ដែលវាអាចជះឥទ្ធិពលដោយផ្ទាល់ទៅលើទិន្នផលនៃការងារដែលបុគ្គលនោះត្រូវបំពេញ។ មានន័យថា បើគេជ្រើសរើសបានមនុស្សដែលល្អ និងពូកែនោះទិន្នផលការងារ និងបានខ្ពស់ឬបានល្អជាមិនខាន។ ដូចគ្នានេះដែរ យើងអាចសន្និដ្ឋានបានថាកាលណាតំណាងរាស្ត្រ ឬមន្ត្រីរដ្ឋសភាមានសមត្ថភាពនោះទិន្នផលការងាររបស់គាត់ពិតជាល្អ។

ហើយរឿងទីពីរដែលយើងយល់ថាវាមានសារសំខាន់និងជះឥទ្ធិពលដល់សមត្ថភាពរបស់រដ្ឋសភាដែរនោះ គឺរចនាសម្ព័ន្ធ និងសេវាកម្មដែលគាំទ្រការងាររបស់រដ្ឋសភា។ រដ្ឋបាលរបស់រដ្ឋសភាដែលទទួលការងារគ្រប់យ៉ាង ក្នុងការជួយសម្របសម្រួលកិច្ចការរបស់តំណាងរាស្ត្រអាចជួយជម្រុញការងារតំណាងរាស្ត្រឱ្យកាន់តែលឿន កាន់តែល្អ ឬក៏អាចធ្វើឱ្យការងារតំណាងរាស្ត្រយឺត និងមិនបានល្អផងដែរ។ ការពិនិត្យទៅលើឥទ្ធិពល របស់ច្បាប់ និងបទដ្ឋានគតិយុត្តនានា ដែលគ្រប់គ្រងលើដំណើរការផ្តល់សេវាកម្មជូនអ្នកតំណាងរាស្ត្រ អាចឱ្យយើងវាយតម្លៃបានមួយចំណែកទៀត ពីកត្តាដែលជះឥទ្ធិពលលើសមត្ថភាពបំពេញមុខងាររបស់រដ្ឋសភា។

ឯចំណែកមួយទៀតដែលសំខាន់ ហើយនាំឲ្យមានផលទៅលើលទ្ធផលការងារដែរនោះគឺល័ក្ខខ័ណ្ឌនៃការបំពេញការងារ។ កាលណាបរិយាកាសបំពេញការងារ ការផ្តល់សិទ្ធិអំណាចគ្រប់គ្រាន់ ដែលផ្តល់អំណោយ ផលល្អដល់អ្នកធ្វើការងារ នោះទិន្នផលការងារក៏នឹងបានល្អប្រសើរជាមិនខាន។ ដូច្នេះនៅក្នុងបរិបទនៃការវាយតម្លៃទៅលើសកម្មភាពនៃការអនុវត្តការងាររបស់អ្នកតំណាងរាស្ត្រ ការពិនិត្យទៅលើលក្ខខណ្ឌនានារបស់ច្បាប់ ដែលកំណត់ពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រ និងមន្ត្រី វាគឺជាការមួយសមស្របសម្រាប់ធ្វើការសន្និដ្ឋានពីលទ្ធភាពបំពេញការងាររបស់គាត់។

### ខ.ការប្រមូលទិន្នន័យ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ការវិភាគដែលសំខាន់ជាងគេគឺជាការវិភាគទៅលើខ្លឹមសាររបស់ច្បាប់ និងបទដ្ឋានគតិយុត្តិនានា ដែលគ្រប់គ្រងទៅលើការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័នរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះការប្រមូលឯកសារច្បាប់

និងបទដ្ឋានគតិយុត្តិទាំងនេះអាចស្វែងរកពីរាជកិច្ច ពីបណ្ណាល័យ និងពីការិយាល័យនានានៅក្នុងរដ្ឋសភា។ ក្រៅពីច្បាប់និងបទដ្ឋានគតិយុត្តិ ព័ត៌មានផ្សេងៗទៀតដែលត្រូវប្រើដើម្បីបញ្ជាក់អះអាងលើទ្រឹស្តី លើការវិភាគឬវាយតម្លៃ ត្រូវបានស្វែងរកតាមបណ្ណាល័យ តាមការិយាល័យនានា តាមអ៊ិនធឺណេតឬតាមការធ្វើទំនាក់ទំនងជាមួយបុគ្គលិកនានានៅក្នុងស្ថាប័នរដ្ឋសភា។

**គ.វង្វាស់អថេរ**

ចរិតលក្ខណៈបំពេញមុខងាររបស់រដ្ឋសភាត្រូវបានរងឥទ្ធិពលដោយកត្តានានាជាច្រើនប្រភេទ ព្រមទាំងអន្តរាគមន៍ពីអថេរផ្សេងៗជាច្រើនទៀត។ តែនៅក្នុងការសិក្សានេះ វង្វាស់អថេរដែលសំខាន់គឺ ឥទ្ធិពល ឬផលប៉ះពាល់របស់ច្បាប់ និងបទដ្ឋានគតិយុត្តនានា ទៅលើសមត្ថភាពនៃការបំពេញមុខងាររបស់រដ្ឋសភា។ ដូច្នេះ សមត្ថភាពនៃការបំពេញមុខងាររបស់រដ្ឋសភាគឺជាអថេរមិនឯករាជ្យ (dependent variable) ដែលអាចប្រែប្រួល ទៅតាមលក្ខខណ្ឌមួយចំនួនរបស់ច្បាប់ដែលជាអថេរឯករាជ្យ (independent variable)។ ហើយលក្ខខណ្ឌទាំងនោះរួមមានលក្ខខណ្ឌនៃការជ្រើសរើស លក្ខខណ្ឌនៃការរៀបចំរចនាសម្ព័ន្ធការងារ និងសេវាកម្មគាំទ្រ ព្រមទាំងលក្ខខណ្ឌនៃការបំពេញការងារ ដែលលក្ខខណ្ឌទាំងនេះកំណត់ដោយច្បាប់ និងបទដ្ឋានគតិយុត្តនានាដូចជារដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា លក្ខន្តិកៈអ្នកតំណាងរាស្ត្រ ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ សេចក្តីសម្រេចរបស់រដ្ឋសភាស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋសភាជាដើម។ ច្បាប់ និងបទដ្ឋានគតិយុត្តទាំងនេះ គឺជាមូលហេតុដែលអាចជួយឲ្យរដ្ឋសភាបំពេញការងារ ប្រកបដោយលទ្ធផលល្អ ហើយវាក៏អាចជាឧបសគ្គ ក្នុងការនាំឲ្យមាននូវភាពប្រែប្រួលមិនល្អទៅដល់សមត្ថភាពបំពេញការងារទាំងនោះវិញផងដែរ។

**ឃ.វិធីសាស្ត្រវិភាគ**

ការវិភាគដែលប្រើប្រាស់នៅក្នុងនិក្ខេបបទនេះរួមមាន ការអះអាងដោយផ្អែកលើការប្រៀបធៀប និងការអធិប្បាយតាមបែបគុណវិស័យ។ ឥទ្ធិពលរបស់ច្បាប់ទៅលើចរិតលក្ខណៈនៃការបំពេញការងាររបស់មនុស្ស អាចបង្ហាញឱ្យឃើញតាមរយៈលទ្ធផល និងគុណភាពនៃការបំពេញការងារ ព្រមទាំងឥរិយាបទនៃការបំពេញមុខងារ។ លទ្ធផល និងគុណភាពនៃការ

បំពេញការងារព្រមទាំងឥរិយាបទនៃការបំពេញមុខងារ អាចវិនិច្ឆ័យដោយពឹងផ្អែកលើការប្រៀបធៀបជាមួយនឹងទ្រឹស្តី និងការអនុវត្តល្អៗក្នុងសភានានា នៅលើពិភពលោក ឬក៏អាចប្រៀបធៀប និងវាយតម្លៃទៅតាមការយល់ឃើញទូទៅ។

# ៣. លទ្ធផលនៃការស្រាវជ្រាវ

## ៣.១ ទ្រឹស្តីពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្តគ្រប់គ្រងលើការងារសភា

### ៣.១.១ ទ្រឹស្តីពាក់ព័ន្ធនឹងសិទ្ធិអំណាចបំពេញមុខងារសភា

**ក.អំណាចនិងមុខងារសភា**

ជាធម្មតា សភាត្រូវបានគេសំគាល់ឃើញថាមានមុខងារសំខាន់បីគឺ៖ មុខងារធ្វើច្បាប់ មុខងារត្រួតពិនិត្យ និងមុខងារធ្វើជាតំណាងឱ្យពលរដ្ឋ។ មុខងារធ្វើច្បាប់របស់សភាគឺជាផ្នែកមួយដ៏សំខាន់របស់កិច្ចការប្រទេស ដែលបង្កើតឱ្យមាននូវសណ្តាប់ធ្នាប់ក្នុងសង្គម និងការរីកចម្រើនខាងសេដ្ឋកិច្ចតាមរយៈរចនាសម្ព័ន្ធច្បាប់ដែល ធានានូវសុវត្ថិភាពនិងការរីកចម្រើនទាំងនេះ។ មុខងារត្រួតពិនិត្យរបស់សភាគឺសំដៅទៅដល់ការតាមដានរបស់ សភានៅក្នុងដំណើរការអនុវត្តច្បាប់ និងគោលនយោបាយជាតិសំខាន់ៗរបស់ផ្នែកនីតិប្រតិបត្តិ ដើម្បីធានាថាផ្នែកនិតិប្រតិបត្តិអនុវត្តត្រឹមត្រូវតាមច្បាប់ និងបម្រើឱ្យផលប្រយោជន៍ប្រជាជន។ ចំពោះមុខងារជាតំណាងរបស់ពលរដ្ឋវិញគឺទាក់ទងនឹងការទទួលនិងប្រមូលនូវមតិយោបល់នានាដែលជាកង្វល់ ឬជាការសម្តែងមតិរបស់ពលរដ្ឋដែលទាក់ទងនឹងជីវភាពរស់នៅរបស់ពួកគាត់ ដើម្បីធ្វើការដោះស្រាយតាមរយៈការធ្វើច្បាប់ ឬការបង្កើតជាគោលនយោបាយនានាដែលអាចជួយដោះស្រាយ ឬក៏ជួយសម្រាលដល់ជីវភាពរស់នៅ[៦]។

**ការសន្និដ្ឋានរបស់យើងទាក់ទងនឹងអំណាចអធិបតេយ្យរបស់សភាគឺថា ដើម្បីធ្វើឱ្យសភាអាចបំពេញមុខងារធ្វើច្បាប់ ត្រួតពិនិត្យកិច្ចការផ្នែកនីតិប្រតិបត្តិ និងជាតំណាងរបស់ពលរដ្ឋបាន សភាត្រូវតែមានអំណាចអធិបតេយ្យមួយជាក់លាក់ដើម្បីបំពេញមុខងាររបស់ខ្លួន ហើយអំណាចអធិបតេយ្យនេះ ត្រូវតែកំណត់ច្បាស់លាស់ដោយច្បាប់កំពូលរបស់រដ្ឋ និង**

[៦] Anthony Tsekpo and Alan Hudson, *Parliamentary Strengthening and the Paris Principles, Cambodia case study*, Overseas Development Institute, ២០០៩, p.២

**បទដ្ឋានគតិយុត្តផ្សេងៗទៀត។ ការបង្កើតសភា ដោយគ្មានការផ្តល់អំណាចសម្រាប់បំពេញមុខងារពេញលេញគឺជារឿងដែលគ្មានប្រយោជន៍សម្រាប់ជាតិ។**

**ខ.ការគោរពច្បាប់និងឆន្ទៈពលរដ្ឋ**

ក្នុងប្រទេសដែលមានការអភិវឌ្ឍយឺតយ៉ាវ ពលរដ្ឋមួយចំនួន បែរជាឱ្យតម្លៃទៅលើសមាជិកសភាណា ដែលមានធនធានហិរញ្ញវត្ថុ ដោយរំពឹងថានៅពេលដែលជាប់ឆ្នោតសមាជិកសភានោះ នឹងនាំមកឱ្យមណ្ឌល របស់ខ្លួននូវសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ អគ្គិសនី ឬការជួយលើពីធីបុណ្យផ្សេងៗទៀតជាដើម[២]។ ទស្សនៈបែបនេះ បានជះឥទ្ធិពលមិនល្អដល់ការពង្រឹងកិច្ចការរបស់សភា និងនាំប្រទេសជាតិមានដំណើរយឺតយ៉ាវក្នុង ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ដូច្នេះ នៅក្នុងលក្ខខណ្ឌដែលប្រទេសមួយមានពលរដ្ឋក្រីក្រច្រើន និងទទួលបានការអប់រំទាប ឆន្ទៈទូទៅមិនអាចការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមបានល្អនោះទេ។ ចំពោះ Rousseau គាត់បានយល់ថា ច្បាប់គឺជាការសម្តែងចេញនូវឆន្ទៈទូទៅ។ ឆន្ទៈរួមមិនមែនជាលទ្ធផលនៃការវាស់ស្ទង់មតិ តាមបែបបរិមាណវិស័យ ដើម្បីរកឱ្យឃើញពីកម្រិតយល់ស្របគ្នាភាគច្រើននោះទេ ប៉ុន្តែវាជាការចូលរួមចំណែកជាមួយគ្នានូវការយល់ឃើញអំពីនយោបាយដ៏ល្អមួយរបស់រដ្ឋ[៣]។ មតិភាគច្រើនដែលគួរទទួលយកត្រូវតែជាមតិដែលកើតចេញពីសេចក្តីសម្រេចចិត្ត ដែលទទួលបានការបំភ្លឺពីរបៀបក្នុងការធ្វើសេចក្តីសម្រេចរបស់ពួកគេដោយហ្មត់ចត់[៤]។

**ការសន្និដ្ឋានរបស់យើងទាក់ទងនឹងការគោរពច្បាប់និងឆន្ទៈពលរដ្ឋគឺថា ដើម្បីឱ្យសភាមួយមាន ដំណើរការទៅដោយរលូនបាន បទដ្ឋានគតិយុត្តដែលគ្រប់គ្រងលើការបំពេញមុខ**

---

[២]Anthony Tsekpo and Alan Hudson, Parliamentary Strengthening and the Paris Principles, Cambodia case study, Overseas Development Institute, 2009, p.2-3

[៣] B.S. Faloon, The Declararion of Rights of Man and Citizen, The Old Limerick Journal, French Edition, p.65, www.limerickcity.ie/...declaration%20of%20the%20rights%20of%20ma( accessed 07 November 2015 )

[៤] Jean Jacques Rousseau, *The Social Contract*, p. 19, www.earlymoderntexts.com/assets/pdf/rousseau1762book2.pdf( accessed 07 November 2015 )

ងាររបស់សភាគឺត្រូវច្បាស់លាស់ មាននីតិវិធីត្រឹមត្រូវ មានគោលបំណងច្បាស់លាស់បម្រើឱ្យផលប្រយោជន៍សាធារណៈ។ ទោះជាមតិភាគច្រើនគួរតែទទួលយកក្តី ក៏មតិនេះត្រូវតែជាមតិដែលកើតចេញពីសេចក្តីសម្រេចចិត្ត ដែលទទួលបានការបំភ្លឺដោយច្បាស់លាស់និងហ្មត់ចត់។ ដូច្នេះ នៅមុនការបោះឆ្នោតលើកិច្ចការណាមួយ ការពិភាក្សាដើម្បីបង្ហាញហេតុផលទាក់ទងនឹងរឿងដែលត្រូវបោះឆ្នោតដោយបើកចំហ គ្មានការហាមឃាត់ ឬគាបសង្កត់ គឺជារឿងមួយដែលមានសារសំខាន់បំផុត។

### គ.ការបែងចែកអំណាច

ការបែងចែកអំណាចគឺជាទស្សនាទានមួយដ៏សំខាន់ នៅក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋនាសម័យទំនើប។ បើគ្មានការបែងចែកអំណាចអោយបានច្បាស់លាស់ទេ ការអនុវត្តនូវភាពជាតំណាងរបស់ពលរដ្ឋមិនអាចលេចចេញជារូបភាពច្បាស់លាស់ និងពិតប្រាកដបានឡើយ។ ការបែងចែកអំណាចបានកម្រិត នូវតុល្យភាពនៃការទទួលខុសត្រូវរបស់អ្នកតំណាងទៅតាមអំណាចដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់នានារបស់រដ្ឋ[៥]។ ក្នុងចំណោមចំណុចនានាជាច្រើន ដែលធ្វើឱ្យសភាខ្សោយគឺមានចំណុចមួយដែលច្បាប់ឬប្រព័ន្ធនយោបាយរបស់ប្រទេសបានដាក់សភានៅក្នុងតំណែងមួយ ដែលមិនមានឯករាជ្យភាពក្នុងការបំពេញមុខងាររបស់ខ្លួនឬមិនមានអំណាចនៅក្នុងការធ្វើសេចក្តីសម្រេចខាងនយោបាយ[៦]។

**ជារួមទស្សនៈរបស់យើងចំពោះការបែងចែកអំណាចគឺថា ការរៀបចំច្បាប់នានា ជាពិសេស ច្បាប់អង្គការដែលគ្រប់គ្រងលើដំណើរប្រព្រឹត្តទៅរបស់ស្ថាប័នរដ្ឋ គឺត្រូវតែមានលក្ខណៈប្រយ័ត្នប្រយែងដើម្បីធានាឱ្យបានថា ដំណើរប្រព្រឹត្តរបស់ស្ថាប័នទាំងនោះមិនបំពានលើអំណាចគ្នាទៅវិញទៅមក។ ការបែងចែកអំណាចមិនដាច់ពីគ្នា ឬការដែលផ្នែកនីតិប្រតិបត្តិប្រមូលអំណាចនិងការអនុវត្តអំណាចទាំងអស់ដោយផ្តាច់មុខ នឹងនាំឱ្យសភាស្ថិតនៅ**

---

[៥] David J samuels and Mathew Soberg Shugart, Presdialsim, Elections and Representation, Journal of theoretical Politics, Sage Publications London, Thousand Oaks, CA and New Helhi,2003. P.34

[៦] Anthony Tsekpo and Alan Hudson, Parliamentary Strengthening and the Paris Principles, Cambodia case study, Overseas Development Institute, 2009, p.2

ក្នុងស្ថានភាពទន់ខ្សោយខាងអំណាចនយោបាយក្នុងប្រព័ន្ធដឹកនាំរដ្ឋ ឬត្រូវបានផាត់ចេញពីអំណាចនយោបាយ ដោយផ្នែកនីតិប្រតិបត្តផង និងដោយពលរដ្ឋផងដែរ ដោយសារពលរដ្ឋគ្មានជំនឿលើអំណាចសភា និងសមត្ថភាពរបស់សភា ថាអាចការពារពួកគេឬធ្វើជាតំណាងរបស់ពួកគេបាន។

### ៣.១.២ ទ្រឹស្តីទាក់ទងនឹងការពង្រឹងសមត្ថភាពសភា

### ក.កត្តាពន្យល់ពីការអភិវឌ្ឍន៍របស់សភា

នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ គេឃើញមានរចនាសម្ព័ន្ធស្មុគ្រស្មាញជាច្រើនដូចជា៖ នីតិវិធីបំពេញការងាររបស់សភា បទប្បញ្ញត្តិផ្សេងៗដែលគ្រប់គ្រងលើដំណើរការរដ្ឋបាលរបស់សភា រចនាសម្ព័ន្ធជំនាញរបស់ស្ថាប័នជាដើម។ ហើយនីតិវិធីបំពេញការងាររបស់សភា បទប្បញ្ញត្តិផ្សេងៗ ដែលគ្រប់គ្រងលើដំណើរការរដ្ឋបាលរបស់សភាទាំងអស់នោះត្រូវតែផ្តល់នូវភាពងាយស្រួលទៅដល់សមាជិកសភា នៅក្នុងការបំពេញការងារ ឬជួយសម្រួលទៅដល់គណបក្សនយោបាយ ក្រុមដែលមានផលប្រយោជន៍ សង្គម ស៊ីវិលជាពិសេស គឺដំណើរការរួមរបស់សភាតែម្តង[៧]។

ដូច្នេះ ការសន្និដ្ឋានរបស់យើងគឺថា ច្បាប់និងបទដ្ឋានគតិយុត្តនានា គឺជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀត ដែលមានតួនាទីមួយយ៉ាងសំខាន់នៅក្នុងការបំពេញមុខងាររបស់សភានិងការអភិវឌ្ឍន៍របស់សភា។

### ខ.ទស្សនាទានទាក់ទងនឹងឥទ្ធិពលនៃច្បាប់បោះឆ្នោត

យើងសន្និដ្ឋានថា ប្រព័ន្ធបោះឆ្នោត និងផលវិបាករបស់ប្រព័ន្ធបោះឆ្នោតបានជះឥទ្ធិពលយ៉ាងខ្លាំង ទៅលើដំណើរការបំពេញការងាររបស់សភា។ ការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធបោះឆ្នោត អាចជះឥទ្ធិពលជាច្រើន ដល់ការផ្លាស់ប្តូរនៅក្នុងអង្គនីតិប្បញ្ញត្តិ តាមរបៀបផ្សេងៗគ្នា ដែលអាចធ្វើឱ្យមានការប្រែប្រួលយ៉ាងច្រើនដែល មានតាំងពីការផ្លាស់ប្តូរខាងសមាសភាពសមាជិកសភា រហូតដល់ធ្វើឱ្យមានការប្រែប្រួលដល់ការគ្រប់គ្រងក្នុង សភាពីគណបក្ស

[៧] Schickler, Eric. *Disjointed Pluralism: Institutional Innovation and the Development of the U.S. Congress*. Princeton: Princeton University Press, 2001.p.3

នយោបាយនានា ឬអាចធ្វើឱ្យមានការផ្លាស់ប្តូរការដឹកនាំនៅក្នុងរដ្ឋាភិបាល នៅក្នុងប្រទេសដែលប្រកាន់របបសភានិយមទៀតផង។

**គ.ទស្សនាទានទាក់ទងនឹងក្រុម ឬអង្គការក្រៅរដ្ឋាភិបាលដែលមានឥទ្ធិពលលើការងារសភា**

ក្រុមឬអង្គការដែលមានឥទ្ធិពលលើសភា អាចប្រែក្លាយផលប្រយោជន៍របស់ផ្នែកនានានៃសង្គមឱ្យទៅ ជាការទាមទារផ្នែកនយោបាយហើយនាំយកការទាមទារទាំងនេះ ដាក់បញ្ចូលក្នុងដំណើរការរៀបចំនយោបាយឬការតាក់តែងច្បាប់[៩]។

ជារួមយើងសន្និដ្ឋានថា ការធ្វើច្បាប់មួយដែលអាចអនុញ្ញាតឱ្យមានការចូលរួមចំណែកជាមតិយោបល់ ឬជាថវិកាពីក្រុមឬអង្គការនានាដែលនៅខាងក្រៅសភាក៏ជាចំណែកមួយនាំឱ្យសភាកាន់តែរឹងមាំផងដែរ។

**ឃ.ទស្សនាទានទាក់ទងនឹងសមត្ថភាពនិងធនធានរបស់ស្ថាប័នសភា**

យើងស្និដ្ឋានថា ដើម្បីឱ្យសភាមានភាពឯករាជ្យ សភាមិនគ្រាន់តែត្រូវការនូវអំណាចនីតិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់នានាប៉ុណ្ណោះទេ តែសភាក៏ត្រូវតែមានសមត្ថភាព ដោយខ្លួនឯងក្នុងកម្រិតណាមួយដែលសមស្របនិងមានមធ្យោបាយគ្រប់គ្រាន់ថែមទៀត ទើបការងាររបស់សភា អាចមានដំណើរការទៅបានល្អនិងមានប្រសិទ្ធិភាព។ ដើម្បីឱ្យសភាមានភាពឯករាជ្យបែបនេះ បទដ្ឋានគតិយុត្តនានាដែលគ្រប់គ្រងលើដំណើរការសភា ត្រូវតែផ្តល់ឱ្យសភាមានភាពងាយស្រួល ក្នុងការកសាងសមត្ថភាពដោយខ្លួនឯងនៅក្នុងកម្រិតណាមួយដែលសមស្របនិងមានមធ្យោបាយគ្រប់គ្រាន់ថែមទៀត ទើបការងាររបស់សភាអាចមានដំណើរការទៅបានល្អនិងមានប្រសិទ្ធិភាព។

**ង.ទស្សនាទានទាក់ទងនឹងសមត្ថភាពរបស់សមាជិកសភា**

ការសន្និដ្ឋានរបស់យើងទាក់ទងនឹងសមត្ថភាពរបស់សមាជិកសភាគឺថា ក្នុងបរិបទនៃការបំពេញការងាររបស់សភា ដែលមានតួនាទីជាស្ថាប័នធ្វើច្បាប់យើងយល់ថា វាជារឿងមួយចាំបាច់ខ្លាំង ណាស់ដែលសមាជិកសភាត្រូវតែមាននូវកម្រិតវប្បធម៌ខ្ពស់។ ហើយដើម្បី

---

[៩] Almond Gabriel A., ***Research Note: A Comparative Study of Interest Groups and Political Process***, American Political Science Review 52.1, 1958, p.273

អាចទទួលបាននូវសមាជិកសភា ដែលមានកម្រិតវប្បធម៌ខ្ពស់បែបនេះ ច្បាប់ដែលគេប្រើដើម្បីជ្រើសរើសសមាជិកសភាត្រូវតែកំណត់នូវលក្ខខណ្ឌនានាដែលផ្ដល់ឱកាសសម្រាប់អ្នកចេះដឹង។

**ច.ទស្សនាទានទាក់ទងនឹងលធម៌ក្នុងការបំពេញមុខងារសភា**

លទ្ធភាពបំពេញមុខងាររបស់សភា គឺមិនត្រឹមតែអាស្រ័យទៅលើធនធានហិរញ្ញវត្ថុរបស់ស្ថាប័នសភា និងសមត្ថភាពបច្ចេកទេសបំពេញមុខងាររបស់សភាប៉ុណ្ណោះទេ តែវាអាស្រ័យមួយចំណែកធំទៅលើក្របខ័ណ្ឌ ច្បាប់ដែលផ្ដល់សេរីភាពក្នុងការបំពេញមុខងារ និងតម្រង់ទិសវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ។ ជាទូទៅ មានការយល់ឃើញដូចគ្នាថា ស្ថាប័នសភាល្អ ឬសមាជិកសភាល្អគឺនៅពេលដែលស្ថាប័នសភាបំពេញមុខងារដោយឯករាជ្យ ក្នុងនាមពលរដ្ឋ និងដើម្បីប្រយោជន៍សាធារណៈគឺមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍របស់គណបក្ស យោបាយនោះឡើយ។

ដូច្នេះយើងសន្និដ្ឋានថា ក្នុងការបំពេញមុខងាររបស់សភា ជាចាំបាច់គឺត្រូវតែមានសំណុំនៃ វិធានឬបទដ្ឋាននានាដែលណែនាំពីរបៀបនៃការបញ្ចេញឥរិយាបទនិងការប្រព្រឹត្តនៅក្នុងវិជ្ជាជីវៈ ដើម្បីតម្រង់ទិសការប្រព្រឹត្តដល់សមាជិកសភាលើជំនាញវិជ្ជាជីវៈរបស់ខ្លួន។ ម្យ៉ាងទៀត ការធ្វើរបៀបនេះ គឺអាចបញ្ចៀសការបកស្រាយទៅតាមការយល់ឃើញរបស់បុគ្គលម្នាក់ៗ ពីឥរិយាបទណាមួយរបស់សមាជិករដ្ឋសភាថាខុសឬត្រូវ តាមការនឹកឃើញរបស់ពួកគេផងដែរ។

## ៣.២ លក្ខណៈបទគតិយុត្តគ្រប់គ្រងលើការងាររដ្ឋសភា

**ក.ការអភិវឌ្ឍបទដ្ឋានគតិយុត្ត**

ចាប់តាំងពីឆ្នាំ១៩៩៣ មកប្រទេសកម្ពុជាបានរៀបចំឡើងវិញនូវបទដ្ឋានគតិយុត្តនានាជាច្រើន ហើយជាមួយនោះដែរ ក៏មានការកែប្រែនូវបទដ្ឋានគតិយុត្តមួយចំនួនធំជាបន្តបន្ទាប់។ ក្នុងចំណោមការកែប្រែទាំងនោះ គេឃើញថារដ្ឋធម្មនុញ្ញមានការធ្វើវិសោធនកម្មចំនួន៨លើកគឺ លើកទី១ ក្នុងឆ្នាំ ១៩៩៤ មានការកែប្រែមាត្រា២៨ ទាក់ទងនឹងសិទ្ធិឡាយព្រះហស្ដលេខារបស់ព្រះមហាក្សត្រលើរាជក្រម ប្រកាសឱ្យប្រើច្បាប់ និងការប្រទានសិទ្ធិនេះក្នុងករណីព្រះអង្គប្រឈួន។ លើកទី២ ក្នុងឆ្នាំ ១៩៩៩ មានការកែប្រែមាត្រាជាច្រើនដូចជា

មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងជំពូក៨ ដល់ជំពូក១៤ ដោយសារមានការបង្កើតបន្ថែមនូវស្ថាប័ននីតិប្បញ្ញត្តិមួយថ្មីទៀត គឺព្រឹទ្ធិសភា។ លើកទី៣ ក្នុងឆ្នាំ ២០០១ មានការកែប្រែមាត្រា ១៩ និងមាត្រា ២៩ ដែលទាក់ទងនឹងការតែងតាំងមន្ត្រីជាន់ខ្ពស់ និងការផ្តល់គ្រឿងឥស្សរិយយសជាតិ។ លើកទី៤ ក្នុងឆ្នាំ ២០០៤ មានការបង្កើតបន្ថែមនូវច្បាប់ធម្មនុញ្ញ។ លើកទី៥ ក្នុងឆ្នាំ ២០០៥ មានការកែប្រែមាត្រា ៨៨ និង១១១ថ្មី ដែលទាក់ទងនឹងការប្រជុំ និងចំនួនកូរ៉ុមរបស់សភានិងព្រឹទ្ធិសភា។ លើកទី៦ ក្នុងឆ្នាំ ២០០៦ មានការកែប្រែមាត្រា ៨២ ៨៨ថ្មី ៩៨ ១០៦ថ្មី ១១៤ថ្មី និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែម។ លើកទី៧ ក្នុងឆ្នាំ ២០០៨ មានការកែប្រែមាត្រា១៤៥ថ្មី និង ១៤៦ថ្មី ដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាល លើកទី៨ ក្នុងឆ្នាំ ២០១៤ មានការកែប្រែមាត្រា៧៦ ជំពូក ១៥ និងជំពូក១៦។

ការកែមួយចំនួនក្នុងចំណោមការកែប្រែទាំងនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រសិទ្ធិភាពបំពេញ មុខងាររបស់រដ្ឋសភាដោយផ្ទាល់ជាពិសេសការកែប្រែចំនួនកូរ៉ុំប្រជុំ និងការអនុវត្តច្បាប់ធម្មនុញ្ញបន្ថែម។

**ខ.លក្ខខណ្ឌគតិយុត្តនៃការជ្រើសរើសមនុស្សសម្រាប់បំពេញមុខងារ**

ជារួមយើងបានឃើញថា លក្ខខណ្ឌនៅក្នុងបទបញ្ញត្តិនានាដែលចែងពីការជ្រើសតាំងសមាជិកសភាមិនបានគូសបញ្ជាក់ពីតម្រូវការខាងសមត្ថភាពសម្រាប់បំពេញមុខងារសភា ឬមុខងារជាអ្នកដឹកនាំនោះឡើយ ហើយបើទោះបីជាមានការកែប្រែច្បាប់ជាច្រើនលើកក៏ដោយក៏ចំណុចនេះគេមិនឃើញមានការកែប្រែនៅអ្វីឡើយទេ។

បើពិនិត្យទៅលើខ្លឹមសារនៃអត្ថបទច្បាប់ដែលទាក់ទងនឹងការជ្រើសរើសមន្ត្រី យើងឃើញថាវាមានលក្ខណៈល្អប្រសើរច្រើន ដែលអាចធ្វើឱ្យរដ្ឋសភាជ្រើសរើសមន្ត្រីដែលមានលក្ខណៈសមស្របសម្រាប់ជួយ ការងារគណៈកម្មការជំនាញ ឬជួយតំណាងរាស្ត្របានយ៉ាងល្អ។ ជំពូកទី៣នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ ដែលនិយាយពីការជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារបានរៀបរាប់ពីគោលការណ៍នៃការជ្រើសរើស[៩] លក្ខណៈ

[៩] ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ មាត្រា១៧

សម្បត្តិរបស់បេក្ខជន[១០] លក្ខខណ្ឌនៃការផ្សព្វផ្សាយព័ត៌មាននៃការជ្រើសរើស[១១] សមាសភាពរបស់គណៈកម្មការជ្រើសរើស[១២] កម្រិតសញ្ញាប័ត្រដែលក្របខណ្ឌនីមួយៗតម្រូវឱ្យមាន[១៣] និងសមត្ថកិច្ចនៃការធ្វើផែនការជ្រើសរើសមន្ត្រីប្រចាំឆ្នាំ[១៤]។ ក៏ប៉ុន្តែរហូតមកទល់ពេលនេះគេមិនឃើញមានភស្តុតាងណាមួយដែលចង្អុលបង្ហាញពីការជ្រើសរើសមន្ត្រីក្របខណ្ឌរដ្ឋសភា ដោយបើកចំហរ និងស្របតាមគោលការណ៍ ច្បាប់ សម្រាប់បំពេញការងារនៅក្នុងគណៈកម្មការជំនាញនៅឡើយទេ ហើយក៏មិនទាន់ឃើញមានផែនការ ជាផ្លូវការរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភាក្នុងការជ្រើសរើសមន្ត្រីសម្រាប់ការងារនេះនៅឡើយដែរ។

### គ.លក្ខខណ្ឌគតិយុត្តនៃការរៀបចំស្ថាប័ន

រដ្ឋធម្មនុញ្ញបានផ្តល់លទ្ធភាពសម្រាប់ការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់រដ្ឋសភា ដោយរដ្ឋធម្មនុញ្ញ មិនបានកំណត់ពីចំនួនជាក់លាក់របស់គណៈកម្មការជំនាញនៃរដ្ឋសភានោះទេ ដោយទុកលទ្ធភាពឱ្យរដ្ឋសភាខ្លួន ឯងជាអ្នកសម្រេចក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន[(១៥)(១៦)] ហើយនេះគឺជាចំណុចដ៏ល្អមួយ ដែលអាចឱ្យរដ្ឋសភាមានឱកាសធ្វើការកែសម្រួលរចនាសម្ព័ន្ធបំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព ស្របទៅតាមស្ថានភាពជាក់ស្តែងរបស់សង្គម។ ក្រោមប្រព័ន្ធបោះឆ្នោតសមាមាត្រដែលមានបញ្ជីបិទ សមត្ថភាពនិងអំណាចបំពេញ មុខងាររបស់តំណាងរាស្ត្រនិងគណៈកម្មការជំនាញមានកម្រិត ហើយក៏ធ្វើឱ្យរាស្ត្រមិនសូវមានទំនាក់ទំនងច្រើន ជាមួយនឹងសមាជិកសភា ឬសមាជិកគណៈកម្មការជំនាញផងដែរ។

---

[១០],ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ មាត្រា១៨

[១១]Ibid,មាត្រា១៩

[១២] Ibid,មាត្រា២០

[១៣]Ibid,មាត្រា២១

[១៤] Ibid,មាត្រា២២

[១៥]រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ១៩៩៣ មាត្រា ៩៤

[១៦] Ibid,មាត្រា ៨២ ថ្មី

ការរៀបចំរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានរដ្ឋសភាមានការផ្លាស់ប្តូរជាច្រើនលើក ក៏ប៉ុន្តែនៅមានចំណុចខ្លះដែលមិនទាន់រលូន ដូចជាមិនទាន់មានការចង្អុលភារកិច្ចច្បាស់លាស់ ការបែកភារកិច្ចជាន់គ្នា ហើយរចនាសម្ព័ន្ធស្មុគ្រស្មាញនិងធំពេក។

**ឃ.លក្ខខណ្ឌនៃការបំពេញមុខងារ**

សិទ្ធិក្នុងការធ្វើសកម្មភាពនិងបញ្ចេញមតិមិនទាន់មានការធានាមួយរឹងមាំ និងច្បាស់លាស់។ ក្នុងការងារនីតិកម្មច្បាប់អាចបើកចំហរនិងបត់បែនមិនច្បាស់លាស់ដោយអាចបកស្រាយបានច្រើនយ៉ាង ទាំងបើកអំណាច និងមិនបើកអំណាច។ ក្នុងការចោទសួរទៅកាន់តំណាងរាជរដ្ឋាភិបាល សមាជិការដ្ឋសភាមិនមានសិទ្ធិដោយស្វ័យប្រវត្តិក្នុងការសួរដេញដោលលម្អិតបន្ថែមទៅលើការឆ្លើយរបស់សមាជិករាជរដ្ឋាភិបាលនោះទេ លុះណាតែមានការបើកឲ្យដដែកដេញដោល ដែលអាចជាការអនុញ្ញាតរបស់ប្រធានរដ្ឋសភា ឬក៏អាចជាការបើកឲ្យសួរបន្ថែមពីអ្នកដែលមកឆ្លើយ ហើយការចោទសួរតែមួយពេលនិងគ្មានការបោះឆ្នោតណាមួយក្រោយ ការចោទសួរគឺជាការកំហិតអំណាចមួយរបស់រដ្ឋសភាផងដែរ។ នីតិវិធីនៃការប្រជុំចំនួនកូរ៉ុមប្រជុំ ការបោះឆ្នោត លើកិច្ចការនានា បានពន្លឿនការប្រជុំ និងការពិភាក្សា ប៉ុន្តែវាបានការត់បន្ថយនូវអំណាចនៃការពិភាក្សា និងការធ្វើសេចក្តីសម្រេចរបស់បុគ្គលម្នាក់ៗដែលជាសមាជិកសភាទៅវិញផងដែរ។ នៅក្នុងការបំពេញមុខងាររបស់រដ្ឋសភាកម្ពុជា គេមិនទាន់ឃើញមានអត្ថបទច្បាប់មួយ ឬបទដ្ឋានគតិយុត្តមួយ ដែលចែងលម្អិតពីក្រមសីលធម៌រដ្ឋសភាដាច់តែឯងដើម្បីធានានូវភាពស្មោះត្រង់ ភាពសុចរិត និងមានសីលធម៌នៅឡើយទេ។

ចំពោះច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ដែលគ្រប់គ្រងលើសកម្មភាពមន្ត្រីវិញគឺ មានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់សម្រាប់ឲ្យសមាជិក ឬសមាជិកាសភាមានភាពកក់ក្តៅក្នុងការទទួលបាននូវ សេវាកម្មដូចៗគ្នាពីអង្គភាពរដ្ឋបាលរបស់ស្ថាប័នរដ្ឋសភាក៏បញ្ញត្តិនេះនៅតែគ្មានប្រសិទ្ធិភាពឬគ្មានប្រយោជន៍ ដោយសារតែមន្ត្រីរាជការនៅតែអាចជ្រើសរើសការអនុវត្តន៍ដោយសេរីតាមការចូលចិត្តរបស់ខ្លួនបាន ព្រោះថាគ្មានបញ្ញត្តិណាមួយដែលចែង អំពីទោសនៅពេលដែលគេល្មើសនឹងច្បាប់នេះទេ។

# ៤.សេចក្តីសន្និដ្ឋាននិងអនុសាសន៍

## ៤.១ សេចក្តីសន្និដ្ឋាន

បើសង្កេតជារួមនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋសភាមានការរីកចម្រើនមួយចំនួនដែលគួរឱ្យកត់សម្គាល់នៅក្នុងការកសាង និងលើកកម្ពស់សមត្ថភាពបំពេញមុខងាររបស់ខ្លួនឱ្យមានភាពប្រសើរជាងមុនដូចជា រដ្ឋសភាបានខិតខំអនុវត្តនូវគោលការណ៍អភិបាលកិច្ចល្អ គណៈកម្មការជំនាញរបស់រដ្ឋសភាបានបំពេញមុខងារ ពិនិត្យលើសេចក្តីព្រាងច្បាប់មានលក្ខណៈសកម្មជាងមុន និងមានការផ្តល់យោបល់ប្រកបដោយលក្ខណៈ បច្ចេកទេសល្អសម្រាប់ការពិភាក្សានៅក្នុងសម័យប្រជុំពេញអង្គ។ នៅក្នុងគណៈកម្មាការជំនាញរដ្ឋសភាមានសមាជិកសភាមកពីគណបក្សប្រឆាំង ហើយអាចមានតួនាទីជាប្រធានគណៈកម្មាការដែលនេះគឺជាផ្នែកមួយ ជួយជម្រុញតួនាទីសភាក្នុងការពិនិត្យ តាមដានការងារផ្នែកនីតិ-ប្រតិបត្តិ ពិនិត្យពិច័យសេចក្តីព្រាងច្បាប់ និងកែលម្អគុណភាពនៃការពិភាក្សានៅក្នុងសម័យប្រជុំពេញអង្គឱ្យមានភាពសកម្មជាងមុន។ គុណភាពនៃការពិភាក្សានៅក្នុងសម័យប្រជុំពេញអង្គរបស់រដ្ឋសភាលើប្រធានបទនានា មានលក្ខណៈប្រសើរជាងមុន។ គណៈកម្មការនានាធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាញឹកញាប់ ហើយរដ្ឋសភាមានកិច្ចសហប្រតិបត្តការច្រើនជាមួយអង្គការនានានៅក្នុងការពង្រឹងសមត្ថភាពរបស់រដ្ឋសភា។ ទាំងអស់នេះគឺជាលទ្ធផលនៃការកែលម្អលើបទបញ្ញត្តិនានា ដែលទាក់ទងនឹងនីតិវិធីបំពេញមុខងាររបស់រដ្ឋសភានិងការកែលម្អរចនាសម្ព័ន្ធរបស់រដ្ឋសភា។

ទោះបីជាមានការវិវត្តល្អៗ មួយចំនួនដូចបានរៀបរាប់ខាងលើក្តី ក៏ចំណុចមួយចំនួនទៀតដែលស្ថិតក្នុង លក្ខខណ្ឌនៃការបំពេញមុខងាររបស់សភានៅតែស្ថិតក្នុងភាពមិនទាន់ជាក់ច្បាស់នៅឡើយ នៅក្នុងលក្ខខណ្ឌនៃបទដ្ឋានគតិយុត្តទាក់ទងនឹងការជ្រើសរើសមនុស្សសម្រាប់បំពេញមុខងារ ការរៀបចំរចនាសម្ព័ន្ធស្ថាប័ន និងលក្ខខណ្ឌនៃការបំពេញមុខងារ។

នៅក្នុងក្របខណ្ឌនៃការជ្រើសតាំងអ្នកតំណាងរាស្ត្រ បទដ្ឋានគតិយុត្តសំខាន់ៗ ដូចជារដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមិនបានតម្រូវពីលក្ខណៈសម្បត្តិខាងកម្រិតវប្បធម៌ ឬវិជ្ជាជីវៈនោះទេ។ ទោះបីជាច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានការកែប្រែជាច្រើនលើកក្តី ក៏ចំណុចខាងលើនេះនៅរក្សាដដែល។ ចំពោះការតម្រូវឱ្យ

បេក្ខជនតំណាងរាស្ត្រត្រូវមានការតែងតាំងពីបក្សណាមួយ ការបោះឆ្នោត រើសយកបញ្ជីគណបក្សនយោបាយ និងការឱ្យជាប់ឆ្នោតទៅតាមលំដាប់លេខរៀងរបស់បញ្ជីគណបក្សនយោបាយ គឺជាការផ្តល់អំណាចយ៉ាងធំដល់គណបក្សនយោបាយ ដែលលក្ខណៈបែបនេះមិនសូវជម្រុញការ បញ្ចេញសមត្ថភាពផ្ទាល់ខ្លួនរបស់សមាជិកសភាម្នាក់ៗនោះទេ។

ចំពោះលក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីវិញយើងឃើញថា ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បានចែងយ៉ាងពេញលេញពីលក្ខណៈសម្បត្តិខាងកម្រិតវប្បធម៌ ឬវិជ្ជាជីវៈ ដែលត្រូវជ្រើសរើសទៅតាមតម្រូវការរបស់រដ្ឋសភា។ ប៉ុន្តែការមិនបានអនុវត្តត្រឹមត្រូវតាមមាត្រានានា ដែលចែងពីការជ្រើសរើសមន្ត្រី គឺជាចំណុចអវិជ្ជមានមួយដែលរាំងដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋសភា។ ការមិនបានកំណត់ទោសទណ្ឌ លើការប្រព្រឹត្តខុសនឹងច្បាប់នេះ អាចជាចំណុចខ្សោយមួយដែលនាំឱ្យច្បាប់នេះមិនមានប្រសិទ្ធិភាព។

នៅក្នុងក្របខណ្ឌនៃការរៀបចំរចនាសម្ព័ន្ធការងារវិញ ទោះបីជាចំនួនគណៈកម្មការជំនាញបានកើនឡើងដល់១០ គណៈកម្មការជំនាញក្តី ក៏បន្ទុកការងាររបស់គណៈកម្មការនៅតែធំដដែល។ ម្យ៉ាងទៀត ដោយសារសមាជិកគណៈកម្មការជំនាញរដ្ឋសភាជាច្រើនមិនមានជំនាញឯកទេសគ្រប់គ្រាន់លើវិស័យដែលខ្លួនទទួលខុសត្រូវដ៏ធំ និងដ៏ច្រើន និងដោយសារតែសេវាកម្មគាំទ្រការងារគណៈកម្មការនៅមានកម្រិត ទាំងចំណេះដឹង ទាំងការលើកទឹកចិត្តក្នុងការបំពេញការងារ និងហិរញ្ញវត្ថុនៅមានកម្រិត ដូច្នេះគណៈកម្មការជំនាញរដ្ឋសភា មិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដាន និងត្រួតពិនិត្យលើការងាររបស់ផ្នែកនីតិប្រតិបត្តិឱ្យបានគ្រប់ជ្រុងជ្រោយនិងពេញលេញនៅឡើយទេ។ ដោយហេតុនេះហើយ ផ្នែកនីតិប្រតិបត្តិនៅតែមានឥទ្ធិពលគ្របដណ្តប់លើផ្នែកនីតិប្បញ្ញត្តិ។

ចំពោះរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានរដ្ឋសភា ដែលទ្រទ្រង់សេវាកម្មទូទៅរបស់រដ្ឋសភាវិញគឺមាន ការរីកធំធាត់យ៉ាងខ្លាំងដោយការកើនឡើងនូវអង្គភាពថ្មីៗ និងបុគ្គលិកបម្រើការងារថ្មីៗជាច្រើននាក់។ បទប្បញ្ញត្តិគតិយុត្តដែលគ្រប់គ្រងលើរចនាសម្ព័ន្ធ និងការបំពេញមុខងាររបស់អគ្គលេខាធិការដ្ឋានបានផ្លាស់ប្តូរ និងកែប្រែជាច្រើនលើក។ តែទោះជាយ៉ាងនេះក្តី សេវាកម្មមួយចំនួនមិនទាន់ បម្រើចំទិសដៅនៃមុខងាររបស់រដ្ឋសភា ឬមិនត្រូវតាម

ជំនាញដែលគណៈកម្មការរដ្ឋសភាត្រូវការនៅឡើយទេ។ ការបែងចែកភារកិច្ចសម្រាប់ អង្គភាពនានា នៅក្នុងអគ្គលេខាធិការដ្ឋាននៅតែមិនទាន់ច្បាស់លាស់និងជាន់ភារកិច្ចគ្នាជាច្រើនកន្លែង។

នៅក្នុងលក្ខខណ្ឌនៃការបំពេញមុខងារវិញ គេឃើញមានការធ្វើវិសោធនកម្មជាច្រើនលើកលើបទដ្ឋាន គតិយុត្តនានាដែលទាក់ទងនឹងការបំពេញមុខងាររដ្ឋសភា ដែលនាំឱ្យរដ្ឋសភាមានដំណើរការបានលឿនជាង មុនដោយមិនមានការជាប់គាំង តែជាមួយគ្នានេះដែរ វិសោធនកម្មទាំងនោះបានកាត់បន្ថយនូវសិទ្ធិ និងអំណាចជាច្រើនរបស់សមាជិកសភា ជាពិសេសវិសោធនកម្មទាក់ទងនឹងចំនួនកូរ៉ុមចាំបាច់សម្រាប់ការប្រជុំ និងរបៀបនៃការបោះឆ្នោតអនុម័តលើការងារសំខាន់ៗមួយចំនួន។ ក្រៅពីនេះ រដ្ឋសភាមិនទាន់មានក្រមសីលធម៌មួយដោយឡែកដែលជួយធានានូវភាពស្មោះត្រង់ ភាពសុចរិត និងមានសីលធម៌ក្នុងការ បំពេញមុខងារនៅឡើយទេ។ ចំពោះការធ្វើទំនាក់ទំនងជាមួយនឹងពលរដ្ឋវិញ សមាជិកសភាច្រើនតែមានទំនាក់ទំនងជាមួយនឹងរាស្ត្រដែលគាំទ្រគណបក្សនយោបាយរបស់ខ្លួន ជាជាងការផ្តល់សារៈសំខាន់លើកង្វល់របស់ពលរដ្ឋទូទៅ ដែលមិនមែនជាសមាជិកគណបក្សនយោបាយរបស់ខ្លួន ដែលលក្ខណៈបែបនេះ គឺស្របទៅនឹងទ្រឹស្តីដែលនិយាយពីឥទ្ធិពលនៃប្រព័ន្ធបោះឆ្នោតទៅលើសកម្មភាពរបស់សមាជិកសភា ដោយបង្ហាញថាប្រព័ន្ធបោះឆ្នោតបញ្ជីសមាមាត្ររបស់គណបក្ស ការគ្រប់គ្រងនិងចាត់ចែងស្ថាប័នគឺធ្វើតាមរបៀបមជ្ឈការ អំណាចហើយអំណាចស្ថិតនៅក្នុងដៃអ្នកដឹកនាំគណបក្ស ដែលជាអ្នកធ្វើសេចក្តីសម្រេចលើគ្រប់បញ្ហា ដែលលក្ខណៈបែបនេះធ្វើឱ្យសមាជិកសភាមិនសូវមានគំនិតដោះស្រាយនូវកង្វល់នានាដែលលើកឡើងដោយប្រជាពលរដ្ឋក្នុងមណ្ឌល ដែលពួកគេឈរឈ្មោះបោះឆ្នោតនោះទេ ដែលទំនោរនេះគឺខុសគ្នាពីសមាសជិកសភាដែលជ្រើសរើសតាមបែបឯកត្តនាម។

ហើយនៅក្នុងការបំពេញមុខងាររបស់មន្ត្រីវិញ យើងឃើញថាច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុម នីតិប្បញ្ញត្តិ បានតម្រូវឱ្យមានអាព្យាក្រឹត្យភាពក្នុងការផ្តល់សេវាកម្មជូនអ្នកតំណាងរាស្ត្រទាំងអស់ ដែលនេះគឺជាលក្ខណៈមួយត្រឹមត្រូវសម្រាប់ឱ្យសមាជិក ឬសមាជិការដ្ឋសភាមានភាពកក់ក្តៅក្នុងការទទួលបាននូវសេវាកម្មដូចៗគ្នា។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងចំណុចនេះមិនទាន់អនុវត្តឱ្យមានប្រសិទ្ធិភាពនៅឡើយទេ ហើយម្យ៉ាងទៀតនៅក្នុងច្បាប់ខាងលើនេះ គេមិនឃើញមានបញ្ញត្តិណាមួយដែលដាក់ទោសទណ្ឌលើការ

ប្រព្រឹត្តល្មើស ឬការប្រតិបត្តិការងារមិនអាព្យាក្រឹត្យក្នុងការផ្តល់សេវានេះនោះទេ ដែលនេះក៏ជាចំណុចមួយជះ ឥទ្ធិពលមិនល្អដល់ការបំពេញមុខងាររបស់រដ្ឋសភាផងដែរ។

**៤.២.អនុសាសន៍**

១.ដើម្បីឱ្យសមាជិកសភាកាន់តែសកម្មនិងមានការទទួលខុសត្រូវជាងមុន ជាចាំបាច់គេត្រូវតែកែប្រែលើបទដ្ឋានគតិយុត្តមួយចំនួនដូចជា៖

- កែសម្រួលលើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលអាចឱ្យពលរដ្ឋធ្វើការជ្រើសរើសដោយផ្ទាល់ នូវបុគ្គលដែលពួកគាត់ចង់បានដោយប្តូរលក្ខខណ្ឌនៃការជ្រើសរើសបេក្ខជន។
- រៀបចំក្រមសីលធម៌សភាមួយសម្រាប់សមាជិករដ្ឋសភា ដែលមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់។

២.ដើម្បីធ្វើឱ្យអគ្គលេខាធិការដ្ឋានរដ្ឋសភាកាន់តែរឹងមាំ និងមានសមត្ថភាពកាន់តែប្រសើរឡើងក្នុងការផ្តល់សេវាកម្មជូនដល់រដ្ឋសភានិងសមាជិកសមាជិការដ្ឋសភាគេត្រូវ៖

- ពង្រឹងការអនុវត្ត **ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ**ឱ្យបានត្រឹមត្រូវនិងពេញលេញ និងធ្វើវិសោធនកម្មលើច្បាប់នេះដោយបន្ថែមមាត្រាមួយចំនួនដែលចែងពីទោសទណ្ឌនៃការមិនអនុវត្តត្រឹមត្រូវ។
- កែសម្រួលការបែងចែកភារកិច្ចនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា ឱ្យកាន់តែមានភាពច្បាស់លាស់ និងងាយស្រួលជាងមុន ដោយចៀសវាងនូវការដាក់ភារកិច្ចដែលមិនច្បាស់លាស់និងត្រួតជាន់លើគ្នា។

# ឯកសារយោង


១- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ១៩៩៣

២- ច្បាប់ស្តីពី *លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ*

៣- Almond Gabriel A., ***Research Note: A Comparative Study of Interest Groups and Political Process***, American Political Science Review 52.1, 1958

៤- Anthony Tsekpo and Alan Hudson, Parliamentary Strengthening and the Paris Principles, Cambodia case study, Overseas Development Institute, 2009

៥- B.S. Faloon, The Declararion of Rights of Man and Citizen, The Old Limerick Journal, French Edition, p.65, www.limerickcity.ie/...declaration%20of%20the%20rights%20of%20ma accessed07 November 2015

៦- David J samuels and Mathew Soberg Shugart, Presdialsim, Elections and Representation, Journal of theoretical Politics, Sage Publications London, Thousand Oaks, CA and New Helhi,2003

៧- Jean Jacques Rousseau, ***The Social Contract***, p. 19, www.earlymoderntexts.com/assets/pdf/rousseau1762book2.pdf accessed 07 November 2015

៨- Schickler, Eric. ***Disjointed Pluralism: Institutional Innovation and the Development of the U.S. Congress***. Princeton: Princeton University Press, 2001

# ការទទួលសេវាថែទាំជំងឺអេដស៍ពីស្ថាប័នសុខាភិបាលសាធារណៈនៅកម្ពុជា (ករណីសិក្សា ការមាក់ងាយ នៃអ្នកផ្ទុកមេរោគអេដស៍)

*បណ្ឌិត* ***ស៊ឹម សុផៃ***

## មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះ ឆ្លើយតបនឹងតម្រូវការចាំបាច់ក្នុងការកំណត់នូវទម្រង់នៃការមាក់ងាយ និងការយល់ឃើញរបស់អ្នកផ្ទុកមេរោគអេដស៍ (PLHIV) ដែលអាចរួមចំណែកក្នុងការកាត់បន្ថយនូវការមាក់ងាយគ្រប់ទម្រង់ និងជួយឱ្យមានទំនុកចិត្តមកទទួលសេវាកាន់តែច្រើន ព្រមទាំងជួយជំរុញដល់ការផ្តល់សេវាថែទាំជំងឺអេដស៍ប្រកបដោយគុណភាព។ ការសិក្សានេះមានគោលបំណងវិភាគនូវ៖ ១) ការមាក់ងាយ ២) ទំនាក់ទំនងរវាងអថេរការមាក់ងាយ និង៣) ទស្សនៈចំពោះការមាក់ងាយលើសេវាថែទាំជំងឺអេដស៍។ ការសិក្សានេះប្រើវិធីសាស្ត្របែបចម្រុះ (បែបគុណវិស័យផង និងបរិមាណវិស័យផង)។

ភាគសំណាកសរុបចំនួន ៣៩៥ មកពី ៤ខេត្តផ្សេងៗគ្នា ដែលចូលរួមក្នុងការសិក្សានេះ ត្រូវបានជ្រើសរើសដោយចៃដន្យ តាមវិធីសាស្ត្រសមាមាត្រ។ ផ្អែកលើការឆ្លើយតបនឹងការសាកសួរ ភាគសំណាកចំនួន ១៩ ត្រូវបានជ្រើសរើសចូលរួមសម្ភាសន៍ពាក់កណ្តាលគ្រោងទុក។ កម្រងសំណួរស្តង់ដារ "ការមាក់ងាយ និងរើសអើង" និង"គុណភាពសេវា" ត្រូវបានកែសម្រួលផ្ទៀងផ្ទាត់ដោយអ្នកស្រាវជ្រាវ និងបកប្រែតាមវិធីបកត្រឡប់។ កម្រងសំណួរជាភាសាខ្មែរត្រូវបានធ្វើតេស្តសាកល្បង និងប្រើប្រាស់។ ទិន្នន័យដែលប្រមូលបាន ត្រូវយកមកវិភាគដោយប្រើស្ថិតិពិពណ៌នា ស្ថិតិវិភាគ តាមរយៈកម្មវិធី SPSS ២៥ និងសម្រង់ទស្សនៈ។ លទ្ធផលសំខាន់ៗ នៃការសិក្សានេះ មានដូចខាងក្រោម៖

១) ការមាក់ងាយខ្លួនឯង មានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់។ តម្លៃមធ្យមខ្ពស់ជាងគេ គឺ"លាក់ស្ថានភាពផ្ទុកមេរោគអេដស៍ពីអ្នកដទៃ"។ ការមាក់ងាយខ្លួនឯងមានទំនាក់ទំនងទីកន្លែង (,០០១) អាយុ (,០៥) និងកម្រិតប្រាក់ចំណូល (,០៥)។ ការមាក់ងាយពីខាង

ក្រៅនៅតែមាន បើទោះបីមានការថយចុះក៏ដោយ។ ការមាក់ងាយពីខាងក្រៅមានទំនាក់ទំនងវិជ្ជមាននឹងទីកន្លែង (,០៥)។

២) ការមាក់ងាយ មានទំនាក់ទំនងសំខាន់ជាវិជ្ជមានជាមួយអថេរនៃអាយុ (,០៥) និងប្រាក់ចំណូល (,០០១)។

៣) តាមទស្សនៈអ្នកទទួលសេវា ការមាក់ងាយនៅតែមានកើតឡើង ជាពិសេសការមាក់ងាយខ្លួនឯងនៅមានកម្រិតខ្ពស់។ ការយល់ឃើញលើសេវាថែទាំជំងឺអេដស៍ មានភាពជាវិជ្ជមានច្រើន។

ការសិក្សានេះ បានផ្តល់ជាអនុសាសន៍ សម្រាប់អ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធនឹងការងារឆ្លើយតបនឹងមេរោគអេដស៍ ជាពិសេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ អាចផ្តល់អត្ថប្រយោជន៍ប្រកបដោយសក្តានុពលដល់អ្នកផ្ទុកមេរោគអេដស៍។

**ពាក្យគន្លឹះ៖ អេដស៍ សេវាជំងឺអេដស៍ ការមាក់ងាយ និង ការយល់ឃើញ**

## ១. សេចក្តីផ្តើម

### ១.១. លំនាំបញ្ហា នៃការស្រាវជ្រាវ

មេរោគអេដស៍ គឺជាមេរោគមួយប្រភេទដែលបង្កឱ្យភាពស៊ាំរបស់មនុស្សចុះខ្សោយ ដែលនឹងបង្កឱ្យមានជាចង្កោមរោគសញ្ញាជាច្រើន និងបានគេរកឃើញជាដំបូងនៅចុងឆ្នាំ ១៩៨០ នៅប្រទេសអាមេរិក។ មេរោគអេដស៍បានរីករាលពាសពេញពិភពលោកយ៉ាងឆាប់រហ័ស រហូតមកដល់ឆ្នាំ២០២១នេះ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណជា ៣៨,៤ លាននាក់ នៅទូទាំងពិភពលោក[១]។

កម្ពុជាជាប្រទេសមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ មានប្រជាជនសរុបប្រមាណជា ១៦ លាននាក់ នៅឆ្នាំ២០១៩[២]។ កម្ពុជាបានរកឃើញករណីផ្ទុកមេរោគអេដស៍ដំបូងនៅឆ្នាំ១៩៩១ និងរីករាលដាលកាន់តែធ្ងន់ធ្ងរពីមួយឆ្នាំទៅមួយឆ្នាំ[៣]។ កម្ពុជាមានអត្រាផ្ទុកមេរោគអេដស៍ ១,៦៨ ភាគរយ ក្នុងឆ្នាំ១៩៩៨[៤] និងធ្លាក់ចុះនៅ ០,៦ ភាគរយ ក្នុងឆ្នាំ២០២១[៥]។ ដោយ

ទទួលស្គាល់ហានិភ័យខ្ពស់នៃឆ្លងការមេរោគអេដស៍ កម្ពុជាបានដាក់ចុះនូវបទអន្តរាគមន៍ជាច្រើន បណ្ដាលអត្រាមេរោគអេដស៍ថយចុះមកនៅត្រឹមតែ ០,៥៤ ភាគរយ ក្នុងឆ្នាំ២០២២ ចំណោមមនុស្សពេញវ័យដែលមានអាយុពី ១៥-៤៥ឆ្នាំ ដែលមានអ្នកផ្ទុកមេរោគអេដស៍ប្រមាណជា ៧៦ ០០០នាក់[៥] [៦]។ បច្ចុប្បន្ននេះ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានជិត ១០០ ភាគរយ នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន[៦]។

ការមាក់ងាយទាក់ទងនឹងមេរោគអេដស៍ មិនត្រឹមតែជាការរំលោភសិទ្ធិមនុស្សប៉ុណ្ណោះទេ តែវាក៏ជះឥទ្ធិពលដល់អ្នកផ្ទុកមេរោគអេដស៍ក្នុងការមកទទួលសេវាថែទាំជំងឺអេដស៍ផងដែរ។ ការមាក់ងាយទាក់ទងនឹងមេរោគអេដស៍នៅតែមាន និងជាបញ្ហាចម្បងនៅកម្ពុជា បើទោះបីមានកាត់បន្ថយក៏ដោយ។ ″ការលុបបំបាត់ការរើសអើងទាក់ទងនឹងមេរោគអេដស៍″ ជាគោលដៅមួយក្នុងចំណោមគោលដៅទាំងបីរបស់អង្គការសុខភាពពិភពលោក[៧]។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍នៅកម្ពុជា ត្រូវបានថយចុះជាបន្តបន្ទាប់ដោយសារមានអន្តរាគមន៍នានាក៏ដោយ ប៉ុន្តែចំនួនអ្នកផ្ទុកមេរោគអេដស៍មកទទួលសេវាជំងឺអេដស៍មានកម្រិតទាបនៅឡើយ។ កត្តាជាច្រើនបានរារាំងដល់ការមកទទួលសេវាជំងឺអេដស៍នៃអ្នកផ្ទុកមេរោគអេដស៍ ក្នុងនោះក៏អាចដោយសារកត្តាមាក់ងាយ។ ការសិក្សាស្រាវជ្រាវពី **"ការទទួលសេវាថែទាំជំងឺអេដស៍ពីស្ថាប័នសុខាភិបាលសាធារណៈនៅកម្ពុជា (ករណីសិក្សាការមាក់ងាយនៃអ្នកផ្ទុកមេរោគអេដស៍"** នឹងយកកត្តាទាំងនេះមកពិភាក្សា និងកំណត់នូវបញ្ហា បន្ទាប់មកផ្តល់នូវអនុសាសន៍ ដើម្បីការផ្តល់សេវាជំងឺអេដស៍នៅកម្ពុជាកាន់តែប្រសើរឡើង។

ការសិក្សាស្រាវជ្រាវខាងលើនេះ នឹងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ដូចខាងក្រោម៖

- តើការមាក់ងាយចំពោះអ្នកផ្ទុកមេរោគអេដស៍មានកម្រិតណា?
- តើអថេរ នៃការមាក់ងាយរបស់អ្នកផ្ទុកមេរោគអេដស៍ មានទំនាក់ទំនងគ្នាកម្រិតណា?

- តើអ្នកផ្ទុកមេរោគអេដស៍មានទស្សនៈ ចំពោះការមាក់ងាយ លើសេវាថែទាំជំងឺអេដស៍ យ៉ាងដូចម្តេច?

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីតម្រូវការពិត និងប្រយោជន៍ដល់អ្នកផ្ទុកមេរោគអេដស៍ ជាពិសេសស្វែងយល់ពីការមាក់ងាយចំពោះពួកគាត់ និងការយល់ឃើញរបស់ពួកគាត់ចំពោះការផ្តល់សេវាថែទាំជំងឺអេដស៍នៅតាមសេវាសុខាភិបាលសាធារណៈ ក្នុងគោលបំណងឱ្យពួកគាត់មកទទួលសេវាថែទាំជំងឺអេដស៍ប្រកបដោយគុណភាព។ គោលបំណងលម្អិតនៃការសិក្សាស្រាវជ្រាវ រួមមាន៖

- វិភាគពីការមាក់ងាយនៃអ្នកផ្ទុកមេរោគអេដស៍
- វិភាគទំនាក់ទំនងរវាងអថេរនៃការមាក់ងាយ របស់អ្នកផ្ទុកមេរោគអេដស៍ដែលមកទទួលសេវាថែទាំជំងឺអេដស៍
- វិភាគទស្សនៈរបស់អ្នកផ្ទុកមេរោគអេដស៍ ចំពោះការមាក់ងាយ លើសេវាថែទាំជំងឺអេដស៍នៃស្ថាប័នសុខាភិបាលសាធារណៈនៅកម្ពុជា។

## ១.៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់លើទិន្នន័យសេវាជំងឺអេដស៍ នៃស្ថាប័នសុខាភិបាលសាធារណៈក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ (២០១២-២០២២) និងផ្តោតតែលើការមាក់ងាយ នៃអ្នកផ្ទុកមេរោគអេដស៍ លើសេវាថែទាំជំងឺអេដស៍នៃស្ថាប័នសុខាភិបាលសាធារណៈនៅកម្ពុជាតែប៉ុណ្ណោះ។

អ្នកផ្តល់ព័ត៌មានជាអ្នកផ្ទុកមេរោគអេដស៍ ត្រូវមានអាយុស្មើ ឬលើសពី ១៨ឆ្នាំ និងមកទទួលសេវាជំងឺអេដស៍ស្មើ ឬលើសពី ១ឆ្នាំ ព្រមទាំងមានសតិស្មារតីធម្មតា និងមានសមត្ថភាពផ្តល់ការយល់ព្រមចូលរួមក្នុងការសិក្សានេះ ព្រមទាំងចេះនិយាយភាសាខ្មែរ ចំនួន ៣៩៥នាក់ នៅក្នុងរាជធានី-ខេត្ត ចំនួន៤ ដូចជា៖ រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យតែប៉ុណ្ណោះ។

ការសិក្សាគ្របដណ្តប់ការអង្កេតលើអ្នកផ្ទុកមេរោគអេដស៍ ដែលទទួលសេវាជំងឺអេដស៍នៅស្ថាប័នសុខាភិបាលសាធារណៈ។ ប៉ុន្តែខកខានក្នុងការស្រង់យកនូវទស្សនៈរបស់អ្នក

ផ្ទុកមេរោគអេដស៍ ដែលមិនបានមកទទួលនូវសេវាថែទាំជំងឺអេដស៍នៅសេវាសុខាភិបាលសាធារណៈ និងអ្នកដែលមកទទួលសេវាជំងឺអេដស៍តិចជាងរយៈពេល ១ឆ្នាំ។

## ១.៥. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរចនាឡើងតាមវិទ្យាសាស្ត្រស្រាវជ្រាវបែបខ្វែង (Cross-sectional Study)[៨ ៩]។ ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងសំណួរនៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រចម្រុះ (Mixed Methodology Research) ត្រូវបានយកមកប្រើប្រាស់[១០] គឺរួមមានវិធីសាស្ត្របរិមាណ (Quantitative method) និងវិធីសាស្ត្រគុណភាព (Qualitative method)[១១]។ សំណាកចំនួន ៣៩៥ ត្រូវបានសាកសួរ (បរិមាណវិស័យ)[១២] និង សំណាក ១៩ ត្រូវបានធ្វើសម្ភាសន៍ពាក់កណ្ដាលគ្រោងទុក ដោយប្រើប្រាស់កម្រងសំណួរតាមប្រធានបទ (បែបគុណវិស័យ) (Semi-structured interview)[១៣]។ នៅក្នុងលក្ខខណ្ឌនៃការប្រមូលទិន្នន័យ ត្រូវបានចាត់ទុកថាជាការស្ទង់មតិ។ ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់នូវវិធីសាស្ត្រមានដូចជា៖ បែបបណ្ណាល័យ (Library research method)[១៤] ប្រើប្រាស់កម្រងសំណួរស្ទង់ដាដូចជាកម្រងសំណួរស្ដីពីការមាក់ងាយ និងរើសអើង (Cambodia Stigma Index ២.០)[១៥] និងប្រើកម្រងសំណួរបើកមានប្រធានបទសម្រាប់សម្ភាសន៍ពាក់កណ្ដាលគ្រោងទុក។

ទិន្នន័យត្រូវបានសម្អាត និងបញ្ចូលទៅក្នុងកម្មវិធី Excel។ ការត្រួតពិនិត្យទ្វេរដង (Double check) ដើម្បីធានាភាពជឿជាក់ និងភាពត្រឹមត្រូវនៃទិន្នន័យនត្រូវបានអនុវត្ត។ កម្មវិធីស្ថិតិ IBM SPSS ២៥[១៦] ត្រូវបានប្រើសម្រាប់វិភាគ និងសាកល្បងសម្មតិកម្មលើទិន្និន័យដែលបានមកពីការសោកសួរ ចំណែកទិន្នន័យដែលបានមកពីការសម្ភាសន៍ ត្រូវបានយកមកវិភាគតាមកម្មវិធីវិភាគ NVivo ១១[១៧]។

លទ្ធផល ត្រូវបានបង្ហាញតាមបែបវិភាគពិពណ៌នា (Descriptive-Analytical)[១៨] ការធ្វើតេស្តសម្មតិកម្ម (Correlational research)[១៩] និងសម្រង់ទស្សនៈ (Quotation)។ ឯកសារគន្ថនិទ្ទេស ត្រូវបានរៀបចំ តាមរយៈការដកស្រង់ឯកសារ (Documentary Citation) និងបញ្ចូលទៅក្នុងកម្មវិធីកំព្យូទ័រសម្រាប់តម្រៀបឯកសារយោង (EndNote X៩)។

ការសិក្សាស្រាវជ្រាវនេះមិនប៉ះពាល់ដល់ ឬរំលោភសិទ្ធិមនុស្សឡើយ។ សំណើប្រើប្រាស់ទិន្នន័យកម្មវិធី ឬទិន្នន័យមិនមានការបោះពុម្ពផ្សាយ ត្រូវបានស្នើសុំទៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) ក្នុងនាមជាម្ចាស់ទិន្នន័យ។

## ២. ទ្រឹស្តីពាក់ព័ន្ធ

**មេរោគអេដស៍** (HIV) ជាមេរោគម្យ៉ាងដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ ដោយវាយប្រហារកោសិកាផ្សេងៗរបស់មនុស្ស ជាពិសេសគោលិកាឈាមស ( CD៤)[២០]។ មេរោគអេដស៍ អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់បានតាមរយៈ បី របៀបសំខាន់ៗ ដូចជា៖ ១) តាមរយៈការរួមភេទ ដោយមិនបានប្រើប្រាស់វិធានការការពារ ២) តាមរយៈការប៉ះពាល់ឈាម ឬសរីរៈរាវរបស់អ្នកផ្ទុកមេរោគអេដស៍ ឬតាមរយៈការចាក់ថ្នាំគ្រឿងញៀន និង៣) ការឆ្លងតាមរយៈពីម្តាយទៅកូន។ មេរោគអេដស៍ត្រូវបានរកឃើញជាលើកដំបូងនៅលើអ្នកជំងឺសួត (Pneumocystis Carnii pneumonia និង Kaposi's Sarcoma) ដែលបង្កឱ្យចំនួនគោលិកាឈាមសធ្លាក់ចុះ បណ្តាលឱ្យភាពស៊ាំនៃសារពាង្គកាយមនុស្សបានចុះខ្សោយជាលំដាប់យ៉ាងឆាប់រហ័ស ព្រមទាំងបង្កឱ្យកើតមាននូវរោគសញ្ញាផ្សេងៗជាច្រើន[២១]។ រហូតដល់ខែមិថុនា ឆ្នាំ១៩៨១ ទើបបានមជ្ឈមណ្ឌលគ្រប់គ្រងជំងឺឆ្លងរបស់សហរដ្ឋអាមេរិក (CDC) និងអង្គការសុខភាពពិភពលោក (WHO) បានកំណត់ឈ្មោះមេរោគនោះជាផ្លូវការថា "**មេរោគអេដស៍**" និងនៅពេលអ្នកផ្ទុកមេរោគអេដស៍បានកើតមាននូវចង្កោមរោគសញ្ញាផ្សេងៗថាជា "**ជំងឺអេដស៍**"។

មេរោគអេដស៍ បានបង្កឱ្យមានបញ្ហាដល់សុខភាព និងអាយុជីវិតរបស់មនុស្សជាច្រើន ជាមួយនឹងផលប៉ះពាល់ដ៏អាក្រក់ដល់សុខភាព និងសុខុមាលភាពសម្រាប់បុគ្គលដែលរងផលប៉ះពាល់ ក៏ដូចជាក្រុមគ្រួសាររបស់ពួកគាត់ និងសង្គមផងដែរ។ ការឆ្លងមេរោគអេដស៍បង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទាំងផ្នែកស្មារតី និងសេដ្ឋកិច្ច[២២]។ អេដស៍បង្កនូវបញ្ហាប្រឈមជាច្រើន និងយ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ព្រមទាំងបានបង្កនូវផលប៉ះពាល់ផ្នែកសុខភាព ស្មារតី និងសេដ្ឋកិច្ចដល់សាមីជនផ្ទុកមេរោគអេដស៍ ក្រុមគ្រួសារ និងសង្គមជាតិ។ តាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រ នៅលើពិភពលោកក្នុងឆ្នាំ២០២១កន្លងទៅនេះ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណជា ៣៨,៤ លាននាក់ អ្នកឆ្លងមេរោគអេដស៍ថ្មីចំនួន

ប្រមាណជា ១,៥លាននាក់ និងស្លាប់ប្រមាណជា ៦៥ ម៉ឺននាក់[១] និងដោយឡែកមានចំនួន ៧៦ ០០០នាក់នៅកម្ពុជា[៥ ៦]។

**ការមាក់ងាយ (Stigma)** ជាបាតុភូតសង្គម ដែលក្រុមណាមួយជាគោលដៅនៃការមាក់ងាយ ប៉ុន្តែបុគ្គលជាអ្នកទទួលរង។ ការមាក់ងាយ គឺជាសំណុំនៃជំនឿបែបអវិជ្ជមាន និងជាញឹកញាប់បង្កឱ្យមានភាពអយុត្តិធម៌ តាមរយៈសង្គម ឬក្រុមមនុស្សមានអំពីអ្វីមួយ[២៣]។ ជាអារម្មណ៍ខ្លាំងក្លាមួយនៅក្នុងសង្គម ដែលស្ថិតក្នុងស្ថានភាពជាក់លាក់មួយ ឬមានជំងឺជាក់លាក់ណាមួយនោះ គឺជាអ្វីដែលបង្កឱ្យមានការខ្មាសអៀន (Longman Dictionary of Contemporary English)។ ជាការបង្ហាញពីការមិនពេញចិត្តពីសង្គម ឬបុគ្គល ហើយអាចនាំឱ្យមានការរើសអើង និងការបដិសេធបុគ្គលដោយអយុត្តិធម៌ (សមាគមជំងឺផ្លូវចិត្តអាមេរិកាំង "American Psychological Association")។ ការមាក់ងាយ មានការទាក់ទងទៅនឹងបញ្ហាជាច្រើន ដូចជា ការងារ អាយុ ភេទ សុខភាព។ល។ ដែលអាចកើតមានឡើងដោយសារតែកង្វះនូវភាពឯកជន និងការរក្សាការសំងាត់ ដែលកន្លែងផ្តល់សេវាថែទាំជំងឺអេដស៍មិនអាចផ្តល់ជូនបាន។ នៅប្រទេសកម្ពុជា ការអង្កេតលើសន្ទស្សន៍នៃការមាក់ងាយត្រូវបានធ្វើឡើងចំនួនពីរលើករួចមកហើយនៅឆ្នាំ២០១០ និងឆ្នាំ២០១៩ ដែលលទ្ធផលនៃការអង្កេតបង្ហាញថានៅតែមានការមាក់ងាយពីខាងក្រៅ និងមាក់ងាយខ្លួនឯងនៅឡើយ[១៥]។ ការមាក់ងាយទាក់ទងនឹងមេរោគអេដស៍ មានប្រភពចំនួន ពីរបែប គឺ**ការមាក់ងាយខ្លួនឯង (Internal stigma)** និង **ការមាក់ងាយពីខាងក្រៅ (External stigma)**។

**ការមាក់ងាយខ្លួនឯង** បង្កឡើងដោយការស្អប់ខ្លួនឯង ដោយមានអារម្មណ៍ថាមានកំហុសធ្ងន់ធ្ងរ ព្រមទាំងមានការខ្មាសអៀនដោយសារមានផ្ទុកមេរោគអេដស៍។ ការមាក់ងាយក៏មានការទាក់ទងផងដែរជាមួយនឹងជំងឺផ្លូវចិត្ត ភាពក្រីក្រ ឬសង្គម ក្នុងការទទួលបាននូវសុខុមាលភាព[២៤]។ ការមាក់ងាយដោយខ្លួនឯង ដោយគិតថាការផ្ទុកមេរោគអេដស៍ជាកំហុសមួយដ៏ធ្ងន់ធ្ងរ[២៥ ២៦]។ បង្កផលជាអវិជ្ជមានដែលបណ្តាលឱ្យមានការខ្មាស់អៀន ភាពគ្មានតម្លៃ និងការស្តីបន្ទោសខ្លួនឯង ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងប្រតិកម្មផ្លូវចិត្ត និងបណ្តាលឱ្យមានភាពតានតឹងផ្លូវចិត្តក្នុងចំណោមមនុស្សជាច្រើនដែលផ្ទុកមេរោគអេដស៍ និងជំងឺរ៉ាំរ៉ៃផ្សេងទៀត។ ការមាក់ងាយខ្លួនឯង បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការសម្រេចចិត្តក្នុងជីវិត

របស់ពួកគេ និងការទទួលបានការថែទាំសុខភាពរបស់ពួកគេ។ ផលប៉ះពាល់ជាអវិជ្ជមាននៃការមាក់ងាយខ្លួនឯង គឺជំងឺធ្លាក់ទឹកចិត្ត។ ការគាំទ្រផ្នែកសង្គម ពីក្រុមគ្រួសារ សហគមន៍ និងអ្នកផ្តល់សេវា តាមរយៈនៃការផ្តល់នូវចំណេះដឹងទាក់ទងនឹងមេរោគអេដស៍និងជំងឺអេដស៍ ការជួយលើកទឹកចិត្ត ការគាំទ្រផ្នែកសង្គម និងការនូវសេវាថែទាំជំងឺអេដស៍ប្រកបដោយគុណភាព នឹងជួយពួកគាត់ក្នុងការកាត់បន្ថយការមាក់ងាយខ្លួនឯង។ ការមាក់ងាយខ្លួនឯងមានដល់ទៅ ៨៨ ភាគរយ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ ដែលក្នុងនោះមាន ៥១ ភាគរយ ជៀសវាងទៅគ្លីនិកក្នុងស្រុកនៅពេលចាំបាច់ ហើយនិង ៤៤ ភាគរយ ជ្រើសរើសមិនចូលរួមក្នុងការជួបជុំសង្គម[២៥]។ គ្រប់ទម្រង់នៃការមាក់ងាយ ជាប្រភពនៃការរើសអើង និងជាឧបសគ្គចម្បងក្នុងការធ្វើសមាហរណកម្ម និងការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ បង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ និងសង្គម ការគោរពខ្លួនឯង និងទំនុកចិត្តលើខ្លួនឯង[២៦] និងមានទំនាក់ទំនងជាមួយនឹងគុណភាពជីវិតដូចជាសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដែលមានឥទ្ធិពលដល់ការយល់ឃើញនៃអ្នកផ្ទុកមេរោគអេដស៍[២៧]។ ជាមូលហេតុឱ្យអ្នកផ្ទុកមេរោគអេដស៍ផ្តាច់ខ្លួនពីគ្រួសារ មិត្តភ័ក្រ និងពីសហគមន៍[២៨]។ មានរោគសញ្ញាថប់បារម្ភ និងធ្លាក់ទឹកចិត្តដោយសារការមាក់ងាយខ្លួន និងមានកាន់តែច្រើន ប្រសិនអ្នកផ្ទុកមេរោគអេដស៍នោះមានកូន។ ពួកគេនឹងមិនទទួលសេវាថែទាំជំងឺអេដស៍ ប្រសិនបើមិនមានការលើកទឹកចិត្ត ឬបន្ថែមការមាក់ងាយពីអ្នកផ្តល់សេវា[២៩] និងជាឧបសគ្គចម្បងដែលរារាំងបុគ្គលម្នាក់ៗពីការស្វែងរកការធ្វើតេស្តមេរោគអេដស៍ និងរបៀបដែលបុគ្គលមានការមាក់ងាយខ្លួនឯងបន្ទាប់ត្រូវបានធ្វើរោគវិនិច្ឆ័យថាផ្ទុកមេរោគអេដស៍ [៣០]។ មានការធ្លាក់ទឹកចិត្ត និងមាក់ងាយខ្លួនឯង កើតមានក្នុងចំណោមបុរសដែលផ្ទុកមេរោគអេដស៍ដែលជាបុរសរួមភេទជាមួយបុរស[៣១] [៣២]។ ការមាក់ងាយខ្លួនឯងក៏ប៉ះពាល់ដល់ធាតុដែលទាក់ទងនឹងអារម្មណ៍ផ្លូវចិត្តផ្ទាល់ខ្លួន[៣៣] ដែលជាកង្វល់ចម្បងដ៏មានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពរបស់ពួកគេ និងសមាជិកគ្រួសាររបស់ពួកគេ បើទោះបីជាមានការអប់រំពីមេរោគអេដស៍និងជំងឺអេដស៍ក្នុងសង្គមក៏ដោយ[៣៤]។ ជាបាតុភូតស្មុគស្មាញ និងពហុវិមាត្រដែលជះឥទ្ធិពលដល់គុណភាពជីវិត និងការទៅទទួលសេវារបស់អ្នកផ្ទុកមេរោគអេដស៍[៣៥]។ ការមាក់ងាយខ្លួនឯង នាំទៅដល់ការបដិសេធមិនចូលក្នុងសង្គម ការជឿជាក់លើខ្លួនឯងទាប និងការពន្យាពេល ឬការបដិសេធសេវាកម្មនៅតាមគ្រឹះស្ថាន

សុខាភិបាល និងទទួលរងទ្វេរដង ប្រសិនបើជាស្ត្រីផ្ទុកមេរោគអេដស៍ និងការប្រើប្រាស់ថ្នាំចាក់[៣៦]។ មានទំនាក់ទំនងជាអវិជ្ជមានរវាងការមាក់ងាយខ្លួនឯង និងការមកទទួលសេវាសុខភាព[៣៧]។ មានការជៀសវាងទៅសេវាជំងឺអេដស៍ ដោយសារខ្លាចការរើសអើងដោយបុគ្គលិក និងការត្រូវបានបដិសេធសេវាសុខភាពដោយសារតែស្ថានភាពមេរោគអេដស៍[២៥]។ ជាពិសេសការមាក់ងាយខ្លួនឯង បង្កឱ្យការទៅទទួលសេវាមានឧបសគ្គ និងផ្ទុយមកវិញការផ្តល់សេវាដោយមិនមានគុណភាព បង្កឱ្យការមាក់ងាយខ្លួនឯងកាន់តែមានទំហំធំ[៣៨]។ ការមាក់ងាយខ្លួនឯង អាចកើតមានលើអ្នកផ្ទុកមេរោគអេដស៍គ្រប់សណ្ឋាន ដូចជាស្ត្រីមានផ្ទៃពោះ និងក្រុមប្រជាជនគន្លឹះ[៣៩]។ ការបង្កើននូវគុណភាពសេវាថែទាំជំងឺអេដស៍ នឹងបង្កើនបាននូវគុណភាពជីវិត ព្រមទាំងជួយកាត់បន្ថយនូវការមាក់ងាយខ្លួនឯង[៤០]។ អ្នកស្រឡាញ់ភេទដូចគ្នាហាក់មាននិន្នាការទទួលការមាក់ងាយនៅគ្រប់ទីកន្លែង រួមទាំងកន្លែងផ្តល់សេវាថែទាំជំងឺអេដស៍ផងដែរ ជាមូលហេតុធ្វើឱ្យពួកគាត់លែងចង់ទៅទទួលសេវា[៤១]។

**ការមាក់ងាយពីខាងក្រៅ** អាកប្បកិរិយាសង្គមអវិជ្ជមានភ្ជាប់ទៅនឹងចរិកលក្ខណៈរបស់បុគ្គលម្នាក់ ដែលអាចចាត់ទុកថាជាកង្វះផ្លូវចិត្ត រាងកាយ ឬសង្គម ក្នុងការទទួលបាននូវសុខុមាលភាព[២៤] ដែលអាចមានប្រភពមកពីក្រុមគ្រួសារ មិត្តភ័ក្រ អ្នកធ្វើការជាមួយ ពីសហគមន៍ ឬអ្នកផ្តល់សេវា ដោយពួកគេមិនត្រូវបានអនុញ្ញាតិឱ្យចូលរួមក្នុងសកម្មភាពសង្គម ឬទទួលការបន្ទោសដោយសារតែស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ឬត្រូវបានបដិសេធមិនទទួលឱ្យធ្វើការងារ។ ការមាក់ងាយពីខាងក្រៅដោយសារអេដស៍ ជះឥទ្ធិពលជាអវិជ្ជមានកើតមាននៅទូទាំងពិភពលោក ជាពិសេសដោយសារភាពក្រីក្រ ប៉ុន្តែនៅតែកើតមានក្នុងចំណោមប្រជាពលរដ្ឋនៅក្នុងប្រទេសជឿនលឿនមួយចំនួន[៤២]។ ការមាក់ងាយដែលកើតមាននៅតាមសេវាជំងឺអេដស៍ នឹងជះឥទ្ធិពលដល់ការមកទទួលសេវាជំងឺអេដស៍របស់អ្នកផ្ទុកមេរោគអេដស៍[៤៣] ដែលអាចបណ្តាលមកពីអ្នកផ្តល់សេវា[៤៤] អ្នកធ្វើការនៅសេវាថែទាំជំងឺ[៤៥] ដោយអ្នកជិតខាងរបស់ខ្លួន និងសហគមន៍[៤៦] ឬដោយពីអ្នកធ្វើការជាមួយគ្នា[៤៧]។ អត្រាទទួលការមាក់ងាយពីខាងក្រៅ មានកម្រិតខ្ពស់[៤៨,៤៩] និងកាន់តែខ្ពស់នៅតំបន់ជនបទ[៤៨] ដូចជាការនិយាយដើមអ្នកផ្ទុកមេរោគអេដស៍ពីសំណាក់អ្នកដទៃ និងបញ្ហាប្រឈមក្នុងការទទួលបានអប់រំនៃអ្នកផ្ទុកមេរោគអេដស៍ ឬកូនរបស់ពួកគាត់[៥០]។ ពួកគេប្រឈមនឹងការមាក់ងាយ

ទាំងនៅក្នុងគ្រួសារ កន្លែងធ្វើការ ក៏ដូចជានៅក្នុងសហគមន៍របស់ពួកគេរស់នៅ[៥១]។ ការមាក់ងាយទាំងពីរបែប ជាពិសេសការមាក់ងាយពីខាងក្រៅគឺជាមូលហេតុសំខាន់មួយ ជាមូលហេតុរាំងមិនពួកគេ មកទទួលសេវាថែទាំជំងឺអេដស៍[៥២]។ អ្នកផ្តល់សេវាមានការរើសអើងចំពោះអ្នកគ្មានទីលំនៅច្បាស់លាស់[៥៣] ចំពោះក្រុមប្រជាជនគន្លឹះ និងសហគមន៍[៥៤] លើអ្នកផ្ទុកមេរោគអេដស៍ របេង[៥៥]។ ការមាក់ងាយទាំងនេះនាំទៅដល់ការបដិសេធ មិនរាប់បញ្ចូលក្នុងសង្គម ការជឿជាក់លើខ្លួនឯងមានកម្រិតទាប និងការពន្យាពេល ឬការបដិសេធសេវាកម្មនានានៅតាមគ្រឹះស្ថានសុខាភិបាល[៣៦]។ ការអន្តរាគមន៍ដែលទាក់ទងនឹងកត្តាខាងលើ គួរត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយការមាក់ងាយបែបនេះ[៥៦]។

**គុណភាពសេវា** អាចជះឥទ្ធិពលផ្ទាល់ទៅលើសមត្ថភាពរបស់ស្ថាប័ន ក្នុងការបំពេញតម្រូវការរបស់អតិថិជន។ គុណភាពសេវាថែទាំជំងឺអេដស៍អាចល្អទៅបាន អាស្រ័យការវាយតម្លៃកម្មវិធីអេដស៍ និងការព្យាបាលមេរោគអេដស៍ប្រកបដោយស្តង់ដារ។ គុណភាពសេវាប្រកបដោយគុណភាព និងតម្លាភាព មានការពឹងផ្អែកលើការយល់ឃើញរបស់អ្នកទទួលសេវានោះចាំបាច់ត្រូវគិតដល់អថេរចំនួន ៥ ដូចជា៖ ១) ភាពជាក់ស្តែង[៥៧] ភាពជឿជាក់[៥៨] ការឆ្លើយតប[៥៩] ការធានារ៉ាប់រង[៦០] និង អាណិតអាសូរនិងការយល់ចិត្ត[៦១]។ កម្មវិធីអេដស៍ប្រកបដោយគុណភាព មានសារៈសំខាន់សម្រាប់ការថែរក្សាសុខភាព ការការពារជំងឺ និងកាត់បន្ថយអត្រាជំងឺ និងការស្លាប់ដោយសារជំងឺ ដែលកត្តាទាំងពីរនេះមានសារៈសំខាន់សម្រាប់ប្រទេសដែលមានស្ថិរភាព។ ការផ្តល់សេវាដែលគុណភាព ក៏ទាក់ទងនឹងទម្រង់កម្មវិធីដែលបានដាក់ឱ្យអនុវត្ត។ បុគ្គលអ្នកផ្ទុកមេរោគអេដស៍ត្រូវបានគេរើសអើងនៅចំណុចណាមួយនៃសេវា នោះការកែសម្រួល និងពង្រឹងក្របខ័ណ្ឌនេះឡើងវិញ ដើម្បីជំរុញគណនីដ៏ទូលំទូលាយនៃផលប៉ះពាល់នៃការមាក់ងាយដោយចាត់ថ្នាក់ការមាក់ងាយ[៦២]។ គុណភាពនៃសេវាកម្មទាក់ទងនឹងការពេញចិត្តរបស់អតិថិជនចំពោះសេវាថែទាំជំងឺអេដស៍ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងភាពអាចរកបាននៃសេវាកម្ម អន្តរកម្មរវាងអ្នកផ្តល់សេវា អ្នកជំងឺ ភាពឯកជនអំឡុងពេលពិនិត្យ ការសម្ងាត់ ស្ថានភាពអប់រំ និងការបង្ហាញពីស្ថានភាពមេរោគអេដស៍ដល់ឪពុកម្តាយ[៦៣]។ ការវាយតម្លៃគុណភាពនៃជីវិត គឺផ្តោតលើធាតុមនុស្សធម៌ ហើយការអន្តរាគមន៍ដែលកើតចេញពីលទ្ធផលនេះ អាចនាំឱ្យសុខុមាលភាពអ្នកជំងឺទូទៅកាន់តែប្រសើរឡើង។

ការរកឃើញទាំងនេះបង្ហាញថា បុគ្គលដែលមានផ្ទុកមេរោគអេដស៍ មានគុណភាពជីវិតអន់ជាងប្រជាជនទូទៅ[៦៤]។ ការព្យាបាលជំងឺអេដស៍ប្រកបដោយស្តង់ដារ និងបំពេញបានផ្នែកខាងតម្រូវការរបស់អ្នកជំងឺ ជាការពិសេសការផ្តល់នូវថ្នាំប្រឆាំងនឹងមេរោគអេដស៍ ជាការផ្តល់សេវាប្រកបដោយការទទួលខុសត្រូវខ្ពស់ និងការរក្សាការសម្ងាត់ [៦៥]។

សេវាជំងឺអេដស៍នៅកម្ពុជា មានដំណើរការនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកស្រុក មន្ទីរពេទ្យបង្អែកខេត្ត មន្ទីរពេទ្យថ្នាក់ជាតិ។ ចំណែកសេវាព្យាបាលថែទាំជំងឺអេដស៍ត្រូវបានដាក់ឱ្យដំណើរការនៅតាមមន្ទីរពេទ្យបង្អែកស្រុក មន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យថ្នាក់ជាតិមួយចំនួន។

# ៣. លទ្ធផល និងការពិភាក្សា

## ៣.១. លទ្ធផលតាមបរិមាណវិស័យ

### ៣.១.១. ប្រជាសាស្ត្រ

ចំណោមអ្នកចូលរួមឆ្លើយតបក្នុងការសិក្សាទាំងអស់ (n= ៣៩៥ ) មានអ្នកចូលរួមឆ្លើយដែលមកទទួលសេវានៅសេវាថែទាំជំងឺអេដស៍ពីរាជធានីភ្នំពេញចំនួន ២៣៦នាក់ ខេត្តកំពង់ចាមចំនួន ៤៦នាក់ ខេត្តបាត់ដំបងចំនួន ៦០នាក់ និងខេត្តបន្ទាយមានជ័យចំនួន ៥៣នាក់ (តារាងទី៣.១)។

តារាងទី៣.១ ៖ ចំនួន និងភាគរយនៃអ្នកចូលរួម តាមក្រុមអាយុ

| ក្រុមអាយុ | សរុប (n= ៣៩៥) | | អ្នកផ្ទុកមេរោគអេដស៍ (n= ៣៩៥) ភ្នំពេញ (n= ២៣៦) | | កំពង់ចាម (n = ៤៦) | | បាត់ដំបង (n = ៦០) | | បន្ទាយមានជ័យ (n = ៥៣) | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| <២៥ | ៦៩ | (១៧,៥) | ៣៨ | (១៦,១) | ៦ | (១៣,០) | ១២ | (២០,០) | ១៣ | (២៤,៥) |
| ២៥-៣៤ | ៨២ | (២០,៨) | ៥១ | (២១,៦) | ១០ | (២១,៧) | ១០ | (១៦,៧) | ១១ | (២០,៨) |
| ៣៥-៤៤ | ១០៩ | (២៧,៦) | ៦២ | (២៦,៣) | ១៣ | (២៨,៣) | ២០ | (៣៣,៣) | ១៤ | (២៦,៤) |
| ៤៥-៥៤ | ៩៨ | (៩,៤) | ៥៩ | (២៥,០) | ១១ | (២៣,៩) | ១៣ | (២១,៧) | ១៥ | (២៨,៣) |
| >៥៤ | ៣៧ | (២១,៥) | ២៦ | (១១,០) | ៦ | (១៣,០) | ៥ | (៨,៣) | ០ | (០,០) |

លទ្ធផលនៃការសិក្សា បានបង្ហាញថាកម្រិតប្រាក់ចំណូលជាមធ្យមនៃអ្នកផ្ទុកមេរោគអេដស៍តិចជាង ឬស្មើ ១៥០ ដុល្លាអាមេរិកក្នុងខែ (US$/month) (មធ្យមភាគ = ១,៧១ ± ០,៧៦៤) និងជិតពាក់កណ្ដាលនៃអ្នកចូលរួម (៤៤,៦ ភាគរយ) មានកម្រិតប្រាក់ចំណូលតិច (≤ ១៥០ US$)។ ចំណែកអ្នកចូលរួមឆ្លើយមានកម្រិតប្រាក់ចំណូលចន្លោះពី ១៥១ US$ ទៅ ៣០០ US$ មាន ៤៣,៨ ភាគរយ និង ៨,១ ភាគរយ នៃអ្នកចូលរួមមានកម្រិតប្រាក់ចំណូលចន្លោះពី ៣០១ US$ ទៅ ៤៥០ US$។ រីឯអ្នកចូលរួមឆ្លើយដែលមានប្រាក់ចំណូលលើសពី ៤៥០ US$ ស្ទើរតែមិនមាន គឺមានតែ ៣,៥ ភាគរយ តែប៉ុណ្ណោះក្នុងអ្នកចូលរួមឆ្លើយតបទាំងអស់ និងសុទ្ធតែអ្នកចូលរួមឆ្លើយមកពីរាជធានីភ្នំពេញ។ (រូបភាពទី៣.១)។

រូបភាពទី៣.១ ៖ ភាគរយ និងចំនួននៃអ្នកផ្ទុកមេរោគអេដស៍ តាមកម្រិតប្រាក់ចំណូល (n= ៣៩៥)




### ៣.១.២. ការមាក់ងាយខ្លួនឯង

តារាងទី៣.១ បង្ហាញថា នៅទូទាំងរាជធានី ខេត្ត ទាំងបួន មាន ៧៧,៩ ភាគរយ នៃអ្នកចូលរួមឆ្លើយតបបានបង្ហាញថា បានបង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនដល់ប្ដី/ប្រពន្ធ ឬកូនរបស់ពួកគេ។ ការបង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនដល់ប្ដី/ប្រពន្ធ ឬកូន ជារឿងធម្មតា ទាំងក្នុងចំណោមស្ត្រីក៏ដូចជាបុរស ក្នុងនោះមាន ៣៥,៩ ភាគរយ នៃអ្នកចូលរួមឆ្លើយបានបង្ហាញថា មិនមានការលំបាកទាល់តែសោះ និង ៤២,០ ភាគរយ មិន

មានការលំបាកប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍។ មានតែ ១១,១ ភាគរយនៃអ្នកចូលរួមឆ្លើយតបប៉ុណ្ណោះ បានឆ្លើយថាមានការលំបាកក្នុងការបង្ហាញស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនដល់ដល់ប្តី/ប្រពន្ធ ឬកូនរបស់ខ្លួន ចំណែកឯ ១១,១ ភាគរយ ទៀតបានឆ្លើយថាមានលំបាកនិងមិនមានដើរទនឹមគ្នា (ធម្មតា) (មធ្យម= ៣,២៣ ± ១,៤៤) (តារាងទី៣.១)។

អ្នកចូលរួមឆ្លើយតបចំនួន ៤៣,៦ ភាគរយ បានបង្ហាញថាពួកគាត់មានអារម្មណ៍ខុសឆ្គងដែលមានផ្ទុកមេរោគអេដស៍ ទល់នឹង ៣៥,៧ ភាគរយ មិនមានអារម្មណ៍ថាខុសឆ្គងទេ។ ក្នុងចំណោមអ្នកចូលរួមឆ្លើយតបដែលមានអារម្មណ៍ខុសឆ្គង មាន ១៥,២ ភាគរយអារម្មណ៍ខុសឆ្គងខ្លាំងបំផុត ២៨,៤ ភាគរយ មានអារម្មណ៍ខុសឆ្គងខ្លាំង និង ២០,៨ ភាគរយមានអារម្មណ៍ធម្មតា។ អ្នកចូលរួមឆ្លើយតបប្រមាណជាជាងពាក់កណ្តាលបានឆ្លើយថា មានការខ្មាសអៀនដោយសារមានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងនោះ ២០,៨ ភាគរយមានការខ្មាសអៀនបំផុតដោយសារមានផ្ទុកមេរោគអេដស៍ ២៩,៩ ភាគរយ ថាមានខ្មាសអៀនដោយសារផ្ទុកមេរោគអេដស៍ និង ១៨,៧ ភាគរយ មានអារម្មណ៍ធម្មតាដែលផ្ទុកមេរោគអេដស៍ (តារាងទី៣.២)។

តារាងទី៣.២ ៖ ភាគរយនៃការមាក់ងាយខ្លួនឯង

| | Internal stigma | | | | | |
|---|---|---|---|---|---|---|
| | Str. Disagree n (%) | Disagree n (%) | Neutral n (%) | Agree n (%) | Strongly Agree n (%) | Mean |
| DiffTell | ១៤២ (៣៥,៩) | ១៦៦(៤២,០) | ៤៣ (១០,៩) | ១៩ (៤,៨) | ២៥ (៦,៣) | ៣,២៣±១,៤៤ |
| FellWrong | ៧៩ (២០) | ៦២ (១៥,៧) | ៨២ (២០,៨) | ១១២ (២៨,៤) | ៦០ (១៥,២) | ៣,០៣±១,៣៦ |
| Shame | ៦៨ (១៧,២) | ៥៣ (១៣,២) | ៧៤ (១៨,៧) | ១១៨ (២៩,៩) | ៨២ (២០,៨) | ៣,២៤±១,៣៨ |
| Hidden | ៧៤ (១៨,៧) | ៤៥ (១១,៤) | ៧០ (១៧,៧) | ៧៦ (១៩,២) | ១៣០(៣២,៩) | ៣,៣៦±១,៥០ |

DiffTell = ប្រាប់អ្នកដទៃថាបានឆ្លងមេរោគអេដស៍

FellWrong = មានអារម្មណ៍ថាស្មោកគ្រោក ឬមានកំហុស

Shame = មានភាពអាម៉ាស់ដែលផ្ទុកមេរោគអេដស៍

Hidden = លាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនពីអ្នកដទៃ

តាមលទ្ធផលនៃការសិក្សាក៏បានបង្ហាញពីអ្នកចូលរួមឆ្លើយតបភាគច្រើន បានលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន មិនឱ្យដឹងដល់អ្នកដទៃក្រៅពីដៃគូ អ្នកធ្វើការជាមួយគ្នា ឬសហគមន៍ (មធ្យម= ៣,៣៦ ± ១,៥០) ដែលក្នុងនោះមានរហូតដល់ទៅ ៥២,១ ភាគរយ បានលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ទល់នឹង ៣០,១ ភាគរយ នៃអ្នកចូលរួមឆ្លើយតបថាមិនបានលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន (តារាងទី៣.២)។

តាមលទ្ធផលនៃការធ្វើតេស្ត គ្រុយស្កល់-វ៉ាលីស អេច (Kruskal-Wallis H test) បង្ហាញថាមានទំនាក់ទំនងសំខាន់រវាងការមាក់ងាយខ្លួនឯង និងទីកន្លែងរស់នៅនៃអ្នកចូលរួម (p< 0,00១) អាយុ (p< 0,0៥) និងកម្រិតប្រាក់ចំណូល (p< 0,0៥) ។ លទ្ធផលក៏បង្ហាញផងដែរថា មិនមានការខុសប្លែកគ្នាទេ នៅក្នុងតម្លៃមធ្យមនៃសន្ទស្សន៍ការមាក់ងាយខ្លួនឯង ទៅតាមភេទ (p> 0,0៥) និងកម្រិតសិក្សា (p> 0,0៥) នៃអ្នកចូលរួមឆ្លើយមកទទួលសេវាថៃទាំជំងឺអេដស៍នៅស្ថាប័នសុខាភិបាលសាធារណៈ (តារាងទី៣.១) (តារាងទី៣.២) និង (តារាងទី ៣.៣)។

តារាងទី៣.៣ ៖ ទំនាក់ទំនងរវាងការមាក់ងាយខ្លួនឯង និងទីកន្លែង

| Location | DiffTell | | FellWrong | | Shame | | Hidden | |
|---|---|---|---|---|---|---|---|---|
| | Mean | P-value | Mean | P-value | Mean | P-value | Mean | P-value |
| PNP | ៣,0៣ (១,៤៩) | | ២,៨១ (១,៤២) | | ៣,0៣ (១,៤៥) | | ៣,២១ (១,៥៩) | |
| KCM | ៤,0៩ (១,0៣) | | ៣,៧៨ (១,១១) | | ៣,៩៦ (១,0៧) | | ៤,២ (0,៩៨) | |
| BTB | ២,៨៧ (១,៤៩)* | <0,00១ | ២,៦៥ (១,៣១)* | <0,00១ | ២,៩ (១,៤២) | <0,00១ | ២,៧២ (១,៤២) | <0,00១ |
| BMC | ៣,៧៧ (0,៨៩) | | ៣,៨១ (0,៥៩) | | ៣,៩១ (0,៥៦) | | ៤,0៤ (0,៩0) | |
| Total | ៣,២៣ (១,៤៤) | | ៣,0៣ (១,៣៦) | | ក,២៤ (១,៣៨) | | ៣,៣៦ (១,៥0) | |

PNP = ភ្នំពេញ KCM = កំពង់ចាម BTB = បាត់ដំបង BMC = បន្ទាយមានជ័យ

តារាងទី៣.៤ ៖ ទំនាក់ទំនងរវាងការមាក់ងាយខ្លួនឯង និងអាយុ

| Age | DiffTell | | FellWrong | | Shame | | Hidden | |
|---|---|---|---|---|---|---|---|---|
| | Mean | P-value | Mean | P-value | Mean | P-value | Mean | P-value |
| <២៥ | ៣,៥៧ (១,៣៨) | | ៣,៣២ (១,៣៧) | | ៣,៥៩ (១,២៦) | | ៣,៩៣ (១,៤៣) | |
| ២៥-៣៤ | ៣,២២ (១,៤៣) | | ៣,១ (១,៤២) | | ៣,១៧ (១,៤៦) | | ៣,២៧ (១,៥៤) | |
| ៣៥-៤៤ | ៣,៣១ (១,៣២) | ០,០១៣ | ២,៩៥ (១,៣០) | ០,០៤៥ | ៣,១១ (១,៣២) | ០,០២៨ | ៣,៣១ (១,៣៧) | ០,០០៣ |
| ៤៥-៥៤ | ២,៨៣ (១,៤៧) | | ២,៧៤ (១,៣៣) | | ៣,០៣ (១,៤០) | | ៣,០២ (១,៥០) | |
| >៥៤ | ៣,៤៣ (១,៦១) | | ៣,៣២ (១,៣៨) | | ៣,៦២ (១,៤២) | | ៣,៥៧ (១,៦៦) | |
| Total | ៣,២៣ (១,៤៤) | | ៣,០៣ (១,៣៦) | | ៣,២៤ (១,៣៨) | | ៣,៣៦ (១,៥០) | |

តារាងទី៣.៥ ៖ ទំនាក់ទំនងរវាងការមាក់ងាយខ្លួនឯង និងប្រាក់ចំណូល

| Income | DiffTell | | FellWrong | | Shame | | Hidden | |
|---|---|---|---|---|---|---|---|---|
| | Mean | P-value | Mean | P-value | Mean | P-value | Mean | P-value |
| ≤ ១៥០$ | ៣,២៦ (១,៣១) | | ៣,០៥ (១,៣៤) | | ៣,៣ (១,២៩) | | ៣,៥២ (១,៣៤) | |
| ១៥១$ - ៣០០$ | ៣,០៦ (១,៥៤) | | ២,៩ (១,៣៩) | | ៣,១២ (១,៤៥) | | ៣,០៨ (១,៥៧) | |
| ៣០១$ - ៤៥០$ | ៣,៩១ (១,១៧) | ០,០២២ | ៣,៦៦ (១,១០) | ០,០៣៦ | ៣,៦៣ (១,២៩) | ០,២២២ | ៤,១៩ (១,៣៦) | *< ០,០០១ |
| > ៤៥០$ | ៣,៣៦ (១,៦៩) | | ៣ (១,៥៧) | | ៣,០៧ (១,៧៣) | | ៣,០៧ (១,៥០) | |
| Total | ៣,២៣ (១,៤៤) | | ៣,០៣ (១,៣៦) | | ៣,២៤ (១,៣៨) | | ៣,៣៦ (១,៥០) | |

### ៣.១.៣. ការមាក់ងាយពីខាងក្រៅ

តាមលទ្ធផលនេះ (តារាងទី ៣.៣) មានបង្ហាញ អ្នកចូលរួមឆ្លើយភាគច្រើនមិនធ្លាប់មានបទពិសោធន៍ដែលត្រូវបានគេផាត់ចេញពីពិធីជួបជុំឬសកម្មភាពក្នុងសង្គម (ឧទាហរណ៍, អាពាហ៍ពិពាហ៍ បុណ្យសព គណបក្ស ក្លឹប ឬសាសនា) ដោយសារតែស្ថានភាពមានផ្ទុកមេរោគអេដស៍ទេ ក្នុងនោះ ៥០,១ ភាគរយ មិនធ្លាប់ជួបទាល់តែសោះ និង ៣០,៤ ភាគរយ មិនធ្លាប់ជួបបទពិសោធន៍នេះ។ មានតែ ៤,៣ ភាគរយ យល់ស្របខ្លាំង និង៤,៦ ភាគរយ យល់ស្របថាធ្លាប់ត្រូវបណ្តេញចេញពីកម្មវិធី ឬការជួបជុំ ឬសកម្មភាពក្នុងសង្គម ដោយសារតែស្ថានភាពមេរោគអេដស៍។

អ្នកចូលរួមឆ្លើយតបចំនួន ៧០,២ ភាគរយ បានបង្ហាញថាគាត់មិនដែលធ្លាប់បានមនុស្សផ្សេងទៀត និយាយរើសអើង ឬនិយាយដើមអ្នក ដោយសារតែស្ថានភាពផ្ទុកមេរោគ

អេដស៍របស់ខ្លួនទេ ទល់នឹង ១៦,៦ ភាគរយ ដែលធ្លាប់ទទួលរងនូវការនិយាយមាក់ងាយពីអ្នកដទៃដោយសារតែមានផ្ទុកមេរោគអេដស៍។ ក្នុងចំណោមអ្នកចូលរួមឆ្លើយតបដែលមិនធ្លាប់ទទួលរងនូវបទពិសោធន៍នេះ មាន ៣៣,៧ ភាគរយ ឆ្លើយថាមិនធ្លាប់រងទាល់តែសោះនូវការនិយាយមាក់ងាយពីអ្នកដទៃដោយសារមានផ្ទុកមេរោគអេដស៍ និង ៣៦,៥ ភាគរយថាមិនធ្លាប់ទទួលរងបទពិសោធន៍នេះទេ។ ចំណែក ១៣,៤ ភាគរយ ធ្លាប់ខ្លះនិងមិនធ្លាប់ខ្លះរងនូវបទពិសោធន៍ ដែលអ្នកធ្លាប់ត្រូវបានមនុស្សផ្សេងទៀត និយាយរើសអើង ឬនិយាយដើមអ្នក ដោយសារតែផ្ទុកមេរោគអេដស៍ (តារាងទី ៤-១២)។

អ្នកចូលរួមឆ្លើយ ៧៧,៩ ភាគរយ បង្ហាញថាពួកគេ មិនធ្លាប់មាននរណាម្នាក់ធ្លាប់បៀតបៀនជាពាក្យសំដី (ឧទា, ស្រែកដាក់ ស្តីបន្ទោស ឬបំពានជាពាក្យសំដីផ្សេងទៀត) ដោយសារតែស្ថានភាពមេរោគអេដស៍ (មធ្យម= ២,០៤ ± ១,១១) ក្នុងនោះមាន ៣៥,៩ ភាគរយ មិនធ្លាប់ទទួលរងទាល់តែសោះ និង ៤២,0 ភាគរយ ថាមិនធ្លាប់ទទួលទេ។ ចំណែក ១០,៩ ភាគរយ ឆ្លើយថា ធ្លាប់ខ្លះនិងមិនធ្លាប់ខ្លះថាមានអ្នកបៀតបៀនជាពាក្យសំដីដោយសារមានផ្ទុកមេរោគអេដស៍។

ចំណែកឯអ្នកចូលរួមឆ្លើយ ៨០,២ ភាគរយ បានបង្ហាញថា គាត់មិនដែលធ្លាប់ត្រូវបានគេបដិសេធមិនយកធ្វើការ ឬបាត់បង់ប្រភពប្រាក់ចំណូល ឬការងារ ដោយសារតែមានផ្ទុកមេរោគអេដស៍ទេ (មធ្យម= ១,៩៣ ± ១,១៥) ដែលក្នុងនោះមាន ៤៤,៦ ភាគរយ ឆ្លើយថាមិនដែលធ្លាប់ទាល់តែសោះ និង ៣៦, ២ ភាគរយ ថាមិនធ្លាប់ត្រូវគេបដិសេធមិនយកធ្វើការ ឬបាត់បង់ប្រភពប្រាក់ចំណូល ឬការងារ ដោយសារតែស្ថានភាពផ្ទុកមេរោគអេដស៍។ ចំណែកអ្នកចូលរួមឆ្លើយ ៧,១ ភាគរយ ទៀតបានឆ្លើយថា ធ្លាប់ផងនិងមិនធ្លាប់ផង (ធម្មតា) ដែលត្រូវគេបដិសេធមិនទទួលឱ្យធ្វើការ ឬបាត់បង់ការងារ ដោយសារមានផ្ទុកមេរោគអេដស៍ (តារាងទី ៤-១២)។

តារាងទី៣.៥ ៖ ភាគរយនៃការមាក់ងាយពីខាងក្រៅ

| External stigma | Strongly Disagree n (%) | Disagree n (%) | Neutral n (%) | Agree n (%) | Strongly Agree n (%) | Mean |
|---|---|---|---|---|---|---|
| TakeOut | ១៩៨ (៥០,១) | ១២០ (៣០,៤) | ៤២ (១០,៦) | ១៨ (៤,៦) | ១៧ (៤,៣) | ៣,២៣±១,៤៤ |
| TalkStig | ១៣៣ (៣៣,៧) | ១៤៤ (៣៦,៥) | ៥៣ (១៣,៤) | ៣៣ (៨,៤) | ៣២ (៨,១) | ២,២១±១,២២ |
| Critic | ១៤២ (៣៥,៩) | ១៦៦ (៤២,០) | ៤៣ (១០,៩) | ១៩ (៤,៨) | ២៥ (៦,៣) | ២,០៤±១,១១ |
| NotAllow | ១៧៦ (៤៤,៦) | ១៤៣ (៣៦,២) | ២៨ (៧,១) | ២៣ (៥,៨) | ២៥ (៦,៣) | ១,៩៣±១,១៥ |

TakeOut = ធ្លាប់ត្រូវបានគេផាត់ចេញពីពិធីជួបជុំឬសកម្មភាពក្នុងសង្គម

TalkStig = ធ្លាប់បានមនុស្សផ្សេងទៀត និយាយរើសអើង ឬនិយាយដើមអ្នក

Critic = មាននរណាម្នាក់ធ្លាប់បៀតបៀនអ្នកជាពាក្យសំដី

NotAllow = ធ្លាប់ត្រូវបានគេបដិសេធមិនយកធ្វើការ ឬបាត់បង់ប្រភពប្រាក់ចំណូល ឬការងារ

តារាងទី៣.៦ ៖ ទំនាក់ទំនងរវាងការមាក់ងាយពីខាងក្រៅ និងអាយុ

| Age Group | TakeOut Mean | TakeOut P-value | TalkStig Mean | TalkStig P-value | Critic Mean | Critic P-value | NotAllow Mean | NotAllow P-value |
|---|---|---|---|---|---|---|---|---|
| <២៥ | ១,៨ (០,៩៦) | ០,១២៥ | ២,២៩ (១,១៦) | ០,០៤៨ | ២,២ (១,០៩) | ០,០៥៤ | ១,៩៣ (១,១២) | ០,២៥៦ |
| ២៥-៣៤ | ១,៨៥ (១,២០) | | ២,១៧ (១,២១) | | ២,០៤ (១,១៣) | | ១,៨ (១,១១) | |
| ៣៥-៤៤ | ១,៨៨ (០,៩៧) | | ២,១ (១,១៣) | | ១,៩៤ (១,០០) | | ១,៨៦ (០,៩៩) | |
| ៤៥-៥៤ | ១,៦៣ (១,០០) | | ២,០៩ (១,២៤) | | ១,៨៧ (១,០១) | | ១,៩៨ (១,២៤) | |
| >៥៤ | ២,១៦ (១,៥៧) | | ២,៧៦ (១,៤៨) | | ២,៤៣ (១,៥២) | | ២,៣ (១,៤៥) | |
| Total | ១,៨៣ (១,០៧) | | ២,២១ (១,២២) | | ២,០៤ (១,១១) | | ១,៩៣ (១,១៥) | |

ការធ្វើតេស្ត គ្រុយស្គល់-វ៉ាលីស អេច (Kruskal-Wallis H test) បង្ហាញថា មិនមានការខុសប្លែកគ្នាទេនៃសន្ទស្សន៍តម្លៃមធ្យមការមាក់ងាយពីខាងក្រៅ (p> ០,០៥) ។ ដូចនេះ ការទទួលរងនូវការមាក់ងាយពីខាងក្រៅ មិនមានទំនាក់ទំនងជាពិសេសណាមួយពីភេទ អាយុ កម្រិតនៃការសិក្សា និងកម្រិតនៃប្រាក់ចំណូលទេ លើកលែងតែការធ្លាប់បានគេ

និយាយរើសអើង ឬនិយាយដើមអ្នក ដោយសារមានផ្ទុកមេរោគអេដស៍របស់ខ្លួន ដែលមានទំនាក់ទំនងជាមួយនឹងអាយុ (p= ០,០៤៨) (តារាងទី ៤-១ )។

## ៣.២. លទ្ធផលនៃការសម្ភាសន៍លើការមាក់ងាយ

### ៣.២.១. លទ្ធផលការមាក់ងាយខ្លួនឯង

ជាលទ្ធផលបង្ហាញថា ការមាក់ងាយខ្លួនឯងមានកម្រិតខ្ពស់តាមរយៈការលាក់លៀមពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ការលាក់មុខក្នុងការទទួលសេវាដែលនៅក្នុងស្រុកភូមិរបស់គាត់ជាដើម។ អ្នកផ្ទុកមេរោគអេដស៍ នៅតែមានការមិនពេញចិត្ត និងមាក់ងាយខ្លួនឯង។ កម្រិតការមាក់ងាយខ្លួនឯង កាន់តែមានកម្រិតខ្ពស់បើសិនអ្នកផ្ទុកមេរោគអេដស៍ទាំងនោះ ជាក្រុមប្រជាជនគន្លឹះ (ដូចជា៖ ក្រុមបុរសរួមភេទបុរស ក្រុមបំប្លែងភេទ ក្រុមស្ត្រីបម្រើសេវាកម្សាន្ត និងអ្នកប្រើប្រាស់ ឬចាក់គ្រឿងញៀន)។ ការមាក់ងាយខ្លួនឯង ជាកត្តាគួរព្រួយបារម្ភក្នុងការមកទទួលសេវាថែទាំជំងឺអេដស៍របស់អ្នកផ្ទុកមេរោគអេដស៍។ ភាគច្រើនអ្នកមិនមកតាមការណាត់របស់គ្រូពេទ្យ បាត់មុខ និងស្លាប់ គឺអ្នកដែលមាក់ងាយនិងរើសអើងខ្លួនឯងហើយមិនហ៊ានបញ្ចេញអត្តសញ្ញាណរបស់ខ្លួន។ លោកស្រីម្នាក់ បានមានមតិថា " *... ហឹម... ពេលដឹងថាផ្ទុកមេរោគអេដស៍ដំបូង ខ្ញុំមិនហ៊ានចេញពីផ្ទះទេ ហើយក៏មិនចង់ទៅជួបពេទ្យដែរ។ មិនដឹងប្រាប់នរណា... តូចចិត្តណាស់។ ណាមួយភ័យខ្លាចសង្គមគេរើសអើងស្អប់ខ្ពើម ណាមួយខ្លាចស្លាប់ ពេលខ្លះគាត់គិតខ្លីចង់សំលាប់ខ្លួន ... គិតថាអនាគតដូចមិនបានវែងឆ្ងាយដូចគេ ...*"។

អ្នកផ្ទុកមេរោគអេដស៍ មានកម្រិតមាក់ងាយខ្លួនឯងកម្រិតខ្ពស់ ដោយបន្ទោសខ្លួនឯងដែលបានឆ្លងមេរោគអេដស៍។ ការមាក់ងាយខ្លួនឯងនេះបានធ្វើអោយមានភាពខ្លាចអោរ ក្នុងការទៅទទួលសេវាថែទាំជំងឺអេដស៍ ដោយសារតែខ្លាចអ្នកផ្តល់សេវារើសអើងចំពោះគាត់ និងបារម្ភអ្នកនៅជុំវិញខ្លួនដឹងពីស្ថានភាពមេរោគអេដស៍។ លោកម្នាក់ បានមានមតិថា៖ "*... ខ្ញុំស្អប់ខ្លួនឯង ដែលឆ្លងអេដស៍ ... មិនចង់ទៅទទួលមន្ទីរពេទ្យទេ ខ្លាចគេស្គាល់ ខ្លាចគេរើសអើងថាខ្ញុំស្រឡាញ់ភេទដូចគ្នា។ ... មិនចង់ទៅបើកថ្នាំនៅកន្លែងបើកថ្នាំរួមរបស់មន្ទីពេទ្យទេ ខ្លាចអ្នកជម្ងឺទូទៅដឹងថាបើកថ្នាំអេដស៍* "។

### ៣.២.២. លទ្ធផលការមាក់ងាយពីខាងក្រៅ

តាមលទ្ធផលនៃការសិក្សានេះ បានបង្ហាញថា ការមាក់ងាយពីខាងក្រៅទាក់ទងមេរោគអេដស៍មានការថយចុះ។ ជាទូទៅអ្នកផ្ទុកមេរោគអេដស៍ ត្រូវបានទទួលការគាំពារពីសង្គមកាន់តែច្រើនឡើងៗ។ ការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ជាប់លាប់ នាំឱ្យអ្នកផ្ទុកមេរោគអេដស៍មានសុខភាពល្អ។ ពួកគាត់អាចប្រកបរបរចិញ្ចឹមជីវិត បម្រើការងារ ជាមន្ត្រីរាជការ ឬឯកជនបានធម្មតា។ លោកស្រីម្នាក់បានមានមតិថា៖ *"ការមាក់ងាយ និងរើសអើងពីអ្នកដ៏ទៃចំពោះពួកខ្ញុំ (អ្នកផ្ទុកមេរោគអេដស៍) នាពេលបច្ចុប្បន្នមានភាពល្អប្រសើរច្រើនហើយ មានន័យថាមិនសូវមានការមាក់ងាយទេ ផ្ទុយទៅវិញប្រជាជនមានការអាណិតអាសូរ និងយោគយល់ច្រើនជាងមុន។ ... ជំងឺអេដស៍សឹងតែក្លាយជាបញ្ហាសាមញ្ញរបស់សហគមន៍ទៅហើយ ដោយមើលឃើញពួកខ្ញុំមានសុខភាពល្អដូចគេដូចឯង និងរស់នៅដូចប្រជាជនដ៏ទៃដែរ ..."*។ ចំណែកលោកម្នាក់ទៀត មានក៏មតិផងដែរថា៖ *"ការមាក់ងាយក្នុងសង្គមកាត់បន្ថយច្រើនហើយ មានតែនៅតាមខេត្តខ្លះៗទេ។ ខ្ញុំគិតថា នៅសល់ប្រហែលជា ២០ ភាគរយ នៅតំបន់ជនបទ។ ... គ្រប់សេវាជំងឺអេដស៍ បានគាំទ្រ និងលើកកំពស់ដល់អ្នកផ្ទុកមេរោគអេដស៍ក្នុងសង្គមដូចជា៖ សុខាភិបាល វិស័យអប់រំ គាំពារសង្គម សាសនា "*។

ការមាក់ងាយពីខាងក្រៅត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ដោយសារមានការអប់រំការផ្សព្វផ្សាយការណែនាំពីចំណេះដឹងទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងវិធានការបង្ការ ពីមន្ត្រីជំនាញ អាជ្ញាធរ និងអ្នកផ្ទុកមេរោគអេដស៍ខ្លួនឯង។ ប៉ុន្តែក៏នៅមានការមាក់ងាយ និងរើសអើងមួយចំនួននៅឡើយ ដូចជាក៏ផ្តល់មតិពីលោកម្នាក់ថា៖ *"ការមាក់ងាយក្នុងសង្គម ជាទូទៅមានការកាត់បន្ថយច្រើនណាស់ តែបញ្ហាប្រឈមសម្រាប់អ្នកផ្ទុកមេរោគអេដស៍គឺនៅតែមាននៅឡើយ ដូចជាបង្ខំឲ្យធ្វើតេស្តឈាមពេលដាក់ពាក្យចូលធ្វើការតាមបណ្តាស្ថាប័នមួយចំនួន ... ទាំងនេះក៏បង្ហាញពីការរើសអើងផងដែរ"*។

## ៣.៣. ពិភាក្សា

### ៣.៣.១. ការមាក់ងាយខ្លួនឯង

កម្រិតនៃការមាក់ងាយផ្ទៃក្នុង ត្រូវបានគេសង្កេតឃើញនៅកម្រិតខ្ពស់នៅក្នុងការស្ទង់មតិនាពេលបច្ចុប្បន្ន ដោយក្នុងនោះ ៤៣,៦ ភាគរយ បានបង្ហាញថាពួកគាត់មាន

អារម្មណ៍ខុសឆ្គង។ អ្នកចូលរួមឆ្លើយប្រមាណជាជាងពាក់កណ្តាលបានឆ្លើយថា មានការខ្មាសអៀនដោយសារមានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងនោះ ៥០,៧ ភាគរយ មានការខ្មាសអៀនបំផុតដោយសារមានផ្ទុកមេរោគអេដស៍។ តាមរយៈការសម្ភាសន៍ស្រង់ទស្សនៈអ្នកផ្ទុកមេរោគអេដស៍បានគាំទ្រថា មានការមាក់ងាយខ្លួនឯង ក៏ដូចការមាក់ងាយផ្ទៃក្នុងនៅក្នុងសហគមន៍របស់ពួកគេ។ ការថយចុះនៃសកម្មភាពអប់រំអំពីមេរោគអេដស៍នៅតាមសហគមន៍ក្រុមជួយខ្លួនឯង ឬក្រុមគាំទ្រពីមិត្តភ័ក្តិ ត្រូវបានកត់សម្គាល់ថា ជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ចាប់តាំងពីវាបានផ្តាច់ចេញអ្នកផ្ទុកមេរោគអេដស៍ពីសហគមន៍ និងជំនួយសង្គម និងអប់រំផ្លូវចិត្តដែលពួកគាត់ត្រូវការ និងលើកទឹកចិត្តក្នុងជីវិត។ ការរកឃើញនេះ ដូចទៅការរកឃើញក្នុងការសិក្សានៅប្រទេសម៉ារ៉ុក ក្នុងឆ្នាំ២០១៦ផងដែរ[២៥] ដែលបានបង្ហាញជាងបីភាគបួននៃអ្នកផ្ទុកមេរោគអេដស៍មានការមាក់ងាយខ្លួនឯង និងជិតពាក់កណ្តាលមិនហ៊ានចូលរួមក្នុងការជួបជុំសង្គមទេ។

ជាងនេះទៅទៀត លទ្ធផលនៃការស្ទង់មតិ និងការសម្ភាសន៍ បានបង្ហាញថា ជារឿងធម្មតាក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ដែលមិនបានដឹងខ្លួនថា បន្ទុកមេរោគដែលមិនអាចរកឃើញក៏មានន័យថាពួកគេមិនអាចចម្លងមេរោគអេដស៍បានដែរ។ ការខ្វះការយល់ដឹងនេះហាក់ដូចជារួមចំណែកដល់កម្រិតខ្ពស់នៃការមាក់ងាយខ្លួនឯង ដោយសារលទ្ធផលស្ទង់មតិបានបង្ហាញពីសមាមាត្រខ្ពស់នៃអ្នកផ្ទុកមេរោគអេដស៍ ដោយកត់សម្គាល់ថាពួកគេ "មានអារម្មណ៍ថាពួកគេកខ្វក់" ឬរាយការណ៍អំពីកម្រិតនៃកំហុសខ្ពស់ (៤៣,៦ ភាគរយ)។ ដោយសារការអប់រំ និងផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ ដូចជាមិនទាន់បានទូលំ-ទូលាយបង្កឱ្យអ្នកផ្ទុកមេរោគអេដស៍ មិនចង់បង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនឱ្យអ្នកដទៃដឹង។ មានកម្រិតសមាមាត្រខ្ពស់ នៃលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន (៥២,១ ភាគរយ បានលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ទល់នឹង ៣០,១ ភាគរយមិនលាក់)។ ករណីនេះ មិនខុសពីការរកឃើញក្នុងការសិក្សាមួយចំនួននៅប្រទេសកំពុងអភិវឌ្ឍនានា ដែលអ្នកផ្ទុកមេរោគអេដស៍មិនប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ក៏ដោយសារចំណេះដឹង ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅតាមសហគមន៍នៅមានកម្រិត។

លទ្ធផលនៃការវិភាគចម្រុះរវាងអថេរនៃការមាក់ងាយផ្ទៃក្នុង និងកត្តាប្រជាសាស្ត្រសង្គម បង្ហាញថាសមត្ថភាពបំពេញតម្រូវការផ្សេងៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងទីកន្លែង អាយុ និងកម្រិតប្រាក់ចំណូលនៃអ្នកផ្ទុកមេរោគអេដស៍។ កម្រិតនៃការមាក់ងាយខ្លួនឯង គឺមានភាពខុសប្លែកគ្នា ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ដែលមានប្រវត្តិខុសៗគ្នាទាក់ទងនឹងកម្រិតប្រាក់ចំណូល ដោយអ្នកមានប្រាក់ចំណូលកាន់តែច្រើន មានការលាក់ពីស្ថានភាពមេរោគអេដស៍និងមានអារម្មណ៍ថាមានកំហុសកាន់តែខ្ពស់។ លទ្ធផលនេះ ហាក់ដូចជាមិនស្របទៅនឹងលទ្ធផលការសិក្សារបស់លោក យ៉ាង ក្នុងឆ្នាំ២០១៧[៩០] ដែលបានបង្ហាញផងដែរថា ការបង្កើនគុណភាពជីវិតនៃអ្នកមេរោគអេដស៍ ជួយកាត់បន្ថយការមាក់ងាយខ្លួនឯង។

អាយុនៃអ្នកផ្ទុកមេរោគអេដស៍ មានទំនាក់ទំនងស្និទ្ធស្នាលជាមួយនឹងការមាក់ងាយ យល់ឃើញពីភាពងាយស្រួលក្នុងការបង្ហាញពីស្ថានភាពមេរោគអេដស៍ ចំណេះដឹងអំពីច្បាប់ជំងឺអេដស៍ និងបទពិសោធន៍ដែលទទួលបាន។ មានអាយុតិចបំផុត និងច្រើនបំផុត មានអារម្មណ៍ងាយស្រួលក្នុងការបង្ហាញពីស្ថានភាពមេរោគអេដស៍របស់ពួកគេ ដល់ដៃគូ ជាងអ្នកមានអាយុវ័យកណ្តាល។ លទ្ធផលនេះ ហាក់ស្របទៅនឹងការសិក្សាមួយចំនួននៅប្រទេសអាស៊ី បង្ហាញថា អ្នកផ្ទុកមេរោគអេដស៍ដែលមានតែអាយុកាន់តែច្រើន ងាយនឹងបង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៍ដល់ក្រុមគ្រួសារ ច្រើនជាងអ្នកមានវ័យកណ្តាល។

លទ្ធផលក៏បង្ហាញថា អត្រាខ្ពស់នៃការមាក់ងាយខ្លួនឯងក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ គឺជាបញ្ហាស្មុគស្មាញដែលអាស្រ័យលើកត្តាប្រជាសាស្ត្រសង្គមជាច្រើន។ ការបង្កើតកម្មវិធី និងគោលនយោបាយដែលអាចកាត់បន្ថយការមាក់ងាយខ្លួនឯង ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍បានយ៉ាងមានប្រសិទ្ធភាព បញ្ហាទាំងនេះជានាឱ្យមានការស៊ើបអង្កេតយ៉ាងម៉ត់ចត់បន្ថែមទៀតដោយប្រើការវិភាគចម្រុះ ដែលអនុញ្ញាតឱ្យពិនិត្យមើលសមាសភាគដាក់លាក់ ខណៈពេលដែលមានការគ្រប់គ្រងចំពោះផលប៉ះពាល់ដែលគួរឱ្យសង្ស័យ។

**៣.៣.២. ការមាក់ងាយពីខាងក្រៅ**

កម្រិតនៃការរើសអើងពីខាងក្រៅ ដែលបានសង្កេតឃើញនៅក្នុងការស្ទង់មតិបច្ចុប្បន្ន បង្ហាញថា ការរើសអើងខាងក្រៅដែលជួបប្រទះដោយសហគមន៍អ្នកផ្ទុកមេរោគអេដស៍នៅក្នុងរាជធានី ខេត្តទាំងបួន មានកម្រិតទាប។ អ្នកផ្ទុកមេរោគអេដស៍ ប្រមាណជាជាង ៨០

ភាគរយ មិនដែលធ្លាប់ទទួលរងនូវការមាក់ងាយពីខាងក្រៅនោះទេ។ ការសង្កេតនេះហាក់ដូចជាមិនធម្មតានោះទេ ព្រោះលទ្ធផលស្រដៀងគ្នា និងមានភ័ស្តុតាងចេញពីប្រទេសផ្សេងៗ (ឧទាហរណ៍ សន្ទស្សន៍ការរើសអើងអ្នកផ្ទុកមេរោគអេដស៍ ២,០ នៅសាធារណរដ្ឋដូមីនីកែន)។ ទោះបីជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងរកឃើញថាការរើសអើងពីខាងក្រៅទាប តែតាមការសិក្សានេះបានបង្ហាញថា ការបង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៍នៅមានអត្រាទាប ជាពិសេសចំពោះសមាជិកដែលមិនមែនជាគ្រួសារ។ ការរកឃើញទាំងនេះបាននាំឱ្យមានការព្រួយបារម្ភថា តើអត្រាប្រេវ៉ាឡង់ទាបនៃការរើសអើងពីខាងក្រៅដែលត្រូវបានរាយការណ៍ អាចត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្រាបង្ហាញទាបនៃស្ថានភាពមេរោគអេដស៍ ជាជាងភស្តុតាងនៃការផ្លាស់ប្តូរការមាក់ងាយជាសាធារណៈចំពោះអ្នកផ្ទុកមេរោគអេដស៍ ដែរឬទេ។

ការពិភាក្សាផ្សេងៗនៅក្នុងសិក្ខាសាលាបកស្រាយតាមរាជធានី ខេត្តទាំងបួន និងការស្រង់យកទស្សនៈនៃអ្នកផ្ទុកមេរោគអេដស៍បានលើកឡើងថា ការព្រួយបារម្ភនេះជានាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត។ អត្រានៃការបញ្ចេញព័ត៌មានទាបអាចជាការឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរបរិយាកាសគាំទ្រចំពោះអ្នកផ្ទុកមេរោគអេដស៍។ កាលពីមុន សហគមន៍អ្នកផ្ទុកមេរោគអេដស៍អាចឃើញពីតម្រូវការខ្លាំងជាងមុន ក្នុងការបង្ហាញពីស្ថានភាពមេរោគអេដស៍របស់ពួកគេ ដើម្បីមានសិទ្ធិទទួលបានគម្រោងផ្សេងៗនៃការគាំទ្រសង្គម។ ទោះជាយ៉ាងណាក៏ដោយ ឥឡូវនេះអ្នកផ្ទុកមេរោគអេដស៍ទទួលបានការគាំទ្រផ្នែកសង្គមតិចជាងមុន ប៉ុន្តែមានការគាំទ្រផ្នែកព្យាបាលកាន់តែច្រើននៅសេវាថែទាំជំងឺអេដស៍កាន់តែច្រើន ដោយកាត់បន្ថយតម្រូវការរបស់ពួកគេ ក្នុងការបង្ហាញពីស្ថានភាពមេរោគអេដស៍របស់ពួកគេទៅកាន់មនុស្សក្នុងវិស័យផ្សេងទៀតនៃជីវិត។ ទោះបីជាការរកឃើញលើការកាត់បន្ថយការរើសអើងពីខាងក្រៅនៅក្នុងខេត្ត ដែលស្ទង់មតិត្រូវបានគាំទ្រយ៉ាងខ្លាំងនៅក្នុងសិក្ខាសាលាបកស្រាយក៏ដោយ ក៏មានការជឿជាក់យ៉ាងខ្លាំងទៅលើអត្ថិភាពនៃការមាក់ងាយពីខាងក្រៅ ឬការភ័យខ្លាចថាការមាក់ងាយពីខាងក្រៅនៅតែមានចំពោះអ្នកផ្ទុកមេរោគអេដស៍មួយចំនួន។ ការអប់រំអំពីមេរោគអេដស៍តាមសហគមន៍សម្រាប់ទាំងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកមិនផ្ទុកមេរោគអេដស៍ ត្រូវបានណែនាំស្រដៀងគ្នានេះនៅទូទាំងសិក្ខាសាលាបកស្រាយ ជាមធ្យោបាយកាត់បន្ថយការមាក់ងាយពីខាងក្រៅ។ ដូច្នេះ ការគិតគូរពីភាពភ័យខ្លាចនៃការមាក់ងាយពីខាងក្រៅ

និងការមិនបញ្ចេញព័ត៌មានកាត់បន្ថយហានិភ័យ នៃការប៉ះពាល់នឹងការរើសអើងពីខាងក្រៅ ថាតើអត្រារាយការណ៍ទាបនៃការរើសអើងពីខាងក្រៅ គឺជាភស្តុតាងនៃការផ្លាស់ប្តូរការមាក់ងាយពីខាងក្រៅចំពោះអ្នកផ្ទុកមេរោគអេដស៍ ឬដោយសារតែអត្រាបញ្ចេញព័ត៌មានទាបនៅតែមិនច្បាស់លាស់។

**៣.៣.៣. បញ្ហាប្រឈម**

ការមាក់ងាយនៃអ្នកផ្ទុកមេរោគអេដស៍នៅតែមាន ជាពិសេសការមាក់ងាយខ្លួនឯង និងមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់។ អ្នកផ្ទុកមេរោគអេដស៍ មានការលំបាកក្នុងការបង្ហាញនូវស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនឱ្យអ្នកដទៃដឹង មានរហូតដល់ ៥២,១ ភាគរយនៃពួកគាត់ បានលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន។ ៤៣,៦ ភាគរយនៃពួកគាត់នៅតែមានអារម្មណ៍ថាមានកំហុស និងរងភាពអាម៉ាស់ និង ៥០,៧ ភាគរយ មានការខ្មាសអៀនដោយសារមានផ្ទុកមេរោគអេដស៍។

ការមាក់ងាយពីខាងក្រៅ បើទោះបីមិនសូវជាកើតមានច្រើន តែមាននៅឡើយ ដែលក្នុងនោះមាន ៨,៩ ភាគរយនៃអ្នកឆ្លើយ ធ្លាប់ត្រូវបណ្តេញចេញពីកម្មវិធី ឬការជួបជុំ ឬសកម្មភាពក្នុងសង្គម និង១៦,៦ ភាគរយ ដែលធ្លាប់ទទួលរងនូវការនិយាយមាក់ងាយពីអ្នកដទៃ ដោយសារតែមានផ្ទុកមេរោគអេដស៍។

អ្នកផ្ទុកមេរោគអេដស៍ភាគច្រើននៅក្នុងប្រទេសកម្ពុជា ជាក្រុមដែលមានសេដ្ឋកិច្ចសង្គមទាបបំផុត ហើយមានការងារធ្វើមិនជាប់លាប់ (៤៤,៦ ភាគរយ មានកម្រិតប្រាក់ចំណូលតិច (≤ ១៥០ US$) និង ៤៣,៥ ភាគរយ មានកម្រិតប្រាក់ចំណូលចន្លោះពី ១៥១ - ៣០០ US$ )។ ពួកគេក៏មិនអាចធ្វើចំណាកស្រុកសម្រាប់ការងារបានងាយស្រួលនៅឆ្ងាយពីសេវាថែទាំជំងឺអេដស៍របស់ពួកគេក្នុងរយៈពេលយូរ ហើយក៏មិនអាចទទួលយកការងារលើកទម្ងន់ធ្ងន់ដោយសារតែស្ថានភាពសុខភាពរបស់ពួកគេ បើពួកគេមិនទទួលបាននូវសេវាថែទាំជំងឺអេដស៍ប្រកបដោយគុណភាព។ អ្នកផ្ទុកមេរោគអេដស៍មួយចំនួនបន្តជ្រើសរើសលាក់ស្ថានភាពរបស់ពួកគេ និងមិនប្រើប្រាស់ជំនួយសង្គម ឬការតភ្ជាប់ជាមួយបណ្តាញគាំទ្រមេរោគអេដស៍ ការផ្តល់ជំនួយសហគមន៍ក្នុងទម្រង់ផ្សេងៗត្រូវបានណែនាំ ថាជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ដើម្បីកាត់បន្ថយការមាក់ងាយផ្ទៃក្នុង។

### ៣.៣.៤ ដំណោះស្រាយ

មានការយល់ដឹងកាន់តែប្រសើរឡើងក្នុងចំណោមប្រជាពលរដ្ឋ ក្នុងប្រទេសកម្ពុជាថា អ្នកផ្ទុកមេរោគអេដស៍អាចរស់នៅបានពេញលេញ និងប្រកបដោយផលិតភាព ប្រសិនបើពួកគេបានប្រកាន់ខ្ជាប់នូវការលេបថ្នាំប្រឆាំងមេរោគអេដស៍ ហើយមេរោគអេដស៍មិនអាចចម្លងបាន ប្រសិនបើការបន្ទុកមេរោគមិនអាចរកឃើញនោះ ដែលអាចជួយសម្រួលដល់ការកាត់បន្ថយការមាក់ងាយពីខាងក្រៅទាក់ទងនឹងមេរោគអេដស៍ ដែលនឹងជះឥទ្ធិពលដល់ការកាត់បន្ថយការមាក់ងាយផ្ទៃក្នុងផងដែរ។

ផ្តល់នូវប័ណ្ណសមធម៌ អាចជួយកែលម្អជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍ និងអាចជួយកាត់បន្ថយការមាក់ងាយខ្លួនឯង ក៏ដូចជាមាក់ងាយពីខាងក្រៅ។

# ៤. សន្និដ្ឋាន និងអនុសាសន៍

## ៤.១. សេចក្តីសន្និដ្ឋាន

ការអប់រំ និងផ្សព្វផ្សាយ អំពីមេរោគអេដស៍ និងជំងឺអេដស៍ នៅមិនទាន់បានគ្រប់ដណ្តប់ទូទាំងប្រទេស និងគ្រប់ក្រុមគោលដៅនៅឡើយ។ ប្រធានបទនៃការអប់រំ ផ្សព្វផ្សាយគួររួមបញ្ចូលនូវ ការបង្ការការចម្លងមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា ការរុករក និងការទប់ស្កាត់ផ្ទុកមេរោគ និងការព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ ទម្រង់ផ្សេងៗនៃការមាក់ងាយនិងការរើសអើង និងសារៈសំខាន់ក្នុងការលុបបំបាត់ការមាក់ងាយ និងការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ និងសង្គមទាំងមូល ជាពិសេសក្រុមប្រជាជនគន្លឹះ និងយុវជនក្រៅសាលា។

ការផ្សព្វផ្សាយអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ និងការបង្កាចម្លង តាមរយៈវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធការឆ្លើយតបនឹងមេរោគអេដស៍ និងប្រជាពលរដ្ឋ មានសារៈសំខាន់ជាពិសេសក្នុងការឈានដល់មិនត្រឹមតែក្រុមគោលដៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឱ្យដល់អ្នកដែលលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេផងដែរ។ អ្នកមានឥទ្ធិពលនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលផ្សព្វផ្សាយសកម្មភាពអប់រំទាក់ទងនឹងមេរោគអេដស៍ និងជំងឺជំងឺអេដស៍ និងបង្ហាញពីសាមគ្គីភាពជាមួយសហគមន៍អ្នកផ្ទុកមេរោគអេដស៍ អាចជួយកាត់បន្ថយការមាក់ងាយខាងក្រៅដែលទាក់ទងនឹងមេរោគ

អេដស៍/ជំងឺអេដស៍។ ក្រុមគោលដៅនៃការអប់រំអំពីមេរោគអេដស៍ និងជំងឺអេដស៍ គួរតែរួមបញ្ចូលទាំងអ្នកផ្ទុកមេរោគអេដស៍ ប្រជាពលរដ្ឋទូទៅ អ្នកធ្វើការនៅសេវាថែទាំជំងឺអេដស៍ ជាពិសេសក្រុមប្រជាជនគន្លឹះ ដើម្បីកាត់បន្ថយការមាក់ងាយ និងការរើសអើង ពីព្រោះមេរោគអេដស៍ និងជំងឺអេដស៍បង្កផលប៉ះពាល់ដល់សហគមន៍ សង្គម និងនៅសេវាថែទាំជំងឺអេដស៍។

ប័ណ្ណសមធម៌ អាចជួយកែលម្អជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍ពួកគេក្នុងទិដ្ឋភាពផ្សេងៗ និងអាចមានសក្តានុពលក្នុងការកាត់បន្ថយការមាក់ងាយខ្លួនឯង ក៏ដូចជាមាក់ងាយពីខាងក្រៅ ដែលអាចឱ្យពួកគាត់អាចដឹកនាំជីវិតបានធម្មតា។ មានភាពរអាក់រអួលមួយចំនួនត្រូវបានកត់សម្គាល់ ពីការទទួលបាន និងប្រើប្រាស់ នូវប័ណ្ណមូលនិធិសមធម៌ ដូចជាអ្នកផ្ទុកមេរោគអេដស៍បានកត់សម្គាល់ពេលវេលារង់ចាំយូរ នៅពេលស្វែងរកសេវាក្រោមមូលនិធិសមធម៌។ លើសពីនេះ នៅមានហានិភ័យនៃការលាតត្រដាងស្ថានភាពផ្ទុកមេរោគអេដស៍ដោយចៃដន្យបានកើនឡើង ដោយសារតែតម្រូវការឯកសារផ្សេងៗ និងតម្រូវការប្រើប្រាស់សម្រាប់ការទូទាត់សងថ្លៃធ្វើដំណើរ។

## ៤.២. អនុសាសន៍

ផ្អែកលើលទ្ធផលនៃការស្ទង់មតិសន្ទស្សន៍ពីការមាក់ងាយ និងយល់ឃើញរបស់អ្នកផ្ទុកមេរោគអេដស៍លើសេវាជំងឺអេដស៍នៃស្ថាប័នសុខាភិបាលសាធារណៈ និងការពិភាក្សានៅក្នុងសិក្ខាសាលាបកស្រាយលទ្ធផលទាំងពីរលើករួចមក សកម្មភាពមួយចំនួនត្រូវបានកំណត់ជាយុទ្ធសាស្ត្រសក្តានុពលក្នុងការដោះស្រាយបញ្ហានានាទាក់ទងនឹងការមាក់ងាយ ការយល់ឃើញជាអវិជ្ជមាននៃអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា និងកែលម្អសេវាជំងឺអេដស៍ប្រកបដោយសមធម៌និងគុណភាព។ ដើម្បីនូវគោលបំណងទាំងនេះ យើងសូមផ្តល់ជាដំណោះស្រាយមួយចំនួនដូចខាងក្រោម៖

- ការលើកកម្ពស់ការអប់រំ និងផ្សព្វផ្សាយ អំពីមេរោគអេដស៍ និងជំងឺអេដស៍។ ការអប់រំ និងផ្សព្វផ្សាយ គួរត្រូវតែធ្វើឡើងនៅក្នុងកន្លែងផ្សេងៗ រួមទាំងសហគមន៍ គ្រឹះស្ថានសុខាភិបាល វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម និងមហាជន ជាពិសេសផ្តោតលើក្រុមប្រជាជនគន្លឹះ និងយុវវ័យក្រៅសាលា ដើម្បីកាត់បន្ថយការមាក់ងាយ និងការរើសអើង និងកែលម្អគុណភាពសេវាជំងឺអេដស៍។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គួរបញ្ចូលទៅក្នុងផែនការយុទ្ធសាស្រ្តជាពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នូវវិធីសាស្រ្តនានាក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងការគ្រប់គ្រងការមាក់ងាយ និងរើសអើងជាពិសេសក្នុងក្រុមអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។
- ការពង្រឹងនូវគុណភាពសេវា ដោយការរួមបញ្ចូលគ្នារវាងសេវាផ្សេងៗ ដូចជាការបង្ការការចម្លងជំងឺអេដស៍ សុខភាពផ្លូវចិត្ត និងសេវាថែទាំជំងឺអេដស៍ ដែលបង្កឱ្យអ្នកទទួលសេវាមានអារម្មណ៍សុវត្ថិភាព និងយល់ឃើញជាវិជ្ជមាន ដែលអាចជំរុញឱ្យមានលទ្ធភាពក្នុងការទៅទទួលសេវាកាន់ច្រើនឡើង និងជួយកាត់បន្ថយការមាក់ងាយ។
- កែលម្អសេវាថែទាំជំងឺអេដស៍ ឱ្យស្របនឹងតម្រូវចាំបាច់នៃអ្នកទទួលសេវា ដោយកន្លែងផ្តល់សេវាពិសេសដាច់ដោយឡែក សម្រាប់តែក្រុមប្រជាជនគន្លឹះ។ បើមិនមានកន្លែងផ្តល់សេវាដាច់ដោយឡែក គួរបន្ថែមម៉ោងការងារ ឬសម្របម៉ោងប្រតិបត្តិការនៃសេវាជំងឺអេដស៍ សម្រាប់ពួកគាត់។
- ការផ្តល់ជំនួយសង្គមតាមសហគមន៍ ដើម្បី ការផ្តល់នូវការគាំទ្រផ្នែកសង្គម និងផ្លូវចិត្តដែលត្រូវការដល់អ្នកផ្ទុកមេរោគអេដស៍ កាត់បន្ថយការមាក់ងាយផ្ទៃក្នុង និងការមាក់ងាយពីខាងក្រៅ។
- ការពង្រីកការគាំទ្រផ្នែកគាំពារសុខភាពសង្គម តាមរយៈការផ្តល់ប័ណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ដើម្បីគាំទ្រតម្រូវការ និងជួយកែលម្អជីវិតរបស់ពួកគេក្នុងទិដ្ឋភាពផ្សេងៗ និងអាចមានសក្តានុពលក្នុងការកាត់បន្ថយការមាក់ងាយខ្លួនឯង ក៏ដូចជាមាក់ងាយពីខាងក្រៅ។

# ឯកសារយោង


១. UNAIDS. Data dashboard. 2022; https://aphub.unaids.org/, 2022.

២. Census. Cambodia: Final General Population Census 2019-English. 2019; https://nis.gov.kh/nis/Census2019/Final%20General%20Population%20Census%202019-English.pdf. Accessed October, 2020.

៣. Chanto SD. CAMBODIA: Current State and Future Projection of the Spread of HIV/AIDS. *Fighting a Rising Tide: The Response to AIDS in East Asia; .* 2006:22.

៤. NCHADS. Report of a Consensus Workshop HIV Estimates and Projections for Cambodia, 2006 - 2012. 2007; https://www.aidsdatahub.org/sites/default/files/resource/report-consensus-workshop-hiv-estimates-projections-cambodia-2006-2012.pdf. Accessed June, 2006.

៥. UNAIDS. Cambodia: Key facts on HIV 2022;https://www.aidsdatahub.org/country-profiles/cambodia, 2021.

៦. NAA. Cambodia HIV/AIDS at a Glance in 2021. Phnom Penh: National AIDS Autorithy; 2021.

៧. UNAIDS. Evidence for eliminationg HIV related stigma and dicrimination_ UNAIDS 2020. 2016; https://www.unaids.org/sites/default/files/media_asset/eliminating-discrimination-guidance_en.pdf, 2020.

៨. Cherry K. How Do Cross-Sectional Studies Work ? Gathering Data From a Single Point in Time. 2022; A cross-sectional study looks at data at a single point in time. The participants in this type of study are selected

based on particular variables of interest. Cross-sectional studies are often used in developmental psychology, but this method is also used in many other areas, including social science and education. Cross-sectional studies are observational in nature and are known as descriptive research, not causal or relational, meaning that you can't use them to determine the cause of something, such as a disease. Researchers record the information that is present in a population, but they do not manipulate variables. This type of research can be used to describe characteristics that exist in a community, but not to determine cause-and-effect relationships between different variables. This method is often used to make inferences about possible relationships or to gather preliminary data to support further research and experimentation. . Available at: https://www.verywellmind.com/what-is-a-cross-sectional-study-2794978. Accessed 25 September, 2022.

๙. Setia MS. Methodology Series Module 3: Cross-sectional Studies. *Indian journal of dermatology.* May-Jun 2016;61(3):261-264.

๑๐. Halcomb E, Hickman L. Mixed methods research. *Nursing standard (Royal College of Nursing (Great Britain) :* 1987). Apr 8 2015;29(32):41-47.

๑๑. Wariri O, Ajani A, Raymond MP, et al. "What will my child think of me if he hears I gave him HIV?": a sequential, explanatory, mixed-methods approach on the predictors and experience of caregivers on disclosure of HIV status to infected children in Gombe, Northeast Nigeria. *BMC Public Health.* Mar 20 2020;20(1):373.

១២. Smith JD, Hasan M. Quantitative approaches for the evaluation of implementation research studies. *Psychiatry research.* Jan 2020;283:112521.

១៣. Gesicho MB, Babic A. Identifying barriers and facilitators in HIV-indicator reporting for different health facility performances: A qualitative case study. *PloS one.* 2021;16(2):e0247525.

១៤. George MW. *The Elements of Library Research*. Princeton: Princeton University Press; 2008.

១៥. CPN+. *The People Living with HIV Stigma Index* 2.0 *Cambodia*: *Research Report* 2019. Phnom Penh 2019 2019.

១៦. SPSS I. IBM SPSS Statistics V25 offers new statistics, stronger integration with third-party applications, and enhanced productivity. 2018; https://www.ibm.com/common/ssi/ShowDoc.wss?docURL=/common/ssi/rep_ca/9/897/ENUS217-279/index.html.

១៧. Dhakal K. NVivo. *Journal of the Medical Library Association : JMLA.* Apr 1 2022;110(2):270-272.

១៨. Rawat AS. An Overview of Descriptive Analysis. 2021; https://www.analyticssteps.com/blogs/overview-descriptive-analysis. Accessed 22 September, 2021.

១៩. Cooper DR, Schindler PS. *Business Research Methods*: McGraw-Hill; 2014.

២០. Gallo RC. HIV/AIDS Research for the Future. *Cell host & microbe.* Apr 8 2020;27(4):499-501.

๒๑. Masur H, Michelis MA, Greene JB, et al. An outbreak of community-acquired Pneumocystis carinii pneumonia: initial manifestation of cellular immune dysfunction. *The New England journal of medicine.* Dec 10 1981;305(24):1431-1438.

๒๒. Alkenbrack Batteh SE, Forsythe S, Martin G, Chettra T. Confirming the impact of HIV/AIDS epidemics on household vulnerability in Asia: the case of Cambodia. *AIDS (London, England).* Jul 2008;22 Suppl 1:S103-111.

๒๓. OxfordLearner'sDictionaries. Stigma definition.

๒๔. Atuhaire L, Shumba CS, Nyasulu PS. "My condition is my secret": perspectives of HIV positive female sex workers on differentiated service delivery models in Kampala Uganda. *BMC health services research.* Feb 4 2022;22(1):146.

๒๕. Moussa AB, Delabre RM, Villes V, et al. Determinants and effects or consequences of internal HIV-related stigma among people living with HIV in Morocco. *BMC Public Health.* Jan 19 2021;21(1):163.

๒๖. Boushab BM, Fall-Malick FZ, Ould Cheikh Melaïnine ML, Basco LK. Forms of Stigma and Discrimination in the Daily Lives of HIV-Positive Individuals in Mauritania. *The open AIDS journal.* 2017;11:12-17.

๒๗. Maluccio JA, Wu F, Rokon RB, Rawat R, Kadiyala S. Assessing the Impact of Food Assistance on Stigma Among People Living with HIV in Uganda Using the HIV/AIDS Stigma Instrument-PLWA (HASI-P). *AIDS and behavior.* Mar 2017;21(3):766-782.

๒๘. Bwalya C, Simwinga M, Hensen B, et al. Social response to the delivery of HIV self-testing in households: experiences from four

Zambian HPTN 071 (PopART) urban communities. *AIDS research and therapy.* Jun 11 2020;17(1):32.

๒๙. Gamarel KE, Kuo C, Boyes ME, Cluver LD. The dyadic effects of HIV stigma on the mental health of children and their parents in South Africa. *Journal of HIV/AIDS & social services.* 2017;16(4):351-366.

๓๐. Ho CL, Pan W, Taylor LD. Stigma of HIV Testing on Online HIV Forums: Self-Stigma and the Unspoken. *Journal of psychosocial nursing and mental health services.* Dec 1 2017;55(12):34-43.

๓๑. Li J, Mo PK, Wu AM, Lau JT. Roles of Self-Stigma, Social Support, and Positive and Negative Affects as Determinants of Depressive Symptoms Among HIV Infected Men who have Sex with Men in China. *AIDS and behavior.* Jan 2017;21(1):261-273.

๓๒. Mulqueeny DM, Nkabini SM, Pokiya MH. Mapping evidence of depression in HIV-seropositive MSM in sub-Saharan Africa: a scoping review protocol. *Systematic reviews.* Feb 5 2021;10(1):50.

๓๓. Lindayani L, Ibrahim K, Wang JD, Ko NY. Independent and synergistic effects of self- and public stigmas on quality of life of HIV-infected persons. *AIDS care.* Jun 2018;30(6):706-713.

๓๔. Ma PHX, Chan ZCY, Loke AY. Self-Stigma Reduction Interventions for People Living with HIV/AIDS and Their Families: A Systematic Review. *AIDS and behavior.* Mar 2019;23(3):707-741.

๓๕. Nobre N, Pereira M, Roine RP, Sutinen J, Sintonen H. HIV-Related Self-Stigma and Health-Related Quality of Life of People Living With HIV in Finland. *The Journal of the Association of Nurses in AIDS Care : JANAC.* Mar-Apr 2018;29(2):254-265.

๓๖. Mburu G, Ayon S, Tsai AC, et al. "Who has ever loved a drug addict? It's a lie. They think a 'teja' is as bad person": multiple stigmas faced by women who inject drugs in coastal Kenya. *Harm reduction journal.* May 25 2018;15(1):29.
๓๗. Mo PKH, Chen X, Lam EHK, Li J, Kahler CW, Lau JTF. The Moderating Role of Social Support on the Relationship Between Anxiety, Stigma, and Intention to Use Illicit Drugs Among HIV-Positive Men Who Have Sex with Men. *AIDS and behavior.* Jan 2020;24(1):55-64.
๓๘. Njejimana N, Gómez-Tatay L, Hernández-Andreu JM. HIV-AIDS Stigma in Burundi: A Qualitative Descriptive Study. *International journal of environmental research and public health.* Sep 3 2021;18(17).
๓๙. Pantelic M, Steinert JI, Park J, Mellors S, Murau F. 'Management of a spoiled identity': systematic review of interventions to address self-stigma among people living with and affected by HIV. *BMJ global health.* 2019;4(2):e001285.
๔๐. Yang X, Mak WW, Ho CY, Chidgey A. Self-in-love versus self-in-stigma: implications of relationship quality and love attitudes on self-stigma and mental health among HIV-positive men having sex with men. *AIDS care.* Jan 2017;29(1):132-136.
๔๑. Zhu Y, Liu J, Chen Y, Zhang R, Qu B. The relation between mental health, homosexual stigma, childhood abuse, community engagement, and unprotected anal intercourse among MSM in China. *Scientific reports.* Mar 5 2018;8(1):3984.

๔๒. Munro S, Dinatale E, Hartley S, St Jacques M, Oursler KA. Barriers and Health Beliefs Related to Weight Management Among Veterans With Human Immunodeficiency Virus. *Military medicine.* Jan 2017;182(1):e1596-e1602.

๔๓. Saki M, Mohammad Khan Kermanshahi S, Mohammadi E, Mohraz M. Perception of Patients With HIV/AIDS From Stigma and Discrimination. *Iranian Red Crescent medical journal.* Jun 2015;17(6):e23638.

๔๔. Oladunni AA, Sina-Odunsi AB, Nuga BB, et al. Psychosocial factors of stigma and relationship to healthcare services among adolescents living with HIV/AIDS in Kano state, Nigeria. *Heliyon.* Apr 2021;7(4):e06687.

๔๕. Sommerland N, Wouters E, Masquillier C, Rau A, Engelbrecht M, Kigozi G. Factors Associated With HIV-Related Stigma Toward Colleagues in the Health Care Workforce in South Africa. *The Journal of the Association of Nurses in AIDS Care : JANAC.* Jul-Aug 2019;30(4):451-461.

๔๖. Muralidharan S, Acharya AK, Margabandu S, et al. Stigma and Discrimination faced by HIV-infected Adults on Antiretroviral Therapy for more than 1 Year in Raichur Taluk, Karnataka, India. *The journal of contemporary dental practice.* Sep 1 2017;18(9):765-770.

๔๗. Utuk G, Osungbade O, Obembe A, Adewole A, Oladoyin O. Stigmatising Attitudes Towards Co-workers with HIV in the Workplace of a Metropolitan State, Southwestern Nigeria. *The open AIDS journal.* 2017;11:67-75.

๔๘. Pourmarzi D, Khoramirad A, Gaeeni M. Perceived Stigma in People Living With HIV in Qom. *Journal of family & reproductive health.* Dec 2017;11(4):202-210.

๔๙. Ncitakalo N, Mabaso M, Joska J, Simbayi L. Factors associated with external HIV-related stigma and psychological distress among people living with HIV in South Africa. *SSM - population health.* Jun 2021;14:100809.

๕๐. Saka B, Tchounga B, Ekouevi DK, et al. [Stigma and discrimination experienced by people living with HIV in Togo, in 2013]. *Sante publique (Vandoeuvre-les-Nancy, France).* Nov-Dec 2017;29(6):897-907.

๕๑. Kulane A, Owuor JOA, Sematimba D, Abdulahi SA, Yusuf HM, Mohamed LM. Access to HIV Care and Resilience in a Long-Term Conflict Setting: A Qualitative Assessment of the Experiences of Living with Diagnosed HIV in Mogadishu, Somali. *International journal of environmental research and public health.* Jul 5 2017;14(7).

๕๒. Barker D, Enimil A, Galárraga O, et al. In-Clinic Adolescent Peer Group Support for Engagement in Sub-Saharan Africa: A Feasibility and Acceptability Trial. *Journal of the International Association of Providers of AIDS Care.* Jan-Dec 2019;18:2325958219835786.

๕๓. Davila JA, Cabral HJ, Maskay MH, et al. Risk factors associated with multi-dimensional stigma among people living with HIV/AIDS who are homeless/unstably housed. *AIDS care.* Oct 2018;30(10):1335-1340.

๕๔. Wiginton JM, Murray SM, Algarin AB, Baral SD, Sanchez TH, Smith LR. Metrics of sexual behavior stigma among cisgender men who

have sex with men in Mexico: exploratory and confirmatory factor analyses. *BMC infectious diseases.* Aug 13 2022;22(1):690.

๕๕. Wouters E, Masquillier C, Sommerland N, et al. Measuring HIV- and TB-related stigma among health care workers in South Africa: a validation and reliability study. *The international journal of tuberculosis and lung disease : the official journal of the International Union against Tuberculosis and Lung Disease.* Nov 1 2017;21(11):19-25.

๕๖. Angwenyi V, Aantjes C, Kajumi M, De Man J, Criel B, Bunders-Aelen J. Patients experiences of self-management and strategies for dealing with chronic conditions in rural Malawi. *PloS one.* 2018;13(7):e0199977.

๕๗. Ruark A, Stern E, Dlamini-Simelane T, Kakuze MF. Love matters: exploring conceptions of love in Rwanda and Swaziland and relationship to HIV and intimate partner violence. *African journal of AIDS research : AJAR.* Dec 2017;16(4):271-282.

๕๘. Dandachi D, de Groot A, Rajabiun S, et al. Reliability and Validity of a Brief Self-Report Adherence Measure among People with HIV Experiencing Homelessness and Mental Health or Substance Use Disorders. *AIDS and behavior.* Feb 2021;25(2):322-329.

๕๙. Adeiza MA, Wachekwa I, Nuta C, et al. Gaps and Opportunities in HIV Service Delivery in High Volume HIV Care Centers in Liberia: Lessons From the Field. *Annals of global health.* 2021;87(1):115.

๖๐. Ikeda DJ, Basenero A, Murungu J, Jasmin M, Inimah M, Agins BD. Implementing quality improvement in tuberculosis programming:

Lessons learned from the global HIV response. *Journal of clinical tuberculosis and other mycobacterial diseases.* Dec 2019;17:100116.

๖๑. Nguyen M, Goldsamt L, Mazibuko N, Zondo S, Fielding-Miller R. Emotional distress among frontline research staff. *Social science & medicine (*1982). Jul 2021;281:114101.

๖๒. Pachankis JE, Hatzenbuehler ML, Wang K, et al. The Burden of Stigma on Health and Well-Being: A Taxonomy of Concealment, Course, Disruptiveness, Aesthetics, Origin, and Peril Across 93 Stigmas. *Personality & social psychology bulletin.* Apr 2018;44(4):451-474.

๖๓. Doyore F, Moges B. Client satisfaction to antiretroviral treatment services and associated factors among clients attending ART clinics in Hossana Town, Southern Ethiopia2016.

๖๔. Agrawal H, Mourya R, Shrestha RK, Agrawal S. Quality of life among HIV positive individuals in Kathmandu valley and Eastern region of Nepal. *Kathmandu University medical journal (KUMJ).* Oct-Dec 2012;10(40):3-7.

๖๕. Ahmed S, Autrey J, Katz IT, et al. Why do people living with HIV not initiate treatment? A systematic review of qualitative evidence from low- and middle-income countries. *Social science & medicine (*1982). Sep 2018;213:72-84.

# ភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនចំពោះ ហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា

បណ្ឌិត **យ៉េន សិត្យា**

## មូលន័យសង្ខេប

យោងតាមការស្រាវជ្រាវ និងចំណេះដឹងរបស់អ្នកស្រាវជ្រាវនៅកម្ពុជា ពុំទាន់មានការសិក្សាស្រាវជ្រាវពីភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជនលើហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជានៅឡើយទេ។ ប្រការនេះ ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងចំនួន ២ គឺ៖ ១) ឈ្វេងយល់និងកំណត់កម្រិតនៃភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា និង២) ស្វែងរកទំនាក់ទំនងរវាងភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា។ ការសិក្សានេះ ជាការស្រាវជ្រាវបែបបរិមាណវិស័យ ដោយប្រើប្រាស់កម្រងសំណួរ ដែលបានរៀបរៀង ចងក្រង និងរៀបចំដោយអ្នកស្រាវជ្រាវ តាមរយៈទ្រីស្តីពាក់ព័ន្ធ។ ភាគសំណាក នៃការសិក្សានេះ ជាអតិថិជនចំនួន២៥០នាក់ ដែលជ្រើសរើសចេញពីហាងសំណាកគោលដៅទាំង៥ ក្នុងរាជធានីភ្នំពេញតាមការស្ម័គ្រចិត្ត។ ទិន្នន័យដែលប្រមូលបានត្រូវបានយកមកវិភាគ ដោយប្រើប្រាស់ស្ថិតិពណ៌នា ដូចជា ប្រេកង់ ភាគរយ តម្លៃមធ្យម និងគម្លាតស្តង់ដា និងស្ថិតិ សន្និដ្ឋាន ដូចជា Independent samples t-test, One-way ANOVA, Correlation Analyses និង Multiple Regression។

លទ្ធផលសំខាន់ៗនៃការសិក្សានេះអាចសរុបបាន ដូចខាងក្រោម៖

១- ភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជាជារួម និងដោយឡែក ស្ថិតនៅកម្រិតមធ្យម។ បើរៀងលំដាប់តម្លៃមធ្យមពីខ្ពស់បំផុតទៅទាបបំផុតគឺ៖ "ភាពពេញចិត្តរបស់អតិថិជន "ការចែកចាយ" "ផលិតផល" "សេវាកម្មក្រោយពេលលក់" "ភក្តីភាពរបស់អតិថិជន" និង "ការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង" តាមលំដាប់។ លទ្ធផលដែលមានភាពដូចគ្នា និងខុសគ្នាផ្នែក ស្ថិតិពី Independent samples t-

test និង One-way ANOVA ប៉ុណ្ណោះ ត្រូវបានយកមកបង្ហាញ។ ពេលពិចារណាអថេរអាយុ ភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជន លទ្ធផលបង្ហាញថា អតិថិជនមានការយល់ឃើញខុសពីគ្នា តែផ្នែកផលិតផល និងផ្នែកសេវាកម្មក្រោយពេលលក់ ខុសគ្នាក្នុងកម្រិត ០.០០១ ផ្នែកការចែកចាយ និងផ្នែកភាពពេញចិត្តរបស់អតិថិជនក្នុងកម្រិត ០.០០៣។ ដោយឡែកផ្នែកពីរទៀតៈ ផ្នែកការលក់ និងយុទ្ធសាស្ត្រទំនាក់ទំនងក្នុងកម្រិត ០.១៥០ និងផ្នែកភក្តីភាពរបស់អតិថិជនក្នុងកម្រិត ០.១៣០ មិនមានភាពខុសគ្នានៃការយល់ឃើញរបស់អតិថិជន។

២- ភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា មានទំនាក់ទំនងខ្លាំង និងវិជ្ជមាន ជារួម (០.៩៦១) និងគ្រប់ផ្នែក។

ការសិក្សានេះ បានផ្តល់អនុសាសន៍សម្រាប់អ្នករៀបចំគោលនយោបាយ អ្នកផលិតផលិតផល និងបម្រើសេវាកម្មពាក់ព័ន្ធនឹងហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា។ លទ្ធផលនៃការសិក្សានេះ អាចផ្តល់អត្ថប្រយោជន៍ប្រកបដោយសក្តានុពល និងមានឥទ្ធិពលសម្រាប់ក្រសួងពាណិជ្ជកម្ម សហគ្រិន ពាណិជ្ជករ អតិថិជន និងមនុស្សទូទៅដែលបូករួមទាំងផ្នែកដែលពាក់ព័ន្ធ ព្រោះអាចឱ្យពួកគេស្គាល់ពីអត្តសញ្ញាណ ចរិត លក្ខណៈ ចំណង់ចំណូលចិត្តរបស់អតិថិជន ស្គាល់ពីប្រភេទនៃក្រុមអ្នកប្រើប្រាស់ ប្រភេទនៃអាជីវកម្មម៉ាកយីហោហាងកាហ្វេបង្កើតក្នុងស្រុក ការបង្កើតអាជីវកម្មដោយខ្លួនឯង និងការសហការពីដៃគូធ្វើពាណិជ្ជកម្ម។

**ពាក្យគន្លឹះ៖ អតិថិជន ភាពពេញចិត្ត ភក្តីភាព ហាងកាហ្វេបង្កើតក្នុងស្រុក**

# ១. សេចក្តីផ្តើម

## ១.១. លំនាំបញ្ហា នៃការស្រាវជ្រាវ

នៅឆ្នាំ ២០២៥ ទីផ្សារកាហ្វេនៅកម្ពុជាត្រូវបានគេរំពឹងថានឹងឈានដល់ប្រមាណ ២៣៣,១៤លានដុល្លារ និង៤១,៧៣លានដុល្លារ សម្រាប់ទីផ្សារកាហ្វេត្រូវមានជាបន្ទាន់។ ក្នុងមួយឆ្នាំ ការប្រមូលផលកាហ្វេនៅកម្ពុជាមានប្រហែល ៣០០តោន ខណៈកាហ្វេជាង ៥០០០ តោនត្រូវបាននាំចូលក្នុងមួយឆ្នាំ។ ភាពខុសគ្នាដ៏ធំនេះប្រែក្លាយជាសក្តានុពលក្នុងការបង្កើនសមត្ថភាពផលិតក្នុងស្រុក។ កម្ពុជា អាចជំរុញផលិតភាពនិងកាត់បន្ថយចំនួនការនាំចូល ខណៈការធ្វើឱ្យប្រសើរឡើងនូវការនាំចេញ។ សេដ្ឋកិច្ច មានស្ថិរភាពដោយសារមាន

វប្បធម៌ប្រើប្រាស់ និងចូលចិត្តកាហ្វេនេះហើយ។ ស្របពេលការដាំកាហ្វេហាក់ដូចជាកំពុងរីកដុះដាលហើយផ្ទៃដីដាំនឹងកើនឡើងដល់ទៅ ១ ម៉ឺនហិកតាក្នុងរយៈពេលបីឆ្នាំខាងមុខ។ ដូចអ្វីដែលបានរៀបរាប់ពីខាងលើ តម្រូវការអាជីវកម្មកាហ្វេកាន់តែមានការប្រកួតប្រជែង និងកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ប្រជាជនកម្ពុជាដែលរស់នៅទីក្រុងដ៏សំបូរបែបនេះ យល់ឃើញថា កាហ្វេពិតជាមានភាពទាក់ទាញខ្លាំង ហើយជាលទ្ធផលមានហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជាជាច្រើន ដែលបង្កើតឡើងដោយកូនខ្មែរហើយបាននឹងកំពុងបន្តអាជីវកម្មនេះ ឱ្យកាន់តែកើនឡើងរីកដុះដាលដូចផ្សិត[១]។

លើសពីនេះ ការកើនឡើងនៃអ្នកប្រើប្រាស់ ដែលមានភាពទាន់សម័យ គឺបានទទួលយករបៀបរស់នៅរបស់បរទេសយ៉ាងឆាប់រហ័សជាមួយនឹងផលិតផលកាហ្វេ និងភេសជ្ជៈស្រដៀងគ្នា ដែលកំពុងមានតម្រូវការខ្ពស់ក្នុងចំណោមយុវវ័យ ស្របពេលទទួលទានអាហារពេលព្រឹក អាហារថ្ងៃត្រង់ និងពេលល្ងាច និងប្រជាពលរដ្ឋ រួមទាំងជនបរទេសផងដែរ ដែលកំពុងធ្វើការនិងស្នាក់នៅក្នុងទីក្រុងភ្នំពេញ។ ការផ្តល់តម្រូវការសម្រាប់ហាងកាហ្វេ ត្រូវមានភាពទាក់ទាញនិងផ្តល់ផាសុកភាពដល់អ្នកទទួលសេវា និងអ្នកប្រើប្រាស់ទាន់សម័យអាចរីករាយក្នុងការនិយាយជាមួយក្រុមគ្រួសារ ឬមិត្តភក្តិនៅពេលទទួលទានអាហារ និងភេសជ្ជៈកាហ្វេ។ នៅរាជធានីភ្នំពេញ មានហាងកាហ្វេជាច្រើន ដែលមានការយកចិត្តទុកដាក់ខ្ពស់នៅក្នុងទីផ្សារកំពូលសម្រាប់ហាងកាហ្វេទំនើបនិងទាន់សម័យ[២]។

បច្ចុប្បន្ននេះ និន្នាការនៃការពិសារកាហ្វេកំពុងពេញនិយមនៅរាជធានីភ្នំពេញតាមរយៈការផ្លាស់ប្តូរ រចនាសម្ព័ន្ធសង្គមនៃការរស់នៅរបស់ប្រជាជនកម្ពុជា។ ដូច្នេះ ហាងកាហ្វេជាច្រើនកំពុងប្រកួតប្រជែងក្នុងរាជធានីភ្នំពេញ។ កត្តានេះ ជាការជំរុញសេដ្ឋកិច្ចខ្លាំងណាស់សម្រាប់ហាងកាហ្វេទាំងនោះ ក្នុងការស្វែងរកអ្វីដែលអាចជំរុញមនុស្សឱ្យប្រើប្រាស់សេវាកម្មរបស់ពួកគេ ដើម្បីទីផ្សារការមកដល់នៃអាជីវកម្មរយៈពេលយូរ។

---

[១] Williams & Marshall. (2020). Strategy Research Reports on Beverage's market. Retrieved on May 10, 2020, pp 80.

[២] Sinit T.., (2018). Factors Influencing Cambodian's Customer Loyalty In Using The Service At Coffee Shops In Phnom Penh, Cambodia. MBA, Graduate School, Bangkok University, pp 55.

ភាពពេញចិត្តនិងការជឿជាក់របស់អតិថិជន ជាគុណតម្លៃស្នូល ដែលស្តែងចេញពីការរីករាយលើការប្រើប្រាស់ផលិតផល សេវាកម្ម និងការរួមចំណែករបស់សេវាកម្មបន្ថែម បរិយាកាស និងបរិស្ថាន គ្រឿងសម្ភារៈ បរិក្ខារក៏បានជួយជាភាពលម្អ និងសោភណ្ឌភាពឱ្យអតិថិជនមានអារម្មណ៍ស្រស់ស្រាយ ធូរស្រាលពីការងារទាំងឡាយបូករួមនឹងការទទួលទានរសជាតិកាហ្វេ[៣]។ ភាពពេញចិត្តនិងភាពជឿជាក់នេះ ទើបអាចបង្កើតបានជាទំនុកចិត្តរបស់អតិថិជនរហូតអាចឈានដល់ក្លាយជាអតិថិជន ដែលមានភក្តីភាព និងស្មោះស្ម័គ្រចំពោះហាងអាជីវកម្មមួយ។ ក្នុងនាមជាអ្នកគិតគូរពីភាពពេញចិត្តនិងធ្វើយ៉ាងណាឱ្យអតិថិជនមានភក្តីភាពចំពោះហាងរបស់ខ្លួន ម្ចាស់ហាងគប្បីខិតខំសិក្សាពីទំនាក់ទំនងរវាងភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជន ដោយធ្វើការវិភាគផ្អែកលើកត្តាវិជ្ជមានមួយចំនួន ដែលកើតចេញពីអតិថិជន ដូចជា កត្តាសង្គម ការប៉ាន់ប្រមាណចិត្តរបស់អតិថិជនក្នុងការវិលត្រឡប់មកទិញវិញម្តងទៀតក្នុងការទិញ ឬប្រើប្រាស់សេវាកម្មនៅពេលអនាគត។ អតិថិជន មានទំនុកចិត្តខ្លាំងចំពោះម៉ាកយីហោហាងនឹងណែនាំបន្តទៅកាន់មនុស្សដែលស្គាល់ផ្សេងទៀត។ អតិថិជនក៏នៅតែបន្តគាំទ្រពេញទំហឹងលើម៉ាកយីហោហាងដោយមិនប្រែប្រួលផ្លាស់ប្តូរ ទោះបីជាពេលខ្លះទៀត មានការកើនឡើងនូវតម្លៃទំនិញថ្លៃជាងហាងម៉ាកយីហោផ្សេងក៏ដោយ[៤]។

ការស្រាវជ្រាវពីភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជន ជាប្រធានបទក្តៅនិងកំពុងពេញនិយមបំផុតក្នុងចំណោមប្រទេសអភិវឌ្ឍទាំងឡាយ ដោយអ្នកជំនាញផ្នែកនេះបានបង្កើតនូវរាល់ទ្រឹស្តី វិធីសាស្ត្រ និងយុទ្ធសាស្ត្រ ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ប្រទេសដទៃទៀតយកជាគំរូ។ ក្នុងបរិការណ៍នេះ ប្រទេសមួយចំនួនក្នុងក្របខណ្ឌអាស៊ាន ដូចជា ប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសសិង្ហបុរី បានសិក្សាលើប្រធានបទនេះយ៉ាងផុសផុលទាំងកម្រិតស្ថាប័ននិងកម្រិត

---

[៣] Lee, H. J., Suh, J. Y., & Yoon, K. H., (2013). A comparative study on the effect of experiences on service encounter, customer satisfaction and brand loyalty in the homemade and foreign coffee shop brands – Centered on the moderating role of brand trust. Journal of Food service Management, 16(3), pp 197–227.

[៤] Martin, C., Molina & Esteban, (2007). An integrated Model of Price, Satisfaction and loyalty: An Empirical Analysis in The Service Sector. Journal of Product & Brand Management, 16(7), pp 459–468.

ជាតិរបស់ខ្លួន តែពុំទាន់មានការសិក្សាណាមួយនៅប្រទេសកម្ពុជានៅឡើយទេ។ ប្រការនេះ ការសិក្សាស្រាវជ្រាវនេះ នឹងវិភាគស៊ីជម្រៅពីទំនាក់ទំនងរបស់អតិថិជនផ្សារភ្ជាប់នឹងភាពពេញចិត្តនិងកត្តាទាំងឡាយធ្វើឱ្យមានទំនុកចិត្ត ដែលបណ្ដាលឱ្យមានជាភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា និងមូលហេតុជាក់លាក់ ដែលជាកត្តាលីករជំរុញឱ្យមានការបង្កើតនូវហាងកាហ្វេបង្កើតក្នុងស្រុកដោយខ្លួនឯងជាច្រើន និងការកកើនឡើងនៃការបង្កើតហាងកាហ្វេក្នុងស្រុកជាបន្តបន្ទាប់នៅប្រទេសកម្ពុជា។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ សំណួរស្រាវជ្រាវចំនួនពីរ ត្រូវបានដាក់ចេញដូចខាងក្រោម៖

១. តើអតិថិជនគោលដៅមានភាពពេញចិត្តនិងភក្ដីភាពចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជាកម្រិតណា?

២. តើមានទំនាក់ទំនងគ្នាដែរឬទេរវាងភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា?

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់ៗចំនួនពីរ ដូចខាងក្រោម៖

១- វិភាគពីកម្រិតភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនគោលដៅចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជាលើ ៦ ផ្នែក៖

១. ផ្នែកផលិតផល (PRO)

២. ផ្នែកការចែកចាយ (DIS)

៣. ផ្នែកសេវាកម្មក្រោយពេលលក់ (ASS)

៤. ផ្នែកការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង (SCS)

៥. ផ្នែកភាពពេញចិត្តរបស់អតិថិជន (SAT)

៦. ផ្នែកភក្ដីភាពរបស់អតិថិជន (LOY)

២- វិភាគស៊ីជម្រៅពីទំនាក់ទំនងគ្នារវាងភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា។

## ១.៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានកំណត់ដែនកំណត់និងវិសាលភាព ដូចខាងក្រោម៖

ខ្លឹមសារ ដែលយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ គឺកម្រងសំណួរអង្កេត ដែលបានសំយោគ ដកស្រង់ រៀបរៀង និងចងក្រងដោយអ្នកស្រាវជ្រាវតាមឯកសារនិងទ្រឹស្តីពាក់ព័ន្ធ។ ភាគសំណាកអង្កេតនៃការស្រាវជ្រាវ គឺអតិថិជនចំនួន ២៥០នាក់ ដែលបានទៅទទួលសេវាកម្មនៅហាងកាហ្វេបង្កើតក្នុងស្រុកចំនួន៥ ហាងគោលដៅក្នុងរាជធានីភ្នំពេញ។ ការជ្រើសរើសហាងកាហ្វេបង្កើតក្នុងស្រុកទាំងអស់នេះ គឺតាមគោលបំណងដោយផ្អែកទៅលើហាងកាហ្វេបង្កើតក្នុងស្រុកជាយីហោរបស់កម្ពុជា និងបង្កើតដោយកូនខ្មែរ។

ក្នុងការស្រាវជ្រាវនេះ អថេរឯករាជ្យ គឺផ្នែកទាំង ៤ នៃការវាយតម្លៃលើភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជន។ អថេរមិនឯករាជ្យ គឺភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនក្នុងការទទួលយកសេវាកម្មរបស់ហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា។ ថេរវេលាក្នុងការសិក្សាស្រាវជ្រាវនេះ គឺចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០២១ រហូតដល់ ខែមិនា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាណិជ្ជកម្ម ស្ថាប័នដែលពាក់ព័ន្ធ និងមានការសហការពីអតិថិជន និងរួមទាំងម្ចាស់ហាងគោលដៅទាំងអស់។

## ១.៥. វិធីសាស្ត្រស្រាវជ្រាវ

ភាគសំណាកគោលដៅ ត្រូវបានជ្រើសរើសចំនួន ២៥០នាក់ ដែលជាអតិថិជនទាំងឡាយ ដែលមកទទួលនូវសេវាកម្មនានាពីហាងកាហ្វេបង្កើតក្នុងស្រុកគោលលដៅចំនួន ៥ ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដោយបានប្រើប្រាស់ការជ្រើសរើសភាគសំណាកតាមគោលបំណង (Purposive Sampling) និងកំណត់ការវិនិច្ឆ័យជ្រើសរើសសំណាកគោលដៅដោយមិនជ្រើសរើសដោយចៃដន្យ។ ប្រការនេះ អ្នកស្រាវជ្រាវ បានចុះទៅកាន់ហាងកាហ្វេបង្កើតក្នុងស្រុកគោលដៅទាំង៥ ដោយផ្ទាល់ ព្រមទាំងបានជួបជាមួយអតិថិជនគោលដៅ និងបានស្នើសុំឱ្យជួយបំពេញកម្រងសំណួរដែលបានរៀបចំ។

ឧបករណ៍ ដែលប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ជាកម្រងសំណួរស្តីពីភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជន។ កម្រងសំណួរនេះ ត្រូវបានបង្កើតឡើងតាមនីតិវិធីនិងវិធីសាស្ត្រ ដូចខាងក្រោម៖

១- សិក្សាឯកសារ ការស្រាវជ្រាវ បញ្ញត្តិ និងទ្រឹស្តី ដែលពាក់ព័ន្ធនឹងភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជនទាំងក្នុងប្រទេស តំបន់ និងសកលលោក ដោយបានដកស្រង់និងសំយោគខ្លឹមសារនៃកម្រងសំណួរ[៥]។

២-សិក្សាពីវិធីបង្កើតកម្រងសំណួរ បែបកម្រិតចំណុចអនុវត្តមាត្រដ្ឋាន ៥ កម្រិតរបស់លីខើត។

៣- នាំយកទិន្នន័យបានមកពីចំណុចទី១ និងទី២ មកបង្កើតកម្រងសំណួរពាក់ព័ន្ធនឹងភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនលើ ៦ ផ្នែក គឺៈ ផ្នែកផលិតផល ផ្នែកការចែកចាយ ផ្នែកសេវាកម្មក្រោយពេលលក់ ផ្នែកការលក់និងយុទ្ធសាស្រ្តទំនាក់ទំនង ផ្នែកភាពពេញចិត្តរបស់អតិថិជន និងផ្នែកភក្តីភាពរបស់អតិថិជន។

៤- នាំយកកម្រងសំណួរ ដែលបានបង្កើតរួចហើយ មកស្នើសុំយោបល់ និងមតិត្រឡប់ពីសាស្រ្តាចារ្យណែនាំគោលនិងសាស្រ្តាចារ្យណែនាំរង ដើម្បីត្រួតពិនិត្យលើសង្គតិភាពភាពត្រឹមត្រូវ និងបានស្នើសុំអនុសាសន៍សម្រាប់យកទៅកែសម្រួលបន្ត។

៥- យកកម្រងសំណួរ ដែលបានបង្កើតនិងឆ្លងកាត់ការពិចារណារបស់សាស្រ្តាចារ្យណែនាំទាំងពីររួចមក យើងបានយកកម្រងសំណួរទៅពិនិត្យសង្គតិភាពប្រត្យក្ស (Face Validity) ដោយអ្នកជំនាញចំនួន ៣រូប និងបានយកលទ្ធផលការពិនិត្យរបស់អ្នកជំនាញមករកតម្លៃភាពត្រឹមត្រូវរវាងចំណុចនីមួយៗជាមួយគោលបំណងការសិក្សា (Index of Item-Objective Congruence) ចំនួនចំណុច ដែលអាចប្រើដើម្បីជួយពិនិត្យលើសង្គតិភាពខ្លឹមសារនិងដើម្បីអាចបញ្ជាក់ថាកម្រងសំណួរនេះមានស្តង់ដា[៦]។

៦-នាំយកកម្រងសំណួរ ដែលបានកែសម្រួលចុងក្រោយតាមអនុសាសន៍ និងការណែនាំរបស់អ្នកជំនាញទៅប្រមូលសាកល្បង ជាមួយអតិថិជនចំនួន២០នាក់ ដើម្បីយកទិន្នន័យមកវិភាគតម្លៃនីមួយៗដោយប្រើការសាកល្បងតម្លៃធី (t-test) ហើយជ្រើសរើស

---

[៥] Rosa, T., (2001). Customer satisfaction key to better retail sales. Caribbean Business, 29(34), pp 23–25.

[៦] Creswell, J. W. (2012). Educational Research: Planning, Conducting, Evaluating, Quantitative and Qualitative Research (4th ed.). United State of America: Pearson Education, Inc

តម្លៃណា ដែលមានតម្លៃខ្ពស់ ដោយតម្លៃធំច្រើនជាង ១,៧៥ ឡើងទៅ គឺត្រូវបានយកមកប្រើជាឧបករណ៍ក្នុងការស្រាវជ្រាវ[៧]។

៧-វិភាគរកតម្លៃនៃភាពជឿជាក់ (Reliability) ចេញពីកម្រងសំណួរ ដែលមានគុណភាព ដោយប្រើវិធីរកតម្លៃសម្ព័ន្ធប្រសិទ្ធភាព អាល់ហ្វា (Alpha Coefficient) ដោយបានប្រើនូវរូបមន្តរបស់គ្រន់បាច[៨]។

## ២. ទ្រឹស្តីពាក់ព័ន្ធ

ភាពពេញចិត្តរបស់អតិថិជន គឺសំដៅទៅដល់ភាពរីករាយនៅពេលអតិថិជនទទួលបានអ្វីមួយផ្គាប់តាមតម្រូវការរបស់ពួកគេ ឬក៏ជាភាពយល់ច្បាស់អំពីចំណង់ចំណូលចិត្តរបស់ពួកគេដែលបានផ្តល់ឱ្យដោយឥតគិតថ្លៃ និងមានការសួរនាំផងដែរ។ ភាពពេញចិត្តរបស់អតិថិជន គឺជាការវាស់វែងនៃភាពពេញចិត្តរបស់អតិថិជនមានចំពោះផលិតផលសេវាកម្ម ឬដំណើរការលក់ផ្សេងៗទៀតរបស់ស្ថាប័នរួមទាំងសេវាកម្មអតិថិជនផងដែរ[៩]។

អតិថិជនថាជា បុគ្គល ឬអង្គភាព ដែលដើរតួនាទីក្នុងការបំពេញប្រតិបត្តិការជាមួយអ្នកទីផ្សារ បានកំណត់ដោយ ហ្សីត និងអ្នកស្រាវជ្រាវផ្សេងទៀត[១០]។

ភក្តីភាពរបស់អតិថិជននៅក្នុងការសិក្សានេះ ត្រូវបានកំណត់ថាជាភាពស្មោះត្រង់របស់អតិថិជន និងការប្តេជ្ញាចិត្តចំពោះអាជីវកម្ម។ រង្វាស់នៃភក្តីភាព ដែលជារឿយៗផ្អែកលើចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ កម្រិតនៃភាពពេញចិត្ត ភាពញឹកញាប់នៃការទិញ ភាពស្មោះត្រង់ ភាពប្រែប្រួលនៃតម្លៃ និង ភាពស្មោះស្ម័គ្រនៃម៉ាកយីហោ។ មានការពន្យល់គ្រប់គ្រាន់មួយ សម្រាប់ភក្តីភាពរបស់អតិថិជន ដែលថា ភក្តីភាពរបស់អតិថិជន អាចត្រូវបាន

---

[៧] Ferguson, G. A. (1981). Statistical analysis in Psychology and Education (5th ed.). Tokyo: Kasodo printing co. ltd, 16(2). https://doi.org/10.3102/10769986016002145

[៨] Cronbach, L. J. (1990). Essentials of Psychological Testing. New York: Harper & Row, 13 (3). DOI: https://doi.org/10.47750/pegegog.13.03.39

[៩] Janahi, M. A., & Almubarak, M. (2017). The Impact of Customer Service Quality on Customer Satisfaction in Islamic Banking. Journal of Islamic Marketing, 8, pp 595–604. https://doi.org/10.1108/JIMA-07-2015-0049

[១០] Sheth, B., Mittal, J. N., & Newman, B. I., (1999). Customer Behaviour: Consumer Behaviour and Beyond, London: Dryden. pp 52. ISBN: 003098016X

កំណត់ថាជាផ្នែកនៃម៉ាកយីហោនិងប្រតិកម្មអាកប្បកិរិយាទៅតាមពេលវេលា ដែលបុគ្គលម្នាក់ចង់ទិញអ្វីមួយពីម៉ាកយីហោនោះជាក់លាក់ជាងម៉ាកយីហោផ្សេងទៀត[១១]។

ទីផ្សារគឺជាសំណុំនៃអថេរដែលអាចគ្រប់គ្រងបាន ដោយសារក្រុមហ៊ុនរួមបញ្ចូលគ្នានូវអថេរ ដែលអាចគ្រប់គ្រងបានទាំងនេះហើយ ដើម្បីបង្កើតប្រតិកម្មដែលចង់បាននៅក្នុងទីផ្សារគោលដៅ។ ភាពពេញចិត្តរបស់អតិថិជនអាចចាត់ទុកថាជាតម្លៃយល់ឃើញ និងតម្លៃរំពឹងទុករបស់អតិថិជន។ ប្រសិនបើតម្លៃដែលយល់ឃើញ គឺស្របតាមតម្លៃដែលរំពឹងទុករបស់អតិថិជននោះអតិថិជននឹងមានភាពពេញចិត្ត[១២]។

ការយល់ដឹងពីអ្វីដែលអតិថិជនរំពឹងទុក គឺជាកត្តាដ៏សំខាន់បំផុតមួយក្នុងការផ្តល់នូវគុណភាព សេវាកម្មល្អ។ ហើយការរំពឹងទុករបស់អតិថិជននេះ គឺជាស្តង់ដានៃការអនុវត្តធៀបនឹងបទពិសោធន៍ និងសេវាកម្មណាមួយដែលត្រូវបានប្រៀបធៀប។ ភាពខុសគ្នារវាងអ្វីដែលអតិថិជនរំពឹងទុក និងការយល់ឃើញរបស់អ្នកផ្តល់សេវា គឺបានបង្កើតគម្លាតនៃការរំពឹងទុករបស់អតិថិជន ដូចជា អតិថិជនមិនពេញចិត្តចំពោះផលិតផល ឬសេវាកម្មណាមួយ។ នេះពិតជាមានសារៈសំខាន់សម្រាប់ក្រុមហ៊ុនក្នុងការរក្សាគម្លាតរវាងការរំពឹងទុក និងការយល់ឃើញរបស់អតិថិជន ដើម្បីបំពេញចិត្តអតិថិជន និងបង្កើតទំនាក់ទំនងរយៈពេលវែងជាមួយពួកគេ[១៣]។

ភាពពេញចិត្តរបស់អតិថិជនថាជា អាកប្បកិរិយាដែលបង្កើតឡើងនៅលើមូលដ្ឋាននៃបទពិសោធន៍ទិញរបស់ពួកគេ បន្ទាប់ពីអតិថិជនទទួលបានផលិតផល ឬប្រើប្រាស់សេវាកម្មមួយ។

ការជឿទុកចិត្តរបស់អតិថិជនជាគំនិត អារម្មណ៍ឬអាកប្បកិរិយាដែលបានបង្ហាញនៅពេលដែលអតិថិជនមានអារម្មណ៍ថាអ្នកផ្តល់សេវាកម្មអាចឱ្យពួកគេអាចពឹងផ្អែកលើហើយ

---

[១១] Wahab, N.A., Hassan, L.F.A., Shahid, S.A.M. & Maon, S.N. (2016), "The relationship between marketing mix and customer loyalty in hijab industry: the mediating effect of customer satisfaction", Procedia Economics and Finance, 37(16), pp 366–371.

[១២] Kotler, Ph., & Armstrong, G. (2004). Principles of Marketing (10th ed). Upper Saddle River,NJ: Pearson, Prentice Hall, 20(1). ISBN: 9780131018617

[១៣] Zeithaml, V. A. & Bitner, M. J. (2003). Services Marketing - Integrating Customers Focus across the Firm, (3rd ed.). Boston: McGraw-Hill. ISBN: 9780071199148

ដើម្បីបម្រើផលប្រយោជន៍របស់ពួកគេនៅពេលដែលពួកគេបានលះបង់គោលគំនិតផ្ទាល់ខ្លួន ហើយបែរមកជឿទុកចិត្តលើអ្នកផ្តល់សេវាវិញ[១៤]។

ភាពពេញចិត្តរបស់អតិថិជន ក៏អាចទទួលបានតាមរយៈគុណភាពនៃផលិតផល ឬសេវាកម្មល្អ។ គុណភាពនៃផលិតផល និងសេវាកម្មត្រូវបានភ្ជាប់ដោយផ្ទាល់ជាមួយនឹងភក្ដីភាពរបស់អតិថិជន។ ដូចគ្នានេះផងដែរ កម្រិតនៃរូបភាពម៉ាកយីហោ គឺត្រូវបានភ្ជាប់ដោយផ្ទាល់ជាមួយនឹងកម្រិតនៃភក្តីភាពរបស់អតិថិជន[១៥]។

ការសម្រេចចិត្តទិញរបស់អតិថិជនពាក់ព័ន្ធនឹងកត្តាមួយចំនួនថែមទៀត ក្នុងនោះកត្តាដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់អតិថិជន គឺតម្លៃនៃទំនិញ និងសេវាកម្ម។ តម្លៃជាធាតុសំខាន់នៅក្នុងអាកប្បកិរិយារបស់អតិថិជន និងការប្រកួតប្រជែង ហើយការផ្អែកលើតម្លៃទាបតែមួយគឺមិនគ្រប់គ្រាន់នោះទេ។ តម្លៃមានសារៈសំខាន់ណាស់ក្នុងការដែលអាចប្រមើមើលពីតម្រូវការរបស់អតិថិជន ហើយតម្លៃអាចជួយកែលម្អការលក់សម្រាប់អ្នកលក់រាយ[១៦]។

ក្រៅពីតម្លៃដើរតួជាសូចនាករសម្រាប់ភាពពេញចិត្តរបស់អតិថិជនហើយ បរិយាកាសដែលមានជាភាពប្រណិត រចនាបទ បរិស្ថាន ក៏ចាត់ចូលជាផ្នែកមួយនៃភាពពេញចិត្តរបស់អតិថិជនដែរ សារៈសំខាន់នៃបរិយាកាសជាឧបករណ៍ទីផ្សារ[១៧]។

សព្វថ្ងៃនេះ ដើម្បីរក្សាទំនាក់ទំនងជាមួយអតិថិជន អ្នកបម្រើសេវាកម្មដល់អតិថិជនតែងតែប្រើពាក្យថា៖ "អតិថិជន គឺត្រូវជានិច្ច" និន្នាការនេះ ត្រូវបានផ្តល់សារៈសំខាន់យ៉ាងខ្លាំង។ ក្រុមហ៊ុនដែលបានអនុវត្តគំនិតនៃការគ្រប់គ្រងទំនាក់ទំនងអតិថិជន គឺជាក្រុមហ៊ុនជោគជ័យបំផុតដោយមិនគិតពីវិស័យអាជីវកម្មរបស់ពួកគេ ព្រោះពួកគេបានយល់ឃើញ

---

[១៤] Patrick, A.S. (2002). Building trustworthy software agents. Journal of IEEE Internet Computing, 6(6), pp 46–53.

[១៥] Clottey, T., Collier D., & Stodnick, M. (2008). Drivers of Customer Loyalty in a Retail Store Environment. Journal of Service Science, 1(1), pp 35–48.

[១៦] Rosa, T. (2001). Customer satisfaction key to better retail sales. Caribbean Business, 29(34), pp 23–25.

[១៧] Kotler, P. (1973). Atmospherics as a Marketing Tool. Journal of Retailing, 49, pp 48–64.

ពីគុណតម្លៃពិតរបស់អតិថិជន។ ដូច្នេះ ការគ្រប់គ្រងទំនាក់ទំនងរបស់អតិថិជន និងទំនាក់ទំនងជាមួយភាគីផ្សេងៗទាមទារឱ្យមានវប្បធម៌តម្រង់ទិសសេវាកម្មជាចាំបាច់[១៨]។

អាជីវកម្មភាគច្រើនយល់ពីការចំណាយដើម្បីទទួលបានអតិថិជន ប៉ុន្តែពួកគេមិនបានដឹងពីការផ្តោតលើគុណតម្លៃសម្រាប់អតិថិជនឱ្យបានពេញលេញនោះទេ។ មានហេតុផលមួយចំនួនដែលអាចនៅពីក្រោយ ដែលអតិថិជនឈប់ប្រើប្រាស់ផលិតផល ឬសេវាកម្មក្រុមហ៊ុន ដូចជាភាពមិនប្រាកដប្រជានៃការចាកចេញរបស់ពួកគេ ការមិនយល់ពីតម្លៃរបស់អតិថិជនជាដើម។ សេវាកម្មមិនល្អ ទំនិញអន់ និងគុណភាពដែលមិនត្រូវនឹងតម្រូវការរបស់អតិថិជនភាគច្រើនតែងជាលទ្ធផលនៃការផ្តល់តម្លៃដល់អតិថិជនឱ្យឈប់រំពឹងទុកថានឹងបន្តការទិញទៀត។ តម្លៃមិនសំដៅទៅលើតម្លៃជាទំនិញដែលគិតជាចន្លសាច់ប្រាក់ទេ តែគឺសំដៅទៅលើអត្ថប្រយោជន៍ដែលគេយល់ឃើញថាទទួលបានក្នុងបរិបទនៃគុណតម្លៃ (Value)។ តម្លៃរបស់អតិថិជន នៅក្នុងអាជីវកម្មមានការបកស្រាយខុសៗគ្នា។ តម្លៃរបស់អតិថិជនសំដៅលើអ្វីដែលអតិថិជនទទួលបាននៅក្នុងផលិតផល ឬសេវាកម្ម។ ចំណែកតម្លៃរបស់អតិថិជននៅក្នុងអាជីវកម្ម គឺជាជំហរដែលរក្សាក្រុមហ៊ុនបានក្នុងការដំណើរការអាជីវកម្ម។ គោលបំណងចម្បងរបស់អង្គភាព អាជីវកម្ម គឺការព្យាយាមធ្វើឱ្យមានភាពច្បាស់លាស់ក្នុងការបង្កើតតម្លៃរបស់អតិថិជន ដើម្បីទាក់ទាញ និងរក្សាបាននូវគុណភាព ក៏ដូចជាតម្លៃដ៏ប្រសើរនៃអាជីវកម្មដល់អតិថិជន[១៩]។

ភក្តីភាពពិតប្រាកដមាននៅពេលដែលអតិថិជន មានអាកប្បកិរិយាវិជ្ជមានចំពោះម៉ាកយីហោជាក់លាក់ ហើយបានបណ្តាលឱ្យមានការទិញម្តងទៀត។ ហើយបន្ថែមពីនេះ ភក្តីភាពរបស់អតិថិជន គឺពិតជាផលវិបាកនៃដំណើរការស្មុគស្មាញផ្លូវចិត្ត។ ការសិក្សាបង្ហាញថា មនុស្សទិញម៉ាកយីហោនោះម្តងទៀតព្រោះមិនចាប់អារម្មណ៍ និងគ្មានពេលគ្រប់គ្រាន់ក្នុងការស្វែងរកម៉ាកយីហោថ្មី។

[១៨] Kumar, V. & Petersen A. J. (2012). Customer relationship management. United Kingdom: John Wiley & Sons, Ltd. 30(12), pp 2725–2729. DOI: 10.1093/molbev/mst197

[១៩] Jobber & Chadwick, (2012). EBOOK: Principles and Practice of Marketing, Nine Edition. McGraw-Hill Education. London. ISBN-13 9781526847232

អាកប្បកិរិយាសំខាន់ៗដែលរំពឹងទុករបស់អតិថិជនដែលមានភក្ដីភាពរួមមានដូចខាងក្រោម៖

- លទ្ធភាពក្នុងការណែនាំផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនដល់អ្នកដទៃ
- លទ្ធភាពបន្តទិញផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន យ៉ាងហោចណាស់ក្នុងកម្រិតដូចគ្នា
- លទ្ធភាពនៃការទិញផលិតផល និងសេវាកម្មផ្សេងទៀតដែលក្រុមហ៊ុនផ្ដល់ជូន
- ជឿជាក់លើផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនថាល្អជាងដៃគូប្រកួតប្រជែង
- មិនស្វែងរកអ្នកផ្ដល់សេវាជំនួសយ៉ាងសកម្ម

ផ្ដល់ឱកាសដល់ក្រុមហ៊ុនក្នុងការកែតម្រូវបញ្ហា និងមិនប្រើប្រាស់ចំណុចទាំងនេះជាមូលដ្ឋានសម្រាប់ការសម្របសម្រួលទំនាក់ទំនង ឬការឈប់គាំទ្រនោះទេ[២០]។

ភក្ដីភាពរបស់អតិថិជនគឺជាកត្តាសំខាន់មួយទៀតក្នុងភាពពេញចិត្តរបស់អតិថិជន។ ឥទ្ធិពលនៃភាពពេញចិត្តក្នុងភក្ដីភាព គឺជាប្រធានបទដ៏ពេញនិយមបំផុតក្នុងការសិក្សាអំពីទ្រឹស្ដីទីផ្សារ។ ដូច្នេះ ការសិក្សាជាច្រើនបានបង្ហាញថា ភាពពេញចិត្តនិងភក្ដីភាពមានទំនាក់ទំនងផ្ទាល់រវាងគ្នាទៅវិញទៅមកដោយសារអតិថិជនមានភាពពេញចិត្ត អតិថិជនមានភក្ដីភាព និងមិនពេញចិត្តគឺអាស្រ័យលើអ្នកលក់ ឬអ្នកផ្ដល់សេវាកម្ម[២១]។ គុណភាពផលិតផលក៏ជាកត្តាស្នូលមួយទៀតនៃភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនដែរ។ គុណភាពផលិតផល គឺជាការប្រមូលផ្ដុំនៃលក្ខណៈពិសេស និងលក្ខណៈផលិតផលម៉ាកយីហោដ៏មុតស្រួចដែលរួមចំណែកដល់សមត្ថភាពក្នុងការបំពេញតម្រូវការជាក់លាក់។ គុណភាពផលិតផល ក៏មានវិមាត្រផ្សេងៗគ្នាដូចជា លក្ខណៈពិសេស ការអនុវត្ត ភាពជឿជាក់ ភាពធន់ សេវាកម្ម និងគុណភាពដែលអតិថិជនយល់ឃើញ។ ក្នុងចំណោមវិមាត្រទាំងអស់នេះ ជាតុសំខាន់ៗចំនួនប្រាំ គឺភាពធន់នៃផលិតផល ភាពខុសគ្នានៃផលិតផល ភាពស្រស់ស្អាតរបស់ផលិតផល ភាព

---

[២០] Rahim Ajao Ganiyu. (2012). The Influence of Product Attributes on Consumer Purchase Decision in the Nigerian Food and Beverages Industry: A Study of Lagos Metropoli, 1(4). https://doi.org/10.11634/216796061706211.P15

[២១] Heskett, J.L., Jones, T.O., Loveman, G.W., Sasser, W.E. & Schelsinger, L.A. (2011). "Putting the Service-Profit Chain to Work." Harvard Business Review, 72(2) pp 164–174.

ទាក់ទាញផលិតផល និងសមធម៌ផលិតផល ត្រូវបានប្រើប្រាស់ដើម្បីវាស់ស្ទង់ពីភាពពេញចិត្ត និងភក្តីភាពរបស់អតិថិជន[២២]។

ភក្តីភាពគឺចំណេញច្រើនជាងការចំណាយដើម្បីទទួលបានអតិថិជនថ្មី គឺត្រូវមានការចំណាយច្រើនជាងការរក្សាអតិថិជនដែលមានស្រាប់។ អតិថិជនដែលមានភក្តីភាពនឹងលើកទឹកចិត្តអ្នកដ៏ទៃឱ្យទិញពីអ្នក ហើយពួកគេគិតច្រើនជាងពីរដងមុននឹងប្តូរចិត្តទៅទិញសេវាកម្មផ្សេងទៀត។ ភក្តីភាពរបស់អតិថិជន ត្រូវបានបង្កើតឡើងតាមពេលវេលាឆ្លងកាត់ប្រតិបត្តិការជាច្រើន ហើយទំនាក់ទំនងជាមួយ អតិថិជនគឺមានសារៈសំខាន់ដូចគ្នា នៅក្នុងភក្តីភាពរបស់អតិថិជន[២៣]។

ទំនាក់ទំនងរវាងភាពពេញចិត្តរបស់អតិថិជន និងភក្តីភាពរបស់អតិថិជនត្រូវបានស្វែងយល់ដោយអ្នកស្រាវជ្រាវជាច្រើន។ ភាពពេញចិត្តរបស់អតិថិជនត្រូវបានគេស្គាល់ថាជាអថេរសម្របសម្រួលដែលអាចនាំមកនូវការកែប្រែចំពោះភក្តីភាពរបស់អតិថិជន[២៤]។

ទំនាក់ទំនងរវាងការតំរង់ទិសរបស់សេវាកម្មនិងគុណភាពសេវាកម្ម សិល្បៈនៃការរក្សាអតិថិជន គឺជាយុទ្ធសាស្ត្រនៃការបង្កើនភាពពេញចិត្តនិងភក្តីភាព។ ដូចដែលបានលើកឡើងនៅពីខាងដើម ភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនគឺជាប់ទាក់ទងគ្នា ទោះបីជាការកសាងមានលក្ខណៈខុសគ្នាទៅវិញទៅមកក៏ដោយ។ ភក្តីភាពរបស់អតិថិជន ត្រូវបានគេហៅថាជាលទ្ធផលចុងក្រោយទាំងមូល ជាមួយនិងបទពិសោធន៍ដែលអតិថិជនមានជាមួយក្រុមហ៊ុនតាំងពីចំណុចចាប់ផ្តើម។ ភាពពេញចិត្តរបស់អតិថិជននាំទៅរកការមានភក្តីភាព

---

[២២] Kabu, K. & Soniya, M. (2017). Customer Satisfation and Customer Loyalty in Trivsel Stadtjanter. Journal of Centria University of Applied Sciences, Business Management, 1, pp 56–58.

[២៣] Thomas, G. (2011). A typology for the case study in social science following a review of definition, discourse, and structure. Qualitative Inquiry, 17, pp 511–521.

[២៤] Wang, I.-M., Shieh, C.-J. & Hsiao, J. (2005), "The relationship between service quality, customer satisfaction and customer loyalty: a study on the management consulting industry", Journal of Information and Optimization Sciences, 26(2), pp 371–384.

របស់អតិថិជន ដោយសារមនុស្សមានបទពិសោធន៍ល្អជាមួយផលិតផល និងសេវាកម្មរួច ហើយដែលបានផ្តល់ដោយក្រុមហ៊ុន[២៥]។

# ៣. លទ្ធផល និងការពិភាក្សា

## ៣.១. លទ្ធផល

### ៣.១.១. ប្រជាសាស្ត្រ

ព័ត៌មានប្រជាសាស្ត្ររបស់ភាគសំណាកអង្កេតគោលដៅរួមមាន៖ ភេទ អាយុ កម្រិតវប្បធម៌ មុខរបរ និងប្រាក់ចំណូល (ប្រចាំខែ)។ ភាគសំណាកគោលដៅ សម្រាប់ការសិក្សានេះ ជាអតិថិជនដែលបានមកទទួលសេវាកម្មក្នុងហាងគោលដៅទាំង ៥ មានចំនួន ២៥០នាក់ បានបំពេញកម្រងសំណួរអង្កេត។

**តារាង៤.១- ចំនួនអតិថិជនបែងចែកតាមភេទ**

| ភេទ | ចំនួន | % | Valid % | Cumulative % |
|---|---|---|---|---|
| ប្រុស | ១៤៤ | ៥៧,៦ | ៥៧,៦ | ៥៧,៦ |
| ស្រី | ១០៦ | ៤២,៤ | ៤២,៤ | ១០០ |
| **សរុប** | **២៥០** | **១០០** | **១០០** | |

តារាងទី៤.១ខាងលើ ការវិភាគបង្ហាញអំពីចំនួនអតិថិជនក្នុងចំណោមសំណាកហាងគោលដៅទាំង៥ ដែលយើងបានប្រមូលទិន្នន័យ និងបញ្ចូលក្នុងកម្មវិធីវិភាគស្ថិតិ ក្នុងនោះមានអ្នកចូលរួមសរុប ២៥០នាក់ ដោយមានការបែងចែកក្រុមភាគសំណាកគោលដៅទៅតាមភេទរួមមាន៖ ១) អតិថិជនភេទប្រុសមានចំនួន ១៤៤នាក់ ត្រូវជា ៥៧,៦ភាគរយ និង ២) អតិថិជនភេទស្រីមានចំនួន ១០៦នាក់ ត្រូវជា ៤២,៤ភាគរយ។

[២៥] Schneider, B., & Bowen, D. E. (1985). Employee and customer perceptions of service in banks: Replication and extension. Journal of Applied Psychology, 70(3), pp 423–433. https://doi.org/10.1037/0021-9010.70.3.423

### ៣.១.២. កម្រិតភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជន

តារាង៤.២-តារាងតម្លៃមធ្យមនៃផ្នែកគាំទ្រទាំង៦

| **អថេរ** | **មធ្យម** | **គម្លាតស្តង់ដា** | **អត្ថន័យ** |
|---|---|---|---|
| ផ្នែកផលិតផល | ៣,៣៨ | ០,៥៥ | មធ្យម |
| ផ្នែកការចែកចាយ | ៣,៤៣ | ០,៥៩ | មធ្យម |
| ផ្នែកសេវាកម្មក្រោយពេលលក់ | ៣,៣៦ | ០,៦០ | មធ្យម |
| ផ្នែកការលក់ និងយុទ្ធសាស្ត្រទំនាក់ទំនង | ៣,២៦ | ០,៥៥ | មធ្យម |
| ផ្នែកភាពពេញចិត្តរបស់អតិថិជន | ៣,៤៥ | ០,៥៧ | មធ្យម |
| ផ្នែកភក្ដីភាពរបស់អតិថិជន | ៣,២៩ | ០,៥៥ | មធ្យម |
| សរុបភាពពេញចិត្តនិងភក្ដីភាព | ៣,៣៦ | ០,៥១៦ | មធ្យម |

សរុបសេចក្ដីមក ភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា ជារួមមានតម្លៃមធ្យមដោយមាន (តម្លៃមធ្យម = ៣,៣៦ និងគម្លាតស្តង់ដា = ០,៥១៦)។ បើមើលនៅតាមផ្នែកនីមួយៗ ដូចជា៖ ១- ផ្នែកផលិតផល (តម្លៃមធ្យម = ៣,៣៨ និងគម្លាតស្តង់ដា = ០,៥៥) ២-ផ្នែកការចែកចាយ (តម្លៃមធ្យម = ៣,៤៣ និងគម្លាតស្តង់ដា = ០,៥៩) ៣- ផ្នែកសេវាកម្មក្រោយពេលលក់ (តម្លៃមធ្យម = ៣,៣៦ និងគម្លាតស្តង់ដា = ០,៦០) ៤- ផ្នែកការលក់ និងយុទ្ធសាស្ត្រទំនាក់ទំនង (តម្លៃមធ្យម = ៣,២៦ និងគម្លាតស្តង់ដា = ០,៥៥) ៥- ផ្នែកភាពពេញចិត្តរបស់អតិថិជន (តម្លៃមធ្យម = ៣,៤៥ និងគម្លាតស្តង់ដា = ០,៥៧) និង ៦- (តម្លៃមធ្យម = ៣,២៩ និងគម្លាតស្តង់ដា = ០,៥៥)។

### ៣.១.៣. ទំនាក់ទំនងរវាងភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជន

**តារាង៤.៣- សរុបអន្តរទំនាក់ទំនង (Intercorrelations) រវាងភាគសំណាកអង្កេតគោលដៅទាំង ៦ក្រុម លើភាពពេញចិត្តនិងមានភក្តីភាពរបស់អតិថិជន**

| | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| ១-ផ្នែកផលិតផល | ១,០០០ | ០,៨៣២** | ០,៧៨៧** | ០,៧៨៧** | ០,៨១៥** | ០,៧៥៧** |
| ២-ផ្នែកការចែកចាយ | ០,៨៣២** | ១,០០០ | ០,៨៣២** | ០,៧៦៩** | ០,៨២៥** | ០,៧២៥** |
| ៣-ផ្នែកសេវាកម្មក្រោយពេលលក់ | ០,៧៨៤** | ០,៨៣២** | ១,០០០ | ០,៨០៩** | ០,៨១៣** | ០,៦៨៩** |
| ៤-ផ្នែកការលក់ និងយុទ្ធសាស្ត្រទំនាក់ទំនង | ០,៧៨៧** | ០,៧៦៩** | ០,៨០៩** | ១,០០០ | ០,៧៧៣** | ០,៧៥៧** |
| ៥-ផ្នែកភាពពេញចិត្តរបស់អតិថិជន | ០,៨១៥** | ០,៨២៥** | ០,៨១៣** | ០,៧៧៣** | ១,០០០ | ០,៧៧៨** |
| ៦-ផ្នែកភក្តីភាពរបស់អតិថិជន | ០,៧៥៧** | ០,៧២៥** | ០,៦៨៩** | ០,៧៥៧** | ០,៧៧៨** | ១,០០០ |

តារាងទី៤.៤៤ ខាងលើ បានបង្ហាញពីភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកទាំង៥ ដែលធ្វើឡើងនៅរាជធានីភ្នំពេញលើផ្នែកទាំង៦ (ផ្នែកផលិតផល ផ្នែកការចែកចាយ ផ្នែកសេវាកម្មក្រោយពេលលក់ ផ្នែកការលក់ និងយុទ្ធសាស្ត្រទំនាក់ទំនង ផ្នែកភាពពេញចិត្តរបស់អតិថិជន និងផ្នែកភក្តីភាពរបស់អតិថិជន) លទ្ធផលនៃការវិភាគ បង្ហាញថាផ្នែកទាំងប្រាំមួយមានទំនាក់ទំនងវិជ្ជមាន។

លទ្ធផលសំខាន់ៗនៃការសិក្សានេះអាចសរុបបាន ដូចខាងក្រោមៈ

១- ភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា ជារួមនិងដោយឡែក ស្ថិតនៅកម្រិតមធ្យម។ បើរៀងលំដាប់តម្លៃមធ្យម ពីខ្ពស់បំផុតទៅទាបបំផុតគឺៈ "ភាពពេញចិត្តរបស់អតិថិជន" "ការចែកចាយ" "ផលិតផល" "សេវាកម្មក្រោយពេលលក់" "ភក្តីភាពរបស់អតិថិជន" និង "ការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង" តាមលំដាប់។

២- ភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា មានទំនាក់ទំនងជាមួយផ្នែកទាំង៦ (ផ្នែកផលិតផល ផ្នែកការចែកចាយ ផ្នែកសេវាកម្មក្រោយពេលលក់ ផ្នែកការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង ផ្នែកភាពពេញចិត្តរបស់អតិថិជន និងផ្នែកភក្ដីភាពរបស់អតិថិជន) និងវិជ្ជមាន។

## ៣.២. ការពិភាក្សា

អន្តរទំនាក់ទំនងលើភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកទាំង៥ដែលធ្វើឡើងនៅរាជធានីភ្នំពេញលើផ្នែកទាំង៦ (ផ្នែកផលិតផល ផ្នែកការចែកចាយ ផ្នែកសេវាកម្មក្រោយពេលលក់ ផ្នែកការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង ផ្នែកភាពពេញចិត្តរបស់អតិថិជន និងផ្នែកភក្ដីភាពរបស់អតិថិជន) របស់ភាគសំណាកទាំងអស់ឃើញថាមានសារៈសំខាន់និងមានទំនាក់ទំនងគ្នាជាវិជ្ជមាន។ ទំនាក់ទំនងនេះ បានរួមបញ្ចូលផ្នែកគាំទ្រទាំងពីរគឺ ១-ផ្នែកការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង និង ២-ផ្នែកភក្ដីភាពរបស់អតិថិជន ជាផ្នែកដែលមិនមានភាពខុសគ្នានោះទេ តាមរយៈការវិភាគ និងបំណកស្រាយបានបង្ហាញថា អតិថិជនហាក់មិនសូវមានភាពពេញចិត្ត មានភាពប្ដេជ្ញាចិត្ត និងភក្ដីភាពចំពោះសំណាកហាងគោលដៅឡើយ។ ដោយអតិថិជនគោលដៅមិនសូវជាខ្វល់ខ្វាយពីការលក់ និងយុទ្ធសាស្ត្ររបស់ហាងទេ តម្រូវការចង់បានពីហាង គឺអតិថិជនគ្រាន់តែចង់ទិញភេសជ្ជៈ និងអាហារដោយថៃដន្យ ឬទិញជាប្រចាំប៉ុណ្ណោះ។

ដូចនេះ អតិថិជនដែលមានកត្តាចន្លោះអាយុខុសគ្នា គឺមានទស្សនៈខុសគ្នា លើភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកទាំង ៥ ដែលធ្វើឡើងនៅរាជធានីភ្នំពេញ។

### ៣.២.១. ការពិភាក្សាស្ដីពីកម្រិតភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជន

តាមលទ្ធផលដែលទទួលបានរកឃើញថា អតិថិជនគោលដៅ មានភាពពេញចិត្តនិងភក្ដីភាពកម្រិតមធ្យមចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា។ លទ្ធផលនេះអាចពន្យល់បានថាគ្រប់ហាងសំណាកគោលដៅ គឺនៅមានភាពចន្លោះខ្វះខាតនៅឡើយដែលភាពកម្សោយនេះបន្ទាប់ពីអ្នកស្រាវជ្រាវបានចុះទៅដល់ហាង និងបានធ្វើការស្ទង់មតិអតិថិជនតាមរយៈកម្រងសំណួរ ឃើញថាមានកត្តាមួយចំនួនដូចជាអតិថិជនកម្ពុជាមានភាពពេញចិត្ត

និងភក្តីភាពស្ថិតនៅកម្រិតមធ្យមដោយអាចមានហេតុផលជាច្រើនដូចជា តម្លៃនិងស្តង់ដាម្ហូបឆ្ងាញ់អតិថិជនយល់ថាតម្លៃលក់ថ្លៃនោះគឺមានស្តង់ដា, កង្វះខាតប្រអប់ព័ត៌មាននិងប្រអប់ធីបនៅតាមហាងនីមួយៗ, បទពិសោធន៍របស់អតិថិជនពីការដូរជូនវិញនូវផលិតផលខូច, ការសម្របសម្រួលនិងមានដំណោះស្រាយជាបន្ទាន់, ការចេញមីនុយមុខម្ហូបឬភេសជ្ជៈថ្មីៗ, ព័ត៌មានបច្ចុប្បន្នភាពរបស់ហាង, សេវាកម្មដឹកជញ្ជូនទូលំទូលាយ, គោលបំណងចង់ទិញផលិតផលថ្មី, និងចង់ទិញនៅពេលខាងមុខទៀត ហាក់ដូចជាមិនសូវមានសញ្ញាណវិជ្ជមានច្បាស់លាស់ អាចទំនងជាទៅតាមកាលៈទេសៈនិងការសាកល្បងថ្មីបើមានហាងម៉ាកយីហោដទៃថ្មីទើបនឹងបើកដំណើរការ។ ការត្រឡប់មកគាំទ្រហាងគោលដៅម្តងទៀតដរាបណាហាងកាហ្វេបង្កើតក្នុងស្រុកនោះនៅតែរក្សាតម្លៃដើម ឬឡើងថ្លៃបន្តិចបន្តួចប៉ុណ្ណោះនេះស្តែងចេញពីចេតនារបស់អតិថិជនលើកម្រិតនៃភាពពេញចិត្ត គឺមិនសូវមានភក្តីភាពចំពោះហាងគោលដៅនៅឡើយទេ។

ទន្ទឹមនឹងនេះ កម្រិតភាពមធ្យមនៃភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជន រួមមានអតិថិជនបានមានភាពពេញចិត្តលើសេវាកម្មដែលមានផាសុកភាព ដូចជាបរិយាកាសហាង ការរៀបចំរចនាបទហាង គ្រឿងបរិក្ខារ ទំហំហាង សម្លេងតន្ត្រី ភាពស្ងប់ស្ងាត់នៅបរិវេណសួនខាងក្រៅហាងជាដើម ដែលបានធ្វើឱ្យអតិថិជនមានភាពស្ងប់ក្នុងការអញ្ជើញមកពិសារកាហ្វេ និងផ្ចង់អារម្មណ៍ធ្វើការ និងសិក្សារៀនសូត្រ របៀបនៃការវេចខ្ចប់ម្ហូប និងភេសជ្ជៈបានល្អនៅតាមហាងគោលដៅ។

**៣.២.២. ការពិភាក្សាស្តីពីទំនាក់ទំនងរវាងភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជន**

តាមរយៈលទ្ធផលបង្ហាញថា មានទំនាក់ទំនងគ្នារវាងភាពពេញចិត្តនិងភក្តីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកទាំង៥ដែលធ្វើឡើងនៅរាជធានីភ្នំពេញលើផ្នែកទាំង៦ (ផ្នែកផលិតផល ផ្នែកការចែកចាយ ផ្នែកសេវាកម្មក្រោយពេលលក់ ផ្នែកការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង ផ្នែកភាពពេញចិត្តរបស់អតិថិជន និងផ្នែកភក្តីភាពរបស់អតិថិជន)។ ក្នុងនោះផ្នែកមានទំនាក់ទំនងមធ្យមមាំទាំជាង មានចំនួន៤ គឺផ្នែកផលិតផលផ្នែកការចែកចាយ ផ្នែកសេវាកម្មក្រោយពេលលក់ និងផ្នែកភាពពេញចិត្តរបស់អតិថិជន។

ទាំងនេះបង្ហាញថាអតិថិជនដែលបានប្រើប្រាស់ផលិតផលនៅក្នុងហាងគោលដៅ និងមានការយល់ឃើញ ហើយបានចូលរួមក្នុងការសិក្សាអង្កេតនេះមានការយល់ស្របត្រឹមកម្រិតមធ្យម។ ផ្នែកការលក់យុទ្ធសាស្ត្រទំនាក់ទំនង និងផ្នែកភក្តីភាពរបស់អតិថិជនមានកម្រិតពីមធ្យមទៅកម្រិតទាប។ លទ្ធផលនេះ អាចបណ្តាលមកពីមូលហេតុ ដូចជា អតិថិជនបានចូលទិញ និងប្រើប្រាស់សេវាកម្មដោយចៃដន្យ និងមិនសូវយកចិត្តទុកដាក់សំខាន់ប៉ុន្មានលើចំណុចក្នុងផ្នែកការលក់និងយុទ្ធសាស្ត្រទំនាក់ទំនង។ អតិថិជនអាចពេញចិត្តចំពោះផលិតផល និងសេវាកម្មផ្សេងៗរបស់សំណាកហាងគោលដៅ តែហាក់មិនប្រាកដប្រជាក្នុងការក្លាយជាម៉ូយប្រចាំ ឬអាចឈានទៅរកការទិញម្តងទៀត និងមិនច្បាស់លាស់ជាអតិថិជនដែលមានភក្តីភាពចំពោះហាង។

**៣.២.១. បញ្ហាប្រឈម**

ដើម្បីទទួលបានភាពជោគជ័យក្នុងអាជីវកម្មលើហាងកាហ្វេបង្កើតក្នុងស្រុក នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជាត្រូវការ ការធ្វើទីផ្សារ ការគិតគូរពីយុទ្ធសាស្ត្រ ការស្វែងរករូបមន្តដំណាក់គ្រាប់ពូជកាហ្វេ បទពិសោធន៍ និងបច្ចេកទេសក្នុងការផលិត ផលិតផល បូករួមជាមួយសេវាកម្ម ការរចនាបរិយាកាសឱ្យមានផាសុកភាព និងស្តង់ដា ដោយអាចតម្រូវតាមការចង់បាន និងឆ្លើយតបនូវតម្រូវការរបស់អតិថិជនគ្រប់វ័យក្នុងបរិបទសជាតិប្រជាជនក្នុងតំបន់ ឬបរទេសអាចមានលទ្ធភាពទទួលយកបាន និងមានភាពពេញចិត្ត ដើម្បីរក្សាអាជីវកម្មនេះឱ្យមានអាយុកាល និងអាចប្រកួតប្រជែងជាមួយម៉ាកយីហោបរទេសដទៃទៀតដែលមានលំហូរទីផ្សារនៅកម្ពុជា។ ដូចនេះ ដើម្បីរក្សាទឹកចិត្តពេញចិត្តរបស់អតិថិជន និងរក្សាបាននូវអតិថិជនមានភក្តីភាពបាន តាមបណ្តាហាងកាហ្វេបង្កើតក្នុងស្រុករបស់កម្ពុជានីមួយៗ គប្បីយកចិត្តទុកដាក់និងប្រណិបត្តិបន្ថែម លើសេវាកម្មដែលមានស្រាប់ និងកម្រិតផលិតផលឱ្យកាន់តែមានស្តង់ដាដុះដាលតាម បច្ចេកវិទ្យាសម័យ ដោយគោរពរបៀបធ្វើអាជីវកម្មស្មោះត្រង់ តម្លៃល្អ សេវាកម្មល្អ ភាពរួសរាយ ទីតាំងមានផាសុកភាព សម្ភារៈ ការដេគ័រមានរចនាបទ WiFi ល្បឿនលឿន និងត្រូវមានសេវាកម្មក្រោយៗបន្ថែមទៀត ដូចជាពង្រីកដៃគូដឹកជញ្ជូន ការផ្សព្វផ្សាយ ការចេញបញ្ជីមុខម្ហូប ភេសជ្ជៈថ្មី ជាដើម។

ក្នុងន័យនេះ ដើម្បីជួយបង្កើនភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជន ការសិក្សានេះធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកកម្រិតនៃភាពពេញចិត្ត ការបង្កើតទំនាក់ទំនងនៃភាពពេញចិត្តរបស់អតិថិជន និងភក្ដីភាពរបស់អតិថិជនស្ថិតនៅក្នុងទិសដៅល្អ ថែមទាំងមានទំនុកចិត្ត តែក៏នឹងមានចំនុចមួយចំនួនត្រូវកែតម្រូវខ្លះៗដូចជា ប្រព័ន្ធផ្សព្វផ្សាយនៅមានកម្រិត មិនសូវមានការចេញនូវបញ្ចីមុខម្ហូបភេសជ្ជៈថ្មីៗ គុណភាពផលិតផល បូករួមជាមួយតម្លៃហាក់នៅមិនទាន់សមរម្យល្មមសម្រាប់បរិបទកម្ពុជា ស្របនឹងម៉ាកឃីហោបរទេសយុទ្ធសាស្ត្រទំនាក់ទំនងនិងសេវាកម្មលក់ ដូចជាមានគោលការណ៍ការប្តូរជូនអតិថិជនវិញនូវផលិតផលខូច ការធ្វើប្រម៉ូសិននិងការបញ្ចុះតម្លៃតាមមុខម្ហូបនិងភេសជ្ជៈថ្មីៗ ការមានពត៌មានគ្រប់ជ្រុងជ្រោយដល់អតិថិជន ការបង្កើតសកម្មភាពសាធារណៈរវាងអតិថិជនដែលបានមកទទួលសេវាកម្មជាជាងតែនៅក្នុងក្រុមអតិថិជន ការដាក់នូវប្រអប់មានមតិរិះគន់និងស្ថាបនាជូនដល់អតិថិជន និងដំណោះស្រាយបន្ទាន់ ការចងចិត្តអតិថិជនពីបទពិសោធន៍ក្រោយការទិញរបស់ពួកគាត់ ដើម្បីជាគន្លឹះឱ្យពួកគាត់មានទឹកចិត្តក្នុងការណែនាំបន្ត និងនៅតែមានភក្ដីភាពត្រឡប់មកកាន់ហាងម្តងហើយម្តងទៀតអាចទៅបាន។

**៣.២.២ ដំណោះស្រាយ**

តាមរយៈការសិក្សាស្រាវជ្រាវ «ភាពពេញចិត្តនិងភក្ដីភាពរបស់អតិថិជនចំពោះហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា (Customer Satisfaction and Loyalty to Local Coffee Shops in Cambodia)» នេះរួចមកមានសំណូមពរសំខាន់ៗមួយចំនួនផ្តល់ជូនដល់ភាគីពាក់ព័ន្ធ មានដូចខាងក្រោម៖

- គួរមានការដូរជូនអតិថិជនវិញនូវផលិតផលខូច
- គួរមានការសម្របសម្រួល និងមានដំណោះស្រាយជាបន្ទាន់ជូនដល់អតិថិជន
- គួរមានព័ត៌មានបច្ចុប្បន្នភាពរបស់ហាង
- គួរមានសេវាកម្មដឹកជញ្ជូនទូលំទូលាយ
- និងគួរមានការចេញមីនុយមុខម្ហូប ឬភេសជ្ជៈថ្មី។

# ៤. សន្និដ្ឋាន និងអនុសាសន៍

## ៤.១. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក តាមរយៈលទ្ធផលនៃការសិក្សា និងការពិភាក្សាវែកញែកទៅលើលទ្ធផលនោះរួចមក ការសិក្សានេះ ពិតជាបានបន្សុីនឹងបរិបទកម្ពុជាដែលឆ្លុះបញ្ចាំងពីគុណភាពផលិតផល សេវាកម្ម ការចែកចាយ យុទ្ធសាស្ត្រក្នុងការធ្វើទីផ្សារ បទពិសោធន៍ភាពពេញចិត្តរបស់អតិថិជន និងកត្តានាំឱ្យមានភក្តីភាព។ ការសិក្សានេះអាចទាញបានជាសេចក្តីសន្និដ្ឋានថា ដើម្បីឱ្យមានភាពពេញចិត្តនិងភក្តីភាពរបស់ អតិថិជនបានល្អគឺទាមទារឱ្យមានការចូលរួមពីសំណាក់អ្នកគ្រប់គ្រងនិងបុគ្គលិករបស់សំណាកហាងគោលដៅ និងការគាំទ្រជាមួយការស្តាបនាពីបណ្តាអតិថិជនផ្ទាល់។ កាលណាដែលអតិថិជនមាន ភាពពេញចិត្តខ្ពស់ នោះភក្តីភាពរបស់ពួកគេកាន់តែលេចចេញមានសញ្ញាណខ្ពស់ដូចគ្នា។ អតិថិជន ហាក់មិនមានសញ្ញាណនៃភាពពេញចិត្ត ឬមិនបានខ្វល់ខ្វាយច្រើនពីផលិតផល ម៉ាកយីហោ និងយុទ្ធសាស្ត្ររបស់ហាងនោះទេ ភាគច្រើនពួកគេសុទ្ធសឹងតែជាអតិថិជនបានចូលទិញ និងបានប្រើប្រាស់សេវាកម្មរបស់ហាងដោយចៃដន្យ ដោយមិនអាចកំណត់បាននូវកម្រិតនៃភាពពេញចិត្ត និងសញ្ញាណជាអតិថិជនមានភក្តីភាពបានច្បាស់លាស់ឡើយ។

## ៤.២. អនុសាសន៍

អនុសាសន៍សម្រាប់ការអនុវត្ត ត្រូវបានដាក់ចេញដូចខាងក្រោម៖

១)- សហគ្រិន និងអ្នកជំនួញ គួរពិចារណា និងគិតគូរដល់៖

- ប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងតាមបែបទាន់សម័យកាល
- មានក្រុមការងារស្រាវជ្រាវ និងបង្កើតរូបមន្តសម្រាប់ការចេញមីនុយថ្មីៗ
- រសជាតិ សេវាកម្ម និងតម្លៃត្រូវបានកំណត់ដោយស្តង់ដាទីផ្សាររួម
- បង្កើតនិងស្វែងរកដៃគូសហការឱ្យបានទូលំទូលាយបន្ថែមទៀត ក្នុងការដឹកជញ្ជូនទៅដល់ទីតាំងរបស់អតិថិជន
- ពង្រីកសាខាតាមខេត្តឱ្យបានច្រើន និងគ្រប់ជ្រុងជ្រោយ
- ការយកចិត្តទុកដាក់ និងដោះស្រាយជូនបន្ទាន់ជូនដល់អតិថិជន

- អភិវឌ្ឍន៍ និងមានលទ្ធភាពនាំយកហាងកាហ្វេបង្កើតក្នុងស្រុកដែលជាម៉ាកយីហោរបស់កម្ពុជាទៅកាន់ទីផ្សារបរទេស
- បើកឱកាសទូលាយ សម្របសម្រួល និងជាជំនួយគាំទ្រដល់អ្នកស្រាវជ្រាវគ្រប់រូប។

២)- បុគ្គលសាធារណៈចង់បើកអាជីវកម្មហាងកាហ្វេបង្កើតក្នុងស្រុកនៅកម្ពុជា គួរស្វែងយល់បន្ថែមអំពី៖

- តម្លៃឱកាសចេញពីការសិក្សាស្រាវជ្រាវនេះ
- ការភ្លក់រសជាតិ និងទទួលយកបទពិសោធន៍ពីគ្រប់បណ្ដាហាងកាហ្វេបង្កើតក្នុងស្រុករបស់កម្ពុជា
- ការចាយថវិកាឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល
- មើលពត៌មានពីអត្ថបទ សិក្សាបន្ថែមនិងចូលរួមសិក្ខាសាលាផ្សេងៗ និងរកអ្នកប្រឹក្សាចំជំនាញនិងវិជ្ជាជីវៈ និងផ្នែកដែលពាក់ព័ន្ធ។

ដើម្បីឱ្យការបកស្រាយស្របនឹងប្រធានបទមានភាពស៊ីជម្រៅ និងកាន់តែមានភាពច្បាស់លាស់បន្ថែមទៀត អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្តមួយចំនួនខាងក្រោមនេះ គួរត្រូវបានពិចារណា៖

១-ការសិក្សានេះបានធ្វើបច្ចុប្បន្នភាពជាមួយបរិបទកម្ពុជា ដែលភាគសំណាកជាអតិថិជននៅរាជធានីភ្នំពេញ។ ដូចនេះ អ្នកស្រាវជ្រាវស្នើដល់អ្នកស្រាវជ្រាវបន្តការសិក្សាស្រាវជ្រាវនាពេលអនាគតគួរតែពង្រីកបន្ថែមនូវតាមបណ្ដាហាង ភាគសំណាកគោលដៅដែលមានសាខានៅតាមខេត្តធំៗ ដូចជា៖ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកំពង់ចាម។ល។ ដើម្បីធ្វើការប្រៀបធៀបលទ្ធផលទាំងពីរនេះ។

២-ការសិក្សាស្រាវជ្រាវនាពេលអនាគត គួរតែធ្វើការអង្កេត ដោយប្រើវិធីសាស្ត្រទាំងបែបគុណវិស័យដើម្បីការសិក្សាស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅលើ កត្តាជំរុញ កត្តាលើកទឹកចិត្ត កត្តាដើមទុន និងកត្តាហិរញ្ញវត្ថុទីផ្សាររួមទាំងតម្រូវការរបស់អតិថិជន និងបញ្ហាប្រឈមដើម្បីវិភាគស៊ីជម្រៅលើបទពិសោធន៍ ទស្សនៈវិស័យ និងជំនឿរបស់ម្ចាស់ហាងម៉ាកយីហោ និងទទួលបានទស្សនៈនិងជម្រើសផ្សេងៗ។

៣-ការសិក្សាតាមបែបចម្រុះ (Mix-Methods) ៖ ការសិក្សាស្រាវជ្រាវបន្តក្នុងពេលអនាគត គួរតែធ្វើជាវិធីសាស្ត្រស្រាវជ្រាវជាពីរដំណាក់កាល ដោយប្រើប្រភេទតាមបែបវិធីសាស្ត្រចម្រុះ (១-បែបបរិមាណវិស័យ ដោយមានការចុះស្ទង់មតិដោយកម្រងសំណួរស្រាវជ្រាវ និងយកលទ្ធផលមកវិភាគដើម្បីសិក្សាលើបែបគុណវិស័យបន្ថែមទៀត និង២-បែបគុណវិស័យដែលមានការសម្ភាសន៍សហគ្រិន និងធ្វើការពិភាក្សាជាក្រុម)។

# ឯកសារយោង


១. Williams & Marshall. (2020). Strategy Research Reports on Beverage's market. Retrieved on May 10, 2020, pp 80.

២. Sinit T.., (2018). Factors Influencing Cambodian's Customer Loyalty In Using The Service At Coffee Shops In Phnom Penh, Cambodia. MBA, Graduate School, Bangkok University, pp 55.

៣. Lee, H. J., Suh, J. Y., & Yoon, K. H., (2013). A comparative study on the effect of experiences on service encounter, customer satisfaction and brand loyalty in the homemade and foreign coffee shop brands – Centered on the moderating role of brand trust. Journal of Food service Management, 16(3), pp 197–227.

៤. Martin, C., Molina & Esteban, (2007). An integrated Model of Price, Satisfaction and loyalty: An Empirical Analysis in The Service Sector. Journal of Product & Brand Management, 16(7), pp 459–468.

៥. Rosa, T., (2001). Customer satisfaction key to better retail sales. Caribbean Business, 29(34), pp 23–25.

៦. Creswell, J. W. (2012). Educational Research: Planning, Conducting, Evaluating, Quantitative and Qualitative Research (4th ed.). United State of America: Pearson Education, Inc

៧. Ferguson, G. A. (1981). Statistical analysis in Psychology and Education (5 th ed.). Tokyo: Kasodo printing co. ltd, 16(2). https://doi.org/10.3102/10769986016002145

៨. Cronbach, L. J. (1990). Essentials of Psychological Testing. New York: Harper & Row, 13 (3). DOI: https://doi.org/10.47750/pegegog.13.03.39

๙. Janahi, M. A., & Almubarak, M. (2017). The Impact of Customer Service Quality on Customer Satisfaction in Islamic Banking. Journal of Islamic Marketing, 8, pp 595–604. https://doi.org/10.1108/JIMA-07-2015-0049

๑๐. Sheth, B., Mittal, J. N., & Newman, B. I., (1999). Customer Behaviour: Consumer Behaviour and Beyond, London: Dryden. pp 52. ISBN: 003098016X

๑๑. Wahab, N.A., Hassan, L.F.A., Shahid, S.A.M. & Maon, S.N. (2016), "The relationship between marketing mix and customer loyalty in hijab industry: the mediating effect of customer satisfaction", Procedia Economics and Finance, 37(16), pp 366–371.

๑๒. Kotler, Ph., & Armstrong, G. (2004). Principles of Marketing (10th ed). Upper Saddle River,NJ: Pearson, Prentice Hall, 20(1). ISBN: 9780131018617

๑๓. Zeithaml, V. A. & Bitner, M. J. (2003). Services Marketing - Integrating Customers Focus across the Firm, (3rd ed.). Boston: McGraw-Hill. ISBN: 9780071199148

๑๔. Patrick, A.S. (2002). Building trustworthy software agents. Journal of IEEE Internet Computing, 6(6), pp 46–53.

๑๕. Clottey, T., Collier D., & Stodnick, M. (2008). Drivers of Customer Loyalty in a Retail Store Environment. Journal of Service Science, 1(1), pp 35–48.

๑๖. Rosa, T. (2001). Customer satisfaction key to better retail sales. Caribbean Business, 29(34), pp 23–25.

១៧. Kotler, P. (1973). Atmospherics as a Marketing Tool. Journal of Retailing, 49, pp 48–64.

១៨. Kumar, V. & Petersen A. J. (2012). Customer relationship management. United Kingdom: John Wiley & Sons, Ltd. 30(12), pp 2725–2729. DOI: 10.1093/molbev/mst197

១៩. Jobber & Chadwick, (2012). EBOOK: Principles and Practice of Marketing, Nine Edittion. McGraw-Hill Education.London. ISBN-13 9781526847232

២០. Rahim Ajao Ganiyu. (2012). The Influence of Product Attributes on Consumer Purchase Decision in the Nigerian Food and Beverages Industry: A Study of Lagos Metropoli, 1(4). https://doi.org/10.11634/216796061706211.P15

២១. Heskett, J.L., Jones, T.O., Loveman, G.W., Sasser, W.E. & Schelsinger, L.A. (2011). "Putting the Service-Profit Chain to Work." Harvard Business Review, 72(2) pp 164–174.

២២. Kabu, K. & Soniya, M. (2017). Customer Satisfation and Customer Loyalty in Trivsel Stadtjanter. Journal of Centria University of Applied Sciences, Business Management, 1, pp 56–58.

២៣. Thomas, G. (2011). A typology for the case study in social science following a review of definition, discourse, and structure. Qualitative Inquiry, 17, pp 511–521.

២៤. Wang, I.-M., Shieh, C.-J. & Hsiao, J. (2005), "The relationship between service quality, customer satisfaction and customer loyalty: a study on the management consulting industry", Journal of Information and Optimization Sciences, 26(2), pp 371–384.

๒๕. Schneider, B., & Bowen, D. E. (1985). Employee and customer perceptions of service in banks: Replication and extension. Journal of Applied Psychology, 70(3), pp 423–433. https://doi.org/10.1037/0021-9010.70.3.423

# សិទ្ធិទទួលបានការអប់រំរបស់ខ្មែរក្រោមនៅកម្ពុជាក្រោម

*បណ្ឌិត* ***ស៊ឹន ជុំជួន***

## មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទ "**សិទ្ធិទទួលបានការអប់រំរបស់ខ្មែរក្រោម នៅកម្ពុជាក្រោម** (Right to Accessed Education of the Khmer Krom in Kampuchea Krom" ក្នុងគោលបំណង ដើម្បីរកឱ្យឃើញពីស្ថានភាពពិតនៃការអប់រំរបស់ខ្មែរក្រោម បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអប់រំរបស់ខ្មែរនៅកម្ពុជាក្រោម បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយសមហេតុផលណាមួយនៃការអប់រំរបស់ខ្មែរក្រោម ក្នុងភាពជាប្រជាពលរដ្ឋមួយរស់នៅប្រកបដោយតម្លៃ និងសេចក្ដីថ្លៃថ្នូរ ដូចជាការរស់នៅរបស់បុគ្គលគ្រប់រូបៗ ត្រូវរួចចាកផុតពីកង្វះខាត់នៃការអប់រំ ការរើសអើងប្រកាន់ពូជសាសន៍ ទទួលបានការអប់រំគ្រប់កម្រិត និង ជីវភាពរស់នៅសមរម្យប្រកបដោយសុខសន្តិភាព និងសុភមង្គល។

ដើម្បីសម្រេចនូវគោលបំណងនៃការស្រាវជ្រាវខាងលើ យើងបានប្រើវិធីសាស្ត្រប្រមូលទិន្នន័យ ដោយផ្អែកទៅលើទិន្នន័យទាំងពីរប្រភេទគឺៈ ទិន្នន័យប្រភេទទី១ (Primary Data) បានពីការចុះធ្វើសម្ភាសន៍ដោយផ្ទាល់ ដោយផ្អែកទៅលើកម្រងសំណួរជាគំរូរបស់សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ និងរបស់អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ ដែលសំណួរទាំងនោះពាក់ព័ន្ធទៅនឹងស្ថានភាពសិទ្ធិទទួលបានការអប់រំរបស់ខ្មែរនៅកម្ពុជាក្រោម ដែលបច្ចុប្បន្នស្ថិតនៅប្រទេសវៀតណាមភាគខាងត្បូង និងទិន្នន័យប្រភេទទីពីរ (Secondary Data) ដែលបានមកពីទិន្នន័យដែលមានស្រាប់ ដូចជារបាយការណ៍ របស់ក្រសួងមន្ទីរពាក់ព័ន្ធការអប់រំរបស់រដ្ឋាភិបាលវៀតណាម របាយការណ៍អប់រំរបស់សមាគមព្រះសង្ឃ សាមគ្គីស្នេហាជាតិ នៃខេត្តត្រាវិញ (ព្រះត្រពាំង) និងការរកឃើញរបស់អ្នកសិក្សាជំនាន់មុន ដែលពាក់ព័ន្ធនឹងការអប់រំរបស់ខ្មែរនៅកម្ពុជាក្រោម ជាដើម។

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ក្នុងទិដ្ឋភាពរួមឃើញថា រដ្ឋាភិបាលវៀតណាមកំពុងតែឈានទៅរកការកសាងប្រទេសជាតិមួយជឿនលឿនសឹងតែគ្រប់វិស័យ ជាពិសេស

ក្នុងវិស័យសេដ្ឋកិច្ច និងដំណើរការនៃការសិក្សាអប់រំ និងបណ្ដុះបណ្ដាល។ រដ្ឋាភិបាលវៀតណាមមានគោលនយោបាយរួបរួមកសាងជាតិសាសន៍តែមួយ ប្រកបទៅដោយសាមគ្គីភាព និងការឯកភាពជាតិ ក្រោមបាវចនាជាតិ ឯករាជ្យ សេរីភាព សុភមង្គល (Doc Lap Tu Do Hanh Phuc)។ និយាយដោយឡែកអំពីជនជាតិភាគតិចនៅប្រទេសវៀតណាមវិញ ជនជាតិដើមភាគតិចមានរហូតទៅដល់៥៤ជនជាតិ[១] រួមជាមួយជនជាតិវៀតណាម ក្នុងនោះក៏មានខ្មែរក្រោមផងដែរ ដែលជាជនជាតិដើមមួយមានចំនួនច្រើនជាងគេក្នុងចំណោមជនជាតិដទៃ ហើយត្រូវតែយកចិត្តទុកដាក់ជាចាំបាច់ ជាសិទ្ធិមិនអាចខានបាន ដែលប្រជាជាតិសឹងតែទូទាំងសាកលលោក ជាពិសេសអង្គការសហប្រជាជាតិបានដឹងឮ និងទទួលស្គាល់ថា ខ្មែរក្រោមគឺជាជនជាតិដើម និងជាអតីតម្ចាស់ទឹកដី នៃវៀតណាមខាងត្បូង។ ពាក់ព័ន្ធនឹងការអប់រំជាស្ថានភាពទូទៅនៃការអប់រំខេមរភាសាសម្រាប់ខ្មែរក្រោមនៅខេត្តត្រាវិញ (ព្រះត្រពាំង) នា០៦ឆ្នាំចុងក្រោយ (២០១២-២០១៨) ស្ថានភាពនៃការអប់រំនេះ ឃើញថាមានភាពកាន់តែ ប្រសើរជាងមុន ដោយប្រៀបធៀបទៅនឹងការអប់រំនាទសវត្សរ៍ឆ្នាំ១៩៧០-៩០។

# ១. សេចក្ដីផ្ដើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ខ្មែរក្រោម គឺជាពលរដ្ឋខ្មែរដែលមានដើមកំណើតនៅឯដែនដីកម្ពុជាក្រោម បច្ចុប្បន្នវៀតណាមខាងត្បូងដែលមានផ្ទៃដីទំហំ ៦៨,៩៦៥ គីឡូម៉ែត្រក្រឡា រួមបញ្ចូលជាមួយដែនកោះធំៗចំនួនពីរ គឺកោះត្រល់ និងកោះត្រឡាច មាន ១៤,៧៧៨ភូមិ មាន ១,៣៦៨ឃុំ មាន ១៧១ស្រុក និងមាន ២១ខេត្តក្រុង[២] និងមានប្រជាពលរដ្ឋខ្មែរជាង ៨,២៤០,០០០នាក់ គិតត្រឹមឆ្នាំ១៩៩៩ មានវត្តព្រះពុទ្ធសាសនាខ្មែរជិត ៦០០វត្ត និងមានព្រះសង្ឃពុទ្ធសាសនា

---

[១] គេហទំព័ររបស់រដ្ឋាភិបាលយៀកណាម៖ *HÌNH ẢNH CỘNG ĐỒNG 54 DÂN TỘC VIỆT NAM,* http://www.chinhphu.vn/portal/page/portal/chinhphu/NuocCHXHCNVietNam/ThongTinTingHop/dantoc, 23/05/2017 10:46 am

[២]គេហទំព័រសហគមន៍ខ្មែរកម្ពុជាក្រោម *http://www.khmerkromngo.org/category/map/*

ខ្មែរប្រមាណជាង ២០០,០០០អង្គ នៅជុំវិញសាកលលោក ទីដែលមានពុទ្ធបរិស័ទខ្មែរក្រោមរស់នៅ[៣]។

នៅកម្ពុជាក្រោម ក្នុងសម័យបារាំងអាណានិគម ពលរដ្ឋខ្មែរក្រោម ទាំងព្រះសង្ឃព្រះពុទ្ធសាសនា ទាំងគ្រហស្ថ ត្រូវបានផ្ដល់សិទ្ធិយ៉ាងពេញលេញក្នុងការទទួលបានការសិក្សាអប់រំដូចប្រជាពលរដ្ឋខ្មែរនៅកម្ពុជាដែរ ដោយមានការទំនាក់ទំនងទៅវិញទៅមកអំពីប្រព័ន្ធអប់រំ ក្រោមការទទួលស្គាល់គុណភាពអប់រំដោយអាណាព្យាបាល និងមានការផ្ដល់ភាពកក់ក្ដៅនៃរាជកិច្ចយកព្រះទ័យទុកដាក់ពីព្រះបាទនរោត្ដម រួមជាមួយសម្ដេចព្រះសង្ឃរាជហួត តាត់ និងសម្ដេចព្រះសង្ឃរាជ ជួន ណាត។

ជាអកុសលក្រោយពីបានធ្វើអាណានិគមអស់រយៈពេល ៩០ឆ្នាំមក នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ បារាំងបានប្រគល់ទឹកដីនេះឲ្យទៅវៀតណាមធ្វើអាណានិគមបន្តបន្ទាប់ពីសង្គ្រាមលោកលើកទី២ តាមច្បាប់បារាំងលេខ៤៩/៧៣៣។ ចាប់តាំងពីការធ្វើអាណានិគមត្រួតត្រាបន្តរបស់អាជ្ញាធរវៀតណាមរួចមក តាមរបាយការណ៍របស់អង្គការសមាគមខ្មែរកម្ពុជាក្រោម សហព័ន្ធខ្មែរកម្ពុជាក្រោម អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិដែលបានសិក្សាស្រាវជ្រាវ និងធ្វើការលើវិស័យសិទ្ធិមនុស្សខ្មែរក្រោម បានរកឃើញថា ខ្មែរក្រោមត្រូវបានប្រឈមទៅនឹងបញ្ហាដោយគ្មានសាលារៀនអក្សរសាស្ត្រខ្មែរស្របច្បាប់ ការសិក្សាអប់រំរបស់ខ្មែរក្រោមនៅមានកម្រិត សេរីភាពនៃអប់រំក្នុងវិស័យវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងប្រវត្តិសាស្ត្រជាដើម គឺត្រូវបានដាក់កម្រិត។ ការរើសអើង និងការដាក់កម្រិតបែបនេះ គឺជាអំពើផ្ទុយទៅនឹងគោលការណ៍សិទ្ធិមនុស្ស ដែលរដ្ឋអំណាចវៀតណាមបានអនុវត្តមកលើខ្មែរក្រោម។

ប៉ុន្តែក្បិតតែបច្ចុប្បន្ននេះ បើយើងមើលទៅក្នុងលក្ខណៈជារួម រដ្ឋាភិបាលវៀតណាមកំពុងតែឆ្ពោះទៅរកការកសាងប្រទេសជាតិមួយជឿនលឿនសឹងតែគ្រប់វិស័យ ជាពិសេសក្នុងវិស័យសេដ្ឋកិច្ច ហើយមានគោលនយោបាយរួបរួមកសាងជាតិសាសន៍តែមួយប្រកបទៅដោយសាមគ្គីភាព និងការឯកភាពជាតិក៏ដោយ។ តែបើនិយាយដោយឡែកអំពីជនជាតិ

---

[៣] គេហទំព័រសហព័ន្ធខ្មែរកម្ពុជាក្រោម *http://www.khmerkrom.org/news-events/human-rights-monitor/142-23khmer-krom-people-statistics*

ដើមនៅប្រទេសវៀតណាមវិញ ជនជាតិដើម និងជនជាតិភាគតិចមានរហូតទៅដល់ ៥៤ជនជាតិ ក្នុងនោះក៏មានខ្មែរក្រោមផងដែរ ដែលជាជនជាតិមួយដែលមានចំនួនពលរដ្ឋ ច្រើនជាងគេ ក្នុងចំណោមជនជាតិដទៃ ហើយគួរតែយកចិត្តទុកដាក់ដែលប្រជាជាតិទាំងឡាយសឹងតែទូទាំង សាកលលោក ជាពិសេសអង្គការសហប្រជាជាតិបានដឹងឮ និងស្គាល់ច្បាស់ថា ខ្មែរក្រោម គឺជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម។ ការរស់នៅរបស់ប្រជាជាតិទាំងឡាយ ជាពិសេស ក្នុងបរិបទនេះ ខ្មែរក្រោមទាំងអស់ត្រូវតែបានគាំពារ និងយកចិត្តទុកដាក់ជាពិសេស ដើម្បី ឱ្យពួកគាត់បានរស់នៅប្រកបដោយសុខសុវត្ថិភាព សុភមង្គល សេរីភាព និងសន្តិភាព ឆ្ពោះទៅរកវឌ្ឍនភាព ដូចប្រជាជាតិទាំងអស់កំពុងរស់នៅលើសកលលោកក្នុងបច្ចុប្បន្ននេះ។

ដូច្នេះការស្រាវជ្រាវនេះ ដើម្បីធ្វើការឆ្លុះបញ្ចាំងបន្ថែម ស្វែងរកឱ្យឃើញពី ស្ថានភាពពិត អំពី **សិទ្ធិទទួលបានការអប់រំរបស់ខ្មែរក្រោមនៅកម្ពុជាក្រោម** ដែលបច្ចុប្បន្នស្ថិតនៅក្រោម ការគ្រប់គ្រងរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម និងដើម្បីចូលរួមរកឱ្យឃើញ គោលនយោបាយអប់រំជាសកល ព្រមទាំងទាញយកមាត្រាបទដ្ឋានច្បាប់នានា យន្តការ និងសំណូមពរក្នុងការដោះស្រាយ បង្កើនឱ្យមានការគោរពសិទ្ធិមនុស្សក្នុងវិស័យ អប់រំឱ្យ មានប្រសិទ្ធភាពសម្រាប់ខ្មែរនៅកម្ពុជាក្រោម។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានផ្តោតសំខាន់ទៅលើសំណួរស្រាវជ្រាវគន្លឹះចំនួន០៣ (បី) ដូចបង្ហាញខាងក្រោម៖

១. តើស្ថានភាពនៃការអប់រំរបស់ខ្មែរក្រោមមានលក្ខណៈដូចម្តេច?

២. តើច្បាប់បទដ្ឋានរបស់ជាតិវៀតណាម និងលិខិតូបករណ៍អង្គការសហប្រជាជាតិអ្វីខ្លះ ដែលបង្ហាញពីការធានា និងលើកឡើងអំពីសិទ្ធិនៃការអប់រំឱ្យបានពេញលេញចំពោះខ្មែរក្រោម?

៣. តើមានបញ្ហាប្រឈមអ្វីខ្លះ និងដំណោះស្រាយបែបណា ដើម្បីលើកស្ទួយការអប់រំសម្រាប់ខ្មែរក្រោមឱ្យមានភាពប្រសើរឡើង?

### ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី *"សិទ្ធិទទួលបានការអប់រំរបស់ខ្មែរក្រោមនៅកម្ពុជាក្រោម"* *"Right to Accessed Education of Khmer Krom in Kampuchea Krom"* មានគោលបំណង ដើម្បីរកឱ្យឃើញពីស្ថានភាពពិត នៃការអប់រំរបស់ខ្មែរក្រោម បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអប់រំរបស់ខ្មែរនៅកម្ពុជាក្រោម បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយដែលកំពុងតែប្រឈម និងចន្លោះខ្វះខាតពាក់ព័ន្ធនឹងការទទួលបានការអប់រំ នាពេលបច្ចុប្បន្នឱ្យមានភាពល្អប្រសើរ ជាពិសេសការអប់រំរបស់ខ្មែរនៅកម្ពុជាក្រោម ក្នុងនោះមានការអប់រំក្នុងវិស័យអក្សរសាស្ត្រខ្មែរ វិស័យប្រវត្តិសាស្ត្រ វិស័យវប្បធម៌ និងវិស័យទំនៀមទម្លាប់ប្រពៃណីខ្មែរ ក្នុងភាពជាប្រជាពលរដ្ឋមួយរស់នៅប្រកបដោយតម្លៃ និងសេចក្តីថ្លៃថ្នូរ ដូចជាការរស់នៅរបស់បុគ្គលគ្រប់រូបៗ ត្រូវរួចចាកផុតពីកង្វះខាត់នៃការអប់រំ ការរើសអើងប្រកាន់ពូជសាសន៍ទទួលបានការអប់រំគ្រប់កម្រិត និងជីវភាពរស់នៅសមរម្យប្រកបដោយសុខសន្តិភាព និងសុភមង្គល។

## ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១. ការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើទិន្នន័យ ០២ប្រភេទគឺៈ ទិន្នន័យប្រភេទទី១ (Primary Data) និង ទិន្នន័យប្រភេទទីពីរ (Secondary Data)។

ទិន្នន័យប្រភេទទី១ (Primary Data) គឺជាប្រភេទទិន្នន័យដែលប្រមូលបានពីការចុះធ្វើសម្ភាសន៍ដោយផ្ទាល់ ដោយផ្អែកទៅលើកម្រងសំណួរជាគំរូរបស់សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ និងរបស់អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ ដែលសំណួរទាំងនោះពាក់ព័ន្ធទៅនឹងស្ថានភាពសិទ្ធិទទួលបានការអប់រំរបស់ខ្មែរនៅឯកម្ពុជាក្រោម។ ទាក់ទងទៅនឹងបញ្ជីសំណួរសម្រាប់ការស្រាវជ្រាវនេះ គឺផ្អែកទៅលើសិស្ស និស្សិត សមណសិស្ស និស្សិតខ្មែរក្រោមផ្ទាល់ ដែលរស់នៅតាមបណ្តាសហគមន៍នៅតាមបណ្តាស្រុកនានានាខេត្តត្រាវិញ ជាពិសេសសំភាសន៍ដោយផ្ទាល់ចំពោះចាស់ព្រឹទ្ធាចារ្យខ្មែរក្រោម ដែលធ្លាប់បានឆ្លងកាត់ និងមានបទពិសោធន៍ទៅលើវិស័យសិក្សាអប់រំនៅកម្ពុជាក្រោម។

ទិន្នន័យប្រភេទទី២ (Secondary Data) គឺជាប្រភេទទិន្នន័យ ដែលបានមកពីទិន្នន័យដែលមានស្រាប់ ដូចជា របាយការណ៍របស់ក្រសួងមន្ទីរពាក់ព័ន្ធការអប់រំរបស់រដ្ឋាភិបាលវៀតណាម របាយការណ៍អប់រំ របស់សមាគមព្រះសង្ឃ សាមគ្គីស្នេហាជាតិនៃខេត្តត្រាវិញ (ព្រះត្រពាំង) និងការរកឃើញរបស់អ្នកសិក្សា ជំនាន់មុន ដែលពាក់ព័ន្ធនឹងការអប់រំរបស់ខ្មែរនៅកម្ពុជាក្រោមជាដើម ដើម្បីធ្វើការស្វែងយល់ និងរុករកនូវ ទ្រឹស្តីបទសំខាន់ៗ ស្តីពីសិទ្ធិមនុស្សការរកឃើញរបស់អ្នកជំនាន់មុនដែលពាក់ព័ន្ធទៅនឹងប្រវត្តិខ្លះៗ ស្តីពីកម្ពុជាក្រោម ក៏ដូចជាប្រវត្តិខ្លះៗនៃប្រទេសកម្ពុជា ដែលពាក់ព័ន្ធនឹងការអប់រំ។ លើសពីនេះទៅទៀតដើម្បីស្វែងរកនូវព័ត៌មានបទពិសោធន៍ គំរូបទដ្ឋាន យន្តការ ដំណោះស្រាយវិធានការអនុវត្តផ្សេងៗដែលទទួលបានជោគជ័យ និងមានប្រសិទ្ធផល។

### ២.២. ការវិភាគទិន្នន័យ

ដើម្បីឆ្លើយតបនូវគោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺយើងប្រើវិធីសាស្ត្រ វិភាគបែបបរិមាណវិស័យ និងគុណវិស័យ។ ការវិភាគ គឺផ្តោតសំខាន់ទៅលើទស្សនាទាននៃការសិក្សាដែលបានលើកឡើងពីខាងដើម។ ទស្សនាទាននៃការសិក្សាដែលបានលើកឡើងនេះនឹងផ្តល់ជាគំរូមួយសម្រាប់ធ្វើការវាស់វែង ដើម្បីស្វែងរកនូវលទ្ធផលនៃការស្រាវជ្រាវ។ ព្រមជាមួយគ្នានេះដែរ ទស្សនាទាននៃការសិក្សានេះ ក៏បានដាក់ចេញជាលក្ខណៈវិនិច្ឆ័យនៅក្នុងការជំរុញឱ្យមានស្ថានភាពប្រសើរឡើង និងចូលរួមដោះស្រាយបញ្ហាប្រកបដោយគុណភាពដែលអាចទទួលយកបាន ក្នុងការអប់រំប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។ លក្ខខណ្ឌវិនិច្ឆ័យទាំងនេះបានផ្តោតទៅលើ ប្រភពឫសគល់ ដែលបណ្តាលឱ្យមានបញ្ហាកើតឡើង បញ្ហាស្នូល ដែលតែងតែប្រឈម និងផលប៉ះពាល់ទៅអនាគតនៃការអប់រំរបស់ខ្មែរក្រោម ដែលជាការវិភាគតាមបែប ប្រៀបធៀបទៅលើទាំងបរិមាណ និងគុណភាពនៃលទ្ធផលបានរកឃើញ។ ក្នុងការវិនិច្ឆ័យនោះផងដែរ ក៏បានផ្តោតទៅលើផលវិជ្ជមាន និងអវិជ្ជមាននៃការចូលរួមដោះស្រាយកន្លងមក និងការអនុវត្តសមស្របតាមបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិ នាពេលបច្ចុប្បន្ន និងអត្ថប្រយោជន៍ផ្សេងៗ។ លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានយកមកធ្វើការពិចារណានៅក្នុងការដោះស្រាយបញ្ហាឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង។

# ៣. ដែនកំណត់ និងវិសាលភាព នៃការស្រាវជ្រាវ

## ៣.១. ដែនកំណត់ នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ដោយផ្ដោតលើស្ថានភាពពិតដែលកើតមាន និងកំពុងប្រឈមជាក់ស្ដែងមួយចំនួននៃការអប់រំរបស់ខ្មែរក្រោមនៅកម្ពុជាក្រោម ដោយគិតពីថេរវេលានៃស្ថានភាពអប់រំក្នុងរយៈពេល ០៦ឆ្នាំ ចុងក្រោយនេះ (២០១២-២០១៨)។ ថេរវេលានៃការចុះកម្មសិក្សាស្រាវជ្រាវអស់រយៈពេល ៨៥ថ្ងៃ គឺចាប់ពីថ្ងៃទី១៤ ខែមីនា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦ នៅខេត្តសុកត្រាំង (ខេត្តឃ្លាំង) ខេត្តត្រាវិញ (ព្រះត្រពាំង) និងសាកលវិទ្យាល័យត្រាវិញ (Tra Vinh University)។ ចាប់ពីថ្ងៃទី២០-៣០ ខែកក្កដា ឆ្នាំ២០១៦ នៅ Archieves Nationales d'Outre-Mer Aix En Provence, France ប្រទេសបារាំង និងចាប់ពីថ្ងៃទី២២ ខែតុលា រហូតដល់ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសមាគមព្រះសង្ឃសាមគ្គី ស្នេហាជាតិខេត្តត្រាវិញ (ព្រះត្រពាំង) សាលាគណខេត្តត្រាវិញ (ព្រះត្រពាំង) មន្ទីរអប់រំ និងបណ្ដុះបណ្ដាលខេត្តត្រាវិញ (ព្រះត្រពាំង) និងសាកលវិទ្យាល័យខេត្តត្រាវិញ (Tra Vinh University)។

## ៣.២. វិសាលភាព នៃការស្រាវជ្រាវ

ការសិក្សាដោយផ្ដោតទៅតាមតំបន់ភូមិសាស្ត្រមួយចំនួន ដែលមានខ្មែរក្រោមរស់នៅកម្ពុជាក្រោម ក្នុងនោះមានជាអទិភាពនៅខេត្តព្រះត្រពាំង (ត្រាវិញ) តាមតំបន់មួយចំនួនដែលមានខ្មែរក្រោមរស់នៅច្រើនដូចជា៖ ក្រុងត្រាវិញ (កំពង់), ស្រុកចូវថាញ់ (ស្រុកកំពង់ជ្រៃ), ស្រុកតេវកឹង (កញ្ចោង), ស្រុកកូវកែ (កំពង់ស្ពាន), ស្រុកកូវង៉ាង (ផ្ទោជាច់), ស្រុកត្រាកុវ (ថ្កូវ), ស្រុកឃៀងហាយ (មាត់សមុទ្រ), ដោយផ្ដោតទៅលើសិទ្ធិក្នុងវិស័យអប់រំ ដែលមានចំណុចសំខាន់ៗមួយចំនួនត្រូវសិក្សាស្វែងយល់អំពី៖ សិទ្ធិទទួលបានការអប់រំអំពី ការជំនឿ និងការប្រតិបត្តិសាសនា ទំនៀមទម្លាប់ ប្រពៃណីខ្មែរ, សិទ្ធិក្នុងការទទួលបានការសិក្សាអប់រំគ្រប់កម្រិត ការប្រើប្រាស់ភាសាខ្មែរ នៅតាមសាលាសាធារណរបស់រដ្ឋ សាលាឯកជន និងតាមវត្តអារាម ព្រះពុទ្ធសាសនា និងសិទ្ធិក្នុងការទទួលបានការសិក្សាអប់រំពីប្រវត្តិសាស្ត្រនៃជនជាតិខ្មែរនៅកម្ពុជាក្រោម។

## ៤. ទស្សនាទាននៃសិទ្ធិទទួលបានការអប់រំ

សិទ្ធិមនុស្ស គឺជាសិទ្ធិ និងសេរីភាពដែលមនុស្សគ្រប់រូបទាំងអស់ត្រូវមានជាចាំបាច់ និងទទួលបានដោយស្វ័យប្រវត្តិពីកំណើតរបស់ខ្លួន។ ប៉ុន្តែការប្រើប្រាស់សិទ្ធិទាំងនោះ គឺត្រូវមានព្រំដែននិងការកំណត់ដោយច្បាប់ មានន័យថា សិទ្ធិតាមផ្លូវច្បាប់ គឺជាសិទ្ធិដែលច្បាប់បានផ្តល់ឲ្យបុគ្គលភាពគតិយុត្ត[៤]។

សិទ្ធិមនុស្សគ្របដណ្តប់ពាសពេញពិភពលោក និងមានភាពស្មើគ្នា។ សិទ្ធិជាចំណែកធម្មជាតិនៃសីលធម៌ពិតរបស់មនុស្ស។ សិទ្ធិមនុស្សត្រូវបានបង្ហាញជាទូទៅ ហើយគឺជាទង្វើនិយមការប្រគល់អំណាចមាន ការចែករំលែកបទដ្ឋានពិតនៃធម្មចរិយារបស់មនុស្សជាការបង្ហាញនូវសមាសភាពសមហេតុផលនៃបទដ្ឋាន សីលធម៌ ឬសិទ្ធិពីធម្មជាតិត្រូវបានគាំទ្រដោយហេតុផលយ៉ាងរឹងមាំ ឬក៏សិទ្ធិត្រឹមត្រូវតាមច្បាប់មួយណាក៏បាន ឱ្យស្មើភាពគ្នានៅក្នុងប្រទេស ឬអន្តរជាតិ[៥]។

ដើម្បីបានបំពេញទៅនឹងនិយមន័យនៃសិទ្ធិមនុស្សខាងលើ និងដើម្បីជាលិខិតូបករណ៍ជាក់លាក់មួយ ដែលមានលក្ខណៈជាគតិយុត្ត នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ គោលគំនិតនិងទស្សនៈទាំងឡាយរបស់ទស្សនវិទូជាច្រើន បានប្រមូលផ្តុំ និងចងក្រងទៅជាច្បាប់ជាមាត្រា ហើយបានប្រកាសជាផ្លូវការ និងចាប់ផ្តើមធ្វើការផ្សាយយ៉ាងទូលំទូលាយនូវសេចក្តីថ្លែងការណ៍ជាសកល ដែលមានចំនួន ៣០មាត្រា ដែលមានចំណុច សំខាន់ៗដែលពាក់ព័ន្ធ **ចំពោះតម្លៃសង្គមនៃសិទ្ធិមនុស្សចំពោះជីវិត អំពីសិទ្ធិមនុស្សចំពោះសមភាព និងគ្មានការរើសអើង** និង **សិទ្ធិមនុស្សចំពោះសេរីភាព** ហើយសិទ្ធិមូលដ្ឋានទាំង៣នេះ បង្កប់ន័យ ដោយការទាមទារឱ្យបុគ្គលគ្រប់ៗរូបត្រូវតែបានទទួលការសិក្សាអប់រំនូវគ្រប់កម្រិត[៦]។

---

[៤] អាឡិច ម៉ាស្សៃលីណូ: *ឯកសារសម្រាប់បណ្តុះបណ្តាលគ្រូអប់រំសិទ្ធិមនុស្ស* ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ១៩៩៩ ទំព័រ២

[៥] ខៃ មីលេស្លី: ***សិទ្ធិអប្បរភាគជននៅកម្ពុជា,*** ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ១៩៩៦ ទំព័រ៤

[៦] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា *កម្រងឯកសារច្បាប់* បោះពុម្ពលើកទី៤ ខែកញ្ញា ឆ្នាំ២០០៥ ទំព័រ១០២

យោងតាមបុព្វកថានៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សចែងថា "*ប្រជាពលរដ្ឋនៃពិភពលោក បានប្រកាសប្តេជ្ញាថានឹងជួយបង្កលក្ខណៈអំណោយផលដល់កិច្ច អភិវឌ្ឍន៍សង្គម ព្រមទាំងបង្កើតឲ្យមានលក្ខណៈគាប់ប្រសើរក្នុងការរស់នៅក្នុងសេរីភាពមួយទូលាយ*"។ ចំណុចសំខាន់មួយទៀតគឺ "*ការទទួលស្គាល់និងយល់ដឹងពីសិទ្ធិមនុស្ស និងសេរីភាពទាំងអស់របស់មនុស្សជាតិ*" ព្រោះថាមនុស្សរស់នៅក្នុងសង្គមត្រូវការចាំបាច់នូវ សេរីភាព សមភាព ការអភិវឌ្ឍន៍ សមត្ថភាព និងទេពកោសល្យរបស់ខ្លួននៅក្នុងសង្គម។

សិទ្ធិក្នុងការអប់រំត្រូវបានបញ្ចូលនៅក្នុងធម្មនុញ្ញជាច្រើន និងសន្ធិសញ្ញាអន្តរជាតិនានា។ រដ្ឋជាភាគីបានយល់ស្របថាការមិនចេះអក្សរត្រូវតែលុបបំបាត់ចោល ហើយយល់ស្របថា កុមារទាំងអស់ត្រូវតែបានចូលរៀន។ ទោះយ៉ាងណាក៏ដោយ នៅមានគម្លាតដ៏ធំមួយ រវាងទ្រឹស្តីនិងការអនុវត្តពិត។ ទូទាំងពិភពលោកនៅមានកុមារជាច្រើនដែលមានអាយុក្នុងវ័យសិក្សាប្រមាណ៦០លាននាក់ ដែលមិនបានទទួលការអប់រំ។ សិទ្ធិទទួលបានការអប់រំ គឺមានសារៈសំខាន់ណាស់សម្រាប់បុគ្គលគ្រប់ៗរូបដែលចូលរួមការអភិវឌ្ឍន៍នៃសង្គមទាំងមូល[៧]។

មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ។ ការអប់រំត្រូវឥតបង់ថ្លៃ យ៉ាងហោចណាស់សម្រាប់ការអប់រំ និងការអប់រំមូលដ្ឋាន។ ការអប់រំបឋមសិក្សាគឺជាកាតព្វកិច្ច។ ការអប់រំខាងបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ។ ការអប់រំឧត្តមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមត្ថភាព។ ការអប់រំគឺសំដៅការរីកចម្រើនពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។ ការអប់រំនេះ ត្រូវលើកកម្ពស់ការយល់ដឹង ការអត់ឱន ការអធ្យាស្រ័យគ្នា និងមិត្តភាព រវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់អង្គការសហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព[៨]។

---

[៧] Moeckli, Shah & Sivakumaran: *International Human Rights Law*, Oxford University Press 3rd edition, 2018, Page 233

[៨] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា *កម្រងឯកសារច្បាប់* បោះពុម្ពលើកទី៤ ខែកញ្ញា ឆ្នាំ២០០៥ ទំព័រ៦២

សិទ្ធិទទួលបានការអប់រំក៏ត្រូវបានធានាដោយលិខិតបករណ៍សិទ្ធិមនុស្សក្នុងតំបន់ផងដែរ។ នៅអឺរ៉ុបបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) បទដ្ឋាននេះធានាដល់ការចូលទៅកាន់ស្ថាប័នអប់រំសាធារណៈដោយគ្មានការរើសអើង ហើយទាមទារឱ្យរដ្ឋនានាជៀសវាងពីការជ្រៀតជ្រែកនៅក្នុងប្រតិបត្តិការដោយឥតគិតថ្លៃ និងការជ្រើសរើសដោយសេរីនូវការអប់រំរបស់សិស្ស និងអាណាព្យាបាលរបស់ពួកគេ។ គណៈកម្មការសហគមន៍អ៊ឺរ៉ុប និងតុលាការសិទ្ធិមនុស្សអឺរ៉ុប ដោយទាមទារឱ្យរដ្ឋនានារក្សានូវកម្រិតនៃសេវាអប់រំនេះ[៩]។

## ៥. លទ្ធផលនៃការស្រាវជ្រាវ

កម្មវិធីបង្រៀន និងមុខវិជ្ជាសិក្សាភាសាខ្មែរមានពីរកម្រិត និងចែកចេញជាប្រាំពីរ (០៧) ឆ្នាំនៃការសិក្សា។ កម្រិតទី១ គឺកម្រិតបឋមសិក្សា និងកម្រិតអនុវិទ្យាល័យ កម្រិតនេះសិក្សារយៈពេលបួន (០៤) ឆ្នាំ និងវិទ្យាល័យមានបី (៣) ឆ្នាំ[១០]។

### ៥.១. ការសិក្សាខេមរភាសាទូទាំងខេត្តត្រាវិញ នៅតាមសាលាចំណេះទូទៅ

ការសិក្សាសាលាចំណេះទូទៅនៅកម្ពុជាក្រោម ត្រូវបានបែងចែកជាបីកម្រិត ដូចនៅព្រះរាជាណាចក្រកម្ពុជាដែរគឺ៖ កម្រិតបឋមសិក្សា (មានថ្នាក់ទី២-៣-៤-៥) កម្រិតអនុ-វិទ្យាល័យ (មានថ្នាក់ទី៦-៧-៨-៩) និងកម្រិតវិទ្យាល័យជាន់ខ្ពស់ (មានថ្នាក់ទី១០-១១-១២)។

| ឆ្នាំសិក្សា | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | សរុប |
|---|---|---|---|---|
| ២០១២-២០១៣ | ៩,៧៧៨ | ១,១០៧ | ៥០១ | ១១,៣៨៦ |
| ២០១៣-២០១៤ | ១២,៦២៣ | ១,៦១៥ | ៣៦៩ | ១៤,៦០៧ |
| ២០១៤-២០១៥ | ១៣,០៦៤ | ១,៦១៥ | ៥៥៧ | ១៥,២៣៦ |

[៩] Moeckli, Shah & Sivakumaran: *International Human Rights Law*, Oxford University Press 3rd edition, 2018, Page 234

[១០] មន្ទីរអប់រំ និងបណ្តុះបណ្តាលខេត្តត្រាវិញ *បទបង្ហាញពីរបាយការណ៍ការអប់រំនិងបណ្តុះបណ្តាលក្នុងតំបន់ដែលមានពលរដ្ឋខ្មែរច្រើន* ឆ្នាំ២០១៨

| | | | | |
|---|---|---|---|---|
| ២០១៥-២០១៦ | ១៣,៨១១ | ២,៩៤៥ | ៥៥០ | ១៧,៣០៦ |
| ២០១៦-២០១៧ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | ១៩.១៩៣ |
| ២០១៧-២០១៨ | ១៤,២៨៥ | ៣,៤៤៦ | ១,៣៩៣ | ១៩,១២៤ |

**ប្រភព៖** *ដកស្រង់ទិន្នន័យពីបាយការណ៍ការអប់រំនិងបណ្តុះបណ្តាលរបស់មន្ទីរអប់រំ និងបណ្តុះបណ្តាលខេត្តត្រាវិញ ឆ្នាំ២០១៨ ទំព័រទី៤ និងទី៥។*

## ៥.២. ការសិក្សាខេមរភាសា នៅសាលាវត្តក្នុងរដូវកាលវិស្សមកាលខេត្តត្រាវិញ

សរុបចំនួនសិស្សនៅកម្រិតមតេយ្យ បឋម អនុវិទ្យាល័យ និងវិទ្យាល័យ សម្រាប់ឆ្នាំសិក្សា២០១៣ ដល់ឆ្នាំ២០១៨ មានជាតារាងដូចខាងក្រោម៖

| ឆ្នាំសិក្សា | មតេយ្យ | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | សរុប |
|---|---|---|---|---|---|
| ២០១៣-២០១៤ | ១០,៥៨៥ | ២៧,៧៥១ | ១៦,១៤៦ | ៣,៨១០ | ៥៨,២៩២ |
| ២០១៤-២០១៥ | ១១,៣៦៩ | ២៨,៣៨៦ | ១៦,៦៨៩ | ៥,៣១១ | ៦១,៧៥៥ |
| ២០១៥-២០១៦ | ១២,១២៦ | ២៨,៧៥៥ | ១៦,៨១២ | ៥,៧២២ | ៦៣,៤១៥ |
| ២០១៦-២០១៧ | ១២,៥៦៧ | ២៩,៣៣១ | ១៧,០០៩ | ៥,៧៩៨ | ៦៤,៧០៥ |
| ២០១៧-២០១៨ | ១៣,២៦០ | ៣០,៦៥៨ | ១៧,២៤៥ | ៥,៨៤០ | ៦៧,០០៣ |

**ប្រភព៖** *ដកស្រង់ទិន្នន័យពីបាយការណ៍ការអប់រំនិងបណ្តុះបណ្តាលរបស់មន្ទីរអប់រំ និងបណ្តុះបណ្តាលខេត្តត្រាវិញ ឆ្នាំ២០១៨។*

## ៥.៣. ការសិក្សាបែបប្រពៃណី (ខេមរភាសា បាលី ធម្មវិន័យ) ទូទាំងខេត្តត្រាវិញ នៅតាមសាលាវត្ត[១១]

អាស្រ័យតម្រូវការសិក្សារបស់ព្រះសង្ឃ មួយថ្ងៃកាន់តែកំណើនជាលំដាប់។ បន្តផ្លាស់ថ្មីប្រព័ន្ធអប់រំ កំណែទម្រង់កម្មវិធីសិក្សាផ្នែកពុទ្ធិកៈ ដើម្បីលើកម្ពស់ចំណេះដឹងដល់ព្រះសង្ឃ និងកូនចៅខ្មែរ។ សមាគមព្រះសង្ឃ សាមគ្គីស្នេហាជាតិខេត្ត សហការជាមួយនឹងសមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិស្រុក ក្រុង ព្រះចៅអធិការ គណៈកម្មការ គណៈអាចារ្យបង្រៀន ចាត់តាំងបើកបើកសាលារៀនពីថ្នាក់ពុទ្ធិកមធ្យមសិក្សាបឋមភូមិ ដល់ទុតិយភូមិ ជួយបង្កលក្ខណៈដល់សមណសិស្ស យុវជន យុវតីសិស្ស បានឱកាសសិក្សាបន្ថែម សាលាសាកល សាលាបំពេញវិជ្ជា និងកូនចៅខ្មែរសិក្សាថ្នាក់វិជ្ជាខេមរភាសា ក្នុងរដូវវិស្សមកាលសាលាសាកល។

### ក. ថ្នាក់វិជ្ជាខេមរភាសា

| ឆ្នាំសិក្សា | បន្ទប់-ថ្នាក់ | សមណសិស្ស-យុវសិស្ស | គ្រូបង្រៀន | លទ្ធផល |
|---|---|---|---|---|
| ២០១៣-២០១៤ | ៩៤៤ | ២០,១១០ | ៧៩០ | ៩៦.៧០% |
| ២០១៤-២០១៥ | ៩៥១ | ២៣,១២៣ | ៨១៧ | ៩៤.៥០% |
| ២០១៥-២០១៦ | ៩១១ | ២០,៧៥០ | ៩១៩ | ៩៩.៥០% |
| ២០១៦-២០១៧ | ៦៩៦ | ១៧,២៧៩ | ៧៨៨ | ៩៧.៥០% |
| ២០១៧-២០១៨ | ៦៨០ | ១៥,៩៣៣ | ៧៧១ | ៩៩.៧៥% |

**ប្រភព៖** របាយការណ៍មហាសន្និបាតលើកទី៧ អាណត្តិកាល ២០១៨-២០២៣ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិខេត្តត្រាវិញ ទំព័រ១៣។

[១១] សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិខេត្តត្រាវិញ ***របាយការណ៍មហាសន្និបាត*** លើកទី៧ អាណត្តិកាល ២០១៨-២០២៣ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨

## ខ. ថ្នាក់ពុទ្ធិកមធ្យមសិក្សាបឋមភូមិ

| ឆ្នាំសិក្សា | បន្ទប់-ថ្នាក់ | សមណសិស្ស-យុវសិស្ស | គ្រូបង្រៀន | លទ្ធផល |
|---|---|---|---|---|
| ២០១៣-២០១៤ | ៩២ | ២,០២៣ | ៨៩៩ | ៩៩.៧២% |
| ២០១៤-២០១៥ | ៩៧ | ២,០៥៦ | ៩៧០ | ៩៦.៥០% |
| ២០១៥-២០១៦ | ៩៧ | ២,៤៦១ | ១,១៥៤ | ៩៩.៧៥% |
| ២០១៦-២០១៧ | ១១២ | ២,៤១៧ | ៩៨៧ | ៩៩.៧៥% |
| ២០១៧-២០១៨ | ១០៩ | ២,៣០៦ | ៨៨៧ | ៩៨.២៥% |

**ប្រភព៖** របាយការណ៍មហាសន្និបាតលើកទី៧ អាណត្តិកាល ២០១៨-២០២៣ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិខេត្តត្រាវិញ ទំព័រ១៣។

## គ. ថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

| ឆ្នាំសិក្សា | បន្ទប់-ថ្នាក់ | សមណសិស្ស-យុវសិស្ស | គ្រូបង្រៀន | លិទ្ធផល |
|---|---|---|---|---|
| ២០១៣-២០១៤ | ១៣ | ៣៦៩ | ១៤៤ | ៩៨.៦៩% |
| ២០១៤-២០១៥ | ១៤ | ៣៧៧ | ១៤០ | ៩៩00% |
| ២០១៥-២០១៦ | ១៣ | ៣៦៧ | ១៣០ | ៩៨.៥០% |
| ២០១៦-២០១៧ | ១៤ | ៣៩១ | ១៥៤ | ៩៩.៥០% |
| ២០១៧-២០១៨ | ១៥ | ២៨៦ | ១៤១ | ៩៨.៧៥% |

**ប្រភព៖** របាយការណ៍មហាសន្និបាតលើកទី៧ អាណត្តិកាល ២០១៨-២០២៣ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិខេត្តត្រាវិញ ទំព័រ១៣។

ទន្ទឹមនឹងការសិក្សាផ្នែកពុទ្ធិកៈ បច្ចុប្បន្ននេះមានសមណសិស្សប្រមាណ ១០០អង្គ កំពុងរៀនសាលាមធ្យមសិក្សាសាកល និងសាលាបំពេញវិជ្ជាថ្នាក់ទី១០ ដល់ទី១២ ជាង ៤០អង្គ កំពុងសិក្សានៅសាលាមហាវិទ្យាល័យត្រាវិញ ១អង្គ កំពុងសិក្សានៅវិទ្យាស្ថានពុទ្ធសាសនា ក្រុងហូជីមិញ ៤អង្គ កំពុងសិក្សាវិជ្ជាស្ថានពុទ្ធសាសនាក្រុងកឹងជឺ ៤អង្គ កំពុងសិក្សាសាលាបំពេញវិជ្ជាមធ្យមសិក្សាបាលីខេត្តស្រុកត្រាំង (ឃ្លាំង)។ ជាពិសេស ឆ្នាំ២០១៤ គណៈកម្មការប្រជាជនខេត្ត អនុញ្ញាតឱ្យបង្កើតសាលាមធ្យមសិក្សាបាលី-ខ្មែរក្រោម ការគ្រប់គ្រង់របស់មន្ទីរអប់រំនិងបណ្តុះបណ្តាល។ សាលានឹងបណ្តុះបណ្តាលចម្រុះ (មានលក្ខណៈពិសេស) រួមមានបណ្តុះបណ្តាល ថ្នាក់បំពេញវិជ្ជា ភាសាបាលី ភាសាខ្មែរ ធម៌វិន័យ ព្រះពុទ្ធសាសនា

សម្រាប់សមណសិស្ស យុវជន យុវតីសិស្សខ្មែរ។ ក្រោយអំពីបញ្ចប់ សិក្ខាកាមនឹងអាចបន្តការសិក្សានូវកម្រិតខ្ពស់ជាងដូចជា ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ តាមសាកលវិទ្យាល័យក្នុងនិងក្រៅប្រទេស ដើម្បីលើកកម្ពស់ចំណេះដឹងឱ្យសមស្របនិងតម្រូវការរបស់សង្គម ក្នុងសម័យសមាហរណកម្ម អន្តជាតិ ដើម្បីឯកភាពក្នុងការគ្រប់គ្រងកម្មវិធីបង្រៀន និងរៀនតាមបទបញ្ញត្តិ បច្ចុប្បន្នមាន សមណសិស្ស និងយុវសិស្សកំពុងសិក្សាចំនួន ១០៤ អង្គ-នាក់។

ក្រៅអំពីនោះ បើតាមសិត្ថិរបស់គណៈអចិន្ត្រៃសមាគមខេត្តមាន ៥៧អង្គ និមន្តទៅសិក្សានៅបរទេស ក្នុងនោះ ប្រទេសថៃ ៥២អង្គ អូស្ត្រាលី ១អង្គ ឥណ្ឌា ២អង្គ កាណាដា ១អង្គ និងកម្ពុជា ១អង្គ។

## ៥.៤. ការវិភាគលើលទ្ធផល

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ក្នុងទិដ្ឋភាពរួមឃើញថា រដ្ឋាភិបាលវៀតណាមកំពុងតែឈានទៅរកការកសាងប្រទេសជាតិមួយជឿនលឿនសឹងតែគ្រប់វិស័យ ជាពិសេសក្នុងវិស័យសេដ្ឋកិច្ច និងដំណើរការ នៃការសិក្សាអប់រំ និងបណ្ដុះបណ្ដាល។ រដ្ឋាភិបាលវៀតណាមមានគោលនយោបាយរួបរួមកសាងជាតិសាសន៍តែមួយ ប្រកបទៅដោយសាមគ្គីភាព និងការឯកភាពជាតិ ក្រោមបាវចនាជាតិ ឯករាជ្យ សេរីភាព សុភមង្គល (Doc Lap Tu Do Hanh Phuc)។ និយាយដោយឡែកអំពីជនជាតិភាគតិចនៅប្រទេសវៀតណាមវិញ ជនជាតិដើមភាគតិចមានរហូតទៅដល់ ៥៤ជនជាតិ[១២] រួមជាមួយជនជាតិវៀតណាម ក្នុងនោះក៏មានខ្មែរក្រោមផងដែរ ដែលជាជនជាតិដើមមួយមានចំនួនច្រើនជាងគេក្នុងចំណោមជនជាតិដទៃ ហើយត្រូវតែយកចិត្តទុក ដាក់ជាចាំបាច់ ជាសិទ្ធិមិនអាចខានបាន ដែលប្រជាជាតិសឹងតែទូទាំងសាកលលោក ជាពិសេសអង្គការសហប្រជាជាតិបានដឹងឮ និងទទួលស្គាល់ថា ខ្មែរក្រោមគឺជាជនជាតិដើម និងជាអតីតម្ចាស់ទឹកដីនៃវៀតណាមខាងត្បូង។

---

[១២] គេហទំព័ររបស់រដ្ឋាភិបាលយៀកណាម៖ *HÌNH ẢNH CỘNG ĐỒNG 54 DÂN TỘC VIỆT NAM,* http://www.chinhphu.vn/portal/page/portal/chinhphu/NuocCHXHCNVietNam/ThongTinTongHop/dantoc, 23/05/2017 10:46 am

ស្ថានភាពទូទៅនៃការអប់រំខេមរភាសាសម្រាប់ខ្មែរក្រោមនៅខេត្តត្រាវិញ (ព្រះត្រពាំង) នា០៦ឆ្នាំចុងក្រោយ (២០១២-២០១៨) ស្ថានភាពនៃការអប់រំនេះ ឃើញថាមានភាពកាន់តែប្រសើរជាងមុន ប្រសិនបើប្រៀបធៀបទៅនឹងការអប់រំនាទសវត្សរ៍ឆ្នាំ១៩៧០-៩០។

តាមការសិក្សាស្រាវជ្រាវប្រវត្តិអប់រំសម្រាប់ខ្មែរក្រោមកន្លងមកឃើញថា កម្មវិធីសិក្សាខេមរភាសា គឺមិនបានបញ្ចូលកម្មវិធីសិក្សានៅតាមសាលាចំណេះដឹងទូទៅរបស់រដ្ឋទេ ហើយសម្រាប់កម្មវិធីសិក្សាខេមរភាសា ក៏មិនបានបញ្ចូលនៅតាមសាលាវត្តដែរ លើកលែងតែការសិក្សាទៅតាមបែបប្រពៃណីដែលមានការសិក្សា ផ្នែកបាលីភាសា និងធម្មវិន័យ ប៉ុណ្ណោះ។ លើសពីនោះទៀតសោត ការសិក្សានោះពិតជាមានកម្រិតទាប ហើយក៏មិនត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលវៀតណាមឡើយ។ គ្រានោះការសិក្សារបស់ខ្មែរក្រោមត្រូវ បានរឹតបន្តឹង និងមិនបានបើកចំហរឱ្យបានទូលំលាយទេ គ្រូបង្រៀនទាំងអស់បានស្ម័គ្រចិត្តបង្រៀនដោយឥតគិតកម្រៃដោយ លះបង់ពេលវេលាជាមួយនឹងការងារគ្រួសារជីវភាពប្រចាំថ្ងៃ ថែមទាំងមានការព្រួយបារម្ភនិងមានការប្រុងប្រយ័ត្នជាប្រចាំពីការតាមដានដោយរដ្ឋអំណាចវៀតណាម។

យ៉ាងណាមិញ ជាការប្រៀបធៀបទៅនឹងស្ថានភាពបច្ចុប្បន្ននា ០៦ឆ្នាំចុងក្រោយនេះ (២០១២-២០១៨) ការសិក្សាវិជ្ជាខេមរភាសា ត្រូវបានរដ្ឋអំណាចវៀតណាមយកចិត្តទុកដាក់ស្របទៅតាមគោលនយោបាយអប់រំ និងបណ្ដុះបណ្ដាលរបស់រដ្ឋសម្រាប់អប់រំដល់ប្រជាជនទូទៅ ជាពិសេសមានគោលនយោបាយចំពោះ ជនជាតិភាគតិច ក្នុងនោះក៏មានខ្មែរក្រោមដែរ។ កម្មវិធីសិក្សាខេមរភាសាសម្រាប់ជនជាតិខ្មែរក្រោម គឺឃើញមានបញ្ចូលទៅនឹងកម្មវិធីសិក្សានៅសាលាចំណេះទូទៅរបស់រដ្ឋ នេះដោយឡែកនៅខេត្តត្រាវិញ (ព្រះត្រពាំង) មានសឹងតែគ្រប់ទីកន្លែងនៅតាមតំបន់ដែលមានខ្មែរក្រោមរស់នៅច្រើន ហើយបានចូលរួមសិក្សាវិជ្ជាខេមរភាសា មានសឹងតែគ្រប់តំបន់ដែរ សម្រាប់ការសិក្សាចាប់ពីថ្នាក់មេតេយ្យរហូតដល់ថ្នាក់ទី១២។ រីឯកម្មវិធីសិក្សា វិជ្ជាខេមរភាសានៅតាមសាលាវត្តក្នុងរដូវវិស្សមកាលក៏មានសុទ្ធសឹងគ្រប់វត្តដែរ ហើយមានសិស្សដែលបានសិក្សា ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៥នៃកម្រិតបឋមសិក្សា។

ដោយឡែកកម្មវិធីសិក្សាវិជ្ជាបាលីភាសា និងធម្មវិន័យសិក្សានៅតាមវត្តអារាមព្រះពុទ្ធសាសនា ក៏ឃើញថាមានការបើកចំហរយ៉ាងទូលាយសម្រាប់សមណសិស្ស យុវជន

យុវនារី ខ្មែរក្រោម ទទួលបានការសិក្សា នៅតាមវត្តអារាមនានា។ នៅខេត្តត្រាវិញ (ព្រះត្រពាំង) មានវត្តអារាមព្រះពុទ្ធសាសនាចំនួន ១៤៤វត្ត ក្នុងនោះមានសុទ្ធសឹងតែគ្រប់វត្តទាំងអស់ ត្រូវបានអនុញ្ញាតិដោយរដ្ឋអំណាចវៀតណាម ហើយគ្រប់គ្រងដោយសមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិ រួមសហការជាមួយមន្ទីរអប់រំ និងបណ្តុះបណ្តាលខេត្ត ព្រះសង្ឃ និងយុវជន យុវនារីខ្មែរក្រោមបានចូលរួមសិក្សាចាប់ពីថ្នាក់ពុទ្ធិកសិក្សាបឋមភូមិរហូតដល់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ។

ចំពោះគ្រូបង្រៀនវិជ្ជាខេមរភាសានៅតាមសាលាចំណេះដឹងទូទៅរបស់រដ្ឋ នៅតាមសាលាវត្តក្នុងរដូវវិស្សមកាល គឺត្រូវបានរដ្ឋអំណាចវៀតណាមផ្តល់ប្រាក់ខែជូនផងដែរ លើកលែងតែកម្មវិធីសិក្សាបាលីភាសា និង ធម្មវិន័យ គឺគ្រូបង្រៀននៅតែស្ម័គ្រចិត្តបង្រៀន ដោយឥតគិតកម្រៃទៅតាមប្រពៃណីដូចពីអតីតកាល។ ទោះជាយ៉ាងនេះក៏ដោយ បច្ចុប្បន្ននេះ តាមគោលនយោបាយអប់រំរបស់រដ្ឋ រដ្ឋអំណាចវៀតណាមកំពុងគិតគូ ដើម្បីផ្តល់ប្រាក់ខែសម្រាប់គ្រូបង្រៀនទាំងនោះ។

ទោះជាស្ថានភាពអប់រំខេមរភាសាសម្រាប់ខ្មែរក្រោម ឃើញថាមានភាពកាន់តែប្រសើរជាងមុនក៏ដោយក៏ភាពប្រឈមនឹងការអប់រំ ដែលជាសិទ្ធិទទួលបានការអប់រំរបស់ពលរដ្ឋខ្មែរក្រោម ក្នុងនាមជាជនជាតិដើម គឺមិនទាន់ត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការសិក្សាស្វែងយល់ និងអនុវត្តនូវសិទ្ធិរបស់ពួកគេនៅឡើយ ហើយសិទ្ធិទាំងនោះមានដូចជាៈ សិទ្ធិក្នុងការទទួលបានការសិក្សាអប់រំគ្រប់កម្រិត ក្នុងនោះមានវិស័យអប់រំពីវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីខ្មែរ ការសិក្សាអប់រំអំពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ការសិក្សាអប់រំអំពីសិទ្ធិមនុស្សជាដើម។

បើយើងមើលទៅក្នុងទិដ្ឋភាពជាលក្ខណៈសាកល មានប្រទេសមួយចំនួននៅតំបន់អាស៊ី ទ្វីបអឺរ៉ុប ទាំងបច្ចឹមប្រទេសជាដើម កំពុងវាយតម្លៃថា រដ្ឋាភិបាលវៀតណាមកំពុងតែយកចិត្តទុកដាក់ទៅលើគោលនយោបាយបង្រួបបង្រួមជាតិសាសន៍ ការផ្តល់ឱកាស និងការកសាងវិស័យវប្បធម៌ ទំនៀមទំលាប់ ប្រពៃណី អក្សរសាស្ត្រ ព្រះពុទ្ធសាសនា និងសាសនាដទៃទៀតទៅតាមជំនឿរបស់ជាតិសាសន៍នីមួយៗ ក្នុងនោះមានខ្មែរក្រោមជាដើម ដែលជាជនជាតិដើមកំពុងរស់នៅដែនដីកំណើតរបស់ពួកគេ។ រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គម

វៀតណាម តែងតែលើកឡើងពីគុណតម្លៃ ថារដ្ឋាភិបាលមួយនេះ បានចូលរួមកសាងយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងការកសាងនូវវត្តអារាមព្រះពុទ្ធសាសនា បង្កើតសាលាអន្តេវាសិកដ្ឋាន ផ្តល់ឱកាសឱ្យខ្មែរក្រោមបានគោរពនិងអនុវត្តទំនៀមទំលាប់ និងប្រពៃណីវប្បធម៌របស់ខ្មែរក្រោម។ល។ ផ្ទុយទៅវិញ ការអភិវឌ្ឍទាំងនោះមានប្រទេសជាច្រើនរហូតដល់ជាង ១០០ប្រទេស នៅលើសាកលលោកដែលជាសមាជិករបស់អង្គការសហប្រជាជាតិ បានរិះគន់យ៉ាងខ្លាំងថា ប្រទេសមួយនេះ មិនទាន់មានការគោរពសិទ្ធិមនុស្សជនជាតិភាគតិច ជនជាតិដើមនៅឡើយ។

របាយការណ៍របស់អង្គការសហប្រជាជាតិកាលពីឆ្នាំ២០១៥[១៣] បានវាយតម្លៃថា វៀតណាមត្រូវបានគេស្គាល់ជាអន្តរជាតិថា ជាប្រទេសទទួលបានជោគជ័យនៃវិស័យអប់រំ ដោយទទួលបានការអប់រំកម្រិតបឋមសិក្សាជាសកលក្នុងឆ្នាំ ២០០០ និងការអប់រំកម្រិតអនុវិទ្យាល័យជាសលក្នុងឆ្នាំ ២០១០។ ទោះបីជាមានសមិទ្ធផលគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ភាពខុសគ្នានៃការអប់រំនៅតែបន្តកើតមានក្នុងចំណោមក្រុមជាច្រើន រួមមានកុមារជនជាតិដើមភាគតិច កុមារពិការ និងកុមារនៅតំបន់ដាច់ស្រយាលដែលពិបាកទៅដល់។ ក្នុងរបាយការណ៍បានបញ្ជាក់ទៀតថា អំពើហឹង្សាប្រឆាំងនឹងភេទ ការគំរាមកំហែង និងការរើសអើងនៅតែមានជាទូទៅនៅក្នុងសាលារៀននៅប្រទេសវៀតណាម។ នេះមិនត្រឹមតែជាឧបសគ្គចំពោះការរៀនសូត្រប៉ុណ្ណោះទេ ថែមទាំងជាការរំលោភបំពានសិទ្ធិមនុស្សផងដែរ។

របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិនាឆ្នាំ២០០៩[១៤] បានលើកឡើងអំពីកម្រិតខ្ពស់អត្រាអនក្ខរកម្ម និងការបោះបង់ចោលសាលា ក្នុងរបាយការណ៍បានសរសេរថា ជាមូលដ្ឋានខ្មែរក្រោមភាគច្រើននៃការរើសអើង នោះគឺជាការពិត គម្លាតនៃភាពក្រីក្រនៃខ្មែរក្រោមនៅតំបន់ដីសណ្តទន្លេមេគង្គ និងគម្លាតនៃភាពខ្វះខាតក្នុងវិស័យអប់រំ គឺតម្រូវឱ្យមានលក្ខខណ្ឌពីរដែលត្រូវតែពង្រឹងទៅវិញទៅមកឱ្យមានសមាមាត្រស្មើគ្នា។ ភាពក្រីក្រ និងកង្វះខាតនៃការអប់រំនោះ មានគម្លាតខុសគ្នារវាងខ្មែរក្រោម និងវៀតណាម

---

[១៣] http://www.un.org.vn/en/publications/one-un-documents/doc_details/510-annual-results-report-2015.html page48-51

[១៤] https://www.hrw.org/report/2009/01/21/margins/rights-abuses-ethnic-khmer-vietnams-mekong-delta

មានដូចតទៅ៖ ខ្មែរក្រោមជាច្រើនជឿថា គោលនយោបាយអប់រំរបស់រដ្ឋាភិបាល ត្រូវបានរៀបចំដើម្បីបញ្ចូល បញ្ច្រាបពួកគាត់ទៅក្នុងសង្គម ជាមួយនឹងប្រជាជនវៀតណាម។ ចំណុចនេះជាភាពឧបសគ្គរាំងធ្វើឱ្យខ្មែរក្រោមមិនបានទទួលការអប់រំនៅក្នុងកម្រិតខ្ពស់ និងធ្វើឱ្យមូលដ្ឋានគ្រឹះនៃវប្បធម៌ និងភាសារបស់ពួកគេចុះខ្សោយ។ ទោះជានៅតំបន់ដីសណ្តទន្លេមេគង្គ សាលាបឋម និងអនុវិទ្យាល័យមានកម្រិតភាគរយខ្ពស់ជាងប្រាំពីរតំបន់ផ្សេងទៀតនៅវៀតណាម នោះនៅតែមានកម្រិតទាបបំផុតនៃអត្រាកំណើនអក្ខរភាពសម្រាប់មនុស្សពេញវ័យជាលំដាប់ទី២ ហើយនិងកម្រិតទាបបំផុតនៃការចុះឈ្មោះចូលរៀននៅសាធារណៈរដ្ឋនៅវៀតណាម ក្នុងនោះមានមួយភាគបីនៃការបោះបង់ការសិក្សា មានរហូតដល់ ៨៣% នៃកម្លាំងពលកម្មទូទៅ និង ៩៦% នៃប្រជាជនដែលមានចំណូលទាប ដោយសារខ្វះការសិក្សានៅវិទ្យាល័យ។ អត្រាកំណើនសិស្សសាលាក្រីក្រ ដែលត្រូវបានបង្កើតឡើងដោយគ្រួសារខ្មែរក្រោមដែលមានប្រាក់ចំណូលទាប ត្រូវការកូនរបស់ខ្លួនដើម្បីរួមចំណែកដល់សេដ្ឋកិច្ចគ្រួសារ។ គ្រូបង្រៀនម្នាក់នៅខេត្តព្រះត្រពាំង (ត្រាវិញ) បាននិយាយថា "សិស្សភាគច្រើនមានសមត្ថភាពរៀនមិនបានល្អ គឺជនជាតិខ្មែរ ដែលពួកគេមិនអាចនិយាយភាសាវៀតណាមបានល្អ ហើយមិនអាចរៀនតាមកម្មវិធីសិក្សា"។ គ្រូបង្រៀនម្នាក់ទៀតបាននិយាយថាសិស្សខ្មែរក្រោម "ខ្លាចសាលារៀន"។ ព្រោះពួកគេមិនអាចនិយាយ និងស្តាប់ភាសាវៀតណាមបានល្អ ពួកគេមិនអាចយល់គ្រូពន្យល់បាន។ រីឯសិស្សខ្មែរក្រោមបាននិយាយថា៖ "យើងខ្វះការបង់ថ្លៃចូលសាលារៀន យើងតស៊ូដើម្បីភាសាយើង ហើយសាលារៀនស្ថិតនៅឆ្ងាយពីផ្ទះរបស់យើង" ។

គោលនយោបាយរបស់រដ្ឋាភិបាលវៀតណាម គឺលើកទឹកចិត្តឱ្យជនជាតិភាគតិចទាំងអស់រៀនភាសាវៀតណាមជាភាសាជាតិ ខណៈពេលដែលទទួលស្គាល់សិទ្ធិរបស់ជនជាតិភាគតិចក្នុងការសិក្សានិងប្រើប្រាស់ភាសាសរសេរ និងនិយាយភាសារបស់ពួកគេ។ គោលនយោបាយអប់រំរបស់រដ្ឋាភិបាល និងច្បាប់ស្តីពីការអប់រំរបស់វៀតណាមផ្តល់សិទ្ធិដល់សិស្សានុសិស្សជនជាតិភាគតិចឱ្យទទួលបានការអនុគ្រោះ ឬដោយផ្នែកណាមួយពីតម្លៃសិក្សា និងអាហារូបករណ៍ទៅសិក្សានៅសាលាជនជាតិភាគតិច។ ទោះជាយ៉ាងណាក៏ដោយ ការពិតគឺសិស្សនិស្សិតខ្មែរក្រោមក្រៅពីការតស៊ូជាមួយភាសាវៀតណាម ជាទូទៅមិនមានការអប់រំ

ល្អជាភាសាខ្មែរទេ។ សាលារៀនសាធារណៈនៅកម្ពុជាក្រោមមានការរៀបចំភាគច្រើននៅក្នុងសាលាវៀតណាម ដែលមានត្រឹមតែពីរម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្នាក់អក្ខរកម្មខ្មែរ។

ខ្មែរក្រោមភាគច្រើន មានវិធីតែមួយគត់ក្នុងការរៀនអាននិងសរសេរអក្សរខ្មែរ គឺសិក្សានៅសាលារៀនបាលីដែលដំណើរការដោយមានអ្នកស្ម័គ្រចិត្ត ព្រះសង្ឃខ្មែរក្រោមនៅវត្តអារាមឬក៏ត្រូវបួសជាព្រះសង្ឃទើបរៀនភាសាខ្មែរបាន។ គោលការណ៍នេះបានធ្វើឱ្យមានអនក្ខរកម្ម និងការអប់រំរបស់ខ្មែរសម្រាប់ក្មេងស្រីភាគច្រើនដែលមិនចេះអក្សរខ្មែរ និងបួសជាសង្ឃព្រះពុទ្ធសាសនានៅតាមវត្តអារាមបានទេ។ ក្នុងវត្តខ្មែរមួយនៅខេត្តព្រះត្រពាំង (ត្រាវិញ) ដែលបានទៅដល់ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ជាឧទាហរណ៍នៃសិស្សបឋមសិក្សាចំនួន ៥០នាក់ បានសិក្សានៅសាលាបាលីមានតែក្មេងស្រីពីរនាក់ប៉ុណ្ណោះ។ នៅសាលាវត្តមួយទៀតនៅខេត្តឃ្លាំង (សុកត្រាំង) អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរកឃើញថា សិស្សខ្មែរក្រោមដែលមានអាយុចន្លោះពី ៦-១២ឆ្នាំ អាចនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ ប៉ុន្តែគ្មាននរណាម្នាក់អាចសរសេរឈ្មោះរបស់ពួកគេជាភាសាខ្មែរហើយមានតែមួយឬពីរប៉ុណ្ណោះអាចសរសេរអក្សរខ្មែរបាន។

កាលពីឆ្នាំ ២០១១ ក្នុងសន្និបាតរបស់អង្គការសហប្រជាជាតិនាទីក្រុងហ្សឺណែវ ប្រទេសស្វីស មានរដ្ឋសមាជិកជាច្រើនបានផ្តល់អនុសាសន៍ដូចៗគ្នាទៅប្រទេសវៀតណាម មានរហូតទៅដល់ ៩៧ អនុសាសន៍ ដើម្បីដាក់ចេញឲ្យរដ្ឋាភិបាលវៀតណាមកែលម្អ និងអនុវត្ត ក្នុងនោះពាក់ព័ន្ធនឹងសិទ្ធិកុមារ និងសិទ្ធិមនុស្សក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល។ និងការរើសអើងពូជសាសន៍។ល។ ប៉ុន្តែតាមរយៈសន្និបាតរបស់អង្គការសហប្រជាជាតិ ស្តីពីការតាមដានរបាយការណ៍តាមកាលកំណត់ នាទីក្រុងហ្សឺណែវ កាលពីឆ្នាំ២០១៤ សន្និបាតបានរកឃើញថារដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមអនុវត្តបានខ្លះៗ ត្រឹមតែ១០ អនុសាសន៍ប៉ុណ្ណោះ[១៥]។

---

[15] សឹង សម្រេច៖ *របាយការណ៍ប៉ានប្រមាណចំពោះកិច្ចប្រតិបត្តិដែលប្រទេសវៀតណាមបានធ្វើនិងមិនបានធ្វើ នៅពាក់កណ្តាលកាលកំណត់* UPR លេខ A/HRC/RES/16/21 ចុះថ្ងៃទី១២ មេសា ២០១២ (Annex I C § 6) ប្រមាណ ៧០ទំព័រ បកប្រែក្រៅផ្លូវការជាភាសាខ្មែរ

កាលពីឆ្នាំ ២០១៦ វេទិកាអ្នកជំនាញស្តីពីសិទ្ធិជនជាតិដើមនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដែលមានអ្នកចូលរួមប្រមាណជាង ២០០នាក់ ដែលមកពីបណ្តាប្រទេសនានាជុំវិញពីភពលោក ភាគច្រើនគឺតំណាងឱ្យជនជាតិដើម ចាប់ពីថ្ងៃទី១១ ដល់ ១៥ ខែកក្កដា ឆ្នាំ២០១៦។ តាមរយៈវេទិកា សហព័ន្ធខ្មែរកម្ពុជាក្រោមបានធ្វើសេចក្តីរាយការណ៍ចំនួនពីរ ដែលទាក់ទងទៅនឹងប្រធានបទ គោលដៅអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិប្រកបដោយនិរន្តរភាព និងយុទ្ធសាស្រ្តនៃការអនុវត្តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិ ជនជាតិដើម។ របាយការណ៍បានលើកឡើងពីចំណុចសំខាន់ៗដូចជា៖ ការប្រើប្រាស់ភាសាអក្សរសាស្រ្ត និងភាសាខ្មែរជាសាធារណៈ ភាពមិនស្មើគ្នាក្នុងការរស់នៅរវាងខ្មែរ និងជនជាតិវៀតណាម ការរក្សាអត្តសញ្ញាណ និងវប្បធម៌របស់ខ្មែរជាដើម ។ល។

អង្គការ INDIG, Hawai, United States បានគាំទ្រអនុសាសន៍របស់ក្រុមប្រឹក្សារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ កាលពីថ្ងៃទី៤-១៥ ខែឧសភា ឆ្នាំ២០០៩ ដែលបានផ្តល់អនុសាសន៍មកប្រទេសវៀតណាម ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលគរុកោសល្យសម្រាប់គ្រូបង្រៀន។ INDIG បានកត់សម្គាល់ថាព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរក្រោម ត្រូវបានផ្តល់ការអប់រំផ្សេងៗទៀត ដើម្បីបង្រៀនដល់កុមារខ្មែរក្រោមនូវភាសាកំណើតរបស់ពួកគេ និងត្រូវតែបង្កើតកម្មវិធីដើម្បីធានាឱ្យមានគុណភាពនៃការអប់រំ[16]។

ក្នុងសេចក្តីថ្លែងការណ៍រួមលេខ១០ បានថ្លែងថារដ្ឋាភិបាលវៀតណាមបានបន្តដកសិទ្ធិអង្គការសាសនាពីសកម្មភាពអប់រំ ដែលជាទង្វើធ្វើឱ្យប៉ះពាល់ដល់ មនុស្សជំនាន់ក្រោយចំពោះភាពល្ងង់ខ្លៅនិងមានគុណវិបត្តិតាមរយៈការគ្រប់គ្រងរបស់បក្ស និងគោលនយោបាយអប់រំដែលមានគ្រោះហានិភ័យមិនខាន។

អង្គការបណ្តាញអន្តរជាតិមួយមានឈ្មោះថា International Network for Diplomacy Indigenous Governance Engaging in Nonviolence Organizing for

---

16 A/HRC/WG.6/5/VNM/3 23 February 2009, Original: ENGLISH/FRENCH , HUMAN RIGHTS COUNCIL Working Group on the Universal Periodic Review Fifth session Geneva, 4-15 May 2009, page9

Understanding & Self-Determination (INDIGENOUS) បានកត់សម្គាល់ថា កុមារខ្មែរក្រោមមិនអាចរៀនភាសាកំណើតរបស់ពួកគេនៅក្នុងសាលារដ្ឋបានទេ។ ការអនុវត្តរបស់រដ្ឋទាំងនេះ អាចបណ្តាលឱ្យយុវជនខ្មែរក្រោម បានបោះបង់ចោលសាលាមានកម្រិតខ្ពស់[១៧]។ សំណួរចោទសួរមួយនៅក្នុងសន្និបាតរបស់អង្គការសហប្រជាជាតិឆ្នាំ២០១៤ ស្តីពីរបាយការណ៍តាមកាលកំណត់របស់ប្រទេសវៀតណាម ប្រទេសន័រវេស្សបានចោទសួររដ្ឋាភិបាលវៀតណាមថា ដើម្បីឱ្យមានភាពរីកចំរើនក្នុងវិស័យការអប់រំសិទ្ធិមនុស្ស តើរដ្ឋាភិបាលវៀតណាមនឹងបង្កើតកម្មវិធីអប់រំសិទ្ធិមនុស្ស នៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ជាអាចិន្រ្តៃយ៍ទូទាំងប្រទេសទេ[១៨]?

**បទដ្ឋានគតិយុត្ត**

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានធ្វើវិសោធនកម្ម និងបានអនុម័តកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម នីតិកាលទី១៣ (XIII) សម័យ ប្រជុំលើក ទី៦ ជំពូក១ មាត្រា៥ ចំណុចទី២ បានចែងថា *"សមភាពជនជាតិដើមភាគតិច សាមគ្គីភាព ការគោរព និងជួយគ្នាទៅវិញទៅមក ដើម្បីអភិវឌ្ឍន៍ ហាមឃាត់សកម្មភាពទាំងអស់នៃការរើសអើងផ្អែកជនជាតិភាគតិច"* ។ ចំណុចទី៣ បានចែងថា *"រាល់ជនជាតិមានសិទ្ធិប្រើប្រាស់ភាសា និយាយ និងសរសេរភាសារបស់ខ្លួន ដើម្បីរក្សាអត្តសញ្ញាណជាតិ ការលើកកម្ពស់ប្រពៃណី ការអនុវត្តន៍ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ បានល្អរបស់ពួកគេ"*។ ជំពូក២ មាត្រា១៤ កថាខណ្ឌ១ បានចែងថា *"សិទ្ធិមនុស្ស គ្រប់រូបសិទ្ធិពលរដ្ឋក្នុងនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ត្រូវបានការទទួលស្គាល់ ការគោរព ការការពារ និងធានាដោយរដ្ឋធម្មនុញ្ញនិងច្បាប់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម"*។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩២ មាត្រា៥៩ ចែងថា *"ប្រជាពលរដ្ឋមានសិទ្ធិក្នុងការអប់រំនិងបណ្តុះបណ្តាវិជ្ជាជីវៈគ្រប់ទម្រង់ទាំងអស់។ រដ្ឋជួយសម្រួលដល់ការរៀនសូត្រពីសង្គមដើម្បីអភិវឌ្ឍទេពកោសល្យ។ អាហារូបករណ៍សម្រាប់សិក្សា គឺជាគោលនយោបាយរបស់រដ្ឋ*។

---

[១៧] Human rights council working group on Universal Periodic Review Eighteen Session, Geneva, 27 January-07 February, 2014 page10

[១៨] https://www.ohchr.org/EN/HRBodies/UPR/Pages/VNindex.aspx

រដ្ឋធម្មនុញ្ញឆ្នាំ២០១៣ មាត្រា៤២ នៃច្បាប់នេះដែរចែងថា "*ប្រជាពលរដ្ឋមានសិទ្ធិដើម្បីកំណត់ជាតិសាសន៍របស់ពួកគេ ការប្រើភាសាកំណើត និងការជ្រើសរើសភាសាដែលពួកគេចង់សិក្សា*"។ មាត្រា៥៩នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩២នេះដែរ បានចែងថា "*រៀនសូត្រ គឺជាសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ចនិងដោយឥតគិតថ្លៃ។ ប្រជាពលរដ្ឋមាន សិទ្ធិក្នុងការអប់រំនិងបណ្តុះបណ្តាវិជ្ជាជីវៈនៅក្នុងគ្រប់ទម្រង់ទាំងអស់។ រដ្ឋនឹងជួយសម្រួលដល់ការរៀនសូត្រ ដើម្បីអភិវឌ្ឍទេពកោសល្យ*"។

ច្បាប់អប់រំនៃសាធារណរដ្ឋសង្គមនិយមវៀតណាមលេខ ២៣/VBHN-VPQH ត្រូវបានធ្វើវិសោធនកម្មកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២៩១៣ នារដ្ឋធានីហាណូយ[១៩] មាត្រា៥ ចំណុច១ បានចែងថា៖ "*ការអប់រំត្រូវតែមានមូលដ្ឋានទូលំទូលាយ អនុវត្តជាក់ស្តែង និងជាប្រព័ន្ធទំនើបកម្ម។ ភ្ជាប់សារៈសំខាន់ដល់ការអប់រំនៃគំនិតនិងស្មារតីប្រជាជន។ លើកកម្ពស់ទំនៀមទម្លាប់ ប្រពៃណី, អត្តសញ្ញាណវប្បធម៌របស់ជនជាតិ*"។ ចំណុច ២.២ ចែងបន្តថា៖ "*កម្មវិធីអប់រំត្រូវតែធានានូវភាពទំនើបកម្ម ស្តេរភាពភាពស៊ីសង្វាក់ការអនុវត្តភាពសមហេតុផលរវាងកម្រិតអប់រំនិងកម្រិតនៃការបណ្តុះបណ្តាល។ បង្កើតលក្ខខណ្ឌសម្រាប់ការបែងចែកផ្ទេរ និងផ្ទេររវាងកម្រិតវគ្គបណ្តុះបណ្តាល និងទម្រង់នៃការអប់រំនៅក្នុងប្រព័ន្ធអប់រំថ្នាក់ជាតិ។ ជាមូលដ្ឋានសម្រាប់ធានានូវគុណភាពការអប់រំឱ្យបានទូលំទូលាយ និងបំពេញតាមតម្រូវការនៃសមាហរណកម្មអន្តរជាតិ*"។

មាត្រា៧ នៅត្រង់ចំណុច២ បានចែងថា៖ "*រដ្ឋត្រូវតែបង្កលក្ខណសម្រាប់ជនជាតិភាគតិច ដើម្បីឱ្យពួកគេបានរៀនភាសានិងអក្សរសាស្ត្រជាតិរបស់ពួកគេ ដើម្បីអភិរក្សនិងលើកកម្ពស់អត្តសញ្ញាណវប្បធម៌ជនជាតិភាគតិច និងជួយឱ្យសិស្សានុសិស្សជនជាតិដើមភាគតិចដែលអាចទទួលយក។ ចំណេះដឹងនៃការរៀននៅតាមសាលារៀននិងស្ថាប័នអប់រំផ្សេងៗទៀត។ ការបង្រៀន និងការរៀនភាសា និងសរសេរជាភាសាជនជាតិភាគតិចត្រូវអនុវត្តតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល*"។

---

[១៩] https://thuvienphapluat.vn/van-ban/Bo-may-hanh-chinh/Van-ban-hop-nhat-២៣-VBHN-VPQH-nam-២០១៣-hop-nhat-Luat-giao-duc-២២០០៤៤.aspx

មាត្រា១០នៃច្បាប់អប់រំឆ្នាំ២០១៣នេះដែរ នៅត្រង់កថាខ័ណ្ឌទី៤បានចែងថា៖ "*រដ្ឋយកចិត្តទុកដាក់និងបង្កលក្ខណសម្រាប់កុមារជនជាតិដើមភាគតិច និងកុមារនៃគ្រួសារនៅតំបន់ជួបប្រទះការលំបាកខាងសេដ្ឋកិច្ច សង្គម ពិសេសអ្នកទទួលផលពីគោលនយោបាយអនុគ្រោះជនពិការ និងអ្នកទទួលផលនៃគោលនយោបាយសង្គមផ្សេងៗទៀត ដើម្បីបានអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេក្នុងការទទួលបានការអប់រំ*"។

សេចក្ដីសម្រេចលេខ ៨២/២០១០/NĐ-CP ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ នារដ្ឋធានីហាណូយ[២០] មាត្រា៣ បានចែងថា៖ "*១.ជនជាតិភាគតិចអាចស្នើសុំនិងតម្រូវការក្នុងការរៀនភាសាជនជាតិភាគតិច។ ២.ទម្រង់នៃភាសាជនជាតិដើមភាគតិចត្រូវបានបង្រៀន និងសិក្សានៅតាមសាលារៀន ត្រូវតែជាទម្រង់បែបរូបភាពដើម/បែបបុរាណដែលសហគមន៍របស់ជនជាតិផាគតិចបានប្រើប្រាស់ជាសាធារណៈ ហើយត្រូវបានទទួលស្គាល់ដោយភ្នាក់ងារជំនាញភាសាដែលត្រូវបានអនុម័តដោយអាជ្ញាធរមានសមត្ថកិច្ចរួចហើយ។ ៣.កម្មវិធីភាសាជនជាតិដើមភាគតិច និងសៀវភៅសិក្សាត្រូវចងក្រងនិងវាយតម្លៃតាមបទប្បញ្ញត្តិរបស់រដ្ឋមន្ត្រីក្រសួងអប់រំ និងបណ្ដុះបណ្ដាល។ ៤.គ្រូបង្រៀនភាសាជនជាតិភាគតិចត្រូវបំពេញតាមស្តង់ដារនៃការបណ្ដុះបណ្ដាលដែលត្រូវគ្នា និងត្រូវបានបណ្ដុះបណ្ដាលក្នុងភាសាជនជាតិភាគតិចនៅមហាវិទ្យាល័យ មហាវិទ្យាល័យគរុកោសល្យ និងនាយកដ្ឋានគរុកោសល្យ។ ៥.មូលដ្ឋានគ្រឹះ និងសម្ភារៈសម្រាប់បង្រៀនភាសាជនជាតិភាគតិចត្រូវគោរពតាមបទប្បញ្ញត្តិរបស់រដ្ឋមន្ត្រីអប់រំ និងបណ្ដុះបណ្ដាល*"។ ក្នុងសេចក្ដីសម្រេចនេះដែរ មាត្រា៦ បានចែងថា៖ "*១.ភាសាជនជាតិភាគតិចគឺជាមុខវិជ្ជាសិក្សាក្នុងគ្រឹះស្ថានអប់រំទូទៅ និងជាមជ្ឈមណ្ឌលអប់រំបន្ត។២.ការបង្រៀនភាសារបស់ជនជាតិភាគតិចត្រូវបានអនុវត្តតាមទម្រង់នៃការរៀបចំការបង្រៀននៅក្នុងគ្រឹះស្ថានអប់រំទូទៅ និងមជ្ឈមណ្ឌលសម្រាប់ការអប់រំបន្ត*"។

[២០] https://thuvienphapluat.vn/van-ban/Giao-duc/Nghi-dinh-82-2010-ND-CP-day-va-hoc-tieng-noi-chu-viet-cua-dan-toc-108787.aspx

សារាចរលេខ២៤/២០១៤/TT-BGDĐT ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ នាវរដ្ឋធានីហាណូយ[២១]ដែលមានបីមាត្រា ក្នុងនោះមាត្រា១ បានប្រកាសឱ្យប្រើជាមួយសារាចរសារាចរនេះនូវកម្មវិធីភាសាខ្មែរក្នុងការអប់រំបឋមសិក្សានិងមធ្យមសិក្សា។ មាត្រា២ បានប្រកាសថា សារាចរនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០១៤។ សារាចរនេះគឺជាប្រធានបទសម្រាប់កម្មវិធីសិក្សាភាសាខ្មែរ ក្នុងកម្រិតការអប់រំបឋមសិក្សា និងមធ្យមសិក្សា ហើយដែលជាមូលដ្ឋានគ្រឹះសម្រាប់តែងសៀវភៅសិក្សា និងរៀបចំបង្រៀនភាសាខ្មែរសម្រាប់សិស្សជនជាតិដើមភាគតិចខ្មែរ។

ដូចដែលបានលើកឡើងខាងដើម សាធារណរដ្ឋសង្គមនិយមយៀកណាម ជារដ្ឋបានចូលជាសមាជិករបស់អង្គការសហប្រជាជាតិ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៧។ ក្រោយពីប្រទេសនេះបានចូលជាសមាជិកពេញសិទ្ធិហើយ ក៏បានផ្តល់សច្ចាប័ននិងទទួលយកលិខិតូបករណ៍មួយចំនួនដែលអនុម័តដោយអង្គការសហប្រជាជាតិ ក្នុងនោះមានដូចជាកតិកាសញ្ញា អនុសញ្ញាអន្តរជាតិ និងសេចក្តីប្រកាសមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិមនុស្សសម្រាប់អនុវត្តក្នុងប្រទេសរបស់ខ្លួន។

ធម្មនុញ្ញអង្គការសហប្រជាជាតិ បានចែងថា សហគមន៍អន្តរជាតិបានយល់ព្រមទទួលយកកាតព្វកិច្ច ដើម្បីជានាបង្កើតឱ្យមានសិទ្ធិមនុស្ស ជាទូទៅអាចនឹងផ្តល់នូវកិច្ចការពារដល់បុគ្គលទាំងឡាយ ក្រុម និងបណ្តាសហគមន៍នានា ដែលត្រូវរងនូវការគំរាមគំហែងពីសំណាក់រដ្ឋាភិបាលរំលោភទៅលើសិទ្ធិរបស់ពួកគេ។ អំណាចនៃច្បាប់ក្នុងស្រុក ត្រូវដាក់ឱ្យនៅក្រោមអំណាចនៃច្បាប់អន្តរជាតិ ដែលបានបង្កើតនូវក្របខ័ណ្ឌមួយ ដើម្បីជានានូវកិច្ចការពារជាលក្ខណអន្តរជាតិ។

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ឆ្នាំ ២០០៩ ត្រង់មាត្រា១១ បានចែងថា *“ជនជាតិភាគតិចមានសិទ្ធប្រតិបត្តិនិងធ្វើឱ្យរស់រវើកឡើងវិញនូវប្រពៃណីនិងទំនៀមទម្លាប់នៃវប្បធម៌របស់ខ្លួន រួមទាំងសិទ្ធិក្នុងការថែរក្សា ការពារ និងអភិវឌ្ឍ*

[២១] https://thuvienphapluat.vn/van-ban/Giao-duc/Thong-tu-24-2014-TT-BGDDT-Chuong-trinh-tieng-Khmer-cap-tieu-hoc-trung-hoc-co-so-241531.aspx

*ដែលបង្ហាញពីអត្តសញ្ញាណវប្បធម៌របស់ខ្លួន ដែលមានពីអតីតកាល បច្ចុប្បន្ន និងអនាគត ដូចជា តំបន់បូរាណវិទ្យានិងតំបន់ប្រវត្តិសាស្ត្រ បូរាណវត្ថុ រចនាប័ថ្ម ពីធីបុណ្យ បច្ចេកវិទ្យា សិល្បៈទស្សនីយភាពនិងការសម្តែងសិល្បៈ និងអក្សរសាស្ត្រ*"។ និងមាត្រា១២ បានចែងថា *ជនជាតិដើមភាគតិច*"មានសិទ្ធិបង្ហាញ ប្រតិបត្តិ អភិវឌ្ឍ និងបង្រៀនប្រពៃណីខាងជំនឿ សាសនារបស់ខ្លួនទាំងទំនៀមទម្លាប់និងពីធីបុណ្យផ្សេងៗ ហើយមានសិទ្ធិរក្សាការពារ និង មានសិទ្ធិជាឯកជនក្នុងការប្រើប្រាស់ និងគ្រប់គ្រងវត្ថុសម្រាប់ពីធីបុណ្យនានា*"។ មាត្រា២៥ *ជនជាតិដើមមានសិទ្ធិក្នុងកិច្ចគាំពារ និងពង្រឹងនូវទំនាក់ទំនងដោយខ្សែកផ្នែកស្មារតី ជាមួយ នឹងដី ដែនដី ទឹក និងឆ្នេរសមុទ្រ ដែលពួកគេបានតាំងនៅ និងប្រើប្រាស់ជាប្រពៃណី ព្រមទាំងប្រភពធនធានផ្សេងទៀត និងរក្សាការទទួលខុសត្រូវសម្រាប់មនុស្ស ជំនាន់ក្រោយ ចំពោះរឿងនេះ*។ មាត្រា២៦ និង មាត្រា២៧ បានចែងក្នុងខ្លឹមសារថា "*ជនជាតិដើមភាគតិច មាន សិទ្ធិគ្រប់គ្រងលើប្រភពធនធាន និងប្រើប្រាស់ និងអភិវឌ្ឍន៍លើដីដែលមានតាម ប្រពៃណីរបស់ពួកគេ។ រដ្ឋត្រូវទទួលស្គាល់ស្របច្បាប់ ហើយនិងផ្តល់កិច្ច ការពារប្រភព ធនធានទាំងនេះ ដោយឯករាជ្យ មិនលំអៀង និង ប្រកបដោយតម្លាភាព ដោយគោរពទទួល ស្គាល់ច្បាប់ ប្រពៃណី ទំនៀមទម្លាប់ និងប្រព័ន្ធនៃការកាន់កាប់ដី សម្រាប់ជនជាតិដើម ដើម្បី ទទួលស្គាល់ និងធ្វើការវិនិច្ឆ័យសិទ្ធិនៃជនជាតិដើម ចំពោះដី ដែនដី និងប្រភពធនធាន ដោយរាប់បញ្ចូលទាំងអ្វីដែលពួកគេបានកាន់កាប់មកជាប្រពៃណី ឬក៏តាំងនៅឬប្រើប្រាស់*"។

សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ សេចក្តីថ្លែងការណ៍ជាសកល ស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មាត្រា១៨ និង១៩នៃសេចក្តីប្រកាសនេះ បានចែង *ទាក់ទងទៅនឹងសិទ្ធិគោរពប្រតិបត្តិនិងជំនឿសាសនា សិទ្ធិសេរីភាពក្នុងការសម្តែង មតិនិងទទួលបានព័ត៌មាន ការសិក្សារៀនសូត្រវប្បធម៌និងអក្សរសាស្ត្ររបស់ខ្លួន។ ការប្រើប្រាស់ សិទ្ធិទាំងនេះដោយគ្មានការរើសអើងប្រកាន់ញើសម្ភ ដោយគ្មានការជ្រៀតជ្រែក*។ សេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនដែលមានក្រុម ភាគតិចជាតិ ឬជាតិពន្ធ សាសនា និងភាសា[២២] នៅខណៈដែលសេចក្តីសម្រេចរបស់មហា

[២២] មហាសន្និបាត អ.ស.ប៖ *សេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនមានសិទ្ធិទទួលបានសញ្ជាតិ ឬជាតិសាសន៍ សាសនា និងភាសាដើមកំណើត* សេចក្តីសម្រេចលេខ ៤៧/១៣៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២ http://www.ohchr.org/EN/ProfessionalInterest/Pages/Minorities.aspx

សន្និបាតមានចងជាកាតព្វកិច្ចផ្លូវច្បាប់ទៅដល់រដ្ឋសមាជិករបស់ អ.ស.ប យ៉ាងណាក្តី សេចក្តីសម្រេចទាំងនេះបង្ហាញពីការប្តេជ្ញាតាមបែបនយោបាយដ៏រឹងមាំមួយរបស់រដ្ឋនានា ក្នុងការគោរពគោលការណ៍ទាំងឡាយដែលមានចែងក្នុងសេចក្តីសម្រេចនោះ។ សេចក្តីប្រកាសនេះជំរុញឱ្យរដ្ឋចូលរួមក្នុងការលើកកម្ពស់ឱ្យបានសកម្មទៅដល់លទ្ធភាព ដែលអាចឱ្យក្រុមភាគតិចទទួលបានសិទ្ធិរបស់ខ្លួនដោយស្មើភាពគ្នាជាមួយនឹងក្រុមផ្សេងទៀត។ រដ្ឋនានាគប្បី *"ការពារការកើតមាន និងការពារអត្តសញ្ញាណជាតិ ឬជាតិពន្ធ វប្បធម៌ សាសនា និងភាសារបស់ក្រុមភាគតិច"* និង *"បង្កលក្ខខណ្ឌអំណោយផលដល់ការលើកកម្ពស់អត្តសញ្ញាណទាំងនេះ"*។ សេចក្តីប្រកាសនេះទទួលស្គាល់ថា *ក្រុមភាគតិចមានសិទ្ធិក្នុងការចូលរួមនៅក្នុងជីវភាពផ្នែកវប្បធម៌ សាសនា សង្គម សេដ្ឋកិច្ច និងសាធារណៈ ក៏ដូចជាក្នុងដំណើរការសម្រេចចិត្តនៅថ្នាក់ជាតិ។* អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ឆ្នាំ១៩៦៥[២៣] រដ្ឋាភិបាលវៀតណាមបានទទួលស្គាល់ កាលពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៨២ មាត្រា ២ តម្រូវឱ្យរដ្ឋភាគីនីមួយៗសន្យា *"មិនធ្វើអំពើ ឬការអនុវត្តណាមួយនៃការរើសអើងពូជសាសន៍"* *និង "ធានាថា អាជ្ញាធរ និងស្ថានប័នសាធារណៈទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ធ្វើស្របតាមកាតព្វកិច្ចនេះ"*។ នៅពេលដែលច្បាប់ បទដ្ឋាន ឬគោលនយោបាយជាតិបង្កើតឱ្យមាន ឬមានការរើសអើងពូជសាសន៍ រដ្ឋភាគីត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការសើរើច្បាប់ បទដ្ឋាន និងគោលនយោបាយ ទាំងនោះ។ មាត្រា៥ នៃអនុសញ្ញានេះបានចែងថា *"រដ្ឋជាភាគីទាំងឡាយត្រូវហាមឃាត់និងលុបបំបាត់ចោលការប្រកាន់ពូជសាសន៍គ្រប់ទម្រង់ទាំងអស់ ហើយត្រូវធានាផ្តល់ឲ្យបុគ្គលម្នាក់ៗនូវសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយឥតបែងចែករវាងភេទ ពណ៌ សម្បុរ សញ្ជាតិ ឬជនជាតិអ្វីឡើយ។*

---

[២៣] មហាសន្និបាត អ.ស.ប៖ *កតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍* សេចក្តីសម្រេចលេខ ២១០៦ (១០) ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ http://www.ohchr.org/EN/ProfessionalInterest/Pages/CERD.aspx

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចូលជាធរមាននៅឆ្នាំ ១៩៧៦។ សិទ្ធិទាំងឡាយដែលមានចែងក្នុងលិខិតូបករណ៍សិទ្ធិមនុស្សនេះមាន "**សិទ្ធិទទួលបាននូវការអប់រំ**"។ ក្នុងមាត្រា១៣ បានចែងដូចខាងក្រោម៖

១. រដ្ឋជាភាគីនៃកតិកាសញ្ញានេះទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូប ដើម្បីទទួលបានការអប់រំ។ រដ្ឋជា ភាគីព្រមព្រៀងគ្នាថា ការអប់រំត្រូវនាំឆ្ពោះទៅរកការរីកចម្រើនពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងអត្ថន័យនៃសេចក្តីថ្លៃថ្នូរបស់មនុស្ស និងពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ រដ្ឋជាភាគីបាន ព្រមព្រៀងគ្នាទៀតថា ការអប់រំ ត្រូវធ្វើឱ្យមនុស្សគ្រប់រូបអាចដើរតួនាទីមានប្រយោជន៍ក្នុងសង្គមសេរី លើកស្ទួយការយោគយល់ ការអត់ឱន និងមិត្តភាពរវាងប្រជាជាតិ និងរវាងក្រុមពូជសាសន៍ ក្រុមជាតិនិយម ឬក្រុមសាសនាទាំងអស់ ព្រមទាំងជ្រោមជ្រែងសកម្មភាពរបស់អង្គការសហប្រជាជាតិដើម្បីរក្សាសន្តិភាព។

២. រដ្ឋជាភាគីនៃកាតិកាសញ្ញានេះ ទទួលស្គាល់ថា ដើម្បីសម្រេចបានការប្រើប្រាស់ពេញលេញនូវសិទ្ធិ ទាំងនេះរួមមាន៖ ក.ការអប់រំកម្រិតបឋមសិក្សា ត្រូវតែជាកាតព្វកិច្ចហើយឥតគិតថ្លៃសម្រាប់អ្នកទាំងអស់គ្នា។ ខ.ការអប់រំកម្រិតមធ្យមសិក្សាតាមទ្រង់ទ្រាយផ្សេងៗ រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យមត្រូវ តែបើកឱ្យមានជាទូទៅនិងមនុស្សគ្រប់គ្នាអាចចូលរៀនបាន តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេសតាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សាដោយឥតគិថ្លៃ។ គ.ការអប់រំកម្រិតឧត្តមសិក្សា ត្រូវតែបើក ចំហរដល់មនុស្សគ្រប់រូបដោយស្មើភាពតាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ។ ឃ.ការអប់រំមូលដ្ឋាន ត្រូវតែជំរុញ ឬពង្រឹងតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានសម្រាប់អ្នក ដែលមិនបានទទួល ឬមិនបានបញ្ចប់កម្រិតបឋមសិក្សារបស់ខ្លួន។ ង.ត្រូវតែបន្តយ៉ាងសកម្មលើការអភិវឌ្ឍន៍បណ្តាញសិក្សាធិការ គ្រប់លំដាប់បង្កើតប្រព័ន្ធអាហារូបករណ៍ឱ្យបានគ្រប់គ្រាន់ និងបង្កើតជាលំដាប់នូវលក្ខណ្ឌសម្ភារៈរបស់បុគ្គលិកសិក្សា។

៣. រដ្ឋជាភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់មាតាបីតា និងអាណា-ព្យាបាលស្រប ច្បាប់ បើសមស្របដើម្បីជ្រើសរើសសាលារៀន ក្រៅពីសាលារៀនសាធារណៈ

ឱ្យកូនរបស់ខ្លួន ប៉ុន្តែត្រូវតាមវិធានអប្បរិមាដែលរដ្ឋអាកំណត់ ឬអនុម័តក្នុងវិស័យអប់រំ និងរ៉ាប់រងការអប់រំសាសនា និងសីលធម៌របស់កូន ស្របតាមជំនឿផ្ទាល់របស់ពួកគេ។

៤. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវយកមកបកស្រាយថា ប៉ះពាល់ដល់សេរីភាពនៃរូបវន្តបុគ្គល និងនីតិបុគ្គលក្នុងការបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សា លើកលែងតែគោលការណ៍ដែលបានចែងក្នុង កថាខ័ណ្ឌ១នៃមាត្រានេះត្រូវបានគោរព និងឱ្យតែការអប់រំដែលផ្តល់ឱ្យនៅក្នុងគ្រឹះស្ថានទាំងនោះ ស្របទៅនឹង បទដ្ឋានអប្បរមាដែលអាចកំណត់ដោយរដ្ឋ។

មាត្រាបទដ្ឋានគតិយុត្តនានា ទាំងច្បាប់ជាតិរបស់វៀតណាម ទាំងច្បាប់សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (អនុសញ្ញា កតិកាសញ្ញា និងលិខិតូបករណ៍ ដែលពាក់ព័ន្ធនឹងគោលការណ៍សិទ្ធិមនុស្ស) គឺបានចែងយ៉ាងច្បាស់ក្នុងការការពារសិទ្ធិសេរីភាពនានានៅលើសកលលោក ជាពិសេសក្នុងវិស័យអប់រំ ក្នុងនោះ ក៏មានខ្មែរក្រោមផងដែរ ដែលត្រូវតែទទួលបានសិទ្ធិកក្នុងការទទួលបានការអប់រំគ្រប់វិស័យ និងការពារដោយបទដ្ឋានច្បាប់ទាំងនោះ។

# ៦. សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៦.១. សន្និដ្ឋាន

សតវត្សទី២១នេះ គឺសម័យកាលទំនើបកម្មមួយ ដែលមនុស្សម្នាសឹងតែក្នុងសកលលោកមានលទ្ធភាពគ្រប់គ្រាន់ទទួលបានការសិក្សាស្វែងយល់ និងទទួលបានចំណេះដឹងថ្មីៗទៅតាមសម័យកាលវិវឌ្ឍនៃបច្ចេកវិទ្យា។ ពួកគេមានសេរីភាពពេញលេញនៅគ្រប់ទិសទីទៅតាមលទ្ធភាព និងសមត្ថភាពដែលពួកគេធ្វើទៅបាន។ ភាពរីកចំរើនទាំងនេះ មានការប្រែប្រួលតាមរយៈរបបគ្រប់គ្រងនៃប្រទេស តំបន់ ពីទ្វីបមួយទៅទ្វីបមួយ ដោយនិយមទៅលើគោលការណ៍សេរីនិយមដែលត្រូវបាន និងកំពុងតែឈានទៅរកការលុបបំបាត់នូវរាល់ទង្វើទាំងឡាយដែលចេញមកពីទង្វើផ្តាច់ការ អំពើឈ្លានពាន ការបៀតបៀន ការជិះជាន់ និងការរំលោភបំពាន ហើយទង្វើទាំងនោះសឹងតែត្រូវបានរលាយសាបសូន្យ ហើយងាកមករកការគោរពគោលការណ៍សិទ្ធិមនុស្ស ស្រឡាញ់ និងរួបរួមកសាងវិថីសន្តិភាវូបនីយកម្មជាក់ជាពុំខាន់។

ស្ថានភាពទូទៅនៃការអប់រំខេមរភាសាសម្រាប់ខ្មែរក្រោមនៅខេត្តត្រាវិញ (ព្រះត្រពាំង) នា០៦ឆ្នាំចុងក្រោយ (២០១២-២០១៨) ស្ថានភាពនៃការអប់រំនេះ ឃើញថាមានភាពកាន់តែប្រសើរជាងមុន ប្រសិនបើប្រៀបធៀបទៅនឹងការអប់រំនាទសវត្សរ៍ឆ្នាំ១៩៧០-៩០។ ការសិក្សាវិជ្ជាខេមរភាសា ត្រូវបានរដ្ឋអំណាចវៀតណាមយកចិត្តទុកដាក់ស្របទៅតាមគោលនយោបាយអប់រំ និងបណ្តុះបណ្តាលរបស់រដ្ឋសម្រាប់អប់រំដល់ ប្រជាជនទូទៅ ជាពិសេសមានគោលនយោបាយចំពោះជនជាតិភាគតិច ក្នុងនោះក៏មានខ្មែរក្រោមដែរ។ កម្មវិធីសិក្សាខេមរភាសាសម្រាប់ជនជាតិខ្មែរក្រោម គឺឃើញមានបញ្ចូលទៅនឹងកម្មវិធីសិក្សានៅសាលាចំណេះ ទូទៅរបស់រដ្ឋ នេះដោយឡែកនៅខេត្តត្រាវិញ (ព្រះត្រពាំង) មានសឹងតែគ្រប់ទីកន្លែងនៅតាមតំបន់ដែលមាន ខ្មែរក្រោមរស់នៅច្រើន ហើយបានចូលរួមសិក្សាវិជ្ជាខេមរភាសា មានសឹងតែគ្រប់តំបន់ដែរ សម្រាប់ការសិក្សា ចាប់ពីថ្នាក់មេតេយ្យរហូតដល់ថ្នាក់ទី១២។ រីឯកម្មវិធីសិក្សាវិជ្ជាខេមរភាសានៅតាមសាលាវត្តក្នុងរដូវវិស្សមកាល ក៏មានសុទ្ធសឹងគ្រប់វត្តដែរ ហើយមានសិស្សដែលបានសិក្សាចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ នៃកម្រិតបឋម សិក្សា។

ដោយឡែកកម្មវិធីសិក្សាវិជ្ជាបាលីភាសា និងធម្មវិន័យសិក្សានៅតាមវត្តអារាមព្រះពុទ្ធសាសនា ក៏ឃើញ ថាមានការបើកចំហរយ៉ាងទូលាយសម្រាប់សមណសិស្ស យុវជន យុវនារី ខ្មែរក្រោម ទទួលបានការសិក្សា នៅតាមវត្តអារាមនានា។ នៅខេត្តត្រាវិញ (ព្រះត្រពាំង) មានវត្តអារាមព្រះពុទ្ធសាសនាចំនួន ១៤៤វត្ត ក្នុងនោះមានសុទ្ធសឹងតែគ្រប់វត្តទាំងអស់ត្រូវបានអនុញ្ញាតិដោយរដ្ឋអំណាចវៀតណាម ហើយគ្រប់គ្រងដោយសមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិ រួមសហការជាមួយមន្ទីរអប់រំ និងបណ្តុះបណ្តាលខេត្ត ព្រះសង្ឃ និង យុវជន យុវនារីខ្មែរក្រោមបានចូលរួមសិក្សាចាប់ពីថ្នាក់ពុទ្ធិកសិក្សាបឋមភូមិរហូតដល់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ។

ទោះជាការសិក្សារៀនសូត្ររបស់ពលរដ្ឋខ្មែរក្រោម នៅឯកម្ពុជាក្រោមនៅមាន កម្រិតទាប តែនេះដោយសារតែប្រព័ន្ធសិក្សាធិការអក្សរសាស្រ្តខ្មែរឋិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលវៀតណាម។ រាល់មុខវិជ្ជាសិក្សាទាំងអស់ គឺត្រូវបានត្រួតពិនិត្យ និង ដាក់កំហិតឱ្យព្រះសង្ឃនិងកូនខ្មែរក្រោមសិក្សា ឧទាហរណ៍ ដូចជា មុខវិជ្ជាភូមិសាស្រ្តនិង ប្រវត្តិសាស្រ្ត

ខ្មែរ គឺត្រូវបានហាមឃាត់ជាដាច់ខាត់មិនឲ្យរៀនឡើយ ក្នុងនោះក៏មានការសិក្សាអប់រំ ស្វែងយល់ ពីវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរផងដែរ។ ចំណុចទាំងនេះ អាចនឹងធ្វើឱ្យកូនចៅខ្មែរក្រោមងាយនឹងភ្លេចបន្តិចម្តងៗអំពីអត្តសញ្ញាណ វប្បធម៌ អរិយធម៌ ប្រវត្តិនៃជាតិសាសន៍របស់ខ្លួន ហើយពួកគេអាចនឹងក្លាយទៅជាជនជាតិភាគតិចទាំងស្រុង នៅលើដែនដីកំណើតរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ភាពក្លាហាន ការអត់ធ្មត់ និងការ ព្យាយាម ចំណុចទាំងនេះធ្វើឱ្យពួកគាត់នៅតែមានការទទួលស្គាល់ជាសកលថា ខ្មែរក្រោម គឺជាជនជាតិដើម ដែលកំពុងរស់នៅឯដែនដីកម្ពុជាក្រោម សាធារណរដ្ឋសង្គមនិយម វៀតណាម (វៀតណាមខាងត្បូង)។ បច្ចុប្បន្ននេះ ពួកគាត់នៅតែរក្សាបានយ៉ាងខ្ជាប់ខ្ជួននូវ ប្រពៃណី ទំនៀមទំលាប់ វប្បធម៌ អរិយធម៌ និងអក្សរសាស្ត្ររបស់ខ្លួនជាខ្មែរ និងពុទ្ធសាសនា ខ្មែរជាដើម។

ទោះបីដែនដីកម្ពុជាក្រោមដែលឋិតនៅក្រោមការគ្រប់គ្រងដោយអាជ្ញាធរវៀតណាម បើគិតជាផ្លូវការមកទល់ពេលនេះអស់រយៈ៦៩ឆ្នាំមកហើយ ភាពរស់រវើកនៃវប្បធម៌ អរិយធម៌ ទំនៀមទំលាប់ ប្រពៃណី អក្សរសាស្ត្រខ្មែរ និងព្រះពុទ្ធសាសនា គឺពលរដ្ឋខ្មែរក្រោមនៅតែរក្សាកេរដំណែលទាំងនេះបានយ៉ាងខ្ជាប់ខ្ជួន បើទោះបីមានការរឹតបន្តឹងពីសំណាក់រដ្ឋអំណាចវៀតណាមក៏ដោយ។ ប្រជាពលរដ្ឋខ្មែរក្រោម នៅតែមានភាពក្លាហាន និងក្រោកឡើងដើម្បីទាមទារសេរីភាពគ្រប់ជំនាន់ និងគ្រប់កាលៈទេសៈទាំងអស់។

## ៦.២. សំណូមពរ

- **វិស័យវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ**

រដ្ឋាភិបាលវៀតណាម គួរតែបង្កើនឱ្យមានកម្មវិធីសិក្សាក្នុងវិស័យវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ សម្រាប់ពលរដ្ឋខ្មែរក្រោម ដែលមាននៅតាមសាលាធារណរបស់រដ្ឋ និងនៅតាមសាលាដែលមាននៅតាមវត្តអារាមព្រះពុទ្ធសាសនា និងមិនត្រូវកម្លាយនាមវត្តអារាមព្រះពុទ្ធសាសនាខ្មែរទៅជាភាសាវៀតណាម។ បូជនីយដ្ឋាន រមណីយដ្ឋាន ដែលជាបូរាណដ្ឋានរបស់បុព្វបុរសខ្មែរ ត្រូវតែរក្សាឈ្មោះដើមរបស់ខ្មែរ មិនត្រូវកែកាឡៃ សិល្បៈ វប្បធម៌របស់ខ្មែរ ដូចជា បទចម្រៀង បទភ្លេង និង គ្រឿងតុបតែងសិល្បៈ ដោយបញ្ចូលលាយឡំជាមួយវប្បធម៌របស់វៀតណាម ហើយត្រូវតែផ្តល់សិទ្ធិគ្រប់គ្រាន់សម្រាប់ពលរដ្ឋខ្មែរក្រោម ក្នុងការថែរក្សា និងអនុវត្ត ទំនៀមទំលាប់ ប្រពៃណីខ្មែរ ដោយពុំមានលក្ខខណ្ឌ

និងរារាំងហាមឃាត់ និង លុបបំបាត់ឡើយ ស្របទៅតាមសេចក្ដីប្រកាស ស្ដីសិទ្ធិមនុស្ស របស់ជនជាតិដើម ឆ្នាំ២០០៩ មាត្រា១១ *សិទ្ធិប្រតិបត្តិប្រពៃណី ទំនៀមទំលាប់ វប្បធម៌ សិទ្ធិរក្សាការពារ និងអភិវឌ្ឍន៍អត្តសញ្ញាណវប្បធម៌ បុរាណវិទ្យា ប្រវត្តិសាស្ត្របុរាណវត្ថុ រចនាបថ ពិធីបុណ្យ បច្ចេកវិទ្យា សិល្បៈទស្សនីយភាព និងអក្សរសាស្ត្រ*។ មាត្រា១២ *ប្រតិបត្តិបង្រៀនប្រពៃណី ខាងជំនឿ ទំនៀមទំលាប់ ប្រើប្រាស់ និងគ្រប់គ្រងសម្រាប់ពិធីបុណ្យផ្សេងៗ*។ រដ្ឋធម្មនុញ្ញនៃប្រទេសយៀកណាម វិសោធនកម្មឆ្នាំ២០១៣ ជំពូក២ មាត្រា១៤ *សិទ្ធិពលរដ្ឋពីនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ត្រូវបានទទួលស្គាល់ ការគោរព ការការពារ និងធានាដោយរដ្ឋធម្មនុញ្ញនិង ច្បាប់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម"*។ *សេចក្ដីសម្រេចស្ដីពីសហប្រតិបត្តិការជនជាតិរបស់យៀកណាម ដោយអនុលោមទៅតាមច្បាប់អង្គការរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១ មាត្រា១៣ អភិវឌ្ឍន៍ និង អភិរក្សវប្បធម៌ ប្រពៃណី ភាសា អក្សរសាស្ត្រ របស់ជនជាតិភាគតិច*។

- **វិស័យអប់រំអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និង សិទ្ធិមនុស្ស**

រដ្ឋាភិបាលវៀតណាម គួរផ្ដល់សិទ្ធិឱ្យបានគ្រប់គ្រាន់ដល់ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមទទួលបានការសិក្សាអប់រំនូវគ្រប់កម្រិត និងទទួលបាននូវអាហារូបករណ៍បាន សិក្សានៅក្រៅប្រទេស និងជាពិសេសទទួលបានការសិក្សាពីប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ នៃពូជសាសន៍របស់ខ្មែរក្រោម និងអំពីសិទ្ធិរបស់ពួកគេក្នុងនាមជាជនជាតិដើម ដោយពុំមានការបែកចែក រើសអើង ប្រកាន់ពូជសាសន៍ឡើយ ហើយស្របទៅតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩២ មាត្រា៥៩ *សិទ្ធិទទួលបានក្នុងការអប់រំ និងវិជ្ជាជីវៈ អាហារូបករណ៍ គឺជាគោលនយោបាយរបស់រដ្ឋ*។ មាត្រា៤២ *ការកំណត់ជាតិសាសន៍ ប្រើប្រាស់ភាសា និងជ្រើសរើសភាសាត្រូវសិក្សា*។ អនុសញ្ញាស្ដីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រកាន់ពូជសាសន៍ មាត្រា ២ តម្រូវឱ្យរដ្ឋភាគីនីមួយៗសន្យា *"មិនធ្វើអំពើ ឬការអនុវត្តណាមួយនៃការរើសអើងពូជសាសន៍"* និង *"ធានាថា អាជ្ញាធរ និងស្ថានប័នសាធារណៈទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ធ្វើស្របតាមកាតព្វកិច្ចនេះ"*។

រដ្ឋាភិបាលវៀតណាម ផ្ដល់សិទ្ធិឱ្យបានគ្រប់គ្រាន់ដល់ពលរដ្ឋខ្មែរក្រោមពីសិទ្ធិជំនឿ ប្រណិប័តន៍សាសនា គ្រប់គ្រង ចាត់ចែងកិច្ចការសាសនាដោយខ្លួនឯង និងមិនត្រូវកំណត់

កម្រិត និងជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងព្រះពុទ្ធសាសនាខ្មែរក្រោមឡើយ ស្របទៅតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ២៧ *សិទ្ធិរបស់បុគ្គលគ្រប់រូបដែលមកពីក្រុមភាគតិចនៃជាតិពន្ធ សាសនា ឬភាសា ដែលត្រូវទទួលបានសិទ្ធិទាំងនេះដូចៗគ្នាជាមួយនឹងសមាជិកផ្សេងទៀតនៃក្រុមរបស់ពួកគេ ដើម្បីឱ្យក្រុមទាំងនេះអាចប្រកាន់យកវប្បធម៌ គោរពនិងប្រតិបត្តិតាមសាសនារបស់ពួកគេ ព្រមទាំងប្រើប្រាស់ភាសារបស់ខ្លួនផងដែរ។* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៨ និង១៩ *គោរព ប្រតិបត្តិ និងជំនឿសាសនា*។ រដ្ឋធម្មនុញ្ញយៀកណាមឆ្នាំ២០១៣ មាត្រា២៥ *សេរីភាព ជំនឿសាសនា*។

រាជរដ្ឋាភិបាលកម្ពុជា គួរសហការ និងសម្របសម្រួលជាមួយអាជ្ញាធរវៀតណាម ជំរុញស្ថានទូតអគ្គកុងស៊ុលខ្មែរ នៅព្រៃនគរ និងទីក្រុងហាណូយ ដើម្បីវិធានការការពារសិទ្ធិក្នុងវិស័យសិក្សាអប់រំសម្រាប់ខ្មែរក្រោម។

អង្គការសហប្រជាជាតិបង្កើតការិយាល័យនៃឧត្តមស្នងការ ទទួលបន្ទុកសិទ្ធិមនុស្ស បង្កើតការិយាល័យ ដើម្បីធ្វើការពិនិត្យពិនិត្យ និងតាមដាន រាល់ការអនុវត្តគោលការណ៍សិទ្ធិមនុស្សរបស់រដ្ឋាភិបាលវៀតណាម និងមានវិធានការដោះស្រាយក្នុងវិស័យសិក្សាអប់រំមកលើខ្មែរក្រោម ជាពិសេសផងដែរប្រទេសដែលជាម្ចាស់ជំនួយ ពិនិត្យ ដាក់សម្ពាធឱ្យរដ្ឋាភិបាលយៀកណាមមានគោរពសិទ្ធមនុស្ស ស្របទៅតាមធម្មនុញ្ញអង្គការសហប្រជាជាតិដែលចែងថា *"សហគមន៍អន្តរជាតិបានយល់ព្រមទទួលយកកាតព្វកិច្ច ធានាបង្កើតឱ្យមានសិទ្ធិមនុស្ស ផ្តល់នូវកិច្ចការពារដល់បុគ្គលទាំងឡាយ ក្រុម និងបណ្តាសហគមន៍នានា ដែលត្រូវរងនូវការគំរាមគំហែងពីសំណាក់រដ្ឋាភិបាលរំលោភទៅលើសិទ្ធិរបស់ពួកគេ។ អំណាច នៃច្បាប់ក្នុងស្រុក ត្រូវដាក់ឱ្យនៅក្រោមអំណាចនៃច្បាប់អន្តរជាតិ ដែលបានបង្កើតនូវក្របខ័ណ្ឌមួយ ដើម្បីធានានូវកិច្ចការពារជាលក្ខណអន្តរជាតិ"*។

សហព័ន្ធ អង្គការ សមាគម ខ្មែរកម្ពុជាក្រោម ត្រូវតែពង្រឹងតួនាទី កាតព្វកិច្ច អន្តរាគមន៍ រាល់ករណីរំលោភសិទ្ធិមនុស្សខ្មែរក្រោម និងតាមដានការអនុវត្តរបស់វៀតណាម ដោយបង្កើតឱ្យមានយន្តការការពារស្របច្បាប់ដល់ខ្មែរក្រោម តាមរយៈសន្និបាតអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសិទ្ធិជនជាតិដើម សហគមន៍

អឺរ៉ុប អង្គការតំបន់ សមាគមអាស៊ាន អង្គទូតនានានៃប្រទេសម្ចាស់ជំនួយដែលមានមូលដ្ឋាននៅប្រទេសវៀតណាម។

បង្កើតផែនការក្នុងការបញ្ជ្រាបចំណេះដឹងសិទ្ធិមនុស្ស ច្បាប់ ការតស៊ូមតិ ដល់ខ្មែរក្រោមចាប់ពីមូលដ្ឋាន ទីកន្លែងដែលខ្មែរក្រោមរស់នៅ និងបង្កើនសមត្ថភាពក្រុមការងារ អនុវត្តតាមបែបចូលរួម បង្កើនការអភិវឌ្ឍន៍វិស័យកិច្ចការមូលដ្ឋាន ព្រមទាំងរៀបចំយុទ្ធសាស្ត្រទៅតាមតក្កវិជ្ជា និងអនុវត្តស្របទៅតាមចក្ខុវិស័យ បេសកកម្ម និងគោលនយោបាយនៃស្ថាប័ននីមួយៗ។

# ឯកសារយោង


១. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា *ក្រមងឯកសារច្បាប់* បោះពុម្ពលើកទី៤ ខែកញ្ញា ឆ្នាំ២០០៥ ទំព័រ១០២

២. ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស៖ *ច្បាប់សិទ្ធិមនុស្សកម្ពុជា* អង្គការសហប្រជាជាតិ ឆ្នាំ២០០៨

៣. ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា៖ *ក្រមង ឯកសារច្បាប់* បោះពុម្ពលើកទី៤ មិថុនា ២០០៩

៤. ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា៖ *ច្បាប់សិទ្ធិមនុស្សកម្ពុជា* អង្គការសហប្រជាជាតិ ភ្នំពេញ២០១២

៥. ខៃ មីលេស្តី៖ *សិទ្ធិអប្បភាគជននៅកម្ពុជា,* ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ១៩៩៦ ទំព័រ៤

៦. នួន ឃឿន៖ *ដំណើរឆ្ពោះទៅទិសខាងលិច និងឥណ្ឌូចចិនឆ្នាំ២០០០* បោះពុម្ពលើកទី៣ ស៊ិន មុយ ឆ្នាំ១៩៧១

៧. មន្ទីរអប់រំ និងបណ្តុះបណ្តាលខេត្តត្រាវិញ *បទបង្ហាញពីរបាយការណ៍ការអប់រំនិងបណ្តុះបណ្តាលក្នុងតំបន់ ដែលមានពលរដ្ឋខ្មែរច្រើន* ឆ្នាំ២០១៨

៨. សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិខេត្តត្រាវិញ *របាយការណ៍មហាសន្និបាត* លើកទី៧ អាណត្តិកាល ២០១៨-២០២៣ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨

៩. សឹង សម្រេច៖ *របាយការណ៍ប៉ាន់ប្រមាណចំពោះកិច្ចប្រតិបត្តិដែលប្រទេសវៀតណាមបានធ្វើ និងមិនបានធ្វើនៅពាក់កណ្តាលកាលកំណត់* UPR លេខ A/HRC/RES/16/21 ចុះថ្ងៃទី១២ មេសា ២០១២ (Annex I C § 6)

១០. អាឡិច ម៉ាស្សៃលីណូ៖ *ឯកសាសម្រាប់បណ្តុះបណ្តាលគ្រូអប់រំសិទ្ធិមនុស្ស* ការិយាល័យនៃឧត្តមស្នងការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ១៩៩៩ ទំព័រ២

១១. Moeckli, Shah & Sivakumaran: International Human Rights Law, Oxford University Press 3rd edition, 2018, Page 233
១២. A/HRC/WG.6/5/VNM/3 23 February 2009, Original: ENGLISH/FRENCH,HUMAN RIGHTS COUNCIL Working Group on the Universal Periodic Review Fifth session Geneva, 4-15 May 2009, page9
១៣. Human rights council working group on Universal Periodic Review Eighteen Session, Geneva, 27 January-07 February, 2014 page10
១៤. ជួន ណាត: វចនានុក្រមខ្មែរភាគ១-២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦៧
១៥. Jonathan Crowther: Oxford Advanced Learner's dictionary Oxford university press England 1995
១៦. Master group: Oxford The first desk for a better future Royal University Phnom Penh
១៧. Nguyen Van Khon: Anh-Viet English-Vietnamese dictionary Khai-Tri 1962
១៨. គេហទំព័ររបស់រដ្ឋាភិបាលវៀតណាម៖ HÌNH ẢNH CỘNG ĐỒNG 54 DÂN TỘC VIỆT NAM, http://www.chinhphu.vn/portal/page/portal/chinhphu/NuocCHXHCNVietNam/ThongTinTongHop/dantoc,
១៩. គេហទំព័រសហគមន៍ខ្មែរកម្ពុជាក្រោម http://www.khmerkromngo.org/category/map/
២០. គេហទំព័រសហព័ន្ធខ្មែរកម្ពុជាក្រោម http://www.khmerkrom.org/news-events/human-rights-monitor/142-23khmer-krom-people-statistics

២១. មហាសន្និបាត អ.ស.បះ សេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនមានសិទ្ធិទទួលបាន សញ្ជាតិ ឬជាតិសាសន៍ សាសនា និងភាសាដើមកំណើត សេចក្តីសម្រេចលេខ ៤៧/១៣៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២
http://www.ohchr.org/EN/ProfessionalInterest/Pages/Minorities.aspx
២២. មហាសន្និបាត អ.ស.បះ កតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍ សេចក្តីសម្រេចលេខ ២១០៦ (១០) ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥
http://www.ohchr.org/EN/ProfessionalInterest/Pages/CERD.aspx
២៣. http://www.un.org.vn/en/publications/one-un-documents/doc_details/510-annual-results-report-2015.html page48-51
២៤. https://www.hrw.org/report/2009/01/21/margins/rights-abuses-ethnic-khmer-vietnams-mekong-delta
២៥. https://www.ohchr.org/EN/HRBodies/UPR/Pages/VNindex.aspx
២៦. https://thuvienphapluat.vn/van-ban/Bo-may-hanh-chinh/Van-ban-hop-nhat-23-VBHN-VPQH-nam-2013-hop-nhat-Luat-giao-duc-220044.aspx
២៧. https://thuvienphapluat.vn/van-ban/Giao-duc/Nghi-dinh-82-2010-ND-CP-day-va-hoc-tieng-noi-chu-viet-cua-dan-toc-108787.aspx
២៨. https://thuvienphapluat.vn/van-ban/Giao-duc/Thong-tu-24-2014-TT-BGDDT-Chuong-trinh-tieng-Khmer-cap-tieu-hoc-trung-hoc-co-so-241531.aspx

# ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រតិបត្តិការរបស់ កងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩

*បេក្ខជនបណ្ឌិត* ***ឡាក់ គួន***

## មូលន័យសង្ខេប

ក្រោយពីការបោះឆ្នោតឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជា បានបង្កើតកងរាជអាវុធហត្ថសាជាថ្មី និងត្រូវបានបង្កើតនូវបញ្ជាការដ្ឋានកងរាជអាវុធហត្ថតាមបណ្តា២៥រាជធានី-ខេត្ត ព្រមទាំងបានធ្វើការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធទូទៅជាបន្តបន្ទាប់ រហូតមកដល់បច្ចុប្បន្ននេះ ដែលមានបាវចនាគឺ «**បង្ការ បង្ក្រាប និងសង្គ្រោះ**»។ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រោមការដឹកនាំរបស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវទទួលបានការយកចិត្តទុកដាក់ខ្ពស់ក្នុងការបណ្តុះបណ្តាល ហ្វឹកហ្វឺន បំប៉ន ចំណេះជំនាញទាំងក្នុង និងក្រៅប្រទេស ការជួសជុល ថែទាំ និងបំពាក់ឧបករណ៍ សម្ភារៈ មធ្យោបាយ គ្រឿងម៉ាស៊ីន ជំរំជម្រកជាអាទិ៍ នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងតាមបណ្តាបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត។ កម្លាំងកងរាជអាវុធហត្ថមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការចេញប្រតិបត្តិការជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ អនុវត្តនូវតួនាទី ភារកិច្ចរបស់ខ្លួន។ ទោះជាយ៉ាងណា រាល់ការគ្រប់គ្រងប្រតិបត្តិការតែងតែជួបនូវ បញ្ហាប្រឈមមួយចំនួនដែលត្រូវរកដំណោះស្រាយ ដើម្បីឱ្យកាន់តែប្រសើរឡើង។ ហេតុដូចនេះ ទើបមានការសិក្សាស្រាវជ្រាវលើអត្ថបទស្តីពី **«ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩»** ចន្លោះចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ និងផ្តោតលើវិសាលភាព នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ រកឱ្យឃើញពីការគ្រប់គ្រងប្រតិបត្តិការដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ របស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដោយពឹងផ្អែកទៅលើ៖ ការអនុវត្តនូវតួនាទីភារកិច្ច ការដឹកនាំ គ្រប់គ្រងកងរាជអាវុធហត្ថតាម

ឋានានុក្រមជំនាញ និងអភិបាលកិច្ច ដូចជាៈ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត សេចក្ដីណែនាំ សារាចរណែនាំ ទិសស្លោក បទបញ្ជាផ្ទៃក្នុង ផែនការសកម្មភាពការងារជំនាញ ផែនការវេជ្ជវស្សា ការគ្រប់គ្រងប្រតិបត្តិការនៅតាមបណ្ដាជំនាញពាក់ព័ន្ធនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ព្រមទាំងរបាយការណ៍ការគ្រប់គ្រងប្រតិបត្តិការជំនាញខ្សែរយៈថ្នាក់ក្រោម នៅតាមបណ្ដាបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត។ សិក្សាវាយតម្លៃអំពី វឌ្ឍនភាពនៃការអនុវត្តនូវតួនាទី ភារកិច្ចលើការងារជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយនៃស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន កងរាជអាវុធហត្ថលើផ្ទៃប្រទេស។ រកឱ្យឃើញនូវបញ្ហាប្រឈមនានា និងមធ្យោបាយដែលត្រូវដោះស្រាយ ដែលបានជួបប្រទះនាពេលកន្លងមក លើការគ្រប់គ្រងប្រតិបត្តិការ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស បណ្ដាលឱ្យមានការបាត់បង់អាយុជីវិតអ្នករងគ្រោះ ការបាត់បង់ទ្រព្យសម្បត្តិ ធនធានមនុស្ស ការរាំងស្ទះដល់ការអភិវឌ្ឍនៃបញ្ជាការដ្ឋាន និងសង្គមជាតិ។ ម្យ៉ាងវិញទៀត ក៏ជាមូលដ្ឋានគ្រឹះសម្រាប់ ថ្នាក់ដឹកនាំតាមឋានានុក្រម នាយអាវុធហត្ថគ្រប់ជាន់ថ្នាក់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលមានតួនាទីភារកិច្ចទទួលបន្ទុកដឹកនាំ គ្រប់គ្រងការងារជំនាញ សម្រាប់ទុកជាផែនទីចង្អុលបង្ហាញផ្លូវឆ្ពោះទៅរកភាពជោគជ័យក្នុងការដឹកនាំ ការគ្រប់គ្រងប្រតិបត្តិការ នៅបញ្ជាការដ្ឋានកងរាជ-អាវុធហត្ថលើផ្ទៃប្រទេស ក៏ដូចជានៅតាមបណ្ដាបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ជូនមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជូនអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ និងជូនប្រមុខដឹកនាំរាជរដ្ឋាភិបាល តាមរយៈវិធីសាស្ត្រនៃការស្រាវជ្រាវលើការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ស្ថានភាពនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អំពីស្ថានភាពទូទៅ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច គោលការណ៍អនុវត្តសង្គ្រោះគ្រោះមហន្តរាយ ជាពិសេសការអនុវត្តជាក់ស្ដែងក្នុងគ្រប់គ្រងប្រតិបត្តិការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការគ្រប់គ្រងប្រតិបត្តិការ

ក្នុងបរិបទកូវីដ-១៩ ទូទាំងប្រទេស ដោយទទួលបានលទ្ធផលល្អប្រសើរ គួរជាទីចាប់អារម្មណ៍ និងមោទនភាពក្នុងឆាកអន្តរជាតិ។

***ពាក្យគន្លឹះ៖*** *ប្រសិទ្ធភាព, ការគ្រប់គ្រងប្រតិបត្តិការ, កងរាជអាវុធហត្ថ, ជំងឺកូវីដ-១៩*

**ប្រសិទ្ធភាព** គឺជាការធ្វើអោយសម្រេច ធ្វើអោយពូកែ ធ្វើអោយមានសេរីសួស្តីជោគជ័យ។[១]

**ការគ្រប់គ្រងប្រតិបត្តិការ** គឺជាសិទ្ធិអំណាចក្នុងការអនុវត្តមុខងារនៃបញ្ជាការលើកងកម្លាំងក្រោមឱវាទដែលពាក់ព័ន្ធនឹងការរៀបចំ និងប្រើប្រាស់បញ្ជាកងកម្លាំង ប្រគល់ភារកិច្ចកំណត់គោលបំណង និងផ្តល់ការណែនាំប្រកបដោយសិទ្ធិអំណាចចាំបាច់ដើម្បីសម្រេចបេសកកម្ម។ ការគ្រប់គ្រងប្រតិបត្តិការរួមមាន ទិសដៅអនុញ្ញាតលើគ្រប់ទិដ្ឋភាពនៃប្រតិបត្តិការយោធា និងការហ្វឹកហ្វឺនរួមគ្នា ដែលចាំបាច់ដើម្បីសម្រេចបេសកកម្មមេបញ្ជាការបានប្រគល់ឱ្យ។ ការគ្រប់គ្រងប្រតិបត្តិការគួរតែត្រូវបានអនុវត្តតាមរយៈមេបញ្ជាការនៃអង្គភាពក្រោមបង្គាប់។ អាជ្ញាធរត្រូវបានអនុវត្តតាមរយៈមេបញ្ជាការកងកម្លាំងរួមក្រោមបង្គាប់ និងមេបញ្ជាការផ្នែកសេវាកម្ម និង/ឬមុខងារ។ ការគ្រប់គ្រងប្រតិបត្តិការជាធម្មតាផ្តល់សិទ្ធិអំណាចពេញលេញក្នុងការរៀបចំបញ្ជាកងកម្លាំង និងដើម្បីប្រើប្រាស់កងកម្លាំងទាំងនោះ ខណៈដែលមេបញ្ជាការគ្រប់គ្រងប្រតិបត្តិការចាត់ទុកថាចាំបាច់ ដើម្បីសម្រេចបេសកកម្មដែលបានកំណត់។ វាមិនរាប់បញ្ចូលនូវទិសដៅអនុញ្ញាតសម្រាប់ភស្តុភារ ឬបញ្ហានៃការគ្រប់គ្រង វិន័យផ្ទៃក្នុងអង្គភាព ឬការបណ្តុះបណ្តាលអង្គភាពទេ។[២]

កងរាជអាវុធហត្ថ បានមកពីការបូកបញ្ចូលគ្នានូវពាក្យចំនួន៤គឺ កង រាជ អាវុធ និង ហត្ថ តាមវចនានុក្រមសម្តេចសង្ឃ ជួន ណាត ពាក្យនីមួយៗមានអត្ថន័យដូចជា៖

- កង មានន័យថា ពួកក្រុមកងទ័ព។
- រាជ មានន័យថា អ្នករុងរឿងដោយវិសេស ព្រោះមានតេជះក្រៃលែង អ្នកញ៉ាំងប្រជាពលរដ្ឋឱ្យរីករាយ។

---

[១] វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ គ.ស ១៩៦៧ ទំព័រទី៦៩៣។

[២] Operational Control (Military), WikiLeaks, September 2007, https://wikileaks.org/wiki/Operational_control_(military), (accessed 30 January 2024).

- អាវុធ មានន័យថា គ្រឿងប្រហារ ឬគ្រឿងចម្បាំងផ្សេងៗ ដែលទីទៃពីសាស្ត្រា រួមមាន៖ ធ្នូ ស្នា កាំភ្លើង....។ល។
- ហត្ថ មានន័យថា ដៃ។

**កងរាជអាវុធហត្ថ** គឺមានន័យថា ជាក្រុម ឬកងប្រដាប់ដោយគ្រឿងចម្បាំងផ្សេងៗ ញ៉ាំងប្រជាពលរដ្ឋអោយរីករាយ។[៣]

**ជំងឺកូវីដ-១៩** គឺបណ្តាមកពីមេរោគSARS-CoV-2។ វាចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ភាគច្រើនតាមរយៈខ្យល់។ មនុស្សជាច្រើនមានរោគសញ្ញាស្រាល ឬក៏គ្មានរោគសញ្ញាតែម្តង ប៉ុន្តែជំងឺCOVID-19 ក៏អាចបណ្តាលអោយធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងស្លាប់ផងដែរ។ មនុស្សអាចចម្លងមេរោគនេះ ទោះបីពួកគេមិនមានរោគសញ្ញាក៏ដោយ។[៤]

## ១. សេចក្តីផ្តើម

កងរាជអាវុធហត្ថ ត្រូវបានបដិសន្ធិឡើងចាប់តាំងពី របបសង្គមរាស្ត្រនិយម នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤[៥] ដែលមានឈ្មោះថា «**កងតម្រួតទាហានខ្មែរ**» និងត្រូវបានបង្កើតជាផ្លូវការតាមលំនាំប្រទេសបារាំង នូវព្រះរាជក្រឹត្យលេខ៤៤៦NS និង៤៤៧NS ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៧ ដោយប្តូរឈ្មោះមកជា «**កងរាជអាវុធហត្ថខ្មែរ**[៦]» ដែលមានតួនាទី ភារកិច្ចគឺនគរបាលទាហាន នគរបាលរដ្ឋបាល និងនគរបាលតុលាការ ដូចគ្នាទៅនឹងកងរាជអាវុធហត្ថរបស់ប្រទេសបារាំង។ ក្រោយពីការបោះឆ្នោតឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជា បានបង្កើតកងរាជអាវុធហត្ថសាជាថ្មី តាមក្រឹត្យចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៣ ព្រមទាំងបានធ្វើការកែសម្រួលនូវតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធទូទៅ[៧] ជាបន្តបន្ទាប់មានដូចជា៖ អនុក្រឹត្យស្តីពីឯកសណ្ឋាន ស្លាកសញ្ញា ទង់ជ័យ និងរចនាសម្ព័ន្ធក្របខណ្ឌចាត់តាំងកងរាជអាវុធហត្ថលើ

[៣] ប្រវត្តិសាស្ត្រកងរាជអាវុធហត្ថ បោះពុម្ពលើកទី១ ឆ្នាំ២០១៨។

[៤] http://publichealth.lacounty.gov/media/coronavirus/docs/about/WhatIsCOVID-Cambodian.pdf (accessed 26 July 2024)

[៥] ប្រវត្តិសាស្ត្រកងរាជអាវុធហត្ថ បោះពុម្ពលើកទី១ ឆ្នាំ២០១៨។

[៦] ព្រះរាជក្រឹត្យលេខ៤៤៦NS និងលេខ៤៤៧NS ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៧។

[៧] អនុក្រឹត្យលេខ ៧៧អនក្រ.បក. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនា សម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ។

ផ្ទៃប្រទេស។ ម្យ៉ាងវិញទៀតបានបង្កើតនូវបញ្ជាការដ្ឋានកងរាជអាវុធហត្ថ នៅតាមបណ្តា២៥ រាជធានី-ខេត្ត រហូតមកដល់បច្ចុប្បន្ននេះ ដែលមានបាវចនាគឺ **«បង្ការ បង្ក្រាប និងសង្គ្រោះ»**។

## ១.១. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីទទួលបានជាសមិទ្ធិផល តាមរយៈនៃការសិក្សាស្រាវជ្រាវ ជាពិសេសទទួលបាននូវចំណេះដឹង បទពិសោធន៍ និងកិច្ចការជំនាញលើការអនុវត្តន៍នៃអត្ថបទស្តីពី **«ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩»** ដែលបានលើកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រង ដោយផ្តោតលើសំណួរស្រាវជ្រាវចំនួនបីដូចខាងក្រោម៖

១. តើនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩ ប្រព្រឹត្តិទៅយ៉ាងដូចម្តេចខ្លះ?

២. តើនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩ មានវឌ្ឍនភាពបែបណា?

៣. តើនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩ ជួបបញ្ហាប្រឈមត្រូវមានដំណោះស្រាយបែបណា និងមានទស្សនទានយ៉ាងដូចម្តេច ដើម្បីចូលរួមដោះស្រាយនូវបញ្ហាទាំងនោះឱ្យកាន់តែប្រសើរឡើង?

## ១.២. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាក់ទងប្រធានបទខាងលើ ការសិក្សាមានគោលបំណង៖

១. រកឱ្យឃើញពី ការគ្រប់គ្រងប្រតិបត្តិការ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដោយពឹងផ្អែកទៅលើ៖ ការអនុវត្តនូវតួនាទី ភារកិច្ច ការដឹកនាំកងរាជអាវុធហត្ថ តាមឋានានុក្រមជំនាញ និងអភិបាលកិច្ច។

២. សិក្សាវាយតម្លៃពី វឌ្ឍនភាពនៃការអនុវត្តនូវតួនាទី ភារកិច្ចលើការងារជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន កងរាជអាវុធហត្ថលើផ្ទៃប្រទេស បណ្តាជំនាញពាក់ព័ន្ធ ខ្សែរយៈជំនាញនៅតាមបណ្តាបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត។

៣. រកឱ្យឃើញនូវបញ្ហាប្រឈមនានា និងមធ្យោបាយដែលត្រូវដោះស្រាយ ដែលបានជួបប្រទះនាពេលកន្លងមក លើការគ្រប់គ្រងប្រតិបត្តិការ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជូន មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាពិសេសគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស បណ្តាលឲ្យមានការបាត់បង់អាយុជីវិតអ្នករងគ្រោះ ការបាត់បង់ទ្រព្យសម្បត្តិ ធនធានមនុស្ស ការរាំងស្ទះដល់ការអភិវឌ្ឍនៃបញ្ជាការដ្ឋាន និងសង្គមជាតិ។

# ២. វិធីសាស្ត្រនៃការស្រាវជ្រាវ

## ២.១. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យយកមកប្រើលើការស្រាវជ្រាវក្នុងការចងក្រងជាអត្ថបទមាន២ប្រភេទរួមមាន៖

### ក. ទិន្នន័យទី១៖

តាមរយៈការផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់មេបញ្ជាការ មេបញ្ជាការរងទទួលការងារជំនាញ និងការផ្តល់កិច្ចសម្ភាសន៍របស់អ្នកនាំពាក្យកងរាជអាវុធហត្ថលើផ្ទៃប្រទេស ការស្តាប់ កិច្ចពិភាក្សា ការចូលរួមផ្លាស់ប្តូរបទពិសោធន៍ក្នុងកិច្ចប្រជុំ សិក្ខាសាលា លំហាត់លើតុ លំហាត់ទីលាន ជាមួយនាយអាវុធហត្ថ នាយទាហានជាតិ និងអន្តរជាតិ ទាំងក្នុង និងក្រៅប្រទេស។

### ខ. ទិន្នន័យទី២៖

ការប្រមូលទិន្នន័យដែលមានស្រាប់ ហើយទិន្នន័យបានត្រូវប្រមូលគឺ យកឯកសារមានដូចជា៖ សូចនាករការងារ ផែនការយុទ្ធសាស្ត្រ របាយកាណ៍ ផែនការរដូវវស្សា ផែនការផ្សេងៗ របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ច្បាប់ ឯកសារពាក់ព័ន្ធពីក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ឯកសារពី បណ្ណាល័យនៃសាកលវិទ្យាល័យការពារជាតិ សាកលវិទ្យាល័យអាស៊ីអឺរ៉ុប បណ្តាញផ្សព្វផ្សាយសង្គម គេហទំព័រ សារព័ត៌មាននានា ទស្សនាវត្តី GRK New ជាពិសេសពីការិយាល័យជំនាញនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

### ២.២. ការវិភាគទិន្នន័យ

ក្រោយពីប្រមូលបានទិន្នន័យ ដើម្បីសរសេរអត្ថបទនេះ ក្នុងការធ្វើការវិភាគតាមបែបៈ បរិមាណវិស័យ គុណភាពវិស័យ និងគោលការណ៍វិចារវិទ្យា ដែលអនុញ្ញាតឱ្យសិក្សាស្រាវជ្រាវ នូវទ្រឹស្តី លិខិតបទដ្ឋានគតិយុត្ត ដែលបានបង្ហាញអំពីដំណើរការងារពាក់ព័ន្ធនឹងការអនុវត្តន៍ជាក់ស្តែង។

វិធីសាស្ត្រនៃការវិភាគនេះ បានផ្តល់ឲ្យការសិក្សាស្រាវជ្រាវជានាបាននូវភាពត្រឹមត្រូវ ពិតប្រាកដ ដែលអាចទុកចិត្តបាន និងឈានទៅរកការសន្និដ្ឋានជាលក្ខណៈបែបវិទ្យាសាស្ត្រ ទំនើប។

### ២.៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់នៃការស្រាវជ្រាវមានចន្លោះរយៈពេល៣ឆ្នាំ គិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដោយផ្តោតលើវិសាលភាពនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការងារផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន ដែលមានកិច្ចការជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ក្តាប់ជាប់កិច្ចការខ្សែរយៈបណ្តោយជំនាញ តាមបណ្តាបញ្ជាការដ្ឋានកងរាជអាវុធហត្ថ២៥រាជធានី-ខេត្ត។

## ៣. ស្ថានភាពនៃការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងបរិបទនៃជំងឺកូវីដ-១៩

### ៣.១. ស្ថានភាពទូទៅ

ស្ថានភាពជំងឺកូវីដ-១៩ ដំបូងនៅព្រះរាជាណាចក្រកម្ពុជា[៩]៖ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ នាវាទេសចរណ៍ខ្នាតអន្តរជាតិ មានឈ្មោះ Westerdam ដែលមានផ្ទុកអ្នកដំណើរចំនួន ១ ៤៥៥នាក់ និងនាវិកចំនួន ៨០២នាក់ មកពី៤១ប្រទេស បានទទួលការអនុញ្ញាតិចូលចត និងទទួលការស្វាគមន៍ដោយផ្ទាល់ពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅកំពង់ផែខេត្តព្រះសីហនុ ដើម្បីសង្គ្រោះជីវិតមនុស្សចំនួន ២ ២៥៧នាក់ ដែលកំពុងអស់សង្ឃឹមហើយ ប្រឈមនឹងភាពអត់ស្បៀងអាហារ

[៩] បណ្តាញផ្សព្វផ្សាយសង្គម, គេហទំព័រ, សារព័ត៌មាននានា, GRK New ។

ជាពិសេសប្រឈមនឹងគ្រោះកាចនៃជំងឺឆ្លងកូវីដ-១៩ នៅកណ្ដាល មហាសាគរ ព្រមទាំងមិនអាចវិលត្រឡប់ទៅប្រទេសកំណើតវិញ។ នាវាទេសចរណ៍នេះ កន្លងមកបានស្នើសុំចូលចត នៅតាមបណ្ដាកំពង់ផែជាច្រើនរួមមាន៖ ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង កោះតៃវ៉ាន់ កោះហ្គាំ ប្រទេសហ្វីលីពីន និងប្រទេសថៃ ប៉ុន្តែត្រូវបានទទួលការបដិសេធរាល់សំណើទាំងនេះ ព្រោះខ្លាចការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២០ មានបុរសជនជាតិខ្មែរ អាយុ៣៨ឆ្នាំ នៅខេត្តសៀមរាប វិជ្ជមានជំងឺកូវីដ១៩។ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ ឯកឧត្តម Peter Szijjarto រដ្ឋមន្ត្រីក្រសួងការបរទេសហុងការី បានធ្វើតេស្តឃើញវិជ្ជមានកូវីដ-១៩ នៅទីក្រុងបាងកក ប្រទេសថៃ បន្ទាប់ពីបានបញ្ចប់ទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ មានស្ត្រីជនជាតិចិន បានលួចចេញពីកន្លែងធ្វើចត្តាឡីស័ក នៅក្នុងសណ្ឋាគារសុខា រាជធានីភ្នំពេញ ដោយមានសន្តិសុខសណ្ឋាគារជាអ្នកសម្របសម្រួលលួចដឹកចេញក្រៅ។ ការស្លាប់ដំបូងរបស់ប្រជាជនកម្ពុជា ដោយសារជំងឺកូវីដ១៩៖ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ អ្នកបើកបររថយន្ត នៅក្នុងខេត្តព្រះសីហនុ កើតជំងឺកូវីដ-១៩ ជាអ្នកស្លាប់ដំបូង នៅព្រះរាជាណាចក្រកម្ពុជា។ នៅខែឧសភា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ សរ សារី បានទទួលមរណភាព ដោយសារការឆ្លងជំងឺកូវីដ-១៩ ក្នុងពេលបំពេញបេសកកម្ម ក្របខណ្ឌកងទ័ពអង្គការសហប្រជាជាតិ ប្រចាំនៅប្រទេសម៉ាលី។ ក្រោយពីបានទទួលនូវផែនការយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងការពារជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានចេញប្រតិបត្តិការផែនការសកម្មភាពក្នុងការដឹកជញ្ជូន និងការពារវ៉ាក់សាំងកូវីដ១៩ ទៅតាមគោលដៅទូទាំងប្រទេស ព្រមទាំងបានលើកនូវផែនការការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។[៩]

---

[៩] ផែនការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រាជអាវុធហត្ថលើផ្ទៃប្រទេស ឆ្នាំ២០២១។

### ៣.២. រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចកងរាជអាវុធហត្ថលើផ្ទៃប្រទេស

#### ក. រចនាសម្ព័ន្ធកងរាជអាវុធហត្ថលើផ្ទៃប្រទេស

**១. រចនាសម្ព័ន្ធបញ្ជាការដ្ឋាន(អង្គភាព)៖** សេនាធិការដ្ឋាន ស្នងការដ្ឋានកសាងកម្លាំង ស្នងការ ដ្ឋានស្រាវជ្រាវព័ត៌មានសន្តិសុខ ស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន ស្នងការដ្ឋានស្រាវជ្រាវ និងបង្ក្រាបបទល្មើស ស្នងការដ្ឋានទំនាក់ទំនងកិច្ចការសាធារណៈ ស្នងការដ្ឋានភស្តុភារ ស្នងការដ្ឋានសម្ភារៈបច្ចេកទេស វិទ្យាស្ថានកងរាជអាវុធហត្ថ (កំបូល) មជ្ឈមណ្ឌលហ្វឹកហ្វឺនកងរាជអាវុធហត្ថ (ភ្នំជំរាយបានស្នើសុំប្តូរជា ភ្នំជុំសែនរីករាយ) បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី/ខេត្ត។[១០]

**២. រចនាសម្ព័ន្ធមុខងារតាមឋានានុក្រម៖** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានប្រគល់ តួនាទីដល់ មេបញ្ជាការរងទាំងអស់ក្នុងការទទួលខុសត្រូវ ដឹកនាំបញ្ជាលើការងារជំនាញនីមួយៗ ជួស មេបញ្ជាការ លើការងារមានដូចជា៖

សេនាធិការដ្ឋានមាន៖ នាយសេនាធិការ និងនាយសេនាធិការរង។ ស្នងការដ្ឋានកសាងកម្លាំង៖ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែក និងបុគ្គលិក។ ស្នងការដ្ឋានស្រាវជ្រាវព័ត៌មានសន្តិសុខ៖ ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែក និងបុគ្គលិក។ ស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន៖ ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែក និងបុគ្គលិក។ ស្នងការដ្ឋានស្រាវជ្រាវ និងបង្ក្រាបបទល្មើស៖ ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែកនិងបុគ្គលិក។ ស្នងការដ្ឋានទំនាក់ទំនងកិច្ចការសាធារណៈ៖ ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែក និងបុគ្គលិក។ ស្នងការដ្ឋានភស្តុភារ៖ ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែក និងបុគ្គលិក។ ស្នងការដ្ឋានសម្ភារៈបច្ចេកទេស៖ ស្នងការ ស្នងការរង នាយការិយាល័យ នាយផ្នែក និងបុគ្គលិក។ វិទ្យាស្ថានកងរាជអាវុធហត្ថ (កំបូល)៖ នាយក នាយករង ប្រធានមន្ទីរ អនុប្រធានមន្ទីរ នាយការិយាល័យ និងបុគ្គលិក។ មជ្ឈមណ្ឌលហ្វឹកហ្វឺនកងរាជអាវុធហត្ថ (ភ្នំជុំសែនរីករាយ) ៖ នាយក នាយករង ប្រធាន

---

[១០] អគ្គបញ្ជាការដ្ឋាន លេខ០០៣/ស.ក.ណ.២០២១ សេចក្តីកំណត់ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច រចនាសម្ពន្ធចាត់តាំង កងឯកភាពចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១។

មន្ទីរ អនុប្រធានមន្ទីរ នាយការិយាល័យ និងបុគ្គលិក។ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីខេត្តៈ មេបញ្ជាការ មេបញ្ជាការរង នាយសេនាធិការ នាយសេនាធិការរង ប្រធានមន្ទីរ អនុប្រធានមន្ទីរ នាយការិយាល័យ និងបុគ្គលិក ព្រមទាំង មេបញ្ជាការ(មេបញ្ជាការរង) មូលដ្ឋានកងរាជអាវុធហត្ថក្រុង-ខណ្ឌ-ស្រុក មេស្នាក់ការសន្តិសុខ (កងរាជអាវុធហត្ថ) និងបុគ្គលិក។

**ខ. តួនាទី ភារកិច្ចកងរាជអាវុធហត្ថលើផ្ទៃប្រទេស**

កងរាជអាវុធហត្ថ មានតួនាទី ភារកិច្ច[១១] ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ដូចខាងក្រោមៈ

**ខ.១. រ៉ាប់រងសកម្មភាពប៉ូលីសរដ្ឋបាល**

- រក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- រ៉ាប់រងអោយមានការគោរពច្បាប់ និងបទបញ្ជាទាំងឡាយ
- ផ្តល់ព័ត៌មាន និងជួយសង្គ្រោះពលរដ្ឋស៊ីវិល

ក្នុងក្របខ័ណ្ឌនេះកងរាជអាវុធហត្ថត្រូវអនុវត្តន៍តាមបទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច។

**ខ.២. រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ**

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និងទោសកម្ម
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភ័ស្តុតាងផ្សេងៗ
- ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តិបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ

ក្នុងក្របខ័ណ្ឌនេះ កងរាជអាវុធហត្ថត្រូវអនុវត្តន៍តាមបទបញ្ជារបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង្គការអយ្យការ និងអាជ្ញាធរតុលាការមានសមត្ថកិច្ច។

---

[១១] អនុក្រឹត្យលេខ៧៧អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤។

**ខ.៣. បំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងយោធា**

- ទទួលបន្ទុករក្សាសុវត្ថិភាព និងបំពេញតួនាទីជា កងកិត្តិយស ជាប្រយោជន៍ដល់ស្ថាប័ន រាជរដ្ឋាភិបាល និងអាជ្ញាធរជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា។

- ការពារទីតាំងយោធា

- កិច្ចការប៉ូលីសយោធានៅក្នុង និងក្រៅទីតាំងកងទ័ព។

ក្នុងក្របខ័ណ្ឌនេះកងរាជអាវុធហត្ថត្រូវអនុវត្តន៍តាមបទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរយោធាមានសមត្ថកិច្ច។

**ខ.៤. ផ្តល់កម្លាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់។**[១២]

**គ. រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចការិយាល័យជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ**

កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដោយមាន ការិយាល័យជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ចំណុះស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន[១៣] ព្រមទាំងមានរចនាសម្ពន្ធការិយាល័យចំណុះមន្ទីរផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន នៅតាមបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្តក្តាប់ជាប់ពត៌មានគ្រោះមហន្តរាយទូទាំងប្រទេស ដោយបំពេញតួនាទីជាសេនាធិការជូន ស្នងការ ស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺនកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ត្រូវអនុវត្តភារកិច្ច មានដូចជាៈ ការត្រួតពិនិត្យកម្លាំងសម្ភារៈ មធ្យោបាយសង្គ្រោះ និងគ្រប់គ្រងភូមិសាស្ត្រ ប្រជាសាស្ត្រ មានទាំងទិន្នន័យប្រជាជន វត្តអារាម ស្ពាន ថ្នល់ សាលារៀន មន្ទីរពេទ្យ និងស្ពានខ្ពង់រាបវាលទំនាបនៃតំបន់ភូមិសាស្ត្រនីមួយៗ ដែលងាយរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ[១៤]។ ធ្វើផែនការស្តីពី ការត្រៀម

---

[១២] អនុក្រឹត្យលេខ៧៧អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤។

[១៣] សេចក្តីកំណត់ពី ការកែសម្រួលតួនាទីភារកិច្ច រចនាសម្ពន្ធចាត់តាំងកងឯកភាព ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខ០០៣/ស.ក.ណ. អគ្គបញ្ជាការដ្ឋាន ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១។

[១៤] សេចក្តីកំណត់ស្តីពី តួនាទី ភារកិច្ច និងរចនាសម្ពន្ធចាត់តាំងបណ្តាស្ថាប័នចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខ០១/២០២១ ស.ក.ណ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១។

ប្រើប្រាស់កម្លាំងជួយសង្គ្រោះគ្រោះមហន្តរាយប្រចាំឆ្នាំ ដែលមានកំណត់ចំនួនច្បាស់លាស់ នូវការប្រើប្រាស់កម្លាំងសរុប ពីបណ្តាអង្គភាពចំណុះកងរាជអាវុធហត្ថលើផ្ទៃប្រទេស កងអន្តរាគមន៍ចល័តបណ្តាកងរាជអាវុធហត្ថរាជធានី-ខេត្ត[១៥]។

### ៣.៣. គោលការណ៍អនុវត្តសង្គ្រោះគ្រោះមហន្តរាយ

ដើម្បីគ្រប់គ្រងប្រតិបត្តិការអោយមានប្រសិទ្ធភាព ត្រូវបានអនុវត្តនូវគោលការណ៍មានដូចជា៖ បែងចែកកម្លាំងបិទខ្ទប់ប្រជាពលរដ្ឋអោយទៅកាន់ទីកន្លែងមានសុវត្ថិភាព។ ការពាររក្សាសន្តិសុខ ផ្តល់សុវត្ថិភាពនៅចំណុចឈរជើង តំបន់បិទខ្ទប់ កន្លែងធ្វើចត្តាឡីស័ក និងកន្លែងព្យាបាល។ ធ្វើចរាចររក្សាសណ្តាប់ធ្នាប់ ដើម្បីបង្កលក្ខណៈអោយបណ្តាស្ថាប័នផ្សេងទៀត ចល័តចូលជួយសង្គ្រោះប្រជាពលរដ្ឋ ដែលសង្ស័យថា បានឆ្លងជំងឺកូវីដ១៩។ ជួយសម្របសម្រួលជូនប្រជាពលរដ្ឋ ដែលជួបការ លំបាកក្នុងពេលបិទខ្ទប់ លើបញ្ហាសុខភាព ឬបញ្ហាផ្សេងៗ។ ធ្វើការណែនាំប្រជាពលរដ្ឋអោយអនុវត្តតាមនូវ វិធានក្នុងពេលបិទខ្ទប់របស់ក្រសួងសុខាភិបាល សារាចររបស់អាជ្ញាធររាជធានី ខេត្ត និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ ឧបត្ថម្ភផ្តល់ជំនួយស្បៀងអាហារ ភេសជ្ជៈសង្គ្រោះបឋម ថ្នាំសង្កូវដល់ប្រជាពលរដ្ឋ និងជួយព្យាបាលជំងឺផ្សេងៗ។ រៀបចំជូនប្រជាពលរដ្ឋដែលត្រូវធ្វើចត្តាឡីស័ក និងសម្រាកព្យាបាល មានដូចជា៖ កន្លែងស្នាក់នៅ កន្លែងហូបចុក អនាម័យ ដើម្បីបញ្ចៀសការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ក្នុងករណីមានសភាពការណ៍ធ្ងន់ធ្ងរត្រូវផ្តល់ព័ត៌មាន និងសំណូមពរទៅថ្នាក់ជាតិ ដើម្បីមានវិធានការណ៍ជាក់ស្តែង។ សរុបមកវិញ កិច្ចប្រតិបត្តិការសង្គ្រោះគ្រប់រូបភាព ការរក្សាសណ្តាប់ធ្នាប់ កិច្ចការពារសន្តិសុខ និងការងារផ្សេងៗទៀត ដែលទាក់ទិនជាមួយនឹងស្ថាប័នពាក់ព័ន្ធ ត្រូវបន្តរហូតដល់មានការធូរស្រាល ទើបបញ្ជូនប្រជាពលរដ្ឋ ទៅកាន់កន្លែងដើមវិញ ដើម្បីបញ្ចប់ភារកិច្ច[១៦]។

---

[១៥] ផែនការស្តីពី ការត្រៀមប្រើប្រាស់កម្លាំងជួយសង្គ្រោះគ្រោះមហន្តរាយ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ឆ្នាំ ២០២១។

[១៦] ខ្លឹមសារបទបង្ហាញស្តីពី ផែនការស្តីពី ជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ កងរាជអាវុធហត្ថលើផ្ទៃប្រទេស របស់លោក វរសេនីយ៍ឯក ឡាក់ គួន នាយការិយាល័យជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ស្នងការដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងវគ្គបំប៉នជំនាញបើកបរអូរប៉័រ និងសង្គ្រោះគ្រោះមហន្តរាយ ជំនាន់ទី១៩ ឆ្នាំ២០១៩។

### ៣.៤. ប្រតិបត្តិការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា បានចេញសេចក្ដីសម្រេចស្ដីពី ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩[១៧] និងបានបង្កើតគណកម្មការជាតិគ្រប់គ្រង និងដឹកនាំអនុវត្តវិធានការបិទខ្ទប់(គ.ប.ខ)[១៨]។

កម្លាំងកងរាជអាវុធហត្ថ បានចេញប្រតិបត្តិការ យោងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ដោយបានបែងចែកកម្លាំងតាមគោលដៅភូមិសាស្ត្រខាងក្រៅគឺ បិទខ្ទប់ការធ្វើដំណើរ ចរាចរចេញចូលរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត កន្លែងព្យាបាលអ្នកជំងឺកូវីដ-១៩ ជាពិសេសតំបន់បានឆ្លងជំងឺកូវីដ ដែលមានអ្នករងគ្រោះច្រើន ដោយត្រូវបានបែងចែកជាបីតំបន់គឺ តំបន់ក្រហម(ជាតំបន់មានការឆ្លងជំងឺកូវីដ១៩ខ្លាំង) តំបន់លឿងទុំ(ជាតំបន់មានការឆ្លងជំងឺកូវីដ១៩ បង្គួរ) និងតំបន់លឿង(ជាតំបន់មានការឆ្លងជំងឺកូវីដ១៩ តិច)។ ការពារទីតាំងធ្វើចត្តាឡីស័ក ការពារទីតាំងយកសំណាករកមេរោគកូវីដ-១៩ ការពារទីតាំងព្យាបាលជំងឺកូវីដ-១៩ ការពារក្បួនដឹកជញ្ជូនវ៉ាក់សាំង ការពារសន្តិសុខកន្លែងចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ បិទខ្ទប់ការធ្វើចរាចរតាមបណ្ដាខេត្តនានា ជាពិសេសខេត្តជាប់ព្រំដែន។

## ៤. លទ្ធផលនៃការស្រាវជ្រាវ

### ៤.១. ការគ្រប់គ្រងប្រតិបត្តិការក្នុងបរិបទនៃជំងឺកូវីដ-១៩ ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១

មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានធ្វើការត្រួតពិនិត្យកម្លាំង ផ្ដល់អនុសាសន៍ណែនាំ បំពាក់សម្ភារៈ និងគ្រឿងបរិក្ខារដល់កម្លាំងកងរាជអាវុធហត្ថទាំងអស់មុនចេញប្រតិបត្តិការ ព្រមទាំងចុះត្រួតពិនិត្យតំបន់គោលដៅបិទខ្ទប់ តាមបណ្ដាខណ្ឌក្នុង

---

[១៧] សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៥៤ ស.ស.រ ឆ្នាំ២០២១។

[១៨] លិខិតលេខ៤៩សសរ សេចក្ដីសម្រេចរាជរដ្ឋាភិបាល ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១។

រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល។ កងរាជអាវុធហត្ថ៖ បានបែងចែកកម្លាំងបិទខ្ទប់ប្រជាពលរដ្ឋ អោយទៅកាន់ទីកន្លែងមានសុវត្ថិភាពការពាររក្សាសន្តិសុខផ្ដល់សុវត្ថិភាពនៅចំណុចឈរជើង តំបន់បិទខ្ទប់ កន្លែងធ្វើចត្តាឡីស័ក និងកន្លែងព្យាបាល។ បានបិទការធ្វើចរាចរ រក្សាសណ្ដាប់ធ្នាប់ ដើម្បីបង្កលក្ខណៈអោយបណ្ដាស្ថាប័នផ្សេងទៀត ចល័តចូលជួយសង្គ្រោះប្រជាពលរដ្ឋ ដែលសង្ស័យថា បានឆ្លងជំងឺកូវីដ១៩។ ធ្វើការណែនាំប្រជាពលរដ្ឋអោយអនុវត្តតាមនូវ វិធានក្នុងពេលបិទខ្ទប់របស់ក្រសួងសុខាភិបាល សារាចររបស់អាជ្ញាធររាជធានីភ្នំពេញ និងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។ឧបត្ថម្ភផ្ដល់ជំនួយស្បៀងអាហារ ភេសជ្ជៈ សង្គ្រោះបឋម ថ្នាំសង្កូវដល់ប្រជាពលរដ្ឋ និងជួយព្យាបាលជំងឺផ្សេងៗ។ សរុបមកវិញ កិច្ចប្រតិបត្តិការសង្គ្រោះគ្រប់រូបភាព ការរក្សាសណ្ដាប់ធ្នាប់ កិច្ចការពារសន្តិសុខ និងការងារផ្សេងៗទៀត ដែលទាក់ទិនជាមួយនឹងស្ថាប័នពាក់ព័ន្ធ ត្រូវបានបន្តរហូតដល់មានការធូរស្រាល ទើបបញ្ចប់ភារកិច្ច។

កិច្ចការពិនិត្យថែទាំសុខភាពកងទ័ព៖ បានទទួលការឧបត្ថម្ភរបស់សម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត៖ ម៉ាស់ខ្មៅរូបឡូហ្គោក អ.ហ ចំនួន១ ៥០០ ០០០ម៉ាស់។ អង្គភាពជានាះ បរិក្ខារចំនួន៥មុខរួមមាន សម្លៀកបំពាក់ មួកពេទ្យ ដែលលាងដៃ ធុងបាញ់ថ្នាំអគ្គិសនី ទឹកថ្នាំម៉ាស៊ីនបាញ់ថ្នាំ សម្លាប់មេរោគ អាល់កុល ឱសថចិន ឧបករណ៍តេស្តរហ័សរកជំងឺកូវីដ-១៩។ កិច្ចការពិនិត្យសុខភាព និងព្យាបាលជំងឺ៖ បានទទួលប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចំនួន២២ ៥០៦នាក់ (គ្រួសារចំនួន ១៣ ៩៧១នាក់)។ បានធ្វើតេស្តសំណាករកមេរោគជំងឺកូវីដ-១៩ (Rapid Test) ចំនួន៦២ ៩៤០នាក់ (វិជ្ជមានចំនួន១ ៩០០នាក់)។ បានទទួលពិនិត្យ និងព្យាបាលជំងឺជូនយោធិននៃកងរាជអាវុធហត្ថចំនួន១៣ ៥៥៥នាក់ (បញ្ជូនសង្គ្រោះចំនួន៣៨៧នាក់)។ កិច្ចការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩៖ ក្រុមគ្រូពេទ្យកងរាជអាវុធហត្ថ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចាក់ដូសទី៣ចំនួន៥០ ៧០៧នាក់ (ស្រីចំនួន២៥ ២៩៦នាក់)៖ កងរាជអាវុធហត្ថចំនួន៩ ២៣០នាក់ (ស្រីចំនួន ២៧០នាក់) គ្រួសារកងរាជអាវុធហត្ថចំនួន១០ ០០១នាក់ (ស្រីចំនួន៦ ៦៧៤នាក់) ប្រជាពលរដ្ឋចំនួន៣១ ៤៧៦នាក់ (ស្រីចំនួន១៨ ៣៥២នាក់)។ ចាក់ដូសទី៤ បានចំនួន១២ ៦៧៧នាក់៖ កងរាជអាវុធហត្ថចំនួន៨ ៨៥៣នាក់ គ្រួសារកងរាជអាវុធហត្ថចំនួន៣ ៨២៤

នាក់។ ចាក់ដូសទី៥ ចំនួន១១ ២៥១នាក់ (ស្រីចំនួន៥៩៨នាក់) កងរាជអាវុធហត្ថចំនួន៩ ១៤៤នាក់ គ្រួសារកងរាជអាវុធហត្ថចំនួន១ ២០៣នាក់ ប្រជាពលរដ្ឋចំនួន៩០៤នាក់ (ស្រីចំនួន៥៩៨នាក់)។

### ៤.២. អនុវត្តការគ្រប់គ្រងប្រតិបត្តិការក្នុងបរិបទកូវីដ-១៩ ផ្សារត្រូវការខ្វះខាតរជំនួយមនុស្សធម៌

ចូលរួមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ ជូនប្រជាពលរដ្ឋបានចំនួន២៨ ៩៣០នាក់(ស្រី១៦ ៧៧៦នាក់)។ ក្រុមគ្រូពេទ្យចុះចាក់វ៉ាក់សាំង (Astra Zenica) ដូសទី៣ និងដូសទី៤ ជូនប្រជាពលរដ្ឋ និងកម្មករនៅខណ្ឌកំបូល រាជធានីភ្នំពេញ ចំនួន១ ៨៤៧នាក់។ ចាក់វ៉ាក់សាំងដូសទី៣ និងដូសទី៤ ជូនប្រជាពលរដ្ឋចំនួន៥ ៣៣៤នាក់ (ខេត្តស្វាយរៀង១ ១៦៨នាក់ បន្ទាយមានជ័យចំនួន៤ ១៦៦នាក់) និងព្យាលបាលជូនប្រជាពលរដ្ឋចំនួន៣៧ នាក់ (ខេត្តស្វាយរៀង ខេត្តប៉ៃលិន) និងបានចែកប័ណ្ណវ៉ាក់សាំងជូនយោធិន ក្រុមគ្រួសារ ប្រជាពលរដ្ឋ បានចំនួន២២១ ៥៦៥នាក់ (គ្រួសារយោធិន ចំនួន៨៥៩នាក់ ប្រជាពលរដ្ឋចំនួន២២០ ៣៣៧ប័ណ្ណ/នាក់)។

ការគ្រប់គ្រងប្រតិបត្តិការកងរាជអាវុធហត្ថក្នុងការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានដោះស្រាយស្បៀងបឋមជូនប្រជាពលរដ្ឋមានការខ្វះខាត ក្នុងតំបន់បិទខ្ទប់ចំនួន២៣លើក ស្មើចំនួន១៥៨គ្រួសារនូវស្បៀងអាហារចំនួន១៨៣កញ្ចប់ និងបានសម្របសម្រួលឱ្យសង្កាត់ ខណ្ឌ និងជូនទៅគណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំអនុវត្តវិធានការបិទខ្ទប់ ជួយដោះស្រាយស្បៀងបឋមចំនួន២១លើក ស្មើចំនួន១០៤គ្រួសារ។[១៩]

## ៥. សន្និដ្ឋាន និងអនុសាសន៍

### ៥.១. សន្និដ្ឋាន

កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ មេបញ្ជាការ នៅតែសម្រេចបានរាល់ការអនុវត្ត តួនាទី ភារកិច្ចស្នូលរបស់ខ្លួន គោរពវិន័យ បទបញ្ជា និងអភិវឌ្ឍ

---

[១៩] របាយការណ៍បូកសរុបក្នុងពេលបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ឆ្នាំ២០២០ ដល់ឆ្នាំ២០២២។

ទោះបីស្ថិតក្នុងស្ថានភាព វិបត្តិនយោបាយជាតិ និងអន្តរជាតិ វិបត្តិសេដ្ឋកិច្ច បង្កការលំបាកដល់ការអភិវឌ្ឍសង្គម ជួបគ្រោះអាសន្ននៃគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស ឬធម្មជាតិក្តី ជាក់ស្តែងក្នុងបរិបទទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ស្ថាប័នកងរាជអាវុធហត្ថបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការ សហប្រតិបត្តិការ ធានាបានសន្តិសុខសង្គម ស្ថិរភាពនយោបាយ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់របៀបរៀបរយជូន ប្រជាពលរដ្ឋ ថ្នាក់ដឹកនាំជាតិ អន្តរជាតិ និងព្រះមហាក្សត្រ ថែមទាំងពង្រឹងការអនុវត្តច្បាប់ និងបទបញ្ជា បង្ក្រាបបទល្មើស និងសង្គ្រោះគ្រោះមហន្តរាយបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធិភាពខ្ពស់។

### ៥.២. អនុសាសន៍

១. ពង្រឹងយន្តការស្រាវជ្រាវ ប្រមូលផ្តុំ និងការគ្រប់គ្រងព័ត៌មាន បម្រើឱ្យព្រឹត្តិការណ៍សង្គ្រោះគ្រោះមហន្តរាយ និងក្តាប់ជាប់ទាន់ពេលវេលានូវរាល់ហេតុការណ៍គ្រោះមហន្តរាយកើតឡើង។

២. ពង្រឹងយន្តការស្រាវជ្រាវបង្ក្រាបរាល់បទល្មើសការរ៉េរាំង ការលាក់ព័ត៌មានអ្នកបង្កអោយមានគ្រោះមហន្តរាយកើតឡើង និងសកម្មភាពផ្សេងៗទៀត ដែលមានចែងក្នុងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ។

៣. បន្តត្រៀមកម្លាំង មធ្យោបាយ ឧបករណ៍សម្ភារៈសង្គ្រោះ ត្រៀមអនុវត្តបទបញ្ជាធ្វើអន្តរាគមន៍ ការពារសន្តិសុខសង្គម រក្សាសណ្តាប់ធ្នាប់សាធារណៈ ជួយសង្គ្រោះគ្រោះមហន្តរាយ និងការពារបូរណភាពទឹកដី រក្សាសន្តិភាពសង្គម។

៤. បើកវគ្គហ្វឹកហ្វឺន បណ្តុះបណ្តាល សិក្ខាសាលា និងបំប៉ន ដល់នាយ នាយរងកងរាជអាវុធហត្ថ ពង្រឹងសមត្ថភាពជំនាញ មានចំណេះដឹងខ្ពស់ និងចេះភាសាបរទេស ដើម្បីបន្តវេនការងារទៅតាមការវិវឌ្ឍនាពេលអនាគត។

៥. ចូលរួមកិច្ចប្រជុំ សិក្ខាសាលា ធ្វើផែនការ លំហាត់សមយុទ្ធសង្គ្រោះគ្រោះមហន្តរាយ ទាំងក្នុង និងក្រៅប្រទេស ជាពិសេសកិច្ចប្រជុំក្រុមការងារជំនាញស្តីពី ជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ក្នុងក្របខណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក។

# គន្ថនិទ្ទេស

## ក. ឯកសារជាខេមរភាសា

១- ព្រះរាជក្រឹត្យលេខ៤៤៦NS និងលេខ៤៤៧NS ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ១៩៥៧។

២- អនុក្រឹត្យលេខ ៧៧អនក្រ.បក. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និង រចនា សម្ពន្ធទូទៅនៃកងរាជអាវុធហត្ថ។

៣- ច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥។

៤- សេចក្តីកំណត់ពី ការកែសម្រួលតួនាទីភារកិច្ច រចនាសម្ពន្ធចាត់តាំងកងឯកភាព ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខ០០៣/ស.ក.ណ. អគ្គ បញ្ជាការដ្ឋាន ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១។

៥- ប្រវត្តិសាស្ត្រកងរាជអាវុធហត្ថ បោះពុម្ពលើកទី១ ឆ្នាំ២០១៨។

៦- ខ្លឹមសារបទបង្ហាញស្តីពី ផែនការស្តីពី ជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្ត រាយ កងរាជអាវុធហត្ថលើផ្ទៃប្រទេស របស់លោក វរសេនីយ៍ឯក ឡាក់ គួន នាយ ការិយាល័យជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ស្នងការដ្ឋាន ផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងវគ្គបំប៉ន ជំនាញបើកបរអូរប៉័រ និងសង្គ្រោះគ្រោះមហន្តរាយ ជំនាន់ទី១៩ ឆ្នាំ២០១៩។

៧- ផែនការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រាជអាវុធហត្ថលើផ្ទៃប្រទេស ឆ្នាំ ២០២១។

៨- សេចក្តីកំណត់ពី ការកែសម្រួលតួនាទីភារកិច្ច រចនាសម្ពន្ធចាត់តាំងកងឯកភាព ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខ០០៣/ស.ក.ណ. អគ្គ បញ្ជាការដ្ឋាន ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១។

៩- សេចក្តីកំណត់ស្តីពី តួនាទី ភារកិច្ច និងរចនាសម្ពន្ធចាត់តាំងបណ្តាស្ថាប័នចំណុះ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខ០១/២០២១ ស.ក.ណ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០២១។

១០- លិខិតលេខ៤៩សសរ សេចក្តីសម្រេចរាជរដ្ឋាភិបាល ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១។

១១- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៥៤ ស.ស.រ ឆ្នាំ២០២១។

១២- ផែនការស្តីពី ការត្រៀមប្រើប្រាស់កម្លាំងជួយសង្គ្រោះគ្រោះមហន្តរាយ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ឆ្នាំ២០២១។

១៣- បណ្តាញផ្សព្វផ្សាយសង្គម គេហទំព័រ សារព័ត៌មាននានា GRK New។

១៤- អនុសាសន៍ផ្ទាល់របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឆ្នាំ២០២១។

១៥- ប្រព័ន្ធបណ្តាញផ្សព្វផ្សាយសង្គម តេឡេក្រាម GRK NEWS។

១៦- របាយការណ៍ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ កិច្ចការជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ។

១៧- របាយការណ៍បូកសរុបក្នុងពេលបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ឆ្នាំ២០២០ ដល់ឆ្នាំ២០២១។

## ខ. ឯកសារបរទេស

១៨- https://wikileaks.org/wiki/Operational_control_(military), (Accessed ៣០ January ២០២៤).

១៩- http://publichealth.lacounty.gov/media/coronavirus/docs/about/WhatIsCOVID-Cambodian.pdf (Accessed ២៦ July ២០២៤)

# ការពង្រឹងគុណភាពអប់រំមធ្យមសិក្សាបឋមភូមិ
# (ករណីសិក្សានៅខេត្តកំពង់ឆ្នាំង)

*បេក្ខជនបណ្ឌិត* **លី សុខា**

## ១. សេចក្តីផ្តើម

### ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ (Background and Rational)

វិស័យអប់រំ ត្រូវបានចាត់ទុកជាវិស័យមួយដ៏មានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ក្នុងរយៈពេលកន្លងមក និងជាពិសេសក្នុងអំឡុងពេលដែលប្រទេសមានសុខសន្តិភាពពេញបរិបូរណ៍ រយៈពេល២០ឆ្នាំចុងក្រោយនេះ[១]។ ដាក់ស្តែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិក៏ដូចជាការប្រកាសដោយផ្ទាល់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសថា ការអភិវឌ្ឍធនធានមនុស្សគឺត្រូវប្តូរមកអាទិភាពទី១វិញមុនទឹក ផ្លូវ និងភ្លើង។ ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនេះ គុណភាពនៃ ការអប់រំ គឺជាកត្តាគន្លឹះក្នុងការកសាងធនធានមនុស្ស ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បាទា ចរិយា សម្បទា និងកាយសម្បទា[២]។

ការអប់រំមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍសង្គមជាក់ស្តែង។ ការកែលម្អការអប់រំដើម្បីទទួល បានមនុស្សដែលមានការអប់រំនោះ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់អភិវឌ្ឍន៍សង្គម ហើយ គ្មានការសង្ស័យទេថា សង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ពិតជានឹងមានការលំបាក ថែមទាំង មិនអាចដំណើរការទៅបាន ប្រសិនបើគ្មានវត្តមាននៃមនុស្សដែលមានចំណេះដឹងទេនោះ។ ក្នុងន័យទូលំទូលាយការអប់រំគឺជាមធ្យោបាយមួយ ដើម្បីរំដោះមនុស្សចេញពីភាពល្ងង់ខ្លៅនិងអវិជ្ជា ឱ្យធ្វើដំណើរទៅរកភាពជាមនុស្សភ្លឺស្វាងក្នុងជីវិត។ កាលណាមនុស្សមានភាពភ្លឺស្វាងក្នុងជីវិតហើយនោះ មនុស្សមិនងាយចាញ់បោកគេដោយ

---

[១]ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១២៖សេចក្តីណែនាំស្តីពីការបង្កើត និងដំណើរការគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា។

[២]ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥៖ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស។

ងាយៗនោះទេព្រោះគេមានមូលដ្ឋានសម្រាប់ពិចារណា និងរិះគិតគ្រប់គ្រាន់ហើយគេអាចបែងចែកអ្វីល្អនិងអាក្រក់បានប្រសើរជាងមុន ព្រមទាំងអាចមានការងារល្អ និងប្រាក់ចំណូលប្រសើរជាងមុន។ ការអប់រំផ្តល់អត្ថប្រយោជន៍ដល់ជីវិតផ្ទាល់ខ្លួន និងអាជីពការងារជាច្រើន។

ក្នុងសង្គមនីមួយៗដំណើរការអប់រំមានការវិវត្តពីមួយជំនាន់ទៅមួយជំនាន់ដូចៗគ្នា។ កាលពីបុរាណសម័យ ដើម្បីការអប់រំគឺគេផ្តល់ឱ្យគ្នាតាមរយៈពីមាត់ទៅមាត់ជាការនិទានទូន្មានផ្សេងៗដោយ បង្កប់នូវចំណេះដឹងនានាតាមរយៈការនិទាននោះហើយគេធ្វើរបៀបនេះ ពីជំនាន់មួយទៅជំនាន់មួយ។ ក្រោយមកទាំងរបៀបអប់រំទាំងរបៀបផ្ទេរពុទ្ធិក៏មានការវិវត្ត។ អ្នកចេះច្រើនចាប់ផ្តើម ក្លាយជាគ្រូរបស់ អ្នកចេះតិចហើយអ្នកចេះតិចធ្វើជាគ្រូ អ្នកមិនទាន់ចេះហើយអ្នកចេះតិចធ្វើជាគ្រូអ្នកមិនទាន់ចេះ ដើម្បីបង្រៀននិងផ្តល់ចំណេះឱ្យគ្នាទៅវិញទៅមក។ លុះក្រោយៗមកក៏ចាប់ផ្តើមបង្កើតឱ្យមាន សាលារៀនហើយនិងមានសិស្សទៅរៀននៅសាលាជាដើមដែលការកើតមានសាលា និងមានការបណ្តុះបណ្តាលនៅតាមសាលារៀននេះ គឺជាការបើកឡើងនូវទំព័រមនុស្សជាតិសម័យទំនើបហើយដែល មនុស្សសម័យទំនើបគេនិយមទៅទទួលការអប់រំ និងបណ្តុះបណ្តាលតាមសាលាតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតាមមហាវិទ្យាល័យឬសាកលវិទ្យាល័យនានាវិញ។ ដូច្នេះនេះគឺជាដំណើរវិវត្តមួយក្នុងប្រព័ន្ធអប់រំមនុស្សជាតិ តាំងពីបរមបុរាណរៀងមកដែលភស្តុតាងពីដំណើរវិវត្តនេះតួយ៉ាងនៅប្រទេស យើងគេឃើញមានសេសសល់ជាអាទិ៍នៅតាមប្រាង្គប្រាសាទនិងវត្តអារាម ស្ទើរពាសពេញផ្ទៃប្រទេស មានទាំងប្រព័ន្ធអប់រំបែបទំនើបនិងប្រព័ន្ធអប់រំតាមបែបសាសនាជាដើម។

ប្រសិនបើគេនិយាយអំពីទិដ្ឋភាពនៃការអប់រំនោះគេនឹងឃើញថា សង្គមមនុស្សត្រូវការការអប់រំ វាជាតម្រូវការដ៏ចាំបាច់បំផុត សម្រាប់សង្គមមនុស្សហើយការអប់រំត្រូវវិនិយោគរយៈពេលយូរទើបទទួលផល ព្រោះការសិក្សាដើម្បីទទួលបានពិន្ទុល្អ។ អត្ថន័យពិតរបស់វាការអប់រំគឺជាមធ្យោបាយមួយស្វែង យល់ពីអ្វីថ្មីៗដែលយើងមិនទាន់បានដឹងដើម្បីឈានទៅបង្កើនចំណេះដឹងរបស់យើង។មានការអប់រំធ្វើឱ្យមនុស្សទទួលបាននូវចំណេះដឹង។ បុគ្គលមានចំណេះដឹងមានសមត្ថភាព ចេះធ្វើការបែងចែករវាងអ្វី ដែលខុសអ្វីដែលត្រូវអ្វីដែលល្អនិងអ្វីដែលអាក្រក់បានប្រសើរជាងអ្នកពុំមានចំណេះដឹង។ ជាការពិត មនុស្សម្នាក់ដែលបានទទួលការអប់រំល្អឥតខ្ចោះគាត់មិនត្រឹមតែជាវិញ្ញូជនអប់រំមួយរូបដ៏ល្អ ប៉ុណ្ណោះ ទេប៉ុន្តែគាត់ក៏

ជាអ្នករួមចំណែកដល់ការរីកចម្រើននៃប្រជាជាតិមួយផងដែរ។ ដូច្នេះហើយការអប់រំពលរដ្ឋ គឺជាទំនួលខុសត្រូវចម្បងរបស់សង្គម។

ប្រទេសកម្ពុជាត្រូវខ្ទេចខ្ទាំដោយសង្គ្រាមរ៉ាំរ៉ៃ និងសង្គ្រាមស៊ីវិលជាច្រើនឆ្នាំពិសេស ក្នុងរបបប្រល័យពូជសាសន៍ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩។ វិស័យអប់រំបានចាប់ផ្តើម ដំណើរការជាបណ្តើរៗ ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ក្រោមរូបភាពខ្វះមុខខ្វះក្រោយ យ៉ាងខ្លាំងទាំងធនធានមនុស្សទាំង ធនធានសម្ភារៈ។ បន្ទាប់ពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ មករាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌគោលនយោបាយនៃការផ្សះផ្សា បង្រួបបង្រួមជាតិហើយរដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសកម្ពុជាក៏ត្រូវបានអនុម័ត។ ដោយការអប់រំ មានតួនាទីសំខាន់ ក្នុងការអភិវឌ្ឍជាតិ និងសម្រាប់ សមាហរណកម្មអាស៊ាន ទើបរាជរដ្ឋា-ភិបាលកម្ពុជាបានគិតគូរយកចិត្តទុកដាក់ខ្លាំងលើវិស័យអប់រំ ដោយបានចែងក្នុងរដ្ឋធម្មនុញ្ញថា "រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋមនិងមធ្យមសិក្សានៅសាលារៀន សាធារណៈសម្រាប់ប្រជាពលរដ្ឋ គ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ"[៣]។ ឆ្លើយតបនឹងខ្លឹមសាររដ្ឋធម្មនុញ្ញនេះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាក៏បាន អនុម័តច្បាប់ ស្តីពីការអប់រំដែលមានគោលបំណង "អភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញ មួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ"[៤]។ រាជរដ្ឋាភិបាលកម្ពុជា ក៏បាន និងនៅតែបន្តប្តេជ្ញាលើកកម្ពស់គុណភាពសេវាអប់រំ និងបន្តបង្កើនការបែងចែកថវិកា ចរន្តរបស់ថវិកាជាតិឱ្យវិស័យអប់រំ និងធានានូវការបញ្ចេញសាច់ប្រាក់បានទាន់ពេល។ ជាក់ស្តែង ក្នុងគោលនយោបាយជាអាទិភាព នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានផ្តោតជាសំខាន់បី គឺការធានាសមធម៌ នៃការចូលរៀន ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនិងការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីអនុវត្តវិមជ្ឈការ។ ម៉្យាងទៀត ដើម្បីសម្រេចបាននូវគោលដៅអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនូវគោល-

[៣]ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៦៨ នៃរដ្ឋធម្មនុញ្ញ។
[៤]ព្រះរាជាណាចក្រកម្ពុជាច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧។

នយោបាយអប់រំសំខាន់ៗបួន គឺ ទី១-ការធ្វើសកលកម្មការ អប់រំមូលដ្ឋានចំនួន៩ឆ្នាំ និងបង្កឱកាសអភិវឌ្ឍអក្ខរកម្មវិជ្ជាជីវៈ ទី២-ការធ្វើទំនើបកម្មនិងការកែលម្អ គុណភាពអប់រំតាមរយៈការកែទម្រង់ដែលមានប្រសិទ្ធភាព ទី៣-ការផ្សារភ្ជាប់ការអប់រំការ បណ្តុះបណ្តាលទៅនឹងទីផ្សារពលកម្ម និងសង្គម និងទី៤-ការស្តារនិងអភិវឌ្ឍការងារយុវជន និងកីឡា[៥]។

ក្រសួងអប់ រំយុវជន និងកីឡាដាក់ឱ្យអនុវត្តបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះដឹងទូទៅនៅកម្ពុជា និងអនុវត្តការគ្រប់គ្រងតាមសាលារៀនផ្តោតលើការធ្វើអធិការកិច្ចសាលារៀនដែលមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវទស្សនៈពីខាងក្រៅនិងការវាយតម្លៃសាលារៀនប្រកបដោយសុក្រឹតភាព ដើម្បីធ្វើការកែលម្អសាលារៀននិងលើកកម្ពស់គុណភាពអប់រំ (លទ្ធផលសិក្សាសិស្ស) ព្រមទាំងចែករំលែកបទពិសោធន៍ល្អៗរវាងសាលារៀនក្នុងក្របខ័ណ្ឌអធិការកិច្ចធានាគុណភាពអប់រំ។ ក្នុងន័យនេះការងារអធិការកិច្ចមានតួនាទីធានាថាការរៀន និងការបង្រៀនប្រព្រឹត្តទៅតាមគរុកោសល្យ និងវិធីសាស្ត្របង្រៀនថ្មីៗហើយលទ្ធផលសិក្សាសិស្សសម្រេចបានតាមការរំពឹងទុក។ ទន្ទឹមនឹងនោះគោលនយោបាយសាលាមធ្យមសិក្សាធនធាន ដែលបានបង្កើតឡើងសម្រាប់កំណត់ និងអភិវឌ្ឍ សាលាមធ្យមសិក្សាធនធានទូទាំងប្រទេសក្នុងគោលបំណងធ្វើឱ្យសាលារៀនមានការរីកចម្រើនលើគ្រប់ផ្នែកដូចជាការអនុវត្តកម្មវិធីសិក្សាលទ្ធផលសិក្សា ចែករំលែកបទពិសោធន៍ល្អការរៀបចំផែនការ កែលម្អសាលារៀនផែនការអភិវឌ្ឍសាលារៀន និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។សាលាមធ្យមសិក្សាធនធានត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងផ្តល់អគារធនធានដែលបំពាក់ហេដ្ឋារចនាសម្ព័ន្ធសម្ភារៈរូបវន្ត (អគារសិក្សាសាលប្រជុំបន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹកបណ្តាញភ្លើង) និងបណ្តុះបណ្តាលការប្រើសម្ភារៈរូបវន្ត។ សាលាមធ្យមសិក្សាធនធានចំនួន៣៦សាលាកំពុងដំណើរការ និងមានថវិការដ្ឋ៣៥លានរៀលក្នុងមួយឆ្នាំសម្រាប់ចំណាយលើការទិញវត្ថុធាតុដើមទិញសៀវភៅដាក់បណ្ណាល័យជួសជុល និងថែទាំឧបករណ៍ចំណាយថ្លៃទឹកភ្លើង និងមុខចំណាយផ្សេងៗនិងថវិកាគាំទ្ររបស់ធនាគារអភិវឌ្ឍអាស៊ី (ADB) សម្រាប់ដំណើរការអគារ

[៥]ក្រសួងអប់រំ យុវជន និងកីឡា ២០០៥-២០០៩ នាយកដ្ឋានផែនការ (អាំងឌីកាទ័រ)។

ធនធានដោយយកចិត្តទុកដាក់លើមុខវិជ្ជាវិទ្យាសាស្ត្ររួមមានរូបវិទ្យា គីមីវិទ្យា ផែនដីវិទ្យា និងជីវវិទ្យា។

ក្នុងក្របខ័ណ្ឌសកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាផ្ដោតលើការធ្វើអធិការកិច្ចសាលារៀនដែលជាវិធីមួយដ៏ចម្បង និងមានប្រសិទ្ធភាពនៅក្នុងបណ្ដាប្រទេសជាច្រើនដើម្បីពិនិត្យថាតើសាលារៀនអនុវត្តនិងទទួលខុសត្រូវលើការងារបានកម្រិតណា។

## ១.២. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ និងកសាងរដ្ឋបាលសាធារណៈឱ្យស័ក្ដិសមជាអ្នកផ្ដល់សេវាសាធារណៈ ពិសេសវិស័យអប់រំ យុវជន និងកីឡាកាន់តែមានភាពឆ្លើយតប មានប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព គណនេយ្យភាព និងជំនឿទុកចិត្តពីប្រជាពលរដ្ឋដែលបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង ពិសេសបង្កិតសេវាឱ្យកៀកកិតប្រជាពលរដ្ឋ និងរចនាសម្ព័ន្ធរូបវន្តការគ្រប់គ្រងសាលារៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ការបង្រៀន និងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ របស់គ្រូ សិស្សនៅមធ្យមសិក្សានៅមានចំណុចខ្វះខាតជាច្រើនះបញ្ហាលើសនិងខ្វះគ្រូបង្រៀនកម្មវិធីសិក្សាមិនទាន់សមស្របនឹងបរិបទភូមិសាស្ត្រខ្វះការចូលរួមពីមាតាបិតាសិស្សសហគមន៍អង្គភាពពាក់ព័ន្ធខ្វះសម្ភារៈសិក្សា និងអនុវត្តការធ្វើពិសោធន៍ផ្នែកមុខវិជ្ជាវិទ្យាសាស្ត្រនៅបន្ទប់ពិសោធន៍។តាមរយៈការសង្កេត និងសម្ភាសរបស់អ្នកស្រាវជ្រាវជាមួយគណៈគ្រប់គ្រងសាលាគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនិងអ្នកសម្របសម្រួល (បរិវច្ឆការីអ្នកគ្រប់គ្រងកុំព្យូទ័រនិងបណ្ណារក្ស) ឃើញថាសិស្សមិនទាន់យកចិត្តទុកដាក់លើការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រឱ្យបានពេញលេញនៅឡើយ។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវក្របខ័ណ្ឌការពិនិត្យតាមដាន និងវាយតម្លៃសាលាមធ្យមសិក្សាធនធានផ្ដោតសំខាន់លើមុខវិជ្ជាវិទ្យាសាស្ត្រ ដោយរៀបចំឱ្យមានបន្ទប់ពិសោធន៍សម្ភារៈពិសោធន៍គ្រប់គ្រាន់ ដើម្បីឱ្យគ្រូបង្រៀនមានសមត្ថភាពគ្រប់គ្រាន់

ក្នុងការបង្រៀនការប្រើវិធីសាស្ត្រថ្មីៗជាលក្ខណៈសិស្សមជ្ឈមណ្ឌល ដើម្បីទាក់ទាញសិស្សឱ្យចូលចិត្តរៀនមុខវិជ្ជាវិទ្យាសាស្ត្រនេះនិងការប្រឡងទទួលបានលទ្ធផលល្អ។

ដើម្បីយល់ដឹងស៊ីជម្រៅចំពោះការពង្រឹងគុណភាពអប់រំនៅមធ្យមសិក្សាក្នុងប្រទេសកម្ពុជា សំណួរស្រាវជ្រាវគន្លឹះរួមមាន៖

១) តើការពង្រឹងគុណភាពអប់រំមធ្យមសិក្សាបឋមភូមិ មានការកែទម្រង់យ៉ាងដូចម្ដេចខ្លះ?

២) តើដំណើរការពង្រឹងគុណភាពអប់រំមធ្យមសិក្សាបឋមភូមិ មានបញ្ហាប្រឈមអ្វីខ្លះ?

៣) តើមានដំណោះស្រាយបែបណា ដើម្បីឱ្យវិស័យអប់រំទទួលបានជោគជ័យប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់?

ការសិក្សាស្រាវជ្រាវនេះ គឺយកតែលទ្ធផលសិក្សាឆ្នាំ ២០២២-២០២៣ ដោយប្រើប្រាស់ទិន្នន័យពីឆ្នាំ ២០១៨-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា។ គោលបំណងនៃការសិក្សាស្រាវជ្រាវលើការពង្រឹងគុណភាពអប់រំ ក្នុងវិស័យអប់រំ យុវជន និងកីឡា ការស្រាវជ្រាវលើដំណើរការសកម្មភាពសំខាន់ៗ និងសិក្សាអំពីវិធីសាស្ត្របង្រៀន ល្បិច និងបច្ចេកទេសបង្រៀនថ្មី ដើម្បីណែនាំបន្ថែមដល់គ្រូបង្រៀន លើការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពដោយផ្ដោតទៅលើៈ

១) កំណែទម្រង់ការពង្រឹងគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិ។

២) ដោះស្រាយបញ្ហាប្រឈមនានា ក្នុងការពង្រឹងគុណភាពអប់រំ។

៣) រកដំណោះស្រាយផ្សេងទៀត ក្នុងការពង្រឹងគុណភាពអប់រំ ឱ្យទទួលបានគុណភាព និងប្រសិទ្ធភាពខ្ពស់។

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះ មានលក្ខណៈស៊ីជម្រៅ និងវិភាគបានគ្រប់ជ្រុងជ្រោយគ្របដណ្ដប់តែ ទៅលើការពង្រឹងគុណភាពអប់រំនៅកម្រិតអនុវិទ្យាល័យ ដោយជ្រើសរើសយកអនុវិទ្យាល័យចំនួន៣ នៃស្រុកជលគិរី ស្រុកកំពង់លែង និងស្រុកបរិបូរណ៌ក្នុងខេត្តកំពង់ឆ្នាំង យកមកធ្វើការបកស្រាយ និងវិភាគ។

អាស្រ័យដោយពេលវេលាមានកំណត់ ការសិក្សាស្រាវជ្រាវមិនអាចធ្វើឡើងឱ្យបានគ្រប់អនុវិទ្យាល័យទាំងអស់បានទេ ដូច្នេះ យើងបានជ្រើសរើសអនុវិទ្យាល័យចំនួន ៣ នៅក្នុងខេត្តកំពង់ឆ្នាំង យកមកធ្វើការសិក្សាស្រាវជ្រាវ។ ចំពោះទិន្នន័យដែលមានស្រាប់គឺយកឆ្នាំសិក្សា ២០២១-២០២២ និងឆ្នាំសិក្សា ២០២២-២០២៣។

ការស្រាវជ្រាវនេះ គឺជាប្រភេទស្រាវជ្រាវបែបបរិមាណ ប៉ុន្តែទិន្នន័យបែបគុណភាពក៏ត្រូវបានប្រមូលផងដែរ ដើម្បីជួយពន្យល់ពីបាតុភូតជាច្រើនទៀតឱ្យបានជាក់លាក់។ ហេតុនេះ វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណ និងតាមបែបគុណភាពមួយចំនួន ត្រូវបានប្រើប្រាស់សម្រាប់ទទួលបាននូវប្រភេទព័ត៌មានផ្សេងៗគ្នា។ ទោះជាបែបនេះក៏ដោយការស្រាវជ្រាវតាមបែបបរិមាណមានលក្ខណៈគ្របដណ្តប់ច្រើនលើសលុប ហើយតាមបែបគុណភាព គឺគ្រាន់តែបង្គ្រប់បន្ថែមនូវចំណុចខ្វះខាតមួយចំនួន ដែលទិន្នន័យតាមបែបបរិមាណមិនបានគ្រប់គ្រាន់។

## ២. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការអប់រំក្នុងច្បាប់នេះ សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះ-បណ្តាលកាយ សម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឱ្យអ្នកសិក្សាទទួលបាន សំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍ សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោកវាក្យសព្ទសំខាន់ៗដែលប្រើក្នុង ច្បាប់នេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ។

រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញ និងឯកភាព ដែលរួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ។ ការអប់រំកុមារតូចជាការសិក្សាត្រៀម នៃប្រព័ន្ធអប់រំ។ប្រព័ន្ធអប់រំកម្ពុជា រួមមានការអប់រំសាធារណៈ និងការអប់រំឯកជន។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ខ្លឹមសារស្តីពីប្រព័ន្ធអប់រំក្នុងលិខិតបទដ្ឋានដោយឡែក។ រដ្ឋត្រូវគាំពារនិងអប់រំកុមារតូចចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាននៅសហគមន៍ ឬនៅផ្ទះ។ការអប់រំមត្តេយ្យសិក្សាត្រូវចាប់អនុវត្តមុនបឋមសិក្សាដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា។ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ខ្លឹមសារស្តីពីការគាំពារ និងការអប់រំកុមារតូច។ ការអប់រំចំណេះទូទៅ ជា

ការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹងនិងសីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា កាយ និងធានាឱ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋាន។ ការអប់រំចំណេះទូទៅជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្ដុះបណ្ដាលផ្សេងៗទៀត។ ការអប់រំចំណេះទូទៅរួមមានការអប់រំបឋមសិក្សា ឬភូមិសិក្សាទី ១ ចាប់ពីថ្នាក់ទី ១ (មួយ) ដល់ថ្នាក់ទី៦ (ប្រាំមួយ) នៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬការអប់រំកម្រិតសមមូលការអប់រំបឋមសិក្សា ត្រូវបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេញលេញ លើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានដំបូងចាំបាច់ ដើម្បីឱ្យអ្នកសិក្សាអាចបន្តការសិក្សានៅមធ្យមសិក្សា និងការអប់រំមធ្យមសិក្សា ឬភូមិសិក្សាទី២ ចាប់ពីថ្នាក់ទី៧ (ប្រាំពីរ) ដល់ថ្នាក់ទី ១២ (ដប់ពីរ)។ ការអប់រំមធ្យមសិក្សាមានពីរដំណាក់កាល គឺ ដំណាក់កាលទី១ (មួយ) មធ្យមសិក្សាបឋមភូមិ ចាប់ពីថ្នាក់ទី៧ (ប្រាំពីរ) ដល់ថ្នាក់ទី៩ (ប្រាំបួន) និងដំណាក់កាលទី២ (ពីរ) មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ (ដប់) ដល់ថ្នាក់ទី១២ (ដប់ពីរ)។ ការអប់រំមធ្យមសិក្សា ត្រូវបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅឧត្ដមសិក្សា ឬបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ ឬ ចូលរួមក្នុងជីវភាពសង្គម។ការអប់រំកម្រិតមូលដ្ឋាន ត្រូវកំណត់ ៩ (ប្រាំបួន)ឆ្នាំ ចាប់ពីថ្នាក់ទី ១ (មួយ)ដល់ ថ្នាក់ទី ៩ (ប្រាំបួន)នៃការអប់រំចំណេះទូទៅក្នុងប្រព័ន្ធ ឬ ការអប់រំកម្រិតសមមូល។ការអប់រំឧត្ដមសិក្សា ឬ ភូមិសិក្សាទី ៣ ជាការអប់រំកម្រិតក្រោយមធ្យមសិក្សា នៅគ្រឹះស្ថានឧត្ដមសិក្សា។ ការអប់រំឧត្ដមសិក្សា ត្រូវបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេញលេញ និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម ដើម្បីឱ្យមានសមត្ថភាពខ្ពស់ទាំងចំណេះដឹងជំនាញសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាពសម្រាប់អភិវឌ្ឍប្រទេសជាតិ។ក្របខ័ណ្ឌ និងលក្ខណៈនៃកម្រិតសញ្ញាបត្រ និងវិញ្ញាបនបត្រ ត្រូវកំណត់ដោយ ក្រសួងទទួលបន្ទុកវិស័យអប់រំ។ គ្រឹះស្ថានឧត្ដមសិក្សាមាន ២ (ពីរ) ប្រភេទសាកលវិទ្យាល័យ និងវិទ្យាស្ថាន។ លក្ខណវិនិច្ឆ័

យនៃប្រភេទគ្រឹះស្ថានឧត្តមសិក្សា និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ[៦]។

ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច ៩ (ប្រាំបួន)ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងវិធានការជាជំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់នេះ។ការចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១ (មួយ) នៃកម្មវិធីអប់រំចំណេះទូទៅក្នុងប្រព័ន្ធត្រូវបានកំណត់ចំពោះកុមារ ដែលមានអាយុចាប់ពី៦ (ប្រាំមួយ)ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០ (ចិតសិប)ខែឡើងទៅ នៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន។ រដ្ឋគោរពសិទ្ធិសេរីភាពខាងជំនឿសាសនា។ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ។ គ្រប់ការបង្ខំឱ្យអ្នកសិក្សា និងអ្នកពាក់ព័ន្ធការអប់រំឱ្យចូលរួមក្នុងសកម្មភាពសាសនា និង/ឬ ការប្រតិបត្តិសាសនាណាមួយដែលជាផ្នែកនៃការអប់រំ ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្ដី ត្រូវហាមឃាត់។ការសិក្សាអំពីសាសនានៅក្នុងកម្មវិធីសិក្សា ត្រូវបានអនុញ្ញាតសម្រាប់តែការយល់ដឹងទូទៅប៉ុណ្ណោះ។ ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវគោរពគោលការណ៍អព្យាក្រឹតភាព។ការធ្វើសកម្មភាពនយោបាយ និង/ឬ ការឃោសនានយោបាយឱ្យគណបក្សនយោបាយណាមួយក្នុងស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវហាមឃាត់។ សិទ្ធិរបស់អ្នកសិក្សាទាក់ទងនឹងការអប់រំមានដូចជា សិទ្ធិបញ្ចេញទស្សនៈសិក្សាដោយសេរី សិទ្ធិមានសេរីភាពខាងការសិក្សា សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព សិទ្ធិប្រមូលផ្ដុំជាក្រុមអ្នកសិក្សា ឬក្លិបអ្នកសិក្សាក្នុងគោលបំណងសម្រាប់ការអប់រំ សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រាផ្ទាល់ខ្លួនស្ដីពីការអប់រំ សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់គ្រឹះស្ថានសិក្សា និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន និងសិទ្ធិទទួលបានការគោរព និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សជាពិសេសសិទ្ធិមានសេចក្ដីថ្លៃថ្នូរ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី។ ករណីយកិច្ចរបស់អ្នកសិក្សាត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់

[៦] ព្រះរាជាណាចក្រកម្ពុជាច្បាប់ស្ដីពីការអប់រំឆ្នាំ២០០៧។

គ្រឹះស្ថានសិក្សា តម្លៃខាងសមធម៌យេនឌ័រដោយអនុវត្តសិទ្ធិរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវ និងគោរពសិទ្ធិអ្នកដទៃនិងខិតខំសិក្សាឱ្យអស់ពីលទ្ធភាពរបស់ខ្លួន ដើម្បីទទួលបានការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាព បញ្ញា និងសេចក្តីថ្លៃថ្នូរ[៧]។ សិទ្ធិរបស់មាតាបិតា ឬអ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជន ដែលស្ថិតក្នុងបន្ទុកមានសិទ្ធិក្នុងការជ្រើសរើសកម្មវិធីអប់រំ និងគ្រឹះស្ថានសិក្សាសម្រាប់អ្នកសិក្សាឱ្យចូលសិក្សា សិទ្ធិទទួលបានព័ត៌មាន និងរបាយការណ៍នៃការសិក្សាពីគ្រឹះស្ថានសិក្សារបស់អ្នកសិក្សា ដែលស្ថិតក្នុងបន្ទុកសិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញ នៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់ សាលារៀន និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន។ករណីយកិច្ចមាតាបិតា ឬអ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជនដែលស្ថិតក្នុងបន្ទុកនាំកុមារ ដែលមានអាយុចាប់ពី ៦ (ប្រាំមួយ)ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០ (ចិត សិប)ខែ ឡើងទៅចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១ នៃកម្មវិធីអប់រំចំណេះទូទៅនៅសាលារៀន ដែលមានអាជ្ញាប័ណ្ណអប់រំខិតខំឱ្យអស់លទ្ធភាព ដើម្បីគាំទ្រការសិក្សារបស់អ្នកសិក្សាជាពិសេសចំពោះ ការអប់រំកម្រិតមូលដ្ឋាននិងយកចិត្តទុកដាក់ផ្សារភ្ជាប់សាលា គ្រួសារ និងសហគមន៍ ដើម្បីចូលរួមជួយបណ្តុះបណ្តាល និងកែលម្អបរិស្ថានសិក្សា។សិទ្ធិរបស់បុគ្គលិកអប់រំមានដូចជា សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ខ្ពស់ពីសង្គម សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈ សិទ្ធិបង្កើត ឬចូលរួមក្នុងសមាគមបុគ្គលិកអប់រំ ឬសមាគមវិជ្ជាជីវៈផ្សេងទៀត តាមច្បាប់កំណត់ជាធរមាន សិទ្ធិរៀបចំការប្រជុំលើការងារអប់រំជាសាធារណៈ សិទ្ធិចូលរួមនៅក្នុងកិច្ចការនយោបាយតាមច្បាប់កំណត់ សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន សិទ្ធិទទួលសេវាអប់រំផ្សេងទៀតប្រកបដោយសមធម៌ និងសិទ្ធិផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។ កាតព្វកិច្ចរបស់បុគ្គលិកអប់រំ ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈបំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ជាធរមានអនុវត្ត និងអភិវឌ្ឍការងាររបស់ខ្លួនដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់។ បុគ្គលិកអប់រំឯកជនមានសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតដូចមានចែងក្នុងច្បាប់ស្តីពី ការងារជាធរមាន។រដ្ឋលើកទឹកចិត្ត និងជំរុញឱ្យមានការ

---

[៧]ព្រះរាជាណាចក្រកម្ពុជាច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧។

អប់រំពិសេស សម្រាប់ជនពិការ និងអ្នកសិក្សា ពូកែដែលមានទេពកោសល្យ និង/ឬ បញ្ញាខ្ពស់។ ការអប់រំពិសេស ផ្តល់ចំពោះអ្នកសិក្សាពូកែឱ្យស្របតាមបញ្ញា និងទេពកោសល្យរបស់ អ្នកសិក្សានោះ និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាពិការអាចសិក្សាបានដោយសមរម្យ។ កម្មវិធីអប់រំពិសេស ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ។ អ្នកសិក្សាពិការមានសិទ្ធិដូចអ្នកសិក្សាមិនពិការដែរ និងមានសិទ្ធិពិសេសដោយឡែកផ្សេងទៀត ដូចជាអ្នកសិក្សាពិការទាំងពីរភេទមានសិទ្ធិសិក្សាជាមួយសិស្ស ឬនិស្សិតទូទៅបាន ប្រសិនបើមានការសម្របសម្រួលសមស្របក្នុងដំណើរការសិក្សា ដែលអ្នកសិក្សាពិការនោះ អាចបំពេញកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សានោះបាន និងអ្នកសិក្សាពិការដែលមានសេចក្តីត្រូវការពិសេស មានសិទ្ធិទទួលបានការបង្រៀនបន្ថែមនៅក្នុងកម្មវិធីសិក្សាធម្មតា ដែលមិនមែនតាមកម្មវិធីសិក្សាពិសេសដោយឡែកទេ និងអ្នកសិក្សាពិការដែលមិនមានលទ្ធភាពចូលសិក្សាជាមួយសិស្ស ឬនិស្សិតទូទៅមានសិទ្ធិទទួលបានការអប់រំពិសេសនៅក្នុងថ្នាក់រៀនពិសេសដោយឡែក។ អ្នកសិក្សាពិការទាំងនេះ អាចចូលសិក្សានៅសាលារៀនក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួនបាន។ មាតាបិតា ឬអ្នកអាណាព្យាបាល អ្នកសិក្សា និងបុគ្គលិកអប់រំដែលត្រូវបានគេបំពានសិទ្ធិដូចមានចែងក្នុងច្បាប់នេះមានសិទ្ធិស្នើ ឬតវ៉ាទៅអាជ្ញាធរអប់រំមានសមត្ថកិច្ចតាមឋានានុក្រម ព្រមទាំងសិទ្ធិប្តឹងទៅតុលាការ។ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវចេញលិខិតបទដ្ឋាន ស្តីពីនីតិវិធីនៃការស្នើ ឬការតវ៉ា និងនីតិវិធីនៃដំណោះស្រាយនេះ។ អ្នកសិក្សានិងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សា ដែលមានអាជ្ញាប័ណ្ណអប់រំមានសិទ្ធិទទួលបាននូវការពិនិត្យសុខភាព។ គោល-ការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យសុខភាពនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួងទទួលបន្ទុកវិស័យសុខាភិបាល។គ្រប់ខ្លឹមសារផ្សព្វផ្សាយឃោសនា ព័ត៌មានអប់រំ ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យអប់រំ។ គ្រប់ការបន្លំបោកប្រាស់ទោះជាតាមរូបភាពណាក៏ដោយ ត្រូវហាមឃាត់។ ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីការផ្សព្វផ្សាយ ឃោសនាព័ត៌មានអប់រំនេះ។ ព័ត៌មានអប់រំនៃគ្រប់ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សាជាព័ត៌មានសាធារណៈ លើកលែងតែព័ត៌មាននោះទាក់ទងរូបវន្តបុគ្គល។ ស្ថាប័នអប់រំ គ្រឹះស្ថាន

សិក្សា ត្រូវផ្តល់ព័ត៌មានអប់រំដែលមាន ឱ្យទៅអ្នកដែលមានផលប្រយោជន៍តាមការស្នើសុំ។ បែបបទស្តីពីការផ្តល់ព័ត៌មានអប់រំ ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ។

គំនិតរួមនៃការអប់រំមានបីចំណុចសំខាន់ៗ៖ (១) តួនាទីអប់រំរបស់ក្រុមគ្រួសារ ជាពិសេសម្តាយ (២) ការគោរព និងតាមដានការអភិវឌ្ឍធម្មជាតិរបស់កុមារ និង(៣)ការកែប្រែជាថ្មីរបស់សាលារៀន និងគោលដៅរបស់សាលារៀន។ ការអប់រំប្រកបដោយគុណភាព គឺជាសេចក្តីត្រូវការរបស់មនុស្ស ការត្រៀមខ្លួនសម្រាប់ចូលប្រឡូកក្នុងពិភពការងារ និងការចូលរួមវិភាគទានក្នុងវឌ្ឍនភាពសង្គម Chilty, Understanding Schools and Schooling, London: Routlege Falmer។ ប្រការនេះបញ្ជាក់ពីតួនាទីរបស់វិស័យអប់រំ ជាពិសេសធនធានមនុស្សក្នុងដំណើរការអភិវឌ្ឍ ពោលគឺការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងប្រទេសជាតិ មូលធនបញ្ញាជំរុញសេដ្ឋកិច្ច ចំណេះដឹង ដូច្នេះអ្នកដែលមានវាច្រើននឹងទទួលបានចំណិតខ្លាញ់... ការអប់រំសំខាន់ជាងអ្វីដែលធ្លាប់មាន ពីព្រោះតម្រូវការកម្លាំងខួរក្បាលបានកើនឡើង[៨]។

## ៣. លទ្ធផល និងពិភាក្សា (Result and Discuss)

### ៣.១. លទ្ធផល (Result)

គោលបំណងនៃការអប់រំ ជានាការអប់រំពលរដ្ឋឱ្យមានលក្ខណសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែកដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

### ៣.២. រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ការពិភាក្សា វាត្រូវបានបែងចែកជាបញ្ហាប្រឈម និងវិធីដោះស្រាយ ដែលត្រូវធ្វើការបំបែក ដូចខាងក្រោម ៖

#### ៣.២.១

បញ្ហាប្រឈមមួយចំនួននៅតែមានដែលបង្អាក់លទ្ធភាពទទួលបានការអប់រំពិសេស ជាពិសេសក្រុមដែលជួបការលំបាក ដូចជាសិស្សមានពិការភាព និងក្រុមជនជាតិដើមភាគតិច

---

[៨] Chilty. 2002

ជាដើម។ បញ្ហាមធ្យោបាយធ្វើដំណើរគឺជាបញ្ហាទូទៅបំផុតមួយសម្រាប់សិស្សានុសិស្សនៅតំបន់ដាច់ស្រយាល។ បញ្ហានេះរួមចំណែកនិងត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្រាបោះបង់ការសិក្សាកម្រិតមធ្យមសិក្សាខ្ពស់។ សិស្សានុសិស្សជាច្រើនដែលរស់នៅជនបទតែងតែបោះបង់ការសិក្សានៅអនុវិទ្យាល័យ ដោយសារការធ្វើដំណើរឆ្ងាយពីផ្ទះទៅសាលារៀន។ បញ្ហាមួយទៀតដែលប៉ះពាល់ដល់លទ្ធភាពទទួលបានការអប់រំ គឺបញ្ហាភាសា។ កុមារមកពីជនជាតិភាគតិចពិបាករៀន ព្រោះពួកគេប្រហែលជាមិនចេះភាសាខ្មែរ។ សាលា និងកម្មវិធីសិក្សានៅកម្ពុជាភាគច្រើនមិនមានបង្រៀនជាភាសាផ្សេងៗនោះទេ ដូចជាភាសាកំណើតរបស់ជនជាតិភាគតិចជាដើម។ នេះបានផ្តល់នូវការលំបាកដល់សិស្សជនជាតិភាគតិច ដែលនៅទីបំផុតពួកគេនឹងត្រូវបង្ខំចិត្តបោះបង់ចោលការសិក្សា។

បញ្ហាប្រឈមផ្សេងទៀតចំពោះវិស័យអប់រំនៅកម្ពុជា គឺវិសមភាពនៃការអប់រំ និងសមត្ថភាពគ្រូបង្រៀន។ សកម្មភាពសំខាន់មួយដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវដោះស្រាយ គឺគម្លាតរវាងគ្រឹះស្ថានអប់រំនៅតាមជនបទ និងទីក្រុង។ សាលារៀននៅតាមទីក្រុងផ្តល់នូវគុណភាពអប់រំ និងហេដ្ឋារចនាសម្ព័ន្ធខ្ពស់ជាងសាលារៀននៅតាមជនបទ និងតំបន់ដាច់ស្រយាល។ ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ គម្លាតនេះកាន់តែខិតឆ្ងាយ។ យោងតាមការស្ទង់មតិ បញ្ហាទូទៅមានដូចជាការដាច់អ៊ីនធឺណិត និងអគ្គិសនី ការលំបាកក្នុងការវាយតម្លៃសិស្ស កង្វះទំនាក់ទំនង សុវត្ថិភាពអនឡាញ និងបញ្ហាអំពីឧបសគ្គឯកជនភាព និងភាសា។ បញ្ហាប្រឈមនៃការរៀនពីចម្ងាយបង្ហាញពីចន្លោះប្រហោងដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវបំពេញជាពិសេសផ្នែកបច្ចេកវិទ្យា និងការត្រៀមខ្លួនឌីជីថល។ របាយការណ៍រកឃើញបានផ្តល់អនុសាសន៍ឱ្យបញ្ចូលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ការអប់រំឌីជីថលរបស់កម្ពុជាផងដែរ។

**៣.២.២**

ដើម្បីដោះស្រាយផលវិជ្ជមានដូចបានរកឃើញតាមរយៈការស្រាវជ្រាវនេះ ដែលបានលើកឡើងពីខាងលើ គេសង្កេតឃើញមានការធ្វើកំណែទម្រង់សំខាន់ៗចំនួនបួនគឺ កំណែទម្រង់វិស័យអប់រំតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កំណែទម្រង់វិស័យអប់រំ

តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ កំណែទម្រង់វិស័យអប់រំក្នុងក្របខ័ណ្ឌសសរស្តម្ភទាំង៥ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំ។

# ៤. សន្និដ្ឋាន និងអនុសាសន៍ ( Conclusion and Recommendations )

## ៤.១. សន្និដ្ឋាន

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា ប្រព័ន្ធអប់រំនៅកម្ពុជាយើងទោះបីមិនទាន់អនុវត្តត្រឹមត្រូវទៅតាមនិយាម ឬបទដ្ឋានសិក្សារបស់ស្ថាប័នទទួលបន្ទុកខាងអប់រំបានគ្រប់ជ្រុងជ្រោយក៏ដោយ វិស័យអប់រំបច្ចុប្បន្នទទួលបានជោគជ័យនិងបន្សល់ឱ្យឃើញនូវសមិទ្ធិល្អៗច្រើន នៅក្នុងសង្គមគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងប្រព័ន្ធអប់រំនាសម័យមុនៗ ឬធៀបទៅនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងតំបន់ ឬលើពិភពលោក។ បណ្តាសមិទ្ធផលទាំងនោះ មានជាអាទិ៍ ការធ្វើឱ្យមានភាពរឹងមាំលើការមធ្យមសិក្សាបឋមភូមិ ដោយបានធ្វើឱ្យមានបម្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធ សេដ្ឋកិច្ច និងតម្រូវការទីផ្សារការងារ ជាមួយគ្នានឹងតម្រូវការសម្រាប់សមាហរណកម្មតំបន់ និងសកលលោក តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំទាំងឡាយរបស់ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចផ្លែផ្កាលើវិស័យនេះយ៉ាងត្រចះត្រចង់ ដូចជាបង្កើនបាននូវការចូលរៀនប្រកបដោយសមធម៌នៅគ្រប់កម្រិត ជាពិសេសការអប់រំមធ្យមសិក្សាបឋមភូមិរយៈពេល ៣ឆ្នាំជាដើមនោះ គឺបានការបង្កលក្ខណសម្បត្តិអនុគ្រោះជាច្រើនដល់កុមារ និងយុវជនដែលជួបការលំបាក ឱ្យកាន់តែមានលទ្ធភាព ចូលសិក្សាបានច្រើននៅគ្រប់កម្រិតបើធៀបនឹងដំណាក់កាលមុនៗ។ ការពង្រឹងនិងពង្រីកអភិបាលកិច្ច នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការពង្រឹងគុណភាពអប់រំ តាមរយៈការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតក្រីក្រ ការអនុវត្តវិធានការលើកកម្ពស់គុណភាព ភាពឆ្លើយតបរបស់សេវាអប់រំគ្រប់ប្រភេទ បានក្លាយជាចំណុចគន្លឹះឈានដល់ការកំណត់អាទិភាពក្នុងកម្មវិធីកំណែទម្រង់ផ្សេងទៀត ដូចជាការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការធ្វើវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការពិនិត្យឡើងវិញកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល ការផ្តល់ជំនាញបច្ចេកទេសនិងជំនាញទន់ ការផ្តល់ព័ត៌មានទីផ្សារការងារ ការប្រឹក្សាអាជីព និងការតម្រង់ទិសសិក្សាជាដើម បានធ្វើឱ្យវិស័យអប់រំក្លាយទៅជាវិស័យឈានមុខមួយ ដែលរាជរដ្ឋាភិបាលបានកំណត់ក្នុងគោលដៅ

អាទិភាពនៅក្នុងរបៀបវារៈការងាររបស់ខ្លួនទាំងរាជរដ្ឋាភិបាលអាណត្តិទី៣ អាណត្តិទី៤ អាណត្តិទី៥ និងអាណត្តិទី៦នៃនីតិកាលរដ្ឋសភា ដូចដែលបានឃើញនៅក្នុងយុទ្ធសាស្ត្រចតុកោណ តាំងពីដំណាក់កាលទី១រហូតដល់យុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ បច្ចុប្បន្ននេះស្រាប់ហើយប្រការដែលគួរឱ្យកត់សម្គាល់បំផុតនោះ គឺនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលបានចាត់ទុកការ អភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ទៀតផង ហើយជាលទ្ធផលក្នុងការអនុវត្ត ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចដោយជោគជ័យនូវមុំទី១ ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" តាមរយៈការកំណត់អាទិភាពការងាររបស់ខ្លួន លើការយកចិត្តទុកដាក់លើគ្រូបង្រៀន ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាបឋមភូមិ ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ និងការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ ព្រមទាំងការដាក់ចេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពី ការអប់រំដោយឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត និងទាំងអស់គ្នានោះបានញ៉ាំងឱ្យប្រព័ន្ធសិក្សាអប់រំរបស់កម្ពុជាកាន់តែមានភាពរឹងមាំពីមួយដំណាក់កាលទៅមួយដំណាក់កាលហើយដែលតឹកតាងនេះបង្ហាញ ឱ្យឃើញតាមរយៈផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០០៩-២០១៣ ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៤-២០១៨ កន្លងមក និងផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣ ដែលកំពុងតែអនុវត្តនាបច្ចុប្បន្នកាលនេះ ហើយដែលតាមរយៈផែនការយុទ្ធសាស្ត្រទាំងនេះ គឺបានកាត់បន្ថយនូវគម្លាតជំនាញ ដោយសហការជាមួយអ្នកពាក់ព័ន្ធក្នុងការបង្កើនការផ្គត់ផ្គង់ជំនាញ ដែលមានតម្រូវការខ្ពស់ក្នុងវិស័យអាទិភាពមួយចំនួនក៏ដូចជាការដាក់ចេញនូវការអប់រំតាមបែបឌីជីថល ដើម្បីឆ្លើយតបនឹងគោលនយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា ដែលកំពុងតែឈានចូលមកដល់ក្នុងសម័យបច្ចុប្បន្ននេះដែរ។

ទន្ទឹមនឹងសមិទ្ធផលដ៏ប្រសើរគួរឱ្យមោទនភាព ក៏មានបញ្ហាប្រឈមមួយចំនួនដែលចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយ មានដូចជា នៅក្នុងការអប់រំកម្រិតចំណេះទូទៅ គុណភាពសិក្សានៅកម្ពុជានៅមានកម្រិត កង្វះខាតបរិក្ខារសិក្សា គុណភាពគ្រូ

បង្រៀននៅមិនទាន់ឆ្លើយតបបាន តាមស្តង់ដាសិស្សដែលរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សានៅមានកម្រិតខ្ពស់ ការអនុវត្តប្រព័ន្ធ ធានាគុណភាពនៅពុំទាន់បានពេញលេញ ការពង្រីកការអប់រំយុវជន និងការជំរុញការចូលរៀននៅ ក្នុងកម្មវិធីអប់រំយុវជនឱ្យបានត្រឹមត្រូវតាមអាយុ នៅមិនទាន់ទទួលបានប្រសិទ្ធភាពល្អតាមការចង់បាន។

### ៤.២. អនុសាសន៍

ការពង្រឹងគុណភាពសិស្សនៅតំបន់ជនបទ គួរតែស្ថាប័នពាក់ព័ន្ធទាំងអស់សហការ និងរួបរួមគ្នាឱ្យបានស្មើដៃគ្នា និងព្រមៗគ្នា អនុវត្តនូវភារកិច្ចប្រកបដោយមនសិការ និងការទទួលខុសត្រូវខ្ពស់ ដែលស្ថាប័នទាំងនោះ មានអាជ្ញាធរអប់រំ ឬអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋាន សហគមន៍ គ្រួសារ នាយកសាលា និងគ្រូបង្រៀន ព្រមទាំងសិស្សខ្លួនឯងផងដែរ។

**ដើម្បីរួមចំណែកលើកកម្ពស់គុណភាព និងប្រសិទ្ធភាព យើងគប្បីគួរពិចារណាដូចខាងក្រោម៖**

- អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ (ស្ថាប័នអប់រំ) ត្រូវគ្រប់គ្រងនូវដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានល្អ ផ្តល់នូវការគាំទ្រទាំងសម្ភារៈរៀន និងត្រូវឱ្យមានការលើកទឹកចិត្តដល់គ្រូបង្រៀនដើម្បីធ្វើយ៉ាងណាឱ្យគ្រូគោរពនូវសីលធម៌វិជ្ជាជីវៈបានល្អ ព្រមទាំងបញ្ចេញឱ្យអស់សមត្ថភាពក្នុងការបង្ហាត់បង្រៀនសិស្ស។ លើសពីនេះទៀត ត្រូវខិតខំធ្វើយ៉ាងណាដើម្បីជួយលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់គ្រូបង្រៀនឱ្យបានសមរម្យ និងត្រូវជួយការពារសន្តិសុខសណ្តាប់ធ្នាប់សង្គមនៅក្នុងសហគមន៍ឱ្យបានល្អ ដោយទប់ស្កាត់ឱ្យបាននូវភាពអសកម្មដូចជាបងធំ បងតូចជាដើម។
- សហគមន៍មូលដ្ឋាន ត្រូវរួមសាមគ្គីគ្នាដើម្បីឧបត្ថម្ភនូវ កង្វះខាតរបស់គ្រួសារក្រីក្រដើម្បីជំរុញ និងលើកទឹកចិត្តឱ្យកូនៗរបស់គេបានទៅសិក្សា។
- នាយកសាលា ត្រូវយកចិត្តទុកដាក់គ្រប់គ្រង និងដោះស្រាយរាល់បញ្ហាក្នុងសាលាឱ្យបានល្អ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ត្រូវគ្រប់គ្រងការបង្រៀនរបស់គ្រូ និងការរៀនឱ្យបានជាប្រចាំ។ បង្កើតឱ្យមានការចូលរួមប្រជុំ ជាប្រចាំខែ ឬប្រចាំត្រីមាស រវាងគ្រូ

បង្រៀន តំណាងសហគមន៍ និងតំណាងមាតាបិតាសិស្ស ដើម្បីស្វែងយល់គ្នាទៅវិញទៅមកពីតម្រូវការ និងវិធីដោះស្រាយ។

- គ្រូបង្រៀនគួរបន្តយកចិត្តទុកដាក់លើការគ្រប់គ្រង ថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ធ្វើឱ្យសិស្ស មានសកម្មភាពរស់រវើកក្នុងពេលរៀន សម្របសម្រួលការរៀនរបស់សិស្សទៅតាមសមត្ថភាព (សិស្ស ពូកែ សិស្សមធ្យម សិស្សរៀនយឺត) និងត្រូវប្រកាន់ខ្ជាប់នូវសីលធម៌វិជ្ជាជីវៈ និងការស្រាវជ្រាវបន្ថែមដើម្បីបង្កើនគុណភាពនៃការបង្រៀនឱ្យបានកាន់តែល្អ។

- មាតាបិតា គួរបង្កើនទំនាក់ទំនងល្អជាមួយគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ដើម្បីទទួលបានអំពីព័ត៌មាននៃលទ្ធផលសិក្សារបស់កូន និងសីលធម៌ព្រមទាំងអាកប្បកិរិយារបស់កូននៅសាលារៀន។ហើយក៏ត្រូវតែចូលរួមលើកទឹកចិត្តកូនៗឱ្យទៅសាលារៀន ឱ្យមានចិត្តព្យាយាមតស៊ូក្នុងការរៀនសូត្រនិងត្រូវបើកគំនិតឱ្យទំលាយ និងត្រូវចេះឱ្យតម្លៃទៅលើការសិក្សារបស់កូនៗរបស់ខ្លួន។

- សិស្សខ្លួនឯងត្រូវខិតខំព្យាយាម ដើម្បីសម្រេចបាននូវគោលដៅនៃការសិក្សារបស់ខ្លួនឱ្យបានល្អ ហើយត្រូវមានសង្ឃឹមជានិច្ចចំពោះអនាគតរបស់ខ្លួន តាមរយៈការបន្តការសិក្សាឱ្យបានដល់កម្រិតឧត្តមសិក្សា។ ត្រូវយល់ថា មានតែការសិក្សាទេ ដែលធ្វើឱ្យជីវភាពរបស់ខ្លួន និងគ្រួសាររបស់ខ្លួនបានប្រសើរឡើង។

- ជាមួយគ្នានេះដែរគួរបន្ថែមការយកចិត្តទុកដាក់លើសេវាកម្មបង្រៀន សេវាអប់រំប្រកបដោយគុណភាព និងត្រូវយកចិត្តទុកដាក់អនុវត្តយន្តការធានាគុណភាពទាំងផ្ទៃក្នុង ទាំងការវាយតម្លៃខាងក្រៅ ជាពិសេសសម្រិតសម្រាំងលើធនធានមនុស្សដែលបម្រើការក្នុងវិស័យនេះ និងយកចិត្តទុកដាក់ផ្សារភ្ជាប់ខ្លួននឹងយន្តការនៃការបណ្តុះបណ្តាលធនធានមនុស្សដោយខ្លួនឯង។

- គួរគិតគូរអំពីការបណ្តុះបណ្តាលគ្រូ ឬ អភិវឌ្ឍសមត្ថភាពគ្រូជាប្រចាំ ដើម្បីរក្សាបាននូវគ្រូដែលមានគុណវុឌ្ឍិ ហើយគ្រូថ្មីត្រូវស្វែងយល់បន្ថែមនូវគរុកោសល្យ នេះជាផ្នែកមួយនៃការលើកកម្ពស់តាមរយៈការរៀន និងបង្រៀន ជួយលើកទឹកចិត្តគ្រូដែលមានគុណវុឌ្ឍិខ្ពស់ឱ្យខិតខំធ្វើការស្រាវជ្រាវដើម្បីបង្កើនពុទ្ធិថ្មី ចំណេះដឹង ឬទ្រឹស្តីថ្មីៗដែលអាចទាន់ការវិវត្តរបស់វិទ្យាសាស្រ្ត ក៏ដូចជាជួយពង្រឹងដល់ការបង្រៀនរបស់ពួកគាត់ និងជួយលើកទឹកចិត្ត

ដល់ការស្រាវជ្រាវនានា ការបង្កើតថ្មី ការច្នៃប្រឌិតថ្មី ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ពង្រឹងឱ្យបានលើការរៀបចំគោលនយោបាយ ផែនការសកម្មភាព ឬផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តប្រចាំឆ្នាំផ្ទាល់ខ្លួនដោយខ្លួនឯង និងសមធម៌ ដើម្បីជួយសម្រួលនូវភាពលំបាក មួយចំនួនរបស់និស្សិតក្រីក្រ និងលើកកម្ពស់ខាងផ្នែកយេនឌ័រ តាមរយៈការសម្រួលការសិក្សា នៅឧត្តមសិក្សា ដូចជា ការសាងសង់បន្ថែមនូវអន្តេវាសិកដ្ឋានសម្រាប់និស្សិតជាដើម។

- គួរតែធ្វើការកែទម្រង់ឱ្យបានល្អក្នុងការរៀបចំកម្មវិធីសិក្សា ឱ្យបានឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍មូលដ្ឋានផង និងតម្រូវការរបស់សង្គមផង។ លើសពីនេះទៀត ក្រសួងគួរមានកម្មវិធីលើកទឹកចិត្តដល់គ្រូបង្រៀនដែលមានស្នាដៃល្អក្នុងការងារ មានការគោរពនូវក្រមសីលធម៌វិជ្ជាជីវៈបានល្អជាដើម។ គួរឱ្យមានស្ថាប័នឯករាជ្យមួយដែលមានជំនាញក្នុងការពិនិត្យតាមដាននិងវាយតម្លៃការបង្រៀន និងក្រមសីលធម៌របស់គ្រូបង្រៀន។ ជាមួយគ្នានេះដែរ ក្រសួងក៏ត្រូវរៀបចំឱ្យមានការលើកទឹកចិត្តដល់នាយកសាលាដែលមានស្នាដៃ និងលើកទឹកចិត្តដល់សិស្សដែលរៀនពូកែ និងមានសីលធម៌រស់នៅល្អ។ ការលើកទឹកចិត្តទាំងអស់ គឺគួរធ្វើតាមរយៈផ្តល់ជាថវិកា ឬជាសម្ភារៈ ព្រោះបច្ចុប្បន្ននេះ តម្រូវការចាំបាច់សម្រាប់ប្រជាជនកម្ពុជា គឺថវិកា និងសម្ភារៈ។ ការផ្តល់ការលើកទឹកចិត្តនេះត្រូវធ្វើឡើងប្រកបដោយតម្លាភាព និងភាពយុត្តិធម៌ បើពុំដូច្នោះទេការលើកទឹកចិត្តនឹងមិនមានប្រយោជន៍សម្រាប់ការប្រកួតប្រជែងដោយស្មោះត្រង់នោះឡើយ។

# ការទប់ស្កាត់បទល្មើសគ្រឿងញៀននៅកម្ពុជា

*បេក្ខជនបណ្ឌិត **សោម សុជាតិ***

## មូលន័យសង្ខេប

ក្នុងទសវត្សរ៍ចុងក្រោយនេះ កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព និងវឌ្ឍនភាពគួរឱ្យគោរពក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសុខភាព និងក្នុងការពង្រឹងក្របខ័ណ្ឌ នីតិប្បញ្ញត្តិរបស់ខ្លួន។ កំណើនសេដ្ឋកិច្ច និងសមាហរណកម្មសេដ្ឋកិច្ចកាន់តែធំជាមួយប្រទេសជិតខាងនៃមហាអនុតំបន់ទន្លេមេគង្គ បាននាំមកនូវការអភិវឌ្ឍជាវិជ្ជមានដល់ប្រទេសកម្ពុជា ពោលគឺការបង្កើនភាពចល័តនៃទំនិញ សេវាកម្ម មនុស្ស និងប្រាក់ លទ្ធភាពទទួលបានចំណេះដឹង និងទំនាក់ទំនង។ កំណើនសេដ្ឋកិច្ចក៏បានពង្រីកនូវវិសមភាពនៃទ្រព្យសម្បត្តិ និងនាំមកនូវឱកាសសម្រាប់ឧក្រិដ្ឋជនពង្រីកឧក្រិដ្ឋកម្ម ឆ្លងដែនផងដែរ។

គ្រឿងញៀន ហើយចំនួនអ្នកប្រើប្រាស់គ្រឿងញៀន ខុសច្បាប់ ជាពិសេសថ្នាំរំញោចសតិប្រភេទអំហ្វេប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាតំបន់មួយនៃប្រភពឆ្លងកាត់ និងតំបន់ គោលដៅសម្រាប់ការជួញដូរមនុស្ស ហើយក៏ជាប្រភពនៃហេរ៉ូអ៊ីនធំជាងគេទីពីររបស់ពិភពលោក និងជាមជ្ឈមណ្ឌលសំខាន់សម្រាប់ផលិត និងជួញដូរសារធាតុរំញោចសតិប្រភេទអាំហ្វេតាមីន (amphetamine type stimulants )។ តំបន់នេះក៏ទទួលរងនូវការទាញយកធនធានធម្មជាតិខុសច្បាប់ រួមទាំងការទិញ និងការនាំចេញដោយខុសច្បាប់នូវប្រភេទសត្វ និងឈើដែលជិតផុតពូជ។ សកម្មភាពខុសច្បាប់នេះបានជះឥទ្ធិពលដល់ព្រះរាជាណាចក្រកម្ពុជា ដោយកម្ពុជាបានក្លាយជា ប្រទេសឆ្លងកាត់ដ៏សំខាន់មួយសម្រាប់ការជួញដូរតាមីន (ATS) បានកើនឡើងយ៉ាងខ្លាំង។

ដើម្បីទប់ទល់បញ្ហាទាំងនេះ កម្ពុជាបានស្វែងរកដំណោះស្រាយនានា ដោយត្រូវបានដាក់ចេញនូវនីតិកម្មនានាដើម្បីទប់ស្កាត់សកម្មភាពមួយចំនួនដូចជា ទប់ស្កាត់ការជួញដូរ និងការរត់ពន្ធថ្នាំញៀន ខុសច្បាប់ ដើម្បីឆ្លើយតបក្នុងការពង្រឹងការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាន

ដែលពេលមុនមានសមត្ថភាពអនុវត្តច្បាប់ទន់ខ្សោយ និងមិនសូវមានកិច្ចសហប្រតិបត្តិការល្អក្នុងរុករក និងបំផ្លាញថ្នាំញៀន។ ក្នុងការងារអភិបាលកិច្ច កម្ពុជាបានខិតខំប្រឹងប្រែង ក្នុងការប្រើប្រាស់អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (United Nations Convention against Corruption) ដែលបានផ្តល់សច្ចាប័ន ដើម្បីធ្វើជាឧបករណ៍វិភាគ។ ការងារនេះរួមមានការគាំទ្រដល់ការកំណត់អត្តសញ្ញាណអំពើពុករលួយ ការបង្កក និងការធ្វើមាតុភូមិនិវត្តន៍នៃទ្រព្យសម្បត្តិដែលត្រូវបានលួច និងការប្រយុទ្ធប្រឆាំងនឹងការលាង លុយកខ្វក់។ រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុម័ត និងអនុវត្តនូវអនុសញ្ញាអន្តរជាតិ និងពង្រឹងប្រព័ន្ធយុត្តិធម៌ និងការអនុវត្តច្បាប់របស់កម្ពុជា ជាពិសេស គឺដើម្បីដោះស្រាយបញ្ហាឧក្រិដ្ឋកម្មថ្នាំញៀនឆ្លងដែន។

ក្រៅពីការបង្ក្រាបថ្នាំញៀន ការកាត់បន្ថយតម្រូវការគ្រឿងញៀន ក៏ជាគោលដៅអាទិភាពមួយទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាបង្កើតជាជម្រើស នៃការព្យាបាលដោយផ្អែកលើភស្តុតាងសម្រាប់ដោះស្រាយ បញ្ហាដែលទាក់ទងនឹងគ្រឿងញៀន។ ការកាត់បន្ថយតម្រូវការគ្រឿងញៀនទាំងនេះ រួមមានការបង្ការ ការព្យាបាលគ្រឿងញៀនតាមសហគមន៍ ការស្តារនីតិសម្បទា និងការប្រឹក្សាផ្តល់យោបល់ព្រមទាំងការធ្វើសមាហរណកម្មអ្នកញៀនថ្នាំទៅក្នុងសង្គមឡើងវិញ។

ប្រធានបទការទប់ស្កាត់បទល្មើសគ្រឿងញៀននៅកម្ពុជានេះ មានគោលដៅចង់ចូលរួមចំណែក ពង្រីកការយល់ដឹងលើការអនុវត្តគោលនយោបាយគ្រប់គ្រងគ្រឿងញៀនដែលមានស្រាប់ទាក់ទងនឹងការកាត់បន្ថយគ្រោះថ្នាក់ដោយគ្រឿងញៀននៅកម្ពុជា ក៏ដូចជាបង្ហាញពីបញ្ហាប្រឈម នានាចំពោះមុខនិងឱកាសដើម្បីកែលម្អ ដើម្បីកាត់បន្ថយប៉ះពាល់ដល់សុខភាព និងកាត់បន្ថយ ផលប៉ះពាល់សេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់គ្រឿងញៀន។ បន្ទាប់ពីការវិភាគលើបញ្ហាដែលពាក់ព័ន្ធនឹងការប្រើគ្រឿងញៀន គោលនយោបាយគ្រប់គ្រងគ្រឿងញៀន និងការអនុវត្តជាក់ស្តែងលើគោលនយោបាយ ការស្រាវជ្រាវនេះ បានកំណត់នូវតម្រូវការច្បាស់លាស់មួយក្នុងការ សម្របសម្រួលការអនុវត្ត នូវគោលនយោបាយគ្រប់គ្រងលើការប្រើប្រាស់គ្រឿងញៀន និងការកាត់បន្ថយនូវគ្រោះថ្នាក់ពីថ្នាំញៀន ដើម្បីសុខភាព និងផលប្រយោជន៍សេដ្ឋកិច្ចសង្គមដែលទាំងអស់គ្នា អាចទទួល

បានជាអតិបរមា ទាំងបុគ្គលដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀនផង និងទាំងសង្គមទាំងមូលផង។

## ១. សេចក្ដីផ្ដើម

### ១.១. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីទទួលបានជាសមិទ្ធិផល តាមរយៈនៃការសិក្សាស្រាវជ្រាវ ជាពិសេសទទួលបាននូវចំណេះដឹង បទពិសោធន៍ និងការងារជំនាញលើការអនុវត្តន៍ប្រធានបទស្ដីពី **«ការទប់ស្កាត់បទល្មើសគ្រឿងញៀននៅកម្ពុជា»** ដែលបានលើកមកធ្វើការសិក្សាស្រាវជ្រាវ ដោយផ្ដោតលើសំណួរស្រាវជ្រាវចំនួនបីដូចខាងក្រោម៖

១. តើការគ្រប់គ្រងប្រតិបត្តិការបង្ក្រាបបទល្មើស កងកម្លាំងនគរបាលជាតិ ប្រព្រឹត្តិទៅយ៉ាងដូចម្ដេចខ្លះ?

២. តើការគ្រប់គ្រងប្រតិបត្តិការបង្ក្រាបបទល្មើស កងកងកម្លាំងនគរបាលជាតិ មានវឌ្ឍនភាពបែបណា?

៣. តើការគ្រប់គ្រងប្រតិបត្តិការបង្ក្រាបបទល្មើស កងកងកម្លាំងនគរបាលជាតិ ជួបបញ្ហាប្រឈម និងត្រូវមានដំណោះស្រាយបែបណា ឬមានទស្សនាទានយ៉ាងដូចម្ដេច ដើម្បីចូលរួមដោះស្រាយនូវបញ្ហាទាំងនោះឱ្យកាន់តែប្រសើរឡើង?

### ១.២. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាក់ទងប្រធានបទខាងលើ ការសិក្សាមានគោលបំណង៖

១. រកឱ្យឃើញពីការរៀបចំការងារគ្រប់គ្រងប្រតិបត្តិការបង្ក្រាបបទល្មើស នៅស្នងការដ្ឋាននគរបាលរាជធានី-ខេត្តដោយពឹងផ្អែកទៅលើ៖ រចនាសម្ព័ន្ធគ្រប់គ្រង គុណវុឌ្ឍិមេស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សមាសភាពថ្នាក់ដឹកនាំស្នងការដ្ឋាននគរបាលរាជធានី-ខេត្តតាមឋានានុក្រមទទួលបន្ទុកការងារជំនាញ និងអភិបាលកិច្ច ដើម្បីធានាឱ្យការគ្រប់គ្រងប្រតិបត្តិការបង្ក្រាបបទល្មើស នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសប្រកបដោយប្រសិទ្ធភាពខ្ពស់ ទទួលបានលទ្ធផលល្អប្រសើរ និងជោគជ័យ លើការទទួលខុសត្រូវជូនថ្នាក់ដឹកនាំតាមឋានានុក្រម ប្រមុខរាជរដ្ឋាភិបាល និងជូនប្រជាពលរដ្ឋទាំងមូល។

២. សិក្សាវាយតម្លៃពីវឌ្ឍនភាពនៅស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដូចជា៖ ការអនុវត្តនូវតួនាទីភារកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ សារាចរណែនាំ ទិសស្លោក បទបញ្ជាផ្ទៃក្នុង ផែនការសកម្មភាពការងារ ផែនការប្រតិបត្តិការផ្សេងៗ ការគ្រប់គ្រងប្រតិបត្តិការបង្រ្កាបបទល្មើសនៅតាមបណ្តាស្នងការដ្ឋានការិយាល័យជំនាញពាក់ព័ន្ធ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងការគ្រប់គ្រងប្រតិបត្តិការបង្រ្កាបបទល្មើសរបស់ជំនាញខ្សែរយៈថ្នាក់ក្រោម នៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលមានកិច្ចការដូចជា៖ កិច្ចការស្រាវជ្រាវព័ត៌មានសន្តិសុខ កិច្ចការស្រាវជ្រាវ និងបង្រ្កាបបទល្មើស កិច្ចការផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន កិច្ចការស្នងការដ្ឋាននគរបាលរាជធានី-ខេត្តចល័ត និងអន្តរាគមន៍។

៣. រកឱ្យឃើញនូវបញ្ហាប្រឈមនានា និងមធ្យោបាយដែលត្រូវដោះស្រាយចំពោះបញ្ជាការដ្ឋាន កងកម្លាំងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តនិងតាមបណ្តាបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត ដែលបានជួបប្រទះនាពេលកន្លងមក ក្នុងនោះមានសមាសធាតុសំខាន់ៗមួយចំនួននៃការគ្រប់គ្រងប្រតិបត្តិការបង្រ្កាបបទល្មើស ដូចជា៖ ការងារស្រាវជ្រាវព័ត៌មានសន្តិសុខ ការងារស្រាវជ្រាវ និងបង្រ្កាបបទល្មើស ការងារផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន (កិច្ចការកងរាជអាវុធហត្ថចល័ត និងអន្តរាគមន៍) ដែលការមិនយកចិត្តទុកដាក់ពីការគ្រប់គ្រងប្រតិបត្តិការទាំងនេះវាបានបង្កឱ្យមាន៖ បទល្មើសជាច្រើនកើតឡើង អសន្តិសុខ អនាធិបតេយ្យក្នុងសង្គមការរាំងស្ទះដល់ការអភិវឌ្ឍនៃអង្គភាព និងសង្គមជាតិ ធ្វើឱ្យបាត់បង់ធនធានមនុស្សបម្រើឱ្យការគ្រប់គ្រងប្រតិបត្តិការបង្រ្កាបបទល្មើស ជូនស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អគ្គស្នងការដ្ឋាននគរបាលជាតិ រដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃ និងប្រមុខដឹកនាំរាជរដ្ឋាភិបាលផងដែរ។

## ២. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ២.១. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យយកមកប្រើប្រាស់លើការស្រាវជ្រាវ ដើម្បីចងក្រងជាអត្ថបទមាន២ប្រភេទទិន្នន័យ រួមមាន៖

**ក. ទិន្នន័យទី១៖**

គឺយើងបានចុះសម្ភាសន៍ផ្ទាល់ជាមួយស្នងការដ្ឋាននគរបាលខេត្ត ការស្តាប់ កិច្ចពិភាក្សា ការចូលរួមផ្លាស់ប្តូរបទពិសោធក្នុងកិច្ចប្រជុំ សិក្ខាសាលា ការចូលរួមប្រតិបត្តិការ និងអន្តរាគមន៍បង្ក្រាបរបស់នគរបាលជាតិ ក៏ដូចជានាយនគរបាល និងអន្តរជាតិ ទាំងក្នុង និងក្រៅប្រទេស។

**ខ. ទិន្នន័យទី២៖**

ការប្រមូលទិន្នន័យដែលមានស្រាប់ ហើយទិន្នន័យបានត្រូវប្រមូលគឺ យកឯកសារមានដូចជា៖ សូចនាករណ៍ការងារ ផែនការយុទ្ធសាស្ត្រ របាយកាណ៍ប្រាំឆ្នាំ ផែនការផ្សេងៗរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ច្បាប់ ឯកសារពាក់ព័ន្ធពីក្រសួងមហាផ្ទៃ ឯកសារពីបណ្ណាល័យនៃសាកលវិទ្យាល័យនានា សាកលវិទ្យាល័យអាស៊ី អឺរ៉ុប បណ្តាញផ្សព្វផ្សាយសង្គម គេហទំព័រ សារព័ត៌មាននានា ទស្សនាវដ្តីជាតិ អន្តរជាតិជាច្រើនទៀត ជាពិសេសពី អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ។

## ២.២. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទនេះ ក្រោយពីប្រមូលបានទិន្នន័យដោយការវិភាគតាមបែប៖ បរិមាណវិស័យ គុណភាពវិស័យ និងគោលការណ៍វិចារវិទ្យា ដែលអនុញ្ញាតឱ្យសិក្សាស្រាវជ្រាវនូវទ្រឹស្តី លិខិតបទដ្ឋានគតិយុត្ត ដែលបានបង្ហាញអំពីដំណើរការងារពាក់ព័ន្ធនឹងការអនុវត្តន៍ជាក់ស្តែង។

វិធីសាស្ត្រនៃការវិភាគនេះ បានផ្តល់ឱ្យការសិក្សាស្រាវជ្រាវជានាបាននូវភាពត្រឹមត្រូវពិតប្រាកដ ដែលអាចទុកចិត្តបាន និងឈានទៅរកការសន្និដ្ឋានជាលក្ខណៈបែបវិទ្យាសាស្ត្រទំនើប។

## ២.៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់នៃការស្រាវជ្រាវមានចន្លោះរយៈពេល៣ឆ្នាំ គិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដោយផ្តោតលើវិសាលភាពនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការងារផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន ដែល

មានកិច្ចការជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ ក្តាប់ជាប់កិច្ចការខ្សែរយៈបណ្តោយជំនាញ តាមបណ្តាបញ្ជាការដ្ឋានកងរាជអាវុធហត្ថ២៥រាជធានី-ខេត្ត។

## ៣. ស្ថានភាពនៃការគ្រប់គ្រងប្រតិបត្តិការ កងកម្លាំងនគរបាលជាតិ

### ៣.១. ស្ថានភាពទូទៅ

កងកម្លាំងនគរបាលជាតិ ដែលគ្រប់គ្រងដោយអគ្គស្នងការដ្ឋាននគរបាលជាតិនោះ ត្រូវស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីជាអ្នកកំណត់ក្របខ័ណ្ឌទូទៅ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និងជាអ្នកផ្តល់សម្ភារៈ និងថវិកាសំរាប់ផ្គត់ផ្គង់ដល់កងកម្លាំងនគរបាលជាតិ។ អគ្គស្នងការដ្ឋាននគរបាលជាតិមានភារៈគ្រប់គ្រងហ្វឹកហ្វឺនសំដៅកសាងរៀបចំកងចងក្រងកម្លាំងនគរបាលជាតិឱ្យរីកចម្រើនដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រងតួនាទី[៤] និងភារកិច្ចរបស់ខ្លួន[១]។

#### ៣.១.១. រចនាសម្ព័ន្ធកងកម្លាំងនគរបាលជាតិ

**១. រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន(អង្គភាព)៖**ប្រកាស ស្តីពី ការកំណត់តួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន និងអធិការដ្ឋាន ចំណុះអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ស្នងការដ្ឋានស្រាវជ្រាវព័ត៌មានសន្តិសុខ ស្នងការដ្ឋានផែនការប្រតិបត្តិការ និងការិយាល័យទទួលពាក្យបណ្តឹង[៥] និងអង្កេតស្រាវជ្រាវរាជធានី/ខេត្ត[២]។

**២. រចនាសម្ព័ន្ធមុខងារតាមឋានានុក្រម៖** អគ្គស្នងការនគរបាលជាតិ បានប្រគល់តួនាទីដល់ ស្នងការនគរបាលរាជធានី-ខេត្ត ទាំងអស់ក្នុងការទទួលខុសត្រូវ ដឹកនាំបញ្ជាលើការងារជំនាញនីមួយៗ ។

---

[៤] នៅថ្ងៃទី ៥ ខែសីហាឆ្នាំ ២០០៦ ព្រះរាជក្រឹត្យលេខ ០៨០៦ / ៣៤២ របស់ព្រះមហាក្សត្រនរោត្តមសីហមុនី

[៥] បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ,បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ។

**៣.១.២. តួនាទីកងកម្លាំងអគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្ថាប័នពាក់ព័ន្ធនៅទូទាំងប្រទេសរួមមាន អគ្គស្នងការដ្ឋាននគរបាលជាតិ ស្នងការដ្ឋានរាជធានី ខេត្តទាំង ២៥ អធិការដ្ឋានក្រុង ស្រុក ខណ្ឌ និងអង្គភាពចំណុះក្រសួងមហាផ្ទៃ ព្រះរាជអាជ្ញានៃស្ថាប័នអយ្យការ ចៅក្រមនៃស្ថាប័នតុលាការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថ។ ទី១. ផ្តល់ឱកាសដល់តួអង្គពាក់ព័ន្ធទាំងអស់ រួមមាន ព្រះរាជាអាជ្ញា ចៅក្រម មេធាវី និងមន្ត្រីនគរបាលយុត្តិធ៌ ធ្វើការសិក្សាស្វែងយល់ ផ្លាស់ប្តូរចំណេះដឹង និងបទ ពិសោធន៍គ្នាទៅវិញទៅមក ក្នុងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដើម្បីឈានទៅដល់ការធ្វើកែសម្រួល កែលម្អ កែតម្រូវ និងកែទម្រង់ លើការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌសម្រាប់ពេលបច្ចុប្បន្ន និងអនាគត ទី២. ដោះស្រាយសំណូមពរ និងបញ្ហាប្រឈមផ្សេងៗរបស់តួអង្គពាក់ព័ន្ធទាំងអស់ ក្នុងដំណើរការនីតិ វិធីនៃរឿងក្តីព្រហ្មទណ្ឌ ជាពិសេសក្នុងដំណាក់កាលនៃការបំពេញតួនាទីនិងភារកិច្ចមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងទី៣. ពង្រឹងកិច្ចសហការឱ្យកាន់តែល្អប្រសើរឡើងរវាង មន្ត្រីនគរបាលយុត្តិធម៌ ជាមួយព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងមេធាវី ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា។

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ជាមួយព្រះរាជ អាជ្ញា ចៅក្រមស៊ើបសួរ និងមេធាវីក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌឱ្យកាន់មានប្រសិទ្ធភាពខ្ពស់ ស្របតាមបទ ប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីបង្កើនការជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌កម្ពុជាពីសាធារណជនទូទៅ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋ។

**៣.១.៣. តួនាទីកងកម្លាំងអគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្ថាប័នពាក់ព័ន្ធនៅទូទាំងប្រទេសរួមមាន អគ្គស្នងការដ្ឋាននគរបាលជាតិ ស្នងការដ្ឋានរាជធានី ខេត្តទាំង ២៥ អធិការដ្ឋានក្រុង ស្រុក ខណ្ឌ និងអង្គភាពចំណុះក្រសួងមហាផ្ទៃ ព្រះរាជអាជ្ញានៃស្ថាប័នអយ្យការ ចៅក្រមនៃស្ថាប័នតុលាការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថ។ ទី១. ផ្តល់ឱកាសដល់តួអង្គពាក់ព័ន្ធទាំងអស់ រួមមាន ព្រះរាជាអាជ្ញា ចៅក្រម មេធាវី និងមន្ត្រីនគរបាលយុត្តិធ៌ ធ្វើការសិក្សាស្វែងយល់ ផ្លាស់ប្តូរចំណេះដឹង និងបទ ពិសោធន៍គ្នាទៅវិញ

ទៅមក ក្នុងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដើម្បីឈានទៅដល់ការធ្វើកែសម្រួល កែលម្អ កែតម្រូវ និងកែទម្រង់ លើការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌសម្រាប់ពេលបច្ចុប្បន្ន និងអនាគត ទី២. ដោះស្រាយសំណួមពរ និងបញ្ហាប្រឈមផ្សេងៗរបស់តួអង្គពាក់ព័ន្ធទាំងអស់ ក្នុងដំណើរការនីតិ វិធីនៃរឿងក្តីព្រហ្មទណ្ឌ ជាពិសេសក្នុងដំណាក់កាលនៃការបំពេញតួនាទីនិងភារកិច្ចមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងទី៣. ពង្រឹងកិច្ចសហការឱ្យកាន់តែល្អប្រសើរឡើងរវាង មន្ត្រីនគរបាលយុត្តិធម៌ ជាមួយព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងមេធាវី ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា។

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ជាមួយព្រះរាជ អាជ្ញា ចៅក្រមស៊ើបសួរ និងមេធាវី ក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌឱ្យកាន់មានប្រសិទ្ធភាពខ្ពស់ ស្របតាមបទ ប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីបង្កើនការជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌កម្ពុជាពីសាធារណជនទូទៅ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋ។

**៣.១.៤. ភារកិច្ចកងកម្លាំងនគរបាលជាតិ**

កងកម្លាំងនគរបាលជាតិ[៦] មានភារកិច្ច[៣] ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ដូចខាងក្រោម៖

**១. រ៉ាប់រងសកម្មភាពប៉ូលីសរដ្ឋបាល៖** រក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ, រ៉ាប់រងអោយ មានការគោរពច្បាប់ និងបទបញ្ជាទាំងឡាយ, ផ្តល់ព័ត៌មាន និងជួយសង្គ្រោះពលរដ្ឋស៊ីវិល។

ក្នុងក្របខ័ណ្ឌនេះកងរាជអាវុធហត្ថ ត្រូវអនុវត្តន៍តាមបទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច។

**២. រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ៖** ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និងទោសកម្ម, ធ្វើកំណាត់ហេតុអំពីបទល្មើស, ប្រមូលផ្តុំភ័ស្តុតាងផ្សេងៗ, ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តិបទល្មើស

[៦] អនុក្រឹត្យលេខ៧៧អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤។

ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ និងទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ។

ក្នុងក្របខ័ណ្ឌនេះ កងរាជអាវុធហត្ថត្រូវអនុវត្តន៍តាមបទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង្គការអយ្យការ និងអាជ្ញាធរតុលាការមានសមត្ថកិច្ច។

**៣. បំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងនគរបាលប៉ុស្តិ៍តាមមូលដ្ឋានៈ** ទទួលបន្ទុករក្សាសុវត្ថិភាព និងបំពេញតួនាទីជាកងកិត្តិយស ជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និងអាជ្ញាធរជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា។ ការពារទីតាំងយោធា កិច្ចការប៉ូលីសយោធានៅក្នុង និងក្រៅទីតាំងកងទ័ព។

ក្នុងក្របខ័ណ្ឌនេះកងរាជអាវុធហត្ថ ត្រូវអនុវត្តន៍តាមបទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរយោធាមានសមត្ថកិច្ច។

**៤. ផ្តល់កម្លាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់។**

### ៣.១.៥. យន្តការណ៍ដឹកនាំស្នងការនគរបាលរាជធានី-ខេត្ត

យន្តការណ៍ដឹកនាំ គ្រប់គ្រងរបស់ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ បានដឹកនាំកិច្ចប្រជុំប្រកាសសមាសភាពគណៈកម្មាធិការសន្តិសុខឌីជីថល ក្របខ័ណ្ឌក្រសួងមហាផ្ទៃ។ ពិធីនេះមានការចូលរួមពី ឯកឧត្តមអគ្គនាយកអគ្គនាយករង អង្គភាព ចំណុះក្រសួងមហាផ្ទៃ ដែលជាអនុប្រធាន និងជាសមាជិកគណៈកម្មាធិការសន្តិសុខឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ។

អគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានគណៈកម្មាធិការសន្តិសុខឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា ការបង្កើតសមាសភាពគណកម្មាធិការនេះឡើងក្នុងគោលបំណងទី១-ការរៀបចំបង្ការទប់ស្កាត់នូវរាល់បទល្មើសបច្ចេកវិទ្យា និងទី២-ការរៀបចំប្រព័ន្ធទំនាក់ទំនងរបៀបរបបការងារប្រចាំថ្ងៃ ក៏ដូចជាការគ្រប់គ្រងនូវមុខសញ្ញាផ្សេងៗ បញ្ជាក់ទៀតថា កន្លងទៅបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាបានកើតឡើងនៅតាមជនបទ មីក្រូហិរញ្ញវត្ថុ ធនាគារ ក្រុមហ៊ុនឯកជន ការឆបោកតាមប្រព័ន្ធអនឡាញ ការគម្រាមតាមប្រព័ន្ធអនឡាញ ក៏ដូចជាការបន្លំទិន្នន័យផ្សេងៗ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបទ

ល្មើសទាំងនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ជាសេនាធិការក៏បានបង្កើតក្រុមការងារ Hotline Scam ២៤/៧ និងបានធ្វើការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានច្រើន ហើយប្រជាពលរដ្ឋក៏មានការសាទរ និងសប្បាយចិត្តចំពោះការដោះស្រាយរបស់សមត្ថកិច្ចផងដែរ ដោយក្នុងនោះជនរងគ្រោះអាចធ្វើការបំពេញពាក្យបណ្តឹងអនឡាញ ដោយមិនចាំបាច់ចំណាយពេលវេលាមកដាក់ពាក្យបណ្តឹងដោយផ្ទាល់ ដើម្បីអោយសមត្ថកិច្ចបើកការស្រាវជ្រាវ កន្លងមកអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏បានសហការជាមួយអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ក៏ដូចជាអគ្គនាយកដ្ឋានផ្សេងៗដទៃទៀតក្នុងការបង្កើនសមត្ថភាពប្រយុទ្ធប្រឆាំងទៅនឹងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញនេះដែរ ដែលជាបទល្មើសមួយថ្មីមិនមែនប្រពៃណី ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់សមស្របសម្រាប់បទល្មើសនៅពេលបច្ចុប្បន្ន។ ក្នុងនោះ យើងក៏បានធ្វើការបណ្តុះបណ្តាលមន្ត្រីជាច្រើនរយនាក់ ក្នុងន័យដើម្បីរួមគ្នា និងសិក្សាបន្ថែមទៀតដើម្បីរារាំងបទល្មើសនេះកាន់តែស៊ីជម្រៅកុំឱ្យគ្រោះថ្នាក់ដល់សង្គម។ អគ្គស្នងការនគរបាលជាតិក៏បានថ្លែងគាំទ្រចំពោះការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងបទល្មើស ដូចជាប្រព័ន្ធគ្រប់គ្រងបទល្មើសព្រហ្មទណ្ឌ (E-Crime) ដើម្បីងាយស្រួលគ្រប់គ្រងទាំងចំនួនបទល្មើស និងសកម្មភាពនៃបទល្មើស។

# ៤. សេចក្តីសន្និដ្ឋាន អនុសាសន៍ និងសំណូមពរ

## ៤.១. សេចក្តីសន្និដ្ឋាន

អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ស ថេត** នៅតែសម្រេចបានរាល់ការអនុវត្ត តួនាទី ភារកិច្ចស្នូលរបស់ខ្លួន គោរពវិន័យ បទបញ្ជា និងអភិវឌ្ឍ ទោះបីស្ថិតក្នុងស្ថានភាព វិបត្តិនយោបាយជាតិ និងអន្តរជាតិ វិបត្តិសេដ្ឋកិច្ច ជួបការលំបាកដល់ការអភិវឌ្ឍសង្គម គ្រោះអាសន្ននៃគ្រោះមហន្តរាយបង្កឡើងដោយមនុស្សឬធម្មជាតិក្តី (ជាក់ស្តែងក្នុងបរិបទទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ-១៩) ក៏ស្ថាប័នអគ្គស្នងការដ្ឋាននគរបាលជាតិ បន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការ សហប្រតិបត្តិការធានាបានសន្តិសុខសង្គម ស្ថិរភាពនយោបាយ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់របៀបរៀបរយ

ជូនប្រជាពលរដ្ឋ ថ្នាក់ដឹកនាំជាតិ អន្តរជាតិ និងព្រះមហាក្សត្រ ថែមទាំងពង្រឹងការអនុវត្ត ច្បាប់ បទបញ្ជា និងបង្ក្រាបបទល្មើស បានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**៤.២. អនុសាសន៍**

១. ពង្រឹងយន្តការស្រាវជ្រាវ ប្រមូលផ្តុំ និងការគ្រប់គ្រងព័ត៌មាន បម្រើឱ្យព្រឹត្តិការណ៍ សំខាន់ៗ និងក្តាប់ជាប់ទាន់ពេលវេលានូវរាល់មហិច្ឆតាប៉ុនប៉ងបង្កអសន្តិសុខ ចលាចល ដែលនាំឱ្យប៉ះពាល់ដល់ស្ថិរភាពសណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងសន្តិភាព។

២. ពង្រឹងយន្តការស្រាវជ្រាវបង្ក្រាបរាល់បទល្មើសព្រហ្មទណ្ឌ (ប្លន់ ឃាតកម្ម ចាប់មនុស្សជំរិតទារប្រាក់ ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស រំលោភសេពសន្ថវៈ) និងបណ្តាបទល្មើសផ្សេងៗទៀត។ទទួល និងចាត់ការតាមនិតិវិធីនូវរាល់បណ្តឹង ដីការបស់តុលាការ និងបន្តរៀបចំបន្ទប់ឃាត់ខ្លួនបណ្តោះអាសន្ន (ប្រុស ស្រី) តាមបណ្តាជំនាញឱ្យបានសមរម្យ។

៣. បន្តត្រៀមកម្លាំង មធ្យោបាយ យុទ្ធោបករណ៍ សម្ភារៈសឹក ឧបករណ៍សម្ភារៈសង្គ្រោះ ត្រៀមអនុវត្តបទបញ្ជា ធ្វើអន្តរាគមន៍ ការពារសន្តិសុខសង្គម រក្សាសណ្តាប់ធ្នាប់សាធារណៈ ជួយសង្គ្រោះគ្រោះមហន្តរាយ និងការពារបូរណភាពទឹកដី រក្សាសន្តិភាពសង្គម។

៤. ពង្រឹង និងបំពេញបន្ថែម ឯកឧត្តម នាយឧត្តមសេនីយ៍ **ស ថេត** មានសមត្ថភាព ជំនាញ មានចំណេះដឹងខ្ពស់ និងចេះភាសាបរទេស ដើម្បីបន្តវេនការងារទៅតាមការវិវឌ្ឍនាពេលអនាគត។

៥. ពង្រឹងយន្តការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងតូច ទាំងធំ ត្រូវស្វែងរកកន្លែងផលិត ស្តុក ដឹកជញ្ជូន ចែកចាយ ក្នុងនោះផងដែរត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រងអាវុធជាតិផ្ទុះឱ្យមានប្រសិទ្ធភាព។ បន្តលប់ឈ្មោះចេញពីក្របខណ្ឌនគរបាលជាស្វ័យប្រវត្តិ ចំពោះនគរបាលរូបណាដែលប្រើប្រាស់ គ្រឿងញៀន។ ពង្រឹងការអនុវត្តវិន័យទណ្ឌកម្មនគរបាលរូបណាដែលបំពានវិន័យលក្ខន្តិកៈនៃកងកម្លាំងនគរបាល ក្រមសីលធម៌វិជ្ជាជីវៈនគរបាល។

# គន្ថនិទ្ទេស

## ក. ព្រះរាជក្រឹត្យ

១. ក្រឹត្យចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤។

២. ព្រះរាជក្រឹត្យលេខ៤៤៦NS និង៤៤៧NS ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៧។

៣. ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០០៣/ ស្តីពី ការបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

៤. ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦ / ៣៨២

## ខ. អនុក្រឹត្យ

១. អនុក្រឹត្យលេខ ៧៧អនក្រ.បក. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ពន្ធ ទូទៅនៃកងរាជអាវុធហត្ថ។

២. អនុក្រឹត្យលេខ១០៧៨ អនក្រ តត ស្តីពី កាតតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

៣. អនុក្រឹត្យលេខ១០៧៩ អនក្រ តត ស្តីពី កាតតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## គ. សារាចរណែនាំ ប្រកាស សេចក្តីកំណត់ និងរបាយការណ៍

១. ប្រវត្តិរបស់នគរបាលជាតិកម្ពុជានៅថ្ងៃទី ៨ ខែសីហាឆ្នាំ ២០០៦។

២. ប្រកាស ស្តីពី តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្ងៃទី ១១ ខែមីនា ឆ្នាំ២០០៩

៣. ប្រកាស ស្តីពី ការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន និងអធិការដ្ឋាន ចំណុះអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ថ្ងៃទី ២០ ខែមិនា ឆ្នាំ២០០៩

៤. របាយការណ៍បូកសរុបសកម្មភាព លទ្ធផលការងារ៥ឆ្នាំ(២០១៦-២០២០) នាយកដ្ឋានសរុប-ផែនការ នៃសេនាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ

៥. នៅព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤នេះ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ស ថេត** អគ្គស្នងការនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ឯកឧត្តម **ង៉ៀប ពីរី** ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តម **នួន ផារ័តកន** អភិបាលខេត្តកំពង់ធំ។

៦. អនុសាសន៍ ឯកឧត្តម នាយឧត្តមសេនីយ៍ **ស ថេត** បានណែនាំឱ្យស្នងការនគរបាលខេត្តកំពង់ស្ពឺថ្មី ត្រូវធ្វើជាសេនាធិការគ្រប់ជ្រុងជ្រោយដល់គណៈបញ្ជាការឯកភាពខេត្ត ដើម្បីរំលេចចេញនូវស្នាដៃរបស់កងកម្លាំងនគរបាលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤។

## ឃ. ស្នាដៃនិពន្ធ

១. វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៥។

២. ទស្សនាវដ្ដីក្រសួងមហាផ្ទៃ-មិត្តនគរបាល។

## សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
## ទស្សនាវដ្តីស្រាវជ្រាវ ( ទ.ស )
RESEARCH JOURNAL ( RJ )


### ១-នាយកការផ្សាយ

-លោក **ស៊ុន សេដ្ឋា** សាកលវិទ្យាធិការ នាយកការផ្សាយ

-លោក **សូត្រ សំណាង** សាកលវិទ្យាធិការរង ទទួលបន្ទុកថ្នាក់ក្រោយបរិញ្ញាបត្រ និងស្រាវជ្រាវ នាយករងការផ្សាយ

### ២-គណ:កម្មការបណ្ណាធិការ

| | | |
|---|---|---|
| -បណ្ឌិត **ទ្រី ចាន់ធុច** | ព្រឹទ្ធបុរស សក឵ | ប្រធាន |
| -ប.ចារ្យ **សោម សុមុនី** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែកអក្សរសាស្ត្រនិងសង្គមសាស្ត្រ |
| -បណ្ឌិត **អ៊ិម វិបុល** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែកនីតិសាស្ត្រ |
| -បណ្ឌិត **សយ រាសី** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែករដ្ឋបាលសាធារណ: |
| -បណ្ឌិត **សួន វានី** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែកទេសចរណ៍ |
| -បណ្ឌិត **កៅ ក្វេងហុង** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែកពាណិជ្ជកម្ម និងសេដ្ឋកិច្ច |
| -បណ្ឌិត **ទេព ឈុនរិទ្ធ** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែកនយោបាយ |
| -បណ្ឌិត **គិន ភា** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទផ្នែកទំនាក់ទំនងអន្តរជាតិ |
| -បណ្ឌិត **ជា មុនីឫទ្ធិ** | សាស្ត្រាចារ្យ | សមាជិកទទួលបន្ទុកអត្ថបទភាសាចិន |

**៣-គណៈកម្មការប្រឹក្សាយោបល់**

- បណ្ឌិត **ជ័យ សារិន** អនុប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រ
- បណ្ឌិត **ជួន ជិរិន** ទីប្រឹក្សា ស.អ.អ.
- បណ្ឌិត **ស៊ុំ ឈុំឡុង** សាស្ត្រាចារ្យ

**៤-ក្រុមរៀបចំ បោះពុម្ព និង ចែកផ្សាយ**

- លោក **ណោ ពិសិដ្ឋ**
- លោក **អាង សុផា**

**៥-អាសយដ្ឋានទាក់ទង**

សាស្ត្រាចារ្យបណ្ឌិត **ទ្រី ចាន់ធុច**

សាលាក្រោយឧត្តម នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

អាសយដ្ឋាន ៖ អគារមាស, #៦០ ផ្លូវ១៤៦កែង២៥៧ សង្កាត់ទឹកល្អក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរសព្ទ ៖ (៨៥៥) ១៧ ៧៩៩ ៨៨៩

អ៊ីម៉ែល ៖ chanthuch@aeu.edu.kh